# ព្រះត្រៃបិដក

## ប្រែរួមនឹង
# ព្រះអដ្ឋកថា

## ភាគ២៩

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

## មនោរថបូរណី អដ្ឋកថា

### សេចក្ដីប្រែជាភាសាខ្មែរ

## អង្គុត្តរនិកាយ

## បញ្ចកនិបាត~ឆដ្ឋភាគ

## ឆក្កនិបាត~សត្តមភាគ

## ២៩

## បាលីប្រែ ៤៥~៤៦



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ២៩

# សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត

## ឆដ្ឋភាគ

## តតិយបណ្ណាសក

## ផាសុវិហារវគ្គ

### វេសារជ្ជករណសូត្រទី ១

[ ១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គលនេះ មាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ បានស្តាប់ច្រើន ១ ប្រារព្ធព្យាយាម ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមិនមានសទ្ធា មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានសទ្ធា ឥតមានសេចក្តី អៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកទ្រុស្តសីល មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានសីលឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចេះដឹងតិច មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកចេះដឹងច្រើន ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿង

ធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកខ្ជិលច្រអូស មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកប្រារព្ធព្យាយាម ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកឥតប្រាជ្ញា មានសេចក្តីអៀនអន់ឯណា ភិក្ខុអ្នកមានប្រាជ្ញា ឥតមានសេចក្តីអៀនអន់នោះទេ ។ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងធ្វើឲ្យក្លៀវក្លារបស់សេក្ខបុគ្គលមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

# តតិយបណ្ណាសក

## ផាសុវិហារវគ្គទី ១

### វេសារជ្ជករណសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងវេសារជ្ជករណសូត្រទី ១ នៃតតិយ-បណ្ណាសកដូចតទៅនេះថា បទថា* **វេសារជ្ជករណា** *បានដល់ គ្រឿងនាំមកនូវការក្លៀវក្លា ។ បទថា* **សារជ្ជំ ហោតិ** *សេចក្តីថា រមែងមានទោមនស្ស ។*

**អដ្ឋកថា វេសារជ្ជករណសូត្រទី ១ ចប់**

# សុត្តន្តបិដក

## សង្កិតសូត្រទី ២

[ ២ ] *ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៥ យ៉ាងសូម្បី តែលោកអ្នកមានធម៌មិនកម្រើក ( ព្រះខីណាស្រព ) ក៏រមែងត្រូវគេរង្កៀសសង្ស័យថាជាភិក្ខុអាក្រក់ដែរ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង*

សាសនានេះជាអ្នកត្រាច់ទៅកាន់សម្នាក់ស្រីពេស្យា ១ ត្រាច់ទៅកាន់សម្នាក់ស្រីមេម៉ាយ ១ ត្រាច់ទៅកាន់សម្នាក់ស្រីក្រមុំចាស់ ១ ត្រាច់ទៅកាន់សម្នាក់មនុស្សខ្ទើយ ១ ត្រាច់ទៅកាន់សម្នាក់ភិក្ខុនី ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីតែលោកអ្នកមានធម៌មិនកម្រើក (ព្រះខីណាស្រព) ក៏រមែងត្រូវគេរង្កៀសសង្ស័យថា ជាភិក្ខុអាក្រក់មិនខានដែរ ។

# អដ្ឋកថា

## សង្កិតសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្កិតសូត្រទី ២ ដូចតទៅនេះ បទថា **ឧស្សង្កិតបរិសង្កិតោ** បានដល់ ត្រូវសេចក្តីងឿងឆ្ងល់ និងត្រូវសេចក្តីសង្ស័យ ។ បទថា **អបិ អកុប្បធម្មោ** សេចក្តីថា ទោះជាព្រះខីណាស្រពដែលមានធម៌មិនកម្រើកក៏ពិត រមែងត្រូវភិក្ខុអាក្រក់ដទៃសង្ស័យបាន ។

ពួកស្រីដែលអាស្រ័យរូបចិញ្ចឹមជីវិត លោកហៅថា **វេសិយា** ក្នុងបទថា **វេសិយគោចរោ** ជាដើម ស្រីទាំងនោះ ជាគោចររបស់ភិក្ខុនោះ ហេតុនោះទើបឈ្មោះថា មានស្រីពេស្យាជាគោចរ អធិប្បាយថា ទៅផ្ទះរបស់ស្រីនោះរឿយៗ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បណ្តាបទទាំងនោះ បទថា **វិធវា** បានដល់ ស្រីប្តីស្លាប់ ។ បទថា **ថុល្លកុមារី** បានដល់ ក្រមុំចាស់ ។

**អដ្ឋកថា សង្កិតសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ចោរសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៥ យ៉ាងរមែង កាត់ទីតខ្លះ ប្លន់ធំខ្លះ ប្លន់ផ្ទះ ១ ខ្នះ ឈរចាំស្ទាក់អ្នកដំណើរតាមផ្លូវខ្លះ ។ អង្គ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកអាស្រ័យនូវទីមិនស្មើ ១ អាស្រ័យព្រៃស្បាត ១ អាស្រ័យជនអ្នកមានកម្លាំង ១ ជាអ្នកស្ទូកទ្រព្យ ១ ជាអ្នកត្រាច់ទៅម្នាក់ឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអ្នកអាស្រ័យនូវទីមិនស្មើ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកអាស្រ័យនូវជង្ហុកស្ទឹង ឬអាស្រ័យនូវភ្នំដែលមិនរាបស្មើ ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យនូវទីមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអ្នកអាស្រ័យព្រៃស្បាត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យនូវស្បាតស្មៅខ្លះ ស្បាតឈើខ្លះ ឆ្នេរស្ទឹងខ្លះ ដងព្រៃធំខ្លះ ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យនូវព្រៃស្បាតយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអាស្រ័យជនអ្នកមានកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យព្រះរាជាខ្លះ អាស្រ័យរាជមហាមាត្យខ្លះ មហាចោរនោះតែងអាងយ៉ាងនេះថា បើនរណាប្តឹងអ្វីៗ ពីអញ ពួកស្តេច ឬរាជមហាមាត្យទាំងនេះ មុខជាកាត់សេចក្តីបន្ធ្របចោល បើនរណាមួយប្តឹងអ្វីៗ ពីចោរនោះ ពួកស្តេច ឬរាជមហាមាត្យទាំងនោះ ក៏កាត់សេចក្តីបន្ធ្របឲ្យចោរនោះ

ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកអាស្រ័យជនមានកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរសូកដោយទ្រព្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើន មហាចោរ នោះតែងអាងយ៉ាងនេះថា បើនរណាមួយប្តឹងអ្វីៗ ពីអញ អញ ( នឹងយក ) ភោគៈអំពីទ្រព្យនេះទៅសូក បើនរណាមួយប្តឹងអ្វីៗ អំពីចោរនោះ ចោរនោះ ( ក៏យក ) ភោគៈអំពីទ្រព្យនោះទៅសូក ម្នាលភិក្ខុទាំងឡាយ មហាចោរអ្នកសូកដោយភោគៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាចោរអ្នកត្រាច់ទៅតែម្នាក់ឯង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ តែងធ្វើការសន្ធត់សន្ធិនតែម្នាក់ឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះមហាចោរនោះគិតថា អាថ៌កំបាំងរបស់អញ កុំខ្ចរខ្ចាយទៅក្រៅឡើយ ម្នាលភិក្ខុទាំងឡាយ មហាចោរជាអ្នកត្រាច់ទៅតែម្នាក់ឯង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងកាត់នូវទីតខ្វះ ប្លន់ធំខ្វះ ប្លន់ផ្ទះ ១ ខ្វះ ចាំស្កាត់អ្នកដំណើរខ្វះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបដែលប្រកបដោយធម៌ ៥ យ៉ាង រមែងរក្សាខ្លួនដែលគាស់រំលើងបំផ្លាញគុណធម៌ចោលផង ប្រកបដោយទោសផង គួរជាទីតិះដៀលនៃអ្នកប្រាជ្ញទាំងឡាយផង ទទួលនូវបាបដ៏ច្រើនផង ក៏យ៉ាងនោះដែរ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ អាស្រ័យកិរិយាមិនស្មើ ១ អាស្រ័យសេចក្តីយល់សាំញ៉ាំ ១ អាស្រ័យជនមានកម្លាំង ១ សូកដោយ

ទ្រព្យ ១ គ្រាប់ទៅតែម្នាក់ឯង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអាស្រ័យកិរិយាមិនស្មើ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះប្រកបដោយកាយកម្មមិនស្មើ ប្រកបដោយវចីកម្មមិនស្មើ ប្រកបដោយមនោកម្មមិនស្មើ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបអាស្រ័យកិរិយាមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាប អាស្រ័យសេចក្ដីយល់សាំញ៉ាំ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះយល់ខុស ប្រកបដោយអន្តគ្គាហិកទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបអាស្រ័យសេចក្ដីយល់សាំញ៉ាំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអាស្រ័យជនមានកម្លាំង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ អាស្រ័យពួកស្ដេច ឬពួករាជមហាមាត្យ ភិក្ខុបាបនោះ តែងអាងយ៉ាងនេះថា បើនរណាមួយចោទអ្វីៗ អំពីអញ ពួកស្ដេច ឬពួករាជមហាមាត្យទាំងនោះ គង់នឹងជម្រះសេចក្ដីបង្គ្របឲ្យ បើនរណាមួយ ចោទអ្វីៗ អំពីភិក្ខុនោះ ពួកស្ដេច ឬពួករាជ-មហាមាត្យទាំងនោះ ក៏ជម្រះសេចក្ដីបង្គ្របឲ្យភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបអាស្រ័យជនមានកម្លាំង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបអ្នកសូកដោយទ្រព្យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុងសាសនានេះ ជាអ្នកសម្បូរចីវរ បិណ្ឌបាត សេនាសនៈ និងគិលាន-ប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុនោះតែងអាងយ៉ាងនេះថា បើនរណាមួយចោទអ្វីៗ អំពីអញ អញនឹងយកលាភអំពីបច្ច័យនេះទៅសូក ។ បើនរណាមួយចោទ

អ្វីៗ អំពីភិក្ខុនោះ ភិក្ខុនោះក៏យកលាភអំពី បច្ច័យនោះទៅសូក ម្នាល ភិក្ខុទាំងឡាយ ភិក្ខុបាបអ្នកសូកដោយទ្រព្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុបាបត្រាច់ទៅតែម្នាក់ឯង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបក្នុង សាសនានេះ តែម្នាក់ឯង សម្រេចការនៅក្នុងជនបទទាំងឡាយ ជាទីបំផុតដែន ភិក្ខុនោះ ចូលទៅរកត្រកូលទាំងឡាយក្នុងជនបទនោះ រមែងបានលាភ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុបាបត្រាច់ទៅម្នាក់ឯង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបាបប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងរក្សាខ្លួន ដែលគាស់រំលើង បំផ្លាញគុណធម៌ចោលផង ប្រកបដោយទោសផង គួរអ្នកប្រាជ្ញទាំងឡាយ តិះដៀលផង ទទួលបាបច្រើនផង ។

# អដ្ឋកថា

## ចោរសូត្រ

[ ៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចោរសូត្រទី ៣ ដូចតទៅនេះ បទថា **ឥតោ ភោគេន បដិសន្ថរិស្សាមិ** សេចក្តីថា អាត្មាអញនឹងកាន់យកភោគៈ ចាកសម្បត្តិរបស់អាត្មាអញនេះ ធ្វើបដិសណ្ឋារៈ បិទបាំងដោយភោគៈនោះ អធិប្បាយថា នឹងបិទឱកាសរវាងបុគ្គលនោះនឹងអញ ។ បទថា **និគ្គហណានិ** បានដល់ ការកាន់យករបស់អ្នកដទៃ ។ បទថា **គុយ្ហមន្តា** បានដល់

មន្តដែលត្រូវបិទបាំង ។ បទថា **អន្ធគ្គាហិកាយ** សេចក្ដីថា ប្រកាន់នូវសស្សតទិដ្ឋិ ឬឧច្ឆេទទិដ្ឋិ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ។

អដ្ឋកថា ចោរសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សុខុមាលសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាសមណសុខុមាលក្នុងពួកសមណៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បើគេអង្វរក៏ប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច គេអង្វរក៏បរិភោគបិណ្ឌបាតច្រើន គេមិនអង្វរក៏បរិភោគតិច គេអង្វរក៏ប្រើប្រាស់សេនាសនៈច្រើន គេមិនអង្វរក៏ប្រើប្រាស់តិច គេអង្វរក៏បរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន គេមិនអង្វរក៏បរិភោគតិច ១ ភិក្ខុនោះនៅជាមួយនឹងពួកសព្រហ្មចារីណា ពួកសព្រហ្មចារីនោះ តែងរាប់រកភិក្ខុនោះដោយកាយកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្ត ( នោះ ) តិច តែងរាប់រកដោយវចីកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច តែងរាប់រកដោយមនោកម្មជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច នាំចូលទៅជិតតែរបស់ដែលគួរនាំចូលទៅ

ជិត ជាទីគាប់ចិត្ត មិនគាប់ចិត្តតិច ១ ជំងឺដែលតាំងឡើងអំពីប្រមាត់ក្តី តាំងឡើងអំពីស្លេស្មក្តី តាំងឡើងអំពីខ្យល់ក្តី កើតអំពីធាតុប្រជុំក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីរក្សាឥរិយាបថមិនស្មើក្តី កើតអំពីសេចក្តីព្យាយាម ( របស់គេមានវាយចងជាដើម ) ក្តី កើតអំពីផលនៃកម្មក្តី ជំងឺទាំងឡាយនោះ មិនកើតឡើងដល់ភិក្ខុនោះច្រើនទេ ជាអ្នកមានអាពាធតិច ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យដោយចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ចូលដល់ចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាសមណសុខុមាលក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើគេពោលសរសើរសមណៈណាថា ជាសមណសុខុមាលក្នុងពួកសមណៈដូច្នេះ ម្នាលភិក្ខុទាំងឡាយ គួរគេពោលសរសើរតថាគតថាជាសមណសុខុមាលក្នុងពួកសមណៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាតថាគតបើគេអង្វរក៏ប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច បើគេអង្វរក៏បរិភោគបិណ្ឌបាតច្រើន បើគេមិនអង្វរក៏បរិភោគតិច បើគេអង្វរក៏ប្រើប្រាស់សេនាសនៈច្រើន បើគេមិនអង្វរក៏ប្រើប្រាស់តិច បើគេអង្វរក៏បរិភោគគិលានប្បច្ចយភេសជ្ជបរិក្ខារច្រើន បើគេមិនអង្វរក៏បរិភោគតិច មួយទៀត តថាគតនៅជាមួយនឹងពួកភិក្ខុណា ពួកភិក្ខុនោះ តែងគប់រកតថាគតដោយកាយកម្ម

ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្ត ( នោះ ) តិច តែងគប់រកដោយវចីកម្ម ជាទីគាប់ចិត្តច្រើន មិនគាប់ចិត្តតិច តែងគប់រកដោយមនោកម្ម ជាទីគាប់ចិត្តច្រើន ដែលមិនគាប់ចិត្ត តិចតែងនាំចូលទៅជិតនូវរបស់ដែលគួរនាំចូលទៅជិត ជាទីគាប់ចិត្តច្រើន ដែលមិនគាប់ចិត្តតិច មួយទៀត ជំងឺដែលកើតអំពីប្រមាត់ក្តី កើតអំពីស្លេស្មក្តី កើតអំពីខ្យល់ក្តី កើតអំពីធាតុដែលប្រជុំគ្នាក្តី កើតអំពីរដូវប្រែប្រួលក្តី កើតអំពីរក្សាឥរិយាបថមិនស្មើក្តី កើតអំពីសេចក្តីព្យាយាម ( របស់គេមានវាយចងជាដើម ) ក្តី កើតអំពីផលនៃកម្មក្តី ជំងឺទាំងនោះមិនកើតដល់តថាគតច្រើនទេ តថាគតក៏ឈ្មោះថា ជាអ្នកមានអាពាធតិច ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យដោយចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ចូលដល់ ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលពោលសរសើរសមណៈណាថា ជាសមណសុខុមាលក្នុងពួកសមណៈដូច្នេះនោះ ម្នាលភិក្ខុទាំងឡាយ គួរគេពោលសរសើរតថាគតថា ជាសមណសុខុមាលក្នុងពួកសមណៈដូច្នេះ ។

# អដ្ឋកថា

## សុខុមាលសូត្រ

សុខុមាលសូត្រទី ៤ គ្រប់បទ មានន័យដូចពោលហើយខាងដើមនោះឯង ៗ ៚

អដ្ឋកថាសុខុមាលសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ផាសុវិហារសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ ការនៅសប្បាយនេះ មាន ៥ យ៉ាង ។ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តាំងទុកនូវកាយកម្មប្រកបដោយមេត្តាក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ១ ភិក្ខុតាំងទុកនូវវចីកម្មប្រកបដោយមេត្តាក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ១ ភិក្ខុតាំងទុកនូវមនោកម្មប្រកបដោយមេត្តា ក្នុងសព្រហ្មចារីទាំងឡាយ ក្នុងទីចំពោះមុខនិងទីកំបាំងមុខ ១ ជាភិក្ខុប្រកបដោយ សីលស្មើគ្នានឹងសព្រហ្មចារីទាំងឡាយ ដោយសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់អ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនប៉ះពាល់ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិទាំងក្នុង ទីចំពោះមុខនិងទីកំបាំងមុខ ១ ប្រកបដោយសេចក្តីយល់ស្មើគ្នានឹងសព្រហ្មចារីទាំងឡាយ ដោយសេចក្តី

យល់ដ៏ប្រសើរ ជាគ្រឿងចេញចាកទុក្ខ នាំជនអ្នកធ្វើតាមសេចក្ដីយល់នោះឲ្យអស់ទុក្ខដោយប្រពៃ បានទាំងក្នុងទីចំពោះមុខ និងទីកំបាំងមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា ការនៅសប្បាយ ៥ យ៉ាង ។

# អដ្ឋកថា

## ផាសុវិហារសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងផាសុវិហារសូត្រទី ៥ ដូចតទៅនេះ បទថា **មេត្តំ កាយកម្មំ** បានដល់ កាយកម្មដែលឲ្យប្រព្រឹត្តទៅដោយចិត្ត ប្រកបដោយមេត្តា ។ បទថា **អាវិ ចេវ រហោ ច** បានដល់ ទាំងចំពោះមុខ និងកំបាំងមុខ ។ ក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះឯង ។

បទថា **យានិ តានិ សីលានិ** ជាដើម ត្រាស់ដោយចតុប្បារិសុទ្ធិ-សីល ។ បទថា **សមាធិសំវត្តនិកានិ** បានដល់ ធ្វើឲ្យមគ្គសមាធិ និងផលសមាធិកើតឡើង ។ បទថា **សីលសាមញ្ញគតោ** ប្រែថា ដល់នូវភាពជាអ្នកមានសីលស្មើគ្នា អធិប្បាយថា ជាអ្នកមានសីលដូចគ្នា ។ បទថា **តក្ករស្ស** បានដល់ ជាអ្នកធ្វើតាមការត្រិះរិះនោះ ។ ព្រះមានព្រះភាគត្រាស់ការមានសីលស្មើគ្នា ត្រាស់ទិដ្ឋិវិបស្សនា និងសម្មាទិដ្ឋិក្នុងសូត្រនេះ ដោយប្រការដូច្នេះ ៕

# សុត្តន្តបិដក

## អានន្ទសូត្រទី ៦

[ ៦ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងឃោសិតារាម ទៀបក្រុងកោសម្ពី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុគង់ក្នុងទីសមគួរហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃគួរនៅសប្បាយបាន ដោយហេតុប៉ុន្មានយ៉ាងហ្ន៎ ។ ម្នាលអានន្ទ កាលណាភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីល ម្នាលអានន្ទ ភិក្ខុសង្ឃដែលគួរនៅសប្បាយ ដោយហេតុប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃគួរនៅសប្បាយបាន ដោយបរិយាយដទៃទៀត តើមានដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ មានដែរ ។ ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ជាអ្នកពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយដោយហេតុមានប្រមាណប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃគួរនៅសប្បាយដោយបរិយាយដទៃទៀត មានដែរឬទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ នៅមានទៀត ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ គឺមានបុណ្យតិច ក៏មិន

ន្ទេត់ ព្រោះតែខ្លួនមិនល្បីឈ្មោះនោះផង ។ ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយ ដោយហេតុប៉ុណ្ណោះឯង បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃគួរនៅសប្បាយដោយ បរិយាយដទៃទៀតមានដែរឬទេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាល អានន្ទ នៅមានទៀត ម្នាលអានន្ទ កាលដែលភិក្ខុបរិបូណ៌ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុ ដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ ក៏មិនរន្ធត់ ព្រោះតែខ្លួនមិនល្បីឈ្មោះនោះ ផង ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ។ ម្នាលអានន្ទ ភិក្ខុសង្ឃគួរនៅសប្បាយដោយហេតុប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុ សង្ឃគួរនៅសប្បាយដោយបរិយាយដទៃទៀត មានដែរឬទេ ។ ព្រះដ៏មានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ នៅមានទៀត ។ ម្នាលអានន្ទ កាលដែលភិក្ខុអ្នកបរិបូណ៌ ដោយសីលខ្លួនឯង មិនតិះដៀលភិក្ខុដទៃ ព្រោះតែអធិសីលផង ពិនិត្យតែខ្លួនឯង មិនពិនិត្យភិក្ខុដទៃផង ទោះជាអ្នកមិនល្បីឈ្មោះ ក៏មិនរន្ធត់ផង ជាអ្នកបានតាម សេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យ ចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្នផង បានដល់ ចេតោវិមុត្តិនិង បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្នផង ។ ម្នាលអានន្ទ ភិក្ខុសង្ឃ គួរនៅសប្បាយ ដោយហេតុប៉ុណ្ណោះឯង ។ ម្នាលអានន្ទ តថាគតពោលថា

*ធម៌ជាគ្រឿងនៅសប្បាយឯទៀត ជាធម៌លើសលុបជាង ឬថ្លៃថ្លាជាងធម៌ជាគ្រឿងនៅសប្បាយនេះគ្មានទេ ។*

# អដ្ឋកថា

## អានន្ទសូត្រ

*[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានន្ទសូត្រទី ៦ ដូចតទៅនេះ បទថា* **នោ ច បរំ អធិសីលេ សម្បវត្តា ហោតិ** *សេចក្តីថា មិនពោលតិះដៀលមិនពោលប្រទូស្តអ្នកដទៃដល់សីល ។ បទថា* **អត្តានុបេក្ខី** *បានដល់ សម្លឹងមើលខ្លួន ដោយដឹងកិច្ចដែលខ្លួនធ្វើហើយ និងមិនទាន់បានធ្វើ ។ បទថា* **នោ បរានុបេក្ខី** *បានដល់ មិនដាក់ចិត្តក្នុងកិច្ចដែលអ្នកដទៃធ្វើ និងមិនបានធ្វើ ។ បទថា* **អប្បញ្ញាតោ** *បានដល់ មិនប្រាកដ គឺមានបុណ្យតិច ។ បទថា* **អប្បញ្ញាតកេន** *បានដល់ ព្រោះភាពជាអ្នកមិនប្រាកដ គឺមិនមានឈ្មោះបោះសំឡេង មានបុណ្យតិច ។ បទថា* **នោ បរិតស្សតិ** *បានដល់ មិនដល់នូវការភ័យខ្លាច ។ ដោយសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះខីណាស្រពប៉ុណ្ណោះ ដោយប្រការដូច្នេះឯង ។*

**អដ្ឋកថា អានន្ទសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សីលសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសីល ១ បរិបូណ៌ដោយសមាធិ ១ បរិបូណ៌ដោយបញ្ញា ១ បរិបូណ៌ដោយវិមុត្តិ ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## សីលសូត្រ

[ ៧ ] សីលសូត្រទី ៧ ត្រាស់ដល់សីល សមាធិនិងបញ្ញាលាយគ្នា ។ វិមុត្តិ គឺអរហត្តផល វិមុត្តិញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ ជាលោកិយតែម្យ៉ាង ៕

**អដ្ឋកថា សីលសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អសេខិយសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកគួរទទួលគ្រឿងបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៥ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រកបដោយសីលក្ខន្ធជាអសេក្ខ ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខ ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខ ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខ ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកគួរទទួលគ្រឿងបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## អសេខិយសូត្រ

[ ៨ ] ក្នុងអសេខិយសូត្រទី ៨ ក៏មានន័យនេះដូចគ្នា តែក្នុងអសេខិយសូត្រទី ៨ នេះ ទ្រង់ត្រាស់បច្ចវេក្ខណញ្ញាណថា ជារបស់អសេក្ខៈ ព្រោះព្រះអសេក្ខៈប្រព្រឹត្ត ។៚

**អដ្ឋកថា អសេខិយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ចាតុទ្ទិសសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកត្រាច់ទៅបានក្នុងទិសទាំង ៤ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ ប្រកបដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ ទោះមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ អ្នកស្តាប់ច្រើន ចាំរឿងដែលស្តាប់ហើយ ចាំមិនភ្លេចនូវរឿងដែលស្តាប់ហើយ ពួកធម៌ណាពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង ប្រកាសព្រហ្មចរិយៈ ព្រមទាំងអត្ថទាំងព្យញ្ជនៈ បរិសុទ្ធិពេញលេញអស់ជើង ភិក្ខុនោះបានស្តាប់ធម៌មានសភាពយ៉ាងនោះច្រើន ចាំស្ទាត់រត់មាត់ យល់ច្បាស់ដោយចិត្ត ចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រនូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅសប្បាយក្នុងបច្ចុប្បន្ន ១ ជាអ្នកបានដល់ចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះក្ស័យទៅនៃអាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយ ធម៌ ៥ នេះឯង ទើបឈ្មោះថាជាអ្នកត្រាច់ទៅបានក្នុងទិសទាំង ៤ ។

# អដ្ឋកថា

## ចាតុទ្ទិសសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចាតុទ្ទិសសូត្រទី ៩ ដូចតទៅនេះ បទថា **ចាតុទ្ទិសោ** បានដល់ ទៅណាមកណា មិនទើសទាក់ ក្នុងទិសទាំង ៤ ក្នុងសូត្រនេះ ក៏ត្រាស់ចំពោះព្រះខីណាស្រពប៉ុណ្ណោះ ។

**អដ្ឋកថា ចាតុទ្ទិសសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## អារញ្ញសូត្រទី ១០

[ ១០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរអាស្រ័យសេនាសនៈស្ងាត់ ជាព្រៃដែលមិនមែនជាទីឧបចារៈរបស់មនុស្ស ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។បេ។ ចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកប្រារព្ធព្យាយាម ។បេ។ មានកម្លាំងប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន មិនបោះបង់ធុរៈក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកបានតាមសេចក្តីប្រាថ្នា បានមិនលំបាក បានមិនក្រ នូវឈានទាំង ៤ ដែលអាស្រ័យចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ជាអ្នកបានចេតោវិមុត្តិ បញ្ញាវិមុត្តិដែល

មិនមានអាសវៈ ព្រោះក្ស័យទៅនៃអាសវៈទាំងឡាយ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរអាស្រ័យសេនាសនៈស្ងាត់ ជាព្រៃដែលមិនមែនជាទីឧបចារៈរបស់មនុស្ស ។

ផាសុវិហារវគ្គទី ១ ចប់

## ឧទ្ទាននៃផាសុវិហារវគ្គនោះ គឺ

ធម៌ធ្វើឲ្យអៀនអន់ ១ ភិក្ខុដែលគេរង្កៀស ១ ចោរ ១
សមណសុខុមាល ១ ជាគម្រប់ ៥ នឹងភិក្ខុនៅសប្បាយ
ព្រះអានន្ទ ១ ភិក្ខុប្រកបដោយសីលជាដើម ១ ភិក្ខុ
ប្រកបដោយសីលជាសេក្ខៈជាដើម ១ ភិក្ខុត្រាច់ទៅបាន
ក្នុងទិសទាំងបួន ១ ភិក្ខុនៅក្នុងព្រៃ ១ ។

# អដ្ឋកថា

## អារញ្ញសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងអារញ្ញសូត្រទី ១០ ដូចតទៅនេះថា

[ ១០ ] បទថា **អលំ** ប្រែថា គួរ ។ ក្នុងសូត្រនេះ ត្រាស់ចំពោះព្រះខីណាស្រពប៉ុណ្ណោះ ។ល។

**អដ្ឋកថា អារញ្ញសូត្រទី ១០ ចប់**

**ផាសុវិហារវគ្គទី ១ ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ បញ្ចកនិបាត

## កុលុបកសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូលប្រកបដោយធម៌ ៥ យ៉ាង ត្រកូលទាំងឡាយ រមែងមិនស្រឡាញ់ផង មិនពេញចិត្តផង មិនគោរពផង មិនសរសើរផង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ គឺជាអ្នកស្និទ្ធស្នាលចំពោះត្រកូល ដែលមិនមានសេចក្តីរាប់អានខ្លួន ១ ខ្លួនមិនមែនជាឥស្សរៈ តែលើកខ្លួនជាឥស្សរៈ ១ ជាអ្នកចូលទៅរាប់រកដើម្បីផ្សះផ្សាត្រកូលដែលបែកបាក់គ្នា ១ ជាអ្នកច្រើនខ្សឹបជិតត្រចៀកអ្នកឯទៀត ១ ជាអ្នកសូមគេរឿយៗ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូល ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ត្រកូលទាំងឡាយ រមែងមិនស្រឡាញ់ផង មិនពេញចិត្តផង មិនគោរពផង មិនសរសើរផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកចូលទៅកាន់ត្រកូលដែលប្រកបដោយធម៌ ៥ យ៉ាង ត្រកូលទាំងឡាយ រមែងស្រឡាញ់ផង ពេញចិត្តផង គោរពផង សរសើរផង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនស្និទ្ធស្នាល ចំពោះត្រកូលដែលមិនមានសេចក្តីរាប់អានខ្លួន ១ ខ្លួនមិនមែនជាឥស្សរៈក៏មិនលើកខ្លួនជាឥស្សរៈ ១ ជាអ្នកមិនចូលទៅរាប់រកដើម្បីផ្សះផ្សាត្រកូលដែលបែកបាក់គ្នា ១ ជាអ្នកមិនខ្សឹបជិតត្រចៀកអ្នកឯទៀត ១ ជាអ្នកមិនសូមគេរឿយៗ ១ ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុអ្នកចូលទៅកាន់ត្រកូល ដែលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ត្រកូលទាំងឡាយ រមែងស្រឡាញ់ផង ពេញចិត្តផង គោរពផង សរសើរផង ។

# អដ្ឋកថា

# អន្ធកវិន្ទវគ្គទី ២

## កុលុបកសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងកុលុបកសូត្រទី ១ នៃអន្ធកវិន្ទវគ្គទី ២ ដូចតទៅថា

[ ១១ ] បទថា **អសន្ថវវិស្សាសី** សេចក្តីថា សម្តែងការស្និទ្ធស្នាលក្នុងបុគ្គលដែលមិនស្និទ្ធស្នាលនឹងខ្លួន គឺមិនស្និទ្ធស្នាលគ្នានោះឯង ។ បទថា **អនិស្សរវិកប្បី** សេចក្តីថា មិនបានជាធំឡើយ តែធ្វើជាធំដោយប្រាប់ថា ពួកអ្នកចូរឲ្យវត្ថុនេះ ចូរទទួលវត្ថុនេះ ។ បទថា **ព្យត្តុបសេវី** សេចក្តីថា ចូលទៅគប់រកត្រកូលដែលបែកគ្នា មិនបំណងល្អចំពោះគ្នា ដើម្បីញុះញង់ ។ បទថា **ឧបកណ្ណកជប្បី** សេចក្តីថា ទទួលមន្តដែលជិតត្រចៀក ។ ឯធម៌ចំណែក.ស គប្បីជ្រាបផ្ទុយគ្នាតាមដែលពោលហើយ ៕

**អដ្ឋកថា កុលុបកសូត្រទី ១ ចប់**

# សុត្តន្តបិដក

## បច្ឆាសមណសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរយកជាបច្ឆាសមណៈឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុដើរឆ្ងាយពេកឬជិតពេក ១ មិនទទួលយកបាត្រ ឬវត្ថុដែលនៅក្នុងបាត្រ ១ មិនហាមឃាត់ព្រះថេរៈដែលនិយាយជិតត្រូវអាបត្តិ ១ កាលព្រះថេរៈកំពុងនិយាយ ក៏និយាយពាក្យកាត់ត្រង់ចន្លោះៗ ១ ជាអ្នកអប្បឥតប្រាជ្ញា ល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរយកជាបច្ឆាសមណៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរយកជាបច្ឆាសមណៈបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនដើរឆ្ងាយពេក មិនជិតពេក ១ ទទួលយកបាត្រ ឬវត្ថុដែលនៅក្នុងបាត្រ ១ ហាមឃាត់ព្រះថេរៈដែលនិយាយជិតត្រូវអាបត្តិ ១ កាលព្រះថេរៈកំពុងនិយាយ មិននិយាយពាក្យកាត់ត្រង់ចន្លោះៗ ១ ជាអ្នកមានប្រាជ្ញា មិនល្ងង់មិនខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរយកជាបច្ឆាសមណៈបាន ។

# អដ្ឋកថា

## បច្ឆាសមណសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ឆាសមណសូត្រទី ២ ដូចតទៅនេះ បទថា **បត្តបរិយាបន្នំ ន គណ្ហាតិ** សេចក្តីថា កាលឧបជ្ឈាយ៍បែរមកឈរនិងប្រគេនបាត្រទទេរបស់ខ្លួន ហើយទទួលបាត្ររបស់លោកក៏មិនមែន ឬមិនទទួលកាន់បាត្រឧបជ្ឈាយ៍ ។ បទថា **ន និវារេតិ** សេចក្តីថា មិនដឹងថាពាក្យនេះជាពាក្យកន្លងអាបត្តិ សូម្បីដឹងក៏មិនបានហាមថា បពិត្រលោកម្ចាស់ លោកម្ចាស់គួរពោលយ៉ាងនេះ ។ បទថា **កថំ ឱបាតេតិ** សេចក្តីថា កាត់នូវពាក្យរបស់លោក ស៊កនូវពាក្យរបស់ខ្លួន ។ បទថា **ជឡោ** ប្រែថា ជាបុគ្គលល្ងីល្ងើ ។ បទថា **ឯឡមូគោ** បានដល់ ធ្លួតមានទឹកមាត់ហូរ ។៚

**អដ្ឋកថា បច្ឆាសមណសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សមាធិសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងចូលកាន់សម្មាសមាធិបានឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១

មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរនឹងចូលកាន់សម្មាសមាធិបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរនឹងចូលកាន់សម្មាសមាធិបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរចូលកាន់សម្មាសមាធិបាន ។

# អដ្ឋកថា

## សមាធិសូត្រ

ក្នុងសមាធិសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសមាធិសូត្រទី ៣ ចប់

# សុត្តន្តបិដក

## អន្ធកវិន្ទសូត្រទី ៤

[ ១៤ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងអន្ធកវិន្ទគ្រាម ក្នុងដែនមគធៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ទើបតែនឹងបួសថ្មី មកកាន់ធម៌វិន័យនេះ ក្នុងកាលឥឡូវនេះ ម្នាលអានន្ទ ភិក្ខុទាំងនោះ ត្រូវអ្នករាល់គ្នាឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ក្នុងធម៌ ៥ យ៉ាង ។ ក្នុងធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងបាតិមោក្ខសំវរសីល ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរមក ចូរជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈបរិបូណ៌ ដោយអាចារៈនិងគោចរៈ ឃើញនូវភ័យក្នុងទោសបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ក្នុងឥន្ទ្រិយសំវរៈដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ តាំងស្មារតីរក្សា ( ទ្វារ ) តាំងស្មារតីប្រកបដោយញាណ ជាអ្នកមានចិត្តរក្សាស្មារតី ប្រកបដោយចិត្តរក្សាស្មារតីដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងពាក្យសំដីឲ្យមានទីបំផុត ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកមានពាក្យសំដីតិច ធ្វើពាក្យសម្តីឲ្យមានទីបំផុតដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងសេចក្តីស្ងប់កាយ ដោយពាក្យថា ម្នាល

អាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកនៅក្នុងព្រៃជាវត្ត គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចព្រៃធំដូច្នេះ ១ ឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងការយល់ឃើញត្រូវ ដោយពាក្យថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរជាអ្នកយល់ត្រូវ ប្រកបដោយការយល់ឃើញត្រូវដូច្នេះ ១ ។ ម្នាលអានន្ទ ភិក្ខុទាំងឡាយណា ទើបនឹងបួសថ្មី មកកាន់ធម៌វិន័យនេះ ក្នុងកាលឥឡូវនេះ ម្នាលអានន្ទ ភិក្ខុទាំងនោះ ត្រូវអ្នករាល់គ្នាឲ្យសមាទាន ឲ្យនៅអាស្រ័យ ឲ្យតាំងនៅស៊ប់ ក្នុងធម៌ទាំង ៥ នេះឯង ។

# អដ្ឋកថា

## អនុកាវិន្ទសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងអន្ទកវិន្ទសូត្រទី ៤ ដូចតទៅនេះថា

[ ១៤ ] បទថា **សីលវា ហោថ** សេចក្តីថា ចូរជាអ្នកមានសីល ។ បទថា **អារក្ខសតិនោ** សេចក្តីថា ជាអ្នកប្រកបដោយសតិជាគ្រឿងរក្សា ។ បទថា **និបកសតិនោ** សេចក្តីថា មានសតិប្រកបដោយញាណ ជាគ្រឿងរក្សានោះឯង ។ បទថា **សតារក្ខេន ចេតសា សមន្នាគតា** សេចក្តីថា ប្រកបដោយចិត្ត មានគ្រឿងរក្សា គឺសតិ ។ បទថា **អប្បកស្សា** ប្រែថា និយាយតែបន្តិចបន្តួច ។ បទថា **សម្មាទិដ្ឋិកា** សេចក្តីថា ប្រកបដោយសម្មាទិដ្ឋិ ៥ យ៉ាង គឺកម្មស្សកតា ១ ឈាន ១ វិបស្សនា ១ មគ្គ ១ ផល ១ ។ ម្យ៉ាងទៀត បច្ចវេក្ខណញ្ញាណក៏គប្បីជ្រាបថា ជាសម្មាទិដ្ឋិដូចគ្នា ៕

# សុត្តន្តបិដក

## មច្ឆរិយសូត្រទី ៥

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីមិនកំណាញ់អាវាស ១ មិនកំណាញ់ត្រកូល ១ មិនកំណាញ់លាភ ១ មិនកំណាញ់គុណ ១ មិនកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

# អដ្ឋកថា

## មច្ឆរិយសូត្រ

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមច្ឆរិយសូត្រទី ៥ ដូចតទៅនេះ បទថា **អាវាសមច្ឆរិនី** សេចក្តីថា រមែងកំណាញ់អាវាស គឺឃើញអ្នកដទៃនៅក្នុង

អាវាសនោះ អត់ធន់មិនបាន ។ បទថា **កុលមច្ឆរិនី** សេចក្តីថា រមែង កំណាញ់ត្រកូលឧបដ្ឋាក គឺឃើញអ្នកដទៃចូលទៅរកត្រកូលនោះ អត់ធន់មិន បាន ។ បទថា **លាភមច្ឆរិនី** សេចក្តីថា រមែងកំណាញ់លាភ គឺឃើញលាភកើតដល់អ្នកដទៃ អត់ធន់មិនបាន ។ បទថា **វណ្ណមច្ឆរិនី** សេចក្តីថា រមែងកំណាញ់គុណ គឺឃើញគេពោលគុណរបស់អ្នកដទៃ អត់ធន់មិនបាន ។ បទថា **ធម្មមច្ឆរិនី** សេចក្តីថា រមែងកំណាញ់បរិយត្តិធម៌ គឺមិនប្រាថ្នាឲ្យដល់ អ្នកដទៃ ។ល។

**អដ្ឋកថា មច្ឆរិយសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## វណ្ណនាសូត្រទី ៦

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូច ម្តេចខ្លះ ។ គឺភិក្ខុនីមិនពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរបុគ្គល ដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយ តិះដៀលបុគ្គលដែលគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសម្តែងនូវសេចក្តីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនបានពិចារណា

មិនបានស្ទាបស្ទង់មើល ហើយសម្តែងនូវសេចក្តីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបព្រមដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីបានពិចារណាស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសម្តែងនូវសេចក្តីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសម្តែងនូវសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

# អដ្ឋកថា

## វណ្ណនាសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវណ្ណនាសូត្រទី ៦ ដូចតទៅនេះ បទថា **សទ្ធាទេយ្យំ វិនិបាតេតិ** សេចក្តីថា មិនកាន់យករបស់ ឬចាកបិណ្ឌបាតដែលអ្នកប្រគេនដោយសទ្ធាមុន ហើយឲ្យដល់អ្នកដទៃ ។៙

**អដ្ឋកថា វណ្ណនាសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ឥស្សាសូត្រទី ៧

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីមិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរបុគ្គល ដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ ជាអ្នកប្រណែន ១ កំណាញ់ ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីបានពិចារណាស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសរសើរបុគ្គល ដែលគួរសរសើរ ១ ជាអ្នកមិនប្រណែន ១ មិនកំណាញ់ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

# អដ្ឋកថា

## ឥស្សាសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥស្សាសូត្រទី ៧ ដូចតទៅនេះ បទថា **ឥស្សុកិនី** បានដល់ ជាអ្នកប្រកបដោយសេចក្ដីប្រណែន ៕

**អដ្ឋកថា ឥស្សាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទិដ្ឋិសូត្រទី ៨

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺភិក្ខុនីមិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរបុគ្គល ដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀលបុគ្គល ដែលគួរសរសើរ ១ ជាអ្នកមានសេចក្ដីយល់ខុស ១ មានសេចក្ដីត្រិះរិះខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀលបុគ្គល ដែលគួរតិះដៀល ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសរសើរ

បុគ្គល ដែលគួរសរសើរ ១ ជាអ្នកមានសេចក្ដីយល់ឃើញត្រូវ ១ មានសេចក្ដីត្រិះរិះត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

## អដ្ឋកថា

## ទិដ្ឋិសូត្រ

[ ១៨ ] ក្នុងទិដ្ឋិសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទិដ្ឋិសូត្រទី ៨ ចប់

# សុត្តន្តបិដក

## វាចាសូត្រទី ៩

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ គឺភិក្ខុនីមិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរបុគ្គល ដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀលបុគ្គល ដែលគួរសរសើរ ១ ជាអ្នកមានវាចាខុស ១ មានការងារខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើល រួចទើបតិះដៀលបុគ្គល ដែលគួរតិះដៀល ១ បានពិចារណាស្ទាបស្ទង់មើលរួច ទើបសរសើរបុគ្គល ដែលគួរសរសើរ ១ មានវាចាត្រូវ ១ មានការងារត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

# អដ្ឋកថា

## វាចាសូត្រ

[ ១៩ ] ក្នុងវាចាសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវាចាសូត្រទី ៩ ចប់

# សុត្តន្តបិដក

## វាយាមសូត្រទី ១០

[ ២០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនីមិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយសរសើរបុគ្គលដែលមិនគួរសរសើរ ១ មិនបានពិចារណា មិនបានស្ទាបស្ទង់មើល ហើយតិះដៀល បុគ្គលដែលគួរសរសើរ ១ មានព្យាយាមខុស ១ មានសតិខុស ១ ធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុនី បានពិចារណា ស្ទាបស្ទង់មើលរួច ទើបតិះដៀល បុគ្គលដែលគួរតិះដៀល ១ បានពិចារណា ស្ទាបស្ទង់មើលរួច ទើបសរសើរ បុគ្គលដែលគួរសរសើរ ១ មានព្យាយាមត្រូវ ១ មានសតិត្រូវ ១ មិនធ្វើសទ្ធាទេយ្យវត្ថុឲ្យធ្លាក់ចុះ ១ ។ ដោយធម៌នេះឯង ។បេ។

**អន្ធកវិន្ទវគ្គទី ២ ចប់**

### ឧទ្ទាននៃអន្ធកវិន្ទវគ្គនោះ គឺ

និយាយអំពីភិក្ខុ ចូលទៅកាន់ត្រកូល ១ អំពីភិក្ខុជា
បច្ឆាសមណៈ ១ អំពីភិក្ខុមិនគួរចូលកាន់សម្មាសមាធិ
១ អំពីព្រះដ៏មានព្រះភាគគង់ក្នុងអន្ធកវិន្ទគ្រាម ១ អំពី

សេចក្តីកំណាញ់ ១ អំពីសេចក្តីសរសើរ ១ អំពីកិក្ខុនី
មានសេចក្តីប្រណែន ១ អំពីសេចក្តីយល់ខុស ១ អំពី
វាចា ១ អំពីព្យាយាម ១ ។

# អដ្ឋកថា

## វាយាមសូត្រ

[ ២០ ] ក្នុងវាយាមសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថា វាយាមសូត្រទី ១០ ចប់

អន្ទុកវិន្ទុវគ្គទី ២ ចប់

# សុត្តន្តបិដក

# គិលានវគ្គទី ៣

## គិលានសូត្រទី ១

[ ២១ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវនជិតក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ចូលទៅឯគិលានសាលា ( មន្ទីរពេទ្យព្យាបាលជំងឺ ) ។ ព្រះអង្គបានឃើញភិក្ខុ ១ រូប មានជំងឺកម្លាំងជាប លុះឃើញហើយក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ស្ងប់ហើយ ទើបត្រាស់ទៅនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ( បើ ) ធម៌ ៥ យ៉ាង មិនលះបង់នូវបុគ្គលណាមួយ ដែលមានជំងឺកម្លាំងជាបទេ គុណវិសេសនុ៎ះ នឹងកើតប្រាកដដល់បុគ្គលនោះ គឺបុគ្គលនោះ មិនយូរប៉ុន្មាន នឹងធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ ក្នុងកាយថា មិនស្អាត ១ ជាអ្នកសម្គាល់ ក្នុងអាហារថា ជារបស់បដិកូល ១ ជាអ្នកសម្គាល់ក្នុងលោកទាំងអស់ថាជាសភាពមិនគួរត្រេកអរ ១ ជាអ្នកពិចារណាឃើញរឿយៗ ក្នុងសង្ខារទាំងពួងថា មិនទៀង ១ ទាំងមរណសញ្ញារបស់បុគ្គលនោះ ក៏តាំងនៅស៊ប់ក្នុងសន្តាន ១ ។ ម្នាលភិក្ខុទាំងឡាយ

( បើ ) ធម៌ទាំង ៥ យ៉ាងនេះ មិនលះបង់បុគ្គលណាមួយ ដែលមានជំងឺកម្លាំង ជាបទេ គុណវិសេសទុំះ នឹងកើតប្រាកដដល់បុគ្គលនោះ គឺបុគ្គលនោះ មិនយូរប៉ុន្មាន នឹងធ្វើឲ្យជាក់ច្បាស់ សម្រេច ។បេ។ ព្រោះអស់អាសវៈ ។

# សុត្តន្តបិដក

## សតិប្បដ្ឋានសូត្រទី ២

[ ២២ ] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ចម្រើននូវធម៌ ៥ យ៉ាង ធ្វើឲ្យច្រើននូវធម៌ ៥ យ៉ាង បណ្តាផលទាំង ២ ប្រការ ផលណាមួយនឹងកើតប្រាកដដល់បុគ្គលនោះ គឺថានឹងបានអរហត្តផល ឬកាលបើឧបាទាននៅមានសល់ ក៏គង់នឹងបាននូវភាពជាអនាគាមិបុគ្គល ក្នុងបច្ចុប្បន្ន ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានតម្កល់ស្មារតី ក្នុងសន្តាន ១ ជាអ្នកពិចារណាឃើញរឿយៗ ក្នុងកាយថា មិនស្អាត ដោយបញ្ញាជាគ្រឿងកំណត់ដឹងនូវការកើត និងការរលត់នៃធម៌ទាំងឡាយ ១ ជាអ្នកសំគាល់ក្នុងអាហារថាជារបស់បដិកូល ១ ជាអ្នកសម្គាល់ក្នុងលោកទាំងអស់ថា មិនគួរត្រេកអរ ១ ជាអ្នកសម្គាល់ក្នុងសង្ខារទាំងពួងថា មិនទៀង ១ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ចម្រើននូវធម៌ ៥ យ៉ាងនេះ ធ្វើឲ្យច្រើននូវធម៌ ៥ យ៉ាងនេះ បណ្តាផលទាំង

២ ប្រការ ផលណាមួយនឹងកើតប្រាកដដល់បុគ្គលនោះ គឺនឹងបានអរហត្តផល ឬកាលបើឧបាទាននៅមានសល់ ក៏គង់នឹងបាននូវភាពជាអនាគាមិបុគ្គល ក្នុងបច្ចុប្បន្ន ។

## បឋមឧបដ្ឋាកសូត្រទី ៣

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺ ប្រកបដោយធម៌ ៥ យ៉ាងជាបុគ្គលលំបាកបម្រើ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនចេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកមិនរានថ្នាំ ១ មិនប្រាប់ជំងឺតាមពិត ដល់អ្នកបម្រើជំងឺដែលប្រាថ្នានូវសេចក្តីចម្រើន ឬជំងឺដែលចម្រើនឡើងមិនប្រាប់ថាចម្រើនឡើង ឬជំងឺដែលធូរថយ មិនប្រាប់ថាធូរថយ ឬក៏ជំងឺដែលនៅនឹង មិនប្រាប់ថានៅនឹង ១ ជាអ្នកមិនចេះអត់ធន់ចំពោះវេទនាប្រជុំក្នុងសរីរៈ ជាទុក្ខដ៏ក្លាខ្លាំង ខ្លោចផ្សា មិនស្រួល មិនជាទីពេញចិត្ត ជាវេទនា អាចនាំយកជីវិតបានដែលកើតហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាបុគ្គលលំបាកបម្រើ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺប្រកបដោយធម៌ ៥ យ៉ាង ជាបុគ្គលងាយបម្រើ ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នករានថ្នាំ ១ ប្រាប់ជំងឺតាមពិតដល់អ្នកបម្រើជំងឺ ដែលប្រាថ្នានូវសេចក្តីចម្រើន ឬជំងឺដែលចម្រើនឡើង ប្រាប់ថា ចម្រើនឡើង ឬជំងឺធូរថយប្រាប់ថា ធូរថយ ឬក៏ជំងឺនៅនឹងប្រាប់ថានៅនឹង ១ ជាអ្នកអត់ធន់ចំពោះវេទនាដែលប្រជុំក្នុងសរីរៈ ជាទុក្ខ ដ៏ក្លាខ្លាំង ខ្លោចផ្សា មិនស្រួល

មិនជាទីពេញចិត្ត ជាវេទនាអាចនាំយកជីវិតបានដែលកើតហើយ ១ ។ ម្នាល ភិក្ខុទាំងឡាយ អ្នកជំងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាបុគ្គលងាយ បម្រើ ។

# អដ្ឋកថា

## គិលានសូត្រជាដើម

[ ២១-២៣ ] អដ្ឋកថាគិលានសូត្រទី ១ ជាដើម មានអត្ថងាយយល់ហើយ ។ល។

អដ្ឋកថាគិលានសូត្រទី ១ ជាដើមចប់

# សុត្តន្តបិដក

## ទុតិយឧបដ្ឋាកសូត្រទី ៤

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជំងឺប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងបម្រើជំងឺទេ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនប្រសប់ចាត់ចែងថ្នាំ ១ មិនស្គាល់នូវការសប្បាយ និងមិនសប្បាយ ១ ធ្វើអ្នកជំងឺឲ្យឈមទៅរកការមិនសប្បាយ ទាំងមិននាំសេចក្តីសប្បាយចូលមក

១ បម្រើជំនឺដោយចង់បានអាមិស មិនបម្រើដោយមេត្តាចិត្ត ជាអ្នកខ្ពើមចំពោះការនាំយកឧច្ចារៈបស្សាវៈ កម្អួត ឬទឹកមាត់ទៅចោល ១ ជាអ្នកមិនប្រសប់ធ្វើអ្នកជំងឺឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លៀវក្លា ឲ្យរីករាយ ដោយធម្មីកថា តាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជំងឺប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរនឹងបម្រើជំងឺបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជំងឺប្រកបដោយធម៌ ៥ យ៉ាង ទើបគួរនឹងបម្រើជំងឺបាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកប្រសប់ចាត់ចែងថ្នាំ ១ ស្គាល់នូវការសប្បាយនិងមិនសប្បាយ ១ នាំចេញនូវសេចក្តីមិនសប្បាយធ្វើអ្នកជំងឺឲ្យឈមទៅរកការសប្បាយ ១ បម្រើជំងឺដោយមេត្តាចិត្ត មិនបម្រើដោយចង់បានអាមិស ទាំងមិនខ្ពើមចំពោះការនាំយកឧច្ចារៈបស្សាវៈ កម្អួត ឬទឹកមាត់ទៅចោល ១ ជាអ្នកប្រសប់ ធ្វើអ្នកជំងឺឲ្យយល់ឃើញ ឲ្យកាន់យក ឲ្យក្លៀវក្លា ឲ្យរីករាយដោយធម្មីកថា តាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកបម្រើជំងឺប្រកបដោយធម៌ ៥ យ៉ាង នេះឯង ទើបគួរនឹងបម្រើជំងឺបាន ។

# អដ្ឋកថា

## ទុតិយឧបដ្ឋាកសូត្រទី ៤

[ ២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឧបដ្ឋាកសូត្រទី ៤ នៃគិលានវគ្គ ទី ៣ ដូចតទៅនេះ បទថា ឆ **បដិពលោ** បានដល់ មិនប្រកបដោយកម្លាំងកាយ និងកម្លាំងញាណ ។ បទថា **អាមិសន្តរោ** បានដល់ ជាអ្នកឃើញដល់អាមិស គឺប្រាថ្នាក្នុងបច្ច័យ មានចីវរជាដើម ។៚

អដ្ឋកថាទុតិយឧបដ្ឋាកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមអនាយុស្សសូត្រទី ៥

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ ( ធម៌ធ្វើឲ្យអាយុថយ ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនចេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហារមិនរលួយ ១ ជាអ្នកត្រាច់ទៅមិនត្រូវតាមកាល ១ ជាអ្នកមិនប្រព្រឹត្តធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ ( ធម៌ធ្វើឲ្យចម្រើនអាយុ ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ ១

ដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហាររលួយ ១ ជាអ្នកត្រាច់ទៅត្រូវតាមកាល ១ ប្រព្រឹត្តធម៌ដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមអនាយុស្សសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអនាយុស្សសូត្រទី ៥ ដូចតទៅនេះ បទថា **អនាយុស្សា** បានដល់ ចូលទៅកាត់អាយុ គឺមិនធ្វើឲ្យអាយុវែង ។ល។

**អដ្ឋកថា បឋមអនាយុស្សសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយអនាយុស្សសូត្រទី ៦

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ ( ធម៌ធ្វើឲ្យអាយុថយ ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកមិនចេះធ្វើខ្លួនឲ្យសប្បាយ ១ មិនដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហារ

មិនរលួយ ១ ជាអ្នកទ្រុស្តសីល ១ ជាអ្នកមានមិត្តអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ អនាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ ( ធម៌ធ្វើឲ្យចម្រើនអាយុ ) នេះមាន ៥ យ៉ាង ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺជាអ្នកចេះធ្វើខ្លួនឲ្យសប្បាយ ១ ដឹងប្រមាណក្នុងការសប្បាយ ១ ជាអ្នកបរិភោគអាហាររលួយ ១ ជាអ្នកមានសីល ១ ជាអ្នកមានកល្យាណមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ អាយុស្សធម៌ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយអនាយុស្សសូត្រ

[ ២៦ ] ក្នុងទុតិយអនាយុស្សសូត្រទី ៦ ក៏មានន័យនេះដូចគ្នា ។

អដ្ឋកថាទុតិយអនាយុស្សសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អវប្បកាសសូត្រទី ៧

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរនឹងចេញចាកសង្ឃ ( ទៅនៅតែម្នាក់ឯង ) ទេ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសន្តោសដោយចីវរ តាមមានតាមបាន ១ មិនសន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ មិនសន្តោសដោយសេនាសនៈ តាមមានតាមបាន ១ មិនសន្តោសដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ជាអ្នកក្រាស់ដោយសេចក្តីត្រិះរិះក្នុងកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នេះឯង មិនគួរនឹងចេញចាកសង្ឃ ( ទៅនៅតែម្នាក់ឯង ) ទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរចេញចាកសង្ឃ ( ទៅនៅតែម្នាក់ឯង ) បាន ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន ១ សន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ សន្តោសដោយសេនាសនៈ តាមមានតាមបាន ១ សន្តោសដោយគិលានប្បច្ច័យភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ជាអ្នកក្រាស់ដោយសេចក្តីត្រិះរិះ ក្នុងការចេញចាកកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរចេញចាកសង្ឃ ( ទៅនៅតែម្នាក់ឯង ) បាន ។

# អដ្ឋកថា

## អវប្បកាសសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអវប្បកាសសូត្រទី ៧ ដូចតទៅនេះ បទថា **នាលំ សង្ឃម្ហាវបកាសិតុំ** សេចក្តីថា មិនគួរចៀសចេញទៅចាកពួកម្នាក់ឯង តែសេចក្តីពិត លោកមិនគួរនៅក្នុងចំណោមសង្ឃដូចគ្នា តែក៏មិនគួរចៀសចេញអំពីពួកដោយត្រង់ ព្រោះមិនជាការធ្វើពួកឲ្យល្អ ព្រោះទាក់ទងដោយឱវាទានុសាសនី ។ បទថា **អលំ សង្ឃម្ហាវបកាសិតុំ** សេចក្តីថា ចៀសចេញអំពីពួកម្នាក់ឯងប៉ុណ្ណោះ ដោយនៅក្នុងទិសទាំង ៤ ក៏គួរ និងនៅក្នុងពួកក៏គួរដូចគ្នា ។ ព្រោះធ្វើពួកឲ្យស្អាត ។l៚

**អដ្ឋកថា អវប្បកាសសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សមណទុក្ខសូត្រទី ៨

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ សមណទុក្ខ ( ទុក្ខរបស់សមណៈ ) នេះមាន ៥ យ៉ាង ។ ទុក្ខ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសន្តោសដោយចីវរ តាមមានតាមបាន ១ មិនសន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ មិនសន្តោសដោយសេនាសនៈ តាមមានតាមបាន ១ មិនសន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាម

មានតាមបាន ១ ប្រព្រឹត្តព្រហ្មចរិយធម៌ ទាំងមិនត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណទុក្ខមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណសុខ ( សុខរបស់សមណៈ ) មាន ៥ យ៉ាង ។ សុខ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ តាមមានតាមបាន ១ សន្តោសដោយបិណ្ឌបាត តាមមានតាមបាន ១ សន្តោសដោយ សេនាសនៈ តាមមានតាមបាន ១ សន្តោសដោយគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ប្រព្រឹត្តព្រហ្មចរិយៈដោយសេចក្តីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ សមណសុខ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## សមណទុក្ខសូត្រ

[ ២៨ ] ក្នុងសមណទុក្ខសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសមណទុក្ខសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បរិកុប្បសូត្រទី ៩

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះ ជាអ្នកទៅកាន់អបាយ ទៅកាន់នរក មានសភាពកម្រើក ជាបុគ្គលកែប្រែមិនបាន ។ បុគ្គល ៥ ពួក តើដូចម្តេច ។ គឺបុគ្គលផ្តាច់ជីវិតមាតា ១ បុគ្គលផ្តាច់ជីវិតបិតា ១ បុគ្គលផ្តាច់ជីវិតព្រះអរហន្ត ១ បុគ្គលធ្វើលោហិតរបស់ព្រះតថាគតឲ្យពុះពងឡើងដោយចិត្តប្រទូស្ត ១ បុគ្គលបំបែកសង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៥ ពួកនេះឯង ជាអ្នកទៅកាន់អបាយ ទៅកាន់នរក មានសភាពកម្រើក ជាបុគ្គលកែប្រែមិនបាន ។

# អដ្ឋកថា

## បរិកុប្បសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិកុប្បសូត្រទី ៩ ដូចតទៅនេះ បទថា **អាបាយិកា** បានដល់ ជាអ្នកត្រូវទៅអបាយ ។ បទថា **នេរយិកា** បានដល់ ត្រូវទៅនរក ។ បទថា **បរិកុប្បា** បានដល់ មានសភាវៈកម្រើក ដូចដំបៅចាស់ ។ បទថា **អតេកិច្ឆា** បានដល់ បុគ្គលណាម្នាក់ធ្វើឲ្យត្រឡប់វិញមិនបាន ៗ។

**អដ្ឋកថា បរិកុប្បសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សម្បទាសូត្រទី ១០

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាសនេះ មាន ៥ យ៉ាង ។ សេចក្តីវិនាស ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺវិនាសញាតិ ១ វិនាសទ្រព្យ ១ វិនាសព្រោះរោគ ១ វិនាសសីល ១ វិនាសទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុវិនាសញាតិ ឬព្រោះហេតុវិនាសទ្រព្យ ឬក៏ហេតុតែវិនាសព្រោះរោគក៏ទេ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុវិនាសសីល ឬព្រោះហេតុវិនាសទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីវិនាស មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌នេះ មាន ៥ យ៉ាង ។ ការបរិបូណ៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺបរិបូណ៌ដោយញាតិ ១ បរិបូណ៌ដោយទ្រព្យ ១ បរិបូណ៌ដោយការមិនមានរោគ ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយ រាងកាយស្លាប់ទៅ ទៅកើត ឯសុគតិសួគ៌ទេវលោក ព្រោះហេតុបរិបូណ៌ដោយញាតិ ឬព្រោះហេតុតែ បរិបូណ៌ដោយទ្រព្យ ឬក៏ព្រោះហេតុតែបរិបូណ៌ ដោយការមិនមានរោគក៏ទេ ម្នាលភិក្ខុទាំងឡាយ ពួកសត្វបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯសុគតិសួគ៌ទេវលោក ព្រោះហេតុបរិបូណ៌ដោយសីល ឬព្រោះហេតុបរិបូណ៌ដោយ

ទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូណ៌មាន ៥ យ៉ាង នេះឯង ។

គិលានវគ្គទី ៣ ចប់

## ឧទ្ទាននៃគិលានវគ្គនោះ គឺ

និយាយអំពីភិក្ខុមានជំងឺ ១ អំពីតម្កល់ស្មារតី ១ អំពី
បុគ្គលបម្រើជំងឺ ២ លើក អំពីអាយុ ២ លើក អំពី
បុគ្គលមិនគួរចេញចាកសង្ឃ ១ អំពីទុក្ខ ១ អំពីបុគ្គល
ជាអ្នកកម្រើក ១ អំពីការបរិបូណ៌ ១ ។

# អដ្ឋកថា

## សម្បទាសូត្រ

[ ៣០ ] ក្នុងសម្បទាសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

### អដ្ឋកថា សម្បទាសូត្រទី ១០ ចប់

### គិលានវគ្គទី ៣ ចប់

# សុត្តន្តបិដក
# រាជវគ្គទី ៤

## ចក្កសូត្រទី ១

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិ ប្រកបដោយអង្គ ៥ យ៉ាង រមែងញ៉ាំងអាណាចក្រឲ្យប្រព្រឹត្តទៅ ដោយកុសលធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិក្នុងលោកនេះ ទ្រង់ឈ្វេងយល់នូវប្រយោជន៍ ( នៃរាជការ ) ១ ទ្រង់ចាំនូវប្រវេណីធម៌ ១ ទ្រង់ស្គាល់ប្រមាណក្នុងអាជ្ញា ឬគ្រឿងបូជា ១ ទ្រង់ស្គាល់កាល ១ ទ្រង់ស្គាល់បរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងញ៉ាំងព្រះរាជអាណាចក្រឲ្យប្រព្រឹត្តទៅដោយធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្សណាមួយមិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ ៥ ប្រការដូច្នោះដែរ ទើបញ៉ាំងធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅដោយធម៌បាន ធម្មចក្រនោះឯង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោកនេះជាអ្នកដឹងអត្ថ ១ ដឹងធម៌ ១

ដឹងប្រមាណ ១ ដឹងកាល ១ ដឹងបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅ ដោយធម៌បានធម្មចក្រនោះឯង ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

# អដ្ឋកថា

# រាជវគ្គទី ៤

## ចក្កសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចក្កសូត្រទី ១ នៃរាជវគ្គទី ៤ ដូច្នេះ បទថា **ធម្មេន** បានដល់ ដោយកុសលធម៌ ១០ ។ បទថា **ចក្កំ** បានដល់ អាណាចក្រ ។ បទថា **អត្ថញ្ញូ** បានដល់ ដឹងប្រយោជន៍នៃ រាជសម្បត្តិ ។ បទថា **ធម្មញ្ញូ** បានដល់ ដឹងធម៌ គឺប្រពៃណី ។ បទថា **មត្តញ្ញូ** បានដល់ ដឹងប្រមាណក្នុងការដាក់រាជអាជ្ញា ឬក្នុងការបង់ពន្ធ ។ បទថា **កាលញ្ញូ** បានដល់ ដឹងកាលសោយសុខក្នុងរាជសម្បត្តិ វេលាធ្វើការវិនិច្ឆ័យ និងវេលាយាងចារិកទៅក្នុងជនបទ ។ បទថា **បរិសញ្ញូ** បានដល់ ដឹងថា នេះជំនុំក្សត្រ នេះជំនុំព្រាហ្មណ៍ នេះជំនុំវេស្សៈ នេះជំនុំសូទ្រៈ នេះជំនុំសមណៈ ។

ក្នុងតថាគតវារៈ គប្បីជ្រាបអត្ថដូច្នេះ ។ បទថា **អត្ថញ្ញូ** បានដល់ ដឹងអត្ថ ៥ ។ បទថា **ធម្មញ្ញូ** បានដល់ ដឹងធម៌ ៤ ។ បទថា **មត្តញ្ញូ** បានដល់ ដឹងប្រមាណក្នុងការទទួលនិងបរិភោគបច្ច័យ ៤ ។ បទថា **កាលញ្ញូ** បានដល់ ដឹងកាលយ៉ាងនេះថា នេះជាកាលពួនសម្ងំ នេះជាពេលចូលសមាបត្តិ នេះជាពេលសម្ដែងធម៌ នេះជាពេលចារិកទៅក្នុងជនបទ ។ បទថា **បរិសញ្ញូ** បានដល់ ដឹងថា នេះខត្តិយបរិស័ទ ។ នេះសមណបរិស័ទ ។ បទថា **អនុត្តរំ** បានដល់ ប្រសើរដោយលោកុត្តរធម៌ ៩ ។ បទថា **ធម្មចក្កំ** បានដល់ ចក្កប្រសើរបំផុត ។l៚

# សុត្តន្តបិដក

## អនុវត្តនសូត្រទី ២

[ ៣២ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះរាជាចក្រពត្តិ ប្រកបដោយអង្គ ៥ យ៉ាង រមែងញុាំងអាណាចក្រដែលបិតាធ្លាប់ឲ្យប្រព្រឹត្ត ទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ដោយធម៌បាន អាណាចក្រនោះ សត្វជាសត្រូវ មានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ប្រកបដោយ អង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ ស្តេចចក្រពត្តិ ក្នុងលោកនេះ ទ្រង់ឈ្វេងយល់នូវប្រយោជន៍ ( នៃរាជការ ) ១ ទ្រង់ចាំនូវប្រពៃណីធម៌ ១ ទ្រង់ស្គាល់ប្រមាណក្នុងអាជ្ញា ឬគ្រឿងបូជា ១ ទ្រង់ស្គាល់កាល ១ ទ្រង់ស្គាល់បរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជ បុត្រច្បងរបស់ព្រះរាជាចក្រពត្តិប្រកបដោយអង្គ ៥ យ៉ាង នេះឯង រមែង ញុាំងអាណាចក្រដែលបិតាធ្លាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅ តាមលំដាប់ ដោយធម៌ អាណាចក្រនោះ សត្វជាសត្រូវមានជាតិជាមនុស្ស មិនអាចឲ្យ ប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៥ យ៉ាងដូច្នោះដែរ ទើបញុាំងធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគត ធ្លាប់ឲ្យ ប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅតាមលំដាប់ ដោយប្រពៃបាន ធម្មចក្រនោះ ទោះបី សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយក្នុង លោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើ ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ សារីបុត្រជាអ្នកដឹង អត្ថ ១ ដឹងធម៌ ១ ដឹងប្រមាណ ១ ដឹងកាល ១ ដឹងបរិសទ្យ ១ ។ ម្នាល ភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបញុាំងធម្មចក្រ

ដ៏ប្រសើរ ដែលព្រះតថាគតធ្លាប់ឲ្យប្រព្រឹត្តទៅ ឲ្យប្រព្រឹត្តទៅ តាមលំដាប់ ដោយប្រពៃបាន ធម្មចក្រនោះ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយ ក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបាន ឡើយ ។

# អដ្ឋកថា

## អនុវត្តនសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុវត្តនសូត្រទី ២ ដូចតទៅនេះ បទថា **បិតរា បវត្តិតំ ចក្កំ** សេចក្តីថា កាលស្តេចចក្រពត្តិទ្រង់ព្រះផ្នួស ឬអស់ព្រះជន្ម ចក្ករតនៈតាំងនៅត្រឹម ៧ ថ្ងៃ ។ សួរថា ព្រះជេដ្ឋោរស និងមហាចក្រវិលតាមទ្រង់ទៅបានដូចម្តេច ។ ឆ្លើយថា ឱរសច្បងនោះតាំងនៅក្នុងបវេណីរបស់ព្រះបិតា បំពេញចក្កវត្តិឲ្យបរិបូណ៌ គ្រប់គ្រងចក្រពត្តិរាជជ័យបាន ឈ្មោះថា ទ្រង់បន្វិលតាមចក្រដែលបិតាឲ្យវិលទៅនោះឯង ។

**អដ្ឋកថា អនុវត្តនសូត្រទី ២ ចប់**

# សុត្តន្តបិដក

## រាជសូត្រទី ៣

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជាចក្រពត្តិណា ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ព្រះរាជានោះឯង មិនញុំាងអាណាចក្រ ដែលមិនជារបស់ព្រះរាជាឲ្យប្រព្រឹត្តទៅឡើយ ។ កាលព្រះដ៏មានបុណ្យទ្រង់ត្រាស់យ៉ាងនេះ ភិក្ខុមួយរូប បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអ្នកណា ជាស្តេចរបស់ព្រះរាជាចក្រពត្តិដែលប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ ព្រះធម៌ ( ជាស្តេច ) ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុ ព្រះរាជាចក្រពត្តិ ក្នុងលោកនេះ ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ទ្រង់ទីពឹងនូវធម៌តែមួយយ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះអន្តោជន គឺអគ្គមហេសី បុត្តធីតា ។ ម្នាលភិក្ខុ មួយទៀត ព្រះរាជាចក្រពត្តិប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ។បេ។ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះពួកក្សត្រិយ៍ ( ដែលបានមុទ្ធាភិសេក ) ចំពោះពួកក្សត្រិយ៍ដែលចុះចូល ចំពោះពួកពល ចំពោះព្រាហ្មណ៍ គហបតី ចំពោះអ្នកនិគម អ្នកជនបទ ចំពោះសមណព្រាហ្មណ៍ ចំពោះម្រឹគ បក្សី ។ ម្នាលភិក្ខុ ព្រះរាជាចក្រពត្តិនោះឯង ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ ។បេ។ យកធម៌ជាធំ លុះចាត់ចែងនូវការរក្សា ការពារ គ្រប់

គ្រងប្រកបដោយធម៌ ចំពោះអន្តោជន លុះចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះពួកក្សត្រិយ៍ ចំពោះពួកក្សត្រិយ៍ដែលចុះចូល ចំពោះពួកពល ចំពោះព្រាហ្មណ៍ គហបតី ចំពោះអ្នកនិគម អ្នកជនបទ ចំពោះសមណព្រាហ្មណ៍ ចំពោះពួកម្រឹគ បក្សីរួចហើយ ទើបញុំាងអាណាចក្រ ឲ្យប្រព្រឹត្តទៅដោយធម៌តែមួយយ៉ាង អាណាចក្រនោះឯង សត្វជាសត្រូវ មានជាតិជាមនុស្សណាមួយ មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។ ម្នាលភិក្ខុ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ជាធម្មិកធម្មរាជក៏យ៉ាងនោះដែរ តែងទីពឹង នូវធម៌តែមួយយ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រង ប្រកបដោយធម៌ ចំពោះភិក្ខុទាំងឡាយថា កាយកម្មបែបនេះ ត្រូវសេព កាយកម្មបែបនេះ មិនត្រូវសេពទេ វចីកម្មបែបនេះ ត្រូវសេព វចីកម្ម បែបនេះ មិនត្រូវសេពទេ មនោកម្មបែបនេះ ត្រូវសេព មនោកម្មបែបនេះ មិនត្រូវសេពទេ ការចិញ្ចឹមជីវិតបែបនេះ ត្រូវសេព ការចិញ្ចឹមជីវិតបែបនេះ មិនត្រូវសេពទេ ស្រុកនិគមបែបនេះ ត្រូវសេព ស្រុកនិគមបែបនេះ មិនត្រូវសេពគប់ទេ ។ ម្នាលភិក្ខុ មួយទៀត ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធជា ធម្មិកធម្មរាជ ។បេ។ យកធម៌ជាធំ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រង ប្រកបដោយធម៌ ចំពោះភិក្ខុនី ... ចំពោះឧបាសក ... ចំពោះឧបាសិកាថា កាយកម្មបែបនេះ ត្រូវសេព កាយ-

កម្មបែបនេះ មិនត្រូវសេពទេ ។បេ។ ស្រុក និគមបែបនេះ ត្រូវសេព ស្រុក និគមបែបនេះ មិនត្រូវសេពទេ ។ ម្នាលភិក្ខុ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ជាធម្មិកធម្មរាជនោះឯង ។បេ។ យកធម៌ជាធំ លុះចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុ ចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ចំពោះភិក្ខុនី ... ចំពោះ ឧបាសក ... ចំពោះ ឧបាសិការួចហើយ ទើបញ៉ាំងធម្មចក្រដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយធម៌តែមួយយ៉ាង ធម្មចក្រនោះ ទោះបីសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬបុគ្គលណាមួយក្នុងលោក មិនអាចឲ្យប្រព្រឹត្តទៅបានឡើយ ។

# អដ្ឋកថា

## រាជសូត្រ

[ ៣៣ ] រាជសូត្រទី ៣ មានន័យដូចពោលហើយ ក្នុងតិកនិបាតនោះឯង ។ តែក្នុងសូត្រនេះ មានផ្សេងគ្នា ២ បទប៉ុណ្ណោះ គឺបទថា គួរសេព និងមិនគួរសេព ។ ក្នុង ២ បទនោះ សម្មាអាជីវៈ គួរសេព មិច្ឆាជីវៈ មិនគួរសេព ។ គាម និងនិគមដែលជាសប្បាយ គួរសេព ដែលមិនជាសប្បាយ មិនគួរសេព ។៚

**អដ្ឋកថា រាជសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## យសស្សនិស្សសូត្រទី ៤

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាង ទ្រង់ប្រថាប់ក្នុងទិសឯណាៗ ក៏រមែងប្រថាប់តែក្នុងដែនរបស់ព្រះអង្គដដែល ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្នុងលោកនេះ ទ្រង់មានព្រះជាតិដ៏ល្អទាំងពីរចំណែក គឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធិ អំពីតំណនៃអយ្យកោនិងអយ្យិកា ជាគម្រប់ ៧ មិនមានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ព្រះជាតិបាន ១ ព្រះអង្គជាស្ដេចស្ដុកស្ដម្ភ មានព្រះរាជទ្រព្យច្រើន មានភោគសម្ប័ទច្រើន មានឃ្លាំងនិងជង្រុកដ៏បរិបូណ៌ ១ ព្រះអង្គមានរេហ៍ពល ប្រកបដោយចតុរង្គសេនា ដែលអាចស្ដាប់បង្គាប់ធ្វើតាមព្រះរាជឱវាទ ១ បរិនាយករតន៍នៃព្រះអង្គ ជាអ្នកប្រាជ្ញវាងវៃ មានប្រាជ្ញា អង់អាច តែងគិតឃើញប្រយោជន៍ដែលជាអតីត អនាគតនិងបច្ចុប្បន្ន ១ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងញ៉ាំងយសបរិវារ របស់ក្សត្រិយ៍នោះឲ្យចាស់ក្លា ។ ព្រះរាជានោះ ប្រកបដោយធម៌ ដែលមានយសបរិវារជាគម្រប់ ៥ នេះ ទ្រង់ប្រថាប់ក្នុងទិសឯណាៗ រមែងប្រថាប់តែក្នុងដែនរបស់ព្រះអង្គដដែល ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ដំណើរនុ៎ះឯង ជាទំនៀមរបស់បុគ្គលទាំងឡាយដែលមានជ័យជម្នះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងក៏ដូច្នោះដែរ ស្ថិតនៅក្នុង

ទិសឯណាៗ រមែងស្ថិតនៅដោយវិមុត្តិចិត្តតែមួយយ៉ាង ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ដូចជាព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ទ្រង់បរិបូណ៌ដោយព្រះជាតិ ១ ជាអ្នកចេះដឹងច្រើន ។បេ។ ជាអ្នកមុតធ្លុះដោយទិដ្ឋិដូចព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិ-សេកហើយ ជាស្តេចស្តុកស្តម្ភ មានព្រះរាជទ្រព្យច្រើន មានភោគសម្ប័ទច្រើន មានឃ្លាំងនិងជង្រុកបរិបូណ៌ ១ មានសេចក្តីព្យាយាមប្រារព្ធ ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីញ៉ាំងកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីខ្មីឃ្មាតដ៏មាំ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ដូចជាព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ព្រះអង្គបរិបូណ៌ដោយកម្លាំង ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងកំណត់ដឹង នូវការកើតនិងការរលត់ជាប្រាជ្ញាដ៏ប្រសើរ អាចទម្លុះទម្លាយ ( នូវគំនរនៃលោភៈជាដើម ) ជាប្រាជ្ញា ធ្វើកងទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃ ដូចជាព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ទ្រង់បរិបូណ៌ដោយបរិនាយករតនៈ ១ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងញ៉ាំងវិមុត្តិរបស់ភិក្ខុនោះឲ្យចាស់ក្លា ១ ។ ភិក្ខុនោះប្រកបដោយធម៌ មានវិមុត្តិជាគម្រប់ ៥ នេះ នៅក្នុងទិសឯណាៗ រមែងស្ថិតនៅដោយវិមុត្តិចិត្តតែមួយយ៉ាង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ដំណើរនុ៎ះឯងជាទំនៀមរបស់ភិក្ខុដែលមានចិត្តរួចស្រឡះចាកកិលេស ។

# អដ្ឋកថា

## យសស្សុទិសសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយសស្សុទិសសូត្រទី ៤ ដូចតទៅនេះ បទថា **ឧភតោ** បានដល់ ទាំង ២ ចំណែក ។ បទថា **មាតិតោ ច បិតិតោ ច** សេចក្តីថា ព្រះរាជាអង្គណា មានព្រះមាតាជាក្សត្រ ព្រះមាតានៃព្រះមាតាជាក្សត្រ សូម្បីព្រះមាតានៃព្រះមាតានោះ ក៏មានមាតាជាក្សត្រ មានព្រះបិតាជាក្សត្រ ព្រះបិតានៃព្រះបិតាជាក្សត្រ សូម្បីព្រះបិតានៃព្រះបិតានោះ ក៏មានបិតាជាក្សត្រ ព្រះរាជាអង្គនោះ ឈ្មោះថា មានកំណើតល្អទាំង ២ ចំណែក គឺខាងមាតាផង ខាងបិតាផង ។ បទថា **សំសុទ្ធគហណិកោ** បានដល់ ប្រកបដោយគភ៌របស់ព្រះមាតាបរិសុទ្ធិល្អ ។ តេជោធាតុកើតអំពីកម្ម លោកហៅថា **គហណី** ក្នុងពាក្យថា **សមវេបា កិណិយា គហណិយា** គឺគភ៌ដែលមានវិបាកស្មើគ្នានេះ ។ បិតានៃបិតា ឈ្មោះថា **បិតាមហា** ជំនាន់នៃ **បិតាមហា** ឈ្មោះថា **បិតាមហាយុគ** ក្នុងពាក្យថា **យាវ សត្តមា បិតាមហាយុគា** គឺដល់ ៧ ជួរ **បិតាមហា** នេះ ។ ប្រមាណអាយុ លោកហៅថា **យុគ** ។ ពាក្យនេះ ត្រឹមតែជាពាក្យនិយាយគ្នាប៉ុណ្ណោះ តែដោយអត្ថ **បិតាមហា** នោះឯង ជា **បិតាមហាយុគ** ។ បុព្វបុរសទាំងអស់ រំលងនោះទៅ លោកកាន់យកដោយសព្ទ **បិតាមហា** ទាំងអស់ ជាបុគ្គលមានព្រះគភ៌បរិសុទ្ធិដល់ទៅ ៧ តំណបុរសយ៉ាងនេះ ។ ម្យ៉ាងទៀត លោកសម្តែងថា មិនត្រូវជំទាស់ មិនត្រូវតិះដៀលដោយកំណើត ។

បទថា **អក្ខិត្តោ** សេចក្ដីថា មិនជំទាស់ គឺមិនសម្ដីងថា ចូរនាំគេចេញទៅ ប្រយោជន៍អ្វីដោយបុគ្គលនេះ ។ បទថា **អនុបក្កុដ្ឋោ** សេចក្ដីថា មិនត្រូវតិះដៀល គឺមិនត្រូវជេរ ឬនិន្ទា ។ សួរថា ព្រោះរឿងអ្វី ឆ្លើយថា ព្រោះរឿងកំណើត ។ អធិប្បាយថា ដោយពាក្យបែបនេះថា បុគ្គលនេះមានកំណើតអាក្រក់ដោយប្រការដូច្នេះ ។ ក្នុងបទថា **អឌ្ឍោ** ជាដើម សេចក្ដីថា បុគ្គលណាម្នាក់ជាអ្នកមាំទាំ ព្រោះសម្បត្តិដែលជារបស់ខ្លួន តែក្នុងទីនេះ មិនមែនជាអ្នកមាំទាំតែម្យ៉ាងប៉ុណ្ណោះទេ ជាអ្នកមានទ្រព្យច្រើន អធិប្បាយថា ជាអ្នកប្រកបដោយទ្រព្យច្រើន គឺរាប់ប្រមាណមិនបាន ។ ជាអ្នកមានភោគៈច្រើន ព្រោះទ្រង់មានភោគៈច្រើន គឺឱឡារដោយកាមគុណ ៥ ។ ពាក្យថា **កោស** ក្នុងពាក្យថា **បរិបុណ្ណកោសកោដ្ឋាគារោ** លោកពោលសំដៅយកឃ្លាំង សេចក្ដីថា មានឃ្លាំងបរិបូណ៌ដោយទ្រព្យដែលរក្សាទុក និងមានជង្រុកបរិបូណ៌ដោយស្រូវ ។ ម្យ៉ាងទៀត កោសៈមាន ៤ យ៉ាង គឺទ័ពដំរី ទ័ពសេះ ទ័ពរថ ទ័ពថ្មើរជើង ។ **កោដ្ឋាគា** គឺជង្រុកមាន ៣ យ៉ាង គឺឃ្លាំងទ្រព្យ ឃ្លាំងស្រូវ ឃ្លាំងសំពត់ ។ ព្រះរាជាជាអ្នកមានឃ្លាំង និងជង្រុកបរិបូណ៌ ព្រោះទ្រង់មានឃ្លាំង និងជង្រុកទាំងអស់នោះបរិបូណ៌ ។

បទថា **អស្សវាយ** សេចក្ដីថា កាលព្រះរាជទានទ្រព្យជាច្រើនដល់អ្នកណា សេនាមិនស្ដាប់ សេនានោះ ឈ្មោះថា ជាអ្នកមិនស្ដាប់បង្គាប់ សូម្បីមិនបានព្រះរាជទានដល់បុគ្គលណាម្នាក់ សេនាក៏ស្ដាប់ សេនានេះ ឈ្មោះថា ជា

អ្នកស្តាប់បង្គាប់ ។ បទថា **ឱវាទប្បដិករាយ** សេចក្តីថា ជាអ្នកធ្វើតាមព្រះឱវាទដែលព្រះរាជទានថា អ្នកទាំងឡាយគប្បីធ្វើវត្តនេះ មិនគប្បីធ្វើវត្តនេះ ។ បទថា **បណ្ឌិតោ** បានដល់ ប្រកបដោយភាពជាបណ្ឌិត ។ បទថា **ព្យត្តោ** បានដល់ ប្រកបដោយភាពជាអ្នកឈ្លាស គឺបញ្ញា ។ បទថា **មេធាវី** បានដល់ ប្រកបដោយបញ្ញាជាគ្រឿងឲ្យកើតតំណែង ។ បទថា **បដិពលោ** បានដល់ អាច ។ បទថា **អត្ថេ ចិន្តេតុំ** បានដល់ ដើម្បីគិតប្រយោជន៍ គឺ សេចក្តីចម្រើន ។ សេចក្តីពិត ព្រះរាជានោះ ទ្រង់ត្រិះរិះអាស្រ័យប្រយោជន៍បច្ចុប្បន្ននោះឯងថា ក្នុងអតីតក៏មានហើយយ៉ាងនេះ ក្នុងអនាគតនឹងមានយ៉ាងនេះ ។ បទថា **វិជិតាវីនំ** បានដល់ ជាអ្នកមានជ័យជម្នះដែលទ្រង់ឈ្នះវិសេសហើយ ឬទ្រង់ប្រកបដោយជ័យជម្នះដ៏ក្រៃលែង ។ បទថា **វិមុត្តចិត្តានំ** បានដល់ មានចិត្តរួចផុតដោយវិមុត្តិ ៥ ។ល។

## អដ្ឋកថា យស្សំទិសសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមបត្ថនាសូត្រទី ៥

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារ ប្រកបដោយអង្គ ៥ យ៉ាងតែងប្រាថ្នានូវរាជ្យ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជដែលបានមុទ្ធាភិសេក ជាព្រះរាជកុមារ មានព្រះជាតិដ៏ល្អទាំងពីរចំណែក គឺខាងព្រះមាតា និងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធិអំពីតំណនៃអយ្យកោនិងអយ្យិកាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ព្រះជាតិបាន ១ ព្រះអង្គមានព្រះរូបល្អ គួរមិលមើល គួរជ្រះថ្លា ប្រកបដោយព្រះឆវីវណ្ណល្អក្រៃលែង ១ ព្រះអង្គជាទីស្រឡាញ់សព្វព្រះរាជហឫទ័យនៃព្រះមាតាព្រះបិតា ១ ជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អ្នកនិគមអ្នកជនបទ ១ ហេតុជាទីកើតនៃសិល្បសាស្ត្រឯណាសម្រាប់ខត្តិយរាជទាំងឡាយដែលបានមុទ្ធាភិសេកហើយ ទោះជាសិល្បៈខាងដំរីក្តី សេះក្តី រថក្តី ធ្នូក្តី ព្រះអង្គជាអ្នកសិក្សាឥតមានទើសទាល់ក្នុងសិល្បសាស្ត្រនោះ ១ ។ ព្រះរាជបុត្រច្បងនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា ខ្លួនអញហ្នឹងឯង មានជាតិដ៏ល្អទាំងពីរចំណែក គឺខាងព្រះមាតា និងព្រះបិតា ប្រសូតចេញចាកព្រះគភ៌ ដ៏បរិសុទ្ធិអំពីតំណនៃអយ្យកោ និងអយ្យិកាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិបាន ព្រោះហេតុអ្វី អញនឹងមិនប្រាថ្នានូវរាជ្យ អញហ្នឹងឯង ជាអ្នកមានរូបល្អ គួរមិលមើល គួរ

ជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ អញជាទីស្រឡាញ់ពេញចិត្តនៃព្រះមាតានិងព្រះបិតា ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ អញជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃអ្នកនិគមអ្នកជនបទ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ ហេតុជាទីកើតនៃសិល្បសាស្រ្តឯណា សម្រាប់ខត្តិយរាជទាំងឡាយ ដែលបានមុទ្ធាភិសេកហើយ ទោះជាសិល្បៈខាងដំរីក្តី សេះក្តី រថក្តី ធ្នូក្តី អញជាអ្នកសិក្សាឥតមានទើសទាល់ ក្នុងសិល្បសាស្រ្តនោះ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ តែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿពោធិញ្ញាណរបស់តថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ត្រៃភពទៀត ១ ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុចាស់ល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ១ មិនជាអ្នកលេងបោកប្រាស មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួន គួរតាមសេចក្តីពិត ក្នុងសម្នាក់សាស្តា ឬក្នុងសម្នាក់នៃសព្រហ្មចារីទាំងឡាយដែលជាអ្នកចេះដឹង ១ ជាបុគ្គលប្រារព្ធព្យាយាម ដើម្បី

លះបង់នូវអកុសលធម៌ទាំងឡាយ ដើម្បីញុំាងកុសលធម៌ឲ្យដុះដាលឡើង ជាបុគ្គលមានកម្លាំងចិត្ត មានសេចក្ដីសង្វាតដ៏មាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលអាចកំណត់ដឹងនូវសេចក្ដីកើតនិងការរលត់បាន ជាប្រាជ្ញាដ៏បរិសុទ្ធិ អាចទម្លុះទម្លាយ ( នូវគំនរនៃលោភៈជាដើម ) ជាប្រាជ្ញាធ្វើកងទុក្ខឲ្យដល់នូវការអស់ទៅ ដោយប្រពៃ ១ ។ ភិក្ខុនោះ រមែងមានសេចក្ដីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានសទ្ធា ជឿព្រះពោធិញ្ញាណរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ព្រះអង្គត្រាស់ដឹងចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ត្រៃភពទៀត ព្រោះអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុចាស់ល្មម មិនត្រជាក់ពេក មិនក្ដៅពេក យ៉ាងកណ្ដាល គួរដល់សេចក្ដីព្យាយាម ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមិនលេង បោកប្រាស់ មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួន គួរតាមសេចក្ដីពិត ក្នុងសម្នាក់សាស្ដា ឬក្នុងសម្នាក់នៃសព្រហ្មចារី ទាំងឡាយដែលជាអ្នកចេះដឹង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅ នៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាបុគ្គលប្រារព្ធព្យាយាមដើម្បីលះបង់ អកុសលធម៌ទាំងឡាយ ។បេ។ មិនដាក់ធុរៈចោល ក្នុងកុសលធម៌ទាំងឡាយ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំង-

ឡាយ អញជាអ្នកមានប្រាជ្ញា ។បេ។ ជាប្រាជ្ញាធ្វើកន្ទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវការអស់ទៅនៃ អាសវៈទាំងឡាយ ។

# អដ្ឋកថា

## បឋមបត្ថនាសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមបត្ថនាសូត្រទី ៥ ដូចតទៅនេះ បទថា **នេគមជានបទស្ស** បានដល់ របស់ជនដែលនៅក្នុងនិគម និងនៅក្នុងដែន ។ ដោយបទថា **ហត្ថិស្មឹ** ជាដើម ទ្រង់សម្តែងសិប្បៈសំខាន់ ១៦ ប្រការ មានសិប្បៈទាក់ទងនឹងដំរី សេះ រថ ធ្នូ ចារឹក និងវិធីគណនាជាដើម ។ បទថា **អនវយោ** បានដល់ សម្រេចបរិបូណ៌ ។ ពាក្យដ៏សេសក្នុងសូត្រនេះ គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។

**អដ្ឋកថា បឋមបត្ថនាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយបត្ថនាសូត្រទី ៦

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាង រមែងប្រាថ្នានូវឧបរាជ្យ ( ភាពជាស្តេចបន្ទាប់ ) ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជាព្រះរាជកុមារ មានព្រះជាតិដ៏ល្អទាំងពីរចំណែក គឺខាងព្រះមាតា និងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធិអំពីតំណាន់នៃអយ្យកោ និងអយ្យិកាជាគម្រប់ ៧ មិនមានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ព្រះជាតិបាន ១ មានព្រះរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយព្រះឆវីវណ្ណល្អក្រៃលែង ១ ជាទីស្រឡាញ់គាប់ព្រះហឫទ័យរបស់ព្រះមាតាព្រះបិតា ១ ជាទីស្រឡាញ់ពេញចិត្តរបស់ពួកពល ១ ជាអ្នកប្រាជ្ញឈ្លាសវៃ មានប្រាជ្ញាអង់អាចៗ គិតឃើញនូវប្រយោជន៍ដែលជាអតីត អនាគត បច្ចុប្បន្ន ១ ។ ព្រះរាជបុត្រច្បងនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានកំណើតល្អទាំងពីរចំណែក គឺខាងព្រះមាតានិងព្រះបិតា ប្រសូតចាកព្រះគភ៌ដ៏បរិសុទ្ធិអំពីតំណាន់នៃអយ្យកោនិងអយ្យិកាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិបាន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរាជ្យ អញហ្នឹងឯង ជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរាជ្យ អញហ្នឹងឯង ជាទី

ស្រឡាញ់ គាប់ព្រះហឫទ័យនៃព្រះមាតា និងព្រះបិតា ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរាជ្យ អញហ្នឹងឯងជាទីស្រឡាញ់ពេញចិត្តនៃពួកពល ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរាជ្យ អញហ្នឹងឯងជាអ្នកប្រាជ្ញឈ្លាសវៃ មានប្រាជ្ញាអង់អាចៗ គិតឃើញនូវប្រយោជន៍ដែលជាអតីត អនាគត បច្ចុប្បន្ន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវឧបរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជបុត្រច្បងរបស់ព្រះខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ប្រកបដោយអង្គ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវឧបរាជ្យ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ រមែងប្រាថ្នានូវការអស់ទៅ នៃអាសវៈទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកមានសេចក្តីចេះដឹងច្រើន ។បេ។ ជាអ្នកមុតចុះដោយសម្មាទិដ្ឋិ ១ ជាអ្នកមានចិត្តតម្កល់ស៊ប់ ក្នុងសតិប្បដ្ឋានទាំងបួន ១ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់អកុសលធម៌ ។បេ។ មិនដាក់ធុរៈចោលក្នុងកុសលធម៌ ១ ជាអ្នកមានប្រាជ្ញាប្រកបដោយប្រាជ្ញា ដែលអាចកំណត់ដឹង នូវការកើតនិងការរលត់បាន ជាប្រាជ្ញាដ៏បរិសុទ្ធិ អាចទម្លុះទម្លាយ ( នូវគំនរនៃលោភៈជាដើម ) ជាប្រាជ្ញាធ្វើកងទុក្ខ ឲ្យអស់ទៅដោយប្រពៃ ១ ។ ភិក្ខុនោះ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អញហ្នឹងឯង ជាអ្នកមានសីល ។បេ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង

ជាអ្នកមានសេចក្ដីចេះដឹងច្រើន ចងចាំនូវសូត្រ ចាំស្ទាត់នូវសូត្រ ។បេ។ ជាអ្នកមុតធ្លុះដោយសម្មាទិដ្ឋិ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅ នៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានចិត្តតម្កល់ស៊ប់ក្នុងសតិប្បដ្ឋាន ៤ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ។បេ។ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ អញហ្នឹងឯង ជាអ្នកមានប្រាជ្ញា ។បេ។ ជាប្រាជ្ញាធ្វើកងទុក្ខឲ្យដល់នូវការអស់ទៅដោយប្រពៃបាន ព្រោះហេតុអ្វី អញមិនប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងប្រាថ្នានូវការអស់ទៅនៃអាសវៈទាំងឡាយ ។

# អដ្ឋកថា

## ទុតិយបត្ថនាសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយបត្ថនាសូត្រទី ៦ ដូចតទៅនេះ បទថា **ឱបរជ្ជំ** បានដល់ ជាឧបរាជ ។៙

### អដ្ឋកថា ទុតិយបត្ថនាសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អប្បសុបតិសូត្រទី ៧

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ ជន ៥ ពួកនេះក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រឭកច្រើន ។ ជន ៥ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺស្រីដែលមានប្រាថ្នាចំពោះបុរស ( ដោយអសទ្ធម្ម ) ក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រឭកច្រើន ១ ម្នាលភិក្ខុទាំងឡាយ បុរសដែលមានប្រាថ្នាចំពោះស្រី ( ដោយអសទ្ធម្ម ) ក្នុងវេលារាត្រី រមែងដេកលក់តិច ភ្ញាក់រឭកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ចោរដែលប្រាថ្នាកាន់យក ( ទ្រព្យរបស់គេ ) ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រលឹកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាខ្វល់ខ្វាយក្នុងរាជកិច្ច ក្នុងវេលារាត្រី ផ្ទំលក់តិច ភ្ញាក់រឭកច្រើន ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលមានប្រាថ្នាដើម្បីអស់សញ្ញោជនៈ ( ព្រះនិព្វាន ) ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រឭកច្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកជន ៥ ពួកនេះឯង ក្នុងវេលារាត្រី ដេកលក់តិច ភ្ញាក់រឭកច្រើន ។

# អដ្ឋកថា

## អប្បសុបតិសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បសុបតិសូត្រទី ៧ ដូចតទៅនេះ បទថា **បុរិសាធិប្បាយា** សេចក្តីថា មានបំណងក្នុងបុរស កើតឡើងដោយ

*អំណាចអសទ្ធម្ម គឺពេញចិត្តក្នុងបុរស ។ បទថា* **អានាធាធិប្បាយោ** *សេចក្តីថា ចោរមានបំណងនឹងលួចយ៉ាងនេះថា ឥឡូវនេះ អញនឹងលួចយកបាន ឥឡូវនេះ លួចមិនបាន ។ បទថា* **វិសញ្ញោគាធិប្បាយោ** *សេចក្តីថា ភិក្ខុជាអ្នកប្រាថ្នាព្រះនិព្វានយ៉ាងនេះថា អាត្មាអញនឹងសម្រេចព្រះនិព្វាន ក្នុងកាលឥឡូវនេះ ។ល។*

**អដ្ឋកថា អប្បសុបតិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ភត្តាទកសូត្រទី ៨

*[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង ជាសត្វបានតែខាងស៊ីអាហារផង វាតទីឱកាសផង ជម្រះសម្អាតអាចម៍ ( ត្រង់ឱកាសនោះ ) ផង កាន់យកស្លាកផង តែដល់នូវការរាប់ថា ជាដំរីដ៏ប្រសើររបស់ស្តេចដែរ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ជាសត្វបានតែខាងស៊ីអាហារផង វាតទីឱកាសផង ជម្រះសម្អាតអាចម៍ ( ត្រង់ទីឱកាសនោះ ) ផង ទទួលយកស្លាក*

*ផង តែដល់នូវការរាប់ថា ជាដំរីដ៏ប្រសើររបស់ស្តេចដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ជាអ្នកបានតែខាងបរិភោគនូវចង្ហាន់ផង ផ្សាយនូវឱកាសផង ដុសខាត់នូវតាំងផង កាន់យកនូវស្លាកផង តែដល់នូវការរាប់ថាជាភិក្ខុដែរ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកបានតែខាងបរិភោគចង្ហាន់ផង ផ្សាយឱកាសផង ដុសខាត់នូវតាំងផង កាន់យកនូវស្លាកផង តែដល់នូវការរាប់ថា ជាភិក្ខុដែរ ។*

# អដ្ឋកថា

## ភត្តាទកសូត្រ

*[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភត្តាទកសូត្រទី ៨ ដូចតទៅនេះ បទថា* **ភត្តាទកោ** *បានដល់ ចាំតែស៊ី អធិប្បាយថា ស៊ីច្រើន ។ បទថា* **ឱកាស-ផរណោ** *សេចក្តីថា ឈ្មោះថា* **ឱកាសផរណោ** *ព្រោះបៀតបៀនដល់ទីរបស់ដំរីដទៃៗ ។ ឈ្មោះថា* **លណ្ឌសារទោ** *បន្ទោបង់មិនដឹងទី ព្រោះបន្ទោបង់លាមករាត់រាយក្នុងទីនោះៗ ។ ឈ្មោះថា* **សលាកគ្គាហី** *ចាំគណនា ព្រោះគណនាក្នុងពេលរាប់ចំនួនថា ដំរីមានចំនួនប៉ុណ្ណោះ ។ ឈ្មោះថា* **បីឋមទ្ទន**

ព្រោះជាន់តាំងកាលទឹងអន្ទុយ ឬដេក ។ ឈ្មោះថា **សលាកគ្គាហី** ចាំគណនា ព្រោះគណនាក្នុងពេលរាប់ភិក្ខុ ៕

**អដ្ឋកថា ភត្តាទកសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អក្ខមសូត្រទី ៩

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេចប្រកបដោយអង្គ ៥ យ៉ាង មិនគួរជារាជយាន មិនសមជារាជបម្រើ មិនដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបានឡើយ ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឃើញពួកពលដំរីក្តី ឃើញពួកពលសេះក្តី ឃើញពួកពលរថក្តី ឃើញពួកពលថ្មើរជើងក្តី ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរូបយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏

ប្រសើររបស់ស្តេច មិនអត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឮសូរសន្ធឹកដំរីក្តី ឮសូរសន្ធឹកសេះក្តី ឮសូរសន្ធឹករថក្តី ឮសូរសន្ធឹកពលថ្មើរជើងក្តី ឮសូរគងរំពងនៃស្គរតូច ស្គរធំ ស័ង្ខ ស្គរសឹកសង្គ្រាមក្តី ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងសំឡេងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានធុំក្លិនមូត្រលាមករបស់ដំរីដែលមានជាតិខ្ពង់ខ្ពស់ ធ្លាប់ចុះស្នាម ក្នុងសង្គ្រាមរបស់ស្តេចដទៃ ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម មិនមានគេរាប់អានដោយឲ្យស្មៅនិងទឹកមួងក្តី មិនមានគេរាប់អានដោយឲ្យស្មៅនិងទឹក ២ ដងក្តី ៣ ដងក្តី ៤ ដងក្តី ៥ ដងក្តី ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចូលទៅកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុង

លោកនេះ ទៅកាន់សង្គ្រាម ត្រូវមុតដោយកម្លាំងព្រួញ ១ ក្តី ឬត្រូវមុតដោយកម្លាំងព្រួញ ២ ក្តី ៣ ក្តី ៤ ក្តី ៥ ក្តី ក៏ក្រាបក្រាញ មិនរុលទៅមុខ មិនហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច មិនអត់ធន់នឹងផស្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើរ របស់ស្តេចប្រកបដោយអង្គ ៥ យ៉ាងនេះឯង មិនគួរជារាជយាន មិនសមជារាជបម្រើ មិនដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ជាអ្នកមិនគួរទទួលនូវទានដែលគេនាំមកបូជា មិនគួរទទួលនូវវត្ថុដែលគេរៀបដើម្បីភ្ញៀវ មិនគួរទទួលនូវទក្ខិណាទាន មិនគួរគេធ្វើអញ្ជលិកម្ម មិនមែនជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនអត់ធន់នឹងរូប ១ មិនអត់ធន់នឹងសំឡេង ១ មិនអត់ធន់នឹងក្លិន ១ មិនអត់ធន់នឹងរស ១ មិនអត់ធន់នឹងផស្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនអត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែក រមែងត្រេកអរក្នុងរូបដែលគួរត្រេកអរ មិនអាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនអត់ធន់នឹងរូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនអត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឮសំឡេងដោយត្រចៀក រមែងត្រេកអរក្នុងសំឡេងដែលគួរត្រេកអរ

មិនអាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនអត់ធន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនអត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធុំក្លិនដោយច្រមុះ រមែងត្រេកអរក្នុងក្លិនដែលគួរត្រេកអរ មិនអាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនអត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនអត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ លិទ្ធភ្លក្សរសដោយអណ្តាត រមែងត្រេកអរក្នុងរសដែលគួរត្រេកអរ មិនអាចដើម្បីតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនអត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុមិនអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានពាល់ត្រូវនូវផ្សព្វដោយកាយ រមែងត្រេកអរក្នុងផ្សព្វ ដែលគួរត្រេកអរ មិនអាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនអត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរទទួលនូវទាន ដែលគេនាំមកបូជា មិនគួរទទួលនូវវត្ថុ ដែលគេរៀបចំដើម្បីភ្ញៀវ មិនគួរទទួលនូវទក្ខិណាទាន មិនគួរគេធ្វើអញ្ជលិកម្ម មិនមែនជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង ទើបគួរជារាជយាន គួរជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបាន ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏

ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ អត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឃើញពួកពលដំរីក្តី ឃើញពួកពលសេះក្តី ឃើញពួកពលរថក្តី ឃើញពួកពលថ្មើរជើងក្តី ក៏មិនក្រាប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងរូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម បានឮសូរសន្ធឹកដំរីក្តី ឮសូរសន្ធឹកសេះក្តី ឮសូរសន្ធឹករថក្តី ឮសូរសន្ធឹកពលថ្មើរជើងក្តី ឬឮសូរគឹកកងរំពងស្គរតូច ស្គរធំ ស័ង្ខ ស្គរ សឹកសង្គ្រាមក្តី មិនក្រាប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ធុំក្លិនមូត្រលាមកជារបស់ដំរីដែលមានជាតិខ្ពង់ខ្ពស់ ធ្លាប់ចុះស្នាមសង្គ្រាមរបស់ស្តេច ក៏មិនក្រាប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់

ស្តេច អត់ធន់នឹងក្លិន យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម មិនមានគេរាប់អានដោយឲ្យទឹកនិងស្មៅមួយក្តី មិនមានគេរាប់អាន ដោយឲ្យស្មៅ និងទឹក ២ ដងក្តី ៣ ដងក្តី ៤ ដងក្តី ៥ ដងក្តី ក៏មិនក្រាប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ត្រូវមុតដោយកម្ទាំងព្រួញ ១ ក្តី ឬត្រូវមុតដោយកម្ទាំងព្រួញ ២ ក្តី ៣ ក្តី ៤ ក្តី ៥ ក្តី ក៏មិនក្រាប មិនក្រាញ រមែងរុលទៅមុខ អាចហ៊ានចុះកាន់សង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច អត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាងនេះឯង ទើបគួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ស្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ទើបគួរទទួលនូវទាន ដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា នេះ

ជាអ្នកអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងផ្សព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអត់ធន់នឹងរូប តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែក មិនត្រេកអរ ក្នុងរូបដែលគួរត្រេកអរ អាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងរូប យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអត់ធន់នឹងសំឡេង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឮនូវសំឡេងដោយត្រចៀក មិនត្រេកអរ ក្នុងសំឡេងដែលគួរត្រេកអរ អាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងសំឡេង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអត់ធន់នឹងក្លិន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធុំក្លិនដោយច្រមុះ មិនត្រេកអរ ក្នុងក្លិនដែលគួរត្រេកអរ អាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងក្លិនយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអត់ធន់នឹងរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ លិទ្ធភ្លក្សរសដោយអណ្តាត មិនត្រេកអរ ក្នុងរសដែលគួរត្រេកអរ អាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុអត់ធន់នឹងរស យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកអត់ធន់នឹងផ្សព្វ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពាល់ត្រូវនូវផ្សព្វដោយកាយ មិនត្រេកអរក្នុងផ្សព្វដែលគួរត្រេកអរ អាចតម្កល់ចិត្តឲ្យនឹងបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុអត់ធន់នឹងផ្សព្វ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរទទួលនូវទាន ដែលគេនាំមកបូជា គួរទទួលនូវវត្ថុ ដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## អក្ខមសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្ខមសូត្រទី ៩ ដូចតទៅនេះ បទថា **ហត្ថិកាយំ** បានដល់ ទ័ពដំរី ក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។ ឈ្មោះថា **សង្គាមាវចរ** ព្រោះត្រាច់ទៅក្នុងសង្គ្រាម ។ បទថា **ឯកិស្សា វា តិណោទកទត្តិយា វិមានិតោ** សេចក្ដីថា មិនបានទទួលស្មៅ និងទឹកត្រឹមតែមួយពេលក្នុងមួយថ្ងៃ អធិប្បាយថា មិនបានស្មៅ និងទឹកត្រឹមតែមួយថ្ងៃ ។ ន័យបន្ទាប់ពីនេះទៅ ក៏ដូចគ្នា ។ បទថា **ន សក្កោតិ ចិត្តំ សមាទហិតុំ** សេចក្ដីថា មិនអាចតាំងចិត្តទុកដោយប្រពៃក្នុងអារម្មណ៍ ។ ពាក្យដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ តែក្នុងសូត្រនេះ គប្បីជ្រាបថា ទ្រង់ត្រាស់វដ្ដៈផង និងវិវដ្ដៈផង ៕

**អដ្ឋកថា អក្ខមសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## សោតវសូត្រទី ១០

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ យ៉ាង គួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ប្រកបដោយអង្គ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វប្រសប់ខាងការស្តាប់ ពាក្យ ១ សម្លាប់ ( សត្រូវ ) ១ រក្សាខ្លួន ១ អត់ធន់ ១ ទៅកាន់ទិស ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វ ( ប្រសប់ ) ខាងការស្តាប់ពាក្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលបើសារថី អ្នកបង្ហាត់ដំរី ប្រើឲ្យធ្វើការណ៍ណា ទោះបីខ្លួនធ្លាប់ធ្វើក្តី មិនធ្លាប់ធ្វើក្តី ក៏ខំផ្ចិតផ្ចង់យកចិត្តទុកដាក់ និងការណ៍នោះ ប្រមូលការណ៍ទាំងអស់ដោយចិត្ត ហើយផ្ទៀងត្រចៀកស្តាប់ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វ ( ប្រសប់ ) ខាងការស្តាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វសម្លាប់ ( សត្រូវ ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម រមែងសម្លាប់ដំរីខ្លះ សម្លាប់ទម័កដំរីខ្លះ សម្លាប់សេះខ្លះ សម្លាប់អ្នកជិះសេះខ្លះ បៀតបៀនរថខ្លះ សម្លាប់អ្នកបររថខ្លះ សម្លាប់ពលថ្មើរជើងខ្លះ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វសម្លាប់ ( សត្រូវ ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វចេះរក្សាខ្លួន

តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម រមែងរក្សាកាយខាងមុខ រក្សាកាយខាងក្រោយ រក្សាជើងខាងមុខ រក្សាជើងខាងក្រោយ រក្សាក្បាល រក្សាត្រចៀក រក្សាភ្លុក រក្សាប្រមោយ រក្សារោមកន្ទុយ រក្សាទម៉ក ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វចេះរក្សា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើរ របស់ស្តេច ជាសត្វអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើរ របស់ស្តេច ក្នុងលោកនេះ ទៅកាន់សង្គ្រាម ជាសត្វអត់ធន់នឹងការប្រហារ ដោយលំពែង ប្រហារដោយព្រួញ ប្រហារដោយប៉ូរថៅ នឹងសូរគឹកកងរំពង ស្គរតូច ស្គរធំ ស័ង្ខ ស្គរសឹកសង្គ្រាម ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើរ របស់ស្តេច ជាសត្វអត់ធន់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះដំរីដ៏ប្រសើររបស់ស្តេច ជាសត្វទៅកាន់ទិស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ កាលបើសារថីអ្នកបង្ហាត់ដំរី ប្រើឲ្យទៅកាន់ទិសណា ទោះបីខ្លួនធ្លាប់ទៅក្តី មិនធ្លាប់ទៅក្តី ទៅកាន់ទិសនោះ ដោយឆាប់រហ័សបាន ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ជាសត្វ ទៅកាន់ ( ទិស ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ដំរីដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៥ នេះឯង ទើបជាសត្វគួរជារាជយាន សមជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ក៏ដូច្នោះដែរ ទើបគួរទទួលនូវទាន ដែលគេនាំមកបូជា គួរ

ទទួលនូវវត្ថុ ដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រសប់ខាងការស្តាប់ ១ សម្លាប់ ( អកុសលវិតក្ក ) ១ រក្សាឥន្ទ្រិយ ១ អត់ធន់ ១ ទៅកាន់ ( ទិសគឺព្រះនិព្វាន ) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រសប់ខាងការស្តាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទំផ្ចិតផ្ចង់យក ចិត្តទុកដាក់ក្នុងធម៌វិន័យ ដែលតថាគតប្រកាសហើយ សំដែងទុក ប្រមូលនូវធម៌ទាំងពួងដោយចិត្ត ហើយផ្ទៀងត្រចៀកស្តាប់ធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រសប់ខាងការស្តាប់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកសម្លាប់ ( អកុសលវិតក្ក ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទទួលទុក លះបង់ បន្ទោបង់ សម្លាប់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើត តទៅទៀតនូវកាមវិតក្កដែលកើតហើយ នូវព្យាបាទវិតក្កដែលកើតហើយ... នូវវិហឹសាវិតក្កដែលកើតហើយ... មិនទទួលទុក លះបង់ បន្ទោបង់ សម្លាប់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀត នូវធម៌ជាបាបអកុសល ដែលកើតហើយរឿយៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសម្លាប់ ( អកុសលវិតក្ក ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នករក្សា ( ឥន្ទ្រិយ ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ហើយមិនក្តួចកាន់នូវនិមិត្ត មិនក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស

ជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ... លិទ្ធរសដោយអណ្តាត ... ពាល់ត្រូវនូវផ្សព្វដោយកាយ ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយមិនកួចកាន់នូវនិមិត្ត មិនកួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលដ៏លាមក គប្បីជាប់តាមបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួម មនិន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួម នូវមនិន្ទ្រិយនោះ រក្សាមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នករក្សាឥន្ទ្រិយ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នកអត់ធន់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់ នឹងត្រជាក់ក្តៅ សេចក្តីឃ្លាន ស្រេក សម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ សត្វទីឃជាតិនិងពាក្យពោលអាក្រក់ គួរឲ្យកើតទុក្ខ ជាអ្នកប្រកបដោយជាតិ ចេះអត់សង្កត់នូវវេទនាដែលប្រជុំក្នុងសរីរៈ ជាទុក្ខ ដ៏ក្លាខ្លាំង ខ្លោចផ្សា មិនស្រួល មិនជាទីគាប់ចិត្ត ជាវេទនាគួរនាំយកនូវជីវិតដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកអត់ធន់ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុអ្នក ( ទៅកាន់ទិស ) តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទិសពោលគឺការរម្ងាប់សង្ខារទាំងអស់ ការលះបោលនូវឧបធិទាំងពួង ការអស់តណ្ហា ការប្រាសចាកតម្រេក ការរលត់ ការមិនមានតណ្ហា

ជាគ្រឿងចាក់ស្រែះ ឯណា ដែលបុគ្គលមិនធ្លាប់ទៅដោយកាលយូរអង្វែងនេះ ភិក្ខុក្នុងសាសនានេះ ជាអ្នកទៅកាន់ទិសនោះបានដោយឆាប់ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកទៅ ( កាន់ទិស ) យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប ដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរទទួលនូវទានដែលគេនាំមកបូជា គួរទទួល នូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរគេធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

**រាជវគ្គទី ៤ ចប់**

## ឧទ្ទាននៃរាជវគ្គនោះ គឺ

និយាយអំពីស្តេចចក្រពត្តិ ញុំាងអាណាចក្រ ឲ្យប្រព្រឹត្តទៅ ១ អំពីព្រះរាជបុត្រប្រព្រឹត្តទៅតាមអាណាចក្រ ១ អំពីស្តេចចក្រពត្តិជាធម្មរាជ ១ អំពីស្តេចចក្រពត្តិគង់នៅក្នុងទិស ១ អំពីសេចក្តីប្រាថ្នា ២ លើក អំពីបុគ្គលដេកលក់តិច ១ អំពីដំរីស៊ីនូវអាហារច្រើន ១ អំពីដំរី មិនអត់ធន់ ១ អំពីដំរីជាសត្វប្រសប់ ខាងការស្តាប់ ១ ។

# អដ្ឋកថា

## សោតវសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោតវសូត្រទី ១០ ដូចតទៅនេះ បទថា **ទុរុត្តានំ** សេចក្តីថា ចំពោះពាក្យគ្រោតគ្រាតដែលគេពោលមិនល្អ និងឲ្យប្រព្រឹត្តទៅដោយអំណាចទោសៈ ។ បទថា **ទុរាគតានំ** សេចក្តីថា ដែលមកក្នុងសោតទ្វារ ដោយអាការដែលឲ្យកើតទុក្ខ ។ បទថា **វចនបថានំ** បានដល់ ចំពោះពាក្យពោលទាំងឡាយ ។ បទថា **ទុក្ខានំ** បានដល់ ដែលអត់ធន់បានលំបាក ។ បទថា **តិព្វានំ** បានដល់ ក្លៀវក្លា ឬមានសភាពមិនក្តៅក្រហាយ ។ បទថា **ខរានំ** បានដល់ គ្រោតគ្រាត ។ បទថា **កដុកានំ** បានដល់ រឹង ។ បទថា **អសាតានំ** បានដល់ មិនពីរោះ ។ បទថា **អមនាបានំ** បានដល់ មិនអាចធ្វើចិត្តឲ្យឆ្អែតស្កប់ស្កល់ គឺជាទីត្រេកអរបាន។ បទថា **បាណហរានំ** បានដល់ ប្រានជីវិតចេញបាន ។ ព្រះនិព្វាន គប្បី ជ្រាបថាឈ្មោះថា **ធិស** ក្នុងពាក្យថា **យា សា ធិសា** ព្រោះប្រាកដឃើញច្បាស់ក្នុងធម៌ មានធម៌ដែលជាទីរម្ងាប់សង្ខារទាំងពួងជាដើម តែព្រោះសង្ខារទាំងពួងអាស្រ័យព្រះនិព្វាននោះ ទើបដល់នូវការរម្ងាប់ ដូច្នោះ ទើបត្រាស់ហៅព្រះនិព្វាននោះថា ធម៌ជាទីរម្ងាប់សង្ខារទាំងពួង ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើងាយយល់ទាំងអស់ហើយ ។ ក្នុងសូត្រនេះត្រាស់សីល សមាធិ បញ្ញារួមគ្នា ដូច្នេះ ។ល។

**អដ្ឋកថាសោតវសូត្រទី ១០ ចប់**

**ភាជវគ្គទី ៤ ចប់**

# សុត្តន្តបិដក
# តិកណ្ណកីវគ្គទី ៥

## ទត្វាអវជានាតិសូត្រទី ១

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ ១ មើលងាយព្រោះការនៅរួមគ្នា ១ មានការកាន់យកតាមពាក្យគេជាប្រមាណ ១ ជាអ្នកឡេះឡោះ ១ ជាអ្នកល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកមានជំងឺ ដល់បុគ្គល ( ដទៃ ) ។ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញរមែងឲ្យ បុគ្គលនោះរមែងទទួល ។ លុះឲ្យរួចហើយត្រឡប់មើលងាយអ្នកទទួលនោះវិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យហើយត្រឡប់មើលងាយគេវិញ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមើលងាយ ព្រោះការនៅរួមគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ នៅរួមជាមួយនឹងបុគ្គលអស់ ២ ឬ ៣ ឆ្នាំ ។ មើលងាយបុគ្គលនោះព្រោះការនៅរួមគ្នា ម្នាលភិក្ខុទាំងឡាយ បុគ្គលមើលងាយ ព្រោះការនៅរួមគ្នា យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានការកាន់ យកតាមពាក្យគេជាប្រមាណ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោក

នេះ កាលគេពោលសរសើរ ឬតិះដៀលដល់បុគ្គលដទៃ រមែងជឿស៊ប់នូវពាក្យនោះមួយរំពេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានការកាន់យកតាមពាក្យគេជាប្រមាណ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឡេះឡោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសទ្ធាតិច មានការសេពគប់តិច មានសេចក្តីស្រឡាញ់តិច មានសេចក្តីជ្រះថ្លាតិច ម្នាលភិក្ខុទាំងឡាយ បុគ្គលឡេះឡោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលល្ងង់ខ្លៅ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងនូវធម៌ជាកុសល និងធម៌ជាអកុសល មិនដឹងនូវធម៌ប្រកបដោយទោស និងធម៌មិនប្រកបដោយទោស មិនដឹងនូវធម៌ថោកទាប និងធម៌ដ៏ឧត្តម មិនដឹងនូវធម៌មានចំណែកប្រៀបដោយខ្មៅនិងស ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលល្ងង់ខ្លៅ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

# អដ្ឋកថា
# តិកណ្ណកិវគ្គទី ៥

## ឧត្វាអវជានាតិសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧត្វាអវជានាតិសូត្រទី ១ នៃតិកណ្ណកិវគ្គ ទី ៥ ដូចតទៅនេះ បទថា **សំវាសេន** បានដល់ ព្រោះការនៅរួមគ្នា ។ បទ ថា **អាធេយ្យមុខោ** ( ឲ្យហើយត្រឡប់មើលងាយគេវិញ ) បានដល់ តាំង មុខជឿ អធិប្បាយថា តាំងមុខកាន់យក ។ បទថា **តមេនំ ឧត្វា អវជានាតិ** សេចក្ដីថា រមែងត្រូវមើលងាយយ៉ាងនេះថា បុគ្គលនេះស្គាល់តែការទទួលនូវ របស់ដែលអញឲ្យប៉ុណ្ណោះ ។ បទថា **តមេនំ សំវាសេន អវជានាតិ** សេចក្ដី ថា ជាអ្នកក្រោធក្នុងបុគ្គលណា ក៏ក្រោធត្រឹមតែតិចតួច ហើយរមែងពោល ពាក្យជាដើមថា ខ្ញុំដឹងកម្មដែលអ្នកធ្វើទុក ខ្ញុំធ្វើកម្មអ្វី អស់កាលយូរមាន ប្រមាណប៉ុណ្ណោះ ខ្ញុំពិចារណាមើលកម្មដែលលោកបានធ្វើ និងមិនបានធ្វើ មិន មែនឬ ពេលនោះ បុគ្គលក្រៅពីនេះគិតថា ទោសណាមួយរបស់អាត្មាអញ នឹងមានពិតប្រាកដ ទើបមិនអាចឆ្លើយឆ្លងពាក្យណាមួយបាន ។ បទថា **តំ ខិប្បញ្ញេវ អធិមុច្ចិតោ ហោតិ** សេចក្ដីថា បុគ្គលរមែងជឿទាំងគុណ និង ទោសនោះៗ ឯង យ៉ាងណា ។ បុគ្គលនេះ លោកពោលថា ឈ្មោះថា **អាធិយឆមុខោ** ព្រោះអត្ថថា ជឿងាយ ។ តែក្នុងបាលីថា **អាធីយមុខោ** គឺតាំងមុខជឿ អធិប្បាយថា តាំងមុខតែនឹងទទួល នូវគុណផង ទោសផង

ដោយការជឿងាយ ដូចអណ្តូងដែលគេជីកត្រង់ផ្លូវ រង់ចាំតែទឹកដែលហូរមក ។

បទថា **ឥត្តរសទ្ធោ** គឺមានសទ្ធាតិចតួច ។ ក្នុងបទថា **កុសលាកុ-សលេ ធម្មេ ន ជានាតិ** ជាដើម សេចក្តីថា មិនស្គាល់ធម៌ជាកុសល ថាធម៌ទាំងនេះជាកុសល មិនស្គាល់ធម៌ដែលជាអកុសល ថាធម៌ទាំងនេះជាអកុសល ម្យ៉ាងទៀត មិនដឹងធម៌មានទោស គឺធម៌ដែលប្រព្រឹត្តទៅជាមួយទោស ថាធម៌ទាំងនេះមានទោស មិនដឹងធម៌មិនមានទោស គឺធម៌ដែលមិនប្រព្រឹត្តទៅជាមួយទោស ថាធម៌ទាំងនេះមិនមានទោស មិនដឹងធម៌អាក្រក់ ថាអាក្រក់ មិនដឹងធម៌ប្រណីត ថាប្រណីត ។ បទថា **កណ្ហសុក្កសប្បដិភាគេ** បានដល់ បុគ្គលរមែងមិនដឹង ថាធម៌ចំណែកខ្មៅទាំងនេះ ឈ្មោះថា ប្រៀបធៀបគ្នា ព្រោះហាមគ្នា ធម៌ចំណែកសតាំងនៅ និងធម៌ចំណែកខ្មៅនេះ ឈ្មោះថា ប្រៀបធៀបគ្នា ព្រោះហាមគ្នា ធម៌ចំណែកខ្មៅតាំងនៅ ដូច្នេះ ។

**អដ្ឋកថា ឧត្តាអរជានាតិសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អារភសូត្រទី ២

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៥ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក

ខ្លះ ក្នុងលោកនេះ រមែងប្រារព្ធផង មានសេចក្ដីក្ដៅក្រហាយផង ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងប្រារព្ធ តែមិនមានសេចក្ដីក្ដៅក្រហាយ ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ តែមានសេចក្ដីក្ដៅក្រហាយ ទាំងមិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ មិនមានសេចក្ដីក្ដៅក្រហាយ តែមិនដឹងច្បាស់តាមពិត នូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងមិនប្រារព្ធ មិនមានសេចក្ដីក្ដៅក្រហាយ ដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាបុគ្គលទាំង ៥ ពួកនោះ

បុគ្គលណារមែងប្រារព្ធផង មានសេចក្តីក្តៅក្រហាយផង មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ផង ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ រមែងចម្រើនឡើង ដល់លោកដ៏មានអាយុ ហេតុនោះ សូមលោកដ៏មានអាយុ លះបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ បន្ទោបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ ហើយចម្រើននូវចិត្តនិងបញ្ញា ដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នានឹងបុគ្គលទី ៥ឯណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណារមែងប្រារព្ធ តែមិនមានសេចក្តីក្តៅក្រហាយ មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើងហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ មិនចម្រើនឡើងដល់លោកដ៏មានអាយុទេ ហេតុនោះ សូមលោកដ៏មានអាយុ លះបង់នូវអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ ហើយចម្រើននូវចិត្តនិងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នា នឹងបុគ្គលទី ៥ ឯណោះ

បាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណារមែង មិនប្រារព្ធ តែមានសេចក្តីក្តៅក្រហាយ មិនដឹងច្បាស់តាមពិត នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមក ដែលកើតឡើង ហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បី ពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែងមិន មានអាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ តែងចម្រើនឡើង ដល់លោកដ៏មានអាយុ ហេតុនោះ សូមលោកដ៏មានអាយុ បន្ទោបង់នូវអាសវៈ ទាំងឡាយ ដែលកើតអំពីសេចក្តីក្តៅក្រហាយ ហើយចម្រើននូវចិត្តនិងបញ្ញា ដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នា នឹងបុគ្គលទី ៥ ឯ ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៥ ពួកនោះ បុគ្គលណា រមែងមិនប្រារព្ធ មិនមានសេចក្តីក្តៅក្រហាយ មិនដឹងច្បាស់តាមពិតនូវចេតោ-វិមុត្តិ និងបញ្ញាវិមុត្តិ ដែលជាធម៌ធ្វើនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើង ហើយ ឲ្យរលត់ទៅ ឥតមានសេសសល់ ។ បុគ្គលនោះ អ្នកទាំងឡាយ គប្បី ពោលយ៉ាងនេះថា អាសវៈទាំងឡាយ ដែលកើតអំពីសេចក្តីប្រារព្ធ រមែង មិនមាន អាសវៈទាំងឡាយដែលកើតអំពីសេចក្តីក្តៅក្រហាយ ក៏មិនចម្រើន ឡើងដល់លោកដ៏មានអាយុទេ ហេតុនោះ សូមលោកដ៏មានអាយុ ចម្រើននូវ ចិត្តនិងបញ្ញាដោយល្អចុះ ធ្វើយ៉ាងនេះ ទើបលោកដ៏មានអាយុស្មើគ្នានឹងបុគ្គល ទី ៥ ឯណោះបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៤ ពួកនេះ កាលបើ

អ្នកទាំងឡាយ ទូន្មានប្រៀនប្រដៅតាមបុគ្គលទី ៥ ឯណោះ យ៉ាងនេះ គង់បានដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ ដោយលំដាប់ដូច្នេះឯង ។

# អដ្ឋកថា

## អារភសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអារភសូត្រទី ២ ដូចតទៅនេះ បទថា **អារភតិ ច វិប្បដិសារី ច ហោតិ** សេចក្តីថា ភិក្ខុព្យាយាមកន្លងអាបត្តិ ហើយជាអ្នកក្តៅក្រហាយ ព្រោះការកន្លងអាបត្តិនោះជាហេតុ ។ បទថា **ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ** បានដល់ អរហត្តសមាធិ និងអរហត្តផលញាណ ។ បទថា **នប្បជានាតិ** បានដល់ មិនដឹង ព្រោះមិនទាន់សម្រេច ។ បទថា **អារភតិ ន វិប្បដិសារី ហោតិ** បានដល់ ត្រូវអាបត្តិ តែជាអ្នកមិនក្តៅក្រហាយ ព្រោះចេញចាកអាបត្តិហើយ ។ បទថា **ន អារភតិ វិប្បដិសារី ហោតិ** បានដល់ ត្រូវអាបត្តិម្តង ហើយចេញចាកអាបត្តិនោះ ខាងក្រោយមិនត្រូវទៀតក៏ពិត តែក៏បន្ទោបង់សេចក្តីក្តៅក្រហាយ មិនបាន ។ បទថា **ន អារភតិ ន វិប្បដិសារី ហោតិ** បានដល់ មិនត្រូវអាបត្តិផង មិនជាអ្នកក្តៅក្រហាយផង ។ បទថា **តញ្ច ចេតោវិមុត្តឹ ។បេ។ និរុជ្ឈន្តិ** បានដល់ មិនទាន់សម្រេចព្រះអរហត្ត ។ លោកពោលដល់ព្រះខីណាស្រពដោយ

ន័យទី ៥ ។

បទថា **អារភជា** បានដល់ បានកើត ព្រោះកន្លងអាបត្តិ ។ បទថា **វិប្បដិសារជា** បានដល់ កើតអំពីការក្តៅក្រហាយ ។ បទថា **បវឌ្ឍន្តិ** បានដល់ អាសវៈទាំងឡាយចម្រើន ព្រោះកើតរឿយៗ ។ បទថា **អារភជេ អាសវេ បဟាយ** បានដល់ លះអាសវៈទាំងឡាយ ដែលកើតព្រោះកន្លងអាបត្តិ ។ ដោយការសម្តែងអាបត្តិឬដោយការចេញចាកអាបត្តិ ។ បទថា **បដិវិនោទេត្វា** បានដល់ នាំចេញដោយការពិចារណា ដល់នូវភាពជាអ្នក តាំងនៅក្នុងសេចក្តីបរិសុទ្ធិ ។ បទថា **ចិត្តំ បញ្ញញ្ច ភាវេតុ** បានដល់ ចូរបំពេញវិបស្សនាចិត្ត និងបញ្ញាដែលសម្បយុត្តដោយវិបស្សនាចិត្តនោះ ។ បទដ៏សេស គប្បីជ្រាបដោយឧបាយនេះ ។៚

**អដ្ឋកថា អារភសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សារន្ទទសូត្រទី ៣

[ ៤៣ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវន ជិតក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ក្រុងវេសាលី ដើម្បី

បិណ្ឌបាត ។ សម័យនោះ ពួកលិច្ឆវីមានប្រមាណ ៥០០ នាក់ បានប្រជុំសន្និបាតគ្នាក្នុងសារន្ទទចេតិយ កើតមានអន្តរាកថានេះឡើងថា ការកើតប្រាកដនៃកែវទាំង ៥ ជារបស់រកបានដោយកម្រក្នុងលោក ។ កែវទាំង ៥ ដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃដំរីកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃសេះកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃកែវមណី រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃស្រីកែវ រកបានដោយកម្រក្នុងលោក ១ ការកើតប្រាកដនៃគហបតីកែវ រកបានដោយកម្រក្នុងលោក ១ ។ ការកើតប្រាកដនៃកែវទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ។ លំដាប់នោះ ពួកលិច្ឆវីទាំងនោះ បញ្ជូនបុរសម្នាក់ទៅក្នុងផ្លូវថា នែបុរស បើអ្នកឃើញព្រះដ៏មានព្រះភាគស្តេចមក ក្នុងកាលណា អ្នកគប្បីប្រាប់យើងទាំងឡាយក្នុងកាលនោះ ។ បុរសនោះ បានឃើញព្រះដ៏មានព្រះភាគ ស្តេចមកអំពីចម្ងាយលុះឃើញហើយ ក៏ចូលទៅរកពួកលិច្ឆវីទាំងនោះ លុះចូលទៅដល់ហើយ ទើបពោលទៅនឹងពួកលិច្ឆវីទាំងនោះថា ន៉ុះហ្ន៎ ព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ កំពុងតែស្តេចមក សូមអ្នកទាំងឡាយ សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ពួកលិច្ឆវីទាំងនោះ បាននាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយស្ថិតក្នុងទីសមគួរ ។ លុះពួកលិច្ឆវីទាំងនោះ ស្ថិតក្នុងទីសមគួរហើយបានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស សូម

ព្រះដ៏មានព្រះភាគ ស្តេចចូលទៅកាន់សារន្ទទចេតិយ ដើម្បីសេចក្តីអនុគ្រោះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានស្តេចចូលទៅកាន់សារន្ទទចេតិយ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទើបត្រាស់ទៅនឹងពួកលិច្ឆវីទាំងនោះដូច្នេះថា ម្នាលលិច្ឆវីទាំងឡាយ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នាដោយកថា ដូចម្តេចហ្ន៎ ក្នុងកាលឥឡូវនេះ ចុះអន្តរាកថាដូចម្តេច ដែលអ្នកទាំងឡាយ និយាយគ្នាមិនទាន់ស្រេច ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ អង្គុយប្រជុំសន្ទនាគ្នា ក្នុងទីនេះ កើតមានអន្តរាកថានេះឡើងថា ការកើតប្រាកដនៃកែវទាំង ៥ ប្រការ រកបានដោយកម្រក្នុងលោក ។ កែវ ៥ ប្រការដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃដីរីកែវ រកបានដោយកម្រក្នុងលោក នៃសេះកែវ ... នៃកែវមណី ... នៃស្រីកែវ ... ការកើតប្រាកដនៃគហបតីកែវ រកបានដោយកម្រក្នុងលោក ។ ការកើតប្រាកដនៃកែវទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ។ ម្នាលលិច្ឆវីទាំងឡាយ អន្តរាកថាប្រារព្ធកាម កើតឡើងដល់អ្នកទាំងឡាយ ដែលមានចិត្តជ្រប់ក្នុងកាមទៅហើយហ្ន៎ ។ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈ ៥ ប្រការ រកបានដោយកម្រក្នុងលោក ។ រតនៈ ៥ ដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ រកបានដោយកម្រក្នុងលោក ១ បុគ្គលអ្នកសម្តែងនូវធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសហើយ រកបានដោយ

កម្រក្នុងលោក ១ បុគ្គលអ្នកដឹងនូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ រកបានដោយកម្រក្នុងលោក ១ បុគ្គលអ្នកដឹងនូវធម្មវិន័យ ដែលព្រះតថាគត ប្រកាសហើយ សំដែងហើយៗ ប្រតិបត្តិធម៌តាមគួរដល់ធម៌ រកបានដោយ កម្រក្នុងលោក ១ បុគ្គលអ្នកដឹងឧបការគុណដែលបុគ្គលដទៃធ្វើហើយ ធ្វើតប វិញ រកបានដោយកម្រក្នុងលោក ១ ។ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដ នៃរតនៈទាំង ៥ នេះឯង រកបានដោយកម្រក្នុងលោក ។

# អដ្ឋកថា

## សារន្ទទសូត្រ

[ ៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសារន្ទទសូត្រទី ៣ ដូចតទៅនេះ បទថា **កាមាធិមុត្តានំ** បានដល់ បង្អោនទៅក្នុងវត្ថុកាម និងកិលេសកាម ។ បទថា **ធម្មានុធម្មប្បដិបន្នោ** សេចក្តីថា បុគ្គលដែលបដិបត្តិបដិបទាខាងដើម មួយ អន្លើដោយសីល ដើម្បីលោកុត្តរធម៌ ៩ ឈ្មោះថា អ្នកនាំបដិបទាឲ្យបរិបូណ៌ ជាបុគ្គលរកបានលំបាកក្នុងលោក ៕

**អដ្ឋកថា សារន្ទទសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## តិកណ្ឌកីសូត្រទី ៤

[ ៤៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងតិកណ្ឌកីវ័ន ( ព្រៃខ្នុរ ៣ ដើម ) ជិតក្រុងសាកេត ។ ក្នុងទីនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមតាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍គួរឃើញខ្ពើមផង តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង តាមកាលគួរ ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរវៀរលែងនូវអារម្មណ៍ទាំងពីរនោះ គឺអារម្មណ៍មិនគួរខ្ពើម និងអារម្មណ៍គួរខ្ពើមចេញហើយ មានស្មារតីដឹងខ្លួន តាំងនៅជាកណ្តាល តាមកាលគួរជាការប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសម្គាល់ថាគួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌

ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើម ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា ទោសៈកុំកើតឡើង ដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសម្គាល់ថា គួរខ្ពើមក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍ដែលគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថាគួរខ្ពើមអារម្មណ៍ដែលមិនគួរខ្ពើមផង ក្នុងអារម្មណ៍ដែលគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរឡើយ ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តឡើយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីសម្គាល់ថា មិនគួរខ្ពើមក្នុងអារម្មណ៍ដែលគួរខ្ពើមផង ក្នុងអារម្មណ៍ដែលមិនគួរខ្ពើមផង ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តឡើយ រាគៈកុំកើតឡើង ដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរ

ឡើយ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុគប្បីវៀរលែងនូវអារម្មណ៍ទាំង ២ នោះគឺ អារម្មណ៍មិនគួរខ្ពើម និងគួរខ្ពើមចេញហើយ មានស្មារតីដឹងខ្លួន តាំងនៅជាកណ្តាល ព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីវៀរលែងនូវអារម្មណ៍ទាំង ២ នោះ គឺអារម្មណ៍មិនគួរខ្ពើម និងគួរខ្ពើមចេញ មានស្មារតីដឹងខ្លួន តាំងនៅជាកណ្តាល ព្រោះអាស្រ័យអំណាចប្រយោជន៍នេះថា រាគៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីត្រេកអរបន្តិចបន្តួច ក្នុងអារម្មណ៍ទីមួយ ក្នុងប្រទេសណាមួយឡើយ ទោសៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីប្រទូស្តបន្តិចបន្តួច ក្នុងអារម្មណ៍ទីមួយ ក្នុងប្រទេសណាមួយឡើយ មោហៈកុំកើតឡើងដល់អាត្មាអញ ក្នុងធម៌ទាំងឡាយ ជាទីតាំងនៃសេចក្តីវង្វេងបន្តិចបន្តួច ក្នុងអារម្មណ៍ទីមួយ ក្នុងប្រទេសណាមួយឡើយ ។

# អដ្ឋកថា

## តិកណ្ឌកីសូត្រ

[ ៤៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតិកណ្ឌកីសូត្រទី ៤ ដូចតទៅនេះ បទថា **អប្បដិក្កូលេ** បានដល់ ក្នុងអារម្មណ៍ដែលមិនបដិកូល ។ បទថា **បដិក្កូលសញ្ញី** បានដល់ មានសេចក្តីសម្គាល់យ៉ាងនេះថា នេះបដិកូល ។ ក្នុងបទទាំងពួងក៏ន័យនេះដូចគ្នា ។ សួរថា ភិក្ខុនេះ នៅយ៉ាងនេះបានដូចម្តេច ។

ធ្វើយថា ភិក្ខុពង្រីកទៅក្នុងវត្ថុដែលគួរប្រាថ្នា ដោយភាពជារបស់មិនស្អាត ឬបង្អោនទាំចូលទៅ ដោយភាពជារបស់មិនទៀង ឈ្មោះថា មានការសម្គាល់ក្នុងវត្ថុ មិនបដិកូលថា ជាបដិកូលដោយអាការយ៉ាងនេះ ។ ភិក្ខុពង្រីកទៅក្នុងវត្ថុដែលមិនគួរប្រាថ្នាដោយមេត្តា ឬបង្អោនទាំចូលទៅថាជាធាតុ ឈ្មោះថា មានការសម្គាល់ក្នុងវត្ថុបដិកូលថាមិនជាបដិកូល ដោយអាការយ៉ាងនេះ ។ ក្នុងបទទាំង ២ នេះ លោកពោលដល់តតិយវារៈ និងចតុត្ថវារៈ ដោយន័យដើម និងន័យក្រោយ ។ លោកពោលន័យទី ៥ ដោយឆឡង្គុបេក្ខាៗ នេះ ដូចគ្នានឹងឧបេក្ខារបស់ព្រះខីណាស្រព តែមិនមែនឧបេក្ខារបស់ព្រះខីណាស្រពទេ ។ ក្នុងបទទាំងនោះ បទថា **ឧបេក្ខកោ វិហរេយ្យ** បានដល់ តាំងនៅក្នុងភាពជាកណ្តាល ។ បទថា **ក្វចិនិ** បានដល់ ក្នុងអារម្មណ៍ណាមួយ ។ បទថា **កត្ថចិ** បានដល់ ក្នុងទីកដីណាមួយ ។ បទថា **កិញ្ចិនា** គឺមានប្រមាណតិចតួចណាមួយ ។ ក្នុងសូត្រនេះ ត្រាស់វិបស្សនាតែម្យ៉ាង ក្នុងឋានៈ ៥ ដោយប្រការដូច្នេះ ។ ភិក្ខុមួយរូបដែលប្រារព្ធវិបស្សនា ក៏បំពេញវិបស្សនានោះបានសូម្បីសមណៈដែលជាពហុស្សូត មានញាណ មានបញ្ញាក្រៃលែងក៏បំពេញបានព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមី រមែងធ្វើបានទាំងអស់ព្រះខីណាស្រព មិនចាំបាច់ពោលឡើយ ៕

## អដ្ឋកថា តិកណ្ឌកីសូត្រទី ៨ ចប់

# សុត្តន្តបិដក

## និរយសូត្រទី ៩

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ដូចជាគេនាំយកទៅទម្លាក់ក្នុងនរក ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺបុគ្គលអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ ប្រកបដោយហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ដូចជាគេនាំទៅទម្លាក់ក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ដូចជាគេនាំទៅដាក់ក្នុងស្ថានសួគ៌ ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺបុគ្គលវៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង ដូចជាគេនាំទៅដាក់ក្នុងស្ថានសួគ៌ ។

# អដ្ឋកថា

## និរយសូត្រ

[ ៤៥ ] ក្នុងនិរយសូត្រទី ៥ មានអត្ថងាយយល់ហើយ ។ល។

អដ្ឋកថានិរយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## មិត្តសូត្រទី ៦

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរគប់រកយកជាមិត្រឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺភិក្ខុប្រើឲ្យធ្វើការងារ ១ បង្កអធិករណ៍ ១ ជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន ១ ត្រាច់ទៅក្នុងទីឆ្ងាយនិងទីមិនមានកំណត់រឿយៗ ១ មិនអង់អាចដើម្បីពន្យល់ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ មិនគួរគប់រកយកជាមិត្រឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរគប់រកយកជាមិត្របាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺភិក្ខុមិនប្រើឲ្យធ្វើការងារ ១ មិនបង្កអធិករណ៍ ១ មិនជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន ១ មិនត្រាច់ទៅក្នុងទីឆ្ងាយ និងទីមិនមានកំណត់រឿយៗ ១ ជាអ្នកអង់អាចដើម្បីពន្យល់ ឲ្យកាន់តាម ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាតាមកាលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរគប់រកយកជាមិត្របាន ។

# អដ្ឋកថា

## មិត្តសូត្រទី ៦

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមិត្តសូត្រទី ៦ ដូចតទៅនេះ បទថា **កម្មន្តំ ការេតិ** បានដល់ ប្រើឲ្យការងារ មានធ្វើស្រែជាដើម ។ បទថា **អធិករណំ អាទិយតិ** បានដល់ ញុំាំងអធិករណ៍ ៤ ។ បទថា **ទាមោក្ខេសុ ភិក្ខូសុ** បានដល់ ក្នុងភិក្ខុដែលជាទិសាបាមោក្ខ គឺប្រធាន ។ បទថា **បដិវិរុទ្ធោ ហោតិ** បានដល់ ជាអ្នកប្រណាំងប្រជែងគ្នា ព្រោះប្រកាន់ ថាជាសត្រូវ ។ បទថា **អវត្ថានចារិកំ** បានដល់ ត្រាច់ទៅមិនមានគោលដៅ ។៙

### អដ្ឋកថាមិត្តសូត្រទី ៦ ចប់

# សុត្តន្តបិដក

## អសប្បុរិសទានសូត្រទី ៧

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ អសប្បុរិសទាននេះ មាន ៥ យ៉ាង ។ អសប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយមិនគោរព ( ក្នុងទេយ្យធម៌ ) ១ ឲ្យទានដោយមិនធ្វើនូវសេចក្តីគោរព ( ក្នុងបដិគ្គាហក ) ១ មិនឲ្យដោយដៃខ្លួន ១ ឲ្យទានដូចជាបោះបោល ១ ឲ្យទានដោយឃើញថាមិនឲ្យផល ១ ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរិសទានមាន ៥ យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានទេះមាន ៥ យ៉ាង ។ សប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយគោរព ១ ឲ្យដោយធ្វើនូវសេចក្តីគោរព ១ ឲ្យទានដោយដៃខ្លួនឯង ១ ឲ្យទានមិនដូចជាបោះចោល ១ ឲ្យទានដោយឃើញថាឲ្យផល ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## អសប្បុរិសទានសូត្រ

[ ៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអសប្បុរិសទានសូត្រទី ៧ ដូចតទៅនេះ បទថា **អសក្កច្ចំ ទានំ ទេតិ** បានដល់ មិនគោរព គឺធ្វើចិត្តឲ្យស្អាត ហើយឲ្យ ។ បទថា **អចិត្តីកត្វា ទេតិ** បានដល់ ឲ្យដោយអាការមិនកោតក្រែង ដោយការមិនគោរព ។ បទថា **អបវិទ្ធំ ទេតិ** បានដល់ ឲ្យរូបតែពីដៃ ។ ម្យ៉ាងទៀត ឲ្យដូចជាបោះចោល ។ បទថា **អនាគមនទិដ្ឋិកោ ទេតិ** បានដល់ មិនធ្វើការឃើញផលកម្មមកយ៉ាងនេះថា ផលនៃកម្មដែលធ្វើនឹងមកដល់ដូច្នេះ ឲ្យកើតឡើងឡើយ ។

ក្នុងធម៌ចំណែកស គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **ចិត្តីកត្វា ទេតិ** បានដល់ ចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ និងក្នុងទក្ខិណេយ្យបុគ្គល ហើយឲ្យ ។ ក្នុងបទ ២ យ៉ាងនោះ បុគ្គលធ្វើទេយ្យធម៌ប្រណីត មាន

សេចក្តាញ់ ហើយឲ្យ ឈ្មោះថា ចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ បុគ្គលជ្រើសរើសបុគ្គល ហើយឲ្យ ឈ្មោះថា ចូលទៅតាំងនូវការកោតក្រែងក្នុងទក្ខិណេយ្យបុគ្គល ។ បទថា **សហត្ថា ទេតិ** សេចក្តីថា មិនប្រើដៃរបស់អ្នកដទៃដើម្បីឲ្យ គឺឲ្យដោយដៃរបស់ខ្លួនប៉ុណ្ណោះ ដោយគិតថា ឈ្មោះថាពេលដែលអាត្មាអញ អន្ទោលទៅក្នុងសង្សារ ដែលមិនមានខាងដើម និងទីបំផុតហើយ បានប្រើដៃ និងជើងនេះ មិនមានប្រមាណឡើយ អញនឹងធ្វើការរួចផុតអំពីវដ្ដៈ ការចេញអំពីភព ដូច្នេះ ។ បទថា **អាគមនទិដ្ឋិកោ** បានដល់ជឿកម្ម និងវិបាកថា ជាបច្ច័យនៃភពក្នុងអនាគត ហើយឲ្យ ដូច្នេះ ។

**អដ្ឋកថា អសប្បុរិសទានសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សប្បុរិសទានសូត្រទី ៨

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៥ យ៉ាង ។ សប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺឲ្យទានដោយសទ្ធា ១ ឲ្យទានដោយគោរព ១ ឲ្យទានតាមកាលគួរ ១ ឲ្យទានដោយចិត្តអនុគ្រោះ ១ ឲ្យទានដោយមិនបានបៀតបៀនខ្លួនឯងនិងអ្នកដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយសទ្ធា ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ

មានទ្រព្យច្រើន មានភោគៈច្រើនផង ជាបុគ្គលមានរូបល្អគួររមិលមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយគោរព ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ពួកជនណា ទោះកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះតែងស្តាប់ដោយល្អ ផ្ទៀងស្រោត្រ តាំងចិត្តដើម្បីដឹងផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានតាមកាលដ៏គួរ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភមានទ្រព្យច្រើន មានភោគៈច្រើនផង ប្រយោជន៍គឺភោគៈដ៏ពោរពេញរមែងមកតាមកាលដ៏គួរដល់បុគ្គលនោះផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយចិត្តអនុគ្រោះ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ ៥ ដ៏លើសលុបផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយមិនបានបៀតបៀនខ្លួនឯងនិងអ្នកដទៃ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង សេចក្តីអន្តរាយនៃភោគៈទាំងឡាយ មិនមានមកអំពីទីណាមួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## សប្បុរិសទានសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសប្បុរិសទានសូត្រទី ៨ ដូចតទៅនេះ បទថា **សទ្ធាយ** បានដល់ ជឿទាន និងផលនៃទាន ។ បទថា **កាលេន** បានដល់ តាមកាលដ៏សមគួរ ។ បទថា **អនុគ្គហិតចិត្តោ** បានដល់ មានចិត្តមិនស្តាយ គឺលះដាច់ទៅ ។ បទថា **អនុបហច្ច** បានដល់ មិនប៉ះខូច គឺមិនលុបនូវគុណទាំងឡាយ ។ បទថា **កាលាគតា ចស្ស អត្ថា បហុតា ហោន្តិ** សេចក្តីថា ប្រយោជន៍ទាំងឡាយ កាលនឹងមកដល់ មិនបានមក កាលចម្រើនវ័យហើយ រមែងមកក្នុងកាលដ៏សមគួរក្នុងបឋមវ័យនោះឯង ហើយច្រើនទៀតផង ។៚

**អដ្ឋកថា សប្បុរិសទានសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមសមយវិមុត្តសូត្រទី ៩

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺត្រេកអរក្នុងការងារ ១ ត្រេកអរក្នុងការពោលតិរច្ឆានកថា ១ ត្រេកអរក្នុងការដេកលក់ ១ ត្រេកអរក្នុងពួកគណៈ ១ មិនពិចារណាចិត្តតាមវិមុត្ត ១ ។

ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនត្រេកអរក្នុងការងារ ១ មិនត្រេកអរក្នុងការពោលតិរច្ឆានកថា ១ មិនត្រេកអរក្នុងការដេកលក់ ១ មិនត្រេកអរក្នុងពួកគណៈ ១ ពិចារណាចិត្តតាមវិមុត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។

# អដ្ឋកថា

## បឋមសមយវិមុត្តសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសមយវិមុត្តសូត្រទី ៩ ដូចតទៅនេះ បទថា **សមយវិមុត្តស្ស** សេចក្តីថា ភិក្ខុឈ្មោះថា មានចិត្តផុតហើយដោយលោកិយវិមុត្ត ពោល គឺផុតជួរសម័យ ព្រោះផុតចាកកិលេសទាំងឡាយដែលសង្កត់សង្កិនបាន ក្នុងខណៈដែលញ៉ាំងចិត្តជាអប្បនានោះឯង ។

**អដ្ឋកថា បឋមសមយវិមុត្តសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយសមយវិមុត្តសូត្រទី ១០

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺត្រេកអរក្នុងការងារ ១ ត្រេកអរក្នុងការពោលតិរច្ឆានកថា ១ ត្រេកអរក្នុងការដេកលក់ ១ មិនបានគ្រប់គ្រងរក្សាទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីមិនសាបសូន្យ ដល់ភិក្ខុជាសមយវិមុត្ត ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនត្រេកអរក្នុងការងារ ១ មិនត្រេកអរក្នុងការពោលតិរច្ឆានកថា ១ មិនត្រេកអរក្នុងការដេកលក់ ១ គ្រប់គ្រងរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសមយវិមុត្ត ។

**តិកណ្ឌកីវគ្គទី ៥ ចប់**

### ឧទ្ទាននៃតិកណ្ឌកីវគ្គនោះ គឺ

និយាយអំពីបុគ្គលឲ្យហើយ ត្រឡប់មើលងាយវិញ ១
អំពីភិក្ខុប្រារព្ធ ១ អំពីពួកលិច្ឆវីប្រជុំគ្នា ក្នុងសារន្ទទ-
ចេតិយ ១ អំពីព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុង
តិកណ្ឌកីវន ១ អំពីធម៌ដែលនាំឲ្យធ្លាក់ទៅក្នុងនរក

និងនាំឲ្យទៅកើតស្ថានសួគ៌ ១ អំពីមិត្តគួរគប់រក និង
មិនគួរគប់រក ១ អំពីអសប្បុរិសទាន ១ អំពីសប្បុ-
រិសទាន ១ អំពីភិក្ខុជាសមយវិមុត្ត ២ លើក ។

បណ្ណាសកទី ៣ ចប់

# អដ្ឋកថា

## ទុតិយសមយវិមុត្តសូត្រ

[ ៥០ ] ទុតិយសមយវិមុត្តសូត្រទី ១០ មានអត្ថងាយយល់ហើយ។

**អដ្ឋកថា ទុតិយសមយវិមុត្តសូត្រទី ១០ ចប់**
**តិកណ្ឌកីវគ្គទី ៥ ចប់**
**តតិយបណ្ណាសក ចប់**

# សុត្តន្តបិដក

# ចតុត្ថបណ្ណាសក

## សទ្ធម្មវគ្គទី ១

### បឋមសទ្ធម្មនិយាមសូត្រទី ១

[ ៥១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង ស្ដាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាមគឺមគ្គ ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ គឺមើលងាយពាក្យពោល ១ មើលងាយបុគ្គលអ្នកពោល ១ មើលងាយខ្លួនឯង ១ មានចិត្តរវើរវាយស្ដាប់ធម៌ ១ មានចិត្តមិននឹងនួននៅក្នុងអារម្មណ៍តែមួយ គឺមិនយកចិត្តទុកដាក់ ដោយឧបាយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះ ស្ដាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្ដាប់ព្រះសទ្ធម្ម គួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនមើលងាយពាក្យពោល ១ មិនមើលងាយបុគ្គលអ្នកពោល ១ មិនមើលងាយខ្លួនឯង ១ មានចិត្តមិនរវើរវាយស្តាប់ធម៌ ១ មានចិត្តនឹងនួននៅក្នុងអារម្មណ៍តែមួយ គឺយកចិត្តទុកដាក់ដោយឧបាយប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់ទីនិយាមជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

# អដ្ឋកថា
# ចតុត្ថបណ្ណាសក

## សទ្ធម្មវគ្គទី ១
### បឋមសទ្ធម្មនិយាមសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសទ្ធម្មនិយាមសូត្រទី ១ នៃចតុត្ថ-បណ្ណាសកដូចតទៅនេះ បទថា **អភព្វោ និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** សេចក្តីថា ភិក្ខុមិនគួរឈានចុះកាន់មគ្គនិយាម ដែលពាល់ត្រូវក្នុងកុសលធម៌ទាំងឡាយ ។ ក្នុងបទថា **កថំ បរិភោតិ** ជាដើម កាលពោលថា រឿងនេះ ឈ្មោះរឿងអ្វី ដូច្នេះ ឈ្មោះថា មើលងាយរឿងដែលសម្តែង ។ កាលពោលថា បុគ្គលនោះនិយាយរឿងអ្វី បុគ្គលនេះដឹងអ្វី ដូច្នេះ ឈ្មោះថា មើលងាយអ្នកសម្តែង ។ កាលពោលថា អញនឹងដឹងកម្លាំងដែលគប្បីស្តាប់រឿងនេះនៃអញបានអំពីណា ដូច្នេះ ឈ្មោះថា មើលងាយខ្លួនឯង ។ គប្បីជ្រាបធម៌ចំណែកស ដោយន័យដែលផ្ទុយគ្នាអំពីនេះ ។

**អដ្ឋកថា បឋមសទ្ធម្មនិយាមសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយសទ្ធម្មនិយាមសូត្រទី ២

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងសូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមើលងាយពាក្យពោល ១ មើលងាយបុគ្គលអ្នកពោល ១ មើលងាយខ្លួនឯង ១ អប្បឥតប្រាជ្ញាល្ងង់ខ្លៅលលា ១ សម្គាល់ថា បានដឹងក្នុងហេតុដែលខ្លួនមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺមិនមើលងាយពាក្យពោល ១ មិនមើលងាយបុគ្គលអ្នកពោល ១ មិនមើលងាយខ្លួនឯង ១ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនលលា ១ មិនសម្គាល់ថា បានដឹងក្នុងហេតុ ដែលខ្លួនមិនបានដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

# អដ្ឋកថា

## ទុតិយសទ្ធម្មនិយាមសូត្រ

[ ៥២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសទ្ធម្មនិយាមសូត្រទី ២ ដូច្នេះ បទថា **អនញ្ញាតេ អញ្ញាតមានី** បានដល់ ជាបុគ្គលតម្កល់ខ្លួនថា អញដឹងហើយក្នុងសេចក្តីដែលមិនទាន់ដឹង ។

**អដ្ឋកថា ទុតិយសទ្ធម្មនិយាមសូត្រទី ២ ចប់**

# សុត្តន្តបិដក

## តតិយសទ្ធម្មនិយាមសូត្រទី ៣

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងសូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកលុបគុណគេ មានសេចក្តីលុបគុណ គ្របសង្កត់ ហើយស្តាប់ធម៌ ១ មានចិត្តប្រុងសង្កត់សង្កិនស្វែងរកទោស ហើយស្តាប់ធម៌ ១ ជាអ្នកមានចិត្តតក់ម៉ក់របើងរើងរូស ក្នុងបុគ្គលអ្នកសម្តែងធម៌ ១ ជាអ្នកអប្បឥតបញ្ញាល្ងង់ខ្លៅលលា ១ ជាអ្នកសម្គាល់ថា បានដឹងក្នុងហេតុដែលខ្លួនមិនបានដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង សូម្បីស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ

បាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺជាអ្នកមិនលុបគុណគេ មិនមានសេចក្តីលុបគុណ គ្របសង្កត់ ហើយស្តាប់ធម៌ ១ មានចិត្តមិនប្រុងសង្កត់សង្កិន មិនស្វែងរកទោស ហើយស្តាប់ធម៌ ១ ជាអ្នកមានចិត្តមិនតក់ម៉ក់ មិនរបើងរើងរូស ក្នុងបុគ្គលអ្នកសម្តែងធម៌ ១ ជាអ្នកមានបញ្ញា មិនល្ងង់ខ្លៅ មិនលលា ១ មិនសម្គាល់ថា បានដឹងក្នុងហេតុដែលខ្លួនមិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៥ យ៉ាងនេះឯង កាលស្តាប់ព្រះសទ្ធម្ម ទើបគួរដើម្បីឈានចុះកាន់និយាម ជាសភាពដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយបាន ។

# អដ្ឋកថា

## តតិយសទ្ធម្មនិយាមសូត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយសទ្ធម្មនិយាមសូត្រទី ៣ ដូចតទៅនេះថា

[ ៥៣ ] បទថា **មក្ខី ធម្មំ សុណាតិ** បានដល់ ជាអ្នកលុបគុណស្តាប់ធម៌ ដោយចិត្តលុបគុណអ្នកសម្តែង ។ បទថា **សឧបារម្ភចិត្តោ** គឺមានចិត្តលើកឡើងដើម្បីផ្ចាញ់ផ្ចាល ។ បទថា **រន្ធគវេសី** គឺរកឱកាសចាប់កំហុស ។

**អដ្ឋកថា តតិយសទ្ធម្មនិយាមសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## បឋមសទ្ធម្មសម្មោសសូត្រទី ៨

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ មិនស្ដាប់ធម៌ដោយគោរព ១ មិនរៀនធម៌ដោយគោរព ១ មិនទ្រទ្រង់ ( ចាំទុក ) ធម៌ដោយគោរព ១ មិនពិចារណាអត្ថនៃធម៌ ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ហើយ មិនប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ ស្ដាប់ធម៌ដោយគោរព ១ រៀនធម៌ដោយគោរព ១ ទ្រទ្រង់ធម៌ដោយគោរព ១ ពិចារណាអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ហើយដោយគោរព ១ ដឹងអត្ថ ដឹងធម៌ ហើយប្រតិបត្តិធម៌តាមសមគួរដល់ធម៌ដោយគោរព ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

# អដ្ឋកថា

## បឋមសទ្ធម្មសម្មោសសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសទ្ធម្មសម្មោសសូត្រទី ៤ ដូច្នេះ បទថា **ន សក្កច្ចំ ធម្មំ សុណន្តិ** បានដល់ មិនផ្ទៀងត្រចៀក តាំងចិត្តស្តាប់ធម៌ ។ បទថា **ន បរិយាបុណន្តិ** បានដល់ កាលបដិបត្តិធម៌តាមធម៌ដែលស្តាប់មក ក៏មិនបដិបត្តិដោយគោរព ។ល។

**អដ្ឋកថា បឋមសទ្ធម្មសម្មោសសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ទុតិយសទ្ធម្មសម្មោសសូត្រទី ៥

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ មិនរៀនធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនសម្តែងធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយ

ពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ មិនបង្ហាញធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមកដល់បុគ្គលដទៃដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយមិនធ្វើនូវការស្វាធ្យាយ ( ទន្ទេញ ) ធម៌តាមដែលបានស្តាប់មកតាមដែលបានរៀនមក ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុទាំងឡាយមិនត្រិះរិះរឿយៗ មិនពិចារណារឿយៗ ដោយចិត្ត មិនជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនធម៌គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្ម វេទល្លៈ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិន

អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ សំដែងធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ បង្ហាញធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដល់បុគ្គលដទៃ ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ធ្វើសេចក្តីស្វាធ្យាយធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ដោយពិស្តារ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ជញ្ជឹងរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

# អដ្ឋកថា

## ទុតិយសទ្ធម្មសម្មោសសូត្រ

[ ៥៥ ] ក្នុងទុតិយសទ្ធម្មសម្មោសសូត្រទី ៥ ងាយយល់ហើយ ។

អដ្ឋកថាទុតិយសទ្ធម្មសម្មោសសូត្រទី ៥ ចប់

# សុត្តន្តបិដក

## តតិយសទ្ធម្មសម្មោសសូត្រទី ៦

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្ម សាបសូន្យ អន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀននូវព្រះសូត្រ ដែលខ្ជូនរៀនខុស ដោយបទនិងព្យញ្ជនៈ ដែលរៀបរៀងខុស ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងខុស រមែងយល់សេចក្តីបានដោយកម្រ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅបានដោយក្រ ប្រកបដោយធម៌ ដែលធ្វើឲ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគម គឺ

និកាយដ៏ស្ទាត់ ចងចាំនូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ មិនឲ្យភិក្ខុដទៃរៀនព្រះសូត្រ ដោយគោរព លុះអំណើះតពីភិក្ខុទាំងនោះទៅ ព្រះសូត្រក៏ដាច់ឫស មិនប្រតិស្ឋានទៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាថេរៈ ជាអ្នកប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈ ក្នុងវិវេក មិនប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេសដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំជនជាខាងក្រោយទាំងនោះ ក៏ជាអ្នកប្រតិបត្តិ ដើម្បីឲ្យកើតលាភច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈ ក្នុងវិវេក មិនប្រារព្ធនូវព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សង្ឃបែកគ្នា ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃបែកគ្នាហើយ ការជេរគ្នានិងគ្នាក៏មាន ការប្រទេចផ្តាសាគ្នានិងគ្នាក៏មាន ការបោះពាក្យសម្តីទៅរកគ្នានិងគ្នាក៏មាន ការលះបង់គ្នានិងគ្នាក៏មាន

ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃទាំងនោះ ក៏មិនមានសេចក្ដីជ្រះថ្លា ដែលជ្រះថ្លាស្រាប់ហើយ ក៏ងាកចិត្តលែងជ្រះថ្លាវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យ អន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មសាបសូន្យអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀននូវព្រះសូត្រដែលខ្លួនរៀនត្រូវ ដោយបទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយបទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ រមែងយល់សេចក្ដីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បី ឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាអ្នកប្រដៅងាយ ប្រកបដោយធម៌ ធ្វើឲ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលពាក្យប្រៀនប្រដៅខាងស្ដាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណា មានសេចក្ដីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំ នូវព្រះសូត្រ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ ឲ្យភិក្ខុដទៃរៀន ព្រះសូត្រ ដោយគោរព លុះអំណើះតពីភិក្ខុទាំងនោះទៅ ព្រះសូត្រក៏មិនបានដាច់ឫស ប្រតិស្ឋាននៅបាន ។

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយជាថេរៈ មិនប្រតិបត្តិ ដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងការប្រតិបត្តិ បន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណ វិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួន មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ប្រជុំជនដែលកើតជាខាងក្រោយ គឺសទ្ធិវិហារិក អន្តេវាសិក ក៏យកតម្រាប់តាមពួកភិក្ខុជាថេរៈទាំងនោះ បច្ឆិមជននោះឯង ក៏មិនជាអ្នក ប្រតិបត្តិដើម្បីឲ្យកើតលាភច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចនូវគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវគុណវិសេសដែលខ្លួន មិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ប្រព្រឹត្តទៅដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សង្ឃព្រមព្រៀងគ្នា មានសេចក្តីរីករាយរកគ្នា មិនទាស់ទែងគ្នា មានឧទ្ទេសជាមួយគ្នា រមែងនៅជាសុខ ម្នាលភិក្ខុទាំងឡាយ កាលបើសង្ឃព្រមព្រៀងគ្នាហើយ ការជេរគ្នានិងគ្នា ក៏មិនមាន ការប្រទេចផ្តាសាគ្នានិងគ្នា ក៏មិនមាន ការបោះពាក្យសំដីទៅរកគ្នានិងគ្នា ក៏មិនមាន ការលះបង់គ្នានិងគ្នា ក៏មិនមាន ពួកជនដែលមិនទាន់ជ្រះថ្លា ក្នុងសង្ឃទាំងនោះ

ក៏រមែងជ្រះថ្លាឡើង ដែលជ្រះថ្លាស្រាប់ហើយ ក៏រឹងរឹតតែជ្រះថ្លាឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៥ ប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យព្រះសទ្ធម្មឋិតថេរ មិនសាបសូន្យ មិនអន្តរធានទៅ ។

# អដ្ឋកថា

## តតិយសទ្ធម្មសម្មោសសូត្រ

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយសទ្ធម្មសម្មោសសូត្រទី ៦ ដូច្នេះ បទថា **អប្បដិសរណោ** បានដល់ មិនមានទីពឹងអាស្រ័យ ពិតហើយ អាចារ្យទាំងឡាយ ឈ្មោះថា ជាទីពឹងពុំនាក់នៃព្រះសូត្រ ព្រោះមិនមានអាចារ្យទាំងនោះ ព្រះសូត្រក៏មិនមានទីពឹងអាស្រ័យ ។ ពាក្យដ៏សេស ក្នុងសូត្រនេះ មានន័យដូចពោលហើយខាងដើមនោះឯង ។៚

### អដ្ឋកថា តតិយសទ្ធម្មសម្មោសសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ទុកថាសូត្រទី ៧

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គល ៥ ពួកជាកថាអាក្រក់ ដោយការលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។ កថារបស់បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីសទ្ធារបស់បុគ្គលមិនមានសទ្ធា ជាកថាអាក្រក់ ១ ការពោលអំពីសីល របស់បុគ្គលទ្រុស្តសីល ជាកថាអាក្រក់ ១ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងតិច ជាកថាអាក្រក់ ១ ការពោលអំពីការលះរបស់បុគ្គលកំណាញ់ ជាកថាអាក្រក់ ១ ការពោលអំពីប្រាជ្ញារបស់បុគ្គលឥតប្រាជ្ញា ជាកថាអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសទ្ធារបស់បុគ្គលមិនមានសទ្ធា ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានសទ្ធា កាលបើពោលអំពីសទ្ធា រមែងរអាក់រអួល កម្រើកញាប់ញ័រ គ្នាន់ក្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមិនមានសទ្ធានោះ មិនឃើញច្បាស់នូវសទ្ធាសម្បទានោះក្នុងខ្លួន មិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះសទ្ធានោះជាហេតុផង ព្រោះហេតុនោះ ការពោលអំពីសទ្ធារបស់បុគ្គលដែលមិនមានសទ្ធា ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលទ្រុស្តសីល ពោលអំពីសីល ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្តសីល កាលបើពោលអំពីសីល រមែងរអាក់រអួល កម្រើកញាប់ញ័រ គ្នាន់ក្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យ

ប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលទ្រុស្ត សីលនោះ មិនឃើញច្បាស់នូវសីលសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវ បីតិនិងបាមោជ្ជៈ ព្រោះសីលនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសីល របស់បុគ្គលទ្រុស្តសីល ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោល អំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងតិច ជាកថាអាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកចេះដឹងតិច កាលពោលអំពីការចេះដឹងច្រើន រមែងរអាក់រអួល កម្រើកញាប់ញ័រ គ្នាន់គ្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តី មិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលអ្នកចេះដឹងតិចនោះ មិនឃើញច្បាស់ នូវសុតសម្បទានោះក្នុងខ្លួន ព្រម ទាំងមិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះការចេះដឹងតិចនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងតិច ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការលះ របស់បុគ្គលកំណាញ់ ជាកថា អាក្រក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកំណាញ់ កាលបើពោល អំពីការលះ រមែងរអាក់រអួល កម្រើកញាប់ញ័រ គ្នាន់គ្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលកំណាញ់នោះ មិនឃើញច្បាស់នូវចាគសម្បទានោះក្នុងខ្លួន ព្រម ទាំងមិនបាន នូវបីតិនិងបាមោជ្ជៈ ព្រោះមានការលះនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការលះរបស់បុគ្គលកំណាញ់ ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុ ទាំងឡាយ ចុះការពោលអំពីបញ្ញា របស់បុគ្គលឥតបញ្ញា ជាកថាអាក្រក់ តើ

ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអប្បឥតបញ្ញា កាលពោលអំពីបញ្ញា រមែងរអាក់រអួល កម្រើកញាប់ញ័រ គ្នាន់ក្នាញ់ ធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលអប្បឥតបញ្ញានោះ មិនឃើញច្បាស់នូវបញ្ញាសម្បទានោះក្នុងខ្លួន ព្រមទាំងមិនបាននូវបីតិនិងបាមោជ្ជៈ ព្រោះបញ្ញានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីបញ្ញា របស់បុគ្គលអប្បឥតបញ្ញា ទើបជាកថាអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គលទាំង ៥ ពួកនេះឯង ជាកថាអាក្រក់ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គល ៥ ពួក ជាកថាល្អ ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។ កថារបស់បុគ្គល ៥ ពួក ដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ជាកថាល្អ ១ ការពោលអំពីសីល របស់បុគ្គលមានសីល ជាកថាល្អ ១ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ជាកថាល្អ ១ ការពោលអំពីការលះ របស់បុគ្គលបរិច្ចាគ ជាកថាល្អ ១ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ជាកថាល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធា កាលបើពោលអំពីសទ្ធា រមែងមិនរអាក់រអួល មិនកម្រើកញាប់ញ័រ មិនគ្នាន់ក្នាញ់ មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមានសទ្ធានោះ ឃើញច្បាស់នូវសទ្ធាសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិ និងបាមោជ្ជ

ព្រោះសទ្ធានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសទ្ធា របស់បុគ្គលមានសទ្ធា ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីសីលរបស់បុគ្គលមានសីល ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសីល កាលបើពោលអំពីសីល រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនគ្នាន់ក្នាញ់ មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលមានសីលនោះ ឃើញច្បាស់នូវសីលសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិ និងបាមោជ្ជៈ ព្រោះសីលនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីសីល របស់បុគ្គលមានសីល ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកចេះដឹងច្រើន កាលបើពោលអំពីការចេះដឹងច្រើន រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនគ្នាន់ក្នាញ់ មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាបុគ្គលចេះដឹងច្រើននោះ ឃើញច្បាស់នូវសុតសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះការចេះដឹងច្រើននោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការចេះដឹងច្រើន របស់បុគ្គលចេះដឹងច្រើន ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ចុះការពោលអំពីការបរិច្ចាគទាន របស់បុគ្គលអ្នកបរិច្ចាគ ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកមានការលះ កាលបើពោលអំពីការលះ រមែងមិនអាក់អួល មិនកម្រើកញាប់ញ័រ មិនគ្នាន់ក្នាញ់

មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលអ្នកមានការលះ រមែងឃើញច្បាស់នូវចាគសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះការលះនោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីការលះ របស់បុគ្គលអ្នកលះទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ជាកថាល្អ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានបញ្ញា កាលបើពោលអំពីបញ្ញា រមែងមិនរអាក់រអួល មិនកម្រើកញាប់ញ័រ មិនគ្នាន់គ្នាញ់ មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីមិនត្រេកអរឲ្យប្រាកដ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមានបញ្ញានោះ ឃើញច្បាស់នូវបញ្ញាសម្បទានោះក្នុងខ្លួន ព្រមទាំងបាននូវបីតិនិងបាមោជ្ជៈ ព្រោះបញ្ញានោះជាហេតុ ព្រោះហេតុនោះ ការពោលអំពីបញ្ញា របស់បុគ្គលមានបញ្ញា ទើបជាកថាល្អ ។ ម្នាលភិក្ខុទាំងឡាយ កថារបស់បុគ្គលទាំង ៥ ពួកនេះឯង ជាកថាល្អ ដោយលើកយកបុគ្គលទៅប្រៀបនឹងបុគ្គល ។

# អដ្ឋកថា

## ទុកថាសូត្រ

[ ៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុកថាសូត្រទី ៧ ដូចតទៅនេះ បទថា **បុគ្គលំ ឧបនិធាយ** សេចក្តីថា អាងដល់បុគ្គលនោះ ហើយធ្វើឲ្យជាបន្ទាល់ ។

បទថា **កច្ឆមាឆាយ** ប្រែថា ពោល ។ ពាក្យដ៏សេស ក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ឧកកថាសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សារជ្ជសូត្រទី ៨

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងស្រុតចុះកាន់សេចក្ដីញាញើតញាញើម ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ ទ្រុស្ដសីល ១ មានសេចក្ដីចេះដឹងតិច ១ ខ្ជិលច្រអូស ១ អប្បឥតបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងស្រុតចុះកាន់សេចក្ដីញាញើតញាញើម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកក្លៀវក្លា ។ ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសីល ១ ចេះដឹងច្រើន ១ ប្រារព្ធព្យាយាម ១ មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងជាអ្នកក្លៀវក្លា ។

# អដ្ឋកថា

## សារជ្ជសូត្រ

[ ៥៨ ] ក្នុងសារជ្ជសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសារជ្ជសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ឧទាយិសូត្រទី ៩

[ ៥៩ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះ ព្រះឧទាយិដ៏មានអាយុមានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសំដែងធម៌ ។ ព្រះអានន្ទដ៏មានអាយុ បានឃើញព្រះឧទាយិដ៏មានអាយុ មានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសម្តែងធម៌ លុះឃើញហើយ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះឧទាយិដ៏មានអាយុ មានបរិសទ្យគ្រហស្ថជាច្រើនចោមរោម កំពុងអង្គុយសម្តែងធម៌ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ការសម្តែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ ម្នាល

អានន្ទ កាលភិក្ខុសម្ដែងធម៌ដល់ជនដទៃ គប្បីតម្កល់ធម៌ ៥ យ៉ាង ឲ្យមានក្នុងខ្លួនសិន ទើបគួរសម្ដែងធម៌ដល់ជនដទៃ ។ ធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ។ ភិក្ខុត្រូវសម្ដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសម្ដែងនូវអនុបុព្វីកថា ១ ភិក្ខុត្រូវសម្ដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសម្ដែង ដោយលើកអាងហេតុផល ១ ភិក្ខុត្រូវសម្ដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសម្ដែងពាក្យ ដោយអាស្រ័យសេចក្ដីអាណិត ( ដល់អ្នកស្ដាប់ ) ១ ភិក្ខុត្រូវសម្ដែងធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងមិនសម្ដែង ព្រោះហេតុនៃអាមិស ១ ភិក្ខុត្រូវសម្ដែង ធម៌ដល់បុគ្គលដទៃ ដោយតាំងចិត្តថា អាត្មាអញនឹងសម្ដែង ដោយមិនបានបៀតបៀនខ្លួនឯង និងបុគ្គលដទៃ ១ ។ ម្នាលអានន្ទ ការសម្ដែងធម៌ដល់ជនដទៃ មិនអាចធ្វើបានដោយងាយទេ ម្នាលអានន្ទ កាលភិក្ខុសម្ដែងធម៌ដល់ជនដទៃ ត្រូវតម្កល់ធម៌ ៥ យ៉ាងនេះ ឲ្យមានក្នុងខ្លួនសិន ទើបគួរសម្ដែងធម៌ដល់ជនដទៃ ។

# អដ្ឋកថា

## ឧទាយិសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទាយិសូត្រទី ៩ ដូចតទៅនេះ បទថា **អនុបុព្វិកថំ កថេស្សាមិ** សេចក្ដីថា លើកលំដាប់នៃទេសនា យ៉ាងនេះថា សីលក្នុងលំដាប់ទាន ស្ថានសួគ៌ក្នុងលំដាប់សីល ឬបទព្រះសូត្រ ឬបទគាថា

ណាមួយ ឬគប្បីតាំងចិត្តថា អាត្មាអញនឹងពោលកថា សមគួរដល់បទនោះៗ ហើយសម្តែងធម៌ដល់អ្នកដទៃ ។ បទថា **បរិយាយទស្សាវី** បានដល់ សម្តែងដល់ហេតុនោះៗ នៃអត្ថនោះៗ ។ ពិតហើយ ក្នុងសូត្រនេះៗ លោកពោលហេតុថា បរិយាយ ។ បទថា **អនុទ្ទយតំ បដិច្ច** បានដល់ អាស្រ័យការអាណិតអាសូរថា អញនឹងដោះសត្វទាំងឡាយ ដែលដល់នូវសេចក្តីលំបាកច្រើន អំពីសេចក្តីលំបាកនេះ ។ បទថា **ន អាមិសន្តរោ** បានដល់ មិនឃើញតែអាមិស អធិប្បាយថា មិនប្រាថ្នាលាភ គឺបច្ច័យ ៤ ដើម្បីខ្លួនឡើយ ។ បទថា **អត្តានញ្ច បរញ្ច អនុបហច្ច** បានដល់ មិនបៀតបៀនខ្លួន និងអ្នកដទៃ ដោយការបៀតបៀននូវគុណ ដោយលើកខ្លួន សង្កត់សង្កិនអ្នកដទៃ ។ល។

**អដ្ឋកថា ឧទាយិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុព្វិនោទយសូត្រទី ១០

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ កើតឡើងហើយបន្ទោបង់បានដោយកម្រ ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ គឺរាគៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ ទោសៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ មោហៈកើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ បដិភាណៈ ( ការឈ្មោកនិយាយ )

កើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ គមិកចិត្ត ( ចិត្តប្រាថ្នានឹងទៅ ) កើតឡើងហើយ បន្ទោបង់បានដោយកម្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ កើតឡើងហើយ បន្ទោបង់បានដោយកម្រ ។

សទ្ធម្មវគ្គទី ១ ចប់

## ឧទ្ទាននៃសទ្ធម្មវគ្គនោះ គឺ

និយាយអំពីការទូន្មានខ្លួន ដោយព្រះសទ្ធម្មមាន ៣ លើក អំពីសេចក្ដីសាបសូន្យនៃព្រះសទ្ធម្មមាន ៣ លើក អំពីពាក្យពោលអាក្រក់ ១ អំពីសេចក្ដីញញើតញញើម ១ អំពីព្រះឧទាយិ ១ អំពីធម៌ដែលបន្ទោបង់បាន ដោយកម្រ ១ ។

# អដ្ឋកថា

## ឧប្បិតោទយសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុប្បិនោទយសូត្រទី ១០ ដូចតទៅនេះ បទថា **ឧប្បដិតោទយា** សេចក្ដីថា ឋានៈទាំងឡាយណា រមែងមានដើម្បីញុំាងកិច្ច មានការត្រេកអរជាដើមឲ្យកើតឡើង កាលឋានៈនោះៗ មិនទាន់អស់ទៅ ឈ្មោះថា នាំចេញលំបាក សង្កត់សង្កិនបានលំបាក ។ ភាពជាអ្នក

*ប្រាថ្នានឹងពោល លោកហៅថា បដិភាណ ។ ធម៌ ៥ យ៉ាងនោះ រម្ងាប់លំបាក មិនមែនរម្ងាប់បានងាយឡើយ តែអាចរម្ងាប់បានដោយបច្ចវេក្ខណៈ និងអនុសាសនៈដែលសមគួរដោយឧបាយ ដោយហេតុ ដោយប្រការដូច្នេះ ។*

**អដ្ឋកថា ទុតិយអាឃាតបដិវិនយសូត្រទី ១០ ចប់**

**សទ្ធម្មវគ្គទី ១ ចប់**

# សុត្តន្តបិដក

# អាឃាតវគ្គទី ២

## បឋមអាឃាតប្បដិវិនយសូត្រទី ១

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនមេត្តាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនករុណាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវចម្រើនឧបេក្ខាចិត្តចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវប្រតិបត្តិនូវការមិនធ្វើទុកក្នុងចិត្ត ដោយស្មារតីចំពោះបុគ្គលនោះ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងចំពោះបុគ្គលណា ភិក្ខុត្រូវតាំងទុកនូវភាពនៃខ្លួន ជាអ្នកមានកម្មជារបស់ខ្លួន ចំពោះបុគ្គលនោះថា អ្នកនេះ មានកម្មជារបស់ខ្លួន ជាអ្នកទទួលយកនូវកម្ម មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់ អ្នកនេះនឹងធ្វើកម្ម

ណា ទោះល្អក្តី អាក្រក់ក្តី គង់អ្នកនោះទទួលយកកម្មនោះពុំខានឡើយ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។

# អដ្ឋកថា

# អាឃាតវគ្គទី ២

## បឋមអាឃាតប្បដិវិនយសូត្រ

[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាឃាតប្បដិវិនយសូត្រទី ១ នៃអាឃាតវគ្គទី ២ ដូចតទៅនេះ ឈ្មោះថា **អាឃាតប្បដិវិនយ** ព្រោះអត្ថថាស្ងប់រម្ងាប់ចាក អាឃាត ។ បទថា **យត្ថ ភិក្ខុនោ ឧប្បន្នោ អាឃាតោ សព្វសោ បដិវិនេតព្វោ** សេចក្តីថា អាឃាតកើតឡើងដល់ភិក្ខុក្នុងអារម្មណ៍ណា គប្បីរម្ងាប់អាឃាតទាំងអស់នោះក្នុងអារម្មណ៍នោះ ដោយអាឃាតប្បដិវិន័យ គឺធម៌រម្ងាប់អាឃាត ទាំង ៥ នេះ ។ បទថា **មេត្តា តស្មឹ បុគ្គលេ ភាវេតព្វា** សេចក្តីថា គប្បីចម្រើនមេត្តា ដោយតិកជ្ឈាន និងចតុក្កជ្ឈាន ។ ក្នុងករុណា ក៏មានន័យនេះដូចគ្នា ។ តែឧបេក្ខាគួរចម្រើនដោយចតុក្កជ្ឈាន និង

បញ្ចកជ្ឈាន ។ ព្រោះចិត្តរបស់បុគ្គលដែលឃើញបុគ្គលណាមិនទាន់រលត់ ទើបមុទិតាមិនប្រាកដក្នុងបុគ្គលនោះ ដូច្នោះ ទើបមិនពោលដល់មុទិតា ។ បទថា **អសតិ អមនសិការោ** បានដល់ គប្បីកាត់នូវការរពឹកដល់ក្នុងបុគ្គលនោះ ដោយអាការដែលបុគ្គលនោះមិនប្រាកដដូចជាយកជញ្ជាំងជាដើមរាំង ដូច្នោះ ។ បទដ៏សេស ងាយយល់ទាំងអស់ហើយ ព្រោះមានន័យដូចពោលហើយខាងដើម ៕

**អដ្ឋកថា បឋមអាឃាតប្បដិវិនយសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយអាឃាតប្បដិវិនយសូត្រទី ២

[ ៦២ ] ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុក្នុងទីនោះថា នែអាវុសោភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ក៏ទទួលស្តាប់ពាក្យព្រះសារីបុត្តដ៏មានអាយុថា អាវុសោ ដូច្នេះ ។ ព្រះសារីបុត្តដ៏មានអាយុក៏មានថេរវាចាយ៉ាងនេះថា នែអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់ដោយសព្វគ្រប់ព្រោះអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។ ៥ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ មានបុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធិ មានការប្រព្រឹត្ត ដោយវាចាដ៏

បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គល មានសភាព យ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោកនេះ មាន បុគ្គលខ្លះ ជាអ្នកមានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គល មានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុងលោក នេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ដែរ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គល មានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ក្នុង លោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានការ ប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តផង សេចក្តី ជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់ បង់គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ មួយ ទៀត ក្នុងលោកនេះ មានបុគ្គលខ្លះ មានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ មានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្តផង សេចក្តី ជ្រះថ្លានៃចិត្តផង ក្នុងកាលម្តងៗ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវកម្ចាត់បង់ គំនុំពីបុគ្គលមានសភាពយ៉ាងនេះចេញ ១ ។ ម្នាលអាវុសោទាំងឡាយ បណ្តា បុគ្គលទាំងនោះ បុគ្គលណា មានការប្រព្រឹត្តដោយ កាយមិនបរិសុទ្ធ តែមានការ

ប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ដូចជាភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល បានឃើញផែនសំពត់នៅនាច្រកផ្លូវ ហើយជាន់នឹងជើងឆ្វេង លាត្រដាងមើលដោយជើងស្ដាំ ហើយហែកសំពត់យក តែត្រង់កន្លែងដែលមានសាច់ជាប់ រួចកាន់យកដើរចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានការប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្ដីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្ត តែត្រង់សេចក្ដីប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធ របស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្ដាបុគ្គលទាំងនោះ បុគ្គលណា មានការប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធិ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណីពាសពេញដោយសារាយនិងចក មានបុរសក្ដៅខ្លាំងដោយកម្ដៅថ្ងៃ ត្រូវកម្ដៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេកដើរមកដល់ បុរសនោះ ក៏ចុះទៅរកស្រះបោក្ខរណីនោះ ហើយវែកសារាយនិងចកដោយដៃទាំងពីរ រួចក្បង់ទឹកផឹកដោយកម្បង់ដៃ ទើបដើរចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានការប្រព្រឹត្ត ដោយវាចា

មិនបរិសុទ្ធ តែមានការប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្ត នូវសេចក្តីប្រព្រឹត្ត ដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ត្រូវធ្វើទុកក្នុងចិត្ត តែត្រង់សេចក្តីប្រព្រឹត្តដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះវិញ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តនិងជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកដ៏តិចដក់ក្នុងជាន់ជើងគោ មានបុរសក្តៅខ្លាំងដោយកម្តៅថ្ងៃ ត្រូវកម្តៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែង ស្រេកដើរមកដល់ បុរសអ្នកស្រេកទឹកនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ទឹកក្នុងជាន់ជើងគោនេះមានតិច បើជាអាត្មាអញជងផឹកដោយ កម្បង់ដៃឬដោយភាជនៈក៏ឈ្មោះថា អាត្មាអញធ្វើទឹកនោះឲ្យកក្រើកផង ឲ្យល្អក់ផង ទាំងធ្វើទឹកនោះឲ្យជាទឹកផឹកមិនបានផង បើដូច្នោះ មានតែអាត្មាអញ ប្រត់លុតជង្គង់ឱនផឹកដូចជាគោ ហើយដើរចេញទៅចុះ ដូច្នេះ បុរសនោះ ក៏ប្រត់ដៃលុតជង្គង់ឱនផឹកដូចជាគោរួចចៀសចេញទៅ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ តែបានឱកាសស្ងប់នៃចិត្តផង សេចក្តីជ្រះថ្លានៃចិត្តផង

ក្នុងកាលមួងៗ ភិក្ខុមិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្ដីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ មិនត្រូវធ្វើទុកក្នុងចិត្តនូវសេចក្ដីប្រព្រឹត្តដោយវាចាមិនបរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះឡើយ ( ព្រោះ ) បុគ្គលនោះ បានឱកាសស្ងប់នៃចិត្តផង សេចក្ដីជ្រះថ្លានៃចិត្តផង ក្នុងកាលមួងៗ ឯណា ភិក្ខុត្រូវធ្វើទុកក្នុងចិត្ត តែត្រង់ការបានឱកាសស្ងប់នៃចិត្តផង សេចក្ដីជ្រះថ្លានៃចិត្តផង ក្នុងកាលមួងៗ នោះ របស់បុគ្គលនោះ ក្នុងសម័យនោះប៉ុណ្ណោះ ក៏យ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាមានសេចក្ដីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្ដីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបានឱកាសស្ងប់នៃចិត្តផង សេចក្ដីជ្រះថ្លានៃចិត្តផង ក្នុងកាលមួងៗ ទេ តើភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គល នោះចេញដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសមានអាពាធដល់នូវសេចក្ដីទុក្ខ ឈឺធ្ងន់ ដើរទៅកាន់ផ្លូវឆ្ងាយ ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅមុខផង ស្រុកបុរសនោះ ក៏នៅឆ្ងាយទៅក្រោយផង បុរសនោះ មិនបាននូវភោជនទាំងឡាយជាទីសប្បាយ មិនបានភេសជ្ជៈទាំងឡាយជាទីសប្បាយ មិនបានអ្នកទំនុកបម្រុងដ៏សមគួរ មិនបានជនអ្នកនាំទៅរកស្រុកសោះ ស្រាប់តែមាន បុរសម្នាក់ទៀតដើរទៅកាន់ផ្លូវឆ្ងាយដែរ ក៏ឃើញបុរសនោះ គាត់ក៏តាំងទុកនូវសេចក្ដីករុណាក្នុងបុរស ( មានអាពាធ ) នោះ តាំងទុកនូវសេចក្ដីអាណិត តាំងទុកនូវសេចក្ដីអនុគ្រោះ

( ដោយបំណងថា ) ធ្វើដូចម្តេចហ្ន៎ ឲ្យបុរសនេះ បាននូវភោជនទាំងឡាយ ជាទីសប្បាយ បាននូវភេសជ្ជៈទាំងឡាយជាទីសប្បាយ បាននូវអ្នកទំនុកបម្រុង ដ៏សមគួរ បាននូវជនអ្នកនាំទៅកាន់ស្រុកផងទៅអេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា បុរសនេះកុំដល់នូវសេចក្តីវិនាស ត្រង់កន្លែងនេះឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយមិនបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏មិនបរិសុទ្ធ ទាំងមិនបាន ឱកាសស្ងប់នៃចិត្ត និងសេចក្តីជ្រះថ្លានៃចិត្តក្នុងកាលម្តងៗ ទេ ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រូវតាំងទុកនូវសេចក្តីករុណា ត្រូវតាំងទុកនូវសេចក្តីអាណិត ត្រូវតាំងទុកនូវសេចក្តីអនុគ្រោះ ចំពោះបុគ្គលមានសភាពយ៉ាងនេះ ( ដោយបំណងថា ) ធ្វើដូចម្តេចហ្ន៎ អ្នកនេះ គប្បីលះកាយទុច្ចរិត ហើយចម្រើនកាយសុចរិត លះវចីទុច្ចរិត ហើយចម្រើនវចីសុចរិត លះមនោទុច្ចរិតហើយ ចម្រើនមនោសុចរិត នឹងគេអេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាកុំឲ្យអ្នកនេះ បែកធ្លាយរាងកាយស្លាប់ទៅកើតក្នុងកំណើត តិរច្ឆាន បិត្តិវិស័យ អសុរកាយ និងនរកបានឡើយ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលណា មានសេចក្តីប្រព្រឹត្ត ដោយកាយបរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាសស្ងប់នៃចិត្ត និងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ តើភិក្ខុត្រូវកម្ចាត់បង់គំនុំពីបុគ្គលនោះដូចម្តេច ។

ម្នាលអាវុសោទាំងឡាយ ស្រះបោក្ខរណី មានទឹកថ្លា ឆ្ងាញ់ ត្រជាក់ ស មានកំពង់រាបល្អ គួររីករាយ ដេរដាសដោយដើមឈើផ្សេងៗ ហើយមានបុរសក្តៅខ្លាំង ដោយកម្តៅថ្ងៃ ត្រូវកម្តៅថ្ងៃគ្របសង្កត់ នឿយហត់ អន្ទះអន្ទែងស្រេក ដើរមកដល់ បុរសនោះ ក៏ចុះក្នុងស្រះបោក្ខរណីនោះ ងូតផង ផឹកផង ហើយ ត្រឡប់ឡើងមកអង្គុយ ឬដេកក្រោមម្លប់ឈើ ប្របស្រះបោក្ខរណីនោះឯង មានឧបមាយ៉ាងណា ម្នាលអាវុសោទាំងឡាយ បុគ្គលណាមានសេចក្តីប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធ មានសេចក្តីប្រព្រឹត្ត ដោយវាចាក៏បរិសុទ្ធ ទាំងបានឱកាស ស្ងប់នៃចិត្តនិងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវ សេចក្តីប្រព្រឹត្ត ដោយកាយដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះផង ត្រូវធ្វើទុកក្នុងចិត្តនូវសេចក្តីប្រព្រឹត្ត ដោយវាចាដ៏បរិសុទ្ធរបស់បុគ្គលនោះ ក្នុងសម័យនោះផង ( ព្រោះ ) បុគ្គលនោះ បានឱកាសស្ងប់នៃចិត្តនិងសេចក្តី ជ្រះថ្លានៃចិត្តក្នុងកាលម្តងៗ ឯណា ភិក្ខុត្រូវធ្វើទុកក្នុងចិត្តនូវការបាននូវឱកាស ស្ងប់នៃចិត្ត និងសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលម្តងៗ នោះរបស់បុគ្គលនោះ ក្នុងសម័យនោះផង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ភិក្ខុត្រូវកម្ចាត់បង់គំនុំពី បុគ្គលនោះចេញ ដោយប្រការយ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ចិត្តជ្រះថ្លា ព្រោះមកកប់ប្រសព្វនឹងបុគ្គល ដែលមានគុណគួរឲ្យជ្រះថ្លាបំផុត ។ ម្នាលអាវុសោទាំងឡាយ គំនុំកើតឡើងដល់ភិក្ខុ ភិក្ខុត្រូវកម្ចាត់បង់សព្វគ្រប់ ដោយអាឃាតប្បដិវិន័យណា អាឃាតប្បដិវិន័យនេះមាន ៥ យ៉ាង ។

# អដ្ឋកថា

## ទុតិយអាឃាតប្បដិវិនយសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអាឃាតប្បដិវិនយសូត្រទី ២ ដូច្នេះ ឈ្មោះថា **អាឃាតប្បដិវិនយ** ព្រោះគួររម្ងាប់អាឃាតក្នុងបុគ្គលទាំង ៥ នោះក្តី ព្រោះគួររម្ងាប់អាឃាតដោយធម៌ទាំង ៥ នោះក្តី ។ ពិតហើយ បទថា **បដិវិនយា** នេះ ជាឈ្មោះរបស់វត្ថុដែលគួររម្ងាប់ខ្លះ ហេតុដែលគួររម្ងាប់ខ្លះ ។ ទាំង ២ យ៉ាងនោះ ក៏ត្រូវក្នុងទីនេះ ។ បុគ្គលទាំងឡាយ ៥ ជាបដិវិនយវត្ថុ គឺវត្ថុដែលគួររម្ងាប់ ។ បដិបទា ៥ ឧបមា ៥ ឈ្មោះថា **បដិវិនយការណា** គឺហេតុដែលគួររម្ងាប់ ។ បទថា **លភតិ ច កាលេន កាលំ ចេតសោ វិវរំ ចេតសោ បសាទំ** សេចក្តីថា បុគ្គលនោះគង់បានឱកាសពោល គឺឱកាសដែលចិត្តជាសមថៈ និងវិបស្សនាកើតបាន និងការផូរផង់ពោល គឺភាពជាអ្នកផូរផង់ដោយសទ្ធាជាគ្រាដំបូង ។

បទថា **រថិយាយ** បានដល់ វាងវិថី ។ បទថា **នន្តកំ** បានដល់ កំណាត់សំពត់ចាស់ៗ ។ បទថា **និគ្គហិត្វា** បានដល់ ជាន់ហើយ ។ បទថា **យោ តត្ថ សារោ** បានដល់ ចំណែកណា ក្នុងសំពត់ផ្នែកនោះនៅល្អ ។ បទថា **តំ បរិចាតេត្វា** បានដល់ ហែកចំណែកនោះ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ គប្បីឃើញថា នៅដោយមេត្តា ដូចភិក្ខុកាន់យកសំពត់បង្សុកូលជាវត្ថុ បុគ្គលដែលមានពៀរ ដូចសំពត់ចាស់លើវិថី ភាពជាអ្នកមានកាយសមាចារមិនបរិសុទ្ធ ដូចកំណាត់សំពត់ប្រឡាក់ ភាពជាអ្នកមានវចីសមាចារបរិសុទ្ធ

ដូចសំពត់ដែលនៅល្អ គប្បីឃើញថា ពេលដែលមិនដាក់ចិត្តដល់ភាពជាអ្នកមានកាយសមាចារមិនបរិសុទ្ធ ដាក់ចិត្តដល់ភាពជាអ្នកមានវចីសមាចារបរិសុទ្ធ រម្ងាប់ចិត្តប្បាទក្នុងបុគ្គលដែលជាសត្រូវនឹងគ្នា ហើយនៅយ៉ាងផាសុក ដូចពេលដែលបោះកំណាត់សំពត់ប្រឡាក់ចោល កាន់យកចំណែកដែលល្អដេរជ្រលក់ ហើយដណ្តប់ត្រាច់ទៅ ។

បទថា **សេវាលបណកបរិយោនទ្ធា** បានដល់ ត្រូវសារាយ និងចកបិទបាំង ។ បទថា **ឃម្មបរេតោ** បានដល់ ញើសហូរព្រោះកម្តៅ ។ បទថា **កិលន្តោ** បានដល់ ដើរផ្លូវនឿយហត់មក ។ បទថា **តសិតោ** បានដល់ ត្រូវការចង់បានគ្រប់សង្កត់ ។ បទថា **បិបាសិតោ** បានដល់ បំណងនឹងផឹកទឹក ។ បទថា **អបវិយូហិត្វា** បានដល់ វែកចេញ ។ បទថា **បិវិត្វា** បានដល់ ផឹកទឹកថ្លា ។ ក្នុងបទថា **ឯវមេវ ខោ** នេះ ភិក្ខុនៅដោយមេត្តា គប្បីឃើញដូចបុរសត្រូវកម្តៅដុតរោល ភាពជាអ្នកមានវចីសមាចារមិនបរិសុទ្ធ ក៏ដូចសារាយនិងចក ភាពជាអ្នកមានកាយសមាចារបរិសុទ្ធ ក៏ដូចទឹកថ្លា ពេលដែលភិក្ខុមិនដាក់ចិត្តដល់ភាពជាអ្នកមានវចីសមាចារមិនបរិសុទ្ធ ហើយដាក់ចិត្តដល់ភាពជាអ្នកមានកាយសមាចារបរិសុទ្ធ ញុំាងចិត្តប្បាទក្នុងបុគ្គលដែលមានពៀរនឹងគ្នា ឲ្យរលត់ទៅ ហើយនៅដោយផាសុក គប្បីឃើញដូចបុរសវែកសារាយនិងចក ហើយផឹកនូវទឹកថ្លាត្រាច់ទៅដូច្នោះ ។

បទថា **ខោភេស្សាមិ** គឺធ្វើឲ្យកល ។ បទថា **លោឡេស្សាមិ** គឺធ្វើឲ្យ

ល្អក់ ។ បទថា **អបេយ្យម្បិ ធំ ករិស្សាមិ** បានដល់ ធ្វើឲ្យផឹកមិនបាន ។ បទថា **ចតុក្កុណ្ឌិកោ** បានដល់ យកជង្គង់ទាំង ២ និងដៃទាំង ២ ក្រាបលើផែនដី ។ បទថា **គោបីតកំ បិវិត្វា** បានដល់ ឱនក្រេបដូចមេគោ ។ ក្នុងបទថា **ឯវមេវ ខោ** នេះ ភិក្ខុដែលនៅដោយមេត្តា គប្បីឃើញដូចបុរសត្រូវកម្តៅ ។ បុគ្គលមានពៀរ ដូចស្នាមជើងគោ គុណបន្តិចបន្តួចខាងក្នុងរបស់ភិក្ខុនោះ ដូចទឹកតិចតួចក្នុងស្នាមជើងគោ ការដែលភិក្ខុនោះ មិនដាក់ចិត្តដល់ភាពជាបុគ្គលមានកាយសមាចារ និងវចីសមាចារ ដែលមិនបរិសុទ្ធ ហើយដាក់ចិត្តដល់ការបានបីតិ និងបាមោជ្ជ ជាការផូរផង់នៃចិត្ត ព្រោះអាស្រ័យការស្តាប់ធម៌តាមកាលដ៏គួរ ហើយញ៉ាំងចិត្តុប្បាទឲ្យរលត់ទៅ គប្បីឃើញដូចបុរសក្រាបចុះ ផឹកទឹក ដូចមេគោចៀសទៅ ដូច្នោះ ។

បទថា **អាពាធិកោ** បានដល់ មានជំងឺដោយរោគ និងរបស់ស្មែងដែលទម្លាយឥរិយាបថ ។ បទថា **បុរតោបិស្ស** ប្រែថា គប្បីមានខាងមុខ ។ បទថា **អនយព្យសនំ** បានដល់ ការមិនចម្រើន គឺសេចក្តីវិនាស ។ ក្នុងបទថា **ឯវមេវ ខោ** នេះ បុគ្គលដែលប្រកបដោយធម៌ចំណែកខ្មៅទាំងអស់ គប្បីឃើញដូចអ្នកជំងឺអនាថា សង្សារដែលរកទីបំផុតខាងដើមមិនមាន ភាពដែលនិព្វានឆ្ងាយ ដូចភាពដែលស្រុកឆ្ងាយទាំងខាងមុខខាងក្រោយ ការដែលមិនមានភោជន គឺផលនៃសមណធម៌ ដូចការមិនបានភោជនដែលជាទីសប្បាយ ការមិនមានសមថៈ និងវិបស្សនា ដូចការមិនបានភេសជ្ជ ដែលជាទីសប្បាយ

ការមិនមានបុគ្គលព្យាបាលកិលេស ដោយឱវាទានុសាសនី ដូចការមិនបានឧបដ្ឋាកដែលសមគួរ ការមិនបានព្រះតថាគត ឬសាវ័ករបស់ព្រះតថាគតដែលធ្វើឲ្យសម្រេចនិព្វាន ដូចការមិនបានបុគ្គលដែលនាំទៅដល់ភូមិស្រុក ការដែលភិក្ខុនៅដោយមេត្តា ធ្វើករុណាឲ្យកើតក្នុងបុគ្គលនោះ ហើយចិត្តអាឃាតរលត់ទៅ គប្បីឃើញដូចបុរសណាម្នាក់ ឃើញអ្នកជំងឺអនាថា ហើយឧបដ្ឋាកដោយសេចក្ដីករុណា ដូច្នោះ ។

បទថា **អច្ឆោទកា** គឺទឹកថ្លា ។ បទថា **សាតោទកា** គឺទឹកផ្អែម ។ បទថា **សីតោទកា** គឺទឹកត្រជាក់ជោកខ្លួន ។ បទថា **សេតកា** បានដល់មានពណ៌ស ក្នុងទីដែលរលកបែក ។ បទថា **សុប្បតិដ្ឋា** គឺមានកំពង់រាប ។ ក្នុងបទថា **ឃម្មេ ខោ** នេះ បុគ្គលនៅដោយមេត្តា គប្បីឃើញដូចបុរសដែលត្រូវកម្ដៅថ្ងៃ ។ បុរសដែលមានទ្វារបរិសុទ្ធដូចស្រះបោក្ខរណីនោះ ការធ្វើវត្ត ដែលត្រូវការក្នុងទ្វារទាំងនោះឲ្យជាអារម្មណ៍ ( គឺចិត្តអាឃាតរលត់ ) ហើយ គប្បីជ្រាបដូចការងូត ផឹក និងឡើងទៅដេកត្រង់ម្លប់ឈើ ហើយទៅតាមសេចក្ដី ត្រូវការ ។ល៕

## អដ្ឋកថា ទុតិយអាឃាតវិនយសូត្រទី ២ ចប់

# សុត្តន្តបិដក

## សាកច្ឆាសូត្រទី ៣

[ ៦៣ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុក្នុងទីនោះថា ។បេ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរសាកសួរ ( ធម៌អាថ៌ ) នឹងសព្រហ្មចារីទាំងឡាយបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ មានភិក្ខុជាអ្នកបរិបូណ៌ ដោយសីលខ្លួនឯងទាំងព្យាករនូវប្រស្នាដែលមក ក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិខ្លួនឯងទាំងព្យាករនូវប្រស្នា ដែលមកក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាខ្លួនឯង ទាំងព្យាករនូវប្រស្នា ដែលមកក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិខ្លួនឯងទាំងព្យាករនូវប្រស្នា ដែលមកក្នុងវិមុត្តិ-សម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈខ្លួនឯងទាំងព្យាករនូវប្រស្នា ដែលមកក្នុងវិមុត្តិញាណទស្សនសម្បទាកថា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរសាកសួរនឹងសព្រហ្មចារីទាំងឡាយបាន ។

# អដ្ឋកថា

## សាកច្ឆាសូត្រ

[ ៦៣ ] ក្នុងសាកច្ឆាសូត្រទី ៣ មានន័យដូចលោកពោលទុកហើយខាងដើម ។៚

### អដ្ឋកថាសាកច្ឆាសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សាជីវសូត្រទី ៨

[ ៦៨ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ ក្នុងទីនោះថា ។បេ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរដល់សាជីវៈ ជាមួយនឹងសព្រហ្មចារីទាំងឡាយបាន ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានភិក្ខុជាអ្នកបរិបូណ៌ដោយសីលខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងសីលសម្បទាកថា ១ បរិបូណ៌ដោយសមាធិខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងសមាធិសម្បទាកថា ១ បរិបូណ៌ដោយបញ្ញាខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងបញ្ញាសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងវិមុត្តិសម្បទាកថា ១ បរិបូណ៌ដោយវិមុត្តិញាណទស្សនៈខ្លួនឯង ទាំងព្យាករនូវប្រស្នាដែលមក ក្នុងវិមុត្តិញាណទស្សនសម្បទាកថា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរដល់សាជីវៈជាមួយនឹងសព្រហ្មចារីទាំងឡាយបាន ។

# អដ្ឋកថា

## សាជីវសូត្រ

[ ៦៤ ] ក្នុងសាជីវសូត្រទី ៤ មានន័យដូចលោកពោលទុកហើយខាងដើម ។

អដ្ឋកថា សាជីវសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បញ្ហាបុច្ឆាសូត្រទី ៥

[ ៦៥ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ ក្នុងទីនោះថា ។បេ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសួរប្រស្នានឹងអ្នកដទៃ ភិក្ខុអស់នោះ ( រមែងសួរ ) ដោយហេតុទាំង ៥ យ៉ាង ឬបណ្ដាហេតុទាំង ៥ យ៉ាងនុ៎ះហេតុណាមួយ ។ ហេតុទាំង ៥ យ៉ាង តើដូចម្ដេច ។ គឺភិក្ខុសួរប្រស្នា នឹងអ្នកដទៃ ព្រោះស្មារតីទន់ ព្រោះល្ងង់ខ្លៅ ១ មានសេចក្ដីប្រាថ្នាលាមក លុះក្នុងអំណាចនៃសេចក្ដីប្រាថ្នា ហើយសួរប្រស្នានឹងអ្នកដទៃ ១ សួរប្រស្នានឹងអ្នកដទៃ ដើម្បីសង្កត់សង្កិន ១ មិនចង់ដឹង ហើយសួរប្រស្នានឹងអ្នកដទៃ ១ មួយយ៉ាងទៀត ភិក្ខុមានគំនិតយ៉ាងនេះហើយ សួរប្រស្នានឹងអ្នកដទៃ ថាបើភិក្ខុដែលអាត្មាអញសួរប្រស្នាហើយ រកដោះស្រាយដោយត្រឹមត្រូវបាន ការដោះសានុ៎ះជាការល្អ បើអាត្មាអញសួរប្រស្នាហើយ ដោះសាដោយត្រឹមត្រូវ

មិនបានទេ អាត្មាអញនឹងដោះសាដោយត្រឹមត្រូវ ឲ្យភិក្ខុនោះវិញ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសួរប្រស្នានឹងអ្នកដទៃ ភិក្ខុអស់នោះ ( រមែងសួរ ) ដោយហេតុទាំង ៥ យ៉ាងនេះ ឬបណ្ដាហេតុទាំង ៥ យ៉ាងនុ៎ះ ហេតុណាមួយក៏មាន ។ ម្នាលអាវុសោទាំងឡាយ ចំណែកខាងខ្ញុំមានគំនិតយ៉ាងនេះ ទើបសួរប្រស្នានឹងអ្នកដទៃ ថាបើភិក្ខុដែលអាត្មាអញសួរប្រស្នាហើយ គេព្យាករដោយត្រឹមត្រូវបាន ការព្យាករណ៍ដោយត្រឹមត្រូវដូច្នេះនេះ ជាការល្អ បើអាត្មាអញសួរប្រស្នាហើយ គេព្យាករដោយត្រឹមត្រូវមិនបានទេ អាត្មាអញនឹងព្យាករដោយត្រឹមត្រូវ ឲ្យភិក្ខុនោះវិញ ១ ។

# អដ្ឋកថា

## បញ្ហាបុច្ឆាសូត្រ

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ហាបុច្ឆាសូត្រទី ៥ ដូចតទៅនេះ បទថា **បរិភវំ** ប្រែថា សង្កត់សង្កិន អធិប្បាយថា សួរដើម្បី សង្កត់សង្កិនដោយគិតថា អញនឹងសួរយ៉ាងនេះ ដូច្នេះ ។ បទថា **ញាតុកាមោ** បានដល់ជាបុគ្គលប្រាថ្នាដឹង ។ល។

**អដ្ឋកថា បញ្ហាបុច្ឆាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ឆិរោគសូត្រទី ៦

[ ៦៦ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុក្នុងទីនោះថា ។បេ។ ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះតែងតែមាន បើមិនបានសម្រេចអរហត្តក្នុងកាលជាបច្ចុប្បន្នទេ ក៏ផ្ទោះរំលងនូវការកើតរួមនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្កា-ហារ ហើយកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះតែងតែមាន ។ កាលបើព្រះសារីបុត្ត មានថេរវាចាយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុក៏និយាយនឹងព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនុ៎ះមិនសមហេតុ មិនសមផលទេ ដែលថា ភិក្ខុនោះផ្ទោះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមានទេ ។ អស់វារៈជាគម្រប់ ២ ដងផង ។បេ។ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ អស់វារៈជាគម្រប់ ៣ ដងថា ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា ហើយចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជា

បច្ចុប្បន្នទេ ក៏ផ្លោះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវ-
ឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ
រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ តែងតែមាន ។
ព្រះឧទាយិដ៏មានអាយុនិយាយនឹងព្រះសារីបុត្តដ៏មានអាយុ ជាគម្រប់ ៣ ដង
យ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនុ៎ះ មិនសមហេតុសមផលទេ
ដែលថា ភិក្ខុនោះផ្លោះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវ
កវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ
រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះ មិនដែលមាន
ទេ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា
ឧទាយិដ៏មានអាយុ ចេះតែហាមឃាត់ ( ពាក្យ ) អាត្មាអញ អស់ ៣ ដង
មកហើយ ភិក្ខុណាមួយក៏មិនអនុមោទនា ( ពាក្យ ) អាត្មាអញសោះ បើដូច្នោះ
មានតែអាត្មាអញចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសារីបុត្ត
ដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏
ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះសារីបុត្តដ៏មាន
អាយុ គង់ក្នុងទីសមគួរហើយ ក៏មានថេរវាចានឹងពួកភិក្ខុថា ម្នាលអាវុសោ
ទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ
បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន
ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្នទេ

ក៏ផ្ទះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន ហេតុនេះតែងតែមាន ។ កាលបើព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោ សារីបុត្ត ដំណើរនោះមិនសមហេតុ មិនសមផលទេ ដែលថា ភិក្ខុនោះ ផ្ទះរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន ហេតុនេះ មិនដែលមានទេ ។ អស់វារៈ ២ ដង ។បេ។ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ អស់វារៈ ៣ ដងថា ម្នាលអាវុសោទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងបច្ចុប្បន្ននេះទេ ក៏ផ្ទះរំលងនូវការកើត ជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន ហេតុនេះ តែងតែមាន ។ ព្រះឧទាយិដ៏មានអាយុ មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុ អស់វារៈជាគម្រប់ ៣ ដងយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ដំណើរនេះ មិនសមហេតុ មិនសម

ផលទេ ដែលថា ភិក្ខុនោះ ផុតរំលងនូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើតក្នុងពួកទេវតា ដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញក៏បាន ហេតុនេះមិនដែលមានទេ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្បាលទីចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ម្តេចព្រះឧទាយិដ៏មានអាយុ ក៏នៅតែរាំងពាក្យរបស់អាត្មាអញ អស់វារៈជាគម្រប់ ៣ ដង រកភិក្ខុណាមួយ អនុមោទនាពាក្យរបស់អាត្មាអញគ្មានសោះ បើដូច្នោះ គួរតែអាត្មាអញ នៅស្ងៀមទៅចុះ ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក៏នៅស្ងៀម ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅព្រះឧទាយិដ៏មានអាយុថា ម្នាលឧទាយិ តើ អ្នកយល់ពួកទេវតា ដែលសម្រេចដោយចិត្តដូចម្តេច ។ ព្រះឧទាយិដ៏មានអាយុ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណាមិនមានរូបមានតែសញ្ញា ( ខ្ញុំព្រះអង្គយល់ពួកទេវតានោះ ) ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលឧទាយិ ប្រយោជន៍អ្វីដោយការនិយាយជាមួយនឹងអ្នក ដែលជាបុគ្គលពាលមិនឈ្លាស ខ្លួនអ្នកដឹងបានតែពាក្យដែលខ្លួនត្រូវពោល ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា មើលចុះអានន្ទ ( តទៅ ) ពួកអ្នកគង់ ព្រងើយកន្តើយនឹងភិក្ខុជាថេរៈ ដែលគេបៀតបៀន ម្នាលអានន្ទ មិនគួរបើនឹង មិនមានសេចក្តីករុណា ចំពោះភិក្ខុអ្នកចាស់ដែលគេបៀតបៀនសោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុ

ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុបរិបូណ៌ដោយសីល បរិបូណ៌ដោយសមាធិ បរិបូណ៌ដោយបញ្ញា គួរចូលកាន់សញ្ញាវេទយិតនិរោធក៏បាន ចេញ ក៏បាន ហេតុនេះ តែងតែមាន បើមិនបានសម្រេចអរហត្ត ក្នុងកាលជាបច្ចុប្បន្ននេះទេ ក៏ផ្ទោះរំលង នូវការកើតជាមួយនឹងពួកទេវតា អ្នកបរិភោគនូវកវឡិង្ការាហារ ហើយទៅកើត ក្នុងពួកទេវតាដែលសម្រេចដោយចិត្តណាមួយ រួចចូលកាន់សញ្ញាវេទយិតនិរោធ ក៏បាន ចេញ ក៏បាន ហេតុនេះ តែងតែមាន ។ ព្រះដ៏មានព្រះភាគ បានត្រាស់ ព្រះពុទ្ធដីកានេះ ហើយ លុះព្រះសុគត ទ្រង់ត្រាស់ព្រះពុទ្ធដីកានេះហើយ ទើបក្រោកចាកអាសនៈ រួចចូលទៅកាន់គន្ធកុដិ ។ កាលព្រះដ៏មានព្រះភាគ ចេញទៅមិនយូរប៉ុន្មាន ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅរកព្រះឧបវានៈដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏មានថេរវាចានឹងព្រះឧបវានៈដ៏មានអាយុ យ៉ាងនេះថា ម្នាលអាវុសោឧបវានៈ ឥឡូវនេះ ពួកភិក្ខុដទៃបៀតបៀនពួកភិក្ខុជាថេរៈ យើងមិនទាន់បានសួរពួកភិក្ខុទាំងនោះទេ ។ ម្នាលអាវុសោឧបវានៈ ហេតុនេះ មិនជាអស្ចារ្យទេ ដែលព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីស្ងាត់ ក្នុងសាយណ្ហសម័យ ហើយត្រាស់ប្រារព្ធហេតុនេះឯង ដូចជាទ្រង់ត្រាស់បំភ្លឺនូវព្រះឧបវានៈដ៏មានអាយុ ក្នុងហេតុនុ៎ះដែរ ។ ឥឡូវនេះ សេចក្តីទោមនស្ស ក៏ជ្រៀតចូល ( ក្នុងចិត្ត ) របស់យើងដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ចេញចាកទីស្ងាត់ ក្នុងសាយណ្ហសម័យ ហើយស្តេចយាងចូលទៅកាន់ឧបដ្ឋានសាលា

លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុកថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស្រេចហើយ ក៏បានត្រាស់នឹងព្រះឧបវានៈដ៏មានអាយុយ៉ាងនេះថា ម្នាលឧបវានៈ ភិក្ខុជាថេរៈ ប្រកបដោយធម៌ប៉ុន្មានយ៉ាង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនិងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនិងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសាសនានេះ ភិក្ខុជាថេរៈ ជាអ្នកមានសីល ។បេ។ សិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះដឹងច្រើន ។បេ។ ជាអ្នកចាក់ធ្លុះល្អដោយប្រាជ្ញា ១ ជាអ្នកមានវាចាដ៏ពីរោះ មានសំដីដ៏ផ្អែមល្ហែម ប្រកបដោយវាចាជារបស់អ្នកក្រុង ជាវាចាក្បោះក្បាយ មិនមានទោស គួរធ្វើអ្នកដទៃឲ្យដឹងសេចក្តីច្បាស់លាស់បាន ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រនូវឈានទាំង ៤ ជាគ្រឿងនៅជាសុខ ក្នុងកាលជាបច្ចុប្បន្ន ដែលប្រកបដោយចេតសិកដ៏ថ្លៃថ្លា ១ បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាងនេះ ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរព និងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ម្នាលឧបវានៈ ត្រូវណាស់ហើយ ត្រូវណាស់ហើយ ម្នាលឧបវានៈ

*ភិក្ខុជាថេរៈប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីគាប់ចិត្ត គួរគោរពនិងគួរសរសើរ របស់សព្រហ្មចារីទាំងឡាយ ។ ម្នាលឧបាលិ បើធម៌ ៥ យ៉ាងនេះ មិនមានដល់ភិក្ខុជាថេរៈទេ តើពួកសព្រហ្មចារី គួរធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុជាថេរៈនោះ ត្រង់ធ្មេញបាក់ សក់ស្កូវ និងស្បែកជ្រួញជ្រីវ ឬដូចម្តេច ។ ម្នាលឧបាលិ ព្រោះហេតុនោះ ធម៌ ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុជាថេរៈ ទើបពួកសព្រហ្មចារីធ្វើសក្ការៈ គោរព រាប់អាន បូជាភិក្ខុជាថេរៈនោះបាន ។*

# អដ្ឋកថា

## និរោធសូត្រ

*[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធសូត្រទី ៦ ដូចតទៅនេះ បទថា* **អដ្ឋានំ ឋានំ** *ប្រែថា ហេតុនោះមាន ។ បទថា* **នោ ចេ ទិដ្ឋេវ ធម្មេ អញ្ញំ អារាធេយ្យ** *សេចក្តីថា បើភិក្ខុនោះមិនទាន់សម្រេច អរហត្តក្នុងអត្តភាពនេះ ។ បទថា* **កពឡិង្ការាហារភក្ខានំ ទេវានំ** *បានដល់ ទេវតាជាន់កាមាវចរ ។ បទថា* **អញ្ញតរំ មនោមយំ កាយំ** *បានដល់ ពួកព្រហ្មជាន់សុទ្ធាវាសណាមួយ ដែលកើតដោយចិត្ត ដែលប្រកបដោយឈាន ។ បទថា* **ឧបបន្នោ** *បានដល់ លោឡុទាយី ។ លោឡុទាយីនោះ បានស្តាប់ថា* **មនោមយំ**

ដូច្នេះ ទើបជំទាស់ថា មិនជាការសមគួរ ។ ដើម្បីការពារលទ្ធិរបស់ពួកបុគ្គល ពាលដែលកើតឡើងយ៉ាងនេះថា ព្រះសារីបុត្រដឹងអ្វី ដែលពួកភិក្ខុនាំគ្នាជំទាស់ពាក្យយ៉ាងនេះចំពោះមុខ ដូច្នេះ ព្រះថេរៈមិនបញ្ឈប់ពាក្យនោះដោយខ្លួនឯង ទើបចូលគាល់ព្រះមានព្រះភាគ ។ បទថា **អត្ថិ ណាម** ជានិបាត ចុះក្នុងអត្ថថា អាងដល់ ។ ដោយហេតុនោះ បទថា **អជ្ឈុបេក្ខិស្សថ** ក្នុងទីនេះ ទើបលោកធ្វើឲ្យជាសព្ទអនាគតកាល ។ ក្នុងសូត្រនេះ មានន័យដូច្នេះថា ម្នាលអានន្ទ ពួកអ្នកចូរសម្លឹងមើល ភិក្ខុដែលជាថេរៈ ដែលត្រូវបៀតបៀនយ៉ាងនេះថា ខ្ញុំមិនអត់ធន់ចំពោះអ្នក មិនអត់ធ្មត់ មិនអត់សង្កត់ ដូច្នេះ ។ សួរថា ព្រោះអ្វី ទើបព្រះមានព្រះភាគ ត្រាស់យ៉ាងនេះ នឹងព្រះអានន្ទប៉ុណ្ណោះ ។ ឆ្លើយថា ព្រោះព្រះអានន្ទជាឃ្លាំងធម៌ ។ ពិតហើយ ព្រះឧទាយីកាលពោលចំពោះបុគ្គលដែលជាឃ្លាំងធម៌យ៉ាងនេះ ទើបជាភារៈដែលនឹងហាមប្រាម ។ ម្យ៉ាងទៀត ព្រះអានន្ទក៏ជាបិយសម្លាញ់របស់ព្រះសារីបុត្រ ដោយហេតុនោះ ទើបជាភារៈរបស់ព្រះអានន្ទ ក្នុងសេចក្តីនោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលព្រះអានន្ទ ទើបត្រាស់យ៉ាងនេះក៏ពិត តែមិនមែនតិះដៀលព្រះអានន្ទប៉ុណ្ណោះទេ គប្បីជ្រាបថា ជាការតិះដៀលភិក្ខុទាំងអស់ ដែលនៅចំពោះមុខនោះឯង ។

បទថា **វិហារំ** បានដល់ ព្រះគន្ធកុដិ ។ បទថា **អឍច្ឆរិយំ** បានដល់ មិនគួរអស្ចារ្យ ។ បទថា **យថា** ជាពាក្យពោលហេតុ ។ ក្នុងបទថា **អាយស្មន្តញ្ញេវេត្ថ ឧបវានំ បដិភាសេយ្យ** ព្រះអានន្ទចង្អុលបង្ហាញថា កាលព្រះ

មានព្រះភាគទ្រង់ប្រារព្ធហេតុនេះ ទ្រង់លើករឿងនេះមកអាងហើយ ចម្លើយជាក់ច្បាស់ ចូរប្រាកដដល់ឧបវាទៈចុះ ។ បទថា **សារជ្ជំ ឱក្កន្តំ** បានដល់ កើតទោមនស្សចិត្ត ។ ព្រះឧបវាទៈពោលដល់សីលរបស់ព្រះទីណាស្រេពជាដើម ដោយបទជាដើមថា **សីលវា** ដូច្នេះ ។ បទថា **១ណ្ហិច្ចេន** ជាដើម ព្រះឧបវាទៈពោលដោយសួរដល់ហេតុនៃសក្ការៈជាដើម ក្នុងសេចក្តីនេះ មានអធិប្បាយថា សព្រហ្មចារីទាំងឡាយ គប្បីសក្ការៈសព្រហ្មចារី ដោយហេតុ មានធ្វេញបាក់ជាដើម ។៚

## អដ្ឋកថា ឆិរោធសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ចោទនាសូត្រទី ៧

[ ៦៧ ] ព្រះសារីបុត្តដ៏មានអាយុ បានហៅពួកភិក្ខុ ក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿន ចង់ដាស់តឿនភិក្ខុដទៃ គួរតម្កល់ធម៌ ៥ យ៉ាងទុកក្នុងខ្លួន ហើយសឹមដាស់តឿនភិក្ខុដទៃ ។ ធម៌ ៥ យ៉ាង តើដូចម្តេចខ្លះ ។ ( គឺភិក្ខុគិតថា ) អាត្មាអញនិយាយដាស់តឿនក្នុងកាលគួរ មិននិយាយដាស់តឿនក្នុងកាលមិនគួរ ១ អាត្មាអញនិយាយដាស់តឿនដោយពាក្យពិត មិននិយាយដាស់តឿនដោយពាក្យមិនពិត ១ អាត្មាអញនិយាយដាស់តឿន

ដោយពាក្យពីរោះ មិននិយាយដាស់តឿនដោយពាក្យទ្រគោះ ១ អាត្មាអញនិយាយដាស់តឿនដោយពាក្យ ដែលប្រកបដោយប្រយោជន៍ មិននិយាយដាស់តឿនដោយពាក្យដែលមិនប្រកបដោយប្រយោជន៍ ១ អាត្មាអញនិយាយដាស់ដឿនដោយចិត្តមេត្តា មិននិយាយដាស់តឿនដោយទោសចិត្ត ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿន ចង់ដាស់តឿនភិក្ខុដទៃ គួរតម្កល់ធម៌ ៥ យ៉ាង នេះទុកក្នុងខ្លួន ហើយសឹមដាស់តឿនភិក្ខុដទៃ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំឃើញបុគ្គលខ្លះ ក្នុងលោកនេះ ដែលគេដាស់តឿនក្នុងកាលមិនគួរ មិនដាស់តឿនក្នុងកាលគួរ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយពាក្យមិនពិត មិនដាស់តឿនដោយពាក្យពិត ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយពាក្យទ្រគោះ មិនដាស់តឿនដោយពាក្យពីរោះ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយពាក្យ មិនប្រកបដោយប្រយោជន៍ មិនដាស់តឿនដោយពាក្យ ដែលប្រកបដោយប្រយោជន៍ ហើយមានសេចក្តីខឹង ១ ដែលគេដាស់តឿនដោយទោសចិត្ត មិនដាស់តឿនដោយចិត្តមេត្តា ហើយមានសេចក្តីខឹង ១ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុមានគេដាស់តឿន មិនប្រកបដោយធម៌ គួរតាំងទុកនូវសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា គេដាស់តឿន អ្នកក្នុងកាលមិនគួរ មិនដាស់តឿនក្នុងកាលគួរ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយពាក្យមិនពិត មិនដាស់តឿនដោយពាក្យពិត គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេ

ដាស់តឿនអ្នកដោយពាក្យទ្រគោះ មិនដាស់តឿនដោយពាក្យពីរោះ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនដាស់តឿនដោយពាក្យដែលប្រកបដោយប្រយោជន៍ គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ គេដាស់តឿនអ្នកដោយទោសចិត្ត មិនដាស់តឿនដោយចិត្តមេត្តា គួរតែអ្នកមិនមានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ បើភិក្ខុមានគេដាស់តឿន មិនប្រកបដោយធម៌ គួរតាំងទុកនូវសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេ មិនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ក្នុងកាលមិនគួរ មិនដាស់តឿនគេក្នុងកាលគួរ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យមិនពិត មិនដាស់តឿនគេដោយពាក្យពិត ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យទ្រគោះ មិនដាស់តឿនគេដោយពាក្យពីរោះ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយពាក្យមិនប្រកបដោយប្រយោជន៍ មិនដាស់តឿនគេដោយពាក្យដែលប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេដោយទោសចិត្ត មិនដាស់តឿនគេដោយចិត្តមេត្តា ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ

ភិក្ខុអ្នកជាស់តឿនគេ មិនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះហេតុថា ដូចយ៉ាងភិក្ខុដទៃ ក៏មិនត្រូវសម្គាល់នូវភិក្ខុ ដែលខ្លួនត្រូវជាស់តឿនដោយពាក្យមិនពិតដែរ ។ ម្នាលអាវុសោទាំងឡាយ ខ្ញុំឃើញបុគ្គលខ្លះ ក្នុងលោកនេះ ដែលគេជាស់តឿន ក្នុងកាលគួរ មិនជាស់តឿន ក្នុងកាលមិនគួរ ហើយមានសេចក្តីខឹង ១ ដែលគេជាស់តឿន ដោយពាក្យពិត មិនជាស់តឿនដោយពាក្យមិនពិត ហើយមានសេចក្តីខឹង ១ ដែលគេជាស់តឿន ដោយពាក្យពីរោះ មិនជាស់តឿន ដោយពាក្យទ្រគោះ ហើយមានសេចក្តីខឹង ១ ដែលគេជាស់តឿនដោយពាក្យប្រកបដោយប្រយោជន៍ មិនជាស់តឿនដោយពាក្យមិនប្រកបដោយប្រយោជន៍ ហើយមានសេចក្តីខឹង ១ ដែលគេជាស់តឿន ដោយចិត្តមេត្តា មិនជាស់តឿនដោយទោសចិត្ត ហើយមានសេចក្តីខឹង ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលគេជាស់តឿនប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា គេជាស់តឿនអ្នក ក្នុងកាលគួរ គេមិនជាស់តឿនអ្នក ក្នុងកាលមិនគួរ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ គេជាស់តឿនអ្នក ដោយពាក្យពិត មិនជាស់តឿន ដោយពាក្យមិនពិត ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ គេជាស់តឿនអ្នក ដោយពាក្យពីរោះ មិនជាស់តឿនអ្នក ដោយពាក្យទ្រគោះ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ គេជាស់តឿនអ្នកដោយពាក្យប្រកបដោយប្រយោជន៍ មិនជាស់តឿន ដោយ

ពាក្យដែលមិនប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ដែលគេដាស់តឿនអ្នក ដោយចិត្តមេត្តា មិនដាស់តឿន ដោយទោសចិត្ត ត្រូវតែអ្នកឯងបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុដែលគេដាស់តឿន ប្រកបដោយធម៌ ត្រូវបានសេចក្តីក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេប្រកបដោយធម៌ ត្រូវបានសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាង ដោយគិតថា ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ក្នុងកាលគួរ មិនដាស់តឿនគេក្នុងកាលមិនគួរ ត្រូវតែអ្នកឯងមិនបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យពិត មិនដាស់តឿនគេ ដោយពាក្យមិនពិត ត្រូវតែអ្នកឯងមិនបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យពីរោះ មិនដាស់តឿនគេ ដោយពាក្យទ្រគោះ ត្រូវតែអ្នកឯងមិនបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយពាក្យប្រកបដោយប្រយោជន៍ មិនដាស់តឿនគេ ដោយពាក្យមិនប្រកបដោយប្រយោជន៍ ត្រូវតែអ្នកឯងមិនបានសេចក្តីក្តៅក្រហាយ ១ ម្នាលអាវុសោ អ្នកឯងដាស់តឿនគេ ដោយចិត្តមេត្តា មិនដាស់តឿនគេ ដោយទោសចិត្ត ត្រូវតែអ្នកឯងមិនបានសេចក្តីក្តៅក្រហាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកដាស់តឿនគេ ប្រកបដោយធម៌ ត្រូវបានសេចក្តីមិនក្តៅក្រហាយ ដោយអាការៈ ៥ យ៉ាងនេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា ដូចយ៉ាងភិក្ខុដទៃក៏

ត្រូវសម្គាល់ភិក្ខុដែលខ្លួនត្រូវដាស់តឿន ដោយពាក្យពិតដែរ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលដែលគេដាស់តឿន ត្រូវប្រតិស្ឋានក្នុងធម៌ ២ យ៉ាង គឺសច្ចៈ ១ សេចក្តីមិនខឹង ១ ។ ម្នាលអាវុសោទាំងឡាយ ពួកភិក្ខុគប្បីដាស់តឿនពួកបុគ្គលដទៃ ដោយអាការៈ ៥ យ៉ាង គឺ ( ដាស់តឿន ) ក្នុងកាលគួរក៏មាន មិនគួរក៏មាន ១ ដោយពាក្យពិតក៏មាន មិនពិតក៏មាន ១ ដោយពាក្យពីរោះក៏មាន ពាក្យទ្រគោះក៏មាន ១ ដោយពាក្យប្រកបដោយប្រយោជន៍ក៏មាន មិនប្រកបដោយប្រយោជន៍ក៏មាន ១ ដោយចិត្តមេត្តាក៏មាន ដោយទោសចិត្តក៏មាន ១ ។ ( ភិក្ខុអ្នកដាស់តឿនគេត្រូវតាំងចិត្ត ) ថា ទោះបីអាត្មាអញ ក៏គួរប្រតិស្ឋានក្នុងធម៌ ២ យ៉ាង គឺសច្ចៈ ១ សេចក្តីមិនខឹង ១ ដែរ ។ បើអាត្មាអញដឹងថា ធម៌នុ៎ះមាននៅក្នុងអាត្មាអញ អាត្មាអញគួរនិយាយប្រាប់គេថាមាន ( ព្រោះ ) ធម៌នុ៎ះ មាននៅក្នុងអាត្មាអញមែន ។ បើអាត្មាអញដឹងថា ធម៌នុ៎ះមិនមានក្នុងអាត្មាអញទេ គួរអាត្មាអញនិយាយប្រាប់គេថា មិនមាន ( ព្រោះ ) ធម៌នុ៎ះ មិនមានក្នុងអាត្មាអញមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត កាលដែលអ្នកពោលយ៉ាងនេះហើយ មានពួកមោឃបុរសខ្លះ ក្នុងសាសនានេះ មិនទទួលយកដោយផ្ចិតផ្ចង់ឡើយ ។ ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកណា ដែលមិនមានសទ្ធា ត្រូវការតែនឹងចិញ្ចឹមជីវិត ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួសដោយមិនមានសទ្ធា ជាអ្នកអួតអាង មានមាយា បោកប្រាស មានចិត្តរាយមាយ លើកកម្ពស់

មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្តីផ្តេសផ្តាស មិនគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបនូវការភ្ញាក់រលឹក មិនបានក្រឡេកមើល ក្នុងភាពនៃខ្លួនជាសមណៈ មិនមានសេចក្តីគោរពដ៏ក្លៀវក្លា ក្នុងសិក្ខា ជាអ្នកល្មោភ មានសេចក្តីព្យាយាម ក្នុងការប្រព្រឹត្តធូរថយ ជាប្រធានខាងការប្រព្រឹត្តិជ្រោកជ្រាក ដាក់ចោលនូវធុរៈ ក្នុងវិវេក ខ្ជិលច្រអូស មានព្យាយាមថោកថយ មានស្មារតីភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តវើរវាយ ជាមនុស្សអប្បឥតប្រាជ្ញា ជាមនុស្សលលា បុគ្គលពួកនោះ កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះ រមែងមិនទទួលយកដោយផ្ចិតផ្ចង់ឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ន័យមួយទៀត ពួកកុលបុត្តណាដែលចេញចាកផ្ទះហើយ ចូលមកកាន់ផ្នួសដោយសទ្ធា ជាអ្នកមិនអួតអាង មិនមានមាយា មិនបោកប្រាស មិនមានចិត្តរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្តីផ្តេសផ្តាស គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបក្នុងការភ្ញាក់រលឹក មានការក្រឡេកមើលក្នុងភាពនៃខ្លួនជាសមណៈ មានសេចក្តីគោរពដ៏ក្លៀវក្លា ក្នុងសិក្ខា មិនល្មោភ មានព្យាយាម ក្នុងការប្រព្រឹត្តមិនធូរថយ ដាក់ការប្រព្រឹត្តជ្រោកជ្រាកចោល ជាអ្នកនាំអាទិ៍ក្នុងសេចក្តីស្ងប់ស្ងាត់ ( ព្រះនិព្វាន ) ជាអ្នកប្រារព្ធនូវព្យាយាម មានចិត្តស្ទុះទៅកាន់ព្រះនិព្វាន ប្រុងស្មារតី មានសម្បជញ្ញៈ បានតាំងទុកនូវចិត្តដ៏មាំមួន មានចិត្តនឹងនៅក្នុងអារម្មណ៍តែមួយ មានបញ្ញា

មិនលះលា កុលបុត្តពួកនោះ កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ រមែង ទទួលយកដោយផ្ចិតផ្ចង់ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ពួក បុគ្គលណា មិនមានសទ្ធា មានសេចក្តីត្រូវការតែនឹងចិញ្ចឹមជីវិត ចេញចាក ផ្ទះចូលមកកាន់ផ្នួសដោយមិនមានសទ្ធា ជាអ្នកអួតអាង មានមាយា បោកប្រាស មានចិត្តរាយមាយ លើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសំដី ផ្តេសផ្តាស មិនបានគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណ ក្នុងភោជន មិនប្រកបនូវការភ្ញាក់រលឹក មិនបានក្រឡេកមើល ក្នុងភាពនៃ ខ្លួនជាសមណៈ មិនមានសេចក្តីគោរពដ៏ក្លៀវក្លាក្នុងសិក្ខា ជាអ្នកល្មោភ មាន សេចក្តីព្យាយាម ក្នុងការប្រព្រឹត្តធូរថយ ជាប្រធានខាងការប្រព្រឹត្តដ៏ជ្រោកជ្រាក ដាក់ចោលនូវធុរៈក្នុងវិវេក ខ្ជិលច្រអូស មានព្យាយាមថោកថយ មានស្មារតី ភ្លេចភ្លាំង មិនមានសម្បជញ្ញៈ មិនបានតាំងចិត្តមាំ មានចិត្តរវើរវាយ ជាមនុស្ស អប្បឥតបញ្ញា ជាមនុស្សលេលា ពួកបុគ្គលនោះ លើកទុកដោយឡែកសិន ម្នាលសារីបុត្ត ពួកកុលបុត្តណា ដែលចេញចាកផ្ទះហើយ ចូលមកកាន់ផ្នួស ដោយសទ្ធា មិនជាអ្នកអួតអាង មិនមានមាយា មិនបោកប្រាស មិនរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនជាអ្នកមាត់រឹង មិនមានសំដីផ្តេស ផ្តាស ជាអ្នកគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងភោជន ប្រឹងប្រកបនូវការភ្ញាក់រលឹក ក្រឡេកមើលក្នុងភាពនៃខ្លួនជាសមណៈ មាន សេចក្តីគោរពដ៏ក្លៀវក្លាក្នុងសិក្ខា មិនល្មោភ មិនប្រព្រឹត្តធូរថយ ដាក់ចោល

នូវធុរៈ ក្នុងការប្រព្រឹត្តិជ្រោកជ្រាក ជាអ្នកនាំអាទិក្នុងវិវេក ប្រារព្ធនូវព្យាយាម មានចិត្តស្ទុងទៅកាន់ព្រះនិព្វាន ប្រុងស្មារតី មានសម្បជញ្ញៈ តាំងចិត្តមាំ មានចិត្តនឹងក្នុងអារម្មណ៍តែមួយ មានបញ្ញា មិនលលា ម្នាលសារីបុត្ត អ្នកត្រូវនិយាយទៅរកតែពួកកុលបុត្តនោះបានហើយ ។ ម្នាលសារីបុត្ត អ្នកចូរទូន្មានពួកសព្រហ្មចារី ម្នាលសារីបុត្ត អ្នកចូរប្រៀនប្រដៅពួកសព្រហ្មចារី ដោយតាំងចិត្តថា អាត្មាអញនឹងធ្វើពួកសព្រហ្មចារីឲ្យចេញផុតចាកអសទ្ធម្ម ហើយឲ្យប្រតិស្ឋាន ក្នុងព្រះសទ្ធម្ម ។ ម្នាលសារីបុត្ត អ្នកត្រូវសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## ចោទនាសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចោទនាសូត្រទី ៧ ដូចតទៅនេះ បទថា **ចោទកេន** សេចក្តីថា ភិក្ខុដែលជាអ្នកចោទ ចោទដោយចោទនវត្ថុ ៤ គឺចន្លុលវត្ថុ ចន្លុលអាបត្តិ ហាមសង្វាស ហាមសាមីចិកម្ម ។ ក្នុងបទថា **កាលេន វក្ខាមិ នោ អកាលេន** នេះ ព្រះសារីបុត្រពោលដល់កាលរបស់ភិក្ខុដែលត្រូវចោទ គឺចុងចោទមិនបានពោលដល់កាលរបស់ដើមចោទ ។ ពិតហើយ ភិក្ខុដែលចោទអ្នកដទៃ មិនគួរចោទក្នុងកណ្តាលបរិស័ទ ឬក្នុងរោងឧបោសថបវារណា ឬត្រង់បន្ទប់អគ្គុយ និងបន្ទប់ឆាន់ជាដើម ។ ក្នុងវេលាអង្គុយក្នុងទី

សម្រាកពេលថ្ងៃ គួរសូមឱកាសយ៉ាងនេះថា បពិត្រលោកម្ចាស់ ចូរឲ្យឱកាស ខ្ញុំបំណងនឹងពោលជាមួយលោកម្ចាស់ ដូច្នេះហើយ សឹមចោទ សម្ដីងដល់បុគ្គលឡេះឡោះណា ពោលពាក្យមិនពិត លើកទោសដល់ភិក្ខុបុគ្គលឡេះឡោះនោះ មិនត្រូវសូមឱកាសចោទឡើយ ។ បទថា **ភូតេន** គឺដោយពិត ដោយសភាវៈ ។ បទថា **សណ្ហេន** គឺដោយសុភាពរាបសា ។ បទថា **អត្ថសញ្ហិតេន** បានដល់ ប្រកបដោយភាពជាអ្នកបំណងល្អ ប្រាថ្នានូវប្រយោជន៍ ។ បទថា **អវិប្បដិសារោ ឧបទហិតព្វោ** បានដល់ មិនឲ្យកើតសេចក្ដីក្ដៅក្រហាយ ។ បទថា **អលន្តេ អវិប្បដិសារាយ** បានដល់ អ្នកគួរជាបុគ្គលមិនក្ដៅក្រហាយ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ទាំងអស់ហើយ ៕៚

## អដ្ឋកថា ចោទនាសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សីលសូត្រទី ៨

[ ៦៨ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាហៅពួកភិក្ខុមក ក្នុងទីនោះ ។បេ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុទ្រុស្តសីល វិបត្តិចាកសីល ជាហេតុសាបសូន្យចាកសម្មាសមាធិ កាលបើសម្មាសមាធិមិនមានហើយ ភិក្ខុវិបត្តិចាកសម្មាសមាធិ ជាហេតុសាបសូន្យចាកយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ ភិក្ខុវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ជាហេតុសាបសូន្យចាកនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈ មិនមានហើយ ភិក្ខុវិបត្តិចាកនិព្វិទាវិរាគៈ ជាហេតុសាបសូន្យចាកវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ដូចជាដើមឈើដែលវិបត្តិចាកមែកនិងស្លឹកហើយ ក្រមរនៃដើមឈើនោះក្តី ក៏មិនបរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនបរិបូណ៌យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុទ្រុស្តសីល វិបត្តិចាកសីល ជាហេតុសាបសូន្យចាកសម្មាសមាធិ កាលបើសម្មាសមាធិ មិនមានហើយ ភិក្ខុវិបត្តិចាកសម្មាសមាធិ ជាហេតុសាបសូន្យចាកយថាភូតញ្ញាណទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ ភិក្ខុវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ជាហេតុសាបសូន្យចាកនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈ មិនមានហើយ ភិក្ខុវិបត្តិចាកនិព្វិទាវិរាគៈ ជាហេតុសាបសូន្យចាកវិមុត្តិញ្ញាណ ទស្សនក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសីល បរិបូណ៌ដោយសីល ឈ្មោះថាបរិបូណ៌ដោយហេតុនៃសម្មាសមាធិ កាលបើមានសម្មាសមាធិហើយ ភិក្ខុ

បរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុនៃយថាភូតញ្ញាណ-ទស្សនៈ កាលបើយថាភូតញ្ញាណទស្សនៈមានហើយ ភិក្ខុបរិបូណ៌ដោយយថា-ភូតញ្ញាណទស្សនៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈមានហើយ ភិក្ខុបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា បរិបូណ៌ដោយហេតុវិមុត្តិញ្ញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ដូចដើមឈើដែលបរិបូណ៌ដោយមែកនិងស្លឹកហើយ ក្រមរនៃដើមឈើនោះក្តី ក៏បរិបូណ៌ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏បរិបូណ៌ យ៉ាងណាមិញ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកមានសីល បរិបូណ៌ដោយសីល ឈ្មោះថា បរិបូណ៌ដោយហេតុនៃសម្មាសមាធិ កាលបើសម្មាសមាធិមានហើយ ភិក្ខុបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា បរិបូណ៌ដោយហេតុនៃយថាភូតញ្ញាណទស្សនៈ កាលបើយថាភូ-តញ្ញាណទស្សនៈមានហើយ ភិក្ខុបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃនិព្វិទាវិរាគៈ កាលបើនិព្វិទាវិរាគៈមានហើយ ភិក្ខុបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា បរិបូណ៌ដោយហេតុនៃវិមុត្តិញ្ញាណទស្សនៈ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## សីលសូត្រ

[ ៦៨ ] ក្នុងសីលសូត្រទី ៨ ជាក់ច្បាស់ហើយ ព្រោះមានន័យដូចពោលទុកហើយខាងដើមនោះឯង ។ល។

### អដ្ឋកថា សីលសូត្រទី ៨ ចប់

# សុត្តន្តបិដក

## និសន្តិសូត្រទី ៩

[ ៦៩ ] គ្រានោះឯង ព្រះអានន្ទដ៏មានអាយុ បានចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុគង់ក្នុងទីដ៏សមគួរហើយ ក៏មានថេរវាចានឹងព្រះសារីបុត្តដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុជាអ្នកពិចារណាឃើញធាប់ ក្នុងពួកធម៌ជាកុសលផង ជាអ្នកកាន់យកនូវធម៌ ដែលខ្លួនកាន់យកដោយល្អផង កាន់យកនូវធម៌បានច្រើនផង មិនភ្លេចធម៌ដែលខ្លួនកាន់យកហើយផង តើដោយហេតុប៉ុន្មានយ៉ាង ។ ព្រះសារីបុត្តមានថេរវាចាថា អានន្ទដ៏មានអាយុ ជាពហុស្សូតស្រាប់ហើយ ចូរអានន្ទដ៏មានអាយុ

សម្តែង ( ខ្លួនឯង ) ចុះ ។ ព្រះអានន្ទមានថេរវាចាថា ម្នាលអាវុសោសារីបុត្ត បើដូច្នោះ លោកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ ខ្ញុំនឹងសម្តែង ។ ព្រះសារីបុត្តដ៏មានអាយុ ក៏បានទទួលស្តាប់ថេរវាចាព្រះអានន្ទដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះអានន្ទដ៏មានអាយុមានថេរវាចា យ៉ាងនេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងអត្ថផង ឈ្លាសក្នុងធម៌ផង ឈ្លាសក្នុងប្រភេទអក្សរផង ឈ្លាសក្នុងភាសាផង ឈ្លាសទាំងដើម ទាំងចុង ( នៃអត្ថនិងធម៌ជាដើម ) ផង ។ ម្នាលអាវុសោសារីបុត្ត ភិក្ខុជាអ្នកពិចារណាឃើញចាប់ក្នុងពួកកុសលធម៌ផង ជាអ្នកកាន់យកនូវធម៌ ដែលខ្លួនកាន់យកដោយល្អផង កាន់យកនូវធម៌បានច្រើនផង មិនភ្លេចធម៌ ដែលខ្លួនកាន់យកហើយផង ដោយហេតុប៉ុណ្ណោះឯង ។ ព្រះសារីបុត្តមានថេរវាចាថា ម្នាលអាវុសោ អស្ចារ្យណាស់ ម្នាលអាវុសោ ចម្លែកណាស់ ពាក្យដែលអានន្ទដ៏មានអាយុពោល មកហើយនេះ ជាសុភាសិតប្រាកដ មួយទៀត យើងនឹងចាំទុកនូវព្រះអានន្ទដ៏មានអាយុថា ជាអ្នកប្រកបដោយធម៌ ៥ យ៉ាងនេះ គឺអានន្ទដ៏មានអាយុ ជាអ្នកឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងដើមទាំងចុង ១ ។

# អដ្ឋកថា

## និសន្តិសូត្រ

[ ៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិសន្តិសូត្រទី ៩ ដូចតទៅនេះ ឈ្មោះថា **ខិប្បនិសំ** ព្រោះកំណត់ចាំបានរហ័ស ។ ឈ្មោះថា **សុគ្គហិតគ្គាហី** ព្រោះទទួលយកល្អហើយ ។ បទថា **អត្ថកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងអដ្ឋកថា ។ បទថា **ធម្មកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងបាលី ។ បទថា **និរុត្តិកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងភាសា ។ បទថា **ព្យញ្ជនកុសលោ** បានដល់ ជាអ្នកឈ្លាសក្នុងប្រភេទនៃអក្ខរៈ ។ បទថា **បុព្វាបរកុសលោ** បានដល់ ជាអ្នកឈ្លាសខាងដើមខាងចុង ៥ គឺខាងដើមខាងចុងនៃអដ្ឋកថា ខាងដើមខាងចុងនៃបាលី ខាងដើមខាងចុងនៃបទ ខាងដើមខាងចុងនៃអក្ខរៈ ខាងដើមខាងចុងនៃអនុសន្ធិ ។ ក្នុងខាងដើមខាងចុងទាំងនោះ ដឹងអត្ថខាងដើមដោយអត្ថខាងចុង ដឹងអត្ថខាងចុង ដោយអត្ថខាងដើម ឈ្មោះថា ជាអ្នកឈ្លាសខាងដើម និងខាងចុងនៃអដ្ឋកថា ។ សេចក្តីនេះដូចម្តេច ឆ្លើយថា ភិក្ខុនោះ កាលលោកវៀរអត្ថខាងដើម ពោលតែអត្ថខាងចុង រមែងដឹងថា អត្ថខាងដើមមានដូច្នេះ កាលលោកវៀរអត្ថខាងចុង ពោលតែអត្ថខាងដើម ក៏ដឹងថា ខាងចុងមានដូច្នេះ កាលលោកវៀរអត្ថទាំង ២ ពោលតែអត្ថកណ្តាល រមែងដឹងអត្ថទាំង ២ មានដូច្នេះ ។ កាលលោកវៀរអត្ថកណ្តាល ពោលតែអត្ថទាំង ២ ចំណែក រមែងដឹងថា អត្ថត្រង់កណ្តាលមានដូច្នេះ ។ ខាងដើម និងខាងចុងនៃបាលី ក៏ន័យនេះដូចគ្នា ។

ក្នុងខាងដើម និងខាងចុងនៃអនុសន្ធិ មានវិនិច្ឆ័យដូចតទៅនេះថា កាលព្រះសូត្រផ្តើមសីលជាខាងដើម ក្នុងទីបំផុត ក៏មកដល់អភិញ្ញា ៦ ភិក្ខុរមែងដឹងថា ព្រះសូត្រទៅតាមអនុសន្ធិ តាមកំណត់បទដូច្នេះ កាលព្រះសូត្រផ្តើមអំពីទិដ្ឋិទៅ ខាងចុងសច្ចៈទាំងឡាយក៏មកដល់ ភិក្ខុរមែងដឹងថា ព្រះសូត្ររមែងទៅតាមអនុសន្ធិ កាលព្រះសូត្រផ្តើមអំពីការជម្លោះ ខាងចុង គឺសារាណីយធម៌ក៏មកដល់ កាលព្រះសូត្រផ្តើមអំពីតិរច្ឆានកថា ៣២ ខាងចុងកថាវត្ថុក៏មកដល់ ភិក្ខុរមែងដឹងថា ព្រះសូត្រទៅតាមអនុសន្ធិ ដូច្នេះ ។ល។

**អដ្ឋកថា និសន្តិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ភទ្ទជិសូត្រទី ១០

[ ៧០ ] សម័យ ១ ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងឃោសិតារាមទៀបក្រុងកោសម្ពី ។ គ្រានោះឯង ព្រះភទ្ទជិដ៏មានអាយុបានចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏បានរីករាយជាមួយនឹងព្រះអានន្ទដ៏មានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររឭកហើយ ក៏គង់ក្នុងទីសមគួរ ។ លុះព្រះភទ្ទជិដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ព្រះអានន្ទដ៏មានអាយុ ក៏មានថេរវាចាយ៉ាងនេះថា ម្នាលអាវុសោភទ្ទជិ ការឃើញដូចម្តេច

ដែលប្រសើរលើសជាងការឃើញទាំងឡាយ ការស្តាប់ដូចម្តេច ដែលប្រសើរលើសជាងការស្តាប់ទាំងឡាយ សុខដូចម្តេច ដែលប្រសើរលើស ជាងសុខទាំងឡាយ ការសម្គាល់ដូចម្តេច ដែលប្រសើរលើស ជាងការសម្គាល់ទាំងឡាយ ទីកើតដូចម្តេច ដែលប្រសើរលើសជាងទីកើតទាំងឡាយ ។ ព្រះកទូដិដ៏មានអាយុមានថេរវាចាតបថា ម្នាលអាវុសោ មានព្រហ្មដែលជាអ្នកគ្របសង្កត់ ( លើព្រហ្មឯទៀត ) ដែលព្រហ្មឯទៀតមិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញ ហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួងឲ្យលុះក្នុងអំណាចខ្លួន ។ បុគ្គលណាឃើញនូវព្រហ្មនោះ ការឃើញនេះ ឈ្មោះថា ប្រសើរលើសជាងការឃើញទាំងឡាយ ។ ម្នាលអាវុសោ មានពួកទេវតាឈ្មោះអាភស្សរៈជ្រួតជ្រាបស្កប់ស្កល់ ដោយសេចក្តីសុខ ពួកទេវតាទាំងនោះ តែងបន្លឺឡើងនូវឧទានក្នុងកាលម្តងៗ ថា ឱហ្ន៎ ចំជាសុខ ចំជាសុខមែន ។ បុគ្គលណា ឮសំឡេងនោះ ការឮនេះ ឈ្មោះថា ប្រសើរលើសជាងការឮទាំងឡាយ ។ ម្នាលអាវុសោ មានពួកទេវតា ឈ្មោះសុភកិណ្ហៈ ពួកទេវតាទាំងនោះ ត្រេកអរតែនឹងសេចក្តីស្ងប់ សោយសេចក្តីសុខ សុខនេះ ឈ្មោះថា ប្រសើរលើសជាងសុខទាំងឡាយ ។ ម្នាលអាវុសោ មានពួកទេវតា ដែលទៅកើតក្នុងអាកិញ្ចញ្ញាយតនភព សេចក្តីសម្គាល់ ( របស់ពួកទេវតា ) នេះឈ្មោះថា ប្រសើរលើសជាងសេចក្តីសម្គាល់ទាំងឡាយ ។ ម្នាលអាវុសោ មានពួកទេវតាដែលទៅកើតក្នុងនេវសញ្ញានាសញ្ញាយតន ភពនេះ ឈ្មោះថា ប្រសើរលើសជាងភព

ទាំងឡាយ ។ សម្តីព្រះភទ្ទជិ ដ៏មានអាយុនេះ សមគ្នានឹងសម្តីរបស់ជនច្រើន ។ អានន្ទដ៏មានអាយុ ជាពហុស្សូតស្រាប់ហើយ ចូរអានន្ទដ៏មានអាយុ សម្តែង ( ខ្លួនឯង ) ចុះ ។ ម្នាលអាវុសោភទ្ទជិ បើដូច្នោះ អ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសម្តែង ។ ព្រះភទ្ទជិដ៏មានអាយុ បានទទួលស្តាប់ថេរវាចាព្រះអានន្ទដ៏មានអាយុថា ករុណា អាវុសោ ។ ព្រះអានន្ទដ៏មានអាយុ បានសម្តែងយ៉ាងនេះថា ម្នាលអាវុសោ បុគ្គលឃើញយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ ការឃើញនេះ ឈ្មោះថា ប្រសើរជាងការឃើញទាំងឡាយ ។ បុគ្គលស្តាប់យ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ ការស្តាប់នេះ ឈ្មោះថា ប្រសើរលើសជាងការស្តាប់ទាំងឡាយ ។ បុគ្គលបាន សុខយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ សុខនេះ ឈ្មោះថា ប្រសើរលើសជាងសុខទាំងឡាយ ។ បុគ្គលមានសេចក្តីសម្គាល់ យ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ សេចក្តីសម្គាល់នេះ ឈ្មោះថា ប្រសើរលើសជាងសេចក្តីសម្គាល់ទាំងឡាយ ។ បុគ្គលកើតយ៉ាងណា ដែលជាហេតុឲ្យអាសវៈទាំងឡាយ អស់ទៅដោយលំដាប់ ទីកើតនេះ ឈ្មោះថា ប្រសើរលើសជាងទីកើតទាំងឡាយ ។

**អាឃាតវគ្គទី ២ ចប់**

**ឧទ្ទាននៃអាឃាតវគ្គនោះ គឺ**

*និយាយអំពីធម៌សម្រាប់កម្ចាត់បង់នូវគំនុំ ២ លើក ភិក្ខុគួរសាកច្ឆា ១ ភិក្ខុគួរដល់សាជីវៈ ១ ការបុច្ឆា ១ ការចូលសញ្ញាវេទយិតនិរោធ ១ ការដាស់តឿន ១ ភិក្ខុវិបត្តិចាកសីល ១ ការពិចារណាធម៌ ១ រឿងព្រះភទ្ទជិ ១ ។*

# អដ្ឋកថា

## ភទ្ទជិសូត្រ

*[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភទ្ទជិសូត្រទី ១០ ដូចតទៅនេះ បទថា* **អភិភូ** *បានដល់ គ្របសង្កត់ហើយតាំងនៅ គឺជាធំ ។ បទថា* **អនភិភូតោ** *បានដល់ ដែលបុគ្គលដទៃគ្របសង្កត់មិនបាន ។ បទថា* **អញ្ញទត្ថុ** *ជានិបាតប្រើក្នុងពាក្យថា ចំណែកមួយ ។ អធិប្បាយថា ឃើញដោយទស្សនៈ រមែងឃើញទាំងអស់ ។ បទថា* **វសវត្តី** *បានដល់ ញុំាងជនទាំងអស់ឲ្យនៅក្នុងអំណាច ។ បទថា* **យថា បស្សតោ** *បានដល់ ឃើញអាការរបស់អារម្មណ៍មិនថា ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ ។ បទថា* **អនន្តរា អាសវានំ ខយោ ហោតិ** *បានដល់ អរហត្តរមែងកើតឡើងក្នុងលំដាប់នោះឯង ។ ក្នុងបទថា* **យថា សុណតោ** *នេះ ក៏មានន័យដូចគ្នា ។ ម្យ៉ាងទៀត ភិក្ខុឃើញរូបឯណា*

ដោយចក្ខុហើយ ផ្តើមតាំងវិបស្សនា សម្រេចអរហត្ត ក្នុងលំដាប់ជាប់តគ្នានោះឯង អរហត្តរបស់ភិក្ខុនោះ ឈ្មោះថា មានក្នុងលំដាប់នៃចក្ខុវិញ្ញាណ ព្រះអានន្ទសំដៅដល់អរហត្តនោះ ទើបពោលថា នេះជាកំពូលនៃការឃើញ ។ ក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។

បទថា **យថា សុខិតស្ស** បានដល់ ដល់នូវសេចក្តីសុខ ដោយមគ្គសុខណា ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** បានដល់ អរហត្តរមែងកើតឡើងក្នុងលំដាប់នៃមគ្គសុខនោះឯង ។ បទថា **ឯតំ សុខានំ អគ្គំ** បានដល់ មគ្គសុខនេះ ជាកំពូលនៃសេចក្តីសុខទាំងឡាយ ។ ក្នុងបទថា **យថា-សញ្ញិស្ស** នេះ លោកបំណងយកមគ្គសញ្ញានោះឯង ។ បទថា **យថាភូតស្ស** បានដល់ តាំងនៅហើយក្នុងភពណា គឺក្នុងអត្តភាពណា ។ បទថា **អនន្តរា** បានដល់ ព្រះអរហត្តកើតឡើងហើយក្នុងលំដាប់នោះឯង ។ បទថា **ឯតំ ភវានំ អគ្គំ** បានដល់ អត្តភាពចុងក្រោយនេះ ឈ្មោះថា ជាកំពូលនៃភពទាំងឡាយ ។ ន័យម្យ៉ាងទៀត បទថា **យថាភូតស្ស** បានដល់ កើត គឺមានក្នុងខណៈនៃមគ្គចិត្ត ដោយខន្ធទាំងឡាយណា ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** បានដល់ ផលរមែងកើតឡើងក្នុងលំដាប់នៃមគ្គនោះឯង ។ បទថា **ឯតំ ភវានំ អគ្គំ** បានដល់ ខន្ធបញ្ចកៈ ក្នុងខណៈនៃមគ្គចិត្តនេះ ឈ្មោះថា ជាកំពូលនៃភពទាំងឡាយ ដោយប្រការដូច្នេះ ៕៙

**អដ្ឋកថា ភទ្ទជិសូត្រទី ១០ ចប់**

**អាឃាតវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ឧបាសកវគ្គ

### សារជ្ជសូត្រទី ១

[ ៧១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគត្រាស់ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណា ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមានចិត្តចុះ កាន់សេចក្តីញញើតញញើម ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជា អ្នកសម្លាប់សត្វ ១ ជាអ្នកកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ជាអ្នកប្រព្រឹត្ត ខុសក្នុងកាមទាំងឡាយ ១ ជាអ្នកនិយាយពាក្យកុហក ១ ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមានចិត្តចុះកាន់សេចក្តី ញញើតញញើម ។ ម្នាលភិក្ខុទាំងឡាយ ឧបាសក ប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកក្លៀវក្លា ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកវៀរចាក បាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយ

ធម៌ ៥ យ៉ាងនេះឯង ជាអ្នកក្លៀវក្លា ។

# វិសារទសូត្រទី ២

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកមិនក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកសម្លាប់សត្វ ១ ។បេ។ ជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកមិនក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកវៀរចាកបាណាតិបាត ១ ។បេ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាអ្នកក្លៀវក្លា នៅគ្រប់គ្រងផ្ទះ ។

# និរយសូត្រទី ៣

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងរមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ចោល ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកសម្លាប់សត្វ ១ ។បេ។ ជាអ្នកផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ចោល ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥

យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺ ឧបាសកជាអ្នកវៀរចាកបាណាតិបាត ១ ។បេ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។

# អដ្ឋកថា

## ឧបាសកវគ្គទី ៣

### អដ្ឋកថា សារជ្ជសូត្រទី ១ ជាដើម

[ ៧១-៧៣ ] ក្នុងសារជ្ជសូត្រទី ១ ជាដើមនៃឧបាសកវគ្គ ទី ៣ លោកពោលដល់អគារិយបដិបត្តិ គឺការបដិបត្តិរបស់អ្នកគ្រប់គ្រងផ្ទះ ។ សូម្បីព្រះសោតាបន្ន ព្រះសកទាគាមី អគារិយបដិបត្តិ ក៏រមែងគួរទាំងអស់ ។l

### អដ្ឋកថា សារជ្ជសូត្រទី ១ ជាដើមចប់

# សុត្តន្តបិដក

## វេរសូត្រទី ៨

[ ៧៤ ] គ្រានោះឯង អនាថបិណ្ឌិកគហបតី បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលគហបតី បុគ្គលមិនបានលះបង់នូវភ័យ នូវពៀរ ៥ យ៉ាង ហៅថា ជាអ្នកទ្រុស្តសីលផង តែងទៅកើតក្នុងនរកផង ។ ពៀរ ៥ យ៉ាង តើដូចម្តេច ។ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលគហបតី បុគ្គលមិនបានលះនូវភ័យ នូវពៀរ ៥ យ៉ាងនេះឯង ហៅថា ជាអ្នកទ្រុស្តសីលផង តែងទៅកើតក្នុងនរកផង ។ ម្នាលគហបតី បុគ្គលបានលះនូវភ័យ នូវពៀរ ៥ យ៉ាង ហៅថា ជាអ្នកមានសីលផង តែងទៅកើតក្នុងសុគតិផង ។ ពៀរ ៥ យ៉ាង តើដូចម្តេច ។ គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ សុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ ម្នាលគហបតី បុគ្គលលះនូវភ័យ នូវពៀរ ៥ យ៉ាងនេះឯង ហៅថា ជាអ្នកមានសីលផង តែងទៅកើតក្នុងសុគតិផង ។ ម្នាលគហបតី បុគ្គលអ្នកសម្លាប់សត្វ តែងបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង បាននូវភ័យ នូវពៀរទៅខាងមុខផង ទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យគឺ បាណាតិបាតណា បុគ្គលវៀរចាកបាណាតិបាតនោះហើយ រមែងមិនបាននូវភ័យ នូវពៀរជា

បច្ចុប្បន្នផង មិនបាននូវភ័យ នូវពៀរទៅខាងមុខផង មិនទទួលទុក្ខទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ។ បុគ្គលវៀរចាកបាណាតិបាតហើយ ភ័យ ពៀរនោះ រមែងស្ងប់រម្ងាប់ដោយប្រការយ៉ាងនេះ ។ ម្នាលគហបតី បុគ្គលអ្នកកាន់យក របស់ដែលគេមិនបានឲ្យ ... ម្នាលគហបតី បុគ្គលអ្នកប្រព្រឹត្តខុស ក្នុងកាម ទាំងឡាយ ... ម្នាលគហបតី បុគ្គលអ្នកនិយាយកុហក ... ម្នាលគហបតី បុគ្គលអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាទីតាំងនៃសេចក្តីធ្វេសប្រហែស រមែងបាននូវភ័យ នូវពៀរជាបច្ចុប្បន្នផង បាននូវភ័យ នូវពៀរទៅខាងមុខផង ទទួលទុក្ខទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ព្រោះបច្ច័យ គឺសុរាមេរយមជ្ជ-ប្បមាទដ្ឋានណា បុគ្គលវៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាននោះ រមែងមិនបាន នូវភ័យ នូវពៀរជាបច្ចុប្បន្នផង មិនបាននូវភ័យនូវពៀរទៅខាងមុខផង មិនទទួល ទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តផង ។ បុគ្គលវៀរចាកសុរាមេរយមជ្ជប្ប-មាទដ្ឋានហើយ ភ័យ ពៀរនោះ រមែងស្ងប់រម្ងាប់ ដោយប្រការយ៉ាងនេះ ។

នរៈណាសម្លាប់សត្វផង និយាយពាក្យកុហកផង កាន់
យកទ្រព្យដែលគេមិនបានឲ្យ ក្នុងលោកផង ក្បត់នឹង
ប្រពន្ធជនដទៃផង ប្រកបនូវការផឹកសុរានិងមេរ័យផង
នរៈអ្នកមិនបានលះនូវពៀរ ៥ យ៉ាងនោះ ហៅថាជា
អ្នកទ្រុស្តសីល ជាអ្នកអប្បឥតបញ្ញា លុះបែកធ្លាយ
រាងកាយ រមែងទៅកើតក្នុងនរក ។ នរៈណាមិនសម្លាប់

សត្វ មិននិយាយកុហក មិនកាន់យកទ្រព្យដែលគេមិន
បានឲ្យក្នុងលោកមិនក្បត់នឹងប្រពន្ធជនដទៃនិងមិនប្រកប
នូវការផឹកសុរា និងមេរ័យ នរៈអ្នកបានលះនូវពៀរ ៥
យ៉ាងនោះ ហៅថាជាអ្នកមានសីល ជាអ្នកប្រកបដោយ
បញ្ញា លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងសុគតិ ។

# អដ្ឋកថា

## វេរសូត្រ

[ ៧៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវេរសូត្រទី ៤ ដូចតទៅនេះ បទថា **ភយានិ** បានដល់ ភ័យដែលធ្វើឲ្យចិត្តតក់ស្លុតហើយ ។ បទថា **វេរានិ** បានដល់ អកុសលវេរក្ខៈ បុគ្គលវេរក្ខៈ ។ បទថា **ចេតសិកំ** បានដល់ ទុក្ខអាស្រ័យចិត្ត ។ បទថា **ទុក្ខំ** បានដល់ ទុក្ខដែលមានកាយបសាទជាទីតាំង ។ បទថា **ទោមនស្សំ** បានដល់ ទោមនស្សវេទនា ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់នូវការលះ ដោយវិរតិចេតនា គឺចេតនាវៀរបាក ។ល។

**អដ្ឋកថា វេរសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ចណ្ឌាលសូត្រទី ៥

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសក ជាអ្នកមិនមានសទ្ធា ១ ជាអ្នកទ្រុស្តសីល ១ ប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែមង្គល មិនជឿកម្ម ១ ស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ហើយធ្វើបុណ្យនឹងទក្ខិណេយ្យបុគ្គលនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា ចណ្ឌាលឧបាសកផង ឈ្មោះថា មលឧបាសកផង ឈ្មោះថា បដិកិដ្ឋឧបាសកផង ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។ ធម៌ ៥ យ៉ាង តើដូចម្តេច ។ គឺឧបាសកជាអ្នកមានសទ្ធា ១ ជាអ្នកមានសីល ១ ជាអ្នកមិនប្រកាន់មង្គលភ្ញាក់ផ្អើល ១ ជឿតែកម្ម មិនជឿមង្គល ១ មិនស្វែងរកទក្ខិណេយ្យបុគ្គល ខាងក្រៅពុទ្ធសាសនា ធ្វើបុណ្យតែក្នុងពុទ្ធសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថា រតនឧបាសកផង ឈ្មោះថា បទុមឧបាសកផង ឈ្មោះថា បុណ្ឌរីកឧបាសកផង ។

# អដ្ឋកថា

## ចណ្ឌាលសូត្រ

[ ៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចណ្ឌាលសូត្រទី ៥ ដូចតទៅនេះ បទថា **ឧបាសកបច្ឆិមកោ** បានដល់ ជាឧបាសកជាន់ទាប ។ បទថា **កោតុហលមង្គលិកោ** គឺជាអ្នកប្រកបដោយអារម្មណ៍ដែលបានឃើញ បានស្តាប់ បានលិទ្ធភ្លក្ស ជាមង្គល បានដល់ ភ្ញាក់ផ្អើល ព្រោះប្រព្រឹត្តទៅយ៉ាងនេះថា វត្ថុនេះមានដោយហេតុនេះ ដូច្នេះ ។ បទថា **មង្គលំ បច្ចេតិ នោ កម្មំ** បានដល់ សម្លឹងមើលតែរឿងមង្គល មិនមើលរឿងកម្ម ។ បទថា **ឥតោ ច ពហិទ្ធា** បានដល់ ខាងក្រៅសាសនានេះ ។ បទថា **បុព្វការំ ករោតិ** បានដល់ ធ្វើកុសលកិច្ច មានទានជាដើមមុន ៕

**អដ្ឋកថា ចណ្ឌាលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បីតិសូត្រទី ៦

[ ៧៦ ] គ្រានោះ អនាថបិណ្ឌិកគហបតីមានឧបាសកប្រមាណប្រាំរយជាបរិវារ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះថា ម្នាលគហបតី ពួកអ្នកបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និង គិលានប្បច្ចយភេសជ្ជបរិក្ខារហើយ ។ ម្នាលគហបតី ពួកអ្នកមិនគួរធ្វើសេចក្តីត្រេកអរដោយគ្រាន់តែគិតថា ពួកយើងបានទំនុកបម្រុងភិក្ខុសង្ឃដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារប៉ុណ្ណោះឡើយ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នកត្រូវសិក្សាយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ពួកយើងនឹងបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ក្នុងកាលដ៏គួរ ។ ម្នាលគហបតី ពួកអ្នកត្រូវសិក្សាយ៉ាងនេះឯង ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះពេញជាសុភាសិតដែលព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលគហបតី ពួកអ្នកបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារហើយ ។ ម្នាលគហបតី ពួកអ្នកមិនគួរធ្វើសេចក្តីត្រេកអរ ដោយគ្រាន់តែគិត

ថា ពួកយើងបានទំនុកបម្រុងភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារប៉ុណ្ណោះឡើយ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នកត្រូវសិក្សាយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ ពួកយើងនឹងបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ក្នុងកាលដ៏គួរ ។ ម្នាលគហបតី ពួកអ្នកត្រូវសិក្សាយ៉ាងនេះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យណា អរិយសាវកបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាង មិនមានដល់អរិយសាវកនោះឡើយ គឺទុក្ខ ទោមនស្សណាដែលជាគ្រឿងប្រកបដោយកាមរបស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយកាមរបស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយអកុសល របស់អរិសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យណា អរិយសាវក បានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាងនេះ មិនមានដល់អរិយសាវកនោះឡើយ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត សម័យណា អរិយសាវកបានចូលកាន់បីតិដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាង មិនមានដល់អរិយសាវកនោះឡើយ គឺទុក្ខ ទោមនស្សណា ដែលប្រកបដោយកាម របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយកាម របស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយអកុសល របស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ សុខ សោមនស្សណា ដែលប្រកបដោយអកុសលរបស់អរិយសាវកនោះ សុខ សោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ទុក្ខ ទោមនស្សណា ដែលប្រកបដោយកុសលរបស់អរិយសាវកនោះ ទុក្ខ ទោមនស្សនោះ មិនមានដល់អរិយសាវកនោះ ក្នុងសម័យនោះ ១ ។ ម្នាលសារីបុត្ត សម័យណា អរិយសាវកបានចូលកាន់បីតិ ដ៏ស្ងប់ស្ងាត់ សម័យនោះ ហេតុ ៥ យ៉ាងនេះឯង មិនមានដល់អរិយសាវកនោះឡើយ ។

# អដ្ឋកថា

## បីតិសូត្រ

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបីតិសូត្រទី ៦ ដូចតទៅនេះ បទថា **កិត្តិមយំ** បានដល់ អាត្មាអញគប្បីចូលដល់វិវេកបីតិ ដោយឧបាយណា ។ បទថា **បវិវេកបីតី** បានដល់ បីតិដែលអាស្រ័យបឋមជ្ឈាន និងទុតិយជ្ឈានកើតឡើង ។ បទថា **កាមូបសញ្ហិតំ** បានដល់ ទុក្ខអាស្រ័យកាម គឺអាស្រ័យកាម ២ យ៉ាង ប្រារព្ធកាម ២ យ៉ាងកើតឡើង ។ បទថា **អកុសលូបសញ្ហិតំ** សេចក្តីថា កាលគិតថា អញនឹងបាញ់ម្រឹគ ជ្រូកជាដើម ដូច្នេះ បាញ់ព្រួញខុសទៅ ទុក្ខទោមនស្សអាស្រ័យអកុសលយ៉ាងនេះថា អញបាញ់ខុសទៅហើយ ដូច្នេះ កើតឡើង ឈ្មោះថា ប្រកបដោយអកុសល ។ កាលបាញ់មិនខុសក្នុងឋានៈបែបនោះ សុខសោមនស្សកើតឡើងថា អញបាញ់ល្អហើយ អញប្រហារល្អហើយ ដូច្នេះ ឈ្មោះថា ប្រកបដោយអកុសល ។ តែទុក្ខទោមនស្សដែលកើតឡើង ព្រោះឧបករណ៍ មានទានជាដើម មិនទាន់ព្រម គប្បីជ្រាបថា ប្រកបដោយកុសល ។

### អដ្ឋកថា បីតិសូត្រទី ៦ ចប់

# សុត្តន្តបិដក

## វណិជ្ជសូត្រទី ៧

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះ ឧបាសកមិនគួរធ្វើឡើយ ។ ជំនួញ ៥ យ៉ាង តើដូចម្តេច ។ គឺការជួញគ្រឿងសស្ត្រាវុធ ១ ការជួញមនុស្ស ១ ការជួញ ( សត្វដែលគេសម្លាប់យក ) សាច់ ១ ការជួញគ្រឿងស្រវឹង ១ ការជួញថ្នាំពិស ១ ។ ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ ប្រការនេះឯង ឧបាសកមិនគួរធ្វើឡើយ ។

# អដ្ឋកថា

## វណិជ្ជសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវណិជ្ជសូត្រទី ៧ ដូចតទៅនេះ បទថា **វណិជ្ជា** បានដល់ ធ្វើការលក់ដូរ ។ បទថា **ឧបាសកេន** បានដល់ បុគ្គលដល់សរណៈ ៣ ។ បទថា **សត្ថវណិជ្ជា** បានដល់ ឲ្យគេធ្វើអាវុធ ហើយក៏លក់អាវុធនោះ ។ បទថា **សត្តវណិជ្ជា** បានដល់ លក់មនុស្ស ។ បទថា **មំសវណិជ្ជា** បានដល់ ចិញ្ចឹមជ្រូក និងម្រឹគលក់ជាដើម ។ បទថា **មជ្ជវណិជ្ជា** បានដល់ ឲ្យគេធ្វើគ្រឿងស្រវឹងណាមួយ ហើយក៏លក់គ្រឿងស្រវឹង ។ បទថា **វិសវណិជ្ជា** បានដល់ ឲ្យគេធ្វើថ្នាំពុល ហើយក៏លក់នូវថ្នាំពុលនោះ ។ ការធ្វើដោយខ្លួនឯង ការដឹកនាំឲ្យអ្នកដទៃធ្វើការលក់ ទាំងអស់នេះ មិនគួរដោយ

ប្រការដូច្នេះ ។ល។

អដ្ឋកថា វណិជ្ជសូត្រទី ៧ ចប់

# សុត្តន្តបិដក

## រាជសូត្រទី ៨

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះដូចម្ដេច អ្នកទាំងឡាយដែលឃើញ ដែលឮថា បុរសនេះបានលះបាណាតិបាត វៀរចាកបាណាតិបាត ស្ដេចទាំងឡាយចាប់បុរសនោះហើយ សម្លាប់ ចង បណ្ដេញ ឬធ្វើឲ្យគួរតាមទោស ព្រោះហេតុតែវៀរចាកបាណាតិបាតដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនដែលមានទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតក៏មិនដែលឃើញ មិនដែលឮហេតុនុ៎ះថា បុរសនេះបានលះបង់បាណាតិបាត វៀរចាកបាណាតិបាត ស្ដេចទាំងឡាយ ចាប់នូវបុរសនោះហើយ សម្លាប់ ចង បណ្ដេញ ឬធ្វើឲ្យគួរតាមទោស ព្រោះហេតុតែវៀរចាកបាណាតិបាតដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះសម្លាប់ប្រុសឬស្រីចាកជីវិត ស្ដេចទាំងឡាយចាប់បុរសនោះ សម្លាប់ ចង បណ្ដេញ ឬធ្វើឲ្យសមគួរតាមទោស ព្រោះហេតុតែបាណាតិបាត ។ អ្នកទាំងឡាយដែលឃើញ ដែលឮបែបនេះ ដែរឬទេ ។

បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គដែលឃើញ ដែលឮរួចមកហើយ គង់នឹងឮតទៅទៀត មិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះ ថាដូចម្តេច អ្នកទាំងឡាយ ដែលឃើញ ដែលឮថា បុរសនេះបានលះនូវអទិន្នាទាន វៀរចាកអទិន្នាទាន ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ផង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកអទិន្នា-ទាន ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគត ក៏មិនដែលបានឃើញ មិនដែលបានឮ នូវហេតុនុ៎ះថា បុរសនេះបានលះអទិន្នាទាន វៀរចាកអទិន្នាទាន ស្តេចទាំងឡាយ ចាប់បុរសនោះហើយសម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកអទិន្នាទានដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះ កាន់យកទ្រព្យដែលគេមិនបានឲ្យក្នុងស្រុកឬក្នុងព្រៃ ដោយចំណែកនៃចិត្តលួច ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែអទិន្នាទាន ។ អ្នកទាំងឡាយ ដែលបានឃើញ ឬបានឮបែបយ៉ាងនេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានឃើញ បានឮរួចមកហើយគង់នឹងឮតទៅទៀតមិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះថាដូចម្តេច អ្នកទាំងឡាយ ដែលបានឃើញ បានឮថា បុរសនេះបានលះបង់នូវកាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ស្តេចទាំងឡាយ

ចាប់បុរសនោះហើយសម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកកាមេសុមិច្ឆាចារដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតក៏មិនដែលបានឃើញ មិនដែលបានឮនូវហេតុនុ៎ះថា បុរសនេះ បានលះបង់នូវកាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ស្តេចទាំងឡាយចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកកាមេសុមិច្ឆាចារដែរ ។ មួយទៀត អ្នកផងតែងដឹងនូវបាបកម្ម របស់បុរសនោះថា បុរសនេះដល់នូវសេចក្តីប្រព្រឹត្ត ក្នុងពួកស្ត្រីនៃជនដទៃ និងពួកកុមារីនៃជនដទៃ ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែកាមេសុមិច្ឆាចារ ។ អ្នកទាំងឡាយ ដែលបានឃើញ បានឮបែបនេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀត មិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់នូវហេតុនោះថា ដូចម្តេច អ្នកទាំងឡាយ ដែលបានឃើញ បានឮថា បុរសនេះបានលះមុសាវាទ វៀរចាកមុសាវាទ ស្តេចទាំងឡាយ ចាប់នូវបុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកមុសាវាទដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគត ក៏មិនដែលបានឃើញ មិនដែលបានឮ នូវហេតុនុ៎ះថា បុរសនេះ

បានលះមុសាវាទ វៀរចាកមុសាវាទ ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកមុសាវាទដែរ ។ មួយទៀត អ្នកផង តែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះកាច់បង់នូវប្រយោជន៍របស់គហបតី ឬគហបតិបុត្ត ដោយពាក្យមុសាវាទ ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ។ អ្នកទាំងឡាយ ដែលបានឃើញ បានឮបែបនេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គ ដែលបានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀតមិនខាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សម្គាល់សេចក្តីនោះថាដូចម្តេច អ្នកទាំងឡាយ ដែលបានឃើញ បានឮថា បុរសនេះបានលះបង់នូវសុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ស្តេចទាំងឡាយ ចាប់បុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាកសុរាមេរយ-មជ្ជប្បមាទដ្ឋានដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដែលបានឃើញ មិនដែលបានឮសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ទោះបីតថាគតក៏មិនដែលបានឃើញ មិនដែលបានឮនូវហេតុនុ៎ះថា បុរសនេះបានលះនូវសុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ស្តេចទាំងឡាយ ចាប់នូវបុរសនោះហើយ សម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែវៀរចាក សុរាមេរយមជ្ជប្បមាទដ្ឋានដែរ ។ មួយទៀត អ្នកផង តែងដឹងនូវបាបកម្មរបស់បុរសនោះថា បុរសនេះប្រកបនូវសុរាមេរយមជ្ជប្ប-

មាទដ្ឋានហើយ ផ្តាច់ផ្តិលនូវស្ត្រីឬបុរសចាកជីវិត បុរសនេះប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ កាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ក្នុងស្រុកឬក្នុងព្រៃដោយចំណែកនៃចិត្តលួច បុរសនេះប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ ដល់នូវការប្រព្រឹត្តិក្នុងពួកស្ត្រីនៃជនដទៃ ក្នុងពួកកុមារីនៃជនដទៃ បុរសនេះ ប្រកបនូវសុរាមេរយមជ្ជប្បមាទដ្ឋានហើយ កាច់បង់នូវប្រយោជន៍របស់គហបតី ឬគហបតិបុត្តដោយមុសាវាទ ស្តេចទាំងឡាយចាប់បុរសនោះហើយសម្លាប់ ចង បណ្តេញ ឬធ្វើតាមទោស ព្រោះហេតុតែសុរាមេរយមជ្ជប្បមាទដ្ឋាន ។ អ្នកទាំងឡាយ ដែលបានឃើញ បានឮ បែបនេះដែរឬទេ ។ បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គ បានឃើញ បានឮរួចមកហើយ គង់នឹងឮតទៅទៀតមិនខាន ។

# អដ្ឋកថា

## រាជសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរាជសូត្រទី ៨ ដូចតទៅនេះ បទថា **បព្វាជេន្តិ** គឺឲ្យបណ្តេញចាកដែន ។ បទថា **យថាបច្ចយំ វា ករោន្តិ** បានដល់ធ្វើតាមបំណង ធ្វើតាមអធ្យាស្រ័យ ។ បទថា **តថេវ ចាបកម្មំ បវេទេន្តិ** បានដល់ ពោលនូវកម្មដែលបុគ្គលនោះធ្វើដល់អ្នកដទៃ ។ល។

**អដ្ឋកថា រាជសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## គិហិសូត្រទី ៩

[ ៧៩ ] គ្រានោះ អនាថបិណ្ឌិកគហបតីមានឧបាសកប្រមាណប្រាំរយជាបរិវារ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគបានត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ពួកអ្នកគួរដឹងនូវគ្រហស្ថទីមួយ ដែលស្លៀកស មានការរ៉ោរសង្រួម ក្នុងសិក្ខាបទទាំង ៥ ប្រការផង បានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្តជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទាំង ៤ ផង កាលបើគ្រហស្ថនោះ ប្រាថ្នាព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល មិនមានការធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងមានសេចក្តីត្រាស់ដឹងទៅខាងមុខ ។ គ្រហស្ថដែលមានការរ៉ោរសង្រួម ក្នុងសិក្ខាបទទាំង ៥ ប្រការ តើដូចម្តេច ។ ម្នាលសារីបុត្ត អរិយសាវកក្នុងសាសនានេះ ជាអ្នកវៀរចាកបាណាតិបាត ១ វៀរចាកអទិន្នាទាន ១ វៀរចាកកាមេសុមិច្ឆាចារ ១ វៀរចាកមុសាវាទ ១ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ១ ។ គ្រហស្ថជាអ្នកមានការរ៉ោរសង្រួម ក្នុងសិក្ខាបទទាំង ៥ នេះ ។ គ្រហស្ថជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានមិនក្រ នូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទាំង ៤ តើដូចម្តេច ។ ម្នាលសារីបុត្ត

អរិយសាវកក្នុងសាសនានេះ ប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងដោយប្រពៃ បរិបូណ៌ដោយវិជ្ជា និងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរបំផុត ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ដូច្នេះ ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទី ១ ដែលអរិយសាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្តដែលមិនទាន់បរិសុទ្ធ ឲ្យបរិសុទ្ធ និងនាំឲ្យចិត្តដែលមិនទាន់ផូរផង់ ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកប ដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ថា ធម៌ដែលព្រះដ៏មានព្រះភាគ សម្ដែងហើយដោយប្រពៃ ជាធម៌ដែលព្រះអរិយបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន ជាធម៌គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បីដឹងដោយខ្លួនឯង ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន ដ៏ប្រកបដោយចេតសិកដ៏ខ្ពង់ខ្ពស់ទី ២ ដែលអរិយសាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្តដែលមិនទាន់បរិសុទ្ធ ឲ្យបរិសុទ្ធ និងនាំឲ្យចិត្តដែលមិនទាន់ផូរផង់ ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះសង្ឃថា ពួកសាវករបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយប្រពៃ ពួកសាវករបស់ព្រះដ៏មានព្រះភាគប្រតិបត្តិដោយត្រង់ ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន

ពួកសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដ៏សមគួរ ពួកសាវកនោះ បើរាប់ជាគូនៃបុរសមាន ៤ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួកសាវករបស់ព្រះដ៏មានព្រះភាគនុ៎ះ លោកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា លោកគួរទទួលនូវអាគន្តុកទាន លោកគួរទទួលនូវទក្ខិណាទាន ជាបុគ្គលដែលសត្វលោក គប្បីធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោកដូច្នេះ ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ទី ៣ ដែលអរិយសាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្តដែលមិនទាន់បរិសុទ្ធ ឲ្យបរិសុទ្ធ និងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ ឲ្យផូរផង់ ។ ម្នាលសារីបុត្ត មួយទៀត អរិយសាវកប្រកបដោយសីលទាំងឡាយ ជាទីគាប់ចិត្តរបស់ព្រះអរិយៈ ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរបស់មនុស្សអ្នកជា ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិ ជាសីលញ៉ាំងសមាធិឲ្យប្រព្រឹត្តទៅបាន ។ នេះជាការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន ដ៏ប្រកបដោយចេតសិកដ៏ខ្ពង់ខ្ពស់ទី ៤ ដែលអរិយសាវកនោះ បានចួបប្រទះហើយ នាំឲ្យចិត្តដែលមិនទាន់បរិសុទ្ធ ឲ្យបរិសុទ្ធ និងនាំឲ្យចិត្ត ដែលមិនទាន់ផូរផង់ ឲ្យផូរផង់ ។ គ្រហស្ថដែលជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានមិនក្រនូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ ៤ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត អ្នកត្រូវដឹងនូវគ្រហស្ថណាមួយ ដែលជាអ្នកស្លៀកស មានការសង្រួម ក្នុងសិក្ខាបទទាំង ៥ នេះផង បានតាមប្រាថ្នា បានមិនលំបាក បាន

មិនក្រនូវការសម្រេចសម្រាន្ត ជាសុខក្នុងបច្ចុប្បន្ន អាស្រ័យនូវចេតសិកដ៏ខ្ពង់ខ្ពស់ ៤ យ៉ាងនេះផង កាលបើគ្រហស្ថនោះ ប្រាថ្នាព្យាករខ្លួនឯង ដោយខ្លួនឯងថា អាត្មាអញអស់នរកហើយ អស់កំណើតតិរច្ឆានហើយ អស់បិត្តិវិស័យហើយ អស់អបាយទុគ្គតិវិនិបាតហើយ អាត្មាអញជាសោតាបន្នបុគ្គល មានការមិនបានធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានសេចក្តីត្រាស់ដឹងទៅខាងមុខដូច្នេះ ។

បើអ្នកប្រាជ្ញ ឃើញភ័យក្នុងនរកហើយ ត្រូវវៀរបាប
ទាំងឡាយ សមាទាននូវអរិយធម៌ ( សីល ៥ ) ។
កាលបើមានសេចក្តីព្យាយាម មិនត្រូវបៀតបៀនសត្វ
ទាំងឡាយផង កាលដឹង មិនត្រូវនិយាយកុហកផង មិន
ត្រូវកាន់យកទ្រព្យដែលគេមិនបានឲ្យផង ត្រូវសន្តោស
តែនឹងកិរិយារបស់ខ្លួន មិនត្រូវត្រេកត្រអាលនឹងកិរិយា
របស់ជនដទៃផង មិនត្រូវផឹកមេរ័យ និងសុរា ដែលនាំ
ចិត្តឲ្យវង្វេងផង ។ បុគ្គលគួររឭកនូវព្រះសម្ពុទ្ធផង ត្រិះរិះ
នូវធម៌ឲ្យរឿយៗ ផង ចម្រើនចិត្តដែលជាប្រយោជន៍
មិនមានព្យាបាទ ដើម្បីប្រយោជន៍ដល់ទេវលោកផង ។
កាលបើមានទេយ្យធម៌គ្រប់គ្រាន់ បុគ្គលអ្នកត្រូវការ
បុណ្យ អ្នកស្វែងរកបុណ្យ បានឲ្យទាន ចំពោះពួក
សប្បុរស ជាមុនហើយ ទាននោះ ជាទានមានផល

បរិបូណ៌ ។ ម្នាលសារីបុត្ត តថាគតនឹងសម្តែងនូវពួក
សប្បុរស អ្នកចូរស្តាប់តថាគតចុះ គោឈ្មោលកើតក្នុង
មេគោណាមួយ ទោះសម្បុរខ្មៅក្តី សក្តី ក្រហមក្តី
លឿងក្តី ពព្រុសក្តី មានរូបប្រហែលនឹងកូនរបស់ខ្លួន
ក្តី ប្រផេះក្តី ដែលគេបង្វឹកបានបទហើយ ជាសត្វអាច
នាំទៅនូវធុរៈបាន បរិបូណ៌ដោយកម្លាំង មានល្បឿន
ដ៏ពូកែ ពួកជនទឹមគោនោះក្នុងភារៈ គេមិនរើសអើង
សម្បុរនៃគោនោះឡើយ មានឧបមាយ៉ាងណាមិញ
បុគ្គលមានមារយាទល្អ កើតក្នុងស្ត្រីណាមួយ ទោះបី
ជាក្សត្រ ឬព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល
បុក្កុសៈ តែបានទូន្មានល្អ ប្រដៅងាយ តាំងនៅក្នុង
ធម៌ បរិបូណ៌ដោយសីល ពោលពាក្យសច្ចៈ មានចិត្ត
ប្រកបដោយហិរិ លះបង់នូវការកើត និងស្លាប់ មាន
ព្រហ្មចរិយៈពេញលេញ ទម្លាក់ចោលនូវភារៈ ប្រាស
ចាកគ្រឿងសៅហ្មង ធ្វើនូវកិច្ចស្រេច មិនមានអាសវៈ
ចេះចប់ធម៌ទាំងពួង រលត់ទុក្ខ ព្រោះមិនប្រកាន់ទាន
( ដែលទាយកឲ្យ ) ចំពោះបុគ្គលដែលជាបុញ្ញក្ខេត្ត
ប្រាសចាកធូលីនោះ ជាទានមានផលពេញបរិបូណ៌ ក៏
មានឧបមេយ្យ យ៉ាងនោះដែរ ។ ពួកជនពាល ដែល

មិនដឹង ឥតប្រាជ្ញា គ្មានការស្តាប់ តែងឲ្យទានខាងក្រៅ មិនចូលទៅអង្គុយជិត ពួកសប្បុរសឡើយ ។ ជនពួកណា តែងចូលទៅអង្គុយជិតពួកសប្បុរស ដែលប្រកបដោយប្រាជ្ញា ដែលអ្នកប្រាជ្ញសន្មតហើយ ជនពួកនោះ រមែងមានសទ្ធាជាមូល ប្រតិស្ឋានក្នុងព្រះសុគត មិនតែប៉ុណ្ណោះ ជនពួកនោះ រមែងទៅកាន់ទេវលោក ឬកើតក្នុងត្រកូលនាលោកនេះ រមែងជាបណ្ឌិតដល់នូវព្រះនិព្វាន ដោយលំដាប់ ។

# អដ្ឋកថា

## គិហិសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគិហិសូត្រទី ៩ ដូចតទៅនេះ បទថា **សំវុតកម្មន្តំ** គឺមានការងារដែលរាំងហើយ ។ បទថា **អាភិចេតសិកានំ** គឺអាស្រ័យចិត្តខ្ពស់ ។ បទថា **ទិដ្ឋធម្មសុខវិហារានំ** បានដល់ នៅជាសុខក្នុងធម៌ដែលប្រចក្ស គឺក្នុងបច្ចុប្បន្ននេះឯង ។ បទថា **អរិយកន្តេហិ** បានដល់ សីលក្នុងមគ្គផលដែលអរិយៈទាំងឡាយប្រាថ្នាហើយ ។ លោកពោលសីល ៥ ជាអរិយធម៌ ក្នុងបទថា **អរិយធម្មំ សមាទាយ** នេះ ។ បទថា **មេរយំ វារុណី** បានដល់ មេរ័យ ៤ យ៉ាង និងសុរា ៥ យ៉ាង ។ បទថា **ធម្មញ្ញានុវិតក្កយេ**

*បានដល់ គប្បីត្រិះរិះដោយរឭកដល់លោកុត្តរធម៌ ៩ ។ បទថា* **អព្យាបជ្ឈំ ហិតំ ចិត្តំ** *បានដល់ ចិត្តដែលប្រកបដោយព្រហ្មវិហារ មានមេត្តាជាដើមដែលមិនមានទុក្ខ ។ បទថា* **ទេវលោកាយ ភាវយេ** *បានដល់ គប្បីចម្រើនដើម្បីព្រហ្មលោក ។ បទថា* **បុញ្ញត្ថស្ស ជិគីសតោ** *បានដល់ បុគ្គលត្រូវការបុណ្យ ស្វែងរកបុណ្យ ។ បទថា* **សន្តេសុ** *បានដល់ ក្នុងព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវករបស់ព្រះតថាគត ។ បទថា* **វិបុលា ហោតិ ទក្ខិណា** *បានដល់ ទានដែលឲ្យហើយយ៉ាងនេះ រមែងមានផលច្រើន ។ បទថា* **អនុបុព្វេន** *បានដល់ ដោយលំដាប់ មានបំពេញសីលជាដើម ។ បទដ៏សេសមានអត្ថដែលពោលហើយ ក្នុងតិកនិបាតនោះឯង ។*

អដ្ឋកថាគិហិសូត្រទី ៩ ចប់

# សុត្តន្តបិដក

## គវេសិសូត្រទី ១០

[ ៨០ ] *សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃជាច្រើន ។ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ បានទតឃើញព្រៃសាលព្រឹក្សដ៏ធំ ក្នុងប្រទេសមួយ លុះទ្រង់*

ទតឃើញហើយ ក៏យាងចុះអំពីផ្លូវ ស្ដេចទៅកាន់ព្រៃសាលព្រឹក្សនោះ លុះចូលទៅដល់ហើយ ក៏អាស្រ័យនៅទីព្រៃសាលព្រឹក្សនោះ រួចទ្រង់ធ្វើនូវការញញឹម ឲ្យប្រាកដត្រង់ប្រទេសមួយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានបរិវិតក្ក យ៉ាងនេះថា អ្វីហ្ន៎ ដែលជាហេតុ អ្វីហ្ន៎ ដែលជាបច្ច័យ នាំឲ្យព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ ( ព្រោះ ) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹម ដោយឥតហេតុឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបទូលសួរព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាហេតុ អ្វីហ្ន៎ ជាបច្ច័យ នាំឲ្យព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវការញញឹមឲ្យប្រាកដ ។ ( ព្រោះ ) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុឡើយ ។ ម្នាលអានន្ទ ហេតុធ្លាប់មានមកហើយថា ត្រង់ប្រទេសនេះ មាននគរមួយ ជានគរស្ដុកស្ដម្ភ មាំមួន មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ មួយទៀត ព្រះដ៏មានព្រះភាគព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ ទ្រង់ចូលទៅអាស្រ័យក្នុងនគរនោះ ។ ម្នាលអានន្ទ ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ មានឧបាសកម្នាក់ឈ្មោះគវេសី ជាអ្នកមិនបានធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយទេ ។ ម្នាលអានន្ទ ទាំងពួកឧបាសកចំនួនប្រាំរយ ដែលគវេសីឧបាសក បានសម្ដែងពន្យល់ឲ្យសមាទានហើយ ក៏ជាអ្នកមិនបានធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយដែរ ។ ម្នាលអានន្ទ គ្រានោះ គវេសីឧបាសក មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញ

មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកឧបាសកទាំងប្រាំរយនេះសមាទាន តែអាត្មាអញ មិនទាន់ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយទេ ឯពួកឧបាសកទាំងប្រាំរយនេះ ក៏មិនជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយឡើយ សុទ្ធតែស្មើៗ គ្នាដូច្នេះ មិនមានលើសលុបជាងគ្នាតិចតួចឡើយ បើដូច្នោះ គួរតែអាត្មា ( ធ្វើ ) ឲ្យលើសលុបជាងចុះ ។ ម្នាលអានន្ទ លំដាប់នោះ ភវេសីឧបាសកបានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយ បាននិយាយទៅរកពួកឧបាសកទាំងប្រាំរយនោះ យ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ អ្នកដ៏មានអាយុទាំងឡាយ ចូរចាំទុកនូវខ្ញុំថា ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយ ។ ម្នាលអានន្ទ គ្រានោះឯង ពួកឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភវេសីជាម្ចាស់ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលភវេសីជាម្ចាស់ ម្តេចគង់ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ លំដាប់នោះឯង ពួកឧបាសកទាំងប្រាំរយនោះ បានចូលទៅរកភវេសីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភវេសីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ ភវេសីជាម្ចាស់ សូមចាំទុកនូវពួកឧបាសកទាំងប្រាំរយនេះ ថាជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយដែរ ។ ម្នាលអានន្ទ លំដាប់នោះ ភវេសីឧបាសក មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកឧបាសកទាំងប្រាំរយនេះសមាទាន ឯអាត្មាអញ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ទាំងពួក

ឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យបរិបូណ៌ ក្នុងសីលទាំងឡាយដែរ សុទ្ធតែស្មើៗ គ្នាដូច្នេះ មិនមានលើសលុបជាងគ្នាតិចតួចឡើយ បើដូច្នោះ គួរតែអាត្មាអញ ( ធ្វើ ) ឲ្យលើសលុបជាងចុះ ។ ម្នាលអានន្ទ លំដាប់នោះឯង កវេសីឧបាសក បានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងពួកឧបាសកប្រាំរយនោះ យ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ ពួកអ្នកដ៏មានអាយុ ចូរចាំទុកនូវខ្ញុំថា ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក ។ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កវេសីជាម្ចាស់ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលកវេសីជាម្ចាស់ ម្ដេចគង់ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ គ្រានោះ ឧបាសកទាំងប្រាំរយនោះ បានចូលទៅរកកវេសីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងកវេសីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះទៅមុខ កវេសីជាម្ចាស់ ចូរចាំទុកនូវឧបាសកទាំងប្រាំរយនេះថា ជាអ្នកប្រព្រឹត្ត នូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរហើយ ។ ម្នាលអានន្ទ លំដាប់នោះឯង កវេសីឧបាសក មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិឲ្យឧបាសកទាំងប្រាំរយនេះសមាទាន តែថា អាត្មាអញជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យពេញលេញ ក្នុងសីលទាំងឡាយដែរ

មួយទៀត អាត្មាអញជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុក សូម្បីពួកឧបាសកទាំងប្រាំរយនោះ ក៏ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរ សុទ្ធតែស្មើៗគ្នាដូច្នេះ មិនមានលើសលុប ជាងគ្នាតិចតួចឡើយ បើដូច្នេះ គួរតែអាត្មាអញប្រតិបត្តិឲ្យលើសលុបជាងទៅចុះ ។ ម្នាលអានន្ទ លំដាប់នោះឯង ភវេសីឧបាសក បានចូលទៅរកពួកឧបាសកទាំងប្រាំរយនោះ លុះចូលទៅដល់ហើយក៏បាន និយាយនឹងឧបាសកទាំងប្រាំរយនោះ យ៉ាងនេះថា អំពីថ្ងៃនេះទៅមុខពួកអ្នកដ៏មានអាយុ ចូរចាំទុកនូវខ្ញុំថាជាអ្នកបរិភោគកត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាល ។ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភវេសីជាម្ចាស់មាន ឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលភវេសីជាម្ចាស់ ម្តេចគង់ជាអ្នកបរិភោគកត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគ ក្នុងវេលាវិកាលទៅហើយ ចុះពួកយើងចាំអ្វីទៀតហ្ន៎ ។ ម្នាលអានន្ទ លំដាប់នោះឯង ឧបាសកទាំងប្រាំរយនោះ បានចូលទៅរកភវេសីឧបាសក លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងភវេសីឧបាសកយ៉ាងនេះថា អំពីថ្ងៃនេះ ទៅមុខ ភវេសីជាម្ចាស់ សូមចាំទុកនូវឧបាសកទាំងប្រាំរយនេះ ថាជាអ្នកបរិភោគ កត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាល ដែរហើយ ។ ម្នាលអានន្ទ លំដាប់នោះ ភវេសីឧបាសក មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ

ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យឧបាសកទាំងប្រាំរយនេះ សមាទាន តែថា អាត្មាអញជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយដែរ មួយទៀត អាត្មាអញជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុនជាធម៌របស់អ្នកស្រុក សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ឆ្ងាយ វៀរចាកមេថុន ជាធម៌របស់អ្នកស្រុកដែរ មួយទៀត អាត្មាអញ ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគភត្តក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាល សូម្បីឧបាសកទាំងប្រាំរយនេះ ក៏ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាលដែរ សុទ្ធតែស្មើៗ គ្នាដូច្នេះ មិនមានលើសលុបជាងគ្នាតិចតួចឡើយ បើដូច្នោះ គួរតែអាត្មាអញ ( ធ្វើ ) ឲ្យលើសលុបជាងទៅចុះ ។ ម្នាលអានន្ទ លំដាប់នោះ គវេសីឧបាសក បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ ម្នាលអានន្ទ គវេសីឧបាសកក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសម្នាក់ព្រះដ៏មានព្រះភាគព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ គវេសីភិក្ខុបានឧបសម្បទាមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ ខំប្រឹងដុតបំផ្លាញនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តដែលចេញ

ចាកផ្ទះហើយ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរគុណណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរគុណនោះ ដែលមានព្រហ្មចរិយៈ ជាទីបំផុតដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងកាលជាបច្ចុប្បន្ន រួចបានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញ បានប្រព្រឹត្តចប់ហើយ សោឡសកិច្ច ដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅអំពីមគ្គភាវនាកិច្ចនេះ មិនមានទៀតឡើយ ម្នាលអានន្ទ ឯកវេសីភិក្ខុក៏បានជាព្រះអរហន្តមួយក្នុងពួក ព្រះអរហន្តទាំងឡាយដែរ ។ ម្នាលអានន្ទ លំដាប់នោះ ឧបាសកទាំងប្រាំរយនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា កវេសីជាម្ចាស់ហ្នឹងឯង មានឧបការៈច្រើន ជាអ្នកនាំអាទិ ឲ្យពួកយើងសមាទាន អម្បាលកវេសីជាម្ចាស់ម្តេច គង់កោរសក់ និងពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់នូវសំពត់ ដែលជ្រលក់ដោយទឹកម្ចត់ រួចចេញចាកផ្ទះ ចូលកាន់ផ្នួសទៅហើយ ចុះពួកយើងចាំអ្វីទៀត ។ ម្នាលអានន្ទ លំដាប់នោះ ឧបាសកទាំងប្រាំរយនោះ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ក៏បានក្រាបទូល ព្រះដ៏មានព្រះភាគព្រះនាមកស្សប អរហន្តសម្មាសម្ពុទ្ធ យ៉ាងនេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុង សម្នាក់ព្រះដ៏មានព្រះភាគដែរ ។ ម្នាលអានន្ទ ឧបាសកទាំងប្រាំរយនោះ ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ព្រះនាម កស្សបអរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ លំដាប់នោះ កវេសីភិក្ខុមានសេចក្តី ត្រិះរិះយ៉ាងនេះថា អាត្មាអញជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក

បានដោយមិនក្រ នូវវិមុត្តិសុខដ៏ប្រសើរបំផុតនេះ ធ្វើម្ដេចហ្ន៎ ភិក្ខុទាំងប្រាំរូបនេះ គប្បីបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយមិនក្រ នូវវិមុត្តិសុខដ៏ប្រសើរបំផុតនេះផងអេះ ។ ម្នាលអានន្ទ លំដាប់នោះ ភិក្ខុទាំងប្រាំរូបនោះក៏ចៀសចេញទៅតែម្នាក់ឯង មិនប្រមាទ ខំប្រឹង ដុតបំផ្លាញនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តដែលចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរគុណណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរគុណនោះ ដែលមានព្រហ្មចរិយៈជាទីបំផុត ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ក្នុងកាលជាបច្ចុប្បន្ន រួចបានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅអំពីមគ្គភាវនាកិច្ចនេះ មិនមានទៀតឡើយ ។ ម្នាលអានន្ទ ភិក្ខុទាំងប្រាំរូបនោះ មានភវេសីភិក្ខុជាប្រធាន កាលប្រឹងប្រែងឲ្យម៉ត់ចត់ លើសលុបឡើងទៅ ក៏បានធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ដោយប្រការដូច្នេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ ក្នុងសាសនានេះ ពួកអ្នកត្រូវសិក្សាយ៉ាងនេះថា ពួកយើងកាលប្រឹងប្រែងឲ្យម៉ត់ចត់ លើសលុបឡើងទៅ គង់ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរបាន ។ ម្នាលអានន្ទ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះចុះ ។

ឧបាសកវគ្គទី ៣ ចប់

### ឧទ្ទាននៃឧបាសកវគ្គនោះ គឺ

និយាយអំពីការញញើតញញើម ១ ក្តៅក្លា ១ នរក ១ ពៀរ ១ ចណ្ឌាលឧបាសកជាគម្រប់ប្រាំ បីតិ ១ ជំនួញ ១ ពួកស្តេច ១ គ្រហស្ថអ្នកស្លៀកស ១ គវេសី-ឧបាសក ១ ។

# អដ្ឋកថា

## គវេសិសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគវេសិសូត្រទី ១០ ដូចតទៅនេះ បទថា **សិតំ បាត្វាកាសិ** សេចក្តីថា ព្រះមានព្រះភាគកាល ទ្រង់យាងទៅតាមមហាមាគ៌ា ទ្រង់ក្រឡេកមើលព្រៃសាលព្រឹក្សនោះ ទ្រង់ត្រិះរិះថា ក្នុងទីនេះមានហេតុអ្វី ធ្លាប់កើតហើយឬហ្ន៎ ទ្រង់ក៏បានឃើញហេតុដែលឧបាសកឈ្មោះគវេសីបានធ្វើហើយ ក្នុងពុទ្ធកាលព្រះកស្សបសម្ពុទ្ធ ទ្រង់ត្រិះរិះបន្តថា ហេតុនេះ បិទបាំងមិនប្រាកដដល់ពួកភិក្ខុ ណ្ហើយចុះ តថាគតនឹងធ្វើហេតុនោះឲ្យប្រាកដដល់ពួកភិក្ខុ ទើបចៀសចេញអំពីផ្លូវ គង់ឈរក្នុងទីមួយកន្លែង ទ្រង់បានធ្វើការញញឹមឲ្យប្រាកដ បង្ហាញជើងព្រះទន្តតិចៗ ។ ព្រះពុទ្ធទាំងឡាយទ្រង់មិនបានសើចដូចពួកមនុស្សក្នុងលោក ដែលសើចរហូតរឹងពោះ ពោលថា ទីណា ទីណា ដូច្នេះ ។ ការសើចរបស់ព្រះពុទ្ធទាំងឡាយ ក៏ត្រឹមតែការញញឹមប៉ុណ្ណោះ ។ ឈ្មោះថា ការញញឹមនេះ រមែងមានដោយចិត្តសហគតៈ

ដោយសោមនស្ស ១៣ ដួង ។ សត្វលោកសើចដោយចិត្ត ៨ ដួង គឺអកុសល ៤ ដួង កាមាវចរកុសល ៤ ដួង ។ ព្រះសេក្ខៈទាំងឡាយនាំចិត្តដែលសម្បយុត្តដោយទិដ្ឋិ ២ ដួងចេញអំពីអកុសល ហើយសើចដោយចិត្ត ៦ ដួង ។ ព្រះខីណាស្រពញញឹមដោយចិត្ត ៥ ដួង គឺដោយកិរិយាចិត្ត ដែលជាសហេតុកៈ ៤ ដែលជាអហេតុកៈ ១ ។ ក្នុងចិត្តទាំងនោះ កាលអារម្មណ៍មានកម្លាំងប្រាកដ ព្រះខីណាស្រពទាំងឡាយ រមែងញញឹមដោយចិត្តដែលសម្បយុត្តដោយញាណ ២ ដួង ។ កាលអារម្មណ៍មានកម្លាំងទន់ប្រាកដ ព្រះខីណាស្រពរមែងញញឹមដោយចិត្ត ៣ ដួង គឺដោយទុហេតុកចិត្ត ២ ដួង និងដោយអហេតុកចិត្ត ១ ដួង តែក្នុងទីនេះ ចិត្តសហគតៈដោយសោមនស្សដែលជាកិរិយាហេតុកៈ និងមនោវិញ្ញាណធាតុ ធ្វើការសើច ត្រឹមតែការញញឹមឲ្យកើតឡើងដល់ព្រះមានព្រះភាគ ការញញឹមនោះ ត្រឹមតែតិចតួចយ៉ាងនេះ ក៏បានប្រាកដដល់ព្រះថេរៈហើយ ។ សួរថា សេចក្តីនេះដូចម្តេច ។ ឆ្លើយថា ក្នុងកាលនោះរស្មីរុងរឿង ដែលចែងចាំងប្រមាណប៉ុនដើមត្នោតធំ ចេញអំពីព្រះទាឋៈទាំង ៤ របស់ព្រះតថាគត ដូចផ្លេកបន្ទោរចេញអំពីលម្អមេឃ ៤ ទិស ផុសឡើង ធ្វើប្រទក្សិណជុំវិញព្រះសីសៈ ៣ ជុំ ហើយបាត់ទៅត្រង់ជើងព្រះទាឋៈនោះឯង ដោយសញ្ញានោះ ព្រះអានន្ទសូម្បីនិមន្តតាមទៅអំពីខាងក្រោយព្រះមានព្រះភាគ ក៏ដឹងថា ព្រះមានព្រះភាគទ្រង់ធ្វើការញញឹមឲ្យប្រាកដ ។

បទថា **ឥទ្ធំ** ប្រែថា សម្បូរ ។ បទថា **ផីតំ** បានដល់ សម្បូរពន់ពេក ដូចផ្ការីកស្គុសស្គាយគ្រប់ជួរ ។ បទថា **អាកិណ្ណមនុស្សំ** បានដល់ ដេរដាស ទៅដោយមហាជន ។ បទថា **សីលេសុ អបរិបូរការី** បានដល់ មិនធ្វើនូវ ការស្មើគ្នាក្នុងសីល ៥ ។ បទថា **បដិទេសិតានិ** បានដល់ សម្តែងនូវភាព ជាឧបាសក ។ បទថា **សមាទបិតានិ** សេចក្តីថា ឲ្យតាំងនៅក្នុងសរណៈ ទាំងឡាយ ។ បទថា **ឥច្ចេតំ សមសមំ** បានដល់ ហេតុនោះស្មើគ្នា គឺស្មើ ដោយអាការទាំងពួង មិនមែនស្មើដោយឯកទេស គឺចំណែកខ្លះៗ ឡើយ ។ បទថា **នត្ថិ កិញ្ចិ អតិរេកំ** បានដល់ អញមិនមានហេតុណាមួយដែល ឈានមុខមនុស្សទាំងនេះ ។ បទថា **ហន្ទ** ជានិបាត ចុះក្នុងអត្ថថា ដាស់តឿន ។ បទថា **អតិរេកាយ** សេចក្តីថា អញនឹងបដិបត្តិដើម្បីហេតុដែលល្អក្រៃលែង ឡើង ។ បទថា **សីលេសុ បរិបូរការី ធារេថ** សេចក្តីថា អ្នកទាំងឡាយ ចូរ ដឹងថា ខ្ញុំធ្វើនូវការប្រៀបធៀបគ្នាក្នុងសីល ៥ ហើយ ។ ដោយហេតុមាន ប្រមាណប៉ុណ្ណោះ ឈ្មោះថា ភវេសីឧបាសកនោះ សមាទាន សីល ៥ ហើយ ។ បទថា **កិមង្គំ បន ន មយំ** សេចក្តីថា ដោយហេតុអ្វីហ្ន៎ ទើបអញមិន ជាបុគ្គលធ្វើឲ្យបរិបូណ៌បាន ។ បទដ៏សេសក្នុងសូត្រនេះងាយយល់ហើយ ៕

**អដ្ឋកថាភវេសិសូត្រទី ១០ ចប់**

**ឧបាសកវគ្គទី ៣ ចប់**

# សុត្តន្តបិដក

# អរញ្ញវគ្គ

## អរញ្ញសូត្រទី ១ ជាដើម

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុអ្នកនៅក្នុងព្រៃ ( ប្រព្រឹត្តអរញ្ញិកង្គ ) នេះមាន ៥ ពួក ។ ភិក្ខុអ្នកនៅក្នុងព្រៃ ៥ ពួក តើដូចម្តេច ។ គឺភិក្ខុអ្នកនៅក្នុងព្រៃ ព្រោះមិនដឹង ព្រោះខ្លៅល្ងង់ ១ នៅក្នុងព្រៃ ព្រោះប្រាថ្នាលាមក លុះក្នុងសេចក្តីប្រាថ្នា ១ នៅក្នុងព្រៃ ព្រោះឆ្កួតរាយមាយចិត្ត ១ នៅក្នុងព្រៃ ព្រោះគិតថា ការនៅក្នុងព្រៃ ព្រះពុទ្ធទាំងឡាយ និងពួកពុទ្ធសាវកសរសើរហើយ ១ នៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកនៅក្នុងព្រៃមាន ៥ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុណាអ្នកនៅក្នុងព្រៃ ដែលជាអ្នកនៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុអ្នកនៅក្នុងព្រៃបែបនេះ ឈ្មោះថា ខ្ពង់ខ្ពស់ផង ប្រសើរផង ជាចម្បងផង ឧត្តមផង ថ្លៃថ្លាផង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកដោះ កើតមកអំពីមេគោ ទធិកើតអំពីទឹកដោះ

នវនីត កើតមកអំពីទធិ សប្បិកើតមកអំពីនវនីត សប្បិមណ្ឌកើតមកអំពីសប្បិ សប្បិមណ្ឌប្រាកដជា ប្រសើរជាងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុណាអ្នកនៅក្នុងព្រៃ ដែលជាអ្នកនៅក្នុងព្រៃ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកនៅក្នុងព្រៃទាំង ៥ ពួកនេះ ភិក្ខុអ្នកនៅក្នុងព្រៃបែបនេះ ឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ជាចម្បងផង ឧត្តមផងថ្លៃថ្លាផង ។

## បំសុកូលិកសូត្រទី ២

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកង្គនេះ មាន ៥ ពួក ។បេ។

## រុក្ខមូលិកសូត្រទី ៣

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តរុក្ខមូលិកង្គនេះ មាន ៥ ពួក ។បេ។

## សោសានិកសូត្រទី ៤

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តសោសានិកង្គនេះ មាន ៥ ពួក ។បេ។

## អព្ភោកាសិកសូត្រទី ៥

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តអព្ភោកាសិកង្គនេះ មាន

៥ ពួក ។បេ។

## នេសជ្ជិកសូត្រទី ៦

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តនេសជ្ជិកង្គនេះ មាន ៥ ពួក ។បេ។

## យថាសន្ថតិសូត្រទី ៧

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តយថាសន្ថតិកង្គនេះ មាន ៥ ពួក ។បេ។

## ឯកាសនិកសូត្រទី ៨

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តឯកាសនិកង្គនេះ មាន ៥ ពួក ។បេ។

## ខលុបច្ឆាភត្តិកសូត្រទី ៩

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តខលុបច្ឆាភត្តិកង្គនេះ មាន ៥ ពួក ។បេ។

## បត្តបិណ្ឌិកសូត្រទី ១០

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គនេះ មាន ៥ ពួក ។ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ៥ ពួក តើដូចម្តេច ។ គឺភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះមិនដឹង ព្រោះខ្លៅល្ងង់ ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះប្រាថ្នាលាមក លុះក្នុងសេចក្តីប្រាថ្នា ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះឆ្កួតរាយមាយចិត្ត ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះគិតថា បត្តបិណ្ឌិកង្គនេះ ព្រះពុទ្ធ

ទាំងឡាយ និងពួកពុទ្ធសាវកសរសើរហើយ ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ មាន ៥ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុណាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ជាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គបែបនេះ ឈ្មោះថាខ្ពង់ខ្ពស់ផង ប្រសើរផង ចម្បងផង ឧត្តមផង ថ្លៃថ្លាផង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាទឹកដោះកើតអំពីមេគោ ទធិកើតអំពីទឹកដោះ នវនីតកើតអំពីទធិ សប្បិកើតអំពីនវនីត សប្បិមណ្ឌកើតអំពីសប្បិ សប្បិមណ្ឌប្រាកដជាប្រសើរលើសជាងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុណាអ្នកប្រព្រឹត្តបត្ត-បិណ្ឌិកង្គ ជាអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ ព្រោះអាស្រ័យសេចក្តីប្រាថ្នាតិច អាស្រ័យសេចក្តីសន្តោស អាស្រ័យសេចក្តីជុសខាត់ ( កិលេស ) អាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីត្រូវការដោយការប្រតិបត្តិល្អ បណ្តាភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គទាំង ៥ ពួកនេះ ភិក្ខុអ្នកប្រព្រឹត្តបត្តបិណ្ឌិកង្គ បែបនេះ ឈ្មោះថា

ខ្ពង់ខ្ពស់ផង ប្រសើរផង ជាចម្បងផង ឧត្តមផង ថ្លៃថ្លាផង ។

អរញ្ញវគ្គទី ៤ ចប់

## ឧទ្ទាននៃអរញ្ញវគ្គនោះ គឺ

និយាយអំពីភិក្ខុអ្នកប្រព្រឹត្តអារញ្ញិកង្គ ១ ប្រព្រឹត្តបំសុកូលិកង្គ ១ ប្រព្រឹត្តរុក្ខមូលិកង្គ ១ ប្រព្រឹត្តសោសានិកង្គ ១ ប្រព្រឹត្តអព្ភោកាសិកង្គ ១ ប្រព្រឹត្តនេសជ្ជិកង្គ ១ ប្រព្រឹត្តយថាសន្ថតិកង្គ ១ ប្រព្រឹត្តឯកាសនិកង្គ ១ ប្រព្រឹត្តខលុបច្ឆាភត្តិកង្គ ១ ប្រព្រឹត្តបត្តបិណ្ឌិកង្គ ១ ។

# អដ្ឋកថា

# អរញ្ញវគ្គទី ៤

## អរញ្ញសូត្រទី ១ ជាដើម

*[ ៨១-៩០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរញ្ញសូត្រទី ១ ជាដើម នៃ អរញ្ញវគ្គទី ៤ ដូចតទៅនេះ បទថា* **មន្ទត្តា មោមូហត្តា** *សេចក្ដីថា មិនដឹងការសមាទាន មិនដឹងអានិសង្ស តែនៅព្រៃជាវត្ត ដោយមិនដឹង ព្រោះខ្លួនល្ងង់ខ្លៅ ។ បទថា* **ចាបិច្ឆោ ឥច្ឆាបកតោ** *សេចក្ដីថា ភិក្ខុតាំងនៅក្នុងសេចក្ដីប្រាថ្នាលាមកយ៉ាងនេះថា កាលអញនៅព្រៃ ជនទាំងឡាយនឹងធ្វើសក្ការៈដោយបច្ច័យ ៤ ដោយគិតថា ភិក្ខុនេះសមាទាននៅព្រៃជាវត្ត និងលើកសរសើរដោយគុណទាំងឡាយជាដើមថា ភិក្ខុនេះជាលជ្ជី ពេញចិត្តក្នុងទីស្ងាត់ ដូច្នេះហើយ ត្រូវសេចក្ដីប្រាថ្នាលាមកនោះឯងគ្របសង្កត់ ទើបជាអ្នកនៅព្រៃជាវត្ត ។ ម្យ៉ាងទៀត ភិក្ខុចូលទៅនៅព្រៃ ដោយភាពឆ្កួត ឈ្មោះថា នៅព្រៃជាវត្ត ព្រោះឆ្កួត ព្រោះចិត្តរាយមាយ ។ បទថា* **វណ្ណិតំ** *សេចក្ដីថា ឈ្មោះថា អង្គនៃភិក្ខុដែលសមាទានការនៅព្រៃជាវត្តនេះ ព្រះមានព្រះភាគ និងសាវករបស់ព្រះមានព្រះភាគលើកតម្កើងហើយ គឺសរសើរហើយ ព្រោះដូច្នោះ ទើបភិក្ខុសមា-*

ទានការនៅព្រៃជាវត្ត ។ បទថា **ឥធមត្ថិតំ** សេចក្តីថា ឈ្មោះថា **ឥធមត្ថិ** ព្រោះមានសេចក្តីត្រូវការដោយបដិបទាដ៏ស្អាតនេះ ។ ជាអ្នកត្រូវការ ឈ្មោះថា **ឥធមត្ថិតា** អធិប្បាយថា អាស្រ័យភាពជាបុគ្គលមានសេចក្តីត្រូវការនោះប៉ុណ្ណោះ មិនបានអាស្រ័យលោកាមិសដទៃណាមួយឡើយ ។ បទដ៏សេសក្នុងសូត្រនេះ និងសូត្រក្រៅអំពីនេះ មានអត្ថងាយយល់ទាំងអស់ហើយ ៕

## អដ្ឋកថា អាញ្ញសូត្រទី ១ ជាដើម ចប់
## អរញ្ញវគ្គទី ៤ ចប់

# សុត្តន្តបិដក

# ព្រាហ្មណវគ្គ

## សោណសូត្រទី ១

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ ទំនៀមរបស់ពួកព្រាហ្មណ៍អំពីបុរាណនេះមាន ៥ យ៉ាង រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ឥឡូវនេះទេ ។ ទំនៀមរបស់ព្រាហ្មណ៍ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បានឮមកក្នុងកាលពីដើម ពួកព្រាហ្មណ៍តែងគប់រកនាងព្រាហ្មណី មិនគប់រកស្រីមិនមែនជាព្រាហ្មណីទេ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍គប់រកស្រីជាព្រាហ្មណីខ្លះ គប់រកស្រីមិនមែនជាព្រាហ្មណីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ រមែងគប់រកតែសុនខញី មិនគប់រកជាតិសត្វ មិនមែនជាសុនខញីឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ពួកព្រាហ្មណ៍អំពីបុរាណទី ១ តែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍រមែងគប់រកព្រាហ្មណី ដែលមានរដូវ មិនគប់រកព្រាហ្មណី ដែលមិនមានរដូវទេ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ តែងគប់រកព្រាហ្មណីដែលមានរដូវខ្លះ គប់រកព្រាហ្មណី ដែលមិនមានរដូវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ រមែងគប់រកសុនខញីដែលមានរដូវ មិនគប់រកសុនខញីដែលមិនមានរដូវទេ ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍អំពី

បុរាណទី ២ រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ក្នុងកាលឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍មិនបានទិញ មិនបានលក់នូវនាងព្រាហ្មណីទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីផ្សំផ្គុំនូវសំវាស តាមសេចក្ដីស្រឡាញ់ និងមិនស្រឡាញ់ប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ទិញខ្លះ លក់ខ្លះ នូវនាងព្រាហ្មណី ប្រព្រឹត្តទៅដើម្បីផ្សំផ្គុំនូវសំវាស តាមសេចក្ដីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកសុនខ នៅតែមិនបានទិញ មិនបានលក់នូវសុនខញីដែរ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីរួមនូវសំវាស តាមសេចក្ដីស្រឡាញ់ប៉ុណ្ណោះ ម្នាលភិក្ខុទាំងឡាយនេះជាទំនៀមរបស់ព្រាហ្មណ៍ អំពីបុរាណទី ៣ រមែងប្រាកដស្មើក្នុងពួកសុនខមិនប្រាកដក្នុងពួកព្រាហ្មណ៍ទេ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមមក ពួកព្រាហ្មណ៍មិនបានធ្វើនូវការសន្សំទុកដាក់នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះទេ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ធ្វើនូវការសន្សំទុកដាក់នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ មិនធ្វើនូវការសន្សំទុកដាក់នូវទ្រព្យខ្លះ ស្រូវខ្លះ ប្រាក់ខ្លះ មាសខ្លះដែរ ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ពីបុរាណទី ៤ តែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះទេ ។ ម្នាល

ភិក្ខុទាំងឡាយ ក្នុងកាលពីដើម ពួកព្រាហ្មណ៍តែងស្វែងរកនូវភិក្ខាក្នុងពេលល្ងាច តាមពេលល្ងាច ក្នុងពេលព្រឹក តាមពេលព្រឹក ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកព្រាហ្មណ៍ បរិភោគ ( អាហារ ) បំពេញពោះដរាបដល់ឆ្អែត ហើយកាន់យកអាហារដ៏សេសសល់ ចៀសចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកសុនខ ក៏ស្វែងរក ( អាហារ ) ក្នុងពេលល្ងាច តាមពេលល្ងាច ក្នុងពេលព្រឹក តាមពេលព្រឹក ម្នាលភិក្ខុទាំងឡាយ នេះជាទំនៀមរបស់ព្រាហ្មណ៍ពីបុរាណទី ៥ រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ក្នុងកាលឥឡូវនេះទេ ។ ម្នាលភិក្ខុទាំងឡាយ ទំនៀមរបស់ព្រាហ្មណ៍ពីបុរាណទាំង ៥ យ៉ាងនេះឯង រមែងប្រាកដស្មើក្នុងពួកសុនខ មិនប្រាកដក្នុងពួកព្រាហ្មណ៍ក្នុងកាលឥឡូវនេះទេ ។

# អដ្ឋកថា

# ព្រាហ្មណវគ្គទី ៥

## សោណសូត្រ

[ ៩១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោណសូត្រទី ១ នៃព្រាហ្មណវគ្គទី ៥ ដូចតទៅនេះ បទថា **ព្រាហ្មណធម្មា** បានដល់ សភាវៈរបស់ព្រាហ្មណ៍ ។ បទថា **សុនខេសុ** ប្រែថា ក្នុងឆ្កែទាំងឡាយ ។ បទថា **នេវ កិណន្តិ ន វិក្កិណន្តិ** បានដល់ កាន់យកមិនទិញ ឲ្យទៅមិនលក់ ។ បទថា **សម្បិយេនេវ សំវាសំ សម្ពន្ធាយ សម្បវត្តេន្តិ** សេចក្តីថា ចូលទៅរកបុគ្គលដែលជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ហើយនៅរួមគ្នា ដើម្បីបន្តបវេណី ។ បទថា **ឧទរាវទេហកំ** បានដល់ បរិភោគពេញពោះ ។ បទថា **អវសេសំ អាទាយ បក្កមន្តិ** បានដល់ ខ្ចប់ចំណែកដែលបរិភោគមិនអស់ កាន់យកហើយត្រឡប់ទៅ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់វដ្តៈតែម្យ៉ាង ។ល។

**អដ្ឋកថាសោណសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទោណសូត្រទី ២

[ ៩២ ] គ្រានោះឯង ទោណព្រាហ្មណ៍ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះទោណព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮថា ព្រះសមណគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យមានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ មិនអញ្ជើញដោយអាសនៈ ។ បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះជាប្រាកដថា ព្រះគោតមដ៏ចម្រើនមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយដែលចាស់គ្រាំគ្រា ជាព្រឹទ្ធាចារ្យមានអាយុច្រើនរស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ មិនអញ្ជើញដោយអាសនៈ ។ បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានការមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ម្នាលទោណៈ អ្នកមិនប្តេជ្ញាថាជាព្រាហ្មណ៍ទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលកាលនឹងពោលនូវរឿងនោះឲ្យត្រូវ គួរពោលថា ព្រាហ្មណ៍អ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបាន

ជាអ្នករាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខា និងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនថោកថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រនិងមហាបុរិសលក្ខណព្យាករណសាស្ត្រ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលកាលនឹងពោលនូវរឿងនោះឲ្យត្រូវ គប្បីពោលនូវខ្ញុំព្រះអង្គហ្នឹងឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា ខ្ញុំព្រះអង្គជាព្រាហ្មណ៍មានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀល ដោយពោលដល់ជាតិកំណើតបាន ជាអ្នករាយមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ និងគម្ពីរកេដុភៈ ព្រមទាំងអក្ខរប្បភេទៈ គឺសិក្ខានិងនិរុត្តិដែលមានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នកដឹងនូវបទ និងវេយ្យាករណ៍ ជាអ្នកមិនថោកថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណ-ព្យាករណសាស្ត្រ ។ ម្នាលទោណៈ ពួកឥសីទាំងអម្បាលម៉ាន ជាប្រធានរបស់ព្រាហ្មណ៍ទាំងឡាយ អ្នកធ្វើនូវមន្តទាំងឡាយ នឹងញុំាងមន្តទាំងឡាយ ឲ្យប្រព្រឹត្តទៅបាន ក៏បទមន្ត និងចម្រៀងចាស់នេះ ដែលពួកឥសីបានពោលធ្វើឲ្យជាគំនរដល់ព្រាហ្មណ៍ទាំងឡាយណា ពួកព្រាហ្មណ៍ក្នុងកាលឥឡូវនេះ រមែងច្រៀងតាម ពោលតាមនូវបទមន្ត និងចម្រៀងនោះ តែងពោលតាមបទមន្តដែលពួកឥសីពោលហើយនោះ បង្ហាញតាមបទមន្ត និងចម្រៀង ដែលពួកឥសី

បង្ហាញហើយ ឥសីទាំងនោះ គឺឥសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្ត ១ យមទគ្គិ ១ អង្គីរស ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឥសីទាំងនោះ តែងនាំគ្នាបញ្ញត្តនូវព្រាហ្មណ៍ទាំង ៥ នេះ គឺព្រហ្មសមៈ ១ ទេវសមៈ ១ មរិយាទៈ ១ សម្ភិន្នមរិយាទៈ ១ និងព្រាហ្មណ៍ចណ្ឌាលជាគម្រប់ ៥ ។ ម្នាលទោណៈ អ្នកជាព្រាហ្មណ៍អ្វី ក្នុងពួកព្រាហ្មណ៍ទាំង ៥ នោះ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមិនស្គាល់ព្រាហ្មណ៍ទាំង ៥ នេះទេ ខ្ញុំព្រះអង្គគ្រាន់តែស្គាល់ថា ជាព្រាហ្មណ៍ប៉ុណ្ណោះឯង ប្រពៃណាស់ហើយ ព្រះគោតមដ៏ចម្រើន សូមព្រះគោតមដ៏ចម្រើន សម្តែងធម៌ឲ្យខ្ញុំព្រះអង្គស្គាល់ព្រាហ្មណ៍ទាំង ៥ នេះឲ្យទាន ។ ម្នាលទោណៈ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ទោណព្រាហ្មណ៍ ក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ដូច្នេះឯង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលទោណៈ ព្រាហ្មណ៍ឈ្មោះព្រហ្មសមៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ជាតិកំណើតបាន ព្រាហ្មណ៍នោះតែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំរួចហើយ ក៏ស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ

ដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្ដេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការភ្ជួរ មិនបានស្វែងរកដោយការជួញ មិនបានស្វែងរកដោយការរក្សាគោ មិនបានស្វែងរកដោយអំពើនៃឋានៈជាទាហាន មិនបានស្វែងរកដោយភាពជារាជបុរស មិនបានស្វែងរកដោយសិប្បកម្មណានីមួយឡើយ គ្រាន់តែស្វែងរកដោយការត្រាច់ទៅ ដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវកិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះប្រគល់ទ្រព្យសម្រាប់អាចារ្យដល់អាចារ្យ ហើយកោរសក់ និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះមកបួស ។ ព្រាហ្មណ៍នោះ កាលដែលបានបួសយ៉ាងនេះហើយ ជាអ្នកមានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹង គឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោក

ទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ ព្រាហ្មណ៍នោះលុះបានចម្រើន នូវព្រហ្មវិហារទាំង ៤ នេះហើយ ក៏ទម្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុង សុគតិ និងព្រហ្មលោក ម្នាលទោណៈ ព្រាហ្មណ៍ជាព្រហ្មសមៈយ៉ាងនេះឯង ។ ម្នាលទោណៈ ចុះព្រាហ្មណ៍ជាទេវសមៈនោះ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និង ខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិន មានអ្នកណារិះគន់ តិះដៀល ដោយពោលដល់ជាតិកំណើតបាន ព្រាហ្មណ៍ នោះ ក៏រៀនយកនូវមន្ត ប្រព្រឹត្តនូវកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀន យកនូវមន្តប្រព្រឹត្តនូវកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ រួចហើយ ទើបស្វែង រកទ្រព្យសម្រាប់អាចារ្យដើម្បីអាចារ្យ ដោយគន្លងធម៌ មិនស្វែងរកខុសគន្លង ធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍ នោះ មិនបានស្វែងរកដោយការភ្ជួរ មិនបានស្វែងរកដោយការជួញ មិនបាន ស្វែងរកដោយការរក្សាគោ មិនបានស្វែងរក ដោយអំពើនៃបាន:ជាទាហាន មិនបានស្វែងរកដោយភាពជារាជបុរស មិនបានស្វែងរក ដោយសិប្បកម្មណា នីមួយឡើយ គ្រាន់តែស្វែងរក ដោយការត្រាច់ទៅដើម្បីភិក្ខាប៉ុណ្ណោះ មិនបាន មើលងាយនូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់ អាចារ្យដល់អាចារ្យ ហើយក៏ស្វែងរកភរិយាដោយធម៌ មិនស្វែងរកខុសធម៌ ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍

នោះ មិនបានស្វែងរកដោយការទិញ មិនបានស្វែងរក ដោយការលក់ដូរ ស្វែងរកតែព្រាហ្មណីដែលគេបរិច្ចាគ ដោយប្រោះទឹកឲ្យ ព្រាហ្មណ៍នោះ រមែង គប់រកនាងព្រាហ្មណីផងគ្នា មិនគប់រកស្ត្រីក្សត្រិយ៍ មិនគប់រកស្ត្រីវេស្សៈ គឺ ស្ត្រីអ្នកជួញ ឬធ្វើស្រែចម្ការ មិនគប់រកស្ត្រីសុទ្រៈ គឺស្ត្រីអ្នកធ្វើគូលីស៊ីឈ្នួលគេ មិនគប់រកស្ត្រីចណ្ឌាល មិនគប់រកស្ត្រីនេសាទ មិនគប់រកស្ត្រីដែលមានផ្នួង សក់ ( សក់ជុក ) មិនគប់រកស្ត្រីជាងរថ មិនគប់រកស្ត្រីអ្នកចោលសំរាម មិនគប់រកស្ត្រីដែលមានគភ៌ មិនគប់រកស្ត្រីដែលមានកូននៅបៅ មិនគប់រក ស្ត្រីដែលមិនមានរដូវ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍ មិន គប់រកស្ត្រី ដែលមានគភ៌ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍ គប់រកស្ត្រី ដែលមានគភ៌ហើយ មាណវកៈ និងមាណវិកានោះ ឈ្មោះថា កើតក្នុងគំនរ លាមកជំ មានក្លិនអាក្រក់ក្រៃពេក ម្នាលទោណៈ ព្រោះហេតុនោះ បានជា ព្រាហ្មណ៍មិនគប់រកស្ត្រីដែលមានគភ៌ឡើយ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍ មិនគប់រកស្ត្រីដែលមានកូននៅបៅ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍គប់រកស្ត្រីដែលមានកូននៅបៅហើយ មាណវកៈ និង មាណវិកានោះ ឈ្មោះថា ផឹករបស់មិនស្អាត ម្នាលទោណៈ ព្រោះហេតុ នោះ បានជាព្រាហ្មណ៍មិនគប់រកស្ត្រី ដែលមានកូននៅបៅ ។ ឯនាង ព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មិនមានប្រយោជន៍ដោយកាម មិនមាន ប្រយោជន៍ដោយការលេង មិនមានប្រយោជន៍ដោយសេចក្តីត្រេកអរ

ក្នុងកាម នាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ មានប្រយោជន៍ដោយបុត្រ ប៉ុណ្ណោះ ព្រាហ្មណ៍នោះញុំាងមេថុនឲ្យកើតឡើងហើយ កោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះមកបួស ។ ព្រាហ្មណ៍នោះ កាលដែលបានបួសយ៉ាងនេះហើយ ក៏ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ដល់នូវចតុត្ថជ្ឈាន ។ ព្រាហ្មណ៍នោះ រមែងចម្រើននូវឈានទាំង ៤ នេះ លុះទម្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ម្នាលទោណៈ ព្រាហ្មណ៍ជាទេវសមៈ យ៉ាងនេះឯង ។ ម្នាលទោណៈ ចុះព្រាហ្មណ៍ជាមរិយាទៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធ ដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់ តិះដៀលដោយពោលដល់ជាតិកំណើតបាន ។ ព្រាហ្មណ៍នោះ ក៏រៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈ អស់ ៤៨ ឆ្នាំរួចហើយ ក៏ស្វែងរកទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការភ្ជួរ មិនបានស្វែងរកដោយការជួញ មិនបានស្វែងរកដោយការរក្សាគោ មិនបានស្វែងរកដោយអំពើនៃឋានៈជាទាហាន មិនបានស្វែងរកដោយការៈជារាជបុរស មិនបានស្វែងរកដោយសិប្បកម្មណាទីមួយ ហើយស្វែងរកដោយការត្រាច់ទៅដើម្បី

ភិក្ខា តែប៉ុណ្ណោះ មិនបានមើលងាយនូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះប្រគល់ទ្រព្យសម្រាប់អាចារ្យដល់អាចារ្យ ហើយស្វែងរកភរិយាដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ ធម៌ដូចម្តេច ក្នុងការស្វែងរកនោះ ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរកដោយការទិញ មិនបានស្វែងរកដោយការលក់ដូរ ស្វែងរកតែព្រាហ្មណីដែលគេបរិច្ចាគដោយប្រោះទឹកឲ្យ ព្រាហ្មណ៍នោះ គប់រកតែនាងព្រាហ្មណីផងគ្នា មិនបានគប់រកស្រ្តីក្សត្រិយ៍ មិនបានគប់រកស្រ្តីវេស្សៈ មិនបានគប់រកស្រ្តីសុទ្រៈ មិនបានគប់រកស្រ្តីចណ្ឌាល មិនបានគប់រកស្រ្តីនេសាទ មិនបានគប់រកស្រ្តីដែលមានផ្នួងសក់ ( សក់ជុក ) មិនបានគប់រកស្រ្តីជាងរថ មិនបានគប់រកស្រ្តីអ្នកចោលសម្រាម មិនបានគប់រកស្រ្តីដែលមានគភ៌ មិនបានគប់រកស្រ្តីដែលមានកូននៅបៅ មិនបានគប់រកស្រ្តីដែលមិនមានរដូវ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍មិនគប់រកស្រ្តីដែលមានគភ៌ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍គប់រកស្រ្តី ដែលមានគភ៌ហើយ មាណវកៈ និងមាណវិកានោះ ឈ្មោះថាកើតក្នុងគំនរលាមកដ៏ធំអាក្រក់ក្រៃពេក ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍ មិនគប់រកស្រ្តីដែលមានគភ៌ឡើយ ។ ម្នាលទោណៈ ចុះហេតុអ្វី បានជាព្រាហ្មណ៍មិនគប់រកស្រ្តីដែលមានកូននៅបៅ ។ ម្នាលទោណៈ ប្រសិនបើព្រាហ្មណ៍គប់រកស្រ្តីដែលមានកូននៅបៅហើយ មាណវកៈ និងមាណវិកានោះ ឈ្មោះថាជាអ្នកផឹករបស់មិនស្អាត ម្នាលទោណៈ ព្រោះហេតុនោះ បានជាព្រាហ្មណ៍មិនគប់រក

ស្ត្រីដែលមានកូននៅជៀ នាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាអ្នកមិនមានប្រយោជន៍ដោយកាម មិនមានប្រយោជន៍ដោយការលេង មិនមានប្រយោជន៍ដោយសេចក្តីត្រេកអរក្នុងកាម នាងព្រាហ្មណីរបស់ព្រាហ្មណ៍ មានប្រយោជន៍ដោយបុត្រតែប៉ុណ្ណោះ ។ ព្រាហ្មណ៍នោះញុំាងមេថុនឲ្យកើតឡើងហើយ ក៏ប្រាថ្នាមិនដាច់នូវសេចក្តីត្រេកអរក្នុងបុត្រនោះឯង ក៏នៅគ្រប់គ្រងទ្រព្យសម្បត្តិមិនបានចេញចាកផ្ទះមកបួសឡើយ ។ ឯព្រាហ្មណ៍ជាមរិយាទៈ តែងឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក មិនបានប្រព្រឹត្តកន្លងនូវធម៌នោះឡើយ ។ មរិយាទព្រាហ្មណ៍ឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក មិនបានប្រព្រឹត្តកន្លងនូវធម៌នោះដូច្នេះឯង ម្នាលទោណៈ ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍មរិយាទៈ ។ ម្នាលទោណៈ ព្រាហ្មណ៍ជាមរិយាទៈយ៉ាងនេះឯង ។ ម្នាលទោណៈ ចុះព្រាហ្មណ៍ជាសម្ភិន្នមរិយាទៈ តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ មានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតា កើតចាកគភ៌ដ៏បរិសុទ្ធដរាបអំពីតំណនៃជីដូនជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់ តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ ។ ព្រាហ្មណ៍នោះរមែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈ អស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈ អស់ ៤៨ ឆ្នាំរួចហើយស្វែងរកនូវទ្រព្យ សម្រាប់អាចារ្យដើម្បីអាចារ្យដោយធម៌ មិនស្វែងរកខុសធម៌ឡើយ ។ ម្នាលទោណៈ បណ្តាការស្វែងរកទាំងនោះ ការស្វែងរក

ដោយធម៌ តើដូចម្ដេច ។ គឺព្រាហ្មណ៍នោះ មិនបានស្វែងរក ដោយការភ្ជួរ មិនបានស្វែងរក ដោយការជួញ មិនបានស្វែងរក ដោយការរក្សាគោ មិនបានស្វែងរក ដោយអំពើនៃឋាន:ជាទាហាន មិនបានស្វែងរក ដោយការ:ជារាជបុរស មិនបានស្វែងរក ដោយសិប្បកម្មណានីមួយឡើយ គ្រាន់តែស្វែងរក ដោយការត្រាច់ទៅដើម្បីកិក្ខាប៉ុណ្ណោះ មិនបានមើលងាយនូវកិក្ខាកាជន:ឡើយ ។ ព្រាហ្មណ៍នោះ ប្រគល់ទ្រព្យសម្រាប់អាចារ្យ ដល់អាចារ្យហើយ ក៏ស្វែងរកកិរិយា ដែលគេបរិច្ចាគ ដោយព្រោះទឹកឲ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការទិញខ្លះ ដោយការលក់ដូរខ្លះ ព្រាហ្មណ៍នោះ រមែងគប់រកនាងព្រាហ្មណីខ្លះ គប់រកស្ត្រីក្សត្រិយ៍ខ្លះ គប់រកស្ត្រីវេស្ស:ខ្លះ គប់រកស្ត្រីសុទ្រ:ខ្លះ គប់រកស្ត្រីចណ្ឌាលខ្លះ គប់រកស្ត្រីនេសាទខ្លះ គប់រកស្ត្រីដែលមានផ្នួងសក់ ( សក់ជុក ) ខ្លះ គប់រកស្ត្រីជាងរថខ្លះ គប់រកស្ត្រីអ្នកចោលសំរាមខ្លះ គប់រកស្ត្រីដែលមានគភ៌ខ្លះ គប់រកស្ត្រីដែលមានកូនទៅបៅខ្លះ គប់រកស្ត្រីដែលមានរដូវខ្លះ គប់រកស្ត្រីដែលមិនមានរដូវខ្លះ ។ ព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាអ្នកមានប្រយោជន៍ដោយកាមខ្លះ មានប្រយោជន៍ដោយការលេងខ្លះ មានប្រយោជន៍ដោយការត្រេកអរក្នុងកាមខ្លះ នាងព្រាហ្មណីរបស់ព្រាហ្មណ៍ មានប្រយោជន៍ដោយបុត្រខ្លះ ។ ព្រាហ្មណ៍ជាមរិយាទ: មិនបានឋិតនៅក្នុងធម៌នោះ របស់ពួកព្រាហ្មណ៍អំពីបុរាណរៀងមក រមែងប្រព្រឹត្តកន្លងនូវធម៌នោះ ។ ព្រាហ្មណ៍មរិយាទ:មិនបានឋិតនៅក្នុងធម៌នោះ ប្រព្រឹត្តកន្លងលើសនូវធម៌របស់

ពួកព្រាហ្មណ៍អំពីបុរាណរៀងមក រមែងប្រព្រឹត្តកន្លងនូវធម៌នោះ ម្នាលទោណៈ ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍ជាសម្ភិន្នមរិយាទៈ ដូច្នេះឯង ។ ម្នាលទោណៈ ព្រាហ្មណ៍ជាសម្ភិន្នមរិយាទៈ យ៉ាងនេះឯង ។ ម្នាលទោណៈ ព្រាហ្មណ៍ជាព្រាហ្មណចណ្ឌាល តើដូចម្តេច ។ ម្នាលទោណៈ ព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកមានកំណើតស្អាតទាំងពីរខាង គឺខាងមាតា និងខាងបិតាកើតចាកគភ៌ដ៏បរិសុទ្ធ អំពីតំណនៃជីដូនទិងជីតាជាគម្រប់ ៧ មិនមានអ្នកណារិះគន់តិះដៀលដោយពោលដល់ជាតិកំណើតបានឡើយ ។ ព្រាហ្មណ៍នោះរមែងរៀនយកនូវមន្ត ប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំ លុះរៀនយកនូវមន្តប្រព្រឹត្តកោមារព្រហ្មចរិយៈអស់ ៤៨ ឆ្នាំរួចហើយ ក៏ស្វែងរកនូវទ្រព្យសម្រាប់អាចារ្យ ដើម្បីអាចារ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការភ្ជួរខ្លះ ដោយការជួញខ្លះ ដោយការរក្សាគោខ្លះ ដោយអំពើនៃបាំនៈជាទាហានខ្លះ ដោយសិប្បកម្មណាទីមួយខ្លះ ដោយការៈជារាជបុរសខ្លះ គ្រាន់តែស្វែងរក ដោយការត្រាច់ទៅដើម្បីភិក្ខាប៉ុណ្ណោះ មិនបានមើលងាយ នូវភិក្ខាភាជនៈឡើយ ។ ព្រាហ្មណ៍នោះក៏ប្រគល់ទ្រព្យ សម្រាប់អាចារ្យ ដល់អាចារ្យហើយ ក៏ស្វែងរកភរិយា ដែលគេបរិច្ចាគ ដោយប្រោះទឹកឲ្យ ដោយធម៌ខ្លះ មិនដោយធម៌ខ្លះ ដោយការទិញខ្លះ ដោយការលក់ដូរខ្លះ ព្រាហ្មណ៍នោះ រមែងគប់រកនាងព្រាហ្មណីខ្លះ គប់រកស្ត្រីក្សត្រិយ៍ខ្លះ គប់រកស្ត្រីវេស្សៈខ្លះ គប់រកស្ត្រីសុទ្ទៈខ្លះ គប់រកស្ត្រីចណ្ឌាលខ្លះ គប់រកស្ត្រីនេសាទខ្លះ គប់រកស្ត្រីដែលមានផ្នួងសក់ខ្លះ

គប់រកស្ត្រីជាងរថខ្លះ គប់រកស្ត្រីដែលចោលសំរាមខ្លះ គប់រកស្ត្រីដែលមានគភ៌ខ្លះ គប់រកស្ត្រីដែលមានកូននៅបៅខ្លះ គប់រកស្ត្រីដែលមានរដូវខ្លះ គប់រកស្ត្រីដែលមិនមានរដូវខ្លះ ។ នាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ជាអ្នកមានប្រយោជន៍ដោយកាមខ្លះ មានប្រយោជន៍ដោយការលេងខ្លះ មានប្រយោជន៍ដោយសេចក្តីត្រេកអរខ្លះ នាងព្រាហ្មណីរបស់ព្រាហ្មណ៍ មានប្រយោជន៍ដោយបុត្រខ្លះ ។ ព្រាហ្មណ៍នោះ រមែងចិញ្ចឹមជីវិតដោយការងារទាំងពួង ពួកព្រាហ្មណ៍ក៏បាននិយាយនឹងព្រាហ្មណ៍នោះ យ៉ាងនេះថា ហេតុអ្វី បានជាព្រាហ្មណ៍ដ៏ចម្រើនប្តេជ្ញា ចិញ្ចឹមជីវិតដោយការងារទាំងពួង ។ ព្រាហ្មណ៍នោះបាននិយាយយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ប្រៀបដូចភ្លើង រមែងឆេះរបស់ស្អាតខ្លះ ឆេះរបស់មិនស្អាតខ្លះ ភ្លើងក៏មិនបានប្រឡាក់ជាប់ ដោយរបស់នោះទេ យ៉ាងណាមិញ ម្នាលអ្នកទាំងឡាយដ៏ចម្រើន បើទុកជាព្រាហ្មណ៍ចិញ្ចឹមជីវិតដោយអំពើទាំងពួង ព្រាហ្មណ៍ ក៏មិនបានជាប់ប្រឡាក់ដោយការងារទាំងពួងនោះ ព្រាហ្មណ៍តែងចិញ្ចឹមជីវិតដោយការងារទាំងពួងដូច្នេះ ក៏យ៉ាងនោះដែរ ម្នាលទោណៈ ព្រោះហេតុនោះ បានជាហៅថា ព្រាហ្មណ៍ ជាព្រាហ្មណចណ្ឌាល ម្នាលទោណៈ ព្រាហ្មណ៍ជាព្រាហ្មណចណ្ឌាលយ៉ាងនេះឯង ។ ម្នាលទោណៈ ពួកឥសីជាប្រធានរបស់ពួកព្រាហ្មណ៍ អ្នកធ្វើមន្ត អ្នកញុំាងមន្តឲ្យប្រព្រឹត្តទៅ ពួកព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ រមែងច្រៀងតាមមន្តនោះ ពោលតាមមន្តនោះ ពោលតាមមន្តដែលឥសីពោលហើយ បង្រៀនតាមមន្តដែលឥសីបង្រៀន

ហើយ ជាមន្តពីបុរាណ ជាមន្តបទដែលឥសីច្រៀងហើយ ឲ្យប្រព្រឹត្តទៅហើយ បានធ្វើឲ្យជាគំនរទុកហើយ ឥសីទាំងនោះ គឺអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមទគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ឥសីទាំងនោះ រមែងបញ្ញត្តព្រាហ្មណ៍ទាំង ៥ នេះ គឺ ព្រហ្មសមៈ ១ ទេវសមៈ ១ មរិយាទៈ ១ សម្ភិន្នមរិយាទៈ ១ គម្រប់ ៥ នឹងព្រាហ្មណចណ្ឌាល ។ ម្នាលទោណៈ អ្នកជាព្រាហ្មណ៍អ្វី ក្នុងព្រាហ្មណ៍ទាំងនោះ ។ បពិត្រព្រះគោតមដ៏ចម្រើន បើតាមទំនងនេះ ខ្ញុំព្រះអង្គមិនពេញជាព្រាហ្មណចណ្ឌាលទេ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតនេះច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់នូវទីពឹងស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

# អដ្ឋកថា

## ទោណសូត្រ

[ ៩២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទោណសូត្រទី ២ ដូចតទៅនេះ បទថា **តុំបិ ធោ** កាត់បទជា **តុម្ហិ នុ** ប្រែថា សូម្បីលោក ។ បទថា **បវត្តារោ** គឺអ្នកបង្រៀន ។ បទថា **យេសំ** គឺជាសម្បត្តិរបស់ឥសីទាំងឡាយណា ។ បទថា **មន្តបទំ** បានដល់ មន្ត គឺវេទនោះឯង ។ បទថា **គីតំ** បានដល់ ពួកបុរាណ

ព្រាហ្មណ៍ ១០ នាក់ មានអដ្ឋកព្រាហ្មណ៍ជាដើម ស្វាធ្យាយហើយ ដោយសរភញ្ញសម្បត្តិ គឺសំឡេង ។ បទថា **បវុត្តំ** បានដល់ ប្រាប់ហើយដល់អ្នកដទៃ ។ បទថា **សមិហិតំ** បានដល់ រួបរួម គឺធ្វើឲ្យជាគំនរ អធិប្បាយថា តាំងជាក្រុមជាដុំ ។ បទថា **តទនុគាយន្តិ** សេចក្តីថា ឥឡូវនេះ ព្រាហ្មណ៍ទាំងឡាយក៏ច្រៀង ស្វាធ្យាយមន្ត តាមដែលបុរាណព្រាហ្មណ៍ទាំងនោះច្រៀងមកអំពីមុន ។ បទថា **តទនុភាសន្តិ** បានដល់ ពោលមន្តនោះតាម ។ បទនេះជាវេវចនៈនៃបទមុននោះឯង ។ បទថា **ភាសិតមនុភាសន្តិ** បានដល់ ពោលតាមបុរាណព្រាហ្មណ៍ទាំងនោះពោល ។ បទថា **សជ្ឈាយិតមនុសជ្ឈាយន្តិ** បានដល់ ស្វាធ្យាយតាមបុរាណព្រាហ្មណ៍ទាំងឡាយនោះស្វាធ្យាយ ។ បទថា **វាចិតមនុវាចេន្តិ** បានដល់ ប្រាប់តាមបុរាណព្រាហ្មណ៍ទាំងឡាយនោះ ប្រាប់ដល់អ្នកដទៃ ។

បទថា **សេយ្យថីទំ** បានដល់ បុរាណព្រាហ្មណ៍ទាំងនោះ គឺអ្នកណាខ្លះ ។ បទថា **អដ្ឋកោ** ជាដើម ជាឈ្មោះរបស់បុរាណព្រាហ្មណ៍ទាំងនោះ ។ បានឮថា បុរាណព្រាហ្មណ៍ទាំងនោះ សម្លឹងមើលដោយទិព្វចក្ខុហើយ មិនធ្វើការបៀតបៀនអ្នកដទៃ ប្រៀបធៀបបាវចនា គឺពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ ព្រះនាមថាកស្សបសម្ពុទ្ធ ហើយរៀបរៀងមន្តទាំងឡាយ ។ តែព្រាហ្មណ៍មួយពួកទៀតដាក់បញ្ចូលកម្ម មានបាណាតិបាតជាដើមចូលទៅទម្លាយវេទទាំង ៣ ធ្វើឲ្យមានការជំទាស់នឹងព្រះពុទ្ធវចនៈ ។

*បទថា* **អស្សុ** *ក្នុងបទថា* **ត្យាស្សុមេ** *នេះ ត្រឹមតែជានិបាត ។ អធិប្បាយថា ព្រាហ្មណ៍ទាំងនោះ បញ្ញត្តព្រាហ្មណធម៌ទាំងឡាយ ៥ នេះ ។ បទថា* **មន្តេ អធិយមានោ** *បានដល់ ទន្ទេញនូវវេទទាំងឡាយ ។ បទថា* **អាចរិយធនំ** *បានដល់ ទ្រព្យបូជាអាចារ្យ គឺទ្រព្យដែលជាចំណែកបូជាដល់អាចារ្យ ។ បទថា* **ន ឥស្សត្ថេន** *បានដល់ មិនមែនឲ្យកើតឡើងដោយការងារអ្នកចម្បាំងអាជីព ។ បទថា* **ន រាជបោរិសេន** *បានដល់ មិនមែនឲ្យកើតឡើងដោយភាពជាខ្ញុំរាជការ ។*

*បទថា* **កេវលំ ភិក្ខាចរិយាយ** *បានដល់ កើតឡើងដោយភិក្ខាចារដែលបរិសុទ្ធប៉ុណ្ណោះ ។ បទថា* **កបាលំ អនតិមញ្ញមានោ** *បានដល់ មិនមើលងាយកិក្ខាភាជនៈ ។ ទោណព្រាហ្មណ៍នោះ កាន់កិក្ខាភាជនៈដាក់ទឹកពេញហើយទូលលើត្រង់ក្បាល ទៅឈរត្រង់ទ្វាររបស់ត្រកូលទាំងឡាយស្រែកថា ខ្ញុំប្រព្រឹត្តកោមារព្រហ្មចារ្យ មកអស់កាល ៤៨ ឆ្នាំ ឯមន្តរបស់ខ្ញុំ ក៏រៀនហើយ ខ្ញុំនឹងឲ្យទ្រព្យបូជាអាចារ្យដល់អាចារ្យ សូមអ្នកទាំងឡាយឲ្យទ្រព្យដល់ខ្ញុំចុះ ដូច្នេះ ។ ពួកមនុស្សបានស្តាប់ពាក្យនោះហើយ ក៏ឲ្យទ្រព្យ ៨ កហាបណៈខ្លះ ១៦ កហាបណៈខ្លះ ១០០ កហាបណៈខ្លះ តាមសមត្ថភាព ទោណព្រាហ្មណ៍ត្រាច់ទៅសូមគ្រប់ភូមិយ៉ាងនេះហើយ ជូនទ្រព្យដែលបានដល់អាចារ្យ ពាក្យនោះ លោកពោលសំដៅដល់កិក្ខាភាជនៈនោះ ។*

*បទថា* **ឯវំ ខោ ទោណព្រាហ្មណោ ព្រហ្មសមោ ហោតិ** *សេចក្តីថា*

ព្រាហ្មណ៍ជាបុគ្គល ឈ្មោះថា ស្មើដោយព្រហ្ម ព្រោះប្រកបដោយព្រហ្មវិហារ យ៉ាងនេះ ។ បទថា **នេវ កាយេន ន វិញ្ញាយេន** បានដល់ មិនមែនខ្លួនឯងទិញ មិនមែនអ្នកដទៃលក់ឲ្យ ។ បទថា **ឧទកូបសដ្ឋំ** បានដល់ ដែលគេប្រូចទឹកលះឲ្យ ។ ទោណព្រាហ្មណ៍នោះ ទៅឈរត្រង់ទ្វាររបស់ត្រកូលដែលមានស្រីជំទង់ កាលជនទាំងនោះសួរថា ហេតុអ្វី ទើបលោកឈរ ព្រាហ្មណ៍ឆ្លើយថា ខ្ញុំប្រព្រឹត្តកោមារព្រហ្មចរិយៈ មក ៤៨ ឆ្នាំ ខ្ញុំនឹងឲ្យវត្តគ្រប់យ៉ាងដល់អ្នក សូមអ្នកឲ្យស្រីក្រមុំដល់ខ្ញុំចុះ ។ ពួកជនទាំងនោះ នាំស្រីក្រមុំមកហើយ ប្រូចទឹកលើដៃរបស់ព្រាហ្មណ៍នោះ ហើយឲ្យ ។ ទោណព្រាហ្មណ៍នោះទទួលស្រីក្រមុំដែលគេប្រូចទឹកឲ្យជាភរិយា ក៏ត្រឡប់ទៅ ។

បទថា **អតិមិឡ្ហជោ** បានដល់ កើតក្នុងទីស្មោកគ្រោកក្រៃលែង គឺគំនរលាមកធំ ។ បទថា **តស្សស្ស** កាត់បទជា **តស្ស ឯតស្ស** ។ បទថា **ន ធវត្ថា** បានដល់ មិនត្រូវការលេង ។ បទថា **ន រតត្ថា** បានដល់ មិនត្រូវការសេចក្តីត្រេកអរក្នុងកាម ។ បទថា **មេថុនំ ឧប្បាទេត្វា** សេចក្តីថា ព្រាហ្មណ៍ឲ្យកំណើត ធីតា ឬបុត្រ ហើយគិតថា ឥឡូវនេះ បវេណីនឹងបន្តទៅ ទើបចេញបួស ។ បទថា **សុគតិំ សគ្គំ លោកំ** នេះ លោកពោលសំដៅដល់ព្រហ្មលោកប៉ុណ្ណោះ ។ បទថា **ទេវសមោ ហោតិ** បានដល់ បុគ្គលឈ្មោះថា ស្មើដោយទេវតា ព្រោះប្រកបដោយទិព្វវិហារធម៌ ។ បទថា **តមេវ បុត្តស្សាទំ និកាមយមានោ** សេចក្តីថា ព្រាហ្មណ៍ប្រាថ្នា គឺស្រឡាញ់ក្នុង

បុត្រ ការពេញចិត្តក្នុងបុត្រដែលកើតឡើង ព្រោះឃើញធីតា ឬបុត្រកើត ។ បទថា **កុដុម្ពំ អជ្ឈាវសតិ** បានដល់ នៅត្រង់កណ្តាលទ្រព្យសម្បត្តិ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ទោណសូត្រទី ២ ចប់**

# សុត្តន្តបិដក

## សង្គារវសូត្រទី ៣

[ ៩៣ ] គ្រានោះឯង សង្គារវព្រាហ្មណ៍ ( ព្រាហ្មណ៍ឈ្មោះសង្គារវៈ ) បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលសួរព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ បានជាមន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ជួនកាលមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន អ្វីជាហេតុ អ្វីជាបច្ច័យ បានជាមន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង ជួនកាលប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ។

ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវកាមរាគរួបរឹត ត្រូវកាមរាគគ្របសង្កត់ហើយ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវកាមរាគដែលកើតឡើង សម័យនោះ ក៏មិនបានដឹង មិនបានឃើញតាមពិតនូវប្រយោជន៍របស់ខ្លួនខ្វះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិតនូវប្រយោជន៍អ្នកដទៃខ្វះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍ទាំងពីរខ្វះ ( ព្រោះហេតុនោះ ) មន្តទាំងឡាយដែលគេបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកដែលលាយដោយល័ក្ត ឬរមៀត ពណ៌លឿង ឬពណ៌ហង្សបាទ បុរសមានចក្ខុពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវកាមរាគរួបរឹត ត្រូវកាមរាគគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវកាមរាគដែលកើតឡើង សម័យនោះ ក៏មិនបានដឹង មិនបានឃើញតាមពិតនូវប្រយោជន៍របស់ខ្លួនខ្វះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍អ្នកដទៃខ្វះ សម័យនោះ មិនបានដឹង មិនបានឃើញតាមពិត នូវប្រយោជន៍ទាំងពីរខ្វះ ( ព្រោះហេតុនោះ ) មន្តទាំងឡាយដែលបុគ្គលបានស្វាធ្យាយអស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា

បុគ្គលមានចិត្តត្រូវព្យាបាទរួបរឹត ត្រូវព្យាបាទគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនបានប្រាកដ មិនបាច់ពោលដល់មន្ត ដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ត្រូវភ្លើងឆេះហើយ ក៏ពុះឡើងចំហាយ បុរសមានចក្ខុពិចារណាមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវព្យាបាទរួបរឹត ត្រូវព្យាបាទគ្របសង្កត់ហើយ រមែងមិនដឹងច្បាស់តាមពិតនូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនមានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនស្វាធ្យាយឡើយ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តត្រូវថីនមិទ្ធៈរួបរឹត ត្រូវថីនមិទ្ធៈគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវថីនមិទ្ធៈ ដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងមិនប្រាកដ មិនបាច់ពោលដល់មន្ត ដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកដែលសារាយនិងចករួបរឹត បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ ក៏មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍

សម័យណា បុគ្គលមានចិត្តត្រូវថីនមិទ្ធៈរួបរឹត ត្រូវថីនមិទ្ធគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវថីនមិទ្ធៈដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយអស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹត ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ត្រូវខ្យល់បក់ដ៏ញាប់ញ័រ កម្រើកកើតទៅជារលក បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹត ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយអស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្ត ដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ត្រូវវិចិកិច្ឆារួបរឹត ត្រូវវិចិកិច្ឆាគ្របសង្កត់ ទាំងមិនដឹងច្បាស់

តាមពិត នូវការរលាស់ចេញនូវវិចិកិច្ឆា ដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកល្អក់ មិនបាននៅនឹង កើតទៅជាភក់ បុគ្គលតម្កល់ទុកក្នុងទីងងឹត បុរសមានចក្ខុ ពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ ក៏មិនគប្បីដឹង មិនគប្បីឃើញតាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ត្រូវវិចិកិច្ឆារួបរឹត ត្រូវវិចិកិច្ឆាគ្របសង្កត់ ទាំងមិនដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវវិចិកិច្ឆាដែលកើតឡើង ។បេ។ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង ក៏មិនបានប្រាកដ មិនបាច់ពោលដល់មន្តដែលមិនបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលកាមរាគ មិនបានរួបរឹត ដែលកាមរាគមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវកាមរាគ ដែលកើតឡើង សម័យនោះ ក៏ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ខ្លួនឯងខ្លះ សម័យនោះដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍អ្នកដទៃខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ទាំងពីរខ្លះ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដមិនបាច់ពោលដល់មន្ត ដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូច

ភាជនៈពេញដោយទឹក ដែលមិនបានច្រឡំដោយល័ក្ត ឬរមៀត ពណ៌លឿង ឬពណ៌ហង្សបាទ បុរសមានចក្ខុពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលកាមរាគមិនបានរួបរឹត ដែលកាមរាគមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវកាមរាគ ដែលកើតឡើង សម័យនោះ រមែងដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ខ្លួនខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍អ្នកដទៃខ្លះ សម័យនោះ ដឹងច្បាស់ ឃើញច្បាស់តាមពិតនូវប្រយោជន៍ទាំងពីរខ្លះ ( ព្រោះហេតុនោះ ) មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍មួយទៀត សម័យណា បុគ្គលមានចិត្តដែលព្យាបាទមិនបានរួបរឹត ដែលព្យាបាទមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក មិនបានក្តៅ មិនបានពុះ មិនបានចំហាយឡើងដោយភ្លើង បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្ត ដែលព្យាបាទមិនបានរួបរឹត ដែល

ព្យាបាទមិនបានគ្រប់សង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវព្យាបាទដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយអស់កាលជាយូរអង្វែងរមែងប្រាកដ មិនបាច់ពោលដល់មន្តដែលបានស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ដែលថីនមិទ្ធៈមិនបានរួបរឹត ដែលថីនមិទ្ធៈមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវថីនមិទ្ធៈដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ដែលសារាយ និងចកមិនបានរួបរឹត បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលថីនមិទ្ធៈមិនបានរួបរឹត ដែលថីនមិទ្ធៈមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញ នូវថីនមិទ្ធៈដែលកើតឡើង ។បេ។ មន្តទាំងឡាយដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ដែលឧទ្ធច្ចកុក្កុច្ចៈមិនបានរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចៈមិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ

អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹក ដែលខ្យល់មិនបានបក់ មិនបានឲ្យកម្រើក មិនបានឲ្យញាប់ញ័រ មិនមានរលក បុរសមានចក្ខុ បានពិចារណាមើលមុខនិមិត្តរបស់ខ្លួន ក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលឧទ្ធច្ចកុក្កុច្ចៈ មិនបានរួបរឹត ដែលឧទ្ធច្ចកុក្កុច្ចៈ មិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ មួយទៀត សម័យណា បុគ្គលមានចិត្ត ដែលវិចិកិច្ឆា មិនបានរួបរឹត ដែលវិចិកិច្ឆាមិនបានគ្របសង្កត់ហើយ ទាំងដឹងច្បាស់តាមពិត នូវការរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង ។បេ។ មន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ម្នាលព្រាហ្មណ៍ ដូចភាជនៈពេញដោយទឹកថ្លាស្អាត មិនល្អក់ដែលបុគ្គលយកទៅតម្កល់ទុកក្នុងទីមានពន្លឺ បុរសមានចក្ខុបានពិចារណាមើលមុខនិមិត្តរបស់ខ្លួនក្នុងភាជនៈនោះ គប្បីដឹងច្បាស់ ឃើញច្បាស់តាមពិត យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ សម័យណា បុគ្គលមានចិត្តដែលវិចិកិច្ឆា មិនបានរួបរឹត ដែលវិចិកិច្ឆា មិនបានគ្របសង្កត់ ទាំងដឹងច្បាស់តាមពិតនូវ

ការរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង ។បេ។ មន្តទាំងឡាយដែលបុគ្គលមិនបានស្វាធ្យាយអស់កាលជាយូរអង្វែង រមែងប្រាកដ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាហេតុ នេះឯងជាបច្ច័យ ឲ្យមន្តទាំងឡាយដែលបុគ្គលបានស្វាធ្យាយ អស់កាលជាយូរអង្វែង មិនឲ្យប្រាកដ ក្នុងកាលខ្លះ មិនបាច់ពោលដល់មន្ត ដែលមិនបានស្វាធ្យាយឡើយ ។ ម្នាលព្រាហ្មណ៍ នេះឯងជាហេតុ នេះឯងជាបច្ច័យ ឲ្យមន្តទាំងឡាយ ដែលបុគ្គលមិនបានស្វាធ្យាយ អស់កាលជាយូរអង្វែង រមែងឲ្យប្រាកដក្នុងកាលខ្លះ មិនបាច់ពោលដល់មន្តដែលស្វាធ្យាយឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតនេះច្បាស់ណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើនចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## សង្គារវសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសង្គារវសូត្រទី ៣ ដូចតទៅនេះ បទថា **បគេវ** ប្រែថា មុននោះឯង ។ បទថា **កាមរាគបរិយុដ្ឋិតេន** បានដល់ត្រូវកាមរាគៈទាញ ។ បទថា **កាមរាគបរេតេន** បានដល់ ត្រូវកាមរាគៈជាប់

តាម ។ បទថា **និស្សរណំ** សេចក្តីថា ការចេញទៅនៃកាមរាគៈ មាន ៣ យ៉ាង គឺចេញទៅដោយការសង្កត់សង្កិន ១ ចេញទៅមួយជួរខណៈ ១ ចេញទៅជាសមុច្ឆេទ ១ ក្នុងនិស្សរណៈ ៣ យ៉ាងនោះ បឋមជ្ឈានក្នុងអសុភកម្មដ្ឋាន ឈ្មោះថា ចេញទៅដោយការសង្កត់សង្កិន ។ វិបស្សនា ឈ្មោះថា ចេញទៅមួយជួរខណៈ អរហត្តមគ្គ ឈ្មោះថា ចេញទៅជាសមុច្ឆេទ អធិប្បាយថា មិនដឹងការចេញទៅទាំង ៣ យ៉ាងនោះ ។ ក្នុងបទថា **អត្តត្ថម្បិ** ជាដើម ប្រយោជន៍នៃខ្លួន បានដល់ អរហត្ត ឈ្មោះថា ប្រយោជន៍ខ្លួន ប្រយោជន៍របស់បុគ្គលដែលឲ្យបច្ច័យ ឈ្មោះថា ប្រយោជន៍អ្នកដទៃ ប្រយោជន៍ទាំង ២ នោះឯង ឈ្មោះថា ប្រយោជន៍ទាំង ២ ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងអស់ដោយន័យនេះ ។

តែគប្បីជ្រាបការផ្សេងគ្នាដូចតទៅនេះ ។ ពិតហើយ ក្នុងបទជាដើមថា **ព្យាបាទស្ស និស្សរណំ** ការចេញទៅ មាន ២ យ៉ាង គឺចេញទៅដោយសង្កត់ទុក និងចេញទៅជាសមុច្ឆេទ ។ ក្នុងនិស្សរណៈ ២ យ៉ាងនោះ នឹងពោលសម្រាប់ព្យាបាទមុន មេត្តាបឋមជ្ឈាន ឈ្មោះថា ចេញទៅដោយការសង្កត់សង្កិន អនាគាមិមគ្គ ឈ្មោះថា ចេញទៅជាសមុច្ឆេទ ។ សម្រាប់ថីនមិទ្ធៈ អាលោកសញ្ញា ឈ្មោះថា ចេញទៅដោយការសង្កត់សង្កិន អរហត្តមគ្គ ឈ្មោះថា ចេញទៅជាសមុច្ឆេទ ។ សម្រាប់ឧទ្ធច្ចកុក្កុច្ចៈ សមថៈណាមួយ ឈ្មោះថា ចេញទៅដោយការសង្កត់សង្កិន តែក្នុងទីនេះ អរហត្តមគ្គ ឈ្មោះថា

នាំចេញទៅជាសមុច្ឆេទនៃឧទ្ធច្ចៈ អនាគាមិមគ្គ ឈ្មោះថា នាំចេញទៅជាសមុច្ឆេទនៃកុក្កុច្ចៈ សម្រាប់វិចិកិច្ឆា ការកំណត់ធម៌ ឈ្មោះថា នាំចេញទៅដោយការសង្កត់សង្កិន បឋមមគ្គ ឈ្មោះថា នាំចេញទៅដោយសមុច្ឆេទ ។

ក្នុងសូត្រនេះ លោកពោលឧបមាទាំងឡាយណា មាន **សេយ្យថាបិ ព្រាហ្មណ ឧទបត្តោ សំសដ្ឋោ លាខាយ វា** ដូច្នេះជាដើម ក្នុងឧបមាទាំងនោះ បទថា **ឧទបត្តោ** បានដល់ ភាជនៈដែលពេញដោយទឹក ។ បទថា **សំសដ្ឋោ** បានដល់ លាយពណ៌ច្រើនប្រភេទ ។ បទថា **ឧក្កុដ្ឋិតោ** បានដល់ ក្តៅខ្លាំង ។ បទថា **ឧស្សទកជាតោ** បានដល់ មានផ្សែងពាសពេញ ។ បទថា **សេវាលបណកបរិយោនទ្ធោ** បានដល់ គ្របដណ្តប់ដោយសារាយមានប្រភេទជាពូជល្វជាដើម ឬចកដែលមានពណ៌ខៀវ និងពណ៌ដូចខ្នងកង្កែបដែលកើតបិទបាំងផ្ទៃទឹក ។ បទថា **វាតេរិតោ** បានដល់ ត្រូវខ្យល់បក់ឲ្យរញ្ជួយ ។ បទថា **អាវិលោ** គឺមិនថ្លា ។ បទថា **លុឡិតោ** គឺមិនស្ងៀមនឹង ។ បទថា **កលលីភូតោ** គឺមានភក់ ។ បទថា **អន្ធការេ និក្ខិត្តោ** បានដល់ ត្រូវដាក់ក្នុងទីមិនមានពន្លឺ ដូចជាក្នុងជង្រុកជាដើម ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់ញ្ញាក់ទេសនាដោយកព ៣ ហើយទ្រង់បញ្ចប់ដោយអគ្គធម៌ គឺអរហត្ត ។ ចំណែកព្រាហ្មណ៍តាំងនៅក្នុងគុណត្រឹមតែសរណៈប៉ុណ្ណោះ ៕

**អដ្ឋកថា សង្គារវសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ការណបាលីសូត្រទី ៤

[ ៩៤ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា ជិតមហាវ័ន ក្បែរក្រុងវេសាលី ។ ក៏ក្នុងសម័យនោះឯង ការណបាលិព្រាហ្មណ៍ ( ព្រាហ្មណ៍ឈ្មោះការណបាលី ) តែងប្រើជនឲ្យធ្វើការងាររបស់ពួកលិច្ឆវិរាជ ។ ការណបាលិព្រាហ្មណ៍បានឃើញបិង្គិយានិព្រាហ្មណ៍ ( ព្រាហ្មណ៍ឈ្មោះបិង្គិ-យានិ ) កំពុងដើរមកអំពីចម្ងាយ ក៏និយាយទៅនឹងបិង្គិយានិព្រាហ្មណ៍ដូច្នេះថា បិង្គិយានិដ៏ចម្រើន មកពីណាហ្ន៎ ក្នុងវេលាថ្ងៃត្រង់ ។ ម្នាលអ្នកដ៏ចម្រើន ខ្ញុំទើបនឹងមកអំពីសម្នាក់ព្រះសមណគោតម ក្នុងទីឯណោះ ។ បិង្គិយានិដ៏ចម្រើន សម្គាល់នូវហេតុនោះដូចម្តេច សម្គាល់ក្នុងសេចក្តីឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតមថា ជាបណ្ឌិតឬ ។ ម្នាលអ្នកដ៏ចម្រើន ខ្ញុំជាអ្វី ខ្ញុំនឹងដឹងក្នុងការឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតមដូចម្តេចបាន ។ បុគ្គលណាដឹងក្នុងការឈ្លាសវៃ ដោយប្រាជ្ញារបស់ព្រះសមណគោតមបាន បុគ្គលនោះស្រដៀងគ្នានឹងព្រះសមណគោតមដោយពិត ឮថាបិង្គិយានិដ៏ចម្រើនរមែងសរសើរព្រះសមណគោតម ដោយពាក្យសរសើរដ៏លើសលុបដូច្នេះ ម្នាលអ្នកដ៏ចម្រើន ខ្ញុំជាអ្វី ខ្ញុំនឹងសរសើរព្រះសមណគោតមដូចម្តេច ។ ព្រះគោតមដ៏ចម្រើននោះ ប្រសើរក្រៃពេក ប្រសើរជាងទេវតា និងមនុស្សទាំងឡាយដូច្នេះ បិង្គិយានិដ៏ចម្រើន ឃើញនូវអំណាចប្រយោជន៍ដូចម្តេច បានជាជ្រះថ្លាក្នុងព្រះសមណគោតមយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ដូចបុរសដែលឆ្អែតដោយរសដ៏

ប្រសើរ រមែងមិនប្រាថ្នានូវរសទាំងឡាយដទៃ ដ៏ថោកទាបឡើយ យ៉ាងណាមិញ ម្នាលអ្នកដ៏ចម្រើន ( បុរស ) រមែងស្តាប់ធម៌ ទោះបីជាសុត្តៈ ឬជាគេយ្យៈ ទោះបីជាវេយ្យាករណៈ ឬជាអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចម្រើននោះ ក្នុងកាលណាៗ ហើយ ( បុរសនោះ ) ក៏មិនប្រាថ្នានូវវាទៈរបស់ពួកសមណព្រាហ្មណ៍ជាច្រើនដទៃ ក្នុងកាលនោះៗ ឡើយ ម្នាលអ្នកដ៏ចម្រើនមួយទៀត ដូចបុរសត្រូវសេចក្តីស្រេកឃ្លាន និងភាពនៃកម្លាំងថមថយ គ្របសង្កត់ហើយ គប្បីបាននូវនំមានរសឆ្ងាញ់ បុរសនោះលិទ្ធភក្ស ក្នុងកាលណាៗក៏បាននូវរសឆ្ងាញ់ ដ៏មិនលាយឡំក្នុងកាលនោះៗ យ៉ាងណាមិញ ម្នាលអ្នកដ៏ចម្រើន ( បុរស ) ស្តាប់ធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចម្រើននោះ ក្នុងកាលណាៗ តែងបាននូវការៈពេញចិត្ត តែងបាននូវសេចក្តីជ្រះថ្លានៃចិត្ត ក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ ម្នាលអ្នកដ៏ចម្រើន មួយទៀត ដូចបុរសបានដុំខ្លឹមចន្ទន៍ នៃខ្លឹមចន្ទន៍លឿង ឬខ្លឹមចន្ទន៍ក្រហម ហើយគប្បីហិតស្រូប ទោះបីអំពីគល់ ឬអំពីកណ្តាល ឬអំពីចុង ក្នុងកាលណាៗ គង់បាននូវក្លិនក្រអូប មិនលាយឡំដូចគ្នា យ៉ាងណាមិញ ម្នាលអ្នកដ៏ចម្រើន ( បុរស ) ស្តាប់ធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចម្រើននោះ ក្នុងកាលណាៗហើយ តែងបាននូវបាមោជ្ជ តែងបាននូវសោមនស្ស ក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ ម្នាលអ្នកដ៏ចម្រើន មួយទៀត ដូចបុរសមានអាពាធ ដល់នូវសេចក្តី

ទុក្ខមានជំងឺធ្ងន់ ពេទ្យអ្នកឈ្លាសអង់អាច គប្បីនាំបង់នូវអាពាធ របស់បុរសនោះចេញបាន ដោយឋានៈ យ៉ាងណាមិញ ម្នាលអ្នកដ៏ចម្រើន ( បុរស ) ស្តាប់នូវធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈរបស់ព្រះគោតមដ៏ចម្រើននោះ ក្នុងកាលណាៗ ហើយ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ ក៏ដល់នូវសេចក្តីវិនាស ក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ ម្នាលអ្នកដ៏ចម្រើន មួយទៀត ដូចស្រះបោក្ខរណីមានទឹកថ្លា មានទឹកឆ្ងាញ់ មានទឹកត្រជាក់ មានទឹកស មានកំពង់រាបស្មើ គួរជាទីត្រេកអរ ជួនជាមានបុរសម្នាក់មកដល់ បុរសនោះត្រូវសេចក្តីក្តៅរោលរាល ត្រូវសេចក្តីក្តៅគ្របសង្កត់ នឿយព្រួយលំបាកតាមផ្លូវ តក់ស្លុតស្រេកឃ្លាន ក៏ចុះទៅកាន់ស្រះបោក្ខរណីនោះ ងូតផង ផឹកផង គប្បីកម្ចាត់បង់នូវសេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក សេចក្តីក្តៅក្រហាយទាំងពួងបាន យ៉ាងណាមិញ ម្នាលអ្នកដ៏ចម្រើន ( បុរស ) ស្តាប់ធម៌ ទោះបីសុត្តៈ ឬគេយ្យៈ ទោះបីវេយ្យាករណៈ ឬអព្ភូតធម្មៈ របស់ព្រះគោតមដ៏ចម្រើននោះ ក្នុងកាលណាៗ ហើយ សេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក សេចក្តីក្តៅក្រហាយទាំងពួង ក៏ស្ងប់រម្ងាប់ទៅក្នុងកាលនោះៗ ក៏យ៉ាងនោះឯង ។ កាលដែលបិង្គិយានិព្រាហ្មណ៍ពោលយ៉ាងនេះហើយ ការណបាលិព្រាហ្មណ៍ក៏ក្រោកចាកអាសនៈធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ហើយលុតមណ្ឌលជង្គង់ខាងស្តាំលើផែនដី ប្រណម្យអញ្ជលីចំពោះទៅព្រះដ៏មានព្រះភាគ ហើយបន្លឺនូវឧទានជាគម្រប់ ៣ ដងថា សូមនមស្ការព្រះ

*ដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្ត-សម្មាសម្ពុទ្ធអង្គនោះ ។ ម្នាលបិង្គិយានិដ៏ចម្រើន ច្បាស់ណាស់ ម្នាលបិង្គិយានិដ៏ចម្រើន ច្បាស់ពេកណាស់ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេង ពុំនោះសោត ដូចជាគេទ្រោលប្រទីប ក្នុងទីងងឹតដោយគិតថា បុរសអ្នកមានចក្ខុ តែងឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលបិង្គិយានិដ៏ចម្រើន បានប្រកាសដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ។ ម្នាលបិង្គិយានិដ៏ចម្រើន ខ្ញុំសូមដល់នូវព្រះគោតមដ៏ចម្រើននោះផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមបិង្គិយានិដ៏ចម្រើន ចាំទុកនូវខ្ញុំថាជាឧបាសកដល់នូវសរណៈ ស្មើដោយជីវិតចាប់ដើមអំពីថ្ងៃនេះតទៅ ។*

# អដ្ឋកថា

## ការណបាលីសូត្រ

*[ ៩៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងការណបាលីសូត្រទី ៤ ដូចតទៅនេះ បទថា* **ការណបាលី** *ជាឈ្មោះនៃព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ ឈ្មោះថាការណបាលី ព្រោះធ្វើរាជការក្នុងរាជសម្នាក់ ។ បទថា* **កម្មន្តំ ការេតិ** *សេចក្តីថា ការណបាលីព្រាហ្មណ៍ក្រោកអំពីព្រឹក ធ្វើទ្វារប៉ម និងកំពែង ដែល*

មិនទាន់បានលាប ពិនិត្យមើលទីដែលបាក់បែក ។

បទថា **បិង្គិយានី ព្រាហ្មណំ** បានដល់ ព្រាហ្មណ៍ដែលជាអរិយសាវក តាំងនៅក្នុងអនាគាមិផល ទើបមានឈ្មោះយ៉ាងនេះ ។ បានឮថា ព្រាហ្មណ៍នោះក្រោកអំពីព្រលឹម កាន់នូវគ្រឿងក្រអូប និងផ្កាជាដើម ទៅគាល់ព្រះ-សាស្តា ថ្វាយបង្គំហើយ បូជាដោយផ្កាជាដើម ហើយទើបចូលក្រុង ។ នេះជាកិច្ចវត្តប្រចាំថ្ងៃរបស់ព្រាហ្មណ៍ ។ ការណបាលីព្រាហ្មណ៍នោះ បានឃើញបិង្គិយានីធ្វើកិច្ចវត្តយ៉ាងនោះហើយ កំពុងដើរមក ។

បទថា **ឯតទវោច** សេចក្តីថា ការណបាលីព្រាហ្មណ៍គិតថា ព្រាហ្មណ៍នេះមានបញ្ញា មានញាណចាស់ក្លា ទៅណាមកណា អំពីព្រលឹមហ្ន៎ ឃើញព្រាហ្មណ៍ដើរចូលមកជិតដោយលំដាប់ ទើបពោលពាក្យជាដើមថា **ហន្ទកុតោ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ទិវា ទិវស្ស** បានដល់ ពេលថ្ងៃ អធិប្បាយថា ថ្ងៃត្រង់ ។

បទថា **បណ្ឌិតោ មញ្ញតិ** ក្នុងសូត្រនេះ មានអត្ថថា ការណបាលីព្រាហ្មណ៍គិតថា បិង្គិយានីព្រាហ្មណ៍ រមែងសម្គាល់ព្រះសមណគោតមថាជាបណ្ឌិត ឬមិនមែនហ្ន៎ ។ បទថា **កោចាហម្ភោ** សេចក្តីថា លោកដ៏ចម្រើន ខ្ញុំជានរណា ដែលថា ដឹងដល់ការឈ្លាសវៃ នៃបញ្ញារបស់ព្រះសមណគោតមបាននោះ ។ បទថា **កោ ច សមណស្ស គោតមស្ស បញ្ញាវេយ្យត្តិយំ ជានិស្សាមិ** សេចក្តីថា បិង្គិយានីព្រាហ្មណ៍សម្តែងការមិនដឹងរបស់ខ្លួន ដោយប្រការទាំង

ពួនយ៉ាងនេះថា ខ្ញុំនឹងដឹងការឈ្លាសនៃព្រះបញ្ញារបស់គោតមបានអំពីណា គឺ ខ្ញុំនឹងដឹងបានដោយហេតុណា ។ បទថា **សោបិ នូនស្ស តាទិសោវ** សេចក្តីថា បិង្គិយានីព្រាហ្មណ៍សម្តែងថា បុគ្គលណាគប្បីដឹងដល់បដិភាណនៃព្រះបញ្ញារបស់ព្រះសមណគោតម បុគ្គលនោះ ក៏នឹងត្រូវបំពេញបារមី ១០ ហើយសម្រេចព្រះសព្វញ្ញុតញ្ញាណ គប្បីជាព្រះពុទ្ធ ដែលមានសភាពដូច្នោះប៉ុណ្ណោះ ។ បុគ្គលបំណងវាស់ភ្នំសិនេរុក្តី ផែនដីក្តី អាកាសក្តី គួរបានឈើវាស់ ឬខ្សែប៉ុនភ្នំសិនេរុ ផែនដី និងអាកាសនោះ បុគ្គលសូម្បីដឹងបញ្ញារបស់ព្រះសមណគោតម ក៏គួរបានព្រះសព្វញ្ញុតញ្ញាណ ដូចគ្នានឹងញាណរបស់ព្រះអង្គដែរ ។ ក្នុងសូត្រនេះ បិង្គិយានីព្រាហ្មណ៍ពោលពាក្យដដែល ដោយការអើពើ ។

បទថា **ឧឡារាយ** បានដល់ ឧត្តម គឺប្រសើរបំផុត ។ បទថា **កោចាហម្ភោ** សេចក្តីថា លោកដ៏ចម្រើន ខ្ញុំជាអ្វី ក្នុងការដែលសរសើរព្រះសមណគោតម ។ បទថា **កោ ច សមណំ គោតមំ បសំសិស្សាមិ** សេចក្តីថា ខ្ញុំនឹងសរសើរបានដោយហេតុណា ។

បទថា **បសដ្ឋប្បសដ្ឋោ** សេចក្តីថា បិង្គិយានីព្រាហ្មណ៍សរសើរ ដោយព្រះគុណទាំងឡាយរបស់ព្រះអង្គ ដែលសត្វលោកទាំងពួងសរសើរហើយ ដែលផ្សាយទៅក្រៃលែងជាងគុណទាំងអស់ មិនចាំបាច់សរសើរព្រះអង្គដោយព្រះគុណដទៃៗ ដូចផ្កាចម្ប៉ាក្តី ឧប្បលខៀវក្តី ឈូកក្រហមក្តី ចន្ទន៍ក្រហមក្តី

ជារបស់ផូវផង់ និងមានក្លិនក្រអូបដោយសិរី គឺពណ៌ និងក្លិន ប្រចាំខាងក្នុង របស់វានោះឯង មិនចាំបាច់សរសើរផ្កានោះ ដោយពណ៌ និងក្លិនដែលផ្សាយ ចេញមកខាងក្រៅ ។ ម្យ៉ាងទៀត ឧបមាដូចកែវមណីក្តី ព្រះចន្ទក្តី រមែង បញ្ចេញពន្លឺខ្លួនឯង កែវមណី និងព្រះចន្ទនោះ មិនចាំបាច់បែងចាំងពន្លឺដទៃ យ៉ាងណា ព្រះសមណគោតម ក៏ដូច្នោះ ទ្រង់បានទទួលនូវការសរសើរ ដល់ នូវភាពជាបុគ្គលប្រសើរនៃលោកទាំងពួង ដោយព្រះគុណរបស់ព្រះអង្គឯង ដែលសត្វលោកទាំងពួងសរសើរហើយ ក៏មិនចាំបាច់សរសើរទ្រង់ដោយព្រះ គុណដទៃ ម្យ៉ាងទៀត ឈ្មោះថា **បសដ្ឋប្បសដ្ឋោ** ព្រោះជាបុគ្គលប្រសើរជាង បុគ្គលដែលប្រសើរទាំងឡាយ ដូច្នេះក៏មាន ។ សួរថា បុគ្គលណា ឈ្មោះថា ជាបុគ្គលប្រសើរ ។ ឆ្លើយថា ព្រះបាទបសេនទិកោសល ជាបុគ្គលប្រសើរជាង អ្នកដែនកាសី និងដែនកោសល ព្រះបាទពិម្ពិសារ ជាបុគ្គលប្រសើរជាងអ្នក ដែនអង្គៈ និងមគធៈ ក្សត្រលិច្ឆវីក្រុងវេសាលី ប្រសើរជាងអ្នកដែនវជ្ជី មល្ល-ក្សត្រក្រុងបាវា ក្រុងកុសិនារា ជាបុគ្គលប្រសើរ សូម្បីក្សត្រនោះៗ ក៏ប្រសើរ ជាងអ្នកជនបទនោះៗ ព្រាហ្មណ៍ មានចង្កីព្រាហ្មណ៍ជាដើម ក៏ប្រសើរជាងពួក ព្រាហ្មណ៍ទាំងឡាយ ឧបាសក មានអនាថបិណ្ឌិកជាដើម ក៏ប្រសើរជាងឧបាសក ទាំងឡាយ ឧបាសិកា មាននាងវិសាខាជាដើម ក៏ប្រសើរជាងឧបាសិកាច្រើនរយ បរិព្វាជក មានសុកុឡុទាយីជាដើម ក៏ប្រសើរជាងបរិព្វាជកច្រើនរយ មហា-សាវិកា មានឧប្បលវណ្ណាថេរីជាដើម ក៏ប្រសើរជាងភិក្ខុនីច្រើនរយ ព្រះមហា-

*ថេរៈ មានព្រះសារីបុត្តត្ថេរជាដើម ប្រសើរជាងភិក្ខុច្រើនរយ ទេវតា មានសក្កៈជាដើម ក៏ប្រសើរជាងទេវតាច្រើនពាន់ ព្រហ្ម មានមហាព្រហ្មជាដើម ក៏ប្រសើរជាងព្រហ្មច្រើនពាន់ ជន និងទេវតាទាំងអស់នោះ ក៏គង់សរសើរ លើកតម្កើងព្រះទសពល ។ ព្រះមានព្រះភាគ លោកហៅថា* **បសន្នប្បសន្នោ** *ដោយប្រការដូច្នេះ ។*

*បទថា* **អត្ថវសំ** *ប្រែថា អំណាចនៃប្រយោជន៍ទាំងឡាយ ។ គ្រានោះ បិង្គិយានីព្រាហ្មណ៍ កាលប្រាប់ដល់ហេតុដែលខ្លួនជ្រះថ្លា ដល់ការណបាលីព្រាហ្មណ៍នោះ ទើបពោលពាក្យជាដើមថា* **សេយ្យថាបិ ភោ បុរិស** *ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **អគ្គរសបរិតិត្តោ** *សេចក្តីថា ឈ្មោះថា រសដ៏សើសបណ្តាភោជន មានបាយាសដ៏ប្រសើរ បណ្តារសសប្បិ មានសប្បិគោដ៏ប្រសើរ បណ្តាទឹកឃ្មុំ មានឃ្មុំផ្អិតដ៏ប្រសើរ បណ្តារសផ្អែម មានស្ករផែនដ៏ប្រសើរ ។ ផ្អែតក្នុងរសទាំងនោះណាមួយ បរិភោគល្មមក្រអូបមាត់ ក្រអូបក តាំងនៅបាន ។ បទថា* **អញ្ញេសំ ហីនានំ** *បានដល់ រសអាក្រក់ដទៃអំពីរសដ៏ប្រសើរ ។ បទថា* **សុត្តសោ** *ប្រែថា ដោយសូត្រ អធិប្បាយថា ដោយបានស្តាប់មក ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* **តតោ តតោ** *បានដល់ បណ្តាសត្ថុសាសនៈ មានសុត្តៈជាដើមនោះៗ ។ បទថា* **អញ្ញេសំ បុថុសមណព្រាហ្មណប្បវាទានំ** *បានដល់ មិនពេញចិត្ត មិនប្រាថ្នាពាក្យប្រៀនប្រដៅដែលជាលទ្ធិរបស់សមណព្រាហ្មណ៍ជាច្រើនដទៃ មិនប្រាថ្នាសូម្បីតែស្តាប់សមណ-*

ព្រាហ្មណ៍ទាំងនោះនិយាយ ។ បទថា **ឯវឃដ្ឋានុក្កពល្យបរេតោ** បានដល់ ត្រូវសេចក្តីឃ្លាន និងការខ្សោយកម្លាំងគ្របសង្កត់ ។

បទថា **មធុបិណ្ឌិកំ** បានដល់ សដូវដុំដែលគេលីងស្រូវសាលី ហើយផ្សំដោយរស ៤ យ៉ាង ឬនំផ្អែមនោះឯង ។ បទថា **អធិគតប្បយុទ្ធ** បានដល់ គប្បីបាន ។ បទថា **អសេចនកំ** បានដល់ មានរសប្រណីតឆ្ងាញ់ មិនលាយដោយរសដទៃ ដើម្បីធ្វើឲ្យផ្អែម ។ បទថា **ហរិចន្ទនស្ស** បានដល់ ចន្ទន៍លឿងពណ៌ដូចមាស ។ បទថា **លោហិតចន្ទនស្ស** បានដល់ ចន្ទន៍ពណ៌ក្រហម ។ បទថា **សុរភិគន្ធំ** បានដល់ មានក្លិនក្រអូប សេចក្តីក្រវល់ក្រវាយជាដើម បានដល់ ក្រវល់ក្រវាយព្រោះវដ្ដៈ លំបាកព្រោះវដ្ដៈ ឈ្មោះថា ក្តៅក្រហាយព្រោះវដ្ដៈ ។

បទថា **ឧទានំ ឧទានេសិ** ប្រែថា បន្លឺឧទាន ដូចពាក្យថា ប្រេងឯណាដែលមិនអាចយកមកវាល់បាន តែហូរទៅ ប្រេងនោះ ហៅថា **អវសេក** ទឹកណាមិនអាចដក់ក្នុងស្រះបាន ហូរទៅ ទឹកនោះ ហៅថា **ឱឃៈ** យ៉ាងណា ។ ពាក្យណាដែលប្រកបដោយបីតិ មិនអាចដក់នៅក្នុងចិត្ត មានច្រើន តាំងនៅមិនបានខាងក្នុង ក៏ហៀរចេញទៅខាងក្រៅ ពាក្យប្រកបដោយបីតិនោះ លោកហៅថា **ឧទាន** ក៏ដូច្នោះ អធិប្បាយថា ការណបាលីព្រាហ្មណ៍បន្លឺពាក្យដែលសម្រេចដោយបីតិបែបនេះ ។៚

**អដ្ឋកថាការណបាលីសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បិង្គិយានីសូត្រទី ៩

[ ៩៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ គង់នៅក្នុងកូដាគារសាលា ជិតព្រៃមហាវ័ន ក្បែរក្រុងវេសាលី ។ ក្នុងសម័យនោះឯង ពួកស្តេចលិច្ឆវី ប្រមាណ ៥០០ អង្គ នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ខៀវ មានសម្បុរខៀវ មានសំពត់ខៀវ មានគ្រឿងតាក់តែងខៀវ ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់លឿង មានសម្បុរលឿង មានសំពត់លឿង មានគ្រឿងតាក់តែងលឿង ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ក្រហម មានសម្បុរក្រហម មានសំពត់ក្រហម មានគ្រឿងតាក់តែងក្រហម ពួកស្តេចលិច្ឆវីខ្លះ មានគ្រឿងប្រដាប់ស មានសម្បុរស មានសំពត់ស មានគ្រឿងតាក់តែងស ព្រះដ៏មានព្រះភាគ រមែងរុងរឿងកន្លងពួកស្តេចលិច្ឆវីនោះ ដោយសម្បុរផង ដោយយសផង ។ គ្រានោះ បិង្គិយានិព្រាហ្មណ៍ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គសម្តែងបន្តិច បពិត្រព្រះសុគត ខ្ញុំព្រះអង្គសម្តែងបន្តិច ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលបិង្គិយានី អ្នកចូរសម្តែងចុះ ។ គ្រានោះឯង បិង្គិយានិព្រាហ្មណ៍ ក៏ពោលសរសើរ ដោយសារូបគាថា ចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា

ផ្កាឈូកឈ្មោះកោកនុទៈ មានក្លិនក្រអូប រីកអំពីព្រឹក

មានក្តិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើល
ព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គដ៏
រុងរឿងដូចព្រះអាទិត្យ ដែលរុងរឿង ក្នុងកណ្តាល
ពពក ក៏យ៉ាងនោះឯង ។

គ្រានោះឯង ពួកស្តេចលិច្ឆវីទាំងនោះ បានញុំាងបិង្គិយានិព្រាហ្មណ៍ឲ្យស្លៀកដណ្តប់ ដោយសំពត់ឧត្តរាសង្គៈ ៥០០ ។ លំដាប់នោះឯង បិង្គិយានិ-ព្រាហ្មណ៍បានញុំាងព្រះដ៏មានព្រះភាគ ឲ្យស្លៀកដណ្តប់ដោយសំពត់ឧត្តរា-សង្គៈទាំង ៥០០ នោះ ។ វេលានោះ ព្រះដ៏មានព្រះភាគ បានត្រាស់ទៅនឹងពួកស្តេចលិច្ឆវីទាំងនោះដូច្នេះថា ការកើតប្រាកដនៃរតនៈ ៥ យ៉ាង រកបានដោយកម្រ ក្នុងលោក ។ ការកើតប្រាកដនៃរតនៈទាំង ៥ យ៉ាង តើដូចម្តេចខ្លះ ។ គឺការកើតប្រាកដនៃព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ រកបានដោយកម្រក្នុងលោក ១ បុគ្គលដែលចេះសម្តែងធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ រកបានដោយកម្រ ក្នុងលោក ១ បុគ្គលដែលដឹងច្បាស់លាស់ នូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ សម្តែងហើយ រកបានដោយកម្រ ក្នុងលោក ១ បុគ្គលដែលដឹងច្បាស់នូវធម្មវិន័យ ដែលព្រះតថាគតប្រកាសហើយ សម្តែងហើយ ប្រតិបត្តិនូវធម៌តាមធម៌ រកបានដោយកម្រ ក្នុងលោក ១ កតញ្ញូកតវេទីបុគ្គល រកបានដោយកម្រ ក្នុងលោក ១ ។ ម្នាលលិច្ឆវីទាំងឡាយ ការកើតប្រាកដនៃរតនៈទាំង ៥ យ៉ាងនេះឯង រកបានដោយកម្រ ក្នុងលោក ។

# អដ្ឋកថា

## បិង្គិយានីសូត្រ

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបិង្គិយានីសូត្រទី ៥ ដូចតទៅនេះ បទថា **នីលា** នេះ សង្គ្រោះពណ៌ខៀវចូលទាំងអស់ ។ ពាក្យថា **នីលវណ្ណា** ជាដើម សម្តែងការចែកពណ៌ខៀវនោះ ។ ក្នុងបទថា **នីលវណ្ណា** នោះ តាមប្រក្រតី វណ្ណៈរបស់ក្សត្រលិច្ឆវីទាំងនោះ មិនខៀវ តែលោកពោលពាក្យនោះ ព្រោះ ក្សត្រទាំងនោះ លាបដោយគ្រឿងលាបពណ៌ខៀវ ។ បទថា **នីលវត្ថា** បានដល់ សំពត់សាច់ល្អ និងសំពត់សូត្រជាដើមរបស់ក្សត្រទាំងនោះ ក៏ជាពណ៌ ខៀវទាំងអស់ ។ បទថា **នីលាលង្ការា** បានដល់ គ្រឿងអលង្ការ ដោយ កែវមណីពណ៌ខៀវ និងផ្កាពណ៌ខៀវ សូម្បីអលង្ការរបស់ដំរី សេះ រថ រាំងនន ពិតាន និងអាវរបស់ក្សត្រទាំងនោះ ក៏ខៀវទាំងអស់ ។ គប្បីជ្រាប អត្ថគ្រប់បទទាំងអស់ដោយន័យនេះ ។ បទថា **បទុមំ យថា** បានដល់ ដូច ផ្កាបទុមពណ៌ក្រហមស្រទាប់ ១០០ ដូច្នោះ ។ បទថា **កោកនទំ** ជាវេវចនៈ នៃពាក្យថា **បទុមំ** នោះឯង ។ បទថា **បាតោ** បានដល់ ព្រលឹម គឺក្នុង ពេលព្រះអាទិត្យរះ ។ បទថា **សិយា** ប្រែថា គប្បីមាន ។ បទថា **អវីត-គន្ធំ** បានដល់ មិនប្រាសចាកក្លិនក្រអូប ។ បទថា **អង្គីរសំ** សេចក្តីថា ព្រះ រស្មីផ្សាយចេញអំពីព្រះកាយតូចធំរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើប ហៅថា ព្រះអង្គីរស ។ បទថា **តបន្តមាទិច្ចមិវន្តលិក្ខេ** សេចក្តីថា បិង្គិយានី-ព្រាហ្មណ៍ពោលថា អ្នកចូរមើលព្រះអង្គីរសដ៏រុងរឿង ដូចព្រះអាទិត្យចែងចាំង

ក្នុងអាកាស អាចធ្វើនូវពន្លឺក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២០០០ ជាបរិវារ បិង្គិយានីព្រាហ្មណ៍ពោលយ៉ាងនេះ សំដៅខ្លួនឯងផង មហាជនផង ។

អដ្ឋកថា បិង្គិយានីសូត្រទី ៥ ចប់

# សុត្តន្តបិដក

## សុបិនសូត្រទី ៦

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានមហាសុបិន ៥ យ៉ាង កើតឡើងប្រាកដ ។ មហាសុបិន ៥ នោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាប្រឹថពីនេះជាសំណិងដ៏ប្រសើរ ស្តេចភ្នំឈ្មោះហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្តូកចុះក្នុងសមុទ្រខាងកើត ព្រះហស្តស្តាំសណ្តូកចុះ ក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្តូកចុះ ក្នុងសមុទ្រខាងត្បូង ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មា-សម្ពុទ្ធ នៅជាពោធិសត្វមិនទាន់បានត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ១ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹង

នៅឡើយ មុនអំពីត្រាស់ដឹង មានស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិត ទៅទល់នឹងអាកាស ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតជាអរហន្តសម្មា-សម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហា-សុបិនទី ២ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានពួកសត្វជន្លេនខ្លួនស ក្បាលខ្មៅ វារចេញអំពីព្រះបាទទាំងគូ ( ចាប់ដើមអំពីចុងក្រចក ) ចោមរោមជិត ដរាបដល់មណ្ឌលនៃជង្គង់ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៣ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានសត្វបក្សី ៤ ពួក មានសម្បុរផ្សេងៗ គ្នា ហើរមកអំពីទិសទាំង ៤ មកក្រាបចុះទៀបបាទមូល ក៏ត្រឡប់ជាមានសម្បុរស ទាំងអស់ទៅវិញ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៤ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង រមែងចង្ក្រមលើភ្នំលាមកធំ មិនបានប្រឡាក់ ដោយលាមកឡើយ

ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទី ៥ នេះ ក៏កើតឡើងប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធនៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង ផែនដីធំនេះជាសយនៈដ៏ប្រសើរ ស្តេចភ្នំហិមវន្តជាខ្នើយ ព្រះហស្តឆ្វេងសណ្តូកចុះ ក្នុងសមុទ្រខាងកើត ព្រះហស្តស្តាំសណ្តូកចុះ ក្នុងសមុទ្រខាងលិច ព្រះបាទទាំងគូសណ្តូកចុះ ក្នុងសមុទ្រខាងត្បូង ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ១ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ដឹងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានស្មៅចិញ្ចៀន ១ សរសៃ ដុះលេចអំពីផ្ចិតទៅទល់នឹងអាកាស ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ២ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹងនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ដឹងហើយ ដរាបតែទេវតា និងមនុស្សទាំងឡាយប្រកាសបានដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានពួកដង្កូវខ្លួនស ក្បាលខ្មៅ វារចេញអំពីព្រះបាទទាំងគូ បោមរោមជិតដរាបដល់មណ្ឌលនៃជង្គង់ ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៣ កើត

ឡើងប្រាកដ ដើម្បីត្រាស់ដឹង ( នូវគុណ ) ដែលពួកគ្រហស្ថច្រើន ស្លៀកពាក់គ្រឿងប្រដាប់មានពណ៌ស ដល់នូវព្រះតថាគត ជាសរណៈស្មើដោយជីវិត ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មានសត្វស្លាប ៤ ពួក មានសម្បុរផ្សេងៗ គ្នា ហើរមកអំពីទិសទាំង ៤ មក ក្រាបទៀបបាទមូល មានខ្លួនត្រឡប់ជាសទាំងអស់ ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៤ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង ( នូវគុណ ) ដែលវណ្ណៈទាំង ៤ នេះ គឺខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្រៈ ១ វណ្ណៈទាំង ៤ នោះ ចេញចាកផ្ទះមកបួស ក្នុងធម្មវិន័យ ដែលព្រះតថាគតបានសម្តែងហើយ ធ្វើឲ្យជាក់ច្បាស់នូវវិមុត្តិដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង រមែងចង្ក្រមលើភ្នំលាមក មិនប្រឡាក់ដោយលាមកឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាមហាសុបិនទី ៥ កើតឡើងប្រាកដ ដើម្បីត្រាស់ដឹង ( នូវគុណ ) ដែលព្រះតថាគត ជាបុគ្គលមានលាភ គឺបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ តែព្រះតថាគតមិនបានជាប់ចំពាក់ មិនបានជ្រប់ មិនបានស្ញុបស្ញៅ ក្នុងលាភទាំងនោះឡើយ មានការឃើញលាភនោះថាជាទោស មានបញ្ញាជាគ្រឿងរលាស់ចេញ ហើយទើបបរិភោគ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ នៅជាពោធិសត្វ

មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីត្រាស់ដឹង មហាសុបិនទាំង ៥ នេះ ក៏បានកើតឡើងប្រាកដ ។

# អដ្ឋកថា

## សុបិនសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុបិនសូត្រទី ៦ ដូចតទៅនេះ បទថា **មហាសុបិនា** សេចក្ដីថា ឈ្មោះថា មហាសុបិន ព្រោះមហាបុរសគប្បីយល់សប្ដិ និងព្រោះភាពជានិមិត្តនៃប្រយោជន៍ធំ ៗ បទថា **ចាតុរហេសុំ** ប្រែថា បានប្រាកដហើយ ។ ក្នុងបទនោះ បុគ្គលយល់សប្ដិ រមែងយល់សប្ដិដោយហេតុ ៤ ប្រការ គឺព្រោះធាតុកម្រើក ១ ព្រោះធ្លាប់កើតមកអំពីមុន ១ ព្រោះទេវតាបណ្ដាល ១ ព្រោះបុព្វនិមិត្ត ១ ។ ក្នុងសុបិនទាំងនោះ បុគ្គលធាតុកម្រើក ព្រោះប្រមាត់ជាដើមជាហេតុធ្វើឲ្យកម្រើក រមែងយល់សប្ដិព្រោះធាតុកម្រើក កាលយល់សប្ដិ រមែងយល់សប្ដិច្រើនយ៉ាង ដូចជាយល់សប្ដិថា ធ្លាក់អំពីភ្នំ ហោះទៅតាមអាកាស ថាត្រូវម្រឹគកាច ដំរី និងចោរជាដើមដេញតាម ។ កាលយល់សប្ដិដោយធ្លាប់កើតមកអំពីមុន រមែងយល់សប្ដិដល់អារម្មណ៍ដែលមកហើយក្នុងកាលមុន ។ សម្រាប់បុគ្គលយល់សប្ដិដោយទេវតាបណ្ដាលចិត្ត ទេវតារមែងបណ្ដាលអារម្មណ៍ច្រើនយ៉ាង ព្រោះបំណង

ល្អក៏មាន បំណងអាក្រក់ក៏មាន បុគ្គលនោះ រមែងយល់សប្តិឃើញអារម្មណ៍ទាំងនោះ ដោយអានុភាពនៃទេវតាទាំងនោះ កាលយល់សប្តិដោយបុព្វនិមិត្ត រមែងយល់សប្តិដែលជាបុព្វនិមិត្តនៃប្រយោជន៍ ឬនៃការវិនាស និងកើតដោយអំណាចបុណ្យបាប ដូចព្រះជននីរបស់ព្រះពោធិសត្វ បាននិមិត្តក្នុងការបានព្រះឱរស ឬដូចព្រះបាទកោសល ទ្រង់សុបិនឃើញហេតុ ១៦ ប្រការ និងដូចព្រះមានព្រះភាគអង្គនេះ កាលនៅជាព្រះពោធិសត្វ ទ្រង់សុបិនឃើញមហាសុបិន ៥ ប្រការនេះ ។

ក្នុងសុបិនទាំងនោះ សុបិនព្រោះធាតុកម្រើក ព្រោះធ្លាប់កើតមកអំពីមុន ជាសុបិនមិនពិត ។ សុបិនព្រោះទេវតាបណ្តាល ពិតខ្លះ មិនពិតខ្លះ ព្រោះថាទេវតាទាំងឡាយ កាលក្រោធឡើងមក បំណងនឹងឲ្យដល់នូវសេចក្តីវិនាសដោយឧបាយ ទើបក្លែងធ្វើឲ្យខុសប្រក្រតី ។ តែសុបិនព្រោះបុព្វនិមិត្ត ពិតដោយចំណែកមួយប៉ុណ្ណោះ ។ ព្រោះទាក់ទងដោយហេតុ ៤ យ៉ាង ទើបយល់សប្តិផ្សេងគ្នាយ៉ាងនេះ ។ ក្នុងសុបិន ៤ នោះ ព្រះសេក្ខៈ និងបុថុជ្ជន រមែងសុបិន ព្រោះមិនទាន់លះវិបល្លាសបាន ព្រះអសេក្ខៈមិនយល់សប្តិ ព្រោះលះវិបល្លាសបានហើយ ។

កាលយល់សប្តិនោះ លក់យល់សប្តិក្តី ភ្ញាក់យល់សប្តិក្តី ឬមិនលក់មិនភ្ញាក់យល់សប្តិក្តី ក្នុងសេចក្តីនេះ មានអធិប្បាយដូចម្តេច ឧបមាថា លក់យល់សប្តិ ក៏ខុសអភិធម្ម ព្រោះថា សត្វរមែងលក់ដោយភវង្គចិត្តនោះ មិន

មានរូបនិមិត្តជាដើមជាអារម្មណ៍ ឬសម្បយុត្តដោយរាគៈជាដើមឡើយ ចិត្តដូច្នេះរមែងកើតដល់អ្នកយល់សប្តិ បើភ្ញាក់យល់សប្តិ ក៏ខុសវិន័យ ព្រោះការយល់សប្តិដែលភ្ញាក់យល់សប្តិ ដោយចិត្តដែលជាអព្វោហារិក គឺឃើញដូចមិនឃើញ មិនប្រព្រឹត្តជាអាបត្តិ ព្រោះកន្ទងល្មើសដោយចិត្ត ដែលជាអព្វោហារិកនោះ ព្រោះបុគ្គលយល់សប្តិ ប្រព្រឹត្តល្មើស ក៏មិនជាអាបត្តិដោយចំណែកមួយប៉ុណ្ណោះ បើមិនលក់មិនភ្ញាក់យល់សប្តិ ឈ្មោះថា មិនយល់សប្តិ កាលបើដូច្នេះ ទើបមិនមានយល់សប្តិ និងមិនមានក៏មិនមែន ។ ព្រោះហេតុអ្វី ព្រោះអ្នកយល់សប្តិ ចូលកាន់និទ្រាដូចស្វា សមដូចព្រះនាគសេនពោលថា បពិត្រមហារាជ បុគ្គលដែលដេកលក់ដូចស្វា រមែងយល់សប្តិ ។ បទថា **កបិមិទ្ធបរេតោ** បានដល់ ប្រកបហើយដោយការលក់របស់ស្វា ដូចការលក់របស់ស្វា ប្រព្រឹត្តទៅរហ័ស យ៉ាងណា ការលក់ដែលឈ្មោះថា ប្រព្រឹត្តទៅរហ័ស ព្រោះជ្រែកដោយចិត្ត មានកុសលចិត្តជាដើមរឿយៗ ក៏ដូច្នោះ ក្នុងការប្រព្រឹត្តទៅរបស់ការលក់ណា ចិត្តរមែងឡើងអំពីភវង្គរឿយៗ បុគ្គលប្រកបហើយ ដោយការលក់នោះ រមែងយល់សប្តិ ។

ដោយហេតុនោះ យល់សប្តិនេះ ទើបជាកុសលខ្លះ អកុសលខ្លះ អព្យាកតៈខ្លះ ។ ក្នុងយល់សប្តិនោះ គប្បីជ្រាបថា ជាកុសលដល់អ្នកធ្វើការថ្វាយបង្គំចេតិយ ស្តាប់ធម៌ និងសម្តែងធម៌ជាដើម ជាអកុសល ដល់អ្នកធ្វើបាណាតិបាតជាដើម ផុតចាកអំពី ២ យ៉ាងនោះ ជាអព្យាកតៈ ក្នុងខណៈ

អាវជ្ជនចិត្ត និងខណៈតទាលម្ពណចិត្តទាញយកយល់សប្តិនោះជាអារម្មណ៍ ។ យល់សប្តិនេះ ព្រោះមានវត្ថុទុព្វល ទើបមិនអាចទាញបដិសន្ធិរបស់ចេតនាមកបាន កាលប្រព្រឹត្តទៅហើយ យល់សប្តិដែលកុសល និងអកុសលដទៃឧបត្ថម្ភ រមែងឲ្យវិបាក ឲ្យវិបាកក៏ពិត តែចេតនាក្នុងយល់សប្តិ ជាអព្វោហារិក គឺពោលអាងមិនបាន ព្រោះកើតក្នុងទីដែលមិនមែនវិស័យ ។

សុបិននេះ ទោះសុបិនក្នុងពេលថ្ងៃ រមែងមិនពិត សូម្បីក្នុងបឋមយាម មជ្ឈិមយាម និងបច្ឆិមយាម ក៏ដូចគ្នា ។ តែក្នុងពេលទៀបភ្លឺ កាលអាហារដែលបរិភោគ ផឹក និងទំពា រលួយល្អហើយ ឱជៈដែលនៅតាមកន្ទែងក្នុងរាងកាយ លុះអរុណរះ រមែងយល់សប្តិពិត កាលយល់សប្តិ មានឥដ្ឋារម្មណ៍ជានិមិត្ត រមែងបានឥដ្ឋារម្មណ៍ កាលយល់សប្តិ មានអនិដ្ឋារម្មណ៍ជានិមិត្ត រមែងបានអនិដ្ឋារម្មណ៍ ។ មហាសុបិន ៥ នេះ លោកិយមហាជនមិនយល់សប្តិ មហារាជទាំងឡាយមិនយល់សប្តិ ស្តេចចក្រពត្តិទាំងឡាយមិនយល់សប្តិ អគ្គសាវកទាំងឡាយមិនយល់សប្តិ ព្រះបច្ចេកពុទ្ធទាំងឡាយមិនយល់សប្តិ ព្រះសម្មាសម្ពុទ្ធទាំងឡាយមិនយល់សប្តិ ព្រះសព្វញ្ញូពោធិសត្វមួយអង្គប៉ុណ្ណោះ រមែងយល់សប្តិ ។

សួរថា ព្រះពោធិសត្វនៃយើង ទ្រង់សុបិននេះក្នុងពេលណា ។ ឆ្លើយថា ទ្រង់សុបិនក្នុងពេលទៀបភ្លឺ ក្នុងថ្ងៃ ១៤ កើត ដោយទ្រង់ដឹងថា ស្អែកនេះ អាត្មាអញនឹងបានជាព្រះពុទ្ធ អាចារ្យពួកខ្លះពោលថា ក្នុងថ្ងៃ ១៣ កើតក៏មាន

ព្រះអង្គទ្រង់ឃើញសុបិនទាំងនេះហើយ ទ្រង់ក្រោកឡើង គង់ពត់ព្រះភ្នែន ទ្រង់ត្រិះរិះថា បើអាត្មាអញសុបិនទាំងនេះ ក្នុងក្រុងកបិលពស្តុ នឹងក្រាបទូល ព្រះជនក បើព្រះជននីរបស់អាត្មាអញ គង់ព្រះជន្មនៅឡើយ អញក៏នឹងទូល ព្រះជននី តែក្នុងទីនេះ មិនមានបុគ្គលដែលនឹងទាយសុបិនទាំងនេះបាន អាត្មា អញ តែឯងប៉ុណ្ណោះ នឹងកាត់សុបិននេះ ។ បន្ទាប់អំពីនោះ ព្រះពោធិសត្វ កាត់សុបិន ដោយព្រះអង្គឯងថា សុបិននេះ នឹងជាបុព្វនិមិត្តរបស់វត្ថុនេះ សុបិននេះ នឹងជាបុព្វនិមិត្តរបស់វត្ថុនេះ ហើយសោយមធុបាយាសដែលនាង សុជាតា ក្នុងឧរុវេលគាមថ្វាយ ទ្រង់ឡើងកាន់ពោធិមណ្ឌលដ្ឋាន ទ្រង់សម្រេច សម្ពោធិញ្ញាណ គង់នៅក្នុងវត្តជេតពនតាមលំដាប់ ដើម្បីញ៉ាំងមហាសុបិន ៥ ដែលទ្រង់ឃើញហើយ ក្នុងមកុលពុទ្ធកាលឲ្យពិស្តារ ទើបត្រាស់ហៅភិក្ខុ ទាំងឡាយ រួចទ្រង់ផ្ដើមទេសនានេះ ។

ក្នុងបទទាំងនោះ បទថា **មហាបថវី** បានដល់ ផែនដីធំដែលតាំងនៅ ពេញផ្ទៃចក្រវាល ។ បទថា **មហាសយនំ អហោសិ** បានដល់ ជាសិរី- សេយ្យាសនៈ ។ បទថា **ឱហិតោ** គឺដាក់ហើយ ។ ព្រះហស្តនោះ គប្បី ជ្រាបថា មិនបានសណ្ដូកលើទឹក ដែលពិត សណ្ដូកទៅខាងលើៗ នៃមហា សមុទ្រទិសខាងកើត ហើយទ្រង់ដាក់ចុះត្រង់ទីបំផុតនៃចក្រវាល នាទិសខាង កើត ។ ក្នុងបទទាំងឡាយថា **បច្ឆិមេ សមុទ្ទេ ទក្ខិណោ សមុទ្ទេ** ដូច្នេះ ក៏ ន័យនេះដូចគ្នា ។ លោកហៅថា **ឧត្តិណា** គឺស្មៅចិញ្ចៀន ក្នុងបទថា

**តិរិយា នាម តិណជាតិ** ។ បទថា **នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ** ស្មៅជុះអំពីព្រះនាភីទល់គ្នានឹងអាកាស សេចក្ដីថា ស្មៅជុះឡើងអំពីព្រះនាភី ជាកំណាត់ឈើពណ៌ក្រហម ទំហំប៉ុនដងនង្គ័ល ហើយដុះវែងឡើងៗ យ៉ាងនេះ គឺ ១ ចំអាម ៣ ហត្ថ ១ ព្យាម ១ យដ្ឋិ គឺ ១ ឈើប្រត់ ១ គាវុត កន្លះយោជន៍ ១ យោជន៍ រហូតទល់អាកាសច្រើនពាន់យោជន៍ ទាំងដែលកំពុងឃើញនោះឯង ។

បទថា **ចរណេហិ ឧស្សក្កិត្វា** បានដល់ ជន្លូវវារឡើងតាមព្រះបាទ តាំងអំពីចុងព្រះនខាមក ។ បទថា **នានាវណ្ណា** សេចក្ដីថា បក្សីមានពណ៌ផ្សេងៗ គឺសត្វខ្លះពណ៌ខៀវ សត្វខ្លះពណ៌លឿង សត្វខ្លះពណ៌ក្រហម សត្វខ្លះ ពណ៌ដូចស្លឹកឈើស្ងួត ។ បទថា **សេតា** បានដល់ ពណ៌ស គឺសសុទ្ធ ។

បទថា **មហតោ មិឡ្ហបព្វតស្ស** បានដល់ ភ្នំដែលពោរពេញទៅដោយលាមក កម្ពស់ប្រមាណ ៣ យោជន៍ ។ បទថា **ឧបរូបរិ ចង្កមតិ** បានដល់ ទ្រង់យាងចង្ក្រមពីលើកំពូល ព្រះពុទ្ធទាំងឡាយ មានព្រះជង្ឃវែង ប្រាកដដូចចូលទៅគង់លើភ្នំ ពេញទៅដោយលាមកប្រមាណ ៣ យោជន៍ ។

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងបុព្វនិមិត្ត ដោយឋានៈប៉ុណ្ណោះ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងដល់ការបានព្រម ដោយបុព្វនិមិត្តនោះ ទើបត្រាស់ពាក្យជាដើមថា **យម្បិ ភិក្ខវេ** ដូច្នេះ ។ ក្នុងពាក្យនោះ អរហត្តមគ្គ

របស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា ជាសម្មាសម្ពោធិញ្ញាណដ៏កំពូល ព្រោះឲ្យនូវគុណគ្រប់យ៉ាង ។ ព្រោះដូច្នោះ ព្រះពោធិសត្វនោះ បានឃើញមហាប្រឹថពីនៃចក្រវាលណា ជាពូកសម្រាប់ផ្ទំដ៏ជាសិរី មហាប្រឹថពីនៃចក្រវាលនោះជាបុព្វនិមិត្តនៃភាពជាព្រះពុទ្ធ ។ ទ្រង់បានឃើញភ្នំហិមពាន្តណាជាខ្នើយ ភ្នំហិមពាន្តនោះ ជាបុព្វនិមិត្តនៃព្រះសព្វញ្ញុតញ្ញាណ ទ្រង់បានឃើញព្រះហស្តនិងព្រះបាទទាំង ៤ ប្រតិស្ឋានលើភ្នំកណ្តាប់ចក្រវាលឯណា នុ៎ះជាបុព្វនិមិត្តក្នុងការប្រកាសធម្មចក្រ ដែលបុគ្គលណាម្នាក់ ឲ្យប្រព្រឹត្តទៅមិនបាន ទ្រង់បានឃើញទ្រង់ផ្ទំផ្ងារឯណា នុ៎ះជាបុព្វនិមិត្តនៃភាពដែលសត្វទាំងឡាយផ្កាប់មុខក្នុងភព ៣ ផ្ងារមុខឡើង ទ្រង់ហាក់ដូចជាបើកព្រះនេត្រឃើញឯណា នុ៎ះជាបុព្វនិមិត្តនៃការបានទិព្វចក្ខុ ពន្លឺបានប្រាកដដូចគ្នា ដរាបដល់ភវគ្គព្រហ្មឯណា នុ៎ះជាបុព្វនិមិត្តនៃអនាវរណញ្ញាណ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យនៃព្រះបាលីនោះឯង ។៚

## អដ្ឋកថាសុបិនសូត្រទី ៦ ចប់

# សុត្តន្តបិដក

## វស្សសូត្រទី ៧

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ អន្តរាយនៃភ្លៀងនេះមាន ៥ យ៉ាង ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជន អ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ អន្តរាយនៃភ្លៀង ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តេជោធាតុកើតឡើង ក្នុងអាកាសខាងលើ ដោយហេតុនោះហើយ បានជាមេឃ ( ពពក ) តាំងឡើងត្រឡប់ជាស្រឡះទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ១ ដែលពួកជនអ្នកទាយនូវនិមិត្តមិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត វាយោធាតុកើតឡើង ក្នុងអាកាសខាងលើ ដោយហេតុនោះហើយបានជាមេឃតាំងឡើងត្រឡប់ជាស្រឡះទៅវិញ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ២ ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត រាហុ-អសុរិន្ទ ត្រងទឹកដោយដៃហើយជះទៅ ក្នុងមហាសមុទ្រ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៣ ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកវស្សវលាហកទេវបុត្ត ធ្វេសប្រហែស ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៤ ដែលពួកជនអ្នកទាយនូវនិមិត្តមិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួក

មនុស្សជាអ្នកមិនប្រកបដោយធម៌ ម្នាលភិក្ខុទាំងឡាយ នេះជាអន្តរាយនៃភ្លៀងទី ៥ ដែលពួកជនអ្នកទាយនូវនិមិត្តមិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។ ម្នាលភិក្ខុទាំងឡាយ អន្តរាយនៃភ្លៀងមាន ៥ យ៉ាងនេះឯង ដែលពួកជនអ្នកទាយនូវនិមិត្ត មិនបានដឹង ទាំងចក្ខុរបស់ពួកជនអ្នកទាយនូវនិមិត្ត ក៏មិនមុតជ្ជះ ។

# អដ្ឋកថា

## វស្សសូត្រ

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវស្សសូត្រទី ៧ ដូចតទៅនេះ បទថា **នេមិត្តា** បានដល់ អ្នកព្យាករ ។ បទថា **តេជោធាតុ បកុប្បតិ** បានដល់ គំនរភ្លើងធំកើតឡើង ។ បទថា **ចាណសិតា ឧទកំ បជិច្ចិត្វា** បានដល់ យកដៃប្រមាណ ៣០០ យោជន៍ទទួលទឹកដែលតាំងឡើងតាមរដូវ ។ បទថា **បមត្តា ហោន្តិ** បានដល់ ជាអ្នកប្រមាទ គឺប្រាសចាកសតិ ព្រោះស្រវឹងក្នុងការលេងរបស់ខ្លួន ។ ពិតហើយ កាលពួកជនទាំងនោះ មានចិត្តគិតថា ពួកយើងនឹងត្រេកអរ ភ្លៀងរមែងធ្លាក់ពុំជួកាល ព្រោះមិនមានចិត្តគិតយ៉ាងនោះទើបភ្លៀងមិនធ្លាក់ ។ ទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់ដូច្នេះថា សូម្បីក្នុងរដូវកាល ភ្លៀងក៏មិនធ្លាក់ ។

# សុត្តន្តបិដក

## វាចាសូត្រទី ៨

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ ឈ្មោះថា សុភាសិត មិនមែនជាទុព្ភាសិត ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។ វាចាដែលប្រកបដោយអង្គ ៥ តើដូចម្តេច ។ គឺវាចាដែលពោលប្រកបតាមកាល ១ វាចាដែលពោលពិត ១ វាចាដែលពោលទន់ភ្លន់ ១ វាចាដែលពោលប្រកបដោយប្រយោជន៍ ១ វាចាដែលពោលប្រកបដោយមេត្តាចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ វាចាដែលប្រកបដោយអង្គ ៥ នេះឯង ឈ្មោះថា សុភាសិត មិនមែនជាទុព្ភាសិតទេ ជាវាចាមិនប្រកបដោយទោសផង ដែលពួកអ្នកប្រាជ្ញ មិនគប្បីតិះដៀលផង ។

# អដ្ឋកថា

## វាចាសូត្រ

[ ៩៨ ] ក្នុងវាចាសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវាចាសូត្រទី ៨ ចប់

# សុត្តន្តបិដក

## កុលសូត្រទី ៩

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីលចូលទៅកាន់ត្រកូលណាហើយ ពួកមនុស្សក្នុងត្រកូលនោះ រមែងបានបុណ្យច្រើន ដោយឋានៈ ៥ យ៉ាង ។ ឋានៈ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ មនុស្សទាំងឡាយបានឃើញ ក៏មានចិត្តជ្រះថ្លា ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះ ក៏ប្រតិបត្តិប្រព្រឹត្តទៅដើម្បីទៅកាន់ស្ថានសួគ៌ ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សរមែងក្រោកទទួលថ្វាយបង្គំ ក្រាលអាសនៈប្រគេន ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីទៅកាន់ត្រកូលខ្ពង់ខ្ពស់ ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក៏បន្ទោបង់មន្ទិល គឺសេចក្តីកំណាញ់ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវយសសក្តិធំ ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីលចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សរមែងចែករំលែក ( នូវទាន ) តាមសមគួរដល់សេចក្តីអង់អាច តាមសមគួរដល់កម្លាំង ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះ ក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវភោគសម្បទច្រើន ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបព្វជិតមានសីល ចូលទៅ

កាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក៏សាកសួរសាកច្ឆា ស្តាប់ធម៌ ម្នាលភិក្ខុទាំងឡាយ ត្រកូលនោះក៏ប្រតិបត្តិនូវបដិបទាប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាច្រើន ក្នុងសម័យនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតមានសីល ចូលទៅកាន់ត្រកូលក្នុងសម័យណាហើយ ពួកមនុស្សក្នុងត្រកូលនោះ រមែងបានបុណ្យច្រើនដោយឋានៈ ៥ យ៉ាងនេះ ។

# អដ្ឋកថា

## កុលសូត្រ

[ ៩៩ ] ក្នុងកុលសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាកុលសូត្រទី ៩ ចប់

# សុត្តន្តបិដក

## និស្សារណីយសូត្រទី ១០

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ ពួកធាតុដែលគួររលាស់ចេញនេះ មាន ៥ យ៉ាង ។ ធាតុដែលគួររលាស់ចេញ ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្ត

ក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅ ក្នុងកាមទាំងឡាយ មួយទៀត កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវនេក្ខម្មៈ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងនេក្ខម្មៈ ចិត្តនោះរបស់ភិក្ខុនោះ ក៏ប្រព្រឹត្តទៅល្អចម្រើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះចាកកាមទាំងឡាយ អាសវៈទាំងឡាយណា មានកាមជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងសេចក្តីក្រវល់ក្រវាយកើតឡើង បុគ្គលនោះក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះក៏លែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវកាមទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីព្យាបាទ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅ ក្នុងសេចក្តីព្យាបាទ កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនព្យាបាទ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងសេចក្តីមិនព្យាបាទ ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចម្រើនល្អ ដាច់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកសេចក្តីព្យាបាទ អាសវៈទាំងឡាយណា មានព្យាបាទជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងសេចក្តីក្រវល់ក្រវាយ កើតឡើង បុគ្គលនោះ ក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះក៏លែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវព្យាបាទ ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីបៀតបៀន ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងសេចក្តីបៀតបៀន កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនបៀតបៀន ចិត្តក៏ស្ទុះទៅជ្រះថ្លា តាំងនៅស៊ប់ក្នុងសេចក្តី

មិនបៀតបៀន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចម្រើនល្អ ជាប់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកសេចក្តីបៀតបៀន ឯអាសវៈទាំងឡាយណា មានសេចក្តីបៀតបៀនជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងសេចក្តីក្រវល់ក្រវាយកើតឡើង បុគ្គលនោះ ក៏ផុតចាកអាសវៈទាំងនោះ បុគ្គលនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវសេចក្តីបៀតបៀន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តក្នុងរូបទាំងឡាយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងរូបទាំងឡាយ កាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវរូប ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងអរូបបាន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចម្រើនល្អ ជាប់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាករូបទាំងឡាយ អាសវៈទាំងឡាយណា មានរូបជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងក្រវល់ក្រវាយកើតឡើង ភិក្ខុនោះ ក៏ផុតចាកអាសវៈទាំងនោះ ភិក្ខុនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសក្កាយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងសក្កាយ កាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសក្កាយនិរោធ តែមួយយ៉ាង ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ក្នុងសក្កាយនិរោធបាន ចិត្តនោះរបស់ភិក្ខុនោះ ប្រព្រឹត្តទៅល្អ ចម្រើនល្អ ជាប់ស្រឡះ ផុតស្រឡះ ប្រាសស្រឡះ ចាកសក្កាយ អាសវៈទាំងឡាយណា មានសក្កាយជាបច្ច័យ នាំមកនូវសេចក្តីទុក្ខ និងសេចក្តី

ក្រវល់ក្រវាយកើតឡើង ភិក្ខុនោះក៏ផុតចាកអាសវៈទាំងនោះ ភិក្ខុនោះលែងទទួលនូវវេទនានោះ ។ នេះហៅថា ការរលាស់ចេញនូវសក្កាយ ។ សេចក្តីត្រេកអរក្នុងកាមក្តី របស់ភិក្ខុនោះ ក៏មិនបានកើត សេចក្តីត្រេកអរ ក្នុងការព្យាបាទក្តី ក៏មិនបានកើត សេចក្តីត្រេកអរក្នុងការបៀតបៀនក្តី ក៏មិនបានកើត សេចក្តីត្រេកអរក្នុងរូបក្តី ក៏មិនបានកើត សេចក្តីត្រេកអរក្នុងសក្កាយក្តី ក៏មិនបានកើត ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតពោលថា មិនមានសេចក្តីអាល័យ បានផ្តាច់បង់នូវតណ្ហា បានកម្ចាត់កម្ចាយនូវសញ្ញោជនៈ ព្រោះមិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងកាមផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងព្យាបាទផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងការបៀតបៀនផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរក្នុងរូបផង មិនដេកត្រាំក្នុងសេចក្តីត្រេកអរ ក្នុងសក្កាយផង ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះបានត្រាស់ដឹងនូវមានះដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ធាតុទាំងឡាយ ដែលគួររលាស់ចេញ មាន ៥ យ៉ាងនេះឯង ។

ព្រាហ្មណវគ្គទី ៥ ចប់

បណ្ណាសកទី ៤ ចប់

## ឧទ្ទាននៃព្រាហ្មណវគ្គនោះ គឺ

និយាយអំពីសោណព្រាហ្មណ៍ ១ ទោណព្រាហ្មណ៍ ១
សង្គារវព្រាហ្មណ៍ ១ ការណបាលិព្រាហ្មណ៍ ១ បិង្គិ-
យានិព្រាហ្មណ៍ ១ មហាសុបិន ១ វៀងភ្លៀង ១ វាចា
១ ត្រកូល ១ ធាតុទាំងឡាយ ដែលគួររលាស់ចេញ ១ ។

# អដ្ឋកថា

## និស្សារណីយសូត្រ

[ ១០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិស្សារណីយសូត្រទី ១០ ដូចតទៅនេះ បទថា **និស្សារណីយា** បានដល់ រលាស់ចេញទៅ គឺប្រាសចេញបាន ។ បទថា **ធាតុយោ** បានដល់ សភាវៈដែលទទេចាកខ្លួន ។ បទថា **កាមំ មនសិករោតោ** បានដល់ ដាក់ចិត្តដល់កាម អធិប្បាយថា ចេញចាកអសុភជ្ឈាន ហើយបញ្ជូនចិត្តចំពោះកាម ដើម្បីសាកល្បង ដូចដាក់ថ្នាំពិសោធពិស ។ បទថា **ន បក្ខន្ទតិ** គឺមិនចូលទៅ ។ បទថា **ន បសីទតិ** គឺមិនដល់នូវការជ្រះថ្លា ។ បទថា **ន សន្តិដ្ឋតិ** គឺមិនតាំងនៅ ។ បទថា **ន វិមុច្ចតិ** គឺមិនបង្អោនទៅ ។ ឧបមាដូចស្លាបមាន់ក្តី សរសៃកន្ត្រែបក្តី ដែលគេដាក់ចូលទៅក្នុងភ្លើង រមែងរួញ មិនលា យ៉ាងណា ចិត្តក៏រួញរា មិនលាចេញ ដូច្នោះ ។ បឋមជ្ឈានក្នុងអសុភ ឈ្មោះថា នេក្ខម្មៈ ក្នុងបទនេះថា **នេក្ខម្មំ ខោ បន** ដូច្នេះ ។ កាលភិក្ខុនោះដាក់ចិត្តដល់នេក្ខម្មៈនោះ ចិត្តរមែងស្ទុះទៅក្នុងនេក្ខម្មៈ ។ បទថា **តស្ស តំ ចិត្តំ** បានដល់ ចិត្តក្នុងអសុភជ្ឈាននៃភិក្ខុនោះ ។ បទថា **សុគតំ** បានដល់ ទៅហើយដោយល្អ ព្រោះទៅក្នុងគោចរ គឺអារម្មណ៍ ។ បទថា **សុភាវិតំ** បានដល់ អប់រំហើយដោយល្អ ព្រោះមិនប្រព្រឹត្តទៅក្នុងចំណែកក្នុងនៃសេចក្តីវិនាស ។ បទថា **សុវុដ្ឋិតំ** បានដល់ ចេញទៅហើយចាកកាម ។ បទថា **សុវិមុត្តំ** បានដល់ ផុតហើយដោយល្អ ចាកកាមទាំងឡាយ អាសវៈទាំងឡាយ ៤ ដែលមានកាមជាហេតុ ឈ្មោះថា អាសវៈ

មានកាមជាបច្ច័យ ។ សេចក្ដីទុក្ខ ឈ្មោះថា **វិឃាត** ការក្ដៅក្រហាយ ព្រោះកាមរាគៈ ឈ្មោះថា **បរិឡាហ**។ បទថា **ន សោ តំ វេទនំ វេទិយតិ** សេចក្ដីថា ភិក្ខុនោះ មិនបានសោយវេទនាកើតអំពីកាមនោះ និងវេទនាកើតអំពីសេចក្ដីទុក្ខ និងការក្ដៅក្រហាយ ។

បទថា **ឥទមក្ខាតំ កាមានំ និស្សរណំ** សេចក្ដីថា អសុភជ្ឈានលោកពោលថា ជាគ្រឿងហូរចេញទៅនៃកាមទាំងឡាយ ព្រោះរលាស់ចេញចាកកាម ។ ភិក្ខុណាធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយសម្រេចតតិយមគ្គ ឃើញនិព្វានដោយអនាគាមិផល ហើយក៏ដឹងថា ឈ្មោះថាកាមទាំងឡាយ នឹងមិនមានទៀត ដូច្នេះ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ជានិស្សរណៈ គឺគ្រឿងរលាស់ចេញដោយចំណែកមួយ ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ តែការផ្សេងគ្នា មានដូច្នេះ ក្នុងវារៈទី ២ មេត្តាឈានឈ្មោះថា ជាគ្រឿងរលាស់ចេញនៃព្យាបាទ ក្នុងវារៈទី ៣ ករុណាឈានឈ្មោះថា ជាគ្រឿងរលាស់ចេញនៃវិហិង្សា ក្នុងវារៈទី ៤ អរូបជ្ឈាន ឈ្មោះថាជាគ្រឿងរលាស់ចេញនៃរូបទាំងឡាយ ។ ម្យ៉ាងទៀត គប្បីប្រកបអរហត្តផលចូលក្នុងបទនេះថា **អច្ចន្តនិស្សរណំ** ដូច្នេះ ។ ក្នុងវារៈទី ៥ បទថា **សក្កាយំ មនសិករោតោ** សេចក្ដីថា កាលភិក្ខុកំណត់សង្ខារសុទ្ធជាអារម្មណ៍ រួចសម្រេចអរហត្ត ជាសុខវិបស្សកៈ ចេញអំពីផលសមាបត្តិ ហើយទើបបញ្ជូនចិត្តចំពោះឧបាទានក្ខន្ធ ៥ ដើម្បីពិចារណា ។ បទថា **ឥទមក្ខាតំ សក្កាយស្ស និស្ស-**

**រណំ** *សេចក្តីថា ចិត្តដែលសម្បយុត្តដោយអរហត្តផលសមាបត្តិ ដែលកើតឡើងថា សក្កាយនឹងមិនមានតទៅទៀត ដូច្នេះ របស់ភិក្ខុដែលឃើញព្រះនិព្វានដោយអរហត្តមគ្គ និងដោយផលតាំងនៅនេះ លោកពោលថា ជាគ្រឿងរលាស់ចេញទៅនៃសក្កាយ ដូច្នេះ ។*

*ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សរសើរគុណនៃព្រះខីណាស្រពដែលសម្រេចសក្កាយនិស្សរណនិរោធ ដូច្នេះ តាំងនៅ ទើបត្រាស់ពាក្យជាដើមថា* **តស្ស កាមនន្ទិបិ ឆានុសេតិ** *ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **ឆានុសេតិ** *គឺមិនកើត ។ បទថា* **អនានុសយា** *គឺព្រោះការមិនកើត ។ បទដ៏សេស ក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ៕*

**អដ្ឋកថានិស្សារណីយសូត្រទី ១០ ចប់**

**ព្រាហ្មណវគ្គទី ៤ ចប់**

**ចតុត្ថបណ្ណាសក ចប់**

# សុត្តន្តបិដក
# បញ្ចមបណ្ណាសក

## កិម្ពិលវគ្គ
### កិម្ពិលសូត្រទី ១

[ ១០១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជិតស្រុកកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះកិមិលៈដ៏មានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មមិនប្រតិស្ឋាននៅយូរបាន ។ ម្នាលកិមិលៈ កាលព្រះតថាគតបរិនិព្វានទៅ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ មិនគោរព មិនកោតក្រែងក្នុងព្រះសាស្តា មិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ មិនគោរព មិនកោតក្រែង ក្នុងព្រះសង្ឃ មិនគោរព មិនកោតក្រែង ក្នុងសិក្ខា មិនគោរព មិនកោតក្រែង នូវគ្នានិងគ្នា ។ ម្នាលកិមិលៈ នេះឯងជាហេតុ នេះជាបច្ច័យ ដែលព្រះតថាគត

បរិនិព្វានទៅ ព្រះសទ្ធម្មមិនប្រតិស្ឋាននៅយូរបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្ម ប្រតិស្ឋាននៅយូរបាន ។ ម្នាលកិមិលៈ កាលព្រះតថាគតបរិនិព្វានទៅ ពួក ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ក្នុងសាសនានេះ មានសេចក្តីគោរព កោត ក្រែង ក្នុងព្រះសាស្តា មានសេចក្តីគោរព កោតក្រែងក្នុងព្រះធម៌ មានសេចក្តី គោរព កោតក្រែង ក្នុងព្រះសង្ឃ មានសេចក្តីគោរពកោតក្រែង ក្នុងសិក្ខា មានសេចក្តីគោរពកោតក្រែង នូវគ្នានិងគ្នា ។ ម្នាលកិមិលៈ នេះឯងជាហេតុ នេះជាបច្ច័យ ដែលព្រះតថាគតបរិនិព្វានទៅ ព្រះសទ្ធម្មប្រតិស្ឋាននៅយូរបាន ។

# អដ្ឋកថា
# បញ្ចមបណ្ណាសក

## កិម្ពិលវគ្គទី ១

### កិម្ពិលសូត្រ

[ ១០១ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងកិម្ពិលសូត្រទី ១ នៃបញ្ចមបណ្ណាសក ដូចតទៅនេះ បទថា **កិម្ពិលាយំ** បានដល់ ក្នុងនគរមានឈ្មោះយ៉ាងនេះ ។ បទថា **វេឡុវនេ** គឺក្នុងព្រៃមុចលិន ។ បទថា **ឯតទវោច** បានឮថា ព្រះថេរៈនេះ ជាសេដ្ឋីបុត្រក្នុងនគរនោះ បួសក្នុងសម្នាក់ព្រះសាស្តា បាននូវបុព្វេនិវាសញ្ញាណ ព្រះថេរៈនោះ កាលរឭកដល់ខន្ធសន្តានរបស់ខ្លួនធ្លាប់អាស្រ័យហើយបួសហើយ ក្នុងកាលសាសនារបស់ព្រះកស្សបទសពលសាបសូន្យទៅ កាលបរិស័ទ ៤ មិនធ្វើសេចក្តីគោរពក្នុងសាសនា ទើបដាក់ជណ្តើរឡើងភ្នំ ធ្វើសមណធម៌លើភ្នំនោះ បានឃើញភាពដែលខ្លួនធ្លាប់អាស្រ័យហើយ លោកចូលទៅគាល់ព្រះសាស្តា ហើយបំណងនឹងទូលសួរដល់ហេតុនោះដូច្នេះ ទើបក្រាបទូលពាក្យជាដើមថា **កោ នុ ខោ ភន្តេ** ដូច្នេះ ជាមួយព្រះសាស្តានោះ ។

បទថា **សត្ថរិ អគារវា វិហរន្តិ អប្បតិស្សា** សេចក្តីថា រមែងមិនតាំងសេចក្តីគោរព និងភាពជាធំទុកក្នុងព្រះសាស្តា ។ ក្នុងបទដ៏សេស ក៏ន័យនេះ

ដូចគ្នា ។

ក្នុងបទទាំងនោះ ភិក្ខុកាលដើរកាន់ឆត្រ ពាក់ស្បែកជើងត្រង់លានព្រះចេតិយជាដើមក្តី និយាយរឿងដែលមិនជាប្រយោជន៍ មានប្រការផ្សេងៗ ក្តី ឈ្មោះថា មិនគោរពក្នុងព្រះសាស្តា ។ ម្យ៉ាងទៀត អង្គុយនិទ្រាក្នុងរោងស្តាប់ធម៌ក្តី និយាយរឿងដែលមិនជាប្រយោជន៍ មានប្រការផ្សេងៗ ក្តី ឈ្មោះថា មិនគោរពក្នុងព្រះធម៌ ។ កាលពោលដល់រឿងផ្សេងៗ លើកដៃគ្រវីកណ្តាលជំនុំសង្ឃ មិនធ្វើការកោតក្រែងក្នុងភិក្ខុដែលជាថេរៈ នវក និងមជ្ឈិម ឈ្មោះថា មិនគោរពក្នុងសង្ឃ ។ កាលមិនធ្វើសិក្ខាឲ្យបរិបូណ៌ ឈ្មោះថា មិនគោរពក្នុងសិក្ខា កាលធ្វើនូវជម្លោះទាស់ទែងដល់គ្នានិងគ្នាជាដើម ឈ្មោះថា មិនគោរពដល់គ្នានិងគ្នា ។

**អដ្ឋកថាកិម្ពិលសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ធម្មស្សវនសូត្រទី ២

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ព្រះសទ្ធម្មនេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺអ្នកស្តាប់តែងបានស្តាប់រឿងមិនទាន់បានស្តាប់ ១ រឿងណាដែលធ្លាប់ស្តាប់ហើយ តែមិនទាន់ចូលចិត្តច្បាស់ នឹងចូលចិត្តច្បាស់ឡើងបាន ១ កម្ចាត់បង់សេចក្តីសង្ស័យចេញបាន ១ ធ្វើសេចក្តីយល់ឃើញឲ្យត្រង់ ១ ចិត្តអ្នកស្តាប់រមែងជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្តាប់ធម៌ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ធម្មស្សវនសូត្រ

[ ១០២ ] ក្នុងធម្មស្សវនសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាធម្មស្សវនសូត្រទី ២ ចប់

# សុត្តន្តបិដក

## អាជានិយសូត្រទី ៣

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនរបស់ព្រះរាជា ប្រកបដោយអង្គ ៥ ជាសេះគួរដល់ព្រះរាជា ជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ប្រកបដោយអង្គ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមានចិត្តត្រង់ ១ មានសម្ទុះលឿន ១ មានចិត្តទន់ ១ មានចិត្តអត់ធន់ ១ មានចិត្តស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ចម្រើនរបស់ព្រះរាជា ប្រកបដោយអង្គទាំង ៥ នេះ ទើបជាសេះគួរដល់ព្រះរាជា ជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជាបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៥ ក៏យ៉ាងនោះដែរ ទើបជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរទទួលទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តរបស់សត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយអង្គ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមានចិត្តត្រង់ ១ មានសម្ទុះលឿន ១ មានចិត្តទន់ ១ មានចិត្តអំណត់ ១ មានចិត្តស្ងប់ស្ងៀម ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ ទើបជាអ្នកគួរទទួលគ្រឿងបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរធ្វើអញ្ជលី ជាបុញ្ញក្ខេត្តរបស់សត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

# អដ្ឋកថា

## អាជានិយសូត្រ

[ ១០៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាជានិយសូត្រទី ៣ ដូចតទៅនេះ បទថា **អាជ្ជវេន** បានដល់ ដោយការត្រង់ គឺដោយការទៅ មិនវៀច ។ បទថា **ជវេន** គឺដោយឫទ្ធិដើររហ័ស ។ បទថា **មទ្ទវេន** គឺមានសរីរៈទន់ភ្លន់ ។ បទថា **ខន្តិយា** គឺអត់ធន់ ដោយការអត់ធន់ ។ បទថា **សោរច្ចេន** គឺដោយមានប្រក្រតីស្អាត ក្នុងភិក្ខុវារៈគប្បីជ្រាបវិនិច្ឆ័យដូច្នេះថា បទថា **អាជ្ជវំ** បានដល់ ការទៅត្រង់នៃញាណ ។ បទថា **ជវោ** បានដល់ ដំណើរទៅនៃញាណដែលចាស់ក្លា ។ បទថា **មទ្ទវំ** គឺការទន់ភ្លន់ជាប្រក្រតី ។ បទថា **ខន្តិ** បានដល់ អត់ធន់ដោយការអត់សង្កត់នោះឯង ។ បទថា **សោរច្ចំ** គឺមានការស្អាតជាប្រក្រតីនោះឯង ៗ៚

**អដ្ឋកថា អាជានិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ពលសូត្រទី ៤

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ ពលនេះមាន ៥ យ៉ាង ។ ពល ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសទ្ធាពល ១ ហិរិពល ១ ឱត្តប្បពល ១ វិរិយពល ១ បញ្ញាពល ១ ។ ម្នាលភិក្ខុទាំងឡាយ ពលមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ពលសូត្រ

[ ១០៤ ] ពលសូត្រទី ៤ ត្រាស់ពល ៥ ទុកលាយឡំគ្នា ។
អដ្ឋកថាពលសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ចេតោខិលសូត្រទី ៥

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ចម្រឹងនៃចិត្តនេះមាន ៥ យ៉ាង ។ ចម្រឹងនៃចិត្ត ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុណាសង្ស័យ ងឿងឆ្ងល់មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីជុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីជុតកម្តៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចម្រឹងនៃចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងព្រះធម៌ ... ក្នុងព្រះសង្ឃ ... ក្នុងសិក្ខា ... ភិក្ខុមានចិត្តខឹងអាក់អន់គ្នាន់ក្នាញ់ របឹងរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមានចិត្តខឹងអាក់អន់គ្នាន់ក្នាញ់ របឹងរឹងរូសក្នុងសព្រហ្មចារីទាំងឡាយ ចិត្តរបស់ភិក្ខុនោះមិនបង្អោន

ទៅ ដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចម្រឹងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចម្រឹងនៃចិត្តមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ចេតោខិលសូត្រ

[ ១០៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចេតោខិលសូត្រទី ៥ ដូចតទៅនេះ បទថា **ចេតោខិលា** បានដល់ ការរឹងត្អឹង ភាពជាសំរាម ភាពជាចម្រឹងនៃចិត្ត ។ បទថា **សត្ថរិ កង្ខតិ** សេចក្ដីថា ភិក្ខុរមែងសង្ស័យក្នុងព្រះរូបកាយ ឬក្នុងព្រះគុណនៃព្រះសាស្ដា ។ កាលសង្ស័យក្នុងព្រះរូបកាយ រមែងសង្ស័យថា ព្រះរូបកាយ ឈ្មោះថា ប្រដាប់ដោយបុរិសលក្ខណៈ ៣២ មាន ឬមិនមានហ្ន៎ ដូច្នេះ កាលសង្ស័យក្នុងគុណ រមែងសង្ស័យថា ព្រះសព្វញ្ញុតញ្ញាណ ដែលអាចដឹងអតីត អនាគត និងបច្ចុប្បន្ន មាន ឬមិនមានហ្ន៎ ដូច្នេះ ។ បទថា **វិចិកិច្ឆតិ** បានដល់ ជ្រើសរើសលំបាក រមែងដល់នូវសេចក្ដីលំបាក គឺមិនអាចសម្រេចបាន ។ បទថា **នាធិមុច្ចតិ** បានដល់ រមែងមិនបាននូវការបង្អោនចិត្តជឿថា វត្ថុនោះយ៉ាងនេះ ។ បទថា **ន សម្បសីទតិ** សេចក្ដីថា ឈម

ចុះក្នុងគុណ ហើយក៏មិនអាចនឹងជ្រះថ្លា គឺមានចិត្តមិនល្អក់ ព្រោះមិនមានសេចក្តីសង្ស័យ ។

បទថា **អាតប្បាយ** បានដល់ ដើម្បីធ្វើសេចក្តីព្យាយាមដុតបំផ្លាញនូវកិលេស ។ បទថា **អនុយោគាយ** បានដល់ ដើម្បីការប្រកបរឿយៗ ។ បទថា **សាតច្ចាយ** បានដល់ ដើម្បីធ្វើជាប់តគ្នា ។ បទថា **បធានាយ** បានដល់ ដើម្បីតាំងសេចក្តីព្យាយាម ។ បទថា **អយំ បឋមោ ចេតោខីលោ** សេចក្តីថា ភាវៈនេះ ជាភាពរឹងត្អឹងនៃចិត្តទី ១ គឺសេចក្តីសង្ស័យក្នុងព្រះសាស្តានេះយ៉ាងនេះឯង ភិក្ខុនោះក៏មិនទាន់លះបាន ។

បទថា **ធម្មេ** គឺក្នុងបរិយត្តិធម៌ និងបដិវេធធម៌ ។ កាលសង្ស័យក្នុងបរិយត្តិធម៌ រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា ព្រះត្រៃបិដក មានពុទ្ធវចនៈ ៨៤០០០ ព្រះធម្មក្ខន្ធ ដូច្នេះ ព្រះពុទ្ធវចនៈនោះ មាន ឬមិនមានហ្ន៎ ដូច្នេះ ។ កាលសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា ផលនៃវិបស្សនា ឈ្មោះថា មគ្គ ផលរបស់មគ្គ ឈ្មោះថា ផល ធម៌ដែលលះបង់សង្ខារទាំងពួង ឈ្មោះថា និព្វាន ដូច្នេះ និព្វាននោះមាន ឬមិនមានហ្ន៎ ដូច្នេះ ។ បទថា **សង្ឃេ កង្ខតិ** សេចក្តីថា រមែងសង្ស័យថា ឈ្មោះថា សង្ឃ ជាអ្នកដើរតាមបដិបទាបែបនេះ តាមបទជាដើមថា **ឧជុបដិបន្នោ** ដូច្នេះ ជាទីប្រជុំនៃបុគ្គល ៨ គឺលោកដែលតាំងនៅក្នុងមគ្គ ៤ លោកដែលតាំងនៅក្នុងផល ៤ មាន ឬមិនមានហ្ន៎ ដូច្នេះ ។

កាលសង្ស័យក្នុងសិក្ខា រមែងសង្ស័យថា អាចារ្យទាំងឡាយពោលថា អធិសីល អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខាដូច្នេះ សិក្ខានោះមាន ឬមិនមានហ្ន៎ ។

បទថា **អយំ បញ្ចមោ** សេចក្ដីថា ភាវៈនេះ ជាការរឹងត្អឹង ជាសំរាម ជាចម្រឹងនៃចិត្តទី ៥ គឺការអាក់អន់ក្នុងសព្រហ្មចារី ។៙

**អដ្ឋកថាចេតោខីលសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## វិនិពន្ធសូត្រទី ៦

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តនេះ មាន ៥ យ៉ាង ។ ចំណងនៃចិត្ត ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្រហល់ក្រហាយ មិនទាន់ប្រាសចាកតណ្ហា ក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្ដីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្ដីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្ដីក្រហល់ក្រហាយ មិនទាន់ប្រាសចាកតណ្ហា ក្នុងកាម

ទាំងឡាយ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅ ដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំណងនៃចិត្តទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ... មិនទាន់ប្រាសចាកតម្រេកក្នុងរូប ... បរិភោគទាល់តែឆ្អែតពេញពោះ ប្រកបការដេកជាសុខ ផ្អែកជាសុខ លក់ជាសុខ ... ប្រព្រឹត្តព្រហ្មចរិយៈដោយប្រាថ្នា នូវទេវនិកាយណាមួយថា អាត្មាអញនឹងបានជាទេវតាសក្តិធំ ឬទេវតាសក្តិតូច ដោយសីលនេះ វត្តនេះ សេចក្តីព្យាយាមនេះ ឬដោយព្រហ្មចរិយៈនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាប្រព្រឹត្តព្រហ្មចរិយៈ ដោយប្រាថ្នាទេវនិកាយណាមួយថា អាត្មាអញនឹងបានជាទេវតាសក្តិធំ ឬទេវតាសក្តិតូច ដោយសីលនេះ វត្តនេះ សេចក្តីព្យាយាមនេះ ឬដោយព្រហ្មចរិយៈនេះ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ ចិត្តរបស់ភិក្ខុណា មិនបង្អោនទៅ ដើម្បីដុតកម្ដៅកិលេស ដើម្បីប្រកបរឿយៗ ដើម្បីធ្វើមិនដាច់ ដើម្បីតាំងមាំ នេះជាចំណងនៃចិត្តទី ៥ ។ ម្នាលភិក្ខុទាំងឡាយ ចំណងនៃចិត្តមាន ៥ យ៉ាង នេះឯង ។

# អដ្ឋកថា

## វិនិពន្ធសូត្រ

[ ១០៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិនិពន្ធសូត្រទី ៦ ដូចតទៅនេះ បទថា **ចេតសោ វិនិពន្ធា** បានដល់ កិលេស ឈ្មោះថា **ចេតសោ វិនិពន្ធ** ព្រោះទាញនូវចិត្ត ដូចធ្វើទុកក្នុងកណ្តាប់ដៃ ។ បទថា **កាមេ** បានដល់ ទាំងវត្ថុកាម ទាំងកិលេសកាម ។ បទថា **កាយេ** បានដល់ ក្នុងកាយរបស់ខ្លួន ។ បទថា **រូបេ** គឺក្នុងរូបខាងក្រៅ ។ បទថា **យាវទត្ថំ** បានដល់ តាមដែលខ្លួនប្រាថ្នា ។ បទថា **ឧទរាវទេហកំ** បានដល់ អាហារដែលពេញពោះ អាហារដែលពេញពោះនោះ ហៅថា **ឧទរាវទេហកំ** ព្រោះដាក់ពេញពោះនោះ ។ បទថា **សេយ្យសុខំ** បានដល់ សេចក្តីសុខដោយការដេកលើគ្រែ ឬតាំង ឬសេចក្តីសុខតាមរដូវ ។ បទថា **បស្សសុខំ** បានដល់ សេចក្តីសុខដែលកើតឡើង ដូចសេចក្តីសុខរបស់បុគ្គលដែលដេកបម្រះទៅជុំវិញទាំងខាងស្តាំ និងខាងឆ្វេង ដូច្នោះ ។ បទថា **មិទ្ធសុខំ** គឺសុខក្នុងការដេកលក់ ។ បទថា **អនុយុត្តោ** បានដល់ ប្រកបសេចក្តីខ្វល់ខ្វាយ ។ បទថា **បណិធាយ** ប្រែថា ប្រាថ្នាហើយ ។ ចតុប្បារិសុទ្ធិសីល ឈ្មោះថា **សីល** ក្នុងបទជាដើមថា **សីលេន** ។ ការសមាទាន គឺកាន់យកវត្ត ឈ្មោះថា **វត្ត** ។ ការប្រព្រឹត្តតបៈ ឈ្មោះថា **តប** ព្រោះវៀរមេថុន ឈ្មោះថា **ព្រហ្មចរិយ** ។ បទថា **ទេវោ វា ភវិស្សាមិ** សេចក្តីថា អាត្មាអញនឹងជាទេវតាធំឬ ។ បទថា **ទេវញ្ញតរោ វា** សេចក្តីថា ឬនឹងជាទេវតាតូចអង្គឯណានីមួយ ៕ល៚

# សុត្តន្តបិដក

## យាគុសូត្រទី ៧

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សបបរនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកម្ចាត់បង់សេចក្តីឃ្លាន ១ កម្ចាត់បង់សេចក្តីស្រេក ១ ញុំាងខ្យល់ឲ្យប្រព្រឹត្តទៅសព្វ ១ ញុំាងសរសៃឲ្យស្អាត ១ ញុំាងអាហារថ្មីដែលនៅសល់ឲ្យឆ្អិន ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សបបរមាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## យាគុសូត្រ

[ ១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយាគុសូត្រទី ៧ ដូចតទៅនេះ បទថា **វាតំ អនុលោមេតិ** បានដល់ ធ្វើខ្យល់ឲ្យដើរស្រួល ។ បទថា **វត្ថឹ សោធេតិ** បានដល់ ជម្រះតម្រងបស្សាវៈឲ្យស្អាត ។ បទថា **អាមាវសេសំ បាចេតិ** សេចក្តីថា អាហារដែលឆៅ មិនទាន់រលួយមាន ក៏ជួយរម្លាយអាហារនោះ ។

**អដ្ឋកថា យាគុសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧន្តកដ្ឋសូត្រទី ៨

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់នេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមានចក្ខុមិនស្អាត ១ មាត់មានក្លិនស្អុយ ១ សរសៃនាំរសអាហារមិនបរិសុទ្ធ ១ ប្រមាត់ និងស្លេស្មរួបរឹតបាយ ១ មិនឆ្ងាញ់បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងការមិនទំពាឈើស្ទន់មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់នេះមាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺនាំឲ្យមានចក្ខុស្អាត ១ មាត់មិនមានក្លិនស្អុយ ១ សរសៃនាំរសអាហារបរិសុទ្ធ ១ ប្រមាត់ និងស្លេស្មមិនរួបរឹតបាយ ១ ឆ្ងាញ់បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការទំពាឈើស្ទន់ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ឧន្តកដ្ឋសូត្រ

[ ១០៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទន្តកដ្ឋសូត្រទី ៨ ដូចតទៅនេះ បទថា **អចក្ខុស្សំ** បានដល់ មិនធ្វើនូវឧបការៈដល់ចក្ខុ គឺមិនធ្វើចក្ខុឲ្យថ្លា ។

**អដ្ឋកថា ឧន្តកដ្ឋសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## គីតស្សរសូត្រទី ៩

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលពោលធម៌ ដោយសំឡេងច្រៀងវែងនេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងក៏ត្រេកអរ ក្នុងសំឡេងនោះ ១ ជនទាំងឡាយដទៃ ក៏ត្រេកអរក្នុងសំឡេងនោះ ១ គហបតីទាំងឡាយ ពោលទោសថា ពួកយើងច្រៀងយ៉ាងណា ពួកសមណសក្យបុត្តិយ៍ទាំងនេះ ក៏ច្រៀងយ៉ាងនោះដែរ ១ បុគ្គលពេញចិត្តក្នុងការស្ងូត្ររលាក់រលែកសំឡេង រមែងខូចសមាធិ ១ ពួកជនខាងក្រោយនឹងដល់នូវទិដ្ឋានុគតិ ( យកតម្រាប់តាម ) ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលពោលធម៌ ដោយសំឡេងច្រៀងវែង មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## គីតស្សរសូត្រ

[ ១០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគីតសូត្រទី ៩ ដូចតទៅនេះ បទថា **អាយតកេន** បានដល់ វែង គឺធ្វើឲ្យលើសគាថា ដែលមានបទ និងព្យញ្ជនៈបរិបូណ៌ឲ្យខូចទៅ ។ បទថា **សរកុត្តិម្បិ និកាមយមានស្ស** សេចក្តីថា កាលប្រាថ្នាការតុបតែងសំឡេង ដោយគិតថា សំឡេងច្រៀង អញគួរធ្វើយ៉ាងនេះ ដូច្នេះ ។ បទថា **សមាធិស្ស ភង្គោ ហោតិ** សេចក្តីថា ចិត្តដែលប្រកប

ដោយសមថៈ និងវិបស្សនា ក៏ខូចទៅ ៕

## អដ្ឋកថាគីតសូត្រទី ៩ ចប់

# សុត្តន្តបិដក

## មុដ្ឋស្សតិសូត្រទី ១០

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលដេកលក់ ភ្លេចស្មារតី មិនដឹងខ្លួននេះមាន ៥ យ៉ាង ៗ ទោស ៥ យ៉ាង គឺអ្វីខ្លះ ៗ គឺដេកលក់ជាទុក្ខ ១ ភ្ញាក់ឡើងជាទុក្ខ ១ យល់សប្តិអាក្រក់ ១ ទេវតាមិនរក្សា ១ អសុចិហូរចេញ ១ ៗ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលដេកលក់ ភ្លេចស្មារតី មិនដឹងខ្លួន មាន ៥ យ៉ាងនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលដេកលក់ ប្រុងស្មារតី ដឹងខ្លួននេះ មាន ៥ យ៉ាង ៗ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ៗ គឺដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនយល់សប្តិអាក្រក់ ១ ទេវតារក្សា ១ អសុចិមិនហូរចេញ ១ ៗ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលដេកលក់ប្រុងស្មារតី ដឹងខ្លួន មាន ៥ យ៉ាងនេះឯង ៗ

**កិមិលវគ្គទី ១ ចប់**

## ឧទ្ទាននៃកិមិលវគ្គនោះ គឺ

ពោលអំពីរឿងកិមិលត្ថេរ ១ អំពីអានិសង្សស្តាប់ធម៌ ១ អំពីសេះអាជានេយ្យ ១ អំពីធម៌ជាកម្លាំង ១ អំពីចម្រើននៃចិត្ត ១ អំពីចំណាំនៃចិត្ត ១ អំពីអានិសង្សប្រឹបរ ១ អំពីឈើស្មុទ ១ អំពីការពោលធម៌ដោយសំឡេងច្រៀងវែង ១ អំពីការដេកលក់ ភ្លេចស្មារតី ១ ។

# អដ្ឋកថា

## មុដ្ឋស្សតិសូត្រ

[ ១១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមុដ្ឋស្សតិសូត្រទី ១០ ដូចតទៅនេះ បទថា **ទុក្ខំ សុបតិ** សេចក្តីថា កាលយល់សប្តិឃើញរឿងរ៉ាវផ្សេងៗ ក៏លក់មិនសប្បាយ ។ បទថា **ទុក្ខំ បដិពុជ្ឈតិ** សេចក្តីថា សូម្បីភ្ញាក់ ក៏ភ្ញាក់ដោយភ័យខ្លាច ។ ក្នុងសូត្រនេះ ត្រាស់សតិសម្បជញ្ញៈលាយគ្នា ៕

**អដ្ឋកថាមុដ្ឋស្សតិសូត្រទី ១០ ចប់**

**កិម្ពិលវគ្គទី ១ ចប់**

# សុត្តន្តបិដក

## អក្កោសកវគ្គ

### អក្កោសកសូត្រទី ១

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជេរ ប្រទេច តិះដៀល ព្រះអរិយៈ ចំពោះសព្រហ្មចារីទាំងឡាយ ទោស ៥ យ៉ាង តែងប្រាកដឡើងដល់ភិក្ខុនោះ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកត្រូវបារាជិក អស់ផ្លូវកែខៃ ១ ជាអ្នកត្រូវអាបត្តិដ៏សៅហ្មងណាមួយ ១ ជាអ្នកប៉ះពាល់នូវរោគយ៉ាងធ្ងន់ ១ ជាអ្នកស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជេរ ប្រទេច តិះដៀលព្រះអរិយៈ ចំពោះសព្រហ្មចារីទាំងឡាយ ទោស ៥ យ៉ាងនេះ តែងប្រាកដឡើងដល់ភិក្ខុនោះ ។

# អដ្ឋកថា

# អក្កោសកវគ្គទី ២

## អក្កោសកសូត្រ

[ ១១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្កោសកសូត្រទី ១ នៃអក្កោសកវគ្គទី ២ ដូចតទៅនេះ បទថា **អក្កោសកបរិភាសកោ** បានដល់ ជេរដោយអក្កោសកវត្ថុ ១០ បរិភាសដោយសម្តែងភ័យ ។ បទថា **ឆន្នបរិបន្ថោ** បានដល់ឈ្មោះថា មានផ្លូវដែលកាត់ផ្តាច់ចោលហើយ ព្រោះភាពដែលលោកុត្តរត្រូវកាត់ផ្តាច់ហើយ ដោយធម៌ជាគ្រឿងឃឹតយូរ ។ បទថា **រោគាតង្កី** បានដល់រោគនោះឯង ឈ្មោះថា **រាគាតង្ក** ព្រោះធ្វើជីវិតឲ្យបង្អៀតបង្អល់ ។l៚

**អដ្ឋកថា អក្កោសកសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ភណ្ឌនសូត្រទី ២

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ធ្វើនូវជម្លោះ ធ្វើនូវវិវាទ ធ្វើនូវតិរច្ឆានកថា ធ្វើនូវអធិករណ៍ក្នុងសង្ឃ ទោស ៥ យ៉ាង តែងប្រាកដឡើងដល់ភិក្ខុនោះ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ

មិនបានគុណវិសេសដែលខ្លួនមិនទាន់បាន ១ គុណវិសេសដែលខ្លួនបានហើយ សាបសូន្យទៅវិញ ១ កិត្តិសព្ទអាក្រក់រមែងខ្ចរខ្ចាយទៅ ១ ស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ជាអ្នកធ្វើសេចក្ដីប្រកួតប្រកាន់ ធ្វើជម្លោះ ធ្វើវិវាទ ធ្វើតិរច្ឆានកថា ធ្វើអធិករណ៍ក្នុងសង្ឃ ទោស ៥ យ៉ាងនេះ តែងប្រាកដឡើងដល់ភិក្ខុនោះ ។

# អដ្ឋកថា

## ភណ្ឌនសូត្រ

[ ១១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភណ្ឌនសូត្រទី ២ ដូចតទៅនេះ បទថា **អធិករណការកោ** បានដល់ ញ៉ាំងអធិករណ៍ ៤ យ៉ាងណាមួយឡើង ។ បទថា **អនធិគតំ** បានដល់ គុណវិសេសដែលមិនទាន់បានសម្រេចមកអំពីមុន ។ល។

### អដ្ឋកថា ភណ្ឌនសូត្រទី ២ ចប់

# សុត្តន្តបិដក

## សីលសូត្រទី ៣

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលនេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ក្នុងលោកនេះ តែងដល់នូវសេចក្តីវិនាសសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីប្រមាទ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ តែងមានកិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ២ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ ( បើ ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី ក៏គ្មានក្លៀវក្លា តែងមានមុខឱនចុះដើរចូលទៅ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៣ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងស្លាប់វង្វេងស្មារតី ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៤ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីលហើយ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៥ នៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល ។ ម្នាលភិក្ខុទាំងឡាយ

ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីល មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីលនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសីល បរិបូណ៌ដោយសីលក្នុងលោកនេះ តែងបាននូវគំនរសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ១ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ តែងមានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីលហើយ (បើ) ចូលទៅកាន់បរិសទ្យណា ទោះបីជាខត្តិយបរិសទ្យក្តី ព្រាហ្មណបរិសទ្យក្តី គហបតិបរិសទ្យក្តី សមណបរិសទ្យក្តី តែងក្លៀវក្លា មិនឱនមុខចុះដើរចូលទៅ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៣ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល តែងស្លាប់មិនវង្វេងស្មារតីឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៥ នៃសីលសម្បទារបស់បុគ្គលមានសីល ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីល មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## សីលសូត្រ

[ ១១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីលសូត្រទី ៣ ដូចតទៅនេះ បទថា **ទុស្សីលោ** បានដល់ មិនមានសីល គឺឥតសីល ។ បទថា **សីលវិបន្នោ** បានដល់ មានសីលវិបត្តិ ដាច់នូវសំវរៈ ។ បទថា **បមាទាធិករណំ** បានដល់ ព្រោះមានការប្រមាទជាហេតុ ។

សូត្រនេះ ប្រើសម្រាប់គ្រហស្ថ ។ សូម្បីបព្វជិតក៏ប្រើបានដូចគ្នា ។ ពិតហើយ គ្រហស្ថ រមែងចិញ្ចឹមជីវិតបានដោយសិប្បៈណាមួយ ទោះជាធ្វើស្រែក្តី លក់ដូរក្តី បើប្រមាទ ដោយធ្វើបាណាតិបាតជាដើម សិប្បៈនោះៗ ក៏ឲ្យសម្រេចផលតាមកាលមិនបាន កាលបើដូច្នោះ បុគ្គលនោះក៏នឹងខាតបង់ ។ កាលធ្វើបាណាតិបាត និងអទិន្នាទានជាដើម ក្នុងកាលដែលបុគ្គលនោះមិនធ្វើទោស ក៏ដល់នូវការវិនាសនៃភោគទ្រព្យដ៏ច្រើន ។ បព្វជិតដែលទ្រុស្តសីល រមែងដល់នូវការវិនាសចាកសីល ពុទ្ធវចនៈ ឈាន និងចាកអរិយទ្រព្យ ៧ ព្រោះមានការប្រមាទជាហេតុ ។ សម្រាប់គ្រហស្ថ កេរ្តិ៍ឈ្មោះអាក្រក់ រមែងផ្សាយទៅកណ្តាលបរិស័ទ ៤ ។ គ្រហស្ថនោះ កើតក្នុងត្រកូលនោះ ជាអ្នកទ្រុស្តសីល មានបាបធម៌ រលោស់លោកនេះ និងលោកខាងមុខចោល ហើយមិនឲ្យទាន សូម្បីតែអាហារដូច្នេះ សម្រាប់បព្វជិត កេរ្តិ៍ឈ្មោះក៏ខ្ចរខ្ចាយទៅយ៉ាងនេះថា បព្វជិតនោះរក្សាសីលមិនបាន រៀនព្រះពុទ្ធវចនៈក៏មិនបាន ចិញ្ចឹមជីវិតដោយវេជ្ជកម្មជាដើម ជាអ្នកប្រកបដោយការមិនគោរព ៦ យ៉ាង ដូច្នេះ ។ បទថា **អវិសារទោ** សេចក្តីថា គ្រហស្ថមុនគេគិតថា បុគ្គលខ្លះ នឹងដឹង

កម្មរបស់អាត្មាអញ កាលបើដូច្នោះ មនុស្សទាំងឡាយនឹងចាប់អញ ឬនឹងប្រាប់អញដល់រាជត្រកូល ដូច្នេះ ទើបចូលទៅរក ដោយមានការភ័យខ្លាច អៀនអន់ មានកជ្ជាក់ចុះ មានមុខសំយុង អង្គុយយកម្រាមដៃឆ្កឹះដី មិនហ៊ានពោលក្នុងទីប្រជុំរបស់មហាជនដោយពិត ។ ចំណែកបព្វជិតគិតថា ភិក្ខុប្រជុំគ្នាច្រើនៗ ភិក្ខុរូបខ្លះ នឹងដឹងកម្មរបស់អញពិត កាលបើដូច្នោះ ពួកភិក្ខុនឹងហាមទាំងឧបោសថ ទាំងបវារណាដល់អញ ឲ្យអញឃ្លាតចាកភាពជាសមណៈ ហើយនឹងអូសចេញទៅ ដូច្នេះ ទើបចូលទៅរកដោយការព្រឺព្រួច មិនហ៊ានពោល ។ ចំណែកបុគ្គលខ្លះទ្រុស្តសីល ត្រូវទម្លាយហើយ ក៏នៅត្រាច់ទៅ បព្វជិតរូបនោះឈ្មោះថា ជាអ្នកអៀនអន់ មុខក្រាស់ ដោយអជ្ឈាស្រ័យនោះឯង ។

បទថា **សម្មុឡ្ហោ កាលំ ករោតិ** សេចក្តីថា ការទាញយកទុស្សីលកម្មប្រព្រឹត្តហើយ រមែងប្រាកដដល់លោកដែលដេកលើគ្រែសម្រាប់ស្លាប់ លោកបើកភ្នែកឡើងឃើញលោកនេះ បិទភ្នែកក៏ឃើញលោកខាងមុខ អបាយ ៤ រមែងប្រាកដដល់លោក លោកហាក់ដូចត្រូវលំពែង ១០០ ប្រហារត្រង់ក្បាល ជននោះបន្លឺសំឡេងស្រែកថា អ្នកទាំងឡាយ ជួយឃាត់ផង អ្នកទាំងឡាយ ជួយឃាត់ផង ក៏ស្លាប់ ដោយហេតុនោះ ទើបត្រាស់ថា **សម្មុឡ្ហោ កាលំ ករោតិ** ។ បទទី ៥ ងាយយល់ទាំងអស់ហើយ ។ អានិសង្សគប្បីជ្រាបដោយបរិយាយ ផ្ទុយគ្នាតាមដែលពោលមកហើយ ៕

## អដ្ឋកថា សីលសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ពហុភាណីសូត្រទី ៨

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលនិយាយច្រើននេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺនិយាយកុហក ១ និយាយញុះញង់ ១ និយាយពាក្យអាក្រក់ ១ និយាយពាក្យឥតប្រយោជន៍ ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលនិយាយច្រើន មាន ៥ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលនិយាយតិចនេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិននិយាយកុហក ១ មិននិយាយញុះញង់ ១ មិននិយាយអាក្រក់ ១ មិននិយាយឥតប្រយោជន៍ ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គលនិយាយតិច មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ពហុភាណីសូត្រ

[ ១១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពហុភាណីសូត្រទី ៨ ដូចតទៅនេះ បទថា **ពហុភាណិស្មឹ** បានដល់ មិនកំណត់ដោយបញ្ញា ក៏ពោលច្រើន ។ បញ្ញាហៅថា **មន្តា** ក្នុងបទថា **មន្តភាណិស្មឹ** បានដល់ កំណត់ដោយបញ្ញាដែលហៅថា **មន្តា** ហើយ ទើបពោល ។

**អដ្ឋកថា ពហុភាណីសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមខន្តិសូត្រទី ៥

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់នេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនច្រើន ១ ជាអ្នកច្រើនដោយពៀរ ១ ច្រើនដោយទោស ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆានប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់នេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាទីស្រឡាញ់ ជាទីពេញចិត្ត របស់ជនច្រើន ១ មិនច្រើនដោយពៀរ ១ មិនច្រើនដោយទោស ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមខន្តិសូត្រ

[ ១១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមខន្តិសូត្រទី ៥ ដូចតទៅនេះ បទថា **វេរពហុលោ** បានដល់ ជាអ្នកមានពៀរច្រើន ដោយបុគ្គលវេរាខ្លះ ដោយ

អកុសលវេរាខ្វះ ។ បទថា **វជ្ជពហុលោ** គឺជាបុគ្គលច្រើនទៅដោយទោស ។៙

## អដ្ឋកថា បឋមខន្តិសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយខន្តិសូត្រទី ៦

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់នេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់ជនច្រើន ១ ជាមនុស្សអាក្រក់ ១ ជាមនុស្សមានសេចក្តីក្តៅក្រហាយ ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសនៃសេចក្តីមិនអត់ធន់ មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់នេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ជនច្រើន ១ មិនជាមនុស្សអាក្រក់ ១ មិនក្តៅក្រហាយ ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃសេចក្តីអត់ធន់ មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយខន្តិសូត្រ

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយខន្តិសូត្រទី ៦ ដូចតទៅនេះ បទថា **លុទ្ទោ** បានដល់ ទារុណយោរយៅ ។ បទថា **វិប្បសារី** គឺ ប្រកបដោយការក្តៅក្រហាយ ។l៚

**អដ្ឋកថា ទុតិយខន្តិសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមអចាសាទិកសូត្រទី ៧

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លានេះមាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងក៏តិះដៀលខ្លួនបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ រមែងតិះដៀលបាន ១ កិត្តិសព្ទអាក្រក់ខ្ចរខ្ចាយទៅ ១ តែងស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លាមាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លានេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងតិះដៀលខ្លួនឯងមិនបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ រមែង

សរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ តែងស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមអបាសាទិកសូត្រ

[ ១១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអបាសាទិកសូត្រទី ៧ ដូចតទៅ បទថា **អបាសាទិកេ** បានដល់ ជាអ្នកប្រកបដោយកាយកម្មជាដើម ដែលមិនគួរជ្រះថ្លា ។ បទថា **បាសាទិកេ** បានដល់ ដែលប្រព្រឹត្តស្មើដោយបរិសុទ្ធ ដែលនាំមកនូវសេចក្តីជ្រះថ្លា ។ល។

**អដ្ឋកថា បឋមអបាសាទិកសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយអចាសាធិកសូត្រទី ៨

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គល អ្នកមានអំពើមិនជាទីជ្រះថ្លានេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺពួកជនដែលមិនទាន់ជ្រះថ្លា រមែងមិនជ្រះថ្លា ១ ពួកជនខ្លះដែលជ្រះថ្លាហើយ ក៏ត្រឡប់ជាឯាកចិត្តចេញ ១ ឈ្មោះថា មិនធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា ១ ប្រជុំជនខាងក្រោយនឹងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះមិនជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសរបស់បុគ្គលអ្នកមានអំពើមិនជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លានេះ មាន ៥ យ៉ាង ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺពួកជនដែលមិនទាន់ជ្រះថ្លា រមែងជ្រះថ្លា ១ ពួកជនដែលជ្រះថ្លារួចហើយ រឹតតែជ្រះថ្លាឡើង ១ ឈ្មោះថា ធ្វើតាមពាក្យប្រដៅរបស់ព្រះសាស្តា ១ ប្រជុំជនខាងក្រោយនឹងយកតម្រាប់តាម ១ ចិត្តរបស់បុគ្គលនោះ រមែងជ្រះថ្លា ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សរបស់បុគ្គល អ្នកមានអំពើជាទីជ្រះថ្លា មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## ទុតិយអបាសាទិកសូត្រ

[ ១១៨ ] ក្នុងទុតិយអបាសាទិកសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយអបាសាទិកសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អគ្គិសូត្រទី ៩

[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ ទោសក្នុងភ្លើងនេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺឲ្យងងឹតភ្នែក ១ ធ្វើសម្បុរឲ្យអាក្រក់ ១ ធ្វើកម្លាំងឲ្យខ្សោយ ១ កុះករដោយពួកគណៈ ១ ប្រព្រឹត្តទៅដើម្បីតិរច្ឆានកថា ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងភ្លើង មាន ៥ យ៉ាងនេះឯង ។

# អដ្ឋកថា

## អគ្គិសូត្រ

[ ១១៩ ] ក្នុងអគ្គិសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអគ្គិសូត្រទី ៩ ចប់

# សុត្តន្តបិដក

## មធុរាសូត្រទី ១០

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ ទោសក្នុងដែនមធុរានេះ មាន ៥ យ៉ាង ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺទីមិនស្មើ ១ មានធូលីច្រើន ១ មានឆ្កែសាហាវ ១ មានយក្សកាច ១ រកបាយបានក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោសក្នុងដែនមធុរា មាន ៥ យ៉ាងនេះឯង ។

អក្កោសកវគ្គទី ២ ចប់

**ឧទ្ទាននៃអក្កោសកវគ្គនោះ គឺ**

ពោលអំពីរឿងជេរប្រទេច ១ អំពីរឿងប្រកួតប្រកាន់ ១
អំពីសីល ១ អំពីរឿងនិយាយច្រើន ១ អំពីសេចក្តី
មិនអត់ធន់ ២ រឿង អំពីសេចក្តីមិនជ្រះថ្លា ២ រឿង
អំពីទោសក្នុងភ្លើង ១ អំពីទោសក្នុងដែនមធុរា ១ ។

# អដ្ឋកថា

## មធុរាសូត្រ

[ ១២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមធុរាសូត្រទី ១០ ដូចតទៅនេះ បទថា **បញ្ចិមេ ភិក្ខវេ អាទីនវា មធុរាយំ** សេចក្តីថា សម័យមួយ ព្រះមានព្រះភាគមានពួកភិក្ខុចោមរោមហើយ កាលទ្រង់ចារិកទៅដល់មធុរានគរ ទើបប្រាវព្ធ

ចូលទៅខាងក្នុងព្រះនគរ ។ គ្រានោះ យក្ខិនីមួយជាមិច្ឆាទិដ្ឋិ អាក្រាតកាយ លាដៃទាំង ២ ចេញ លៀនអណ្តាត ឈរខាងមុខព្រះទសពល ព្រះសាស្តា មិនចូលខាងក្នុងព្រះនគរ ហើយយាងចេញអំពីទីនោះ ទ្រង់ទៅកាន់វិហារ ។ មហាជនកាន់យករបស់ទំពា របស់បរិភោគ និងគ្រឿងសក្ការៈបូជាទៅកាន់វិហារ បានថ្វាយទានដល់ភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ព្រះសាស្តាទ្រង់ប្រារព្ធព្រះសូត្រនេះ ដើម្បីទ្រង់ដាក់និគ្គហនគរនោះ ។ បណ្តាបទទាំងនោះ បទថា **វិសមា** បានដល់ មានផ្ទៃដីមិនរាបស្មើ ។ បទថា **ពហុរជា** បានដល់ ក្នុងកាលខ្យល់បក់ បានហាក់ដូចជាត្រូវគំនរធូលីហុយឡើង គ្របដណ្តប់ទុក ។ ពាក្យដ៏សេសក្នុងបទទាំងពួងមានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា មធុរាសូត្រទី ១០ ចប់**

**អក្កោសកវគ្គទី ២ ចប់**

# សុត្តន្តបិដក

## ឱយចារិកវគ្គ

### បឋមឱយចារិកសូត្រទី ១

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរច្ធាយ ដើរមិនឈប់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខានស្តាប់រឿង ដែលខ្លួនមិនធ្លាប់ស្តាប់ ១ រឿងដែលធ្លាប់ស្តាប់ហើយ មិនចូលចិត្តច្បាស់ ១ មិនក្លៀវក្លាដោយរឿងខ្លះដែលបានស្តាប់ហើយ ១ មានរោគធ្ងន់មកប៉ះពាល់ ១ ឥតមានមិត្តសម្លាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរច្ធាយ ដើរមិនឈប់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺបានស្តាប់រឿងដែលមិនធ្លាប់បានស្តាប់ ១ រឿងធ្លាប់ស្តាប់ហើយ នឹងចូលចិត្តច្បាស់ ១ ក្លៀវក្លាដោយរឿងខ្លះដែលបានស្តាប់ហើយ ១ មិនមានរោគជាទម្ងន់មកប៉ះពាល់ ១ មានមិត្តសម្លាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គលដើរតែល្មមៗ ។

# អដ្ឋកថា

## ទីឃចារិកាវគ្គទី ៣

### បឋមទីឃចារិកសូត្រ

[ ១២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមទីឃចារិកសូត្រទី ១ នៃទីឃចារិកវគ្គទី ៣ ដូចតទៅនេះ បទថា **អនវត្ថចារិកំ** បានដល់ ត្រាច់ទៅមិនមានកំណត់ ។ បទថា **សុតំ ន បរិយោទបេតិ** សេចក្តីថា ពាក្យណាដែលលោកធ្លាប់ស្តាប់ហើយ ក៏មិនអាចយល់ច្បាស់សេចក្តីនោះបាន ។ បទថា **សុតេនេកច្ចេន អវិសារទោ ហោតិ** សេចក្តីថា រមែងមិនដល់សោមនស្ស ដោយពាក្យដែលបានស្តាប់មក គឺការដឹង មានតិចតួច ។ បទថា **សមវដ្ឋចារេ** បានដល់ ក្នុងការត្រាច់ទៅ មានកំណត់ ។ល។

**អដ្ឋកថា បឋមទីឃចារិកសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយទីឃចារិកសូត្រទី ២

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរឆ្ងាយ ដើរមិនឈប់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនបានគុណវិសេសដែលខ្លួនមិនទាន់បាន ១ គុណវិសេសដែលខ្លួនបានហើយ ក៏សាបសូន្យទៅវិញ ១ មិនក្លៀវក្លាដោយគុណវិសេសបន្តិចបន្តួចដែលខ្លួនបានហើយ ១ មានរោគយ៉ាងធ្ងន់មកប៉ះពាល់ ១ ឥតមិត្តសម្លាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាង រមែងមានដល់បុគ្គលប្រកបរឿយៗ នូវការដើរឆ្ងាយ ដើរមិនឈប់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺគុណវិសេសដែលខ្លួនមិនបាន ក៏គង់នឹងបាន ១ គុណវិសេសដែលខ្លួនបានហើយមិនសាបសូន្យទៅវិញ ១ ក្លៀវក្លាដោយគុណវិសេសបន្តិចបន្តួចដែលខ្លួនបានហើយ ១ ឥតមានរោគយ៉ាងធ្ងន់មកប៉ះពាល់ ១ មានមិត្តសម្លាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលដើរតែល្មមៗ ។

# អដ្ឋកថា

## ទុតិយទីឃចារិកសូត្រ

[ ១២២ ] ក្នុងទុតិយទីឃចារិកសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុតិយទីឃចារិកសូត្រទី ២ ចប់

# សុត្តន្តបិដក

## អតិនិវាសសូត្រទី ៣

[ ១២៣ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកមានទ្រព្យសម្បត្តិច្រើន សន្សំទ្រព្យសម្បត្តិច្រើន ១ ជាអ្នកមានភេសជ្ជៈច្រើន សន្សំភេសជ្ជៈច្រើន ១ ជាអ្នកមានកិច្ចការច្រើន ត្រូវធ្វើការច្រើន មិនឈ្លាសក្នុងកិច្ចការ ១ ច្រឡូកច្រឡំដោយពួកគ្រហស្ថនិងបព្វជិត នៅរួមតែនឹងគ្រហស្ថដែលមិនសមគួរ ១ កាលបើចេញអំពីអាវាសនោះទៅ ចេញទៅទាំងអាឡោះអាល័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គល នៅតែល្មមៗ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនមានទ្រព្យសម្បត្តិច្រើន មិនសន្សំទ្រព្យសម្បត្តិច្រើន ១ មិនមានភេសជ្ជៈច្រើន មិនសន្សំភេសជ្ជៈច្រើន ១ មិនមានកិច្ចការច្រើន មិនត្រូវធ្វើកិច្ចការច្រើន ជាអ្នកឈ្លាសក្នុងការងារទាំង-ឡាយ ១ មិនច្រឡូកច្រឡំដោយពួកគ្រហស្ថ និងបព្វជិត មិននៅរួមជាមួយ

នឹងគ្រហស្ថដ៏មិនសមគួរ ១ កាលបើចៀសចេញពីអាវាសនោះទៅ ចៀសចេញទៅទាំងមិនអាឡោះអាល័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គលនៅតែលួមៗ ។

# អដ្ឋកថា

## អភិនិវាសសូត្រ

[ ១២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិនិវាសសូត្រទី ៣ ដូចតទៅនេះ បទថា **ពហុភណ្ឌោ** បានដល់ ជាអ្នកមានបរិក្ខារច្រើន ។ បទថា **ពហុភេសជ្ជោ** បានដល់ ជាអ្នកមានភេសជ្ជៈច្រើន ព្រោះសប្បិ និងនវនីតជាដើមមានច្រើន ។ បទថា **អព្យត្តោ** គឺជាបុគ្គលមិនឈ្លាស ។ បទថា **សំសដ្ឋោ** គឺជាបុគ្គលច្រឡូកច្រឡំ ដោយការច្រឡូកច្រឡំ ៥ យ៉ាង ។ បទថា **អននុលោមិកេន** បានដល់ មិនសមគួរដល់សាសនា ។៚

**អដ្ឋកថា អភិនិវាសសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មច្ឆរសូត្រទី ៤

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺជាអ្នកកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅជាប់មិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅតែល្អមៗ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកមិនកំណាញ់អាវាស ១ មិនកំណាញ់ត្រកូល ១ មិនកំណាញ់លាភ ១ មិនកំណាញ់គុណ ១ មិនកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលនៅតែល្អមៗ ។

# អដ្ឋកថា

## មច្ឆរសូត្រ

[ ១២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមច្ឆរសូត្រទី ៤ ដូចតទៅនេះ បទថា **វណ្ណមច្ឆរី** បានដល់ គឺជាអ្នកកំណាញ់គុណ ។ បទថា **ធម្មមច្ឆរី** គឺជាអ្នកកំណាញ់បរិយត្តិ ៕

**អដ្ឋកថា មច្ឆរសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមកុលុបកសូត្រទី ៥

[ ១២៥ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺរមែងត្រូវអាបត្តិ ព្រោះត្រាច់ទៅមិនលា ១ រមែងត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីស្ងាត់ ១ ត្រូវអាបត្តិ ព្រោះអង្គុយក្នុងទីកំបាំង ១ ត្រូវអាបត្តិ ព្រោះសម្តែងធម៌ដល់មាតុគ្រាមលើសជាង ៥ ឬ ៦ មាត់ ១ ជាអ្នកច្រើនដោយសេចក្តីត្រិះរិះក្នុងផ្លូវកាម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ។

# អដ្ឋកថា

## បឋមកុលុបកសូត្រ

[ ១២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមកុលុបកសូត្រទី ៥ ដូចតទៅនេះ បទថា **អនាមន្តចារេ អាបជ្ជតិ** សេចក្តីថា ត្រូវអាបត្តិ ដែលត្រាស់ទុកក្នុងសិក្ខាបទថា ភិក្ខុទទួលនិមន្តហើយ មានភត្តហើយ មិនលាភិក្ខុដែលមានដល់នូវភាពជាបុគ្គលត្រាច់ទៅក្នុងត្រកូលទាំងឡាយ មុនអាហារ ឬក្រោយអាហារ ដូច្នេះ ។ ក្នុងបទជាដើមថា **រហោនិសជ្ជាយ** គប្បីជ្រាបតាមសិក្ខាបទទាំងនោះ ៕

**អដ្ឋកថា បឋមកុលុបកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ទុតិយកុលុបកសូត្រទី ៦

[ ១២៦ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុ អ្នកចូលទៅកាន់ត្រកូល ប្រឡូកប្រឡំ ក្នុងត្រកូលហួសវេលា ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺឃើញមាតុគ្រាមរឿយៗ ១ កាលបើឃើញហើយរមែងជាប់ចិត្ត ១ កាលបើជាប់ចិត្តហើយ រមែងមានសេចក្តីស្និទ្ធស្នាល ១ កាលបើមានសេចក្តីស្និទ្ធស្នាលហើយ រមែងចុះចិត្ត ( ស្រឡាញ់ ) ១ ដែលចុះចិត្តស្រឡាញ់ហើយ រមែងមិនត្រេកអរ នឹងប្រព្រឹត្តព្រហ្មចរិយៈ នឹងត្រូវអាបត្តិសៅហ្មង ឬនឹងលាសិក្ខាត្រឡប់ទៅកាន់ភេទថោកទាបវិញ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់ភិក្ខុអ្នកចូលទៅកាន់ត្រកូល ប្រឡូកប្រឡំក្នុងត្រកូលហួសវេលា ។

# អដ្ឋកថា

## ទុតិយកុលុបកសូត្រ

[ ១២៦ ] ទុតិយកុលុបកសូត្រទី ៦ បទថា **អតិវេលំ** បានដល់ ហួសកាលដែលកំណត់ទុក ។ល។

**អដ្ឋកថា ទុតិយកុលុបកសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ភោគសូត្រទី ៧

[ ១២៧ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺភោគៈសាធារណៈដល់ភ្លើង ១ ភោគៈសាធារណៈដល់ទឹក ១ ភោគៈសាធារណៈដល់ព្រះរាជា ១ ភោគៈសាធារណៈដល់ចោរ ១ ភោគៈសាធារណៈដល់អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺអាស្រ័យភោគៈហើយ ញ៉ាំងខ្លួនឲ្យសុខ ឲ្យឆ្អែត រក្សាខ្លួនឲ្យសុខសប្បាយ ១ ញ៉ាំងមាតានិងបិតាឲ្យសុខ ឲ្យឆ្អែត រក្សាមាតាបិតាឲ្យសុខសប្បាយ ១ ញ៉ាំងកូនប្រពន្ធ ខ្ញុំ និងបុរសជាកម្មករ ឲ្យសុខ ឲ្យឆ្អែត រក្សាកូនប្រពន្ធ ខ្ញុំ និងបុរសជាកម្មករ ឲ្យសុខសប្បាយ ១ ញ៉ាំងមិត្ត និងអាមាត្យឲ្យសុខ ឲ្យឆ្អែត រក្សាមិត្ត អាមាត្យឲ្យបានសុខសប្បាយ ១ តម្កល់ទុកនូវទាន មានផលដ៏ខ្ពស់ក្នុងពួកសមណព្រាហ្មណ៍ ជាទានឲ្យនូវអារម្មណ៍ដ៏ប្រសើរល្អ មានផលជាសុខ ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។

## អដ្ឋកថា

### ភោគសូត្រ

[ ១២៧ ] ក្នុងភោគសូត្រទី ៧ មានអត្ថងាយយល់ហើយ ៕

អដ្ឋកថាភោគសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ភត្តសូត្រទី ៨

[ ១២៨ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូលអ្នកបរិភោគអាហារក្នុងវេលាថ្ងៃពេក ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភ្ញៀវជាអាគន្តុកៈណា ( មកកាន់ផ្ទះ ) ជនក្នុងត្រកូលមិនបានបូជាភ្ញៀវ ជាអាគន្តុកៈនោះ តាមកាល ១ ពួកទេវតាណា ជាអ្នកទទួលពលិកម្ម ជនក្នុងត្រកូលមិនបានបូជាពួកទេវតានោះ តាមកាល ១ ពួកសមណព្រាហ្មណ៍ណា ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ជនក្នុងត្រកូលមិនបានបូជាពួកសមណព្រាហ្មណ៍នោះ តាមកាល ១ ខ្ញុំនិងបុរសជាកម្មករ មុខក្រៀម ប្រឹងធ្វើការងារ ១ កត្តដែលខ្លួនបរិភោគខុសកាលហើយ ក៏ឥតឱជារស ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូល ដែលបរិភោគអាហារក្នុងពេលថ្ងៃពេក ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូល អ្នកបរិភោគអាហារត្រូវវេលា ។ អានិសង្ស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺពួកភ្ញៀវជាអាគន្តុកៈណា ( មកកាន់ផ្ទះ ) ជនក្នុងត្រកូលបានបូជាពួកភ្ញៀវជាអាគន្តុកៈនោះ តាមកាល ១ ពួកទេវតាណាជាអ្នកទទួលពលិកម្ម ពួកជនក្នុងត្រកូល បានបូជាពួកទេវតានោះ តាមកាល ១ ពួកសមណព្រាហ្មណ៍ណា ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកវិកាលភោជន ពួកជនក្នុងត្រកូលបានបូជាពួកសមណព្រាហ្មណ៍នោះ តាមកាល ១ ពួកខ្ញុំ និងបុរសជាកម្មករ មាន

មុខមិនក្រៀម ប្រឹងធ្វើការងារ ១ ភត្តដែលខ្លួនបរិភោគត្រូវពេលហើយ ក៏មានឱជារសឆ្ងាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានក្នុងត្រកូលអ្នកបរិភោគភត្តត្រូវពេល ។

# អដ្ឋកថា

## កត្តសូត្រ

[ ១២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកត្តសូត្រទី ៨ ដូចតទៅនេះ បទថា **ឧស្សូរភត្តេ** បានដល់ ក្នុងត្រកូលដែលចម្អិនអាហារយឺតយូរ ។ បទថា **ន កាលេន បដិបូជេន្តិ** សេចក្តីថា ពួកបុគ្គលទាំងនោះមិនចម្អិនបបរ ក្នុងកាលនៃបបរ របស់ទំពា ក្នុងកាលនៃរបស់ទំពា អាហារក្នុងកាលនៃអាហារ ទើបមិនបូជាតាមកាល ព្រោះកាលដែលប្រកបសេចក្តីខ្វល់ខ្វាយ ហួសពេលទៅហើយ ។ ឈ្មោះថា ឲ្យដោយចិត្តរបស់ខ្លួនប៉ុណ្ណោះ ។ បន្ទាប់មក កាលពួកជនទាំងនោះមកកាន់ផ្ទះរបស់ខ្លួន បុគ្គលក៏រមែងធ្វើយ៉ាងនោះដូចគ្នា ។ សូម្បីទេវតាដែលរង់ចាំទទួលពលី មកហើយតាមបវេណីរបស់ត្រកូល លុះបានលាភតាមកាលដ៏សមគួរ ទើបគ្រប់គ្រងរក្សា ។ តែកាលបានទទួលការកៀបសង្កត់មិនបានតាមកាលវេលា ក៏មិនធ្វើការរក្សា ដោយគិតថា ជនទាំងនេះ ជាអ្នកមិនអើពើក្នុងពួកយើង ដូច្នេះ ។ សូម្បីសមណព្រាហ្មណ៍ រមែងមិនធ្វើកិច្ច

ដែលគួរធ្វើក្នុងការងារមង្គល និងអពមង្គល ដោយគិតថា ក្នុងផ្ទះរបស់មនុស្ស ទាំងនោះ មិនមានអាហារ ក្នុងកាលនៃអាហារ បុគ្គលទាំងនោះឲ្យក្នុងពេលថ្ងៃត្រង់ ដូច្នេះ ។ បទថា **វិមុខា កម្មំ ករោន្តិ** សេចក្តីថា ពួកអ្នកបម្រើជាដើម លះបង់ការងារ នៅអង្គុយដោយគិតថា ក្នុងពេលព្រឹក ពួកយើងមិនបានអ្វីឡើយ ។ ពួកយើងស្រេកឃ្លានពន់ពេក ហើយមិនអាចធ្វើការងារបាន ដូច្នេះ ។ បទថា **អនោជវន្តំ ហោតិ** បានដល់ អាហារដែលបរិភោគ មិនប្រព្រឹត្តទៅតាមកាល រមែងមិនអាចផ្សាយឱជៈទៅបាន ។ ធម៌ដែលជាសុក្កបក្ខ គប្បីជ្រាបផ្ទុយគ្នា តាមដែលពោលហើយ ។

**អដ្ឋកថា ភត្តសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមសប្បសូត្រទី ៩

[ ១២៩ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺពស់វែកមិនស្អាត ១ មានក្លិនស្អុយ ១ គួរតក់ស្លុត ១ គួរខ្លាច ១ ទ្រុស្តមិត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ដូច្នោះដែរ ។ ទោស ៥ យ៉ាងគឺអ្វីខ្លះ ។ គឺ

មាតុគ្រាមមិនស្អាត ១ មានក្លិនស្អុយ ១ គួរតក់ស្លុត ១ គួរខ្លាច ១ ទ្រុស្ត-មិត្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ។

# អដ្ឋកថា

## បឋមសប្បសូត្រ

[ ១២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសប្បសូត្រទី ៩ ដូចតទៅនេះ បទថា **សភីរុ** បានដល់ ជាសត្វក្នុងរូង ដេកលក់ស៊ប់បានយូរ ។ បទថា **សប្បដិភយោ** បានដល់ ភ័យរមែងកើតឡើង ព្រោះអាស្រ័យពស់វែកនោះ ។ ព្រោះដូច្នោះ ទើបពស់នោះ ឈ្មោះថា មានភ័យចំពោះមុខ ។ បទថា **មិត្តទុព្ភី** បានដល់ ប្រទូស្តបៀតបៀនមិត្រ សូម្បីជាអ្នកឲ្យទឹក និងបាយ បរិភោគ ។ សូម្បីក្នុងមាតុគ្រាម ក៏មានន័យនេះដូចគ្នា ។៚

**អដ្ឋកថា បឋមសប្បសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយសប្បសូត្រទី ១០

[ ១៣០ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺពស់វែកមានចិត្តក្រោធ ១ ចងពៀរ ១ មានពិសពន្លឹក ១ មានអណ្ដាតអាក្រក់ ១ ទ្រុស្ដមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងពស់វែក ម្នាលភិក្ខុទាំង-ឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ដូច្នោះដែរ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមាតុគ្រាមច្រើនក្រោធ ១ ចងគំនុំ ១ មានពិសពន្លឹក ១ មានអណ្ដាតអាក្រក់ ១ ទ្រុស្ដមិត្ត ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមមានពិសពន្លឹកនេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមមានរាគៈខ្លាំងក្លា ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមមានអណ្ដាតអាក្រក់នេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមមានវាចាញុះញង់ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា មាតុគ្រាមជាអ្នកទ្រុស្ដមិត្រនេះ ម្នាលភិក្ខុទាំងឡាយ ដោយច្រើនមាតុគ្រាមប្រព្រឹត្តក្បត់ចិត្តស្វាមី ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងមាតុគ្រាម ។

**ទីឃចារិកវគ្គទី ៣ ចប់**

### ឧទ្ទាននៃទីឃចារិកវគ្គនោះ គឺ

និយាយអំពីចារិកទៅកាន់ទីឆ្ងាយ ២ រឿង អំពីការទៅ
ជាប់មិនដាច់ ១ អំពីសេចក្ដីកំណាញ់ ១ អំពីការចូល

ទៅកាន់ត្រកូល ២ រឿង អំពីភោគៈ ១ អំពីកត្ត ១

អំពីពស់វែក ២ រឿង ។

# អដ្ឋកថា

## ទុតិយសប្បសូត្រ

[ ១៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសប្បសូត្រទី ១០ ដូចតទៅនេះ បទថា **ឃោរវិសោ** គឺមានពិសដ៏ពន្លឹក ។ បទថា **ទុជិវ្ហោ** គឺមានអណ្តាតបែកជា ២ ។ បទថា **ឃោរវិសតា** គឺព្រោះជាសត្វដែលមានពិសដ៏ពន្លឹក ។ ក្នុងពីរបទដ៏សេស ក៏មានន័យដូចគ្នា ។

**អដ្ឋកថា ទុតិយសប្បសូត្រទី ១០ ចប់**

**ទីឃចារិកវគ្គទី ៣ ចប់**

# សុត្តន្តបិដក

# អាវាសិកវគ្គ

## អាវាសិកសូត្រទី ១

[ ១៣១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង មិនគួរសរសើរឡើយ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបរិបូណ៌ដោយមារយាទ មិនបរិបូណ៌ដោយវត្ត ១ មិនជាពហុស្សូត មិនទ្រទ្រង់នូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ១ មិនត្រេកអរក្នុងទីស្ងាត់ មិនត្រេកអរក្នុងកុសលធម៌ ១ មានវាចាមិនពីរោះ និយាយមិនពីរោះ ១ ឥតប្រាជ្ញា ល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាងនេះឯង មិនគួរសរសើរឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង គួរសរសើរ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បរិបូណ៌ដោយមារយាទ បរិបូណ៌ដោយវត្ត ១ ជាពហុស្សូត ទ្រទ្រង់ពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ ១ ជាអ្នកជុសខាត់ចិត្ត ត្រេកអរក្នុងទីស្ងាត់ ត្រេកអរក្នុងកុសលធម៌ ១ ជាអ្នកមានវាចាពីរោះ ចេះនិយាយពីរោះ ១ ជាអ្នកមានប្រាជ្ញាមិនល្ងង់ខ្លៅ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរសរសើរ ។

# អដ្ឋកថា
# អាវាសិកវគ្គទី ៤

## អាវាសិកសូត្រ

[ ១៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាវាសិកសូត្រទី ១ នៃអាវាសិកវគ្គទី ៤ ដូចតទៅនេះ បទថា **ន អាកប្បសម្បន្នោ** បានដល់ ជាអ្នកមិនដល់ព្រម ដោយកិរិយានៃសមណៈ ។ បទថា **អភាវនីយោ ហោតិ** បានដល់ ជាអ្នក មិនគួរសរសើរ ។ល។

**អដ្ឋកថាអាវាសិកសូត្រទី ១ ចប់**

# សុត្តន្តបិដក
## បិយសូត្រទី ២

[ ១៣២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរសរសើររបស់សព្រហ្មចារី ទាំងឡាយ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាសជា អ្នកមានសីល សង្រួមក្នុងបាតិមោក្ខ បរិបូណ៌ដោយអាចារៈ និងគោចរ ឃើញ ភ័យក្នុងទោស សូម្បីមានប្រមាណតិច សមាទានសិក្សា ក្នុងសិក្ខាបទទាំង-

ឡាយ ១ ជាពហុស្សូត ទ្រទ្រង់ពុទ្ធវចនៈ ដែលខ្លួនបានស្តាប់ហើយ បានសន្សំហើយ ធម៌ទាំងឡាយណា មានពីរោះខាងដើម ពីរោះកណ្តាល ពីរោះខាងចុង ប្រកាសនូវព្រហ្មចរិយៈប្រកបដោយអត្ថ និងព្យញ្ជនៈបរិសុទ្ធ បរិបូណ៌សព្វគ្រប់ ធម៌មានសភាពដូច្នោះ ភិក្ខុនោះបានស្តាប់ច្រើន បានចាំរត់មាត់ រំពឹងដោយចិត្ត ចាក់ធ្លុះដោយសេចក្តីយល់ នូវធម៌មានសភាពដូច្នោះ ១ ជាអ្នកមានវាចាពីរោះ និយាយពីរោះ ប្រកបដោយវាចាជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ ជាវាចាប្រាសចាកទោស អាចញុំាងមហាជនឲ្យដឹងសេចក្តីបាន ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក បានបរិបូណ៌នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ជាអ្នកធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះក្សយអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរសរសើររបស់សព្រហ្មចារីទាំងឡាយ ។

# អដ្ឋកថា

## បិយសូត្រ

[ ១៣២ ] ក្នុងបិយសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបិយសូត្រទី ២ ចប់

# សុត្តន្តបិដក

## សោភនសូត្រទី ៣

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងញ៉ាំងអាវាសឲ្យល្អ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ ភិក្ខុជាចៅអាវាស ជាអ្នកមានសីល ។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។បេ។ ចាក់ធ្លុះដោយសេចក្តីយល់ ១ ជាអ្នកមានវាចាពីរោះ និយាយពីរោះ ប្រកបដោយសំដីនៃអ្នកក្រុង ជាសម្តីច្បាស់លាស់ ជាវាចាប្រាសចាកទោស អាចញ៉ាំងមហាជនឲ្យដឹងសេចក្តីបាន ១ ជាអ្នកអង់អាច ដើម្បីពន្យល់មនុស្សដែលបានមករកខ្លួន ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក បានបរិបូណ៌នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ នេះ រមែងញ៉ាំងអាវាសឲ្យល្អ ។

# អដ្ឋកថា

## សោភនសូត្រ

[ ១៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោភនសូត្រទី ៣ ដូចតទៅនេះ បទថា **បដិភាណោ** បានដល់ ឈ្មោះថា ជាអ្នកអាច ព្រោះជាអ្នកប្រកប

*ដោយកម្លាំងកាយ និងកម្លាំងញាណ ។*

**អដ្ឋកថា សោភនសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ពហុបការសូត្រទី ៨

*[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកមានឧបការៈច្រើនដល់អាវាស ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ជាអ្នកមានសីល ។បេ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាពហុស្សូត ។បេ។ ចាក់ធ្លុះដោយសេចក្តីយល់ ១ ជួសជុលទីសេនាសនៈដែលបាក់បែក ១ មានភិក្ខុសង្ឃជាច្រើននិមន្តចូលមក ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ គ្នា ភិក្ខុជាចៅអាវាសក៏ចូលទៅប្រាប់ដល់គ្រហស្ថទាំងឡាយថា ម្នាលអាវុសោទាំងឡាយ មានភិក្ខុសង្ឃជាច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ គ្នា អ្នកទាំងឡាយ ចូរធ្វើបុណ្យ ពេលនេះជាពេលត្រូវធ្វើបុណ្យ ១ ជាអ្នកបានដូចសេចក្តីប្រាថ្នា បានមិនលំបាក បានបរិបូណ៌នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ក្រៃលែង ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ ប្រការនេះ រមែងជាអ្នកមានឧបការៈច្រើនដល់អាវាស ។*

# អដ្ឋកថា

## ពហុបការសូត្រ

[ ១៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពហុបការសូត្រទី ៤ ដូចតទៅនេះ បទថា **ខណ្ឌផុល្លំ** បានដល់ ទីដែលទ្រុឌទ្រោមបាក់បែក ។ បទថា **បដិសង្ខរោតិ** បានដល់ ជួសជុល គឺធ្វើឲ្យដូចប្រក្រតីដូចដើម ។ បទថា **អារោចេតិ** នេះ លោកពោលដោយត្រកូលដែលគេបានបវារណាហើយ ។

អដ្ឋកថា ពហុបការសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនុកម្បកសូត្រទី ៥

[ ១៣៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងជាអ្នកអនុគ្រោះដល់ពួកគ្រហស្ថ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស ណែនាំគ្រហស្ថឲ្យតាំងនៅក្នុងអធិសីល ១ ណែនាំឲ្យឃើញធម៌ ១ ចូលទៅជិតមនុស្សមានជំងឺហើយ រឭកឲ្យមានស្មារតីថា នែអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរតម្កល់ទុកនូវស្មារតី ឲ្យតាំងនៅក្នុងអរហគុណ ១ មានភិក្ខុសង្ឃចូលមកច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ ភិក្ខុចៅអាវាសចូលទៅប្រាប់ពួកគ្រហស្ថថា ម្នាលអាវុសោទាំងឡាយ

មានភិក្ខុសង្ឃចូលមកច្រើន ភិក្ខុទាំងឡាយមកអំពីដែនផ្សេងៗ អ្នកទាំងឡាយចូរនាំគ្នាធ្វើបុណ្យ ពេលនេះជាពេលគួរធ្វើបុណ្យ ១ ពួកទាយកប្រគេនភោជនណាដល់ភិក្ខុនោះ ជារបស់សៅហ្មងក្តី ល្អក្តី ខ្ជួនឯង ក៏បរិភោគភោជននោះមិនធ្វើសទ្ធាទេយ្យរបស់ទាយកឲ្យធ្លាក់ចុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងជាអ្នកអនុគ្រោះដល់ពួកគ្រហស្ថ ។

# អដ្ឋកថា

## អនុកម្បកសូត្រ

[ ១៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុកម្បកសូត្រទី ៥ ដូចតទៅនេះ បទថា **អធិសីលេសុ** បានដល់ ក្នុងសីល ៥ ។ បទថា **ធម្មទស្សនេ និវេសេតិ** បានដល់ ឲ្យតាំងនៅក្នុងធម្មទស្សនៈ គឺសច្ចៈ ៤ ។ បទថា **អរហគ្គតំ** បានដល់ តាំងសតិប្រព្រឹត្តទៅក្នុងព្រះរតនត្រ័យដ៏សមគួរ ដល់សក្ការៈទាំងពួង ។ អធិប្បាយថា លោកចូលទៅតាំងសេចក្តីគោរព កោតក្រែងក្នុងព្រះរតនត្រ័យនោះឯង ដូច្នេះ ៗល។

**អដ្ឋកថា អនុកម្បកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## យថាភតអវណ្ណសូត្រទី ៦

[ ១៣៦ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលសរសើរគុណបុគ្គលដែលមិនគួរសរសើរ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរសរសើរគុណ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយខ្ជាំងខ្ជប់សេចក្តីជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយខ្ជាំងខ្ជប់សេចក្តីមិនជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ញុំាងសទ្ធាទេយ្យរបស់ទាយកឲ្យធ្លាក់ចុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរពោលទោស ១ បានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលគួរសរសើរ ១ បានស្ទាបស្ទង់ពិចារណាមើល ហើយខ្ជាំងខ្ជប់សេចក្តីមិនជ្រះថ្លា ក្នុងទីដែលមិនគួរជ្រះថ្លា ១ បានស្ទាបស្ទង់ពិចារណាមើល ហើយតម្កល់ទុកនូវសេចក្តីជ្រះថ្លា ក្នុងទីដែលគួរជ្រះថ្លា ១ ញុំាងសទ្ធាទេយ្យរបស់ទាយក មិនឲ្យធ្លាក់ចុះ ១ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។

# អដ្ឋកថា

## យថាភតអវណ្ណសូត្រ

[ ១៣៦ ] ក្នុងយថាភតអវណ្ណសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាយថាភតអវណ្ណសូត្រទី ៦ ចប់

# សុត្តន្តបិដក

## យថាភតគេធសូត្រទី ៧

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលមិនគួរសរសើរ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរសរសើរ ១ ជាអ្នកកំណាញ់អាវាស ជាប់ក្នុងអាវាស ១ ជាអ្នកកំណាញ់ត្រកូល ជាប់ក្នុងត្រកូល ១ ញុំាងសទ្ធា-

ទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។បេ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរពោលទោស ១ បានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលគួរសរសើរ ១ មិនជាអ្នកកំណាញ់អាវាស មិនជាប់ក្នុងអាវាស ១ មិនជាអ្នកកំណាញ់ត្រកូល មិនជាប់ក្នុងត្រកូល ១ មិនញ៉ាំងសទ្ធាទេយ្យរបស់ទាយកឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## យថាភតគេជសូត្រ

[ ១៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងយថាភតគេជសូត្រទី ៧ ដូចតទៅនេះ បទថា **អាវាសបលិគេធី** បានដល់ តាំងនៅហាក់បីដូចលេបនូវអាវាស ដោយអំណាចនៃការជាប់ជំពាក់យ៉ាងខ្លាំងក្លា ។ បទដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា យថាភតគេជសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## បឋមយថាភតមច្ឆេរសូត្រទី ៨

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស មិនបានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលមិនគួរសរសើរ ១ មិនបានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរសរសើរ ១ ជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ។ ៥ យ៉ាងនេះឯង ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាចៅអាវាស បានស្ទាបស្ទង់ពិចារណាមើល ហើយពោលទោសបុគ្គលដែលគួរពោលទោស ១ បានស្ទាបស្ទង់ពិចារណាមើល ហើយសរសើរគុណបុគ្គលដែលគួរសរសើរ ១ មិនជាអ្នកកំណាញ់អាវាស ១ មិនជាអ្នកកំណាញ់ត្រកូល ១ មិនជាអ្នកកំណាញ់លាភ ១ ។ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## បឋមយថាភតមច្ឆេរសូត្រ

[ ១៣៨ ] ក្នុងបឋមយថាភតមច្ឆេរសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមយថាភតមច្ឆេរសូត្រទី ៨ ចប់

# សុត្តន្តបិដក

## ទុតិយយថាភតមច្ឆេរសូត្រទី ៩

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ជាអ្នកកំណាញ់គុណ ១ ជាអ្នកញ៉ាំងសទ្ធាទេយ្យរបស់ទាយក ឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនកំណាញ់អាវាស ១ ជាអ្នកមិនកំណាញ់ត្រកូល ១ ជាអ្នកមិនកំណាញ់លាភ ១ ជាអ្នកមិនកំណាញ់គុណ ១ មិនញ៉ាំងសទ្ធាទេយ្យរបស់ទាយកឲ្យធ្លាក់ចុះ ១ ។ ៥ យ៉ាងនេះឯង ។បេ។

# អដ្ឋកថា

## ទុតិយយថាភតមច្ឆេរសូត្រ

[ ១៣៩ ] ក្នុងទុតិយយថាភតមច្ឆេរសូត្រទី ៩ មានអត្ថងាយយល់ហើយ ។ល។

អដ្ឋកថាទុតិយយថាភតមច្ឆេរសូត្រទី ៩ ចប់

# សុត្តន្តបិដក

## តតិយយថាភតមច្ឆេរសូត្រទី ១០

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាសប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកកំណាញ់អាវាស ១ ជាអ្នកកំណាញ់ត្រកូល ១ ជាអ្នកកំណាញ់លាភ ១ ជាអ្នកកំណាញ់គុណ ១ ជាអ្នកកំណាញ់ធម៌ ១ ។ ៥ យ៉ាងនេះឯង ។បេ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាចៅអាវាស ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុជាអ្នកមិនកំណាញ់អាវាស ១ ជាអ្នកមិនកំណាញ់ត្រកូល ១ ជាអ្នកមិនកំណាញ់លាភ ១ ជាអ្នកមិនកំណាញ់គុណ ១ ជាអ្នកមិនកំណាញ់ធម៌ ១ ។ ៥ យ៉ាងនេះឯង ។បេ។

អាវាសិកវគ្គទី ៤ ចប់

### ឧទ្ទាននៃអាវាសិកវគ្គនោះ គឺ

និយាយអំពីភិក្ខុចៅអាវាសដែលមិនគួរសរសើរ ១ អំពីចៅអាវាស មិនជាទីស្រឡាញ់ដល់ពួកសព្រហ្មចារី ១ អំពីចៅអាវាស ធ្វើអាវាសឲ្យល្អ ១ អំពីចៅអាវាស មានឧបការៈច្រើន ១ អំពីចៅអាវាស មានសេចក្តីអនុគ្រោះដល់គ្រហស្ថ ១ អំពីចៅអាវាសកើតក្នុងនរក ឬស្ថានសួគ៌ដូចជាគេនាំយកទៅដាក់ ១ អំពីចៅអាវាសជាអ្នកពោលទោស ១ អំពីចៅអាវាសជាប់ក្នុងអាវាសនិងត្រកូល ១ អំពីចៅអាវាសមានសេចក្តីកំណាញ់ជាគម្រប់បួន ១ អំពីចៅអាវាសមានកំណាញ់ ៥ យ៉ាង ១ ។

## អដ្ឋកថា

### តតិយយថាភតមច្ឆេរសូត្រ

[ ១៤០ ] ក្នុងតតិយយថាភតមច្ឆេរសូត្រទី ៩ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា តតិយយថាភតមច្ឆេរសូត្រទី ១០ ចប់**

**អាវាសិកវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# ទុច្ចរិតវគ្គ

## ទុច្ចរិតសូត្រទី ១

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង តិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយតិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ វេលាស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលអ្នកប្រព្រឹត្តល្អ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ វេលាស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។

## កាយទុច្ចរិតសូត្រទី ២

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយកាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥

យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ដោយកាយ ។បេ។

## វចីទុច្ចរិតសូត្រទី ៣

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ដោយវាចា ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយវាចា ។បេ។

## មនោទុច្ចរិតសូត្រទី ៤

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ដោយចិត្ត ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ តិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ វេលាស្លាប់វង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយចិត្ត ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយក៏សរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ វេលាស្លាប់មិនវង្វេងស្មារតី ១ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្ត

ល្អដោយចិត្ត ។

## អបរទុច្ចរិតសូត្រទី ៥

[ ១៤៥ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង តិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយតិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកព្រះសទ្ធម្ម ១ តាំងនៅក្នុងអសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយ ពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកអសទ្ធម្ម ១ តាំងនៅក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អ ។

## អបរកាយទុច្ចរិតសូត្រទី ៦

[ ១៤៦ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ ដោយកាយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយកាយ ។បេ។

## អបរវចីទុច្ចរិតសូត្រទី ៧

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ដោយវាចា ។បេ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥

យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយវាចា ។បេ។

# អបរមនោទុច្ចរិតសូត្រទី ៨

[ ១៤៨ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ដោយចិត្ត ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯងតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយពិចារណាហើយ តិះដៀលបាន ១ កិត្តិសព្ទដ៏អាក្រក់ខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកព្រះសទ្ធម្ម ១ តាំងនៅក្នុងអសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តអាក្រក់ដោយចិត្ត ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយចិត្ត ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺខ្លួនឯង មិនតិះដៀលខ្លួនឯងបាន ១ អ្នកប្រាជ្ញទាំងឡាយ ពិចារណាហើយសរសើរ ១ កិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១ ឃ្លៀងឃ្លាតចាកអសទ្ធម្ម ១ តាំងនៅក្នុងព្រះសទ្ធម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងមានដល់បុគ្គលប្រព្រឹត្តល្អដោយចិត្ត ។

# អដ្ឋកថា

# ទុច្ចរិតវគ្គទី ៥

## ទុច្ចរិតសូត្រជាដើម

[ ១៤១-១៤៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងទុច្ចរិតសូត្រទី ១ នៃទុច្ចរិតវគ្គទី ៥ ដូចតទៅនេះ បទថា* **ទុច្ចរិតេ** *នេះ លោកពោលទុកមិនចែកប្រភេទ ។ បទថា* **កាយទុច្ចរិតេ** *ជាដើម លោកពោលចែកប្រភេទ មានកាយទ្វារជាដើម ។ បទថា* **សទ្ធម្មា** *បានដល់ ចាកធម៌ គឺកុសលកម្មបថ ១០ ។ បទថា* **អសទ្ធម្មេ** *បានដល់ ក្នុងអសទ្ធម្ម គឺអកុសលកម្មបថ ។*

**អដ្ឋកថា ទុច្ចរិតសូត្រជាដើម ចប់**

# សុត្តន្តបិដក

## សីវថិកាសូត្រទី ៩

[ ១៤៩ ] *ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងព្រៃស្មសាន ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាទីមិនស្អាត ១ មានក្លិនស្អុយ ១ ប្រកបដោយភ័យ ១ ជាទីនៅរបស់ពួកអមនុស្សកាច ១ ជាទីទ្រហោយំរបស់ជនច្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងព្រៃ*

ស្មសាន ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងបុគ្គលដូចជាព្រៃស្មសាន ក៏ដូច្នោះដែរ ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាត នេះតថាគតហៅបុគ្គលនោះថា មិនស្អាត ម្នាលភិក្ខុទាំងឡាយ ដូចជាព្រៃស្មសាននោះ ជាទីមិនស្អាត ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ កាលបើបុគ្គលនោះ ប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតហើយ កិត្តិសព្ទដ៏អាក្រក់ ក៏ខ្ចរខ្ចាយទៅ នេះតថាគតហៅបុគ្គលនោះថា មានក្លិនស្អុយ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីមានក្លិនស្អុយ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ ពួកសព្រហ្មចារីដែលមានសីលជាទីស្រឡាញ់ តែងចៀសវាងបុគ្គល អ្នកប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតនោះអំពីចម្ងាយ នេះតថាគតហៅបុគ្គលនោះថា ប្រកបដោយភ័យ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីប្រកបដោយភ័យ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ បុគ្គលនោះប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាត តែងនៅរួមជាមួយនឹងពួកបុគ្គលស្មើគ្នា នេះតថាគតហៅបុគ្គលនោះថា ជាលំនៅនៃអមនុស្សសាហាវ ម្នាលភិក្ខុ

*ទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីនៅរបស់អមនុស្សសាហាវ ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះមានឧបមេយ្យដូច្នោះ ១ ។ ពួកសព្រហ្មចារីដែលមានសីលជាទីស្រឡាញ់ បានឃើញបុគ្គលអ្នកប្រកបដោយកាយកម្មមិនស្អាត ប្រកបដោយវចីកម្មមិនស្អាត ប្រកបដោយមនោកម្មមិនស្អាតនោះ តែងតិះដៀលថា ឱហ្ន៎ ពួកយើងវេទនា ព្រោះតែនៅរួបរួមជាមួយនឹងពួកបុគ្គលយ៉ាងនេះ នេះតថាគតហៅបុគ្គលនោះថា ជាទីទ្រហោយំ ម្នាលភិក្ខុទាំងឡាយ ដូចព្រៃស្មសាននោះ ជាទីទ្រហោយំរបស់ជនច្រើន ម្នាលភិក្ខុទាំងឡាយ តថាគតថា បុគ្គលនេះ មានឧបមេយ្យដូច្នោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមាន ក្នុងបុគ្គលមានឧបមេយ្យដូចព្រៃស្មសាន ។*

# អដ្ឋកថា

## សីវថិកាសូត្រ

*[ ១៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីវថិកាសូត្រទី ៩ ដូច្នេះ បទថា* **សីវថិកាយ** *គឺក្នុងព្រៃខ្មោច ។ បទថា* **អារោទនា** *គឺទីទ្រហោយំ ។ បទថា* **អសុចិនា** *គឺគួរខ្ពើម ។*

**អដ្ឋកថា សីវថិកាសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## បុគ្គលប្បសាទសូត្រទី ១០

[ ១៥០ ] ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមាន ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។ ទោស ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រះថ្លា ក្នុងបុគ្គលណា បុគ្គលនោះ ត្រូវអាបត្តិ តាមដែលសង្ឃលើកវត្តនោះ បុគ្គលអ្នកជ្រះថ្លានោះ ត្រិះរិះយ៉ាងនេះថា បុគ្គលណា ជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះត្រូវសង្ឃលើកវត្តហើយដូច្នេះ ក៏ច្រើនតែមិនជ្រះថ្លា ក្នុងពួកភិក្ខុ កាលមិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុហើយ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនស្តាប់ព្រះសទ្ធម្ម កាលមិនស្តាប់ព្រះសទ្ធម្មហើយ រមែងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ១ ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លា ក្នុងបុគ្គលណា បុគ្គលនោះ ត្រូវអាបត្តិ តាមដែលសង្ឃ ឲ្យបុគ្គលនោះអង្គុយក្នុងទីបំផុតនោះ បុគ្គលអ្នកជ្រះថ្លានោះ ត្រិះរិះយ៉ាងនេះថា បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះត្រូវសង្ឃឲ្យអង្គុយ ក្នុងទីចុងគេបំផុត ដូច្នេះ ក៏មិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុ កាលមិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុហើយ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលបើមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលបើមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏សាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ២ ក្នុងសេចក្តីជ្រះថ្លា ចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ

មួយទៀត បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះ ក៏ចៀសចេញទៅកាន់ទិស ។បេ។ បុគ្គលនោះ ក៏សឹកទៅ ។បេ។ បុគ្គលនោះ ក៏ស្លាប់ទៅ បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីស្រឡាញ់ពេញចិត្តរបស់អញ បុគ្គលនោះស្លាប់ទៅហើយ ដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលបើមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំង-ឡាយ នេះជាទោសទី ៥ ក្នុងសេចក្តីជ្រះថ្លា ចំពោះបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាង នេះ រមែងមានក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។

ទុច្ចរិតវគ្គទី ៥ ចប់

## ឧទ្ទាននៃទុច្ចរិតវគ្គនោះ គឺ

និយាយអំពីទោស និងអានិសង្សនៃទុច្ចរិត និងសុចរិត
១ អំពីកាយទុច្ចរិត និងកាយសុចរិត ១ អំពីវចីទុច្ចរិត
និងវចីសុចរិត ១ អំពីមនោទុច្ចរិត និងមនោសុចរិត ១
អំពីទុច្ចរិត និងសុចរិត ៤ លើកដទៃទៀតជាពីរដង
អំពីព្រៃស្មសាន ១ អំពីសេចក្តីជ្រះថ្លា ចំពោះបុគ្គល
១ ។

បណ្ណាសកទី ៥ ចប់

# អដ្ឋកថា

## បុគ្គលប្បសាទសូត្រ

[ ១៥០ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបុគ្គលបសាទសូត្រទី ១០ ដូច្នេះ បទថា* **បុគ្គលប្បសាទេ** *បានដល់ ក្នុងការជ្រះថ្លា ដែលកើតឡើងក្នុងបុគ្គលណាម្នាក់ ។ បទថា* **អន្តេ និសីទាបេតិ** *បានដល់ ឲ្យលោកគង់ចុងអាសនៈរបស់ពួកភិក្ខុ ។ បទដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។l៚*

**អដ្ឋកថាបុគ្គលប្បសាទសូត្រទី ១០ ចប់**

**ទុច្ចរិតវគ្គទី ៥ ចប់**

**បញ្ចមបណ្ណាសក ចប់**

# សុត្តន្តបិដក

## ពួកសូត្រមិនសង្គ្រោះក្នុងវគ្គ

[ ១៥១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរញុំាងកុលបុត្តឲ្យឧបសម្បទាបាន ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធ ជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធ ជាអសេក្ខៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង គួរញុំាងកុលបុត្តឲ្យឧបសម្បទាបាន ។

[ ១៥២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរឲ្យនិស្ស័យបាន ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ។បេ។ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ ៥ យ៉ាងនេះឯង ។បេ។

[ ១៥៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង គួរឲ្យសាមណេរបម្រើបាន ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ។បេ។ ប្រកបដោយវិមុត្តិញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ ៥ យ៉ាងនេះឯង ។បេ។

[ ១៥៤ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់នេះមាន ៥ យ៉ាង ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល

១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីកំណាញ់ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីកំណាញ់ ៥ យ៉ាងនេះ សេចក្តីកំណាញ់ធម៌នេះ ជាសេចក្តីកំណាញ់ ដែលអ្នកប្រាជ្ញតិះដៀល ។

[ ១៥៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ ផ្តាច់បង់ នូវសេចក្តីកំណាញ់ ៥ យ៉ាង ។ សេចក្តីកំណាញ់ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ ផ្តាច់បង់ នូវសេចក្តីកំណាញ់អាវាស ១ នូវសេចក្តីកំណាញ់ត្រកូល ១ ... នូវសេចក្តីកំណាញ់លាភ ១ ... នូវសេចក្តីកំណាញ់គុណ ១ ប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីលះបង់ផ្តាច់បង់នូវសេចក្តីកំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រព្រឹត្តព្រហ្មចរិយៈដើម្បីលះបង់ ផ្តាច់បង់នូវសេចក្តីកំណាញ់ទាំង ៥ យ៉ាងនេះឯង ។

[ ១៥៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ៥ យ៉ាងនេះ មិនគួរដើម្បីបានបឋមជ្ឈានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះ គួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៥ យ៉ាងនេះ គួរដើម្បីបាន បឋមជ្ឈាន ។

[ ១៥៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិន គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវទុតិយជ្ឈាន ... នូវតតិយជ្ឈាន ... នូវចតុត្ថជ្ឈាន ... នូវសោតាបត្តិផល ... នូវសកទាគាមិផល ... នូវអនាគាមិផល ... នូវអរហត្ត ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់ លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល មិនលះបង់ធម៌ ៥ យ៉ាងនេះឯង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាង គួរដើម្បីធ្វើឲ្យ ជាក់ច្បាស់ នូវអរហត្តបាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ កំណាញ់ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីធ្វើឲ្យជាក់ ច្បាស់នូវអរហត្តបាន ។

[ ១៥៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិន គួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្ស អកតញ្ញូអកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង នេះឯង មិនគួរដើម្បីបានបឋមជ្ឈានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល

លះបង់ធម៌ ៥ យ៉ាង គួរដើម្បីបានបឋមជ្ឈាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូអកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីបានបឋមជ្ឈាន ។

[ ១៥៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទុតិយជ្ឈាន ... នូវតតិយជ្ឈាន ... នូវចតុត្ថជ្ឈាន ... នូវសោតាបត្តិផល ... នូវសកទាគាមិផល ... នូវអនាគាមិផល ... នូវអរហត្តឡើយ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូអកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៥ យ៉ាងនេះ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ កំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់គុណ ១ ជាមនុស្សអកតញ្ញូ អកតវេទី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៥ យ៉ាងនេះឯង គួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្តបាន ។

[ ១៦០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺ លុះក្នុងឆន្ទាគតិ ១ លុះក្នុងទោសាគតិ ១ លុះក្នុងមោហាគតិ ១ លុះក្នុង

ភយាគតិ ១ មិនដឹងកត្តដែលខ្លួនគួរសម្តែង និងមិនគួរសម្តែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃគួរសន្មតឲ្យជាភត្តុទ្ទេសកៈបាន ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវភត្តដែលខ្លួនគួរសម្តែង និងមិនគួរសម្តែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង សង្ឃគួរសន្មតឲ្យជាភត្តុទ្ទេសកៈបាន ។

[ ១៦១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាភត្តុទ្ទេសកៈឡើយ បើសន្មត ក៏មិនគួរប្រើ ។បេ។ សន្មតហើយ គួរប្រើ ។បេ។ បណ្ឌិតគប្បីដឹងថាជាពាល ។បេ។ បណ្ឌិតគប្បីដឹងថាជាអ្នកប្រាជ្ញ ។បេ។ រមែងរក្សាខ្លួន ដែលជីករម្លើងគុណចោល ។បេ។ រក្សាខ្លួនដូចជាដើមឈើ ដែលមិនជីករម្លើងគុណចោល ។បេ។ រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។បេ។ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។បេ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវភត្តដែលខ្លួនគួរសម្តែង និងមិនគួរសម្តែង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាភត្តុទ្ទេសកៈ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំយកទៅដាក់ ។

[ ១៦២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៥ យ៉ាង សង្ឃមិនគួរសន្មតឲ្យជាសេនាសនបញ្ញាបកៈ ... មិនដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង និងមិនគួរចាត់ចែង ... សង្ឃគួរសន្មតឲ្យជាសេនាសនបញ្ញាបកៈ ... ដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង និងមិនគួរចាត់ចែង ... សង្ឃមិនគួរសន្មតឲ្យជាសេនាសនគ្គាហាបកៈ ... មិនដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង និងមិនគួរចាត់ចែង ... សង្ឃគួរសន្មតឲ្យជាសេនាសនគ្គាហាបកៈ ... ដឹងនូវសេនាសនៈដែលខ្លួនគួរចាត់ចែង និងមិនគួរចាត់ចែង ... សង្ឃមិនគួរសន្មតឲ្យជាកណ្ឌាគារិកៈ ... មិនដឹងនូវទ្រព្យដែលខ្លួនគួររក្សាទុក និងមិនគួររក្សាទុក ... សង្ឃគួរសន្មតឲ្យជាកណ្ឌាគារិកៈ ... ដឹងនូវទ្រព្យដែលខ្លួនគួររក្សាទុក និងមិនគួររក្សាទុក ... សង្ឃមិនគួរសន្មតឲ្យជាចីវរប្បដិគ្គាហកៈ ... មិនដឹងចីវរដែលខ្លួនគួរទទួល និងមិនគួរទទួល ... សង្ឃគួរសន្មតឲ្យជាចីវរប្បដិគ្គាហកៈ ... ដឹងនូវចីវរដែលខ្លួនគួរទទួល និងមិនគួរទទួល ... សង្ឃមិនគួរសន្មតឲ្យជាចីវរភាជកៈ ... មិនដឹងនូវចីវរដែលខ្លួនគួរចែក និងមិនគួរចែក ... សង្ឃគួរសន្មតឲ្យជាចីវរភាជកៈ ... ដឹងនូវចីវរដែលខ្លួនគួរចែក និងមិនគួរចែក ... សង្ឃមិនគួរសន្មតឲ្យជាយាគុភាជកៈ ( អ្នកចែកបបរ ) ... សង្ឃគួរសន្មតឲ្យជាយាគុភាជកៈ ... សង្ឃមិនគួរសន្មតឲ្យជាផលភាជកៈ ( អ្នកចែកផ្លែឈើ ) ... សង្ឃគួរសន្មតឲ្យជាផលភាជកៈ ... សង្ឃមិនគួរសន្មតឲ្យជាខជ្ជកភាជកៈ ( អ្នកចែកបង្អែម ) ... មិនដឹងបង្អែមដែលខ្លួនគួរចែក និង

មិនគួរបែក ... សង្ឃគួរសន្មតឲ្យជាខជ្ជកភាជកៈ ... ដឹងបង្អែមដែលខ្លួនគួរបែក និងមិនគួរបែក ... សង្ឃមិនគួរសន្មតឲ្យជាអប្បមត្តកវិស្សជ្ជកៈ ( ចំណាយរបស់បន្តិចបន្តួច ) ... មិនដឹងរបស់បន្តិចបន្តួចដែលខ្លួនគួរចំណាយ និងមិនគួរចំណាយ ... សង្ឃគួរសន្មតឲ្យជាអប្បមត្តកវិស្សជ្ជកៈ ... ដឹងនូវរបស់បន្តិចបន្តួច ដែលខ្លួនគួរចំណាយ និងមិនគួរចំណាយ ... សង្ឃមិនគួរសន្មតឲ្យជាសាដិយគ្គាហាបកៈ ( អ្នកប្រើគេឲ្យកាន់យកនូវសំពត់ងូតទឹក ) ... មិនដឹងសំពត់ងូតទឹក ដែលខ្លួនគួរកាន់យក និងមិនគួរកាន់យក ... សង្ឃគួរសន្មតឲ្យជាសាដិយគ្គាហាបកៈ ... ដឹងនូវសំពត់ងូតទឹក ដែលខ្លួនគួរកាន់យក និងមិនគួរកាន់យក ... សង្ឃមិនគួរសន្មតឲ្យជាបត្តគ្គាហាបកៈ ( អ្នកប្រើគេឲ្យកាន់យកបាត្រ ) ... មិនដឹងនូវបាត្រ ដែលខ្លួនគួរកាន់យក និងមិនគួរកាន់យក ... សង្ឃគួរសន្មតឲ្យជាបត្តគ្គាហាបកៈ ... ដឹងនូវបាត្រ ដែលខ្លួនគួរកាន់យក និងមិនគួរកាន់យក ... សង្ឃមិនគួរសន្មតឲ្យជាអារាមិកបេសកៈ ( អ្នកប្រើញោមវត្ត ) ... មិនដឹងញោមវត្ត ដែលខ្លួនគួរប្រើ និងមិនគួរប្រើ ... សង្ឃគួរសន្មតឲ្យជាអារាមិកបេសកៈ ... ដឹងញោមវត្ត ដែលខ្លួនគួរប្រើ និងមិនគួរប្រើ ... សង្ឃមិនគួរសន្មតឲ្យជាសាមណេរបេសកៈ ( អ្នកប្រើសាមណេរ ) ... សង្ឃគួរសន្មតឲ្យជាសាមណេរបេសកៈ ... បើបានជាសន្មតហើយ មិនគួរប្រើឡើយ បើបានជាសន្មតរួចហើយ គួរប្រើ ... បណ្ឌិតគប្បីជ្រាបថាជាពាល ... បណ្ឌិតគប្បីជ្រាបថាជាអ្នកប្រាជ្ញ ... រមែងរក្សាខ្លួន ដែលគាស់ជីករម្លើងគុណ

ចោល ... រមែងរក្សាខ្លួនដែលមិនគាស់រម្លើងគុណចោល ... រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ... មិនដឹងសាមណេរដែលគួរប្រើ និងមិនគួរប្រើ ... រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺភិក្ខុមិនលុះក្នុងឆន្ទាគតិ ១ មិនលុះក្នុងទោសាគតិ ១ មិនលុះក្នុងមោហាគតិ ១ មិនលុះក្នុងភយាគតិ ១ ដឹងនូវសាមណេរ ដែលគួរប្រើ និងមិនគួរប្រើ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រើសាមណេរប្រកបដោយធម៌ ៥ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[ ១៦៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តធម៌មិនប្រសើរ ១ និយាយកុហក ១ ផឹកទឹកស្រវឹង គឺសុរានិង មេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកវៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តធម៌មិនប្រសើរ ១ វៀរចាកការនិយាយកុហក ១ វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទី

តាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ១ ។

[ ១៦៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនី ... សិក្ខមានា ... សាមណេរ ... សាមណេរី ... ឧបាសក ... ឧបាសិកា ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ១ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ និយាយកុហក ១ ផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកា ប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកវៀរបាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកការផឹកទឹកស្រវឹង គឺសុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសិកាប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

[ ១៦៥ ] ម្នាលភិក្ខុទាំងឡាយ អាជីវកប្រកបដោយធម៌ ៥ យ៉ាងរមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺ

អ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ១ និយាយកុហក ១ ផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំងឡាយ អាជីវកប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

[ ១៦៦ ] ម្នាលភិក្ខុទាំងឡាយ និគ្រន្ថ ... មុណ្ឌសាវក ... ជដិលកៈ ... បរិព្វាជកៈ ... មាគណ្ឌិកៈ ... តេទណ្ឌិកៈ ... អារុទ្ធកៈ ... គោតមកៈ ... ទេវធម្មិកៈ ប្រកបដោយធម៌ ៥ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺជាអ្នកសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តធម៌មិនប្រសើរ ១ និយាយកុហក ១ ផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ទេវធម្មិកៈប្រកបដោយធម៌ ៥ យ៉ាងនេះ រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

[ ១៦៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសម្គាល់ឃើញថាមិនស្អាត ១ សម្គាល់ឃើញក្នុងសេចក្តីស្លាប់ ១ សម្គាល់ឃើញថាមានទោស ១ សម្គាល់ឃើញថាគួរខ្ពើមក្នុងអាហារ ១ សម្គាល់ឃើញថាមិនគួរត្រេកអរក្នុងលោកទាំងពួង ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១៦៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសម្គាល់ឃើញថាមិនទៀង ១ សម្គាល់ឃើញថាជាទុក្ខក្នុងរបស់មិនទៀង ១ សម្គាល់ឃើញថាមិនមែនរបស់ខ្លួនក្នុងរបស់ជាទុក្ខ ១ សម្គាល់ឃើញក្នុងធម៌ជាគ្រឿងលះ ១ សម្គាល់ឃើញក្នុងធម៌ជាគ្រឿងនឿយណាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១៦៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១៧០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៥ យ៉ាង គឺអ្វីខ្លះ ។ គឺសទ្ធាពល ១ វីរិយពល ១ សតិពល ១ សមាធិពល ១ បញ្ញាពល ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាងនេះឯង គួរចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[ ១៧១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៥ យ៉ាង គួរចម្រើន ដើម្បីកំណត់ដឹងនូវរាគៈ ។បេ។ ដើម្បីអស់ទៅ ដើម្បីលះ ដើម្បីក្ស័យ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរម្ងត់ ដើម្បីលះបង់ ដើម្បីរលាស់នូវរាគៈ ។បេ។ ធម៌ ៥ យ៉ាងនេះ គួរចម្រើន ដើម្បីដឹងច្បាស់នូវទោសៈ មោហៈ កោធៈ ឧបនាហៈ

( ចងក្រោធទុក ) មក្ខៈ ( រមិលគុណ ) បលាសៈ ( លើកខ្លួនផ្ទឹម ) ឥស្សា ( ឫស្យា ) មច្ឆរិយៈ ( កំណាញ់ ) មាយា ( បិទបាំងទោស ) សាឋេយ្យៈ ( អួតអាង ) ថម្ភៈ ( មុខរឹង ) សារម្ភៈ ( ប្រណាំងវាស្នា ) មានះ ( ប្រកាន់ខ្លួន ) អតិមានះ ( មើលងាយគេ ) មទៈ ( ស្រវឹង ) បមាទៈ ( ប្រាសចាកសតិ ) ។បេ។ ដើម្បីកំណត់ដឹង ដើម្បីអស់ទៅ ដើម្បីលះ ដើម្បីក្ស័យ ដើម្បីសូន្យទៅ ដើម្បីនឿយណាយ ដើម្បីរម្ងត់ ដើម្បីលះបង់ ដើម្បីរលាស់នូវទោសៈ ។

## បញ្ចកនិបាត ចប់

# អដ្ឋកថា

## សូត្រដែលមិនបានសង្គ្រោះចូលក្នុងវគ្គ

[ ១៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ ជាដើមនៃវគ្គទី ៦ ដូច្នេះ បទថា **ឧបសម្បាទេតព្វំ** បានដល់ ជាឧបជ្ឈាយ៍គួរឲ្យឧបសម្បទា ។

[ ១៥២ ] ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **និស្សយោ ទាតព្វោ** បានដល់ ជាអាចារ្យគប្បីឲ្យនិស្ស័យបាន ។

[ ១៥៣ ] ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សាមណេរោ ឧបដ្ឋាបេតព្វោ** បានដល់ ជាឧបជ្ឈាយ៍ គប្បីឲ្យសាមណេរឧបដ្ឋាកបាន ។ ក្នុងសូត្រទី ៣ នេះ ទ្រង់ត្រាស់ដោយសំដៅដល់ព្រះខីណាស្រព ក្នុងបឋមពោធិកាលប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងសូត្រទី ៤ ជាដើម មានអត្ថងាយយល់ទាំងអស់ហើយ ដោយពណ៌នាតាមលំដាប់បទ ។ រឿងវិនិច្ឆ័យភត្តុទ្ទេសកៈជាដើម គប្បីជ្រាបដោយន័យនេះ លោកពោលហើយក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះសមន្តប្បាសាទិកានោះឯង ។

[ ១៦១ ] បទថា **សម្មតោ ច បេសេតព្វោ** បានដល់ ភិក្ខុបានទទួលសន្មតតាមប្រក្រតី ក៏មិនគួរបញ្ជូនទៅដោយពាក្យថា លោកចូរទៅ ចូរសម្តែងភត្តទាំងឡាយ ដូច្នេះ ។

[ ១៦២ ] បទថា **សាដិយគ្គាហាបកោ** បានដល់ អ្នកចែកសំពត់ងូតទឹកភ្លៀង ។ បទថា **បត្តគាហាបកោ** បានដល់ អ្នកចែកបាត្រ ដែលលោកពោលទុកក្នុងសេចក្តីនេះថា បាត្រណាជាបាត្រចុងក្រោយរបស់ភិក្ខុ-

បរិស័ទនោះ បាត្រនោះ គួរឲ្យដល់ភិក្ខុនោះ ។

[ ១៦៥ ] បទថា **អាជីវកោ** បានដល់ អ្នកបួសអាក្រាត ។

[ ១៦៦ ] បទថា **និគណ្ឋោ** បានដល់ បិទកាយកំណាត់ខាងលើ ។ បទថា **មុណ្ឌសាវកោ** បានដល់ សាវ័ករបស់និគ្រន្ថ ។ បទថា **ជដិលកោ** គឺតាបស ។ បទថា **បរិព្វាជកោ** គឺបរិព្វាជកដែលស្លៀកសំពត់ ។ អ្នកបួសមានមាគណ្ឌិកជាដើម ក៏ចាត់ជាតិរ្ថិយដូចគ្នា ។ ចំណែកសុក្កបក្ខ មិនបានកាន់យក ព្រោះអ្នកបួសទាំងនោះ មិនមានការធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយ ។ បទដ៏សេស ក្នុងទីគ្រប់អន្លើ មានអត្ថងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា អង្គុត្តរនិកាយ**
**ឈ្មោះមនោរថបូរណី**
**បញ្ចកនិបាត ចប់**

# សុត្តន្តបិដក

# អង្គុត្តរនិកាយ ឆក្កនិបាត

# សត្តមភាគ

*សូមនមស្ការចំពោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ*

## បឋមបណ្ណាសក

## អាហុនេយ្យវគ្គ

### បឋមអាហុនេយ្យសូត្រទី ១

[ ១ ] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយភ្នែក ជាអ្នកមិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិ-*

សម្បជញ្ញៈ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ជាអ្នកមិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយកន្តើយ ប្រកបដោយសតិ-សម្បជញ្ញៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលនាំមកបូជា គួរទទួលវត្ថុ ដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តប្រសើររបស់សត្វលោក ។ លុះព្រះដ៏មានព្រះភាគ សម្តែងសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតនៃព្រះដ៏មានព្រះភាគ ។

# អដ្ឋកថា
# អង្គុត្តរនិកាយ ឈ្មោះ មនោរថបូរណី
# ឆក្កនិបាត
# បឋមបណ្ណាសក

## អាហុនេយ្យវគ្គទី ១

### បឋមអាហុនេយ្យសូត្រ

[ ១ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាហុនេយ្យសូត្រទី ១ នៃឆក្កនិបាត ដូចតទៅនេះ បទថា* **ឥធ ភិក្ខវេ ភិក្ខុ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ។ បទថា* **នេវ សុមនោ ហោតិ ន ទុម្មនោ** *សេចក្តីថា រមែងជាបុគ្គលមិនត្រេកអរក្នុងឥដ្ឋារម្មណ៍ ដោយសោមនស្សដែលសហគតៈដោយរាគៈ ឬរមែងជាបុគ្គលមិនខូចចិត្ត ព្រោះអនិដ្ឋារម្មណ៍ដោយទោមនស្សដែលសហគតៈដោយទោសៈ ។ បទថា* **ឧបេក្ខកោ វិហរតិ សតោ សម្បជានោ** *សេចក្តីថា មិនដល់នូវភាពជាបុគ្គលព្រងើយដោយឧបេក្ខាដែលមិនមានញាណ ដោយមិនពិចារណាក្នុងមជ្ឈត្តារម្មណ៍ ឈ្មោះថា ជាបុគ្គលមានសតិសម្បជញ្ញៈ មានចិត្តជាកណ្តាលក្នុងអារម្មណ៍ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ វិហារធម៌ជានិច្ចរបស់ព្រះខីណាស្រពហើយ ។*

**អដ្ឋកថា បឋមអាហុនេយ្យសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ទុតិយអាហុនេយ្យសូត្រទី ២

[ ២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងបាននូវការតាក់តែង ឫទ្ធិច្រើនប្រការបាន គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាម្នាក់ក៏បាន ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ ( ទម្លុះ ) ទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ ឥតទើសទាល់ ដូចដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការមុជងើបក្នុងផែនដី ដូចមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក ឥតបែកធ្លាយទឹក ដូចជាដើរលើផែនដី ក៏បានអណ្តែតទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន ចាប់ស្ទាបអង្អែលព្រះចន្ទ និងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះដោយដៃក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយរហូតដល់ព្រហ្មលោកក៏បាន ១ ។ ភិក្ខុមានសោតធាតុជាទិព្វដ៏បរិសុទ្ធ កន្លងសោតធាតុរបស់មនុស្សធម្មតា រមែងស្តាប់សំឡេង ២ ប្រការ គឺសំឡេងទិព្វ និងសំឡេងមនុស្ស ក្នុងទីឆ្ងាយក៏បាន ជិតក៏បាន ១ ។ ភិក្ខុរមែងកំណត់ដឹងច្បាស់នូវចិត្តរបស់សត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ...

ចិត្តដែលប្រកបដោយទោសៈក្តី ... ចិត្តដែលប្រាសចាកទោសៈក្តី ... ចិត្តដែលប្រកបដោយមោហៈក្តី ... ចិត្តដែលប្រាសចាកមោហៈក្តី... ចិត្តដែលរួញរាក្តី... ចិត្តដែលរាយមាយក្តី... ចិត្តដែលជាមហគ្គតៈក្តី... ចិត្តដែលមិនមែនជាមហគ្គតៈក្តី... ចិត្តដែលជាសឧត្តរៈក្តី... ចិត្តដែលជាអនុត្តរៈក្តី... ចិត្តដែលតាំងមាំក្តី... ចិត្តដែលមិនតាំងមាំក្តី... ចិត្តដែលរួចចាកកិលេសក្តី... ចិត្តមិនរួចចាកកិលេសក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចចាកកិលេស ១ ។ ភិក្ខុរឭកឃើញនូវជាតិដែលខ្លួនធ្លាប់នៅអាស្រ័យ ក្នុងកាលមុនជាច្រើនជាតិ គឺរឭកឃើញបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បានខ្លះ រឭកឃើញបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា អញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអញច្យុតចាកភពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលអញបានទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ លុះអញច្យុតចាកភពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុរឭកឃើញនូវជាតិដែលខ្លួនធ្លាប់នៅអាស្រ័យក្នុងកាលមុនបានច្រើនជាតិ ព្រមទាំងអាការ ទាំងឧទ្ទេស ដោយប្រការដូច្នេះ ១ ។ ភិក្ខុមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្ស

ធម្មតា ឃើញនូវសត្វទាំងឡាយដែលកំពុងច្យុត និងកំពុងកើត មានសភាពថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ មានគតិល្អ និងគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវអំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ចំណែកឯសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវអំពើជាសម្មា-ទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិ សួគ៌ទេវលោក ភិក្ខុមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយដែលច្យុត ដែលចាប់បដិសន្ធិ មានសភាពថោកទាប និងឧត្តម មានសម្បុរល្អ និងសម្បុរអាក្រក់ មានគតិល្អ និងគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនដោយប្រការដូច្នេះ ១ ។ ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

# អដ្ឋកថា

## ទុតិយអាហុនេយ្យសូត្រ

[ ២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអាហុនេយ្យសូត្រទី ២ ដូចតទៅនេះ បទថា **អនេកវិហិតំ ឥទ្ធិវិធំ** ដូច្នេះ ខ្ញុំបានពោលហើយ ក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា **អាសវានំ ខយា អនាសវំ** សេចក្តីថា ឈ្មោះថា មិនមានអាសវៈ ព្រោះអាសវៈទាំងឡាយអស់ទៅ មិនមែនព្រោះការមិនមាននៃចក្ខុវិញ្ញាណជាដើមឡើយ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់អភិញ្ញាសម្រាប់ព្រះខីណាស្រពតាមលំដាប់ ។៚

**អដ្ឋកថា ទុតិយអាហុនេយ្យសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឥន្ទ្រិយសូត្រទី ៣

[ ៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុប្រកបដោយសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែល

មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេរៀបចំទទួលភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

## ពលសូត្រទី ៤

[ ៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺភិក្ខុប្រកបដោយសទ្ធាពល ១ វីរិយពល ១ សតិពល ១ សមាធិពល ១ បញ្ញាពល ១ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## ឥន្ទ្រិយសូត្រទី ៣ ជាដើម

[ ៣-៤ ] ក្នុងឥន្ទ្រិយសូត្រទី ៣ និងពលសូត្រទី ៤ ព្រះមានព្រះភាគត្រាស់ព្រះទីណាស្រេចតែម្យ៉ាង ។

អដ្ឋកថា ឥន្ទ្រិយសូត្រទី ៣ ជាដើមចប់

# សុត្តន្តបិដក

## បឋមអាជានិយសូត្រទី ៥

[ ៥ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វចេះអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់រស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយសម្បុរ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាងនេះឯង ទើបជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថា ជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មាន

ឧបមេយ្យដូចភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ធម៌ ៦ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះអត់ធន់នឹងរូប ១ អន់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## បឋមអាជានិយសូត្រ

[ ៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអាជានិយសូត្រទី ៥ ដូចតទៅនេះ បទថា **អង្គេហិ** បានដល់ ដោយអង្គនៃគុណទាំងឡាយ ។ បទថា **ខមោ** ប្រែថា អត់សង្កត់ ។ បទថា **រូបានំ** បានដល់ រូបារម្មណ៍ទាំងឡាយ ។ បទថា **វណ្ណសម្បន្នោ** បានដល់ សម្បូរដោយវណ្ណៈនៃសរីរៈ ។៚

### អដ្ឋកថា បឋមអាជានិយសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយអាជានិយសូត្រទី ៦

[ ៦ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ក្នុងលោកនេះ ជាសត្វចេះអត់ធន់នឹងរូប ១ អន់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយកម្លាំង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាងនេះឯង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ អន់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## ទុតិយអាជានិយសូត្រ

[ ៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអាជានិយសូត្រទី ៦ ដូចតទៅនេះ បទថា **ពលសម្បន្នោ** បានដល់ សម្បូរដោយកម្លាំងកាយ ។

**អដ្ឋកថាទុតិយអាជានិយសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## តតិយអាជានិយសូត្រទី ៧

[ ៧ ] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើរ របស់ស្តេច ក្នុងលោកនេះ ជាសត្វចេះអត់ធន់នឹងរូប ១ អត់ធន់នឹងសំឡេង ១ អត់ធន់នឹងក្លិន ១ អត់ធន់នឹងរស ១ អត់ធន់នឹងការពាល់ត្រូវ ១ បរិបូណ៌ដោយសម្ផុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ប្រសើររបស់ស្តេច ប្រកបដោយអង្គ ៦ យ៉ាងនេះឯង ជាសត្វគួរដល់ព្រះរាជា គួរជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ មាន

ឧបមេយ្យដូចភិក្ខុ ប្រកបដោយធម៌ ៦ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ប្រកបដោយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកអត់ធន់នឹងរូប ១ ។បេ។ អត់ធន់នឹងធម្មារម្មណ៍ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## តតិយអាជានិយសូត្រ

[ ៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអាជានិយសូត្រទី ៧ ដូចតទៅនេះ បទថា **ជវសម្បន្នោ** បានដល់ សម្បូរដោយសម្ទុះជើង ។

**អដ្ឋកថា តតិយអាជានិយសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## អនុត្តរិយសូត្រទី ៨

[ ៨ ] ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ ( ធម្មជាតដ៏ប្រសើរ ) នេះ មាន ៦ យ៉ាង ។ អនុត្តរិយៈ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺទស្សនានុត្តរិយៈ ១ សវនានុត្តរិយៈ ១ លាភានុត្តរិយៈ ១ សិក្ខានុត្តរិយៈ ១ បារិចរិយានុត្តរិយៈ ១ អនុស្សតានុត្តរិយៈ ១ ។ ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ មាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## អនុត្តរិយសូត្រ

[ ៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុត្តរិយសូត្រទី ៨ ដូចតទៅនេះ បទថា **អនុត្តរិយានិ** សេចក្តីថា ការឃើញជាដើមដែលវៀរចាកវត្ថុដទៃ ដែលក្រៃលែងជាង ឈ្មោះថា **និរុត្តរានិ** ។ បទថា **ទស្សនានុត្តរិយំ** សេចក្តីថា ការឃើញព្រះពុទ្ធជាដើម ជាការឃើញដ៏កំពូលក្នុងការឃើញរូបទាំងឡាយ ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។ អធិប្បាយថា ការឃើញដំរីកែវជាដើម មិនឈ្មោះថាជាទស្សនានុត្តរិយឡើយ ឯការឃើញព្រះទសពលក្តី ភិក្ខុសង្ឃក្តី ដោយអំណាចសេចក្តីស្រឡាញ់ដ៏មាំទាំ ការឃើញនិមិត្តណាមួយ ក្នុងបណ្តាកសិណ និងអសុភនិមិត្តជាដើមក្តី នៃបុគ្គលដែលមានសទ្ធាតាំងមាំ

ហើយ ឈ្មោះថា **ទស្សនានុត្តរិយ** ។ ការស្តាប់កថាពោលអំពីគុណរបស់ស្តេចជាដើម មិនឈ្មោះថា ជាសវនានុត្តរិយៈឡើយ ឯការស្តាប់គុណកថានៃព្រះរតនត្រ័យ ដោយអំណាចនៃសេចក្តីស្រឡាញ់ដ៏មាំទាំក្តី ការស្តាប់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកក្តី នៃបុគ្គលដែលមានសទ្ធាតាំងមាំហើយ ឈ្មោះថា **សវនានុត្តរិយ** ។ ការបានកែវមណីជាដើម មិនជាលាភានុត្តរិយៈឡើយ ឯការបានអរិយទ្រព្យ ៧ ឈ្មោះថា **លាភានុត្តរិយ** ។ ការសិក្សាសិប្បៈ មានសិប្បៈដំរីជាដើម មិនឈ្មោះថា សិក្ខានុត្តរិយៈឡើយ ឯការបំពេញសិក្ខា ៣ ឈ្មោះថា **សិក្ខានុត្តរិយ** ។ ការបម្រើក្សត្រជាដើមមិនឈ្មោះថា ជាបារិចរិយានុត្តរិយៈឡើយ ឯការបម្រើព្រះរតនត្រ័យ ឈ្មោះថា **ចារិចរិយានុត្តរិយ** ។ ការរឭកដល់គុណរបស់ក្សត្រជាដើម មិនឈ្មោះថា ជាអនុស្សតានុត្តរិយៈឡើយ ឯការរឭកដល់គុណព្រះរតនត្រ័យ ឈ្មោះថា **អនុស្សតានុត្តរិយ** ។

អនុត្តរិយៈទាំង ៦ នេះ ព្រះមានព្រះភាគ ត្រាស់ទាំងជាលោកិយ និងលោកុត្តរ ដោយប្រការដូចពណ៌នាមកដូច្នេះ ។ល។

## អដ្ឋកថាអនុត្តរិយសូត្រទី ៨ ចប់

# សុត្តន្តបិដក

## អនុស្សតិសូត្រទី ៩

[ ៩ ] ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន ( ហេតុជាទីតាំងនៃសេចក្តីរឭក ) នេះមាន ៦ យ៉ាង ។ អនុស្សតិដ្ឋាន ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន មាន ៦ យ៉ាងនេះឯង ។

## អដ្ឋកថា

## អនុស្សតិសូត្រ

[ ៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុស្សតិសូត្រទី ៩ ដូចតទៅនេះ បទថា **ពុទ្ធានុស្សតិ** បានដល់ អនុស្សតិ មានពុទ្ធគុណជាអារម្មណ៍ ។ ក្នុងបទទាំងឡាយដ៏សេស ក៏មានន័យនេះដូចគ្នា ៕

**អដ្ឋកថា អនុស្សតិសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## មហានាមសូត្រទី ១០

[ ១០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ។ គ្រានោះ មហានាមសក្កៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីដ៏សមគួរ ។ លុះមហានាមសក្កៈ ប្រថាប់ក្នុងទីសមគួរស្រេចហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវកណាបានសម្រេចអរិយផល ដឹងច្បាស់នូវសាសនា គឺត្រៃសិក្ខាហើយ តើអរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌ដូចម្តេច ។ ថ្វាយព្រះពរមហានាម អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយសាវកនោះ ច្រើនតែនៅដោយវិហារធម៌នេះ ។ បពិត្រមហានាម អរិយសាវកក្នុងសាសនានេះរឭករឿយៗ នូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាករាគាទិក្កិលេស ត្រាស់ដឹងនូវញេយ្យធម៌ដោយប្រពៃចំពោះព្រះអង្គឯង ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ដោយហេតុនេះៗ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករឭករឿយៗ នូវគុណនៃព្រះតថាគត ក្នុងសម័យនោះ អរិយសាវក

នោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តអរិយសាវកនោះ ក៏រមែងជាចិត្តត្រង់បាន ព្រោះប្រារព្ធនូវគុណនៃព្រះតថាគត ។ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ លុះប្រកបដោយសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ក្នុងពួកសត្វ ដែលប្រកបដោយសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្រតៈ គឺវិបស្សនា ចម្រើននូវពុទ្ធានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករឭករឿយៗ នូវគុណព្រះធម៌ថា ព្រះបរិយត្តិ-ធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ចំពោះខ្លួន ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករឭករឿយៗ នូវព្រះធម៌ ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យ

នោះ ចិត្តរបស់ព្រះអរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះធម៌ ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថា ជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចម្រើននូវធម្មានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករឭករឿយៗ នូវគុណនៃព្រះសង្ឃថា ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិល្អហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិត្រង់ហើយ ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងព្រះនិព្វាន ព្រះសង្ឃសាវកនៃព្រះដ៏មានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលបាន ៨ ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ គួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបចំដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករឭករឿយៗ នូវគុណព្រះសង្ឃ ក្នុងសម័យនោះ អរិយសាវក

នោះ ក៏មិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវគុណព្រះសង្ឃ ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្រតៈ គឺវិបស្សនា ចម្រើនសង្ឃានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករឭករឿយៗ នូវសីលរបស់ខ្លួន ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករឭករឿយៗ នូវសីលរបស់ខ្លួន ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយ-សាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវសីល ។ បពិត្រមហានាម លុះអរិយសាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការ

ដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះហៅថា ជាអ្នកដល់ការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងាប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចម្រើននូវសីលានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយទៀត អរិយសាវករឭករឿយៗ នូវចាគៈរបស់ខ្លួនថា ឱហ្ន៎អញពេញជាមានលាភហើយ ឱហ្ន៎ អត្តភាពជាមនុស្សអញពេញជាបានល្អហើយ ព្រោះកាលពួកសត្វមានសេចក្តីកំណាញ់ ជាមន្ទិលកំពុងរួបរឹត អញមានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល ជាអ្នកមានការលះរួចផុតហើយ មានដៃលាងស្អាតហើយ ត្រេកអរក្នុងការលះបង់ ជាបុគ្គលគួរគេសូម ត្រេកអរក្នុងការចែកចាយទាន នៅគ្រប់គ្រងផ្ទះ ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវករឭករឿយៗ នូវចាគៈ ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបានក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ ក៏រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវចាគៈ ។ បពិត្រមហានាម លុះអរិយសាវក មានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្ត

ប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ហើយ ក៏រមែងទទួលនូវសេចក្ដីសុខ កាលបើមានសេចក្ដីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថា ជាអ្នកដល់ការស្ងប់រម្ងាប់ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនបៀតបៀនក្នុងពួកសត្វដែលមានសេចក្ដីបៀតបៀន ជាអ្នកសម្រេចនូវធម្មសោតៈ គឺវិបស្សនា ចម្រើននូវចាគានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម មួយវិញទៀត អរិយសាវកចម្រើននូវទេវតានុស្សតិថា ទេវតាទាំងឡាយ ជាន់ចាតុម្មហារាជិកៈក៏មាន ទេវតាទាំងឡាយជាន់តាវត្តិង្សក៏មាន ទេវតាទាំងឡាយជាន់យាមៈក៏មាន ទេវតាទាំងឡាយជាន់តុសិតក៏មាន ទេវតាទាំងឡាយជាន់និម្មានរតីក៏មាន ទេវតាទាំងឡាយជាន់បរនិម្មិតវសវត្តីក៏មាន ទេវតាទាំងឡាយជាព្រហ្មកាយិកៈក៏មាន ទេវតាទាំងឡាយខ្ពស់លើសជាងនោះក៏មាន ទេវតាទាំងនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សទ្ធារបស់អញ ដែលមានសភាពយ៉ាងនោះក៏មាន ទេវតាទាំងនោះប្រកបដោយសីល មានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សីលរបស់អញ ដែលមានសភាពយ៉ាងនោះក៏មាន ពួកទេវតាទាំងនោះ ប្រកបដោយសុតៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ សុតៈរបស់អញ ដែលមានសភាពយ៉ាងនោះក៏មាន ពួកទេវតាទាំងនោះប្រកបដោយចាគៈមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ ចាគៈរបស់អញ ដែលមានសភាពដូច្នោះក៏មាន ពួកទេវតាទាំងនោះ

ប្រកបដោយបញ្ញាមានសភាពយ៉ាងណា លុះច្យុតចាកលោកនេះហើយ ទៅកើតក្នុងទីនោះ បញ្ញារបស់អញ ដែលមានសភាពដូច្នោះក៏មាន ។ បពិត្រមហានាម ក្នុងសម័យណា អរិយសាវក រឭករឿយៗ នូវសទ្ធា សីល សុតៈ ចាគៈ និងបញ្ញា របស់ខ្លួនផង របស់ទេវតាទាំងនោះផង ក្នុងសម័យនោះ អរិយសាវកនោះ រមែងមិនត្រូវរាគៈរួបរឹតចិត្ត មិនត្រូវទោសៈរួបរឹតចិត្ត មិនត្រូវមោហៈរួបរឹតចិត្តបាន ក្នុងសម័យនោះ ចិត្តរបស់អរិយសាវកនោះ រមែងជាចិត្តត្រង់ ព្រោះប្រារព្ធនូវពួកទេវតា ។ បពិត្រមហានាម លុះអរិយ-សាវកមានចិត្តត្រង់ហើយ រមែងបាននូវការដឹងនូវអត្ថ បាននូវការដឹងនូវធម៌ បាននូវសេចក្តីរីករាយ ដែលប្រកបដោយធម៌ កាលបើមានសេចក្តីរីករាយហើយ បីតិក៏កើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះនាមកាយស្ងប់រម្ងាប់ ក៏រមែងទទួលនូវសេចក្តីសុខ កាលបើមានសេចក្តីសុខហើយ ចិត្តក៏រមែងតម្កល់មាំ ។ បពិត្រមហានាម អរិយសាវកនេះ ហៅថាជាអ្នកដល់នូវការស្ងប់រម្ងាប់ ក្នុងពួកសត្វដែលប្រាសចាកការស្ងប់រម្ងាប់ ជាអ្នកមិនចង្អៀតចង្អល់ ក្នុងពួកសត្វដែលមានសេចក្តីចង្អៀតចង្អល់ ជាអ្នកសម្រេចនូវធម្មសោ្សាតៈ គឺវិបស្សនា ចម្រើននូវទេវតានុស្សតិកម្មដ្ឋាន ។ បពិត្រមហានាម អរិយសាវកណា បានសម្រេចអរិយផល ដឹងច្បាស់នូវសាសនាហើយ អរិយ-សាវកនោះ ច្រើនតែនៅដោយវិហារធម៌នេះ ។

អាហុនេយ្យវគ្គទី ១ ចប់

## ឧទ្ទាននៃអាហុនេយ្យវគ្គនោះ គឺ

និយាយអំពីអាហុនេយ្យបុគ្គល ២ លើក អំពីឥន្ទ្រិយ
១ ពល ១ សេះអាជានេយ្យ ៣ លើក អនុត្តរិយៈ ១
អនុស្សតិ ១ មហានាមសក្កៈ ១ រួមជា ១០ ។

# អដ្ឋកថា

## មហានាមសូត្រទី ១០

[ ១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហានាមសូត្រទី ១០ ដូចតទៅនេះ បទថា **មហានាមោ** បានដល់ សក្យរាជមួយអង្គដែលជាព្រះរាជឱរសនៃព្រះបិតុលារបស់ព្រះទសពល ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា លោកសោយព្រះក្រយាហារព្រឹកហើយ ចោមរោមទៅដោយទាសៈ និងជនជាបរិវារ ឲ្យមនុស្សកាន់យកគ្រឿងក្រអូប និងផ្កាកម្រងជាដើម ហើយបានយាងទៅក្នុងទីដែលព្រះសាស្តាគង់ ។ អរិយសាវក ឈ្មោះថា **អាគតផលោ** ព្រោះមានអរិយផលមកដល់ហើយ ។ ឈ្មោះថា **វិញ្ញាត-សាសនោ** ព្រោះមានពាក្យប្រៀនប្រដៅ គឺសិក្ខា ៣ ដែលលោកដឹងច្បាស់ហើយ ។ ព្រះរាជាអង្គនេះ កាលនឹងទូលសួរថា ខ្ញុំព្រះអង្គទូលសួរដល់វិហារធម៌ ដែលជាទីអាស្រ័យរបស់ព្រះសោតាបន្ន ដូច្នេះ ទើបក្រាបទូលយ៉ាងនេះ ។

*បទថា* **នេវស្ស រាគបរិយុដ្ឋិតំ** *សេចក្តីថា ចិត្តនៃព្រះអរិយសាវកនោះ មិនត្រូវរាគៈដែលកើតឡើងរួបរឹតឡើយ ។ បទថា* **ឧជុគតំ** *សេចក្តីថា ចិត្តនៃអរិយសាវកនោះ ប្រព្រឹត្តទៅត្រង់ក្នុងពុទ្ធានុស្សតិកម្មដ្ឋាន ។ បទថា* **តថាគតំ អារព្ភ** *បានដល់ ប្រារព្ធគុណរបស់ព្រះតថាគត ។*

*បទថា* **អត្ថវេទំ** *បានដល់ បីតិ និងបាមោជ្ជដែលកើតឡើង អាស្រ័យអដ្ឋកថា ។ បទថា* **ធម្មវេទំ** *បានដល់ បីតិ និងបាមោជ្ជ ដែលកើតឡើងអាស្រ័យបាលី ។ បទថា* **ធម្មូបសញ្ហិតំ** *បានដល់ បីតិ និងបាមោជ្ជ ដែលកើតឡើង អាស្រ័យទាំងបាលី និងអដ្ឋកថា ។ បទថា* **បមុទិតស្ស** *សេចក្តីថា ដល់បុគ្គលដែលត្រេកអរហើយ ដោយបាមោជ្ជ ២ យ៉ាង ។ បទថា* **បីតិ ជាយតិ** *សេចក្តីថា បីតិ ៥ យ៉ាង រមែងកើតឡើង ។ បទថា* **កាយោ បស្សម្ភតិ** *សេចក្តីថា នាមកាយក្តី ករជកាយក្តី រមែងស្ងប់ ដោយធម៌ជាគ្រឿងស្ងប់រម្ងាប់ នូវសេចក្តីក្រវល់ក្រវាយ ។ បទថា* **សមាធិយតិ** *សេចក្តីថា រមែងតាំងមាំដោយជុំវិញ ក្នុងអារម្មណ៍ ។ បទថា* **វិសមគតាយ បជាយ** *សេចក្តីថា ក្នុងសត្វទាំងឡាយ ដែលដល់នូវការមិនស្ងប់ ព្រោះរាគៈ ទោសៈ និងមោហៈ ។ បទថា* **សមប្បត្តោ** *សេចក្តីថា ជាអ្នកដល់នូវការស្ងប់ជានិច្ច ។ បទថា* **សព្យាបជ្ឈាយ** *ប្រែថា ជាអ្នកមានទុក្ខ ។ បទថា* **ធម្មសោ្សតំ សមាបន្នោ** *សេចក្តីថា ជាអ្នកដល់នូវក្រសែនៃធម៌ គឺវិបស្សនា ។*

*បទថា* **ពុទ្ធានុស្សតឹ ភាវេតិ** *សេចក្តីថា រមែងបន្ថែម គឺចម្រើនពុទ្ធា-*

នុស្សតិកម្មដ្ឋាន ។ ក្នុងបទទាំងពួង គប្បីជ្រាបដោយន័យនេះ ។ ព្រះបាទមហានាមទូលសួរដល់វិហារធម៌ ជាទីអាស្រ័យរបស់ព្រះសោតាបន្ន ដោយប្រការដូចពណ៌នាមក ដូច្នេះ ។ ព្រះបរមសាស្តាត្រាស់វិហារធម៌ ជាទីអាស្រ័យរបស់ព្រះសោតាបន្ននោះឯងដល់ទ្រង់ ដោយប្រការដូច្នេះ ។ ក្នុងសូត្រនេះឈ្មោះថា ត្រាស់ដល់ព្រះសោតាបន្នតែម្យ៉ាងប៉ុណ្ណោះ ដូច្នេះឯង ។ល។

**អដ្ឋកថា មហានាមសូត្រទី ១០ ចប់**

**អាហុនេយ្យវគ្គទី ១ ចប់**

# សុត្តន្តបិដក
# សារាណីយាទិវគ្គ

## បឋមសារាណិយសូត្រទី ១

[ ១១ ] ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ( ធម៌គួររឭក ) នេះ មាន ៦ យ៉ាង ។ សារាណីយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់នូវកាយកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុតម្កល់នូវវចីកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុតម្កល់នូវមនោកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីបុគ្គលទាំង-ឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកបរិភោគ មិនញែកមុខដោយលាភទាំងឡាយដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ ជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីទាំងឡាយដែលមានសីល នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីលស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ ដែលជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីល

រួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមានសេចក្ដីយល់ឃើញស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃកងទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

# សារាណីយាទិវគ្គទី ២

## បឋមសារាណីយសូត្រ

[ ១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសារាណីយសូត្រទី ១ នៃសារាណីយាទិវគ្គទី ២ ដូចតទៅនេះ បទថា **សារាណីយា** បានដល់ ធម៌ដែលគួរឲ្យរឭកដល់គ្នា ។ បទថា **មេត្តំ កាយកម្មំ** បានដល់ កាយកម្មដែលគប្បីធ្វើដោយចិត្តប្រកបដោយមេត្តា ក្នុងវចីកម្ម និងមនោកម្មទាំងឡាយក៏មានន័យនេះដូចគ្នា ។

មេត្តាកាយកម្មជាដើមនេះ ត្រាស់ដោយអំណាចនៃភិក្ខុទាំងឡាយ ។ សូម្បីគ្រហស្ថទាំងឡាយ ក៏នាំទៅប្រើបាន អធិប្បាយថា សម្រាប់ភិក្ខុទាំង-ឡាយ ការបំពេញធម៌ គឺអភិសមាចារិកវត្ត ដោយមេត្តាចិត្ត ឈ្មោះថា មេត្តាកាយកម្ម ។ សម្រាប់គ្រហស្ថទាំងឡាយ កម្មមានការធ្វើដំណើរទៅ ដើម្បីថ្វាយបង្គំចេតិយ ដើម្បីថ្វាយបង្គំពោធិព្រឹក្ស ដើម្បីនិមន្តព្រះសង្ឃ ការឃើញភិក្ខុទាំងឡាយដែលចូលទៅកាន់ផ្ទះ ដើម្បីបិណ្ឌបាត ហើយក្រោកឡើងទទួលការទទួលបាត្រ ការក្រាលអាសនៈ និងជូនដំណើរ ឈ្មោះថា មេត្តាកាយកម្ម ។

សម្រាប់ភិក្ខុទាំងឡាយ ការប្រាប់ ការបង្រៀន អាចារប្បញ្ញត្តិ ការប្រាប់កម្មដ្ឋាន ការសម្តែងធម៌ ការប្រាប់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ដោយមេត្តាចិត្ត ឈ្មោះថា មេត្តាវចីកម្ម ។ សម្រាប់គ្រហស្ថទាំងឡាយ ក្នុងពេលដែល

ពោលពាក្យជាដើមថា ពួកយើងនឹងទៅដើម្បីថ្វាយបង្គំព្រះចេតិយ ពួកយើងនឹងទៅដើម្បីថ្វាយបង្គំព្រះពោធិព្រឹក្ស ពួកយើងនឹងធ្វើការស្តាប់ធម៌ ពួកយើងនឹងធ្វើការបូជា ដោយប្រទីប កម្រងផ្កា និងផ្កា ពួកយើងនឹងសមាទាននូវសុចរិត ៣ ពួកយើងនឹងថ្វាយសលាកភត្តជាដើម ពួកយើងនឹងថ្វាយសំពត់ចំណាំវស្សា ថ្ងៃនេះ ពួកយើងនឹងប្រគេនបច្ច័យ ៤ ដល់ព្រះសង្ឃ អ្នកទាំងឡាយ ចូរនិមន្តព្រះសង្ឃ ហើយចាត់ចែងខាទនីយជាដើម ពួកអ្នកចូរក្រាលអាសនៈ ពួកអ្នកចូរតាំងទឹកផឹក ពួកអ្នកចូរទទួល ចូរនាំព្រះសង្ឃមក ពួកអ្នកចូរឲ្យព្រះសង្ឃគង់លើអាសនៈដែលក្រាល ហើយកើតនូវឧស្សាហ៍ ធ្វើវេយ្យាវច្ចកិច្ច ដូច្នេះ ឈ្មោះថា មេត្តាវចីកម្ម ។

សម្រាប់ភិក្ខុទាំងឡាយ កាលក្រោកឡើងអំពីព្រលឹម ធ្វើកិច្ចបដិបត្តិសរីរៈក្តី ធ្វើវត្តត្រង់លានព្រះចេតិយក្តី គង់លើអាសនៈដែលស្ងាត់ ហើយគិតថា ភិក្ខុទាំងឡាយ ក្នុងវិហារនេះ ចូរមានសេចក្តីសុខ មិនមានពៀរ មិនមានទុក្ខ ដូច្នេះ ឈ្មោះថា មេត្តាមនោកម្ម សម្រាប់គ្រហស្ថទាំងឡាយ ការគិតថា សូមលោកម្ចាស់ទាំងឡាយនៅជាសុខ កុំបីមានពៀរ មិនមានទុក្ខ ដូច្នេះ ឈ្មោះថា មេត្តាមនោកម្ម ។

បទថា **អាវិ ចេវ រហោ ច** សេចក្តីថា ទាំងក្នុងទីចំពោះមុខ និងកំបាំងមុខ ក្នុង ២ យ៉ាងនោះ ការដល់នូវភាពជាសម្មាញ់ក្នុងចីវរកម្មជាដើមរបស់ភិក្ខុថ្មីទាំងឡាយ ឈ្មោះថា កាយកម្មចំពោះមុខ ។ ឯក្នុងវចីកម្មគ្រប់យ៉ាង មានការប្រគេនទឹកលាងជើងដល់ព្រះថេរៈជាដើម ឈ្មោះថា កាយកម្មចំពោះមុខ ។

ការជួយទុកដាក់ទ្រព្យទាំងឡាយ មានឧសជាដើម ដែលភិក្ខុថ្មី និងព្រះថេរៈទាំង ២ ចំណែករក្សាទុកមិនល្អ មិនធ្វើឲ្យវិនាស ក្នុងកណ្ឌៈទាំងនោះ ទុកដាក់ដូចរបស់ដែលខ្លួនទុកដាក់មិនល្អឲ្យរៀបរយ ដូច្នេះ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ ការពោលសរសើរយ៉ាងនេះថា លោកម្ចាស់ទេវត្ថេរ លោកម្ចាស់តិស្សត្ថេរ ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។ កាលសួរដល់ព្រះថេរៈដែលមិននៅក្នុងវិហារ ការពោលពាក្យជាទីស្រឡាញ់យ៉ាងនេះថា លោកម្ចាស់ទេវត្ថេររបស់ខ្ញុំ ទៅណា លោកម្ចាស់តិស្សត្ថេររបស់ខ្ញុំ ទៅណា កាលណានឹងត្រឡប់មកហ្ន៎ ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ។

ចំណែកការបើកភ្នែកសម្លឹងដោយស្នេហា សម្លឹងមើលដោយទឹកមុខផូរផង់ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ បំណងល្អថា សូមលោកម្ចាស់ទេវត្ថេរ លោកម្ចាស់តិស្សត្ថេរ កុំបីមានរោគ កុំបីមានអាពាធ ដូច្នេះ ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។

បទថា **លាភា** បានដល់ បច្ច័យដែលបានមក មានចីវរជាដើម ។ បទថា **ធម្មិកា** បានដល់ លាភដែលកើតឡើងដោយភិក្ខាចារិយវត្តដោយធម៌ស្មើ ដោយវៀរមិច្ឆាអាជីវៈ មានកុហកជាដើម ។ បទថា **អន្តមសោ បត្តបរិយាបន្នមត្តម្បិ** សេចក្តីថា ដោយហោចត្រឹមតែភិក្ខា ២-៣ វែក ដែលទាក់ទងហើយក្នុងបាត្រ គឺនៅជាប់គូថបាត្រ ។

ក្នុងបទថា **អប្បដិវិភត្តភោគី** នេះ ការបែងចែក មាន ២ យ៉ាង គឺ បែងចែកអាមិស ១ បែងចែកបុគ្គល ១ ។

*ក្នុង ២ យ៉ាងនោះ ការចែករំលែកដោយគិតយ៉ាងនេះថា អញនឹងឲ្យប៉ុណ្ណេះ មិនឲ្យប៉ុណ្ណេះ ដូច្នេះ ឈ្មោះថា បែងចែកដោយអាមិស ។ ការចែករំលែកដោយគិតយ៉ាងនេះថា អញនឹងឲ្យដល់ភិក្ខុនោះ មិនឲ្យភិក្ខុនោះ ដូច្នេះ ឈ្មោះថា ចែករំលែកបុគ្គល ។ ភិក្ខុមិនហួងហែងនូវលាភបរិភោគ ដោយមិនធ្វើទាំង ២ នោះ ឈ្មោះថា* **អប្បដិវិភត្តភោគី ។**

*លក្ខណៈរបស់អ្នកបរិភោគរួមគ្នា ក្នុងបទថា* **សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី** *នេះ មានដូច្នេះ ភិក្ខុណា បានអាហារណាមួយប្រណីត មិនព្រមឲ្យដល់គ្រហស្ថទាំងឡាយ ដោយបំណងយកលាភទាក់លាភ មិនបរិភោគដោយខ្លួន ហើយកាលទទួល ក៏ទទួលដោយគិតថា ចូរជារបស់សាធារណៈជាមួយពួកសង្ឃ រមែងឃើញដូចជារបស់សង្ឃ ដែលត្រូវវាយគងឲ្យមកបរិភោគរួមគ្នា ។ សួរថា នរណា បំពេញសារាណីយធម៌នេះឲ្យបរិបូណ៌បាន បុគ្គលណាបំពេញឲ្យបរិបូណ៌មិនបាន ។ ឆ្លើយថា ជាបឋម បុគ្គលទ្រុស្តសីល រមែងបំពេញឲ្យបរិបូណ៌មិនបាន ព្រោះភិក្ខុអ្នកមានសីលទាំងឡាយ មិនព្រមទទួលវត្ថុរបស់បុគ្គលទ្រុស្តសីលនោះ ចំណែកភិក្ខុ អ្នកមានសីលបរិសុទ្ធ មិនព្រមឲ្យវត្តពព្រុសពពាល រមែងបំពេញឲ្យបរិបូណ៌បាន ក្នុងការបំពេញសារាណីយធម៌ឲ្យបរិបូណ៌បាននោះ មានទំនៀម ដូច្នេះ ។*

*ភិក្ខុតាំងចិត្តឲ្យរបស់ដល់មាតាក្តី ដល់បិតាក្តី ដល់អាចារ្យ និងឧបជ្ឈាយ៍ជាដើមក្តី ភិក្ខុនោះ ឈ្មោះថា រមែងឲ្យវត្ថុដែលគួរឲ្យ ដល់បុគ្គលដែលគួរឲ្យ តែមិនឈ្មោះថា មានសារាណីយធម៌ មានត្រឹមតែកិច្ចបដិបត្តិ ដែលគួរជាប់*

ចំពាក់ ។ ព្រោះថា សារាណីយធម៌ រមែងសមគួរដល់បុគ្គលដែលផុតចាកបលិពោធហើយ ។ បុគ្គលដែលបំពេញសារាណីយធម៌នោះ កាលនឹងឲ្យដោយចំពោះ គួរឲ្យដល់ភិក្ខុឈឺ អ្នកថែភិក្ខុឈឺ អាគន្តុកភិក្ខុ ភិក្ខុត្រៀមដើរផ្លូវ និងភិក្ខុអ្នកបួសថ្មី ដែលមិនទាន់ដឹងការទទួលសង្ឃាដិ និងការទទួលបាត្រ កាលឲ្យដល់ភិក្ខុទាំងនេះហើយ នៅមានរបស់សេសសល់ រាប់ចាប់តាំងអំពីអាសនៈនៃព្រះថេរៈទៅ ភិក្ខុណានឹងទទួលប៉ុនណា គួរឲ្យភិក្ខុនោះប៉ុណ្ណោះ ដោយមិនឲ្យមួយអន្លុបន្តិចបន្តួច ។ បើមិនមានរបស់សល់ ចេញទៅបិណ្ឌបាតទៀត គួរឲ្យចំណែកដែលប្រណីតៗ នោះ ចាប់តាំងអំពីអាសនៈនៃព្រះថេរៈទៅ បរិភោគចំណែកដែលសល់ ។

ព្រោះមានព្រះបាលីថា **សីលវន្តេហិ** ដូច្នេះ ទោះបីមិនឲ្យដល់ភិក្ខុដែលទ្រុស្តសីលក៏គួរ ។ សារាណីយធម៌នេះ បំពេញបានងាយ ក្នុងបរិស័ទដែលសិក្សាល្អហើយ ព្រោះក្នុងពួកបរិស័ទដែលសិក្សាល្អហើយ ភិក្ខុណាបាននូវអាហារ មកអំពីទីដទៃ ភិក្ខុនោះមិនព្រមទទួល ទោះបីមិនបានមកអំពីទីដទៃ ក៏នឹងទទួលតែល្មមប្រមាណប៉ុណ្ណោះ មិនទទួលរហូតហៀរហូរ ។ សារាណីយ-ធម៌នេះ បើភិក្ខុឲ្យរបស់ដែលខ្លួនទៅបិណ្ឌបាតបានមករឿយៗ យ៉ាងនេះ បំពេញឲ្យបរិបូណ៌បាន ត្រូវប្រើពេល ១២ ឆ្នាំ ទាបជាងនោះ បរិបូណ៌មិនបាន ។ ព្រោះបើលោកបំពេញសារាណីយធម៌ក្នុងឆ្នាំទី ១២ ដាក់បាត្រដែលពេញដោយអាហារលើអាសនៈសាលា ហើយទៅងូតទឹក ព្រះសង្ឃត្ថេរមកដល់ សួរថា នេះបាត្រនរណា កាលភិក្ខុឆ្លើយថា បាត្ររបស់ភិក្ខុបំពេញសារាណីយធម៌

ព្រះថេរៈក៏ពោលថា ចូរនាំយកបាត្រនោះមក ហើយឆាន់បិណ្ឌបាត រហូតអស់ទាំងអស់ តម្កល់បាត្រទទេទុក កាលភិក្ខុនោះឡើងមក ឃើញបាត្រទទេ ក៏កើតទោមនស្សថា ភិក្ខុទាំងឡាយឆាន់អស់ មិនបន្សល់ទុកឲ្យអញសោះ សារាណីយធម៌នឹងបែក នឹងត្រូវបំពេញជាថ្មី ១២ ឆ្នាំទៀត ដូចគ្នានឹងតិត្ថិយ-បរិវាស ភិក្ខុនោះកាលសារាណីយធម៌ពុះពពាល ត្រូវបំពេញជាថ្មីទៀត ។ ឯភិក្ខុណាកើតសោមនស្សថា ជាលាភរបស់អញហ្ន៎ អញបានល្អហើយហ្ន៎ ដែលសព្រហ្មចារីមិនសាកសួរដល់អាហារ ដែលនៅក្នុងបាត្ររបស់អញ ហើយឆាន់ ដូច្នេះ សារាណីយធម៌របស់ភិក្ខុនោះ ឈ្មោះថា សម្បូរហើយ ភិក្ខុមានសារាណីយធម៌បរិបូណ៌យ៉ាងនេះ រមែងមិនមានសេចក្តីច្រណែន មិនមានសេចក្តីកំណាញ់ រមែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ ជាទីស្រឡាញ់នៃអមនុស្សទាំងឡាយ រកបច្ច័យបានងាយ សូម្បីរបស់ដែលគេប្រគេនដល់បុគ្គលមានសារាណីយធម៌បរិបូណ៌ រមែងមិនអស់ទៅ ។ លោករមែងបានរបស់ដែលមានតម្លៃក្នុងឋានៈដែលលោកចែករបស់ កាលជួបនូវភ័យ ឬការស្រេកឃ្លាន ទេវតាទាំងឡាយ រមែងជួយផ្គត់ផ្គង់ ។ ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះជាគំរូ ។

## រឿង ព្រះតិស្សត្ថេរ

បានឮមកថា ព្រះតិស្សត្ថេរ អ្នកលេណគិរីវិហារ នៅអាស្រ័យស្រុកឈ្មោះថា មហាទីរៈ ។ ព្រះមហាថេរៈ ៥០ រូប ធ្វើដំណើរទៅថ្វាយបង្គំ

នាគទីបចេតិយ ត្រាច់បិណ្ឌបាតក្នុងវិរគាម មិនបានសូម្បីវត្ថុតិចតួច ទើបនាំគ្នាចេញទៅ ។ ព្រះតិស្សត្ថេរចូលទៅឃើញព្រះថេរៈទាំងនោះ ទើបសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់បានអាហារហើយឬ ព្រះថេរៈទាំងនោះឆ្លើយថា លោកម្ចាស់ ពួកខ្ញុំទៅមកវិញហើយ លោកដឹងថា ព្រះថេរៈទាំងនោះមិនបានអាហារ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយបង្អង់ក្នុងទីនេះសិន ទម្រាំខ្ញុំត្រឡប់មក ។ ព្រះថេរៈទាំងនោះពោលថា លោកម្ចាស់ ពួកខ្ញុំមាន ៥០ រូប នៅតែមិនបាន សូម្បីត្រឹមតែទឹកលាងបាត្រ ។ ព្រះតិស្សត្ថេរពោលថា បពិត្រលោកម្ចាស់ ឈ្មោះថា ភិក្ខុជាម្ចាស់ទីកន្លែងរមែងជាអ្នកអាច សូម្បីមិនបានភិក្ខា ក៏រមែងដឹងឱកាសភិក្ខាចារ ។ ព្រះថេរៈទាំងឡាយរង់ចាំហើយ ព្រះតិស្សត្ថេរចូលទៅកាន់ស្រុកហើយ មហាឧបាសិការៀបចំខីរភត្តក្នុងស្រុកជិតៗ នោះឯង ឈរមើលព្រះថេរៈហើយ គ្រាន់តែព្រះថេរៈមកដល់ទ្វារប៉ុណ្ណោះ ក៏ប្រគេនអាហាររហូតពេញបាត្រ លោកកាន់យកបាត្រនោះ ទៅកាន់សម្នាក់របស់ព្រះថេរៈទាំងឡាយ ហើយពោលនឹងព្រះ-សង្ឃត្ថេរថា សូមនិមន្តលោកម្ចាស់ទទួលចុះ ។ ព្រះថេរៈគិតថា ពួកយើងចំនួនប៉ុណ្ណោះមិនទាន់បានអ្វីឡើយ ភិក្ខុរូបនេះកាន់បាត្រទៅ ត្រឡប់មករហ័សពិត នេះមានរឿងអ្វីហ្ន៎ ដូច្នេះហើយ មើលមុខព្រះថេរៈដ៏សេសទាំងឡាយ ។ ព្រះតិស្សត្ថេរ ដឹងដោយអាការដែលមើលមុខនោះឯង ពោលថា បពិត្រលោកម្ចាស់ បិណ្ឌបាត ខ្ញុំបានមកដោយធម៌ សូមលោកម្ចាស់ទាំងឡាយកុំរង្កៀសថ្វី

ឡើយ សូមនិមន្តឆាន់ចុះ ហើយប្រគេនបិណ្ឌបាតដល់ព្រះថេរៈគ្រប់រូប សម
គួរដល់សេចក្តីត្រូវការ ឯខ្លួនឯង ក៏ឆាន់របូតផ្អែត ។

ក្នុងកាលសម្រេចភត្តកិច្ច ព្រះថេរៈទាំងឡាយ សួរលោកថា នែលោក
ម្ចាស់ លោកម្ចាស់សម្រេចលោកុត្តរធម៌អំពីកាលណា លោកឆ្លើយថា បពិត្រ
លោកម្ចាស់ ខ្ញុំមិនទាន់មានលោកុត្តរធម៌ឡើយ ព្រះថេរៈទាំងឡាយ សួរថា
អាវុសោ លោកបានឈានឬ ។ លោកឆ្លើយថា បពិត្រលោកម្ចាស់ ឈាន
ក៏ខ្ញុំមិនទាន់បាន ។ ព្រះថេរៈទាំងឡាយសួរថា លោកម្ចាស់មានបាដិហារិយ៍ឬ ។
លោកឆ្លើយថា ខ្ញុំបំពេញសារាណីយធម៌ លោកម្ចាស់ ។ តាំងអំពីខ្ញុំបំពេញ
សារាណីយធម៌បរិបូណ៌ហើយ ទោះបីមានភិក្ខុមួយសែនរូប អាហារដែលនៅ
ក្នុងបាត្រ ក៏មិនអស់ឡើយ ព្រះថេរៈទាំងនោះពោលថា សាធុ សាធុ សប្បុរស
សេចក្តីនេះសមគួរដល់លោកហើយ ដូច្នេះ ។ ពាក្យដែលពោលមកនេះគ្រាន់
តែជាភស្តុតាងក្នុងពាក្យថា អាហារដែលនៅក្នុងបាត្រក៏មិនអស់ទៅមុន ។

ព្រះតិស្សត្ថេរ ១ អង្គទៀតនោះឯង ទៅកាន់ទីឲ្យទានដើម្បីមហាបូជា
ក្នុងចេតិយបព៌ត ឈ្មោះថា គិរិកណ្ឌ ហើយសួរថា ក្នុងការឲ្យទាននេះ មាន
អ្វីជារបស់ប្រសើរបំផុត មនុស្សទាំងឡាយឆ្លើយថា មានសំពត់សាដក ២
ផ្ទាំង លោកម្ចាស់ ។ ព្រះថេរៈពោលថា សាដកគូនេះ នឹងដល់លំដាប់អាត្មា
អមាត្យបានឮពាក្យនោះហើយ ទៅក្រាបទូលព្រះរាជាថា ភិក្ខុកំលោះមួយរូប
ពោលយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា ភិក្ខុកំលោះមានការគិតយ៉ាងនេះ តែសំពត់
សាដកសាច់ម៉ដ្ឋ សមគួរដល់ព្រះថេរៈទាំងឡាយ ហើយទ្រង់ដាក់គូសំពត់

សាជកដោយទ្រង់ព្រះតម្រិះថា អញនឹងប្រគេនដល់ព្រះមហាថេរៈទាំងឡាយ ។ កាលព្រះរាជាប្រគេនក្នុងភិក្ខុសង្ឃ ដែលឈរតាមលំដាប់ សំពត់សាជកដែលដាក់ខាងលើ ក៏មិនជាប់ព្រះហស្ត សំពត់ផ្ទាំងដទៃបែរជាជាប់ព្រះហស្ត តែក្នុងគ្រាទ្រង់ប្រគេនដល់ភិក្ខុកំលោះ សំពត់សាជកទាំង ២ ផ្ទាំងនោះ បែរជាជាប់ព្រះហស្ត ព្រះរាជាទ្រង់ដាក់លើដៃរបស់ភិក្ខុកំលោះ ហើយទ្រង់សម្លឹងមើលមុខ អមាត្យនិមន្តឲ្យភិក្ខុកំលោះអង្គុយថ្វាយទាន ទ្រង់លះភិក្ខុសង្ឃ ហើយប្រថាប់ក្នុងសម្នាក់របស់ភិក្ខុកំលោះ ត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់សម្រេចធម៌នេះតាំងពីពេលណា ។ លោកមិនទូលគុណធម៌ដែលមិនមានដោយអម តែបែរជាទូលថា បពិត្រមហារាជ លោកុត្តរធម៌របស់អាត្មាមិនមាន ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ក្នុងកាលមុនលោកម្ចាស់ក៏បានពោលហើយ មិនមែនឬ ភិក្ខុកំលោះឆ្លើយថា ថ្វាយព្រះពរមហាបពិត្រ ត្រូវហើយ អាត្មាភាពបំពេញសារាណីយធម៌ តាំងអំពីកាលដែលអាត្មាភាពបំពេញសារាណីយធម៌ចប់ហើយ ក្នុងទីដែលគេចែករបស់គ្រប់យ៉ាង របស់ដែលមានតម្លៃច្រើន នឹងដល់លំដាប់អាត្មាភាព ។ ព្រះរាជាត្រាស់ថា សាធុ សាធុ លោកម្ចាស់ សំពត់សាជកគូនេះ សមគួរដល់លោកម្ចាស់ ហើយទ្រង់ក៏ចៀសចេញទៅ ។ រឿងដែលពោលមកនេះ ជាសាធកៈក្នុងពាក្យថា ក្នុងទីដែលចែករបស់មានតម្លៃ នឹងធ្លាក់ដល់អ្នកបំពេញសារាណីយធម៌ ។

អ្នកស្រុកដែលអាស្រ័យនៅក្នុងការតគាម មិនទាន់បានប្រាប់ដល់ព្រះនាងនាគថេរី ប្រញាប់ចៀសចេញទៅ ព្រោះព្រហ្មតិស្សភ័យ ។ ក្នុងថ្ងៃស្អែកឡើង

ព្រះថេរីពោលនឹងភិក្ខុនីក្រមុំ ឈ្មោះថា ចណ្ឌាលតិស្សៈថា ស្រុកស្ងាត់ពេក នាងទាំងឡាយចូរទៅពិនិត្យមើលមុន ភិក្ខុនីក្រមុំទាំងនោះទៅហើយ ដឹងភាពដែលមនុស្សទាំងពួងចៀសចេញទៅ ទើបត្រឡប់មកប្រាប់ដល់ព្រះថេរី ។ ព្រះថេរីស្តាប់ហើយ ទើបពោលថា ពួកនាងកុំគិតដល់ការដែលមនុស្សទាំងនោះគេចទៅឡើយ ចូរធ្វើសេចក្តីព្យាយាមក្នុងឧទ្ទេស ការសាកសួរ និងយោនិសោ-មនសិការរបស់ខ្លួនចុះ ដូច្នេះហើយ ក្នុងពេលភិក្ខាចារ ដណ្តប់ចីវរហើយ មានគ្នា ១២ រូបទាំងខ្លួនឯង បាននាំគ្នាទៅឈរត្រង់គល់ជ្រៃ ជិតទ្វារស្រុក ។ ទេវតាដែលអាស្រ័យត្រង់គល់ឈើ បានប្រគេនបិណ្ឌបាតដល់ភិក្ខុនីទាំង ១២ រូប ហើយពោលថា បពិត្រអ្នកនាងម្ចាស់ សូមអ្នកនាងម្ចាស់កុំទៅទីដទៃឡើយ និមន្តមកទីនេះជាប្រចាំចុះ ។ ក្នុងទីនោះ មានព្រះថេរៈមួយអង្គ ឈ្មោះថា នាគៈ ជាប្អូនប្រុសរបស់ព្រះថេរី លោកគិតថា ភ័យធំ អញមិនអាចញុំាងជីវិតឲ្យប្រព្រឹត្តទៅបាន អញនឹងទៅត្រើយនាយ រួមនឹងភិក្ខុ ១២ រូប ទាំងខ្លួនឯង ចេញពីលំនៅរៀងៗ ខ្លួន មកកាន់ការតគាម ដោយគិតថា អញនឹងទៅសួរសុខទុក្ខព្រះថេរី ។ ព្រះថេរីបានជ្រាបថា ព្រះថេរៈមក ទើបទៅកាន់សម្នាក់របស់ព្រះថេរៈទាំងនោះ ហើយសួរថា មានរឿងអ្វីឬ លោកម្ចាស់ ព្រះថេរៈប្រាប់ព្រឹត្តិការណ៍នោះហើយ ព្រះថេរីពោលថា ថ្ងៃនេះ សូមលោកម្ចាស់នៅក្នុងវិហារនេះ ត្រឹមតែមួយថ្ងៃ ស្អែកឡើងសឹមទៅ ។ ព្រះថេរៈទាំងឡាយបានទៅកាន់វិហារហើយ ។

ក្នុងថ្ងៃស្អែកឡើង ព្រះថេរីទៅបិណ្ឌបាតត្រង់គល់ឈើ ហើយចូលទៅរកព្រះថេរៈពោលថា សូមលោកម្ចាស់ឆាន់បិណ្ឌបាតនេះ ។ ព្រះថេរៈមិនពោលថា នឹងសមគួរ ដូច្នេះហើយ ឈរនៅស្ងៀម ។ ព្រះថេរីពោលថា បពិត្រលោកម្ចាស់ បិណ្ឌបាតនេះ ជារបស់កើតឡើងដោយធម៌ សូមលោកម្ចាស់កុំរង្កៀសឡើយ និមន្តឆាន់ចុះ ។ ព្រះថេរៈពោលថា គួរឬ ព្រះថេរី ។ ព្រះថេរីនោះចាប់បាត្ររបស់ព្រះថេរៈ ហើយបោះទៅក្នុងអាកាស បាត្របានអណ្តែតនៅលើអាកាស ។ ព្រះថេរៈពោលថា នែព្រះថេរី កត្តអណ្តែតនៅលើអាកាសកម្ពស់ ៧ ជួរដើមត្នោត ជាភត្តាហារសម្រាប់ភិក្ខុនីប៉ុណ្ណោះ ដូច្នេះហើយ ពោលតទៅថា ឈ្មោះថា ភ័យ នឹងមិនមានគ្រប់កាល កាលភ័យស្ងប់ហើយ ខ្ញុំនឹងពោលអរិយវង្ស ត្រូវចិត្តពោលជាស់តឿនរឿយៗ ថា បុគ្គលដែលកាន់យកបិណ្ឌបាតជាវត្តដ៏ចម្រើន អ្នកទាំងឡាយ នឹងឆាន់កត្តាហាររបស់ភិក្ខុនី ហើយបណ្តោយឲ្យកាលកន្លងទៅឬ ដូច្នេះ នឹងមិនអាចនៅតទៅបាន នែភិក្ខុនីទាំងឡាយ ចូរនាងទាំងឡាយ ជាអ្នកមិនប្រមាទចុះ ។

ចំណែករុក្ខទេវតាក៏គិតថា បើព្រះថេរៈឆាន់បិណ្ឌបាតអំពីដៃរបស់ព្រះថេរីហើយសោត អញនឹងមិនឲ្យលោកត្រឡប់ បើមិនឆាន់ អញនឹងឲ្យលោកត្រឡប់ ឈរមើលការនិមន្តទៅរបស់ព្រះថេរៈ ហើយចុះអំពីដើមឈើ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ឲ្យបាត្រដល់ខ្ញុំ ហើយទទួលបាត្រ នាំព្រះថេរៈទៅកាន់គល់ឈើនោះឯង ក្រាលអាសនៈ ប្រគេនបិណ្ឌបាត ឲ្យព្រះថេរៈសម្រេចភត្តកិច្ចហើយ ធ្វើប្តេជ្ញាទំនុកបម្រុងទាំងភិក្ខុនី ១២ រូប ទាំងភិក្ខុ ១២

រូប អស់កាល ៧ ឆ្នាំ ។ នេះជាសាធកៈ ក្នុងពាក្យថា ទេវតាទាំងឡាយ រមែងខ្វល់ខ្វាយ ព្រោះក្នុងរឿងនោះ ព្រះថេរីបានបំពេញសាវកណីយធម៌មក គ្រប់បរិបូណ៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **អខណ្ឌានិ** ជាដើម ដូចតទៅនេះ បណ្តាអាបត្តិទាំង ៧ កង បុគ្គលណាមានសិក្ខាបទដាច់ខាងចុង ឬខាងដើម សីលរបស់ភិក្ខុនោះ ឈ្មោះថា ដាច់ ដូចសំពត់ដែលដាច់ត្រង់ជាយ ចំណែក បុគ្គលណាមានសិក្ខាបទដាច់ត្រង់កណ្តាល សីលនៃបុគ្គលនោះ ឈ្មោះថា ធ្លុះ ដូចសំពត់ដែលធ្លុះត្រង់កណ្តាល បុគ្គលណាមានសិក្ខាបទ ២-៣ សិក្ខាបទ ដាច់តាមលំដាប់ សីលនៃបុគ្គលនោះ ឈ្មោះថា ពពាល ដូចមេគោដែល មានពណ៌ខ្មៅលាយពណ៌ក្រហមជាដើម ពណ៌ណាមួយដោយមានពណ៌កាត់ គ្នាប្រាកដត្រង់ខ្នង ឬត្រង់ពោះ ។ បុគ្គលណាមានសិក្ខាបទដាច់ក្នុងចន្លោះៗ សីលនៃបុគ្គលនោះ ឈ្មោះថា ពព្រុស ដូចមេគោដែលមានពណ៌ចម្រុះ ពាស ពេញឆ្លាស់គ្នា ត្រង់ចន្លោះៗ ។ ចំណែកបុគ្គលមានសិក្ខាបទទាំងអស់ មិនដាច់ បុគ្គលនោះ ឈ្មោះថា មានសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ។ តែសិក្ខាបទទាំងនេះ លោកហៅថា ឈ្មោះថា **ភុជិស្សៃ** ព្រោះធ្វើភាពជាអ្នកជា ដោយផុតអំពីទាសៈនៃតណ្ហា ។ ឈ្មោះថា **វិញ្ញុប្បសដ្ឋ** ព្រោះវិញ្ញូជនទាំង-ឡាយ មានព្រះពុទ្ធជាដើមទ្រង់សរសើរ ។ ឈ្មោះថា **អបរាមដ្ឋ** ព្រោះតណ្ហា និងទិដ្ឋិ មិនស្ទាបអង្អែល និងព្រោះបុគ្គលណាម្នាក់ មិនអាចស្ទាបអង្អែលថា លោកម្ចាស់ធ្លាប់ត្រូវអាបត្តិ ឈ្មោះនេះមកហើយ លោកហៅថា ឈ្មោះថា

**សមាធិសំវត្តនិកា** ព្រោះញុំាងឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅ ។

បទថា **សីលសាមញ្ញគតោ វិហរតិ** សេចក្តីថា ជាអ្នកមានប្រក្រតីចូលដល់ភាពជាអ្នកស្មើគ្នា ដោយភិក្ខុទាំងឡាយ ដែលនៅក្នុងទិសាភាគនោះ ព្រោះថា សីលរបស់ព្រះសោតាបន្នជាដើម រមែងជាសីលស្មើគ្នា ដោយសីលរបស់ព្រះអរិយៈដទៃ មានព្រះសោតាបន្នជាដើម ដែលនៅក្នុងរវាងនៃមហាសមុទ្រខ្លះ ក្នុងទេវលោកនោះឯងខ្លះ ព្រោះដូច្នោះ ក្នុងមគ្គសីល គឺសីលក្នុងអន្តមគ្គ ទើបមិនមានការផ្សេងគ្នា ។ ព្រះមានព្រះភាគត្រាស់ពាក្យថា **សីលសាមញ្ញគតោ វិហរតិ** ដូច្នេះ ដោយទ្រង់សំដៅយកសីលនៃព្រះសោតាបន្នជាដើមនោះ ។

បទថា **យាយំ ទិដ្ឋិ** បានដល់ សម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ ។ បទថា **អរិយា** គឺមិនមានទោស ។ ទិដ្ឋិ ឈ្មោះថា **និយ្យានិកា** ព្រោះជាហេតុនាំសត្វចេញទៅអំពីភព ។ បទថា **តក្ករស្ស** បានដល់ បុគ្គលដែលធ្វើយ៉ាងនោះ ។ បទថា **ទុក្ខក្ខយាយ** សេចក្តីថា ដើម្បីអស់នូវទុក្ខទាំងពួង ។ បទថា **ទិដ្ឋិសាមញ្ញគតោ** សេចក្តីថា ជាអ្នកចូលដល់នូវភាពជាបុគ្គលមានទិដ្ឋិស្មើគ្នា ។៚

## អដ្ឋកថា បឋមសារាណីយសូត្រទី ១ ចប់

# សុត្តន្តបិដក

## ទុតិយសារាណីយសូត្រទី ២

[ ១២ ] ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ ៦ យ៉ាងនេះ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ សារាណីយធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់កាយកម្ម ប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុតម្កល់វចីកម្ម ប្រកបដោយមេត្តា ។បេ។ តម្កល់មនោកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុអ្នកបរិភោគ មិនញែកមុខ ដោយលាភទាំងឡាយដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ ជាអ្នកបរិភោគ ជាសាធារណៈ ដោយសព្រហ្មចារីទាំងឡាយដែលមានសីល នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀង

គ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមាន សីលស្មើគ្នា នឹងសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយ ដែលជាសីល មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីល ប្រព្រឹត្តទៅដើម្បីសមាធិ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយ-ធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តី សង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាល ភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុមានសេចក្តីយល់ឃើញស្មើគ្នា នឹង សព្រហ្មចារីទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វ ប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃកងទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តី គោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀង គ្នា ដើម្បីមូលមិត្តគ្នា ។ ម្នាលភិក្ខុទាំងឡាយ សារាណីយធម៌ទាំង ៦ យ៉ាង នេះឯង ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តី សង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីមូលមិត្តគ្នា ។

# អដ្ឋកថា
## ទុតិយសារាណីយសូត្រ

[ ១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសារាណីយសូត្រទី ២ ដូចតទៅនេះ សារាណីយធម៌ ឈ្មោះថា **បិយករណា** ព្រោះធ្វើបុគ្គលដែលបំពេញធម៌ទាំងនោះឲ្យបរិបូណ៌ ឲ្យជាទីស្រឡាញ់របស់សព្រហ្មចារីទាំងឡាយ ។ ឈ្មោះថា **គរុករណា** ព្រោះធ្វើឲ្យជាបុគ្គលគួរគោរព ។ បទថា **សង្គហាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការសង្គ្រោះ ។ បទថា **អវិវាទាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ការមិនទាស់ទែងគ្នា ។ បទថា **សាមគ្គិយា** បានដល់ ដើម្បីជាប្រយោជន៍ដល់សេចក្តីសាមគ្គី ។ បទថា **ឯកីភាវាយ** បានដល់ ដើម្បីជាប្រយោជន៍ដល់ភាពតែមួយ ។ បទថា **សំវត្តន្តិ** បានដល់ រមែងប្រព្រឹត្តទៅ គឺប្រព្រឹត្តទូទៅ ៕៚

**អដ្ឋកថា ទុតិយសារាណីយសូត្រទី ២ ចប់**

# សុត្តន្តបិដក

## មេត្តាសូត្រទី ៣

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ និស្សារណីយធាតុនេះមាន ៦ យ៉ាង ។ និស្សារណីយធាតុ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមេត្តា ខ្ញុំបានអប់រំបន្ទុំច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកផងគប្បីនិយាយឃាត់ភិក្ខុនេះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះមិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយមេត្តា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ ព្យាបាទក៏គង់នៅគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោវិមុត្តិដែលប្រកបដោយមេត្តាហ្នឹងឯង ជាធម៌សម្រាប់រលាស់បោលនូវព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើន

ហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ វិហេសា ( សេចក្តីបៀតបៀន ) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកផងគប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយករុណា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសា ក៏គង់តែគ្របសង្កត់ចិត្តរបស់គេបានដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមតែពិតនុ៎ះ គឺចេតោវិមុត្តិដែលប្រកបដោយករុណាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវវិហេសា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមុទិតា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិ ( សេចក្តីមិនត្រេកអរ ) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកផងគប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការ

និយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយមុទិតាដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិក៏គង់តែគ្របសង្កត់ចិត្តរបស់គេបានដូច្នេះ ហេតុនោះ មិនដែលមានឡើយ ម្នាលអាវុសោ តាមតែពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយមុទិតាហ្នឹងឯង ជាធម៌រលាស់ចោលនូវអរតិ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយឧបេក្ខា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកផង គួរនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយឧបេក្ខា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ បើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់តែគ្របសង្កត់ ចិត្ត

របស់គេបានដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមតែពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយឧបេក្ខាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ និមិត្តានុសារីវិញ្ញាណ គឺវិញ្ញាណដែលរឮកឃើញនូវនិមិត្តរបស់ខ្ញុំនៅតែមាន ។ អ្នកផង គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ បើទុកជាដូច្នោះក៏ដោយ និមិត្តានុសារីវិញ្ញាណរបស់គេគង់តែនៅមានដូច្នេះ ហេតុនោះ មិនដែលមានឡើយ ម្នាលអាវុសោ តាមតែពិតនោះ ចេតោវិមុត្តិដែលប្រកបដោយអនិមិត្តហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវនិមិត្តទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា អស្មិមានះរបស់ខ្ញុំនេះទៅប្រាសអស់ហើយ ខ្ញុំពិចារណាមិនឃើញថា អាត្មាអញមានអស្មិមានះដូច្នេះ

ឡើយ តែបើទុកជាដូច្នោះក៏ដោយ សរ គឺសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ អ្នកផង គប្បីនិយាយឃាត់ភិក្ខុនោះយ៉ាងនេះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ លោកកុំនិយាយបង្កាច់ព្រះដ៏មានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា អស្មិមានះរបស់គេនេះ ទៅប្រាសអស់ហើយ គេពិចារណាមិនឃើញថា អាត្មាអញមានអស្មិមានះដូច្នេះឡើយ តែបើទុកជាដូច្នោះ សរ គឺសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ក៏គង់តែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ ហេតុនុ៎ះ មិនដែលមានឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ការដកឡើងនូវអស្មិមានះបានហ្នឹងឯង ជាធម៌សម្រាប់រលាស់ចេញនូវសរ គឺសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ។ ម្នាលភិក្ខុទាំងឡាយ និស្សារណីធាតុ មាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## មេត្តាសូត្រ

[ ១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមេត្តាសូត្រទី ៣ ដូចតទៅនេះ បទថា **និស្សារណីយា ធាតុយោ** បានដល់ ធាតុដែលជាផ្លូវចេញទៅ ។ ក្នុងបទថា **មេត្តា ហិ ខោ មេ ចេតោវិមុត្តិ** នេះ មានអធិប្បាយថា មេត្តានោះឯង ដែលប្រព្រឹត្តទៅក្នុងឈានពួក ៣ ឬពួក ៤ ឈ្មោះថា **មេត្តាចេតោវិមុត្តិ** ព្រោះរួចផុតចាកធម៌ដែលជាសឹកសត្រូវទាំងឡាយ ។

បទថា **ភាវិតា** គឺឲ្យចម្រើនហើយ ។ បទថា **ពហុលីកតា** គឺធ្វើហើយរឿយៗ ។ បទថា **យានីកតា** គឺធ្វើឲ្យដូចជាយានដែលទឹមហើយ ។ បទថា **វត្ថុកតា** គឺធ្វើឲ្យជាទីតាំង ។ បទថា **អនុដ្ឋិតា** គឺតាំងមាំហើយ ។ បទថា **បរិចិតា** សេចក្តីថា ផ្តើម គឺសន្សំ បានដល់ អប់រំហើយដោយប្រពៃ ។ បទថា **សុសមារទ្ធា** បានដល់ ប្រារព្ធដោយល្អ ដោយធ្វើឲ្យស្ទាត់ជំនាញយ៉ាងល្អ ។ បទថា **បរិយាទាយ តិដ្ឋតិ** បានដល់ ប្រកាន់ គឺប្រកាន់តាំងនៅ ។ បទថា **មា ហេវន្តិស្ស វចនីយោ** សេចក្តីថា ព្រោះហេតុដែលភិក្ខុនោះ ព្យាករមិនពិតដូច្នោះ ទើបភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយពោលថា លោកកុំពោលយ៉ាងនេះ ។

បទថា **យមិទំ មេត្តាចេតោវិមុត្តិ** បានដល់ មេត្តាចេតោវិមុត្តិនេះ ។ ពាក្យថា **មេត្តាចេតោវិមុត្តិ** នេះ ជាផ្លូវចេញទៅនៃព្យាបាទ អធិប្បាយថា ជាការរលាស់ព្យាបាទចេញទៅ ។ បុគ្គលណាចេញអំពីតិកជ្ឈាន ចតុក្កជ្ឈាន

ដោយមេត្តាភាវនា ហើយពិចារណាសង្ខារទាំងឡាយ សម្រេចមគ្គទី ៣ ដឹងថា ព្យាបាទនឹងមិនមានទៀត ដូច្នេះ រមែងឃើញព្រះនិព្វានដោយតតិយផល ចិត្តរបស់បុគ្គលនោះ ជាផ្លូវចេញទៅដោយចំណែកមួយនៃព្យាបាទ ។ ក្នុងបទទាំងអស់ គប្បីជ្រាបអធិប្បាយដោយឧបាយនេះ ។ បទថា **អនិមិត្តា ចេតោ-វិមុត្តិ** បានដល់ វិបស្សនាដែលមានកម្លាំង ឯអាចារ្យអ្នកពោលទីឃនិកាយពោលថា បានដល់ សមាបត្តិដែលសម្បយុត្តដោយអរហត្តផល ។ អរហត្ត-ផលសមាបត្តិនោះ ព្រះមានព្រះភាគត្រាស់ថា មិនមាននិមិត្ត ព្រោះមិនមានគ្រឿងសម្គាល់ គឺរាគៈជាដើម គ្រឿងសម្គាល់ គឺរូបជាដើម និងគ្រឿងសម្គាល់ថាទៀងជាដើម ។

បទថា **និមិត្តានុសារិ** បានដល់ មានការតាមរឭកដល់និមិត្ត ។ មានប្រភេទដូចពោលហើយជាសភាវៈ ។ បទថា **អស្មិ** បានដល់ អស្មិមានះ ។ បទថា **អយមហមស្មិ** សេចក្តីថា អញឈ្មោះថា ជាវត្ថុនេះ ក្នុងខន្ធ ៥ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ឈ្មោះថា ជាការព្យាករណ៍អរហត្តផលហើយ ។ បទថា **វិចិកិច្ឆាកថំកថាសល្លំ** បានដល់ ព្រួញ គឺសេចក្តីសន្ទិះសង្ស័យ ។

បទថា **មា ហេវន្តិស្ស វចនីយោ** សេចក្តីថា បើវិចិកិច្ឆាដែលបឋមមគ្គគប្បីសម្លាប់កើតឡើងដល់អ្នកសោត ការព្យាករណ៍អរហត្តផល រមែងខុស ព្រោះដូច្នោះ ទើបលោកត្រូវហាមថា កុំពោលរឿងមិនពិត ។

បទថា **អស្មីតិ មានសមុគ្ឃាតោ** បានដល់ អរហត្តមគ្គ អធិប្បាយថា កាលឃើញព្រះនិព្វានដោយអរហត្តមគ្គហើយ អស្មិមានៈ រមែងមិនមានទៀត ព្រោះដូច្នោះ ទើបអរហត្តមគ្គ ព្រះមានព្រះភាគត្រាស់ហៅថា ដកឡើងបាននូវមានៈថា អញមាន ។ ក្នុងព្រះសូត្រនេះ ត្រាស់ឈ្មោះថា **អភូតព្យាករ** គឺព្យាករឿងមិនពិត ដោយប្រការដូចពណ៌នាមក ដូច្នេះ ។

**អដ្ឋកថា មេត្តាសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ភទ្ទកសូត្រទី ៤

[ ១៤ ] ព្រះសារីបុត្តដ៏មានអាយុ ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ថេរវាចាព្រះសារីបុត្តដ៏មានអាយុថា ករុណាអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចនូវការនៅ យ៉ាងណាៗ មរណៈមិនល្អ កាលកិរិយាក៏មិនល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅ យ៉ាងណាៗ មរណៈ មិនល្អ កាលកិរិយាក៏មិនល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ តើដោយប្រការ

ដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីរីករាយក្នុងការងារ ត្រេកអរក្នុងការងារ ប្រកបរឿយៗ នូវសេចក្តីរីករាយក្នុងការងារ ជាអ្នកមានសេចក្តីរីករាយក្នុងការចរចា ត្រេកអរក្នុងការចរចា ប្រកបរឿយៗ នូវសេចក្តីរីករាយក្នុងការចរចា រមែងជាអ្នកមានសេចក្តីរីករាយនឹងការដេកលក់ ត្រេកអរក្នុងការដេកលក់ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងការដេកលក់ ជាអ្នកមានសេចក្តីរីករាយក្នុងពួកគណៈ ត្រេកកអរក្នុងពួកគណៈ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងពួកគណៈ ជាអ្នកមានសេចក្តីរីករាយ ក្នុងការប្រឡូកប្រឡំ ត្រេកអរក្នុងការប្រឡូកប្រឡំ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងការប្រឡូកប្រឡំ ជាអ្នកមានសេចក្តីរីករាយ ក្នុងបបញ្ចធម៌ គឺតណ្ហា ទិដ្ឋិ មានះ ត្រេកអរក្នុងបបញ្ចធម៌ ប្រកបរឿយៗ នូវសេចក្តីរីករាយនឹងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចនូវការនៅយ៉ាងណាៗ មរណៈមិនល្អ កាលកិរិយាក៏មិនល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរ ចំពោះសក្កាយ គឺវដ្តៈក្នុងត្រៃភូមិ មិនលះបង់សក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខ ដោយប្រពៃឡើយ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ ។ ម្នាលអាវុសោ គេកាលសម្រេចការនៅយ៉ាងណាៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ តើដោយប្រការដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិន

មានសេចក្ដីរីករាយក្នុងការងារ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយៗ នូវសេចក្ដីរីករាយក្នុងការងារ ជាអ្នកមិនមានសេចក្ដីរីករាយក្នុងការចរចា មិនត្រេកអរក្នុងការចរចា មិនប្រកបរឿយៗ នូវសេចក្ដីរីករាយក្នុងការចរចារ ជាអ្នកមិនមានសេចក្ដីរីករាយ ក្នុងការដេកលក់ មិនត្រេកអរក្នុងការដេកលក់ មិនប្រកបរឿយៗ នូវសេចក្ដីរីករាយក្នុងការដេកលក់ ជាអ្នកមិនរីករាយក្នុងពួកគណៈ មិនត្រេកអរក្នុងពួកគណៈ មិនប្រកបរឿយៗ នូវសេចក្ដីរីករាយក្នុងពួកគណៈ ជាអ្នកមិនរីករាយ ក្នុងការប្រឡូកប្រឡំ មិនត្រេកអរ ក្នុងការប្រឡូកប្រឡំ មិនប្រកបរឿយៗ នូវសេចក្ដីរីករាយ ក្នុងការប្រឡូកប្រឡំ ជាអ្នកមិនមានសេចក្ដីរីករាយ ក្នុងបបញ្ចធម៌ មិនត្រេកអរក្នុងបបញ្ចធម៌ មិនប្រកបរឿយៗ នូវសេចក្ដីរីករាយ ក្នុងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ មរណៈល្អ កាលកិរិយាក៏ល្អ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះព្រះនិព្វាន លះបង់ហើយនូវសក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃ ។

បុគ្គលណា ប្រកបរឿយៗ នូវបបញ្ចធម៌ ត្រេកអរ
ក្នុងបបញ្ចធម៌ ដូចជាម្រឹគ បុគ្គលនោះ ឈ្មោះថា
វៀរនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។
លុះតែបុគ្គលណា លះបង់នូវបបញ្ចធម៌ ត្រេកអរ
ក្នុងព្រះនិព្វាន ដែលមិនមានបបញ្ចធម៌ បុគ្គលនោះ

ឈ្មោះថា ញុំាងព្រះនិព្វាន ជាទីក្សេមចាកយោគៈ
ដ៏ប្រសើរឲ្យសម្រេចបាន ។

# អដ្ឋកថា

## ភទ្ទកសូត្រ

[ ១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភទ្ទកសូត្រទី ៤ ដូចតទៅនេះ បទថា **ន ភទ្ទកំ** សេចក្តីថា មិនបាន អធិប្បាយថា ក្នុង ២ យ៉ាងនោះ បុគ្គលណាខ្លាចច្រើន ហើយស្លាប់ បុគ្គលនោះ ឈ្មោះថា ស្លាប់មិនល្អ ។ បុគ្គលណាបដិសន្ធិក្នុងអបាយ បុគ្គលនោះ ឈ្មោះថា មានកាលកិរិយាមិនល្អ ។

ក្នុងបទថា **កម្មារាមោ** ជាដើម ដូច្នេះ វត្ថុដែលមកត្រេកអរ ឈ្មោះថា **អារាម** អធិប្បាយថា បានដល់ ត្រេកអរក្រៃលែង ។ បុគ្គលឈ្មោះថា **កម្មារាមោ** ព្រោះមានការត្រេកអរក្នុងនវកម្ម មានការសាងវិហារជាដើម ។ ឈ្មោះថា **កម្មរតោ** ព្រោះត្រេកអរក្នុងកម្មនោះៗ ឯង ។ ឈ្មោះថា **អនុ-យុត្តោ** ព្រោះប្រកបភាពដែលបុគ្គលមានកម្ម ដែលមកត្រេកអរនោះឯងរឿយៗ ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។

ការចរចាគ្នាអំពីរឿងស្ត្រី រឿងបុរស ឈ្មោះថា **ភស្ស** ក្នុងទីនេះ ។ បទថា **និទ្ទា** បានដល់ ការដេកលក់ ។ បទថា **សង្គណិកា** បានដល់

ជាអ្នកប្រឡូកប្រឡំដោយពួក ការប្រឡូកប្រឡំដោយពួកគណៈនោះ គប្បីជ្រាបដោយន័យជាដើមថា កាលមានបុគ្គលម្នាក់ ក៏បន្ថែមជាគម្រប់ ២ កាលមាន ២ នាក់ ក៏មានមនុស្សទី ៣ ។ បទថា **សំសគ្គោ** បានដល់ ភាពជាអ្នកជាប់ទាក់ទងគ្នា ប្រព្រឹត្តទៅហើយដោយអំណាចនៃការទាក់ទងគ្នា ដោយការស្ដាប់ ការឃើញ ការចរចា ការរួមគ្នានិងការទាក់ទងគ្នាផ្លូវកាយ ។

បទថា **បបញ្ចោ** បានដល់ កម្មជាគ្រឿងយឺតយូរ គឺកិលេសដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃតណ្ហា ទិដ្ឋិ និងមានះ ដែលតាំងនៅដោយការស្រវឹង ។ បទថា **សក្កាយំ** បានដល់ វដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **សម្មាទុក្ខស្ស អន្តកិរិយាយ** សេចក្ដីថា ដើម្បីធ្វើការកាត់ផ្ដាច់ផ្លូវនៃវដ្ដទុក្ខទាំងអស់ ដោយហេតុ ដោយន័យ ។ បទថា **មគោ** បានដល់ ដូចម្រឹគ ។ បទថា **និព្វបញ្ចបទេ** បានដល់ ក្នុងធម៌ជាគ្រឿងដល់នូវព្រះនិព្វាន ។ បទថា **អារាធយិ** សេចក្ដីថា ឲ្យបរិបូណ៌ បានដល់ ញុំាងវត្តបដិបត្តិនោះឲ្យដល់ព្រម ៕

## អដ្ឋកថាភទ្ទកសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនុតប្បិយសូត្រទី ៥

[ ១៥ ] ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចា នឹងពួកភិក្ខុក្នុងទីនោះថា ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយា ក៏រមែងក្តៅក្រហាយរឿយៗ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ ម្នាល អាវុសោទាំងឡាយ ចុះគេសម្រេចការនៅយ៉ាងណាៗ កាលកិរិយា ក៏រមែង ក្តៅក្រហាយរឿយៗ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីរីករាយក្នុង ការងារ ត្រេកអរក្នុងការងារ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងការងារ ជាអ្នកមានសេចក្តីរីករាយ ក្នុងការចរចា... ជាអ្នកមានសេចក្តីរីករាយក្នុងការ ដេកលក់...ជាអ្នកមានសេចក្តីរីករាយក្នុងពួកគណៈ...ជាអ្នកមានសេចក្តីរីករាយ ក្នុងការប្រឡូកប្រឡំ... ជាអ្នកមានសេចក្តីរីករាយក្នុងបបញ្ចធម៌ ត្រេកអរក្នុង បបញ្ចធម៌ ប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាល អាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏ក្តៅ ក្រហាយរឿយៗ ភិក្ខុសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាល អាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះសក្កាយ មិនលះបង់ សក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃឡើយ ។ ម្នាលអាវុសោទាំង-ឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏មិនក្តៅក្រហាយ រឿយៗ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ ។ ម្នាលអាវុសោទាំងឡាយ

ចុះគេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយាក៏មិនក្តៅក្រហាយរឿយៗ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ តើដូចម្តេច ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីរីករាយក្នុងការងារ មិនត្រេកអរក្នុងការងារ មិនប្រកបរឿយៗ នូវសេចក្តីរីករាយក្នុងការងារ ជាអ្នកមិនមានសេចក្តីរីករាយក្នុងការចរចា ។បេ។ ជាអ្នកមិនមានសេចក្តីរីករាយក្នុងការដេកកលក់ ជាអ្នកមិនមានសេចក្តីរីករាយក្នុងពួកគណៈ ជាអ្នកមិនមានសេចក្តីរីករាយក្នុងការប្រឡូកប្រឡំ ។បេ។ ជាអ្នកមិនមានសេចក្តីរីករាយក្នុងបបញ្ចធម៌ មិនត្រេកអរក្នុងបបញ្ចធម៌ មិនប្រកបរឿយៗ នូវសេចក្តីត្រេកអរក្នុងបបញ្ចធម៌ ។ ម្នាលអាវុសោទាំងឡាយ គេកាលសម្រេចការនៅយ៉ាងណាៗ កាលកិរិយា ក៏មិនក្តៅក្រហាយរឿយៗ ភិក្ខុរមែងសម្រេចការនៅយ៉ាងនោះៗ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ភិក្ខុអ្នកត្រេកអរចំពោះព្រះនិព្វាន លះបង់នូវសក្កាយ ដើម្បីធ្វើនូវទីបំផុតនៃទុក្ខដោយប្រពៃបាន ។

បុគ្គលណា ប្រកបរឿយៗ នូវបបញ្ចធម៌ ត្រេកអរក្នុង
បបញ្ចធម៌ ប្រាកដដូចជាម្រឹគ បុគ្គលនោះ ឈ្មោះថា វៀរនូវ
ព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរ ។ លុះតែបុគ្គល
ណា លះបង់នូវបបញ្ចធម៌ ត្រេកអរក្នុងព្រះនិព្វានដែលមិន
មានបបញ្ចធម៌ បុគ្គលនោះ ទើបឈ្មោះថា ញ៉ាំងព្រះ
និព្វាន ជាទីក្សេមចាកយោគៈ ដ៏ប្រសើរឲ្យសម្រេចបាន ។

# អដ្ឋកថា

## អនុតប្បិយសូត្រ

[ ១៥ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងអនុតប្បិយសូត្រទី ៥ ដូចតទៅនេះ បទថា* **អនុតប្បា** *សេចក្តីថា ត្រូវសេចក្តីសោកក្នុងកាលខាងក្រោយ គឺ ធ្វើនូវការក្តៅក្រហាយក្នុងកាលខាងក្រោយ ។ ក្នុងព្រះសូត្រទាំង ២ នេះក្តី ក្នុងគាថាទាំងឡាយក្តី ព្រះសារីបុត្រពោលទាំងវដ្តៈ និងវិវដ្តៈ ។ល។*

**អដ្ឋកថា អនុតប្បិយសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## នកុលបិតុសូត្រទី ៦

[ ១៦ ] *សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់សត្វម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ សម័យនោះឯង នកុលបិតាគហបតី មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ ។ គ្រានោះ នកុលមាតាគហបតានី បាននិយាយនឹងនកុលបិតាគហបតី ដូច្នេះថា បពិត្រគហបតី អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គលដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តី*

ត្រិះរិះយ៉ាងនេះថា អំណើះអំពីអញទៅ នកុលមាតាគហបតានី នឹងមិនអាច ដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ទាំងគ្រប់គ្រងនូវឃរាវាសបានឡើយ បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ខ្ញុំជាស្ត្រីប្រសប់រវៃកប្បាស ធ្មៀវធ្លាសបួងក្នុងសក់ បពិត្រគហបតី អំណើះអំពីអ្នកទៅ ខ្ញុំអាចដើម្បីចិញ្ចឹមនូវទារកទាំងឡាយ ទាំងគ្រប់គ្រងនូវឃរាវាសបាន បពិត្រគហបតី ព្រោះហេតុដូច្នោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណើះអំពីអញទៅ នកុលមាតាគហបតានី ជប់តែយកប្តីទៀត បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនោះឡើយ បពិត្រគហបតី អ្នកក្តី ខ្ញុំក្តី ក៏ដឹងថា ព្រហ្មចរិយធម៌របស់គ្រហស្ថយើងធ្លាប់សន្សំមកអស់ ១៦ ឆ្នាំហើយ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាល ទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ រមែងនាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណើះអំពីអញទៅ នកុលគហបតានី ជប់តែមិនចង់ឃើញ

ព្រះដ៏មានព្រះភាគ មិនចង់ឃើញព្រះភិក្ខុសង្ឃ បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ជឿចុះអំណឹះអំពីអ្នកទៅ ខ្ញុំនឹងរឹងរឹតតែចង់ឃើញព្រះដ៏មានព្រះភាគផង នឹងរឹងរឹតតែចង់ឃើញព្រះភិក្ខុសង្ឃផង បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា អំណឹះអំពីអញទៅ នកុលមាតាគហបតី ថប់តែលែងបំពេញសីលទាំងឡាយ បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ពួកស្រ្តីគ្រហស្ថ ជាសាវិការបស់ព្រះដ៏មានព្រះភាគអង្គនោះ ទាំងប៉ុន្មាននាក់ ជាស្រ្តីស្លៀកដណ្តប់សំពត់ស បំពេញសីលទាំងឡាយ បណ្តាពួកសាវិកាទាំងនោះ ខ្ញុំជាសាវិកាមួយដែរ ( រឿងនេះ ) បើបុគ្គលណាមានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់គង់នៅភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះចូរចូលទៅគាល់ព្រះដ៏មានព្រះភាគនោះ ហើយសួរល្បងចុះ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាល ទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែល

ប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ បពិត្រគហបតី អ្នកប្រហែលជាមានសេចក្តីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានីជាស្រ្តីមិនបាននូវចេតោសមថៈក្នុងសន្តាន បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ បពិត្រគហបតី ពួកស្រ្តីគ្រហស្ថ ជាសាវិការបស់ព្រះដ៏មានព្រះភាគ ទាំងប៉ុន្មាននាក់ ជាស្រ្តីស្លៀកដណ្តប់សំពត់ស បាននូវចេតោសមថៈក្នុងសន្តាន បណ្តាពួកសាវិកាទាំងនុ៎ះ ខ្ញុំក៏ជាសាវិកាមួយដែរ ( រឿងនេះ ) បើបុគ្គលណាមានសេក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់គង់នៅក្នុងភេសកឡាវន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ បុគ្គលនោះ ចូរចូលទៅគាល់ព្រះដ៏មានព្រះភាគនោះ ហើយសួរល្បងចុះ បពិត្រគហបតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាល ទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តីអាល័យ ព្រះដ៏មានព្រះភាគ ទ្រង់តិះដៀលផង ។ បពិត្រគហបតី ប្រហែលជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា នកុលមាតាគហបតានី មិនទាន់ដល់នូវការចុះចិត្តស៊ប់ មិនទាន់ដល់នូវទីពឹង មិនទាន់ដល់នូវការកក់ក្តៅ មិនទាន់ឆ្លងផុតសេចក្តីសង្ស័យ មិនទាន់ប្រាសចាកសេចក្តីងឿងឆ្ងល់ មិនទាន់ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនទាន់លែងជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បពិត្រគហបតី ដំណើរនុ៎ះ អ្នកមិនត្រូវយល់ឃើញយ៉ាងនុ៎ះឡើយ

បពិត្រគហបតី ពួកស្ត្រីគ្រហស្ថជាសាវិការបស់ព្រះដ៏មានព្រះភាគ ទាំងប៉ុន្មាន នាក់ ជាស្ត្រីស្លៀកដណ្តប់សំពត់ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹង ដល់នូវការកក់ក្តៅ មានសេចក្តីសង្ស័យច្ងងផុតហើយ ប្រាសចាកសេចក្តីងឿង ឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុង សាសនានៃព្រះសាស្តា បណ្តាសាវិកាទាំងនុ៎ះ ខ្ញុំជាសាវិកាមួយដែរ ( រឿង នេះ ) បើបុគ្គលណា មានសេចក្តីសង្ស័យក្តី មានសេចក្តីងឿងឆ្ងល់ក្តី ព្រះ ដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់គង់នៅក្នុង ភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងសុំសុមារគីរៈ ក្នុងភគ្គជនបទ បុគ្គលនោះ ចូរចូលទៅគាល់ព្រះដ៏មានព្រះភាគអង្គនោះ ហើយសួរល្បងចុះ ។ បពិត្រគបហតី ព្រោះហេតុនោះ អ្នកកុំធ្វើមរណកាលទាំងសេចក្តីអាល័យឡើយ បពិត្រគហបតី ( ព្រោះ ) កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តី អាល័យ នាំមកនូវទុក្ខផង កាលកិរិយារបស់បុគ្គល ដែលប្រកបដោយសេចក្តី អាល័យ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលផង ។ លំដាប់នោះ នកុលបិតាគហបតី ដែលនកុលមាតាគហបតានីទូន្មានដោយឱវាទនេះ អាពាធនោះ ក៏ស្ងប់រម្ងាប់ ដោយឋានៈ ទាំងនកុលបិតាគហបតី ក៏សះស្បើយចាកអាពាធនោះ ។ អាពាធ នោះ ជាស្រឡះអំពីនកុលបិតាគហបតីហើយ ។ លុះនកុលបិតាគហបតីស្បើយ ចាកជំងឺ ក្រោកចាកជំងឺ មិនយូរប៉ុន្មាន ក៏ច្រត់នូវឈើច្រត់ ចូលទៅគាល់ ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះនកុលបិតាគហបតី អង្គុយក្នុងទីដ៏សមគួរ

ហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ជាអ្នកទូន្មានប្រៀនប្រដៅ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថជាសាវិកា របស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស បំពេញសីលទាំងឡាយ បណ្តាពួកសាវិកាទាំងនុ៎ះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថ ជាសាវិការបស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស បាននូវចេតោសមថៈក្នុងសន្តាន បណ្តាពួកសាវិកាទាំងនុ៎ះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី ពួកស្ត្រីគ្រហស្ថ ជាសាវិការបស់តថាគតទាំងប៉ុន្មាននាក់ ជាអ្នកស្លៀកដណ្តប់សំពត់ស ដល់នូវការចុះចិត្តស៊ប់ ដល់នូវទីពឹងមាំ ដល់នូវការកក់ក្តៅ មានសេចក្តីសង្ស័យឆ្លងផុតហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម្មវិន័យនេះ មិនជឿតាមបុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បណ្តាពួកសាវិកាទាំងនុ៎ះ នកុលមាតាគហបតានី ជាសាវិកាមួយដែរ ម្នាលគហបតី អ្នកពេញជាមានលាភហើយ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានល្អហើយ ត្រង់ដែលអ្នកបាននកុលមាតាគហបតានី មកជាអ្នកអនុគ្រោះ ប្រាថ្នានូវប្រយោជន៍ ទូន្មានប្រៀនប្រដៅ ។

# អដ្ឋកថា

## នកុលបិតុសូត្រ

[ ១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនកុលបិតុសូត្រទី ៦ ដូចតទៅនេះ បទថា **ពាឡ្ហគិលានោ** ប្រែថា មានជំងឺជាទម្ងន់ ។ បទថា **ឯតទវោច** សេចក្ដីថា គហបតានីដែលជានកុលមាតា កាលមិនអាចដាក់ថ្នាំ រម្ងាប់ព្យាធិរបស់ប្ដីបាន ឥឡូវនេះ កាលរម្ងាប់ព្យាធិក្នុងការបន្លឺសីហនាទ ធ្វើសច្ចកិរិយា ទើបអង្គុយក្បែរប្ដី ហើយពោលពាក្យជាដើម **មា ខោ ត្វំ** ដូច្នេះ ។ បទថា **សាបេក្ខោ** បានដល់ នៅមានតណ្ហា ។ **ន** អក្ខរៈ ក្នុងបទថា **ន នកុលមាតា** នេះ ត្រូវប្រកបចូលដោយបទក្រោយយ៉ាងនេះថា **ន បេក្ខតិ** ។ បទថា **សណ្ឋាបេតុំ** សេចក្ដីថា ដើម្បីធ្វើមិនឲ្យមានឱកាស អធិប្បាយថា ក្រាលឲ្យពេញ ។ បទថា **វេណឹ ឱលិខិតុំ** សេចក្ដីថា ដើម្បីត្រៀមរោមចៀម យកមកត្រដោះធ្វើឲ្យជារមូរ ។ បទថា **អញ្ញំ ភត្តារំ គមិស្សតិ** សេចក្ដីថា ខ្ញុំនឹងមានប្ដីថ្មីទៀត ។ បទថា **សោឡសវស្សានិ គហដ្ឋព្រហ្មចរិយំ សមាចិណ្ណំ** សេចក្ដីថា រាប់ថយក្រោយអំពីនេះ ១៦ ឆ្នាំ ខ្ញុំបានប្រព្រឹត្តព្រហ្មចរិយៈ របស់គ្រហស្ថយ៉ាងស្មោះស្មើ ។ បទថា **ទស្សនកាមតរា** សេចក្ដីថា ចង់គាល់ក្រៃលែងឡើងទៅ នាងបានបន្លឺសីហនាទដោយអង្គ ៣ នេះហើយ បានធ្វើសច្ចកិរិយាថា ដោយពាក្យសត្យនេះ សូមព្យាធិក្នុងរាងកាយរបស់អ្នក ជាសះស្បើយ ដល់នូវផាសុកចុះ ។

ឥឡូវនេះ ដើម្បីយកព្រះមានព្រះភាគជាបន្ទាល់ ធ្វើសច្ចកិរិយាដោយគុណ

មានសីលជាដើមរបស់ខ្លួន ទើបនាងពោលពាក្យជាដើមថា **សិយា ខោ បន តេ** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **បរិបូរការិនី** បានដល់ ធ្វើឲ្យសម្បូរ ។ បទថា **ចេតោសមថស្ស** បានដល់ សមាធិកម្មដ្ឋាន ។ បទថា **ឱគាធប្បត្តា** បានដល់ ដល់នូវការឈមចុះ គឺចូលដល់រឿយៗ ។ បទថា **បដិគាធប្បត្តា** បានដល់ ដល់នូវការចុះស៊ប់ចំពោះ គឺមាំទាំ ។ បទថា **អស្សាសប្បត្តា** បានដល់ ដល់នូវការទូលាយ គឺយកជាទីពឹងបាន ។ បទថា **វេសារជ្ជប្បត្តា** បានដល់ ដល់នូវសោមនស្សញ្ញាណ ។ បទថា **អបរប្បច្ចយា** សេចក្ដីថា សទ្ធាទាក់ទងដោយអ្នកដទៃ គឺបដិបទាដែលត្រូវអាស្រ័យអ្នកដទៃ លោកហៅថា **បរប្បច្ចយ** គឺមានអ្នកដទៃជាបច្ច័យ អធិប្បាយថា វៀរចាកការមានអ្នកដទៃជាបច្ច័យនោះ ។

គហបតានី ដែលជាមាតារបស់នកុលមាណព បានធ្វើសច្ចកិរិយា ប្រារព្ធគុណរបស់ខ្លួនដោយអង្គ ៣ នេះ ។ បទថា **គិលានា វុដ្ឋិតោ** សេចក្ដីថា កើតជំងឺ ហើយជា ។ បទថា **យាវតា** បានដល់ គណៈនៃអ្នកបំពេញព្យាយាម ។ បទថា **តាសំ អញ្ញតរា** បានដល់ ជាបុគ្គលម្នាក់ ក្នុងរវាងសាវិកាទាំងនោះ ។ បទថា **អនុកម្បិកា** បានដល់ ដែលអនុគ្រោះដោយប្រយោជន៍ ។ បទថា **ឱវាទិកា** បានដល់ ជាអ្នកឲ្យឱវាទ ។ បទថា **អនុសាសិកា** បានដល់ ជាអ្នកឲ្យនូវពាក្យប្រៀនប្រដៅ ។ល។

## អដ្ឋកថា នកុលបិតុសូត្រទី ៦ ចប់

# សុត្តន្តបិដក

## កុសលសូត្រទី ៧

[ ១៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ចូលទៅឯឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ ចំណែកព្រះសារីបុត្តដ៏មានអាយុ ក៏ចេញអំពីទីសម្ងំក្នុងសាយណ្ហសម័យ ហើយចូលទៅឯឧបដ្ឋានសាលាដែរ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ទាំងព្រះមោគ្គល្លានដ៏មានអាយុ ព្រះមហាកស្សបៈដ៏មានអាយុ ព្រះមហាកច្ចានៈដ៏មានអាយុ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ ព្រះមហាចុន្ទដ៏មានអាយុ ព្រះមហាកប្បិនដ៏មានអាយុ ព្រះអនុរុទ្ធដ៏មានអាយុ ព្រះរេវតៈដ៏មានអាយុ ព្រះអានន្ទដ៏មានអាយុ ក៏ចេញអំពីទីសម្ងំក្នុងសាយណ្ហ-សម័យ ហើយចូលទៅឯឧបដ្ឋានសាលាដែរ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់គង់កន្លងវេលារហូតយប់ជ្រៅ ហើយក៏ទ្រង់ក្រោកចាកអាសនា ស្តេចទៅកាន់វិហារ ។ ពួកព្រះថេរៈដ៏មានអាយុទាំងនោះ កាលដែលព្រះដ៏មានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ក៏ក្រោកចាកអាសនៈ ទៅកាន់លំនៅនៃខ្លួនៗ ។ ចំណែកពួកភិក្ខុណា ដែលនៅក្នុងឧបដ្ឋានសាលានោះ ជាភិក្ខុថ្មី បួសមិនទាន់អស់កាលយូរប៉ុន្មាន ទើបនឹងមកកាន់ធម្មវិន័យនេះ ពួកភិក្ខុ

ទាំងនុ៎ះ ក៏សិងស្រមុកលទ់លក់ដរាបដល់ព្រះអាទិត្យរះឡើង ។ ព្រះដ៏មានព្រះភាគ បានឃើញពួកភិក្ខុទាំងនុ៎ះ កំពុងសិងស្រមុកលទ់លក់ ដរាបដល់ព្រះអាទិត្យរះឡើង ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សសាមញ្ញ លុះឃើញហើយ ក៏យាងចូលទៅឯឧបដ្ឋានសាលា លុះយាងចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ស៊ប់ហើយ ក៏ត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តទៅក្នុងទីណា មោគ្គល្លានទៅក្នុងទីណា មហាកស្សបៈទៅក្នុងទីណា មហាកច្ចានៈទៅក្នុងទីណា មហា-កោដ្ឋិកៈទៅក្នុងទីណា មហាចុន្ទទៅក្នុងទីណា មហាកប្បិនទៅក្នុងទីណា អនុរុទ្ធទៅក្នុងទីណា រេវតៈទៅក្នុងទីណា អានន្ទទៅក្នុងទីណា ម្នាលភិក្ខុទាំងឡាយ ពួកសាវកជាថេរៈទាំងនោះ ទៅក្នុងទីណា បាត់អស់អេះ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គស្តេចចេញទៅមិនយូរប៉ុន្មាន ពួកលោកទាំងនោះ ក៏ក្រោកចាកអាសនៈ ហើយទៅកាន់លំនៅនៃខ្លួនៗ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយជាថេរៈ ឬជាភិក្ខុថ្មី សុទ្ធតែដេកស្រមុកលទ់លក់ ដរាបដល់ព្រះអាទិត្យរះឡើង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់នូវហេតុនោះ ថាដូចម្តេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា ព្រះរាជាជាក្សត្រ ដែលបានមុទ្ធាភិសេកហើយ ទ្រង់សព្វព្រះរាជហឫទ័យ តែខាងសុខអំពីការផ្ទំ សុខអំពីការផ្អែក សុខអំពីផ្ទំលក់ទាល់តែស្កប់ស្កល់ សោយរាជ្យដរាបដល់អស់ព្រះជន្មហើយ បានជាទីស្រឡាញ់ពេញចិត្ត នៃអ្នកជនបទដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ

ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ដំណើរនោះ សូម្បីតថាគតក៏មិនដែលឃើញ មិនដែលឮថា ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ទ្រង់សព្វព្រះរាជហឫទ័យ តែខាងសុខអំពីទីការផ្ទុំ សុខអំពីការផ្អែក សុខអំពីផ្ទុំលក់ទាល់តែស្កប់ស្កល់ សោយរាជ្យដរាបដល់អស់ព្រះជន្មហើយ បានជាទីស្រឡាញ់ពេញចិត្ត នៃអ្នកជនបទដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះថា ដូចម្ដេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកជំក្នុងដែន អ្នកប្រើប្រាស់ទ្រព្យជាដំណែលបិតា ជាសេនាបតី ជាចៅហ្វាយស្រុក អ្នកជាធំលើប្រជាជន ចូលចិត្តតែខាងសុខអំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់ទាល់តែស្កប់ស្កល់ គ្រាន់តែទទួលតំណែងជាចៅហ្វាយស្រុកនៃប្រជាជនដរាបដល់អស់ជីវិតហើយ បានជាទីស្រឡាញ់ពេញចិត្តនៃប្រជាជនដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគតក៏មិនដែលឃើញ មិនដែលឮថា អ្នកជាធំលើប្រជាជន ចូលចិត្តតែខាងសុខអំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់ទាល់តែស្កប់ស្កល់ ទទួលតំណែងជាចៅហ្វាយស្រុកនៃប្រជាជន ដរាបដល់អស់ជីវិត ហើយបានជាទីស្រឡាញ់ ជាទីពេញចិត្តនៃប្រជាជនដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនុ៎ះថាដូចម្ដេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា សមណៈក្ដី ព្រាហ្មណ៍ក្ដី ខ្វល់ខ្វាយតែខាងសុខ អំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់ទាល់តែស្កប់ស្កល់ ជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មិនដឹង

ប្រមាណក្នុងភោជន មិនប្រកបនូវការភ្ញាក់រឭក មិនពិចារណារកកុសលធម៌ទាំងឡាយ ក្នុងកាលជាខាងដើមរាត្រី និងកាលជាខាងចុងរាត្រី មិនខ្វល់ខ្វាយនូវការព្យាយាម ចម្រើនពោធិបក្ខិយធម៌ទាំងឡាយទេ ហើយអាចធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ដូច្នេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា សមណៈក្តី ព្រាហ្មណ៍ក្តី ខ្វល់ខ្វាយតែខាងសុខ អំពីការដេក សុខអំពីការផ្អែក សុខអំពីការដេកលក់ ទាល់តែស្កប់ស្កល់ ជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ មិនស្គាល់ប្រមាណក្នុងភោជន មិនប្រកបរឿយៗនូវការភ្ញាក់រឭក មិនពិចារណា រកកុសលធម៌ទាំងឡាយ ក្នុងកាលជាដើមរាត្រី និងកាលជាខាងចុងរាត្រី មិនខ្វល់ខ្វាយនូវការព្យាយាម ចម្រើនពោធិបក្ខិយធម៌ទាំងឡាយទេ ហើយអាចធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអសវៈ ព្រោះអស់អាសវៈ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ដូច្នេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងគួរជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្គាល់ប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រឭក ជាអ្នកពិចារណានូវកុសលធម៌ទាំងឡាយ ក្នុងកាលជាខាងដើមរាត្រី និងកាលខាងចុងរាត្រី គួរខ្វល់ខ្វាយនូវការព្យាយាម ចម្រើនពោធិបក្ខិយធម៌

ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សា យ៉ាងនេះឯង ។

# អដ្ឋកថា

## កុសលសូត្រ

[ ១៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកុសលសូត្រទី ៧ ដូចតទៅនេះ បទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ចេញអំពីវិហារធម៌ គឺផលសមាបត្តិ ដែលអត់ធន់ចំពោះការសម្លឹងធម៌ ដើម្បីភាពជាបុគ្គលម្នាក់ឯង ។ បទថា **យេនាវិហារំ** បានដល់ វិហារដែលជាលំនៅរបស់ខ្លួន ។ បទថា **នវា** បានដល់ នៅថ្មីចំពោះបព្វជ្ជា ភិក្ខុទាំងនោះមានប្រមាណ ៥០០ រូប ។

បទថា **កាកច្ឆមានា** បានដល់ ធ្វើសំឡេងក្រឹតៗ គឺដេកសង្កៀតធ្មេញ ។ បទថា **ថេរា** បានដល់ ភិក្ខុដែលដល់នូវភាពជាបុគ្គលមាំទាំ ។ បទថា **តេន នោ** ប្រែថា អ្នកទាំងឡាយជាព្រះថេរៈបានដូចម្តេចហ្ន៎ ។ បទថា **សេយ្យសុខា** ជាដើម មានអត្ថដូចពោលហើយខាងដើមនោះឯង ។ អ្នកគ្រប់គ្រងរដ្ឋ ឈ្មោះថា **រដ្ឋិកោ** ។ អ្នកគ្រប់គ្រងរដ្ឋជាប់ទាក់ទងអំពីមាតាបិតាគ្រប់គ្រង ឈ្មោះថា **បេត្តណិកោ** ។ បុគ្គលជាប្រធាននៃសេនា ឈ្មោះថា **សេនាបតិក** អ្នកគ្រប់គ្រងស្រុក ឈ្មោះថា **គាមគាមណិកោ** ។ បុគ្គលដែលជាប្រធានក្រុម ឈ្មោះថា **បូគគាមណិកោ** ។

បទថា **អាវិបស្សកោ កុសលានំ ធម្មានំ** សេចក្តីថា ជាអ្នកមិនស្វែងរក

គឺមិនស្វែងរកកុសលធម៌ទាំងឡាយ ។ បទថា **ពោធិបក្ខិយានំ ធម្មានំ** បាន ដល់ ពោធិបក្ខិយធម៌ ៣៧ ប្រការ ។៙

## អដ្ឋកថាកុសលសូត្រទី ៧ ចប់

# សុត្តន្តបិដក

## មច្ឆសូត្រទី ៨

[ ១៨ ] សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចទៅកាន់ចារិក ក្នុងដែនកោសល មួយអន្លើដោយភិក្ខុសង្ឃច្រើនរូប ។ កាលព្រះដ៏មានព្រះភាគស្តេចទៅកាន់ផ្លូវឆ្ងាយ បានឃើញព្រានត្រី អ្នកចាប់ត្រី កំពុងកាប់សម្លាប់ត្រីលក់ ក្នុងប្រទេសមួយ លុះទតឃើញហើយ ស្តេចចេញអំពីផ្លូវទៅគង់លើអាសនៈដែលគេក្រាលទុក ទៀបគល់ឈើមួយដើម ។ លុះព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ក៏បានត្រាស់នឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញព្រានត្រី អ្នកចាប់ត្រីឯណោះ កំពុងកាប់សម្លាប់ត្រីលក់ដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់នូវហេតុនោះដូចម្តេច អ្នកទាំងឡាយធ្លាប់ឃើញ ឬធ្លាប់ឮថា បុគ្គលជាព្រានត្រី អ្នកចាប់ត្រីសម្លាប់ត្រីលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ ឬនៅគ្រប់គ្រងនូវគំនរភោគ-

សម្បត្តិដ៏ច្រើន ព្រោះអំពើបែបនោះ ព្រោះការចិញ្ចឹមជីវិត បែបនោះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ សូម្បីតថាគត ក៏មិនធ្លាប់ឃើញ មិនធ្លាប់ឮថា បុគ្គលជាព្រានត្រី អ្នកចាប់ត្រី សម្លាប់ត្រីលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវគំនរ ភោគសម្បត្តិដ៏ច្រើន ព្រោះអំពើបែបនោះ ព្រោះការចិញ្ចឹមជីវិតបែបនោះ ដូច្នេះដែរ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រានត្រីនោះតែងរំពៃរកត្រី ដែលខ្លួនត្រូវសម្លាប់នាំមកដើម្បីសម្លាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ ព្រាននោះ ទើបជាអ្នកមិនបានទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបានគ្រប់គ្រងនូវគំនរភោគសម្បត្តិដ៏ច្រើនឡើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ហេតុនោះដូចម្តេច អ្នកទាំងឡាយ ធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកពិឃាតគោ សម្លាប់គោលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងនូវគំនរ ភោគសម្បត្តិដ៏ច្រើន ព្រោះអំពើបែបនោះ ព្រោះការចិញ្ចឹមជីវិតបែបនោះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនធ្លាប់ឃើញ មិនធ្លាប់ឮថា អ្នកពិឃាតគោ សម្លាប់គោលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ

ទៅដោយរថ ទៅដោយយាន ឬបានជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ដូច្នេះដែរ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អ្នកពិឃាតគោនោះ រមែងរំពៃរកគោ ដែលខ្លួនត្រូវសម្លាប់ ដែលខ្លួននាំមកដើម្បីសម្លាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ អ្នកពិឃាតគោនោះ ទើបមិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិននៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់ហេតុនោះ ដូចម្តេច អ្នកទាំងឡាយ ធ្លាប់ឃើញ ឬធ្លាប់ឮថា អ្នកសម្លាប់កែះ ។បេ។ អ្នកសម្លាប់ជ្រូក អ្នកសម្លាប់សត្វស្លាប អ្នកសម្លាប់ម្រឹគ ដែលសម្លាប់ម្រឹគលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ដោយអំពើបែបនោះ ដោយការចិញ្ចឹមជីវិតបែបនោះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ហេតុនុ៎ះ សូម្បីតថាគត ក៏មិនដែលឃើញ មិនដែលឮថា អ្នកសម្លាប់ម្រឹគ ដែលសម្លាប់ម្រឹគលក់ បានជាអ្នកទៅដោយដំរី ទៅដោយសេះ ទៅដោយរថ ទៅដោយយាន ឬជាអ្នកបរិភោគនូវភោគសម្បត្តិ នៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ដូច្នេះដែរ ។ ដំណើរនុ៎ះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា ព្រានម្រឹគនោះ រមែងរំពៃរកម្រឹគ ដែលខ្លួនត្រូវសម្លាប់ ដែលខ្លួននាំមក ដើម្បីសម្លាប់នោះ ដោយចិត្តអាក្រក់ ព្រោះហេតុនុ៎ះ ព្រាន

ម្រឹគនោះ មិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបាននៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះព្រាននោះរមែងរំពៃរកសត្វតិរច្ឆានទាំងនោះ ដែលខ្លួនត្រូវសម្លាប់ ដែលខ្លួននាំមកដើម្បីសម្លាប់ ដោយចិត្តអាក្រក់ ព្រោះហេតុនោះ បានជាព្រានម្រឹគនោះ មិនបានជាអ្នកទៅដោយដំរី មិនបានទៅដោយសេះ មិនបានទៅដោយរថ មិនបានទៅដោយយាន មិនបានជាអ្នកបរិភោគនូវភោគសម្បត្តិ មិនបាននៅគ្រប់គ្រងគំនរភោគសម្បត្តិដ៏ច្រើន ចាំបាច់និយាយថ្វីដល់បុគ្គលដែលសម្លឹងរកមនុស្ស ដែលខ្លួនត្រូវសម្លាប់ ដែលខ្លួននាំមកដើម្បីសម្លាប់ដោយចិត្តអាក្រក់ ម្នាលភិក្ខុទាំងឡាយ ដ្បិតការសម្លឹងរកបែបនោះ រមែងប្រព្រឹត្តទៅ មិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែងដល់បុគ្គលនោះ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។

# អដ្ឋកថា

## មច្ឆសូត្រ

[ ១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមច្ឆសូត្រទី ៨ ដូចតទៅនេះ បទថា **មច្ឆិកំ** បានដល់ អ្នកសម្លាប់ត្រី ។ បុគ្គលឈ្មោះថា **ហាត្ថិយាយី** ព្រោះ

ទៅដោយដំរី សត្វខាងមុខក៏មានន័យដូច្នេះ ។ បទថា **វជ្ឈេ** ប្រែថា ដែលត្រូវសម្លាប់ ។ បទថា **វធាយានីតេ** សេចក្តីថា សត្វដែលគេនាំទៅដើម្បីសម្លាប់ ។ បទថា **ចាបកេន មនសា** សេចក្តីថា ដោយចិត្តដែលគិតសម្លាប់ដ៏លាមក ។ តែក្នុងព្រះបាលី លោកបានរចនាថា **វធាយុបនីតេ** ។ បទថា **មាគវិកោ** បានដល់ អ្នកសម្លាប់ម្រឹគ ។

បទថា **កោ បន វាទោ មនុស្សភូតំ** សេចក្តីថា សម្រាប់អ្នកមានចិត្តលាមក ចូលទៅសម្លឹងមនុស្ស មិនមានអ្វីដែលត្រូវពោលដល់ ក្នុងការមិនមានសម្បត្តិ សេចក្តីនេះ ព្រះមានព្រះភាគ ត្រាស់ដើម្បីសម្តែងដល់ភាពដែលបាបកម្ម មានផលមិនគួរប្រាថ្នា តែកាលបុគ្គលណា ធ្វើបាបកម្មបែបនោះ បុគ្គលនោះបែរជាបានយស សេចក្តីនោះគប្បីយល់ថា កុសលឲ្យផលដល់បុគ្គលទាំងនោះ ដោយអាស្រ័យអកុសលនោះ តែវិបាកមិនស្ថិតស្ថេរអស់កាលយូរ ព្រោះបុគ្គលនោះ ត្រូវអកុសលកម្មនោះកាត់ផ្តាច់ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ធម៌ដែលជាចំណែកអកុសលតែម្យ៉ាង ៕

## អដ្ឋកថាមច្ឆសូត្រទី ៨ ចប់

# សុត្តន្តបិដក

## បឋមមរណស្សតិសូត្រទី ៩

[ ១៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទឥដ្ឋ ទៀបនាទិកគ្រាម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិ ឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ ចម្រើននូវមរណស្សតិដែរឬ ។ និមិត្តតែព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ភិក្ខុ ១ រូប ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះករុណា ចម្រើននូវមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើននូវមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅតែត្រឹមមួយយប់មួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើនូវកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិ យ៉ាងនេះឯង ។ ភិក្ខុ ១ រូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើន

មរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គ បានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើនូវកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុ ១ រូបទៀត ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញបរិភោគបិណ្ឌបាត ១ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុ ១ រូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេបពំនូតបាយ ៤ ពំនូត ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិយ៉ាងនេះឯង ។

ភិក្ខុ ១ រូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ បែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គបានតាំងចិត្តទុក យ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេប ពំនូតបាយមួយពំនូត ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះឯង ។ ភិក្ខុ ១ រូបទៀត ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើននូវមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិបែបណា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គ បានតាំងចិត្តទុកយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញដកដង្ហើមចេញ ហើយដកដង្ហើមចូលវិញ ឬដកដង្ហើមចូល ហើយដកដង្ហើមចេញវិញ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះឯង ។ កាលដែលភិក្ខុនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ បានត្រាស់នឹងពួកភិក្ខុដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ យ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយយប់មួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់

នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែត្រឹមមួយថ្ងៃ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញបរិភោគបិណ្ឌបាត ១ ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិយ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេបពំនូតបាយ ៤ ឬ ៥ ពំនូត ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុទាំងនេះ ហៅថា ជាអ្នកប្រមាទ ចម្រើនមរណស្សតិយ៉ាងទន់ខ្សោយ ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ យ៉ាងនេះថា ឱហ្ន៎ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញទំពាលេបពំនូតបាយមួយពំនូត ( ដូច្នេះ ) អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិយ៉ាងនេះថា

ឱហ្ន៍ អញមុខជានឹងរស់នៅ តែក្នុងខណៈដែលអញដកដង្ហើមចេញ ហើយដកដង្ហើមចូលវិញ ឬដកដង្ហើមចូលហើយ ដកដង្ហើមចេញវិញដូច្នេះ អញគប្បីយកចិត្តទុកដាក់ នូវសាសនារបស់ព្រះដ៏មានព្រះភាគ អញគប្បីធ្វើកិច្ច ( ក្នុងសាសនារបស់ព្រះដ៏មានព្រះភាគ ) ឲ្យបានច្រើនក្តី ម្នាលភិក្ខុទាំង-ឡាយ ពួកភិក្ខុទាំងនោះ ទើបហៅថា ជាអ្នកមិនប្រមាទ ចម្រើននូវមរណស្សតិ យ៉ាងក្លៀវក្លា ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ គួរជាអ្នកមិនប្រមាទ គួរចម្រើនមរណស្សតិយ៉ាងក្លៀវក្លា ដើម្បីឲ្យអស់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។

# អដ្ឋកថា

## បឋមមរណស្សតិសូត្រ

[ ១៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមមរណស្សតិសូត្រទី ៩ ដូចតទៅនេះ បទថា **នាតិកេ** បានដល់ ក្នុងស្រុកដែលមានឈ្មោះយ៉ាងនេះ ។ បទថា **គិញ្ជកាវសថេ** បានដល់ ក្នុងប្រាសាទដែលធ្វើដោយឥដ្ឋ ។ បទថា **អមតោគធា** បានដល់ ឈមចុះកាន់ព្រះនិព្វាន អធិប្បាយថា ចូលកាន់ព្រះនិព្វាន ។ បទថា **អហោ វត** ជានិបាត ចុះក្នុងអត្ថថា ទីបំផុត ។ បទថា

**ភាវេថ នោ** ប្រែថា ចូរចម្រើនចុះ ។ បទថា **មរណស្សតឹ** បានដល់ មរណស្សតិកម្មដ្ឋាន ។ សព្ទថា **អហោ វត** ជានិបាត ចុះក្នុងអត្ថថា ប្រាថ្នា ។ បទថា **ពហុ វត មេ កតំ អស្ស** សេចក្តីថា កិច្ចរបស់ខ្ញុំព្រះអង្គ ក្នុងសាសនារបស់ព្រះអង្គ គប្បីជាកិច្ចដែលខ្ញុំព្រះអង្គធ្វើឲ្យច្រើន ។ បទថា **តទន្តរំ** សេចក្តីថា ក្នុងរវាង គឺខណៈ បានដល់ ឱកាសនោះ ។ ក្នុងបទថា **អស្សសិត្វា វា បស្សសាមិ** នេះ ខ្យល់ដែលចូលទៅខាងក្នុង លោកហៅថា **អស្សាស** ខ្យល់ដែលចេញមកខាងក្រៅ លោកហៅថា **បស្សាស**។ ភិក្ខុនេះប្រាថ្នាឲ្យជីវិតតាំងនៅមួយជួរកាលដែលខ្យល់ចូលទៅខាងក្នុង ត្រឡប់ចេញមកខាងក្រៅ ខ្យល់ដែលចេញទៅខាងក្រៅ ត្រឡប់ចូលមកខាងក្នុង ទើបបានទូលយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **ឧទ្ធំ** បានដល់ ប្រព្រឹត្តទៅយឺតពេក គឺមិនរហ័ស ។ បទថា **អាសវានំ ខយាយ** បានដល់ ដើម្បីអរហត្តផល ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់មរណស្សតិ រហូតដល់អរហត្តផល ។៚

## អដ្ឋកថាបឋមមរណស្សតិសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយមរណស្សតិសូត្រទី ១០

[ ២០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទឥដ្ឋ ទៀបនាទិកគ្រាម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុដែលនៅក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ចុះមរណស្សតិដែលភិក្ខុចម្រើនហើយ ដោយប្រការដូចម្តេច ធ្វើឲ្យច្រើនហើយដោយប្រការដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ កាលបើថ្ងៃអស្តង្គតហើយ រាត្រីក៏ដល់មក ភិក្ខុក្នុងសាសនានេះពិចារណាដូច្នេះថា បច្ច័យនៃសេចក្តីស្លាប់របស់អញ មានច្រើនណាស់ គឺពស់នឹងចឹកអញ ឬខ្ទួយនឹងទិចអញ ក្អែបនឹងខាំអញ អញគប្បីធ្វើមរណកាលដោយហេតុនោះ សេចក្តីអន្តរាយនោះ នឹងមានដល់អញ អញនឹងភ្លាត់ដួល ឬបាយដែលអញបរិភោគហើយ នឹងឲ្យទោស ប្រមាត់របស់អញ នឹងកម្រើក ស្លេស្មរបស់អញនឹងកម្រើក ខ្យល់មានអាការដូចកាំបិតកោរ របស់អញនឹងកម្រើក អញគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្តីអន្តរាយនោះនឹងមានដល់អញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គួរពិចារណាដូច្នេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹង

នាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាលក្នុងវេលារាត្រី តើមានឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុ កាលពិចារណាទៅ ដឹងយ៉ាងនេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាលក្នុងវេលារាត្រី ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង កាលប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលត្រូវភ្លើងឆេះសំពត់ក្តី ឆេះក្បាលក្តី ធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលត់ភ្លើង ( ដែលឆេះ ) សំពត់ ឬក្បាលនោះចេញ សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុកាលពិចារណាទៅ ដឹងយ៉ាងនេះវិញថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាលក្នុងវេលារាត្រីមិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីជាអ្នកសិក្សារឿយៗ ក្នុងកុសលធម៌ទាំងឡាយ ទាំងវេលាថ្ងៃ និង

វេលាយប់ ដោយបីតិ និងបាមោជ្ជនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលបើវេលាយប់កន្លងផុតទៅ វេលាថ្ងៃ ក៏ដើរមកដល់ ភិក្ខុក្នុងសាសនានេះ រមែងពិចារណាដូច្នេះថា បច្ច័យនៃសេចក្តីស្លាប់របស់អាត្មាអញ មានច្រើនណាស់ គឺពស់នឹងចឹកអញ ឬខ្ទួយនឹងទិចអញ ក្អែបនឹងខាំអញ អញគប្បីធ្វើមរណកាលដោយហេតុនោះ សេចក្តីអន្តរាយនោះ នឹងមានដល់អញ អញនឹងភ្លាត់ជួល ឬបាយដែលអញបរិភោគហើយ នឹងឲ្យទោស ប្រមាត់របស់អញនឹងកម្រើក ស្លេស្មរបស់អញ នឹងកម្រើក ខ្យល់មានអាការដូចកាំបិតកោររបស់អញ នឹងកម្រើក អញគប្បីធ្វើមរណកាល ដោយហេតុនោះ សេចក្តីអន្តរាយនោះ នឹងមានដល់អញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីពិចារណាដូច្នេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាល ក្នុងវេលាថ្ងៃ តើមានឬទេ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុកាលពិចារណាទៅ ដឹងយ៉ាងនេះថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញ កាលធ្វើមរណកាល ក្នុងវេលាថ្ងៃមាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់អកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលត្រូវភ្លើងឆេះសំពត់ក្តី ឆេះក្បាលក្តី គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹង

ប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលត់ភ្លើងដែលឆេះសំពត់ ឬក្បាលនោះចេញ សេចក្តីនេះ មានឧបមា យ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ គប្បីធ្វើនូវសេចក្តីប៉ុនប៉ងផង សេចក្តីព្យាយាមផង សេចក្តីខ្មីឃ្មាតផង សេចក្តីប្រឹងប្រែងផង ការប្រព្រឹត្តមិនថយក្រោយផង សតិផង សម្បជញ្ញៈផង ឲ្យមាំមួន ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ តែបើភិក្ខុកាលពិចារណាទៅ ដឹងយ៉ាងនេះវិញថា អកុសលធម៌ដ៏លាមកទាំងឡាយ ដែលអញមិនទាន់លះបង់ ជាធម៌ដែលនឹងនាំឲ្យអន្តរាយដល់អញកាលធ្វើមរណកាល ក្នុងវេលាថ្ងៃមិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ក្នុងកុសលធម៌ទាំងឡាយ ទាំងវេលាថ្ងៃ និងវេលាយប់ ដោយបីតិ និងបាមោជ្ជនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលបុគ្គលចម្រើនយ៉ាងនេះ ធ្វើឲ្យច្រើនយ៉ាងនេះ ទើបជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ជាគុណជាតិឈមទៅរកព្រះនិព្វាន មានព្រះនិព្វានជាទីបំផុត ។

*សាកណីយាទិវគ្គទី ២ ចប់*

## ឧទ្ទាននៃសារាណីយាទិវគ្គនោះ គឺ

និយាយអំពីសារាណីយធម៌ ២ លើក អំពីមេត្តា ១ អំពីកាលកិរិយាល្អ ១ អំពីកាលកិរិយាក្តៅក្រហាយ ១ អំពីរឿងនកុលបិតា ១ អំពីការមិនពិចារណានូវកុសលធម៌ ១ អំពីអ្នកសម្លាប់ត្រី ១ អំពីមរណស្សតិ ២ លើក ត្រូវជា ១០ រឿង ។

# អដ្ឋកថា

## ទុតិយមរណស្សតិសូត្រ

[ ២០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយមរណស្សតិសូត្រទី ១០ ដូចតទៅនេះ បទថា **បដិហិតាយ** ប្រែថា ប្រព្រឹត្តទៅហើយ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** សេចក្តីថា រមែងពិចារណាយ៉ាងនេះ ។ ក្នុងបទនេះថា **សោ មមស្ស អន្តរាយោ** ដូច្នេះ អន្តរាយមាន ៣ យ៉ាង គឺអន្តរាយនៃជីវិត ១ អន្តរាយនៃសមណធម៌ ១ អន្តរាយនៃសួគ៌ អន្តរាយនៃមគ្គ សម្រាប់អ្នកធ្វើកាលកិរិយារបស់បុថុជ្ជន ១ ។ ព្រះមានព្រះភាគ ត្រាស់សំដៅដល់អន្តរាយទាំង ៣ នោះឯង ។

បទថា **ព្យាបជ្ជេយ្យ** សេចក្តីថា គប្បីវិបត្តិទៅដោយអំណាចនៃការមិនល្មួយជាដើម ។ បទថា **អធិមត្តោ** ប្រែថា មានកម្លាំង ។ ការពេញចិត្ត គឺភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ឈ្មោះថា **ឆន្ទ** ។ សេចក្តីព្យាយាមក្នុងការប្រកបកិច្ច ឈ្មោះថា **វាយាម** ។ សេចក្តីព្យាយាមដែលជាហេតុនៃសេចក្តីភ្ញាក់រឭក ឈ្មោះថា **ឧស្សាហ** ។ សេចក្តីព្យាយាមដែលជាហេតុឲ្យដល់ព្រម ឈ្មោះថា **ឧស្សោឡ្ហី** ។ ការមិនរួញរា គឺការមិនថយក្រោយ ឈ្មោះថា **អប្បដិវានី** ។ ពាក្យដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ហើយដូច្នេះឯង ។

**អដ្ឋកថាទុតិយមរណស្សតិសូត្រទី ១០ ចប់**

**សារាណីយាទិវគ្គទី ២ ចប់**

# សុត្តន្តបិដក
# អនុត្តរិយវគ្គ

## សាមកសូត្រទី ១

[ ២១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ប្រថាប់នៅក្នុងវិហារឈ្មោះ បោក្ខរណិយា ជិតសាមគ្រាម ក្នុងដែនសក្កៈ ។ គ្រានោះ ទេវតា ១ អង្គ មានរស្មីរុងរឿង កាលរាត្រីបឋមយាមកន្លងហើយ បណ្តាលវិហារឈ្មោះ បោក្ខរណិយាទាំងមូលឲ្យភ្លឺប្រាល ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីសមគួរ ។ លុះទេវតានោះ ឈរនៅក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៣ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងការបរបោ ១ សេចក្តីត្រេកអរក្នុងការដេកលក់ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៣ យ៉ាងនេះឯង តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យដល់ភិក្ខុ ។ លុះទេវតានោះ ក្រាបបង្គំទូលដូច្នេះហើយ ព្រះសាស្តាក៏ទ្រង់ពេញព្រះហឫទ័យ ។ ទើបទេវតានោះ ដឹងថា ព្រះសាស្តារបស់អញ ទ្រង់ពេញព្រះហឫទ័យហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ បាត់ទៅក្នុងទីនោះឯង ។ លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំង-

ឡាយថា ម្នាលភិក្ខុទាំងឡាយ កាលរាត្រីបឋមយាមយប់មិញ កន្លងទៅហើយ ទេវតាមួយអង្គ មានរស្មីរុងរឿង បណ្ដាលវិហារឈ្មោះបោក្ខរណិយាទាំងមូល ឲ្យភ្លឺច្រាល ហើយចូលមកគាល់តថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំ តថាគត ហើយឈរនៅក្នុងទីសមគួរ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឈរនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលតថាគតយ៉ាងនេះថា បពិត្រព្រះអង្គ ដ៏ចម្រើន ធម៌ ៣ យ៉ាងនេះឯង តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ ដល់ភិក្ខុ ។ ៣ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីត្រេកអរក្នុងការងារ ១ សេចក្ដី ត្រេកអរក្នុងការចរចា ១ សេចក្ដីត្រេកអរក្នុងការដេកលក់ ១ ។ បពិត្រព្រះអង្គ ដ៏ចម្រើន ធម៌ ៣ យ៉ាងនេះឯង តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ ដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយយ៉ាងនេះ លុះនិយាយ យ៉ាងនេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយបាត់ទៅក្នុងទីនោះ ឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតា ដឹងលោកទាំងឡាយណា ដែលកំពុង សាបសូន្យចាកកុសលធម៌ទាំងឡាយ លោកទាំងនោះ ឈ្មោះថា ឥតលាភ លោកទាំងនោះ ឈ្មោះថា បានដោយអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសម្ដែងនូវបរិហានិយធម៌ ( ធម៌ជាគ្រឿងសាបសូន្យ ) ៣ ដទៃទៀត អ្នកទាំងឡាយចូរស្ដាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យស្រួលប្រួល តថាគតនឹង សម្ដែងប្រាប់ ។ ភិក្ខុទាំងនោះ បានទទួលស្ដាប់ព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ

បរិហានិយធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺសេចក្តីត្រេកអរនឹងការវឹកវរដោយគ្នីគ្នា ១ ភាពជាអ្នកដែលគេប្រដៅបានដោយក្រ ១ ភាពជាអ្នកមានមិត្តអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង បរិហានិយធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ សាបសូន្យហើយចាកកុសលធម៌ទាំងឡាយក្នុងអតីតកាល បុគ្គលទាំងអស់នោះ សាបសូន្យហើយចាកពួកកុសលធម៌ដោយធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ទោះពួកបុគ្គលណាមួយនឹងសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងអនាគតកាល បុគ្គលទាំងអស់នោះគង់នឹងសាបសូន្យចាកពួកកុសលធម៌ដោយធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកបុគ្គលណាមួយ កំពុងសាបសូន្យចាកកុសលធម៌ទាំងឡាយក្នុងកាលឥឡូវនេះ បុគ្គលទាំងអស់នោះ គង់សាបសូន្យចាកពួកកុសលធម៌ដោយធម៌ទាំង ៦ នេះឯង ។

# អដ្ឋកថា

# អនុត្តរិយវគ្គទី ៣

## សាមកសូត្រ

[ ២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសាមកសូត្រទី ១ នៃអនុត្តរិយវគ្គទី ៣ ដូចតទៅនេះ បទថា **សាមគាមកេ** សេចក្តីថា ក្នុងស្រុកដែលមានឈ្មោះយ៉ាងនេះ ព្រោះមានថ្នសំលៀងជាច្រើន ។ បទថា **ពោក្ខរណិយាយំ** បានដល់ក្នុងវិហារមានឈ្មោះថាបោក្ខរណិយៈ ។ បទថា **អភិក្កន្តាយ រត្តិយា** សេចក្តីថា កាលបឋមយាមនៃរាត្រីឈានចូលមជ្ឈិមយាម ។ បទថា **អភិក្កន្តវណ្ណា** បានដល់ មានពណ៌ល្អគួរពេញចិត្តក្រៃលែង ។ បទថា **កេវលកប្បំ** បានដល់ទាំងអស់ ។ បទថា **ពោក្ខរណិយំ ឱភាសេត្វា** សេចក្តីថា ផ្សាយរស្មីរបស់ខ្លួនទៅពេញមហាវិហារឈ្មោះបោក្ខរណីយៈនោះ ។ បទថា **សមនុញ្ញោ** សេចក្តីថា ទ្រង់ពេញព្រះហឫទ័យ គឺមានចិត្តស្មើ ។ បទថា **ទោវចស្សតា** បានដល់ ភាពជាបុគ្គលប្រដៅក្រ ។ បទថា **បាបមិត្តតា** បានដល់ ភាពជាអ្នកមានមិត្រអាក្រក់ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់បរិហានិយធម៌ គឺធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យតែម្យ៉ាង ។

### អដ្ឋកថា សាមកសូត្រទី ១ ចប់

# សុត្តន្តបិដក

## អបរិហានិយសូត្រទី ២

[ ២២ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអបរិហានិយធម៌ ( ធម៌ដែលមិនសាបសូន្យ ) ៦ យ៉ាងនេះ អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះចុះ ។បេ។ ម្នាលភិក្ខុទាំងឡាយ អបរិហានិយធម៌ ៦ យ៉ាង តើដូចម្តេច ។ គឺសេចក្តីមិនត្រេកអរក្នុងការងារ ១ សេចក្តីមិនត្រេកអរក្នុងការចរចា ១ សេចក្តីមិនត្រេកអរក្នុងការដេកលក់ ១ សេចក្តីមិនត្រេកអរក្នុងការរីករាយដោយគ្នីគ្នា ១ ភាពជាអ្នកដែលគេប្រដៅងាយ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអបរិហានិយធម៌ទាំង ៦ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ទោះពួកបុគ្គលណាមួយ មិនសាបសូន្យហើយចាកកុសលធម៌ទាំង-ឡាយ ក្នុងអតីតកាល បុគ្គលទាំងអស់នោះមិនសាបសូន្យហើយចាកពួកកុសលធម៌ ដោយធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ទោះពួកបុគ្គលណាមួយ នឹងមិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងអនាគតកាល បុគ្គលទាំងអស់នោះ នឹងមិនសាបសូន្យចាកពួកកុសលធម៌ ដោយធម៌ទាំង ៦ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ទោះពួកបុគ្គលណាមួយ មិនសាបសូន្យចាកកុសលធម៌ទាំងឡាយ ក្នុងកាលឥឡូវនេះ បុគ្គលទាំងអស់នោះ មិនសាបសូន្យចាកពួកកុសលធម៌ដោយធម៌ទាំង ៦ នេះឯង ។

# អដ្ឋកថា

## អបរិហានិយសូត្រ

[ ២២ ] ក្នុងអបរិហានិយសូត្រទី ២ នេះ ព្រះមានព្រះភាគ ត្រាស់អបរិហានិយធម៌ដែលលាយដោយលោកុត្តរហើយ ។ល។

**អដ្ឋកថា អបរិហានិយសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ភយសូត្រទី ៣

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ ត្រង់ពាក្យថា ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា រោគនោះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា គណ្ឌៈ ( ពក ) នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា សង្គៈ ( ការជាប់ចំពាក់ចិត្ត ) នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ពាក្យថា បង្កៈ ( ភក់ ) នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ( ព្រោះថា ) បុគ្គលដែលត្រេកអរដោយកាមរាគនេះ រមែងជាប់ចំពាក់ដោយឆន្ទរាគ មិនរួចអំពីភ័យក្នុងបច្ចុប្បន្នផង មិនរួចអំពីភ័យក្នុងបរលោកផង ព្រោះហេតុនោះ បានជាពាក្យថា

ភ័យនុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខ... រោគ...គណ្ឌៈ...សង្គៈ...បង្កៈ នុ៎ះ ជាឈ្មោះនៃកាមទាំងឡាយ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ( ព្រោះថា ) បុគ្គលដែលត្រេកអរដោយកាមនេះ រមែងជាប់ចំពាក់ដោយឆន្ទរាគ មិនរួចអំពីបង្កៈក្នុងបច្ចុប្បន្នផង មិនរួចអំពីបង្កៈក្នុងបរលោកផង ហេតុនោះ បានជាពាក្យថា បង្កៈនុ៎ះ ទើបជាឈ្មោះនៃកាមទាំងឡាយ ។

កាមទាំងឡាយ ដែលជាទីជាប់នៅរបស់បុថុជ្ជននុ៎ះ
លោកតែងហៅថា ភ័យផង ទុក្ខផង រោគផង និង
ធម្មជាតទាំង ២ គឺសង្គៈផង បង្កៈផង ។ អរិយ-
សាវកទាំងឡាយ ឃើញភ័យក្នុងឧបាទាន ដែលជា
ហេតុឲ្យកើតជាតិ និងមរណៈ លុះមិនប្រកាន់ហើយ
រមែងរួចស្រឡះ ព្រោះការអស់ជាតិ និងមរណៈ ។
អរិយសាវកនោះ ដល់នូវសេចក្តីក្សេមក្សាន្ត មាន
សេចក្តីសុខ រម្ងាត់កិលេសក្នុងអត្តភាពនេះ ប្រព្រឹត្ត
កន្លងនូវវេរ និងភ័យទាំងអស់ហើយ លះបង់នូវ
ទុក្ខទាំងអស់បាន ។

# អដ្ឋកថា

## ភយសូត្រ

[ ២៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភយសូត្រទី ៣ ដូចតទៅនេះ បទថា **កាមរាគរត្តាយំ** កាត់បទជា **កាមរាគរត្តោ អយំ** ប្រែថា ភិក្ខុនេះ ត្រូវកាមរាគៈជ្រលក់ហើយ ។ បទថា **ឆន្ទរាគវិនិពន្ធោ** សេចក្តីថា ត្រូវឆន្ទរាគៈចងភ្ជាក់ហើយ ។ បទថា **ភយា** បានដល់ ចាកភ័យ គឺការតក់ស្លុតនៃចិត្ត ។ បទថា **បង្កា** បានដល់ អំពីភក់ គឺកិលេស ។ បទថា **សង្គោ បង្កោ ច ឧភយំ** សេចក្តីថា ទាំង ២ យ៉ាងនេះ គឺសង្គៈ និងបង្កៈ ។

២ បទ ក្នុងព្រះគាថាថា **ឯតេ កាមា បវុច្ចន្តិ យត្ថ សត្តោ បុថុជ្ជនោ** សេចក្តីថា បុថុជ្ជនជាប់ជំពាក់ ពាក់ព័ន្ធ រឹតរុំ ក្នុងគ្រឿងជាប់ជំពាក់នឹងភក់ឯណា ។

បទថា **ឧបាទានេ** បានដល់ ក្នុងឧបាទាន ៤ យ៉ាង ។ បទថា **ជាតិមរណសម្ភវេ** សេចក្តីថា ជាទីកើត គឺជាបច្ច័យនៃជាតិ និងមរណៈ ។ បទថា **អនុបាទា វិមុច្ចន្តិ** បានដល់ រួចផុតទៅ ព្រោះមិនប្រកាន់មាំ ។ បទថា **ជាតិមរណសង្ខយេ** បានដល់ ក្នុងព្រះនិព្វាន ពោល គឺការអស់ទៅនៃជាតិ និងមរណៈទាំងឡាយ អធិប្បាយថា រមែងរួចផុតដល់វិមុត្តិ មានព្រះនិព្វានជាអារម្មណ៍ ។ ភិក្ខុនេះសម្រេចហើយនូវអរហត្តផលនោះឯង ដោយមិនវិលទៅក្នុងឋានៈនេះ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរភាពជាព្រះខីណាស្រព ទើបត្រាស់ពាក្យជាដើមថា **តេ ខេមប្បត្តា** ដូច្នេះ ។ បណ្តាបទ

ទាំងនោះ បទថា **ខេមប្បត្តា** បានដល់ ដល់នូវការក្សេម ។ បទថា **សុខិនោ** បានដល់ ដល់នូវសេចក្តីសុខ ដោយលោកុត្តរសុខ ។ បទថា **ទិដ្ឋធម្មា-ភិនិព្វុតា** បានដល់ រលត់ឥតសេសសល់ហើយក្នុងទិដ្ឋធម៌នោះឯង ព្រោះមិនមានកិលេសខាងក្នុង ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់ចំពោះវដ្តៈហើយក្នុងគាថា ទើបត្រាស់វដ្តៈផង និងវិវដ្តៈផង ។

**អដ្ឋកថា ភយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ហិមវន្តសូត្រទី ៤

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង គប្បីទម្លាយភ្នំហិមពាន្តជាស្តេចភ្នំបាន មិនបាច់និយាយ ( ដល់ការទម្លាយ ) អវិជ្ជាដែលលាមកទេ ។ ធម៌ទាំង ៦ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ឈ្លាសក្នុងការចូលសមាធិ ១ ឈ្លាសក្នុងការធ្វើសមាធិឲ្យតាំងនៅតាមកំណត់ ១ ឈ្លាសក្នុងការចេញចាកសមាធិ ១ ឈ្លាសក្នុងការបែងចំណែកសមាធិ ១ ឈ្លាសក្នុងគោចររបស់សមាធិ ១ ឈ្លាសក្នុងការសាងសន្សំនូវសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៦ នេះឯង គប្បីទម្លាយភ្នំហិមពាន្តជាស្តេចភ្នំបាន មិនបាច់និយាយដល់អវិជ្ជាដែលលាមកទេ ។

# អដ្ឋកថា

## ហិមវន្តសូត្រ

[ ២៤ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងហិមវន្តសូត្រទី ៤ ដូចតទៅនេះ បទថា* **បទាលេយ្យ** *ប្រែថា គប្បីទម្លាយ ។ បទថា* **ឆវាយ** *បានដល់ ថោកទាប ។ បទថា* **សមាធិស្ស សមាបត្តិកុសលោ ហោតិ** *សេចក្តីថា ភិក្ខុរមែងជាអ្នកឈ្លាស គឺមុតស្រួច បានដល់ មានបដិភាណអាចចូលសមាធិ ដោយកំណត់យកអាហារជាទីសប្បាយ និងឧតុជាទីសប្បាយ ។ បទថា* **សមាធិស្ស ឋិតិកុសលោ** *សេចក្តីថា ជាអ្នកឈ្លាសក្នុងការបញ្ឈប់សមាធិបាន អធិប្បាយថា អាចបញ្ឈប់បាន ។ បទថា* **សមាធិស្ស វុដ្ឋានកុសលោ** *សេចក្តីថា ជាអ្នកឈ្លាសក្នុងការចេញចាកសមាធិ អធិប្បាយថា អាចចេញបានតាមកំណត់ ។ បទថា* **សមាធិស្ស កល្លតាកុសលោ** *សេចក្តីថា ជាអ្នកឈ្លាសក្នុងភាពដែលសមាធិគួរដល់កាល អធិប្បាយថា អាចធ្វើឲ្យសមគួរ ដើម្បីសមាធិចិត្តក្លៀវក្លា ។*

*បទថា* **សមាធិស្ស គោចរកុសលោ** *សេចក្តីថា ភិក្ខុកាលវៀរសប្បាយ គឺធម៌ដែលមិនបានជាឧបការៈដល់សមាធិ សេពនូវសប្បាយ គឺធម៌ដែលជាឧបការៈក្តី ដឹងថា សមាធិមាននិមិត្តជាអារម្មណ៍ សមាធិនេះមានលក្ខណៈជាអារម្មណ៍ក្តី ឈ្មោះថា ជាអ្នកឈ្លាសក្នុងអារម្មណ៍របស់សមាធិ ។ បទថា* **សមាធិស្ស អភិនីហារកុសលោ** *សេចក្តីថា ភិក្ខុកាលអាចនាំសមាធិ មានបឋមជ្ឈានជាដើមឲ្យជាប្រមុខ ដើម្បីជាប្រយោជន៍ដល់ការចូលសមាបត្តិខ្ពស់ៗ*

ឡើងទៅ ឈ្មោះថា ជាអ្នកឈ្លាសក្នុងភាពជាប្រមុខនៃសមាធិ គឺលោកចេញអំពីបឋមជ្ឈាន ហើយចូលទុតិយជ្ឈាន ចេញអំពីទុតិយជ្ឈានហើយ ។បេ។ ចេញអំពីតតិយជ្ឈានហើយ ចូលចតុត្ថជ្ឈាន ដូច្នេះឯង ។៚

អដ្ឋកថា ហិមវន្តសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនុស្សតិដ្ឋានសូត្រទី ៥

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ អនុស្សតិដ្ឋាន ( ហេតុជាទីតាំងនៃសេចក្ដីរឭក ) នេះមាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ រឭកនូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ដោយប្រការដូច្នេះ ។បេ។ ជាសាស្ដានៃទេវតា និងមនុស្សទាំងឡាយ ជ្រាបច្បាស់នូវសច្ចៈទាំង ៤ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកព្រះតថាគត សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈ នោះ ជាឈ្មោះនៃកាម

គុណទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងសាសនានេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវពុទ្ធានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះធម៌ថា ព្រះធម៌ ដែលព្រះដ៏មានព្រះភាគសម្ដែងល្អហើយ ។បេ។ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយគប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកនូវព្រះធម៌ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណទាំង ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងសាសនានេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវធម្មានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះសង្ឃថា ព្រះសង្ឃជាសាវករបស់ព្រះដ៏មានព្រះភាគ ប្រតិបត្តិដោយប្រពៃ ។បេ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកព្រះសង្ឃ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈ គ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ

តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវសង្ឃានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវករឭកនូវសីលទាំងឡាយ របស់ខ្លួនជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីសមាធិ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវសីល សម័យនោះ អរិយសាវក មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើសីលានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក រឭកនូវចាគៈរបស់ខ្លួនថា ជាលាភរបស់អញហើយ អញឈ្មោះថាបានស្រួលហើយ ព្រោះអាត្មាអញ ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការឲ្យ និងការចែករំលែក ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកនូវចាគៈ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាម-គុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវចាគានុស្សតិកម្មដ្ឋាន ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំង-

ឡាយ មួយទៀត អរិយសាវក រឭកនូវពួកទេវតាថា មានពួកទេវតាជាន់ចាតុម្មហារាជិកៈ ទេវតាជាន់តាវត្តិង្ស ទេវតាជាន់យាមៈ ទេវតាជាន់តុសិតៈ ទេវតាជាន់និម្មានរតី ទេវតាជាន់បរនិម្មិតវសវត្តី មានទេវតាជាពួករបស់ព្រហ្ម មានទេវតាជាន់ខ្ពស់ជាងនោះទៀត ទេវតាទាំងនោះ ដែលប្រកបដោយសទ្ធា យ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ យើងសោតក៏មានសទ្ធា ដូច្នោះដែរ ទេវតាទាំងនោះ ប្រកបដោយសីលៈ សុតៈ ចាគៈ បញ្ញា យ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ យើងសោតក៏មានបញ្ញា ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ខ្លួនផង របស់ទេវតាទាំងនោះផង សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តរួចឃ្លាតអំពីគេធៈបាន ម្នាលភិក្ខុទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះរបស់កាមគុណ ៥ ។ ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ តែងបរិសុទ្ធបានយ៉ាងនេះ ព្រោះធ្វើនូវទេវតានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអនុស្សតិដ្ឋានទាំង ៦ ។

# អដ្ឋកថា

## អនុស្សតិដ្ឋានសូត្រ

[ ២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុស្សតិដ្ឋានសូត្រទី ៥ ដូចតទៅនេះ បទថា **អនុស្សតិដ្ឋានានិ** បានដល់ ជាហេតុនៃអនុស្សតិ ។ បទថា **ឥតិបិ សោ ភគវា** ជាដើម ខ្ញុំបានឲ្យពិស្តារក្នុងវិសុទ្ធិមគ្គហើយ ។ បទថា **ឥធម្បិ ខោ ភិក្ខវេ អារម្មណំ ករិត្វា** សេចក្តីថា ធ្វើពុទ្ធានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ បទថា **វិសុជ្ឈន្តិ** សេចក្តីថា ដល់នូវព្រះនិព្វាន ដែលបរិសុទ្ធក្រៃលែង ។ ក្នុងបទទាំងពួងឆាយយល់ទាំងអស់ហើយ ក្នុងព្រះសូត្រនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ អនុស្សតិកម្មដ្ឋាន ៦ លាយគ្នា ។៚

**អដ្ឋកថា អនុស្សតិដ្ឋានសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## កច្ចានសូត្រទី ៦

[ ២៦ ] ក្នុងទីនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ បានហៅពួកភិក្ខុថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ព្រះមហាកច្ចានៈដ៏មានអាយុថា អាវុសោដូច្នេះ ។ ទើបព្រះមហាកច្ចានៈដ៏មានអាយុ បាននិយាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ហេតុគួរឲ្យអស្ចារ្យ ម្នាល

អាវុសោទាំងឡាយ ហេតុមិនធ្លាប់កើត ក៏កើតឡើងបាន ព្រោះព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ បានត្រាស់ដឹងនូវការបានឱកាសក្នុងទីដ៏ចង្អៀត ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្តីសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ការត្រាស់ដឹងនេះ គឺអនុស្សតិដ្ឋានទាំង ៦ ។ អនុស្សតិដ្ឋានទាំង ៦ តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ អរិយសាវកក្នុងសាសនានេះ រឭកនូវព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ដោយប្រការដូច្នេះ ។បេ។ ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវសច្ចៈទាំង ៤ ទ្រង់លែងវិលត្រឡប់មកកាន់កពថ្មីទៀត ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវព្រះតថាគត សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវពុទ្ធានុស្សតិកម្មដ្ឋាននេះ ឲ្យ

ជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះធម៌ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សំដែងហើយដោយល្អ ។បេ។ ជាធម៌ដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងចំពោះខ្លួន ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវព្រះធម៌ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថាគេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវធម្មានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវករឭកនូវព្រះសង្ឃថា ព្រះសង្ឃជាសាវករបស់ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយល្អ ។បេ។ លោកជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុងរឭកនូវព្រះសង្ឃ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយ

យ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវក នោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុង លោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវសង្ឃានុស្សតិ កម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយ-សាវករឭកនូវសីលរបស់ខ្លួន ជាសីលមិនដាច់ ។បេ។ ប្រព្រឹត្តទៅដើម្បីបាន នូវសមាធិ ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវក កំពុង រឭកនូវសីល សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្ត ចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថាគេធៈនេះ ជា ឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្ត ស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមាន ពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតាបានយ៉ាងនេះ ព្រោះធ្វើនូវសីលានុស្សតិកម្មដ្ឋាន នេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវក រឭកនូវចាគៈរបស់ខ្លួនថា ជាលាភរបស់អញហើយ អញឈ្មោះថាបាន

ស្រួលហើយ ព្រោះអាត្មាអញ ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការឲ្យទាន ការចែករលែក ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកនូវចាគៈ សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែល ទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពី គេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថាគេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាស ទាំងមូលជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតា បានយ៉ាងនេះ ព្រោះធ្វើនូវចាគានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត អរិយសាវករឭកនូវពួកទេវតាថា ទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ។ បេ ។ ទេវតាជាន់ខ្ពស់ជាងនោះទៀតក៏មាន ទេវតាទាំងនោះប្រកបដោយសទ្ធាយ៉ាងណា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ អាត្មាអញតែងមានសទ្ធាដូច្នោះដែរ ទេវតាទាំងនោះប្រកបដោយសីលយ៉ាងណា ។ បេ ។ ដោយសុតៈ ចាគៈ បញ្ញា ច្យុតអំពីទីនេះហើយ ទៅកើតក្នុងទីនោះ អាត្មាអញតែងមានបញ្ញាដូច្នោះដែរ ។ ម្នាលអាវុសោទាំងឡាយ សម័យណា អរិយសាវកកំពុងរឭកនូវគុណ គឺសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា របស់ខ្លួនផង របស់

ទេវតាទាំងនោះផង សម័យនោះ អរិយសាវកនោះ មិនមានចិត្តដែលរាគៈគ្របសង្កត់ មិនមានចិត្តដែលទោសៈគ្របសង្កត់ មិនមានចិត្តដែលមោហៈគ្របសង្កត់ទេ សម័យនោះ អរិយសាវកនោះ មានចិត្តប្រព្រឹត្តទៅត្រង់តែមួយយ៉ាង ជាចិត្តចេញរួចឃ្លាតអំពីគេធៈបាន ម្នាលអាវុសោទាំងឡាយ ពាក្យថា គេធៈនេះ ជាឈ្មោះនៃកាមគុណ ៥ ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកនោះ មានចិត្តស្មើដោយអាកាសទាំងមូល ជាចិត្តដ៏ទូលាយធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ។ ម្នាលអាវុសោទាំង-ឡាយ សត្វពួកខ្លះក្នុងលោកនេះ មានសេចក្តីបរិសុទ្ធិជាធម្មតា បានយ៉ាងនេះព្រោះធ្វើនូវទេវតានុស្សតិកម្មដ្ឋាននេះ ឲ្យជាអារម្មណ៍ ។ ម្នាលអាវុសោទាំង-ឡាយ ហេតុគួរឲ្យអស្ចារ្យ ម្នាលអាវុសោទាំងឡាយ ហេតុមិនធ្លាប់កើត ក៏កើតឡើងបាន ត្រង់ដែលព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ បានត្រាស់ដឹងនូវការបានឱកាស ក្នុងទីចង្អៀតនេះ ដើម្បីសេចក្តីបរិសុទ្ធិដល់ពួកសត្វ ដើម្បីប្រព្រឹត្តកន្លងនូវសេចក្តីសោក និងខ្សឹកខ្សួលទាំងឡាយ ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ការត្រាស់ដឹងនេះ គឺ អនុស្សតិដ្ឋានទាំង ៦ នេះ ។

# អដ្ឋកថា

## កច្ចានសូត្រ

[ ២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកច្ចានសូត្រទី ៦ ដូចតទៅនេះ បទថា **សម្ពាធេ** សេចក្តីថា ក្នុងទីដែលចង្អៀតដោយកាមគុណទាំង ៥ ។ អនុស្សតិ ៦ លោកហៅថា ឱកាស ក្នុងបទថា **ឱកាសាធិគមោ** នេះ ការសម្រេចហេតុនៃអនុស្សតិ ៦ នោះ ។ បទថា **វិសុទ្ធិយា** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់សេចក្តីបរិសុទ្ធ ។ បទថា **សោកបរិទេវានំ សមតិក្កមាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការកន្លងនូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ។ បទថា **អត្ថង្គមាយ** សេចក្តីថា ដើម្បីដល់នូវការរលត់ ។ បទថា **ញាយស្ស អធិគមាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការសម្រេចមគ្គ មួយអន្លើដោយវិបស្សនាខាងដើម ។ បទថា **និព្វានស្ស សច្ឆិកិរិយាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលមិនមានបច្ច័យតាក់តែង ។

បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង ។ បទថា **អាកាសសមេន** សេចក្តីថា ដូចគ្នានឹងអាកាស ព្រោះអត្ថថា មិនជាប់ជំពាក់ និងព្រោះអត្ថថា មិនមានកង្វល់ ។

បទថា **វិបុលេន** សេចក្តីថា មិនមែនតិចតួច ។ បទថា **មហគ្គតេន** សេចក្តីថា ដល់នូវភាពជារបស់ធំ ម្យ៉ាងទៀត អធិប្បាយថា ដល់ គឺប្រព្រឹត្តទៅ មួយអន្លើដោយព្រះអរិយសាវ័កដែលជាធំ ។

បទថា **អប្បមាណេន** សេចក្ដីថា ឈ្មោះថា មិនមានប្រមាណ ព្រោះថា ចិត្តនោះមានការផ្សាយទៅមិនមានប្រមាណ ។ បទថា **អវេរេន** សេចក្ដីថា វៀរចាកអកុសលធម៌ដែលជាពៀរ និងបុគ្គលដែលជាពៀរ ។ បទថា **អព្យាបជ្ជេន** សេចក្ដីថា វៀរចាកសេចក្ដីទុក្ខដែលកើតអំពីសេចក្ដីក្រោធ ។

ពាក្យទាំងអស់នេះ ព្រះមហាកច្ចានៈពោលសំដៅដល់ចិត្ត ដែលមានពុទ្ធានុស្សតិជាអារម្មណ៍ប៉ុណ្ណោះ ក្នុងប្រការតទៅក៏មានន័យនេះដូចគ្នា ។ បទថា **វិសុទ្ធិធម្មា** បានដល់ មានសេចក្ដីបរិសុទ្ធិជាសភាវៈ ក្នុងព្រះសូត្រនេះ ព្រះមហាកច្ចានៈ ក៏ពោលហេតុនៃអនុស្សតិ ៦ លាយឡំគ្នាដូចគ្នា ដូច្នេះឯង ។

**អដ្ឋកថា កច្ចានសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមសមយសូត្រទី ៧

[ ២៧ ] គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយក្នុងទីសមគួរស៊ប់ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យដែលគួរចូលទៅឃើញ ភិក្ខុជាអ្នកមានចិត្តចម្រើនហើយ តើមានប៉ុន្មាន ។ ម្នាលភិក្ខុ សម័យដែលគួរចូល

ទៅឃើញ ភិក្ខុមានចិត្តចម្រើនហើយនេះ មាន ៦ យ៉ាង ។ ៦ តើអ្វីខ្លះ ។ ម្នាលភិក្ខុ សម័យណា ភិក្ខុក្នុងសាសនានេះ មានចិត្តដែលកាមរាគគ្របសង្កត់ហើយ រវើរវាយដោយកាមរាគ ទាំងមិនដឹងនូវការលះកាមរាគ ដែលកើតឡើងហើយ ឲ្យពិតប្រាកដបាន សម័យនោះ ត្រូវចូលទៅរកភិក្ខុជាអ្នកមានចិត្តចម្រើនហើយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវកាមរាគគ្របសង្កត់ហើយ រវើរវាយដោយកាមរាគ ទាំងមិនដឹងនូវការលះកាមរាគដែលកើតឡើងហើយ ឲ្យពិតប្រាកដបានទេ សូមលោកដ៏មានអាយុ អាណិតសម្តែងធម៌ ដើម្បីលះកាមរាគដល់ខ្ញុំ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ ដើម្បីលះកាមរាគដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើនទី ១ ។ ម្នាលភិក្ខុ មួយទៀត សម័យណា បើភិក្ខុមានចិត្តត្រូវព្យាបាទគ្របសង្កត់ហើយ រវើរវាយដោយព្យាបាទ ទាំងមិនដឹងនូវការលះព្យាបាទ ដែលកើតឡើងហើយ ឲ្យពិតប្រាកដ សម័យនោះ ទើបត្រូវចូលទៅរកភិក្ខុដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវព្យាបាទគ្របសង្កត់ហើយ រវើរវាយដោយព្យាបាទ ទាំងមិនដឹងនូវការលះព្យាបាទ ដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ អាណិតសម្តែងធម៌ ដើម្បីលះព្យាបាទដល់ខ្ញុំ ។ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ ដើម្បីលះព្យាបាទដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទី ២ ។ ម្នាលភិក្ខុ

មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ រវើរវាយដោយថីនមិទ្ធៈ ទាំងមិនដឹងនូវការលះថីនមិទ្ធៈដែលកើតឡើងឲ្យពិតប្រាកដ សម័យនោះត្រូវចូលទៅរកភិក្ខុដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ ហើយរវើរវាយដោយថីនមិទ្ធៈ ទាំងមិនដឹងនូវការលះថីនមិទ្ធៈ ដែលកើតឡើងហើយឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុអាណិតសម្តែងធម៌ ដើម្បីលះថីនមិទ្ធៈដល់ខ្ញុំ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ដើម្បីលះថីនមិទ្ធៈដល់ភិក្ខុនោះ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទី ៣ ។ ម្នាលភិក្ខុមួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ រវើរវាយដោយឧទ្ធច្ចកុក្កុច្ចៈ ទាំងមិនដឹងនូវការលះឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើងហើយឲ្យពិតប្រាកដទេ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយរវើរវាយដោយឧទ្ធច្ចកុក្កុច្ចៈ ទាំងមិនដឹងនូវការលះឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើងហើយ ឲ្យពិតប្រាកដបានទេ សូមលោកដ៏មានអាយុអាណិតសម្តែងធម៌ដល់ខ្ញុំដើម្បីលះនូវឧទ្ធច្ចកុក្កុច្ចៈ ភិក្ខុជាអ្នកមានចិត្តចម្រើន គង់នឹងសម្តែងធម៌ដល់ភិក្ខុនោះ ដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើនទី ៤ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ រវើរវាយដោយវិចិកិច្ឆា ទាំងមិនដឹងនូវការ

លះវិចិកិច្ឆា ដែលកើតឡើងហើយឲ្យពិតប្រាកដទេ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ រវើរវាយដោយវិចិកិច្ឆា ទាំងមិនដឹងនូវការលះវិចិកិច្ឆាដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុអាណិតសម្តែងធម៌ដល់ខ្ញុំដើម្បីលះវិចិកិច្ឆា ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ដល់ភិក្ខុនោះដើម្បីលះនូវវិចិកិច្ឆា ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទី ៥ ។ ម្នាលភិក្ខុ មួយទៀត សម័យណា ភិក្ខុមិនដឹងមិនឃើញនូវនិមិត្ត ដែលខ្លួនអាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សម័យនោះ ត្រូវចូលទៅរកភិក្ខុដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមិនដឹង មិនឃើញនូវនិមិត្ត ( ដែលខ្ញុំ ) អាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណាហើយ អស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សូមលោកដ៏មានអាយុ អាណិតសម្តែងធម៌ដល់ខ្ញុំ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ដល់ភិក្ខុនោះ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុ នេះជាសម័យដែលគួរចូលទៅឃើញ នូវភិក្ខុដែលមានចិត្តចម្រើនទី ៦ ។ ម្នាលភិក្ខុ នេះឯងជាសម័យទាំង ៦ ដែលគួរចូលទៅឃើញភិក្ខុមានចិត្តចម្រើន ។

# អដ្ឋកថា

## បឋមសមយសូត្រ

[ ២៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសមយសូត្រទី ៧ ដូចតទៅនេះ បទថា **មនោភាវនីយស្ស** នេះ មានវិគ្គហៈថា ភិក្ខុឈ្មោះថា ជាអ្នកចម្រើនភាវនាផ្លូវចិត្ត ព្រោះអប់រំចិត្ត គឺញ៉ាំងចិត្តឲ្យចម្រើន ។ បទថា **ទស្សនាយ** បានដល់ ដើម្បីឃើញ ។ បទថា **និស្សរណំ** បានដល់ ផ្លូវចេញ គឺការស្ងប់រម្ងាប់ ។ បទថា **ធម្មំ ទេសេតិ** សេចក្ដីថា ប្រាប់អសុភកម្មដ្ឋាន ដើម្បីឲ្យលះកាមរាគៈ ។

ក្នុងទុតិយវារៈជាដើម គប្បីជ្រាបអធិប្បាយថា ប្រាប់មេត្តាកម្មដ្ឋាន ដើម្បីលះព្យាបាទនីវរណៈ ប្រាប់កម្មដ្ឋានដែលជាហេតុបន្ទោបង់នូវថីនមិទ្ធៈ គឺអាលោកសញ្ញា ឬកម្មដ្ឋានដែលជាទីតាំងនៃវីរិយារម្ភៈជាដើមឯណានីមួយ ដើម្បីលះថីនមិទ្ធនីវរណៈ សម្ដែងធម៌ពោលកថា ប្រារព្ធគុណរបស់ព្រះរតនត្រ័យ ដើម្បីលះវិចិកិច្ឆានីវរណៈ ។

បទថា **អាគម្ម** ប្រែថា ប្រារព្ធ ។ បទថា **មនសិករោតោ** សេចក្ដីថា ធ្វើទុកក្នុងចិត្តដោយអំណាចឲ្យជាអារម្មណ៍ ។ បទថា **អនន្តរា អាសវានំ ខយោ ហោតិ** សេចក្ដីថា ការអស់ទៅនៃអាសវៈទាំងឡាយ រមែងមានដោយប្រាសចាកអន្តរាយ ។ល។

**អដ្ឋកថា បឋមសមយសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយសមយសូត្រទី ៨

[ ២៨ ] សម័យមួយ ភិក្ខុជាថេរៈច្រើនអង្គ នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះ ភិក្ខុជាថេរៈអម្បាលនោះ ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលជាខាងក្រោយពេលចង្ហាន់ហើយ បានអង្គុយប្រជុំគ្នា ក្នុងរោងនៅក្នុងមណ្ឌលទី ( រោងសាលា ) ហើយនិយាយឡើងក្នុងចន្លោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ សម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើន តើសម័យណា ។ កាលបើពួកព្រះថេរៈនិយាយយ៉ាងនេះហើយ ភិក្ខុ ១ រូប បាននិយាយនឹងពួកភិក្ខុជាថេរៈយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ សម័យណា ភិក្ខុដែលមានចិត្តចម្រើន ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលជាខាងក្រោយពេលចង្ហាន់ លោកលាងជើងហើយ អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាសម័យ គួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើនទេ ។ ម្នាលអាវុសោ ព្រោះថាសម័យណា ភិក្ខុដែលមានចិត្តចម្រើន ផុតកិច្ចដោយបិណ្ឌបាត ក្នុងកាលក្រោយពេលចង្ហាន់ លោកលាងជើងហើយ អង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ លោកកំពុងមានសេចក្តីលំបាក នឹងការត្រាច់ទៅ ( បិណ្ឌបាត ) មិនទាន់ស្ងប់រម្ងាប់ ក្នុងសម័យនោះនៅឡើយ សូម្បីសេចក្តី

លំបាកព្រោះភត្ត ក៏មិនទាន់ស្ងប់រម្ងាប់ ក្នុងសម័យនោះនៅឡើយដែរ ហេតុនោះ បានជាសម័យនេះ មិនមែនជាសម័យ គួរចូលទៅឃើញភិក្ខុ ដែលមានចិត្តចម្រើនទេ ។ ម្នាលអាវុសោ សម័យណា ភិក្ខុដែលមានចិត្តចម្រើន ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយអង្គុយក្នុងម្លប់ខាងក្រោយវិហារ ផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបជាសម័យគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើនបាន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុដទៃទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាសម័យ ដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើន ( នោះទេ ) ។ ម្នាលអាវុសោ ព្រោះថា សម័យណា ភិក្ខុមានចិត្តចម្រើនចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ អង្គុយក្នុងម្លប់ខាងក្រោយវិហារ ផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ ហើយធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តណា ក្នុងវេលាថ្ងៃ សមាធិនិមិត្តរបស់លោកនោះឯង រមែងកម្រើក ( ក្នុងមនោទ្វារ ) ក្នុងសម័យនោះ ។ ហេតុនោះ បានជាសម័យនោះ មិនមែនជាសម័យ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទេ ។ ម្នាលអាវុសោ លុះតែសម័យណា ភិក្ខុដែលមានចិត្តចម្រើន ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ ទើបគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុឯទៀត និយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ មិនមែន

ជាសម័យ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទេ ។ ម្នាលអាវុសោ លុះតែសម័យណា ភិក្ខុដែលមានចិត្តចម្រើនក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងសតិចំពោះមុខ សម័យនោះ កាយរបស់លោក កំពុងតាំងនៅក្នុងឱជារស ( អាហារ ) លោកកំពុងសប្បាយនឹងធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ព្រោះហេតុនោះ សម័យនោះ ទើបជាសម័យ គួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ទើបព្រះមហាកច្ចានៈដ៏មានអាយុ បាននិយាយនឹងពួកភិក្ខុជាថេរៈយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ការនោះខ្ញុំបានស្តាប់ចំពោះព្រះភក្ត្រ ខ្ញុំបានរៀនចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគយ៉ាងនេះថា ម្នាលភិក្ខុ សម័យដែលគួរចូលទៅឃើញភិក្ខុដែលមានចិត្តចម្រើននេះ មាន ៦ ។ ៦ តើអ្វីខ្លះ ។ ម្នាលភិក្ខុ សម័យណា ភិក្ខុក្នុងសាសនានេះ មានចិត្តត្រូវកាមរាគៈគ្របសង្កត់ហើយ រវើរវាយដោយកាមរាគ ទាំងមិនដឹងនូវការលះកាមរាគដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សម័យនោះ ត្រូវចូលទៅរកភិក្ខុជាអ្នកមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំមានចិត្តត្រូវកាមរាគគ្របសង្កត់ហើយ រវើរវាយដោយកាមរាគ ទាំងមិនដឹងនូវការលះកាមរាគ ដែលកើតឡើងហើយ ឲ្យពិតប្រាកដទេ សូមលោកដ៏មានអាយុ អាណិតសម្តែងធម៌ដល់ខ្ញុំ ដើម្បីលះកាមរាគ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្តែងធម៌ដល់ភិក្ខុនោះ ដើម្បីលះកាមរាគ ។ ម្នាលភិក្ខុ

នេះជាសម័យដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទី ១ ។ ម្នាល ភិក្ខុ មួយទៀត សម័យណា ភិក្ខុមានចិត្តត្រូវព្យាបាទគ្របសង្កត់ ។បេ។ មានចិត្តត្រូវថីនមិទ្ធៈគ្របសង្កត់ មានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ មានចិត្តត្រូវវិចិកិច្ឆាគ្របសង្កត់ ។បេ។ មិនដឹង មិនឃើញ នូវនិមិត្តដែលខ្លួនអាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សម័យនោះ ទើបជាសម័យគួរចូលទៅរកភិក្ខុ ដែលមានចិត្តចម្រើន ហើយនិយាយយ៉ាងនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ ខ្ញុំមិនដឹង មិនឃើញនិមិត្ត ( ដែលខ្ញុំ ) អាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្ត នូវនិមិត្តណា ហើយអស់អាសវៈទាំងឡាយ ដោយឥតអន្តរាយនោះ សូមលោកដ៏មានអាយុ អាណិតសម្ដែងធម៌ដល់ខ្ញុំ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ភិក្ខុដែលមានចិត្តចម្រើន គង់នឹងសម្ដែងធម៌ដល់ភិក្ខុនោះ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុ នេះជាសម័យ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើនទី ៦ ។ ម្នាលអាវុសោទាំងឡាយ ការនោះ ខ្ញុំបានស្ដាប់ចំពោះព្រះភក្ត្រ ខ្ញុំបានរៀនហើយចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា ម្នាលភិក្ខុ នេះឯងជាសម័យទាំង ៦ នេះ ដែលគួរចូលទៅឃើញ ភិក្ខុដែលមានចិត្តចម្រើន ។

# អដ្ឋកថា

## ទុតិយសមយសូត្រ

[ ២៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសមយសូត្រទី ៨ ដូចតទៅនេះ បទថា **មណ្ឌលមាឡេ** បានដល់ ក្នុងរោងឆាន់ ។ បទថា **ចារិត្តកិលមថោ** បានដល់ សេចក្តីលំបាក ដែលកើតឡើងអំពីការត្រាច់បិណ្ឌបាត ។ បទថា **ភត្តកិលមថោ** បានដល់ ការក្រវល់ក្រវាយដែលកើតអំពីភត្ត ។ បទថា **វិហារបច្ឆាយាយំ** បានដល់ ស្រមោលខាងចុងវិហារ ។ បទថា **យទេវស្ស ឋិតា សមាធិនិមិត្តំ មនសិកតំ ហោតិ** សេចក្តីថា ក្នុងសម័យនោះ សមថ-និមិត្តនោះឯង នឹងសញ្ចរទៅក្នុងមនោទ្វាររបស់ភិក្ខុ ដែលអង្គុយក្នុងទីសម្រាក ពេលថ្ងៃ ។ បទថា **ឱជដ្ឋាយី** សេចក្តីថា ស្ថិតនៅ គឺប្រតិស្ឋាននៃឱជៈ ។ បទថា **ជាសុកស្ស ហោតិ** សេចក្តីថា លោកមានផាសុក ។ បទថា **សម្មុខា** សេចក្តីថា ក្នុងទីចំពោះមុខអ្នកប្រាប់ ។ បទថា **សុតំ** សេចក្តីថា បានស្តាប់ ដោយសោតធាតុ ។ បទថា **បដិគ្គហិតំ** សេចក្តីថា ផ្គងដោយចិត្ត ៗ។

**អដ្ឋកថាទុតិយសមយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ឧទាយិសូត្រទី ៩

[ ២៩ ] គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះឧទាយិដ៏មានអាយុថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ កាលបើព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀម ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុអស់វារៈ ២ ដងថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ កាលបើព្រះដ៏មានព្រះភាគត្រាស់យ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀមទៀត ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុជាគម្រប់ ៣ ដងថា ម្នាលឧទាយិ អនុស្សតិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ ព្រះឧទាយិដ៏មានអាយុ ក៏នៅស្ងៀមអស់វារៈ ៣ ដងទៀត ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បាននិយាយនឹងព្រះឧទាយិដ៏មានអាយុយ៉ាងនេះថា ម្នាលអាវុសោឧទាយិ ព្រះសាស្តាទ្រង់ត្រាស់ហៅអ្នក ។ ម្នាលអាវុសោ អានន្ទ ខ្ញុំបានឮព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ រឭកឃើញនូវបុព្វេនិវាសបានច្រើនប្រការ គឺ ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រឭកឃើញនូវបុព្វេនិវាសបានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ការរឭកឃើញជាតិនេះ ឈ្មោះថា អនុស្សតិដ្ឋាន ។ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ តថាគតដឹងច្បាស់ថា ឧទាយិនេះ ជាមោឃបុរស មិនមែនជា

ប្រកបរឿយៗ នូវអធិចិត្ត ( សមាធិវិបស្សនា ) ទេ ។ ម្នាលអានន្ទ អនុស្ស-តិដ្ឋាន តើមានប៉ុន្មានយ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន អនុស្សតិដ្ឋាន មាន ៥ ។ ៥ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ។បេ។ ចូលតតិយជ្ឈាន ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុចម្រើនយ៉ាងនេះហើយ បានធ្វើរឿយៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីជាសុខក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុធ្វើទុកក្នុងចិត្ត នូវសេចក្តីសម្គាល់នូវពន្លឺ អធិដ្ឋាននូវសេចក្តីសម្គាល់ថាថ្ងៃ គឺតាំងចិត្តក្នុងវេលាថ្ងៃ យ៉ាងណា ក្នុងវេលាយប់ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា ក្នុងវេលាថ្ងៃក៏យ៉ាងនោះ ជាបុគ្គលមានចិត្តជាប្រក្រតីដែលនីវរណៈរួបរឹតមិនបាន តែងចម្រើនចិត្ត ប្រកបដោយពន្លឺ ( ដើម្បីបានទិព្វចក្ខុ ) ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចម្រើនយ៉ាងនេះហើយ បានធ្វើរឿយៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីបានញាណទស្សនៈ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះ ខាងលើតាំងអំពីបាតជើង ខាងក្រោមតាំងអំពីចុងសក់ទីបំផុតជុំវិញអំពីត្រឹមស្បែក ដែលពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស

ខ្ទាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចម្រើនយ៉ាងនេះហើយ បានធ្វើរឿយៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅ ដើម្បីលះនូវកាមរាគ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ដូចភិក្ខុណា ឃើញនូវសរីរៈ ដែលគេចោលទៅក្នុងព្រៃស្មសាន ទោះស្លាប់ ១ ថ្ងៃក្តី ស្លាប់ ២ ថ្ងៃក្តី ស្លាប់ ៣ ថ្ងៃក្តី ជាសាកសពហើមប៉ោង មានសម្បុរខៀវដោយច្រើន មានខ្ទុះចេញតាមទ្វារផ្សេងៗ ភិក្ខុនោះប្រៀបផ្ទឹមនឹងកាយ ( ខ្លួន ) នេះ យ៉ាងនេះថា សូម្បីកាយនេះសោត ក៏មានសភាពដូច្នោះ គង់នឹងក្លាយទៅដូច្នោះ កន្លងមិនផុត ដូច្នោះដែរ ។ ពុំនោះសោត ដូចភិក្ខុណាឃើញសរីរៈដែលគេចោលនៅក្នុងព្រៃស្មសាន ត្រូវពួកក្អែកជញ្ជែងក្តី ពួកត្រដក់គម្រង់ជញ្ជែងក្តី ពួកត្មាតជញ្ជែងក្តី ពួកស្វានជញ្ជែងក្តី ពួកចចកកកេរស៊ីក្តី បាណកជាតិ ( ពួកដង្កូវ ) ផ្សេងៗ រួងជញ្ជក់ស៊ីក្តី ភិក្ខុនោះ ប្រៀបផ្ទឹមនឹងកាយនេះយ៉ាងនេះថា ទោះកាយនេះសោត ក៏មានសភាពដូច្នោះ គង់នឹងក្លាយទៅដូច្នោះ មិនកន្លងយ៉ាងនោះទៅបានឡើយ ។ ឬថា ដូចភិក្ខុឃើញសរីរៈដែលគេចោលក្នុងព្រៃស្មសាន ជារាងឆ្អឹងប្រកបដោយសាច់ និងឈាម មានសរសៃជាគ្រឿងចងរាងឆ្អឹងឥតមានសាច់ គ្រាន់តែនៅប្រឡាក់ដោយឈាម ដែលជាប់គ្នាដោយសរសៃ រាងឆ្អឹងឥតមានសាច់ និងឈាមជាប់គ្នា ដោយសរសៃជាគ្រឿងចងឆ្អឹងដែលដាច់ចេញហើយ ខ្ចាត់ខ្ចាយរាត់រាយ ទៅក្នុងទិសតូច និងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅ

ដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះ ទៅដោយឡែក ឆ្អឹងទ្រូងខ្នងទៅដោយឡែក រលាក្បាលទៅដោយឡែក ភិក្ខុនោះប្រៀបផ្ទឹមនឹងកាយនេះ យ៉ាងនេះថា កាយនេះសោត ក៏មានសភាពដូច្នោះ គង់នឹងក្លាយទៅដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ មួយទៀតឬថា ដូចភិក្ខុឃើញនូវសរីរៈដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងទទេមានសម្បុរសដូចស័ង្ខ រាងឆ្អឹងដែលគរជាពំនូក កន្លងហួស ១ ឆ្នាំហើយពុកផុយខ្ទេចខ្ទីជាកម្ទេច ភិក្ខុនោះ ប្រៀបផ្ទឹមនឹងកាយនេះយ៉ាងនេះថា ទោះជាកាយនេះក៏ដោយ ក៏មានសភាពយ៉ាងដូច្នោះ គង់នឹងក្លាយទៅដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះ ពុំបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាអនុស្សតិដ្ឋានដែលភិក្ខុបានចម្រើនយ៉ាងនេះ បានធ្វើរឿយៗ យ៉ាងនេះហើយ តែងប្រព្រឹត្តទៅដើម្បីដកចោលនូវអស្មិមានះ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុលះបង់សេចក្តីសុខផង ។បេ។ ចូលចតុត្ថជ្ឈាន ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចម្រើនយ៉ាងនេះ បានធ្វើរឿយៗ យ៉ាងនេះហើយតែងប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹងនូវធាតុច្រើនប្រការ ។ បពិត្រព្រះអង្គដ៏ចម្រើននេះឯងជាអនុស្សតិដ្ឋានទាំង ៥ ។ ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទបើដូច្នោះ ចូរអ្នកចាំនូវអនុស្សតិដ្ឋានទី ៦ នេះថែមទៀតចុះ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ប្រុងស្មារតីឈានដើរទៅមុខ ប្រុងស្មារតីត្រឡប់មកវិញប្រុងស្មារតីឈរ ប្រុងស្មារតីដេក ប្រុងស្មារតីអធិដ្ឋានការងារ ។ ម្នាលអានន្ទ

នេះជាអនុស្សតិដ្ឋាន ដែលភិក្ខុបានចម្រើនយ៉ាងនេះ បានធ្វើរឿយៗ យ៉ាងនេះ តែងប្រព្រឹត្តទៅដើម្បីបាននូវសតិសម្បជញ្ញៈ ។

# អដ្ឋកថា

## ឧទាយិសូត្រ

[ ២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទាយិសូត្រទី ៩ ដូចតទៅនេះ បទថា **ឧទាយិ** បានដល់ ព្រះលោឡុទាយិត្ថេរ ។ បទថា **សុណាមហំ អាវុសោ** សេចក្តីថា នែអាវុសោ ខ្ញុំមិនមែនមនុស្សគ ខ្ញុំបានឮព្រះតម្រាស់របស់ព្រះមានព្រះភាគ តែខ្ញុំនៅពិចារណាបញ្ហានៅឡើយ ។ បទថា **អធិចិត្តំ** បានដល់ សមាធិចិត្ត និងវិបស្សនាចិត្ត ។ បទថា **ឥទំ ភន្តេ អនុស្សតិដ្ឋានំ** សេចក្តីថា ហេតុនៃអនុស្សតិ ពោល គឺឈានទាំង ៣ នេះ ។ បទថា **ទិដ្ឋ-ធម្មសុខវិហារាយ សំវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការនៅជាសុខក្នុងអត្តភាពនេះប៉ុណ្ណោះ ។ បទថា **អាលោកសញ្ញំ** បានដល់ សញ្ញាដែលកើតឡើងក្នុងអាលោកនិមិត្ត ។ បទថា **ទិវាសញ្ញំ អធិដ្ឋាតិ** បានដល់ តាំងសញ្ញាថា ពេលថ្ងៃ ។ បទថា **យថា ទិវា តថា រត្តឹ** សេចក្តីថា ក្នុងពេលថ្ងៃ លោកមនសិការអាលោកសញ្ញា ដោយប្រការណា ក្នុងពេលយប់ ក៏មនសិការអាលោកសញ្ញានោះ យ៉ាងនោះដូចគ្នា ។

*បទថា* **យថា រត្តឹ តថា ទិវា** *សេចក្ដីថា ក្នុងពេលយប់ លោកមន-សិការអាលោកសញ្ញា យ៉ាងណា ក្នុងពេលថ្ងៃ ក៏មនសិការអាលោកសញ្ញានោះ យ៉ាងនោះដូចគ្នា ។ បទថា* **វិវដេន** *បានដល់ ប្រាកដហើយ ។ បទថា* **អបរិយោនទ្ធេន** *សេចក្ដីថា ត្រូវនីវរណៈរួបរឹតក៏មិនមែន ។ បទថា* **សប្បភាសំ ចិត្តំ ភាវេតិ** *សេចក្ដីថា ចម្រើននូវចិត្ត មួយអន្លើដោយពន្លឺ គឺញុំាងចិត្តនោះឲ្យចម្រើន ដើម្បីជាប្រយោជន៍ដល់ទិព្វចក្ខុញ្ញាណ ។ ពាក្យណាដែលអានន្ទត្ថេរក្រាបទូលថា* **អាលោកសញ្ញំ មនសិករោតិ** *ពាក្យនោះគប្បីយល់ថា លោកពោលសំដៅយកអាលោកសញ្ញា ដែលកម្ចាត់ថីនមិទ្ធៈចេញទៅ មិនគួរយល់ថា សំដៅយកអាលោកសញ្ញា គឺទិព្វចក្ខុញ្ញាណ ។*

*បទថា* **ញាណទស្សនប្បដិលាភាយ** *សេចក្ដីថា ដើម្បីការបានចំពោះនូវញាណទស្សនៈ ពោល គឺទិព្វចក្ខុ ។ បណ្ដាពាក្យជាដើមថា* **ឥមមេវ កាយំ** *ពាក្យណាដែលគប្បីពោល ពាក្យទាំងអស់នោះ ខ្ញុំបានពោលដោយពិស្ដារហើយ ដោយអាការទាំងពួង ក្នុងវគ្គដែលពោលដោយកាយគតាសតិកម្មដ្ឋានក្នុងវិសុទ្ធិមគ្គ ។ បទថា* **កាមរាគស្ស បហានាយ** *សេចក្ដីថា ដើម្បីលះរាគៈដែលកើតឡើងអំពីបញ្ចកាមគុណ ។ បទថា* **សេយ្យថាបិ បស្សេយ្យ** *សេចក្ដីថា គប្បីឃើញយ៉ាងណា ។ បទថា* **សរីរំ** *បានដល់ សរីរៈនៃបុគ្គលដែលស្លាប់ហើយ ។ បទថា* **សីវថិកាយ ឆឌ្ឌិតំ** *បានដល់ រាងកាយដែលគេចោលក្នុងព្រៃស្មសាន ។ សាកសពដែលឈ្មោះថា* **ឯកាហមតំ** *ព្រោះជាសាកសព*

របស់សត្វដែលស្លាប់ហើយ ១ ថ្ងៃ ។ ឈ្មោះថា **ទ្វីហមតំ** ព្រោះជាសាកសព របស់សត្វដែលស្លាប់ហើយ ២ ថ្ងៃ ។ ឈ្មោះថា **តីហមតំ** ព្រោះជាសាកសព របស់សត្វដែលស្លាប់ហើយ ៣ ថ្ងៃ ។ សរីរសត្វ ឈ្មោះថា **ឧទ្ធុមាត** ព្រោះក្រោយអំពីអស់ជីវិតហើយ នឹងប៉ោងធំឡើងៗ តាមលំដាប់ ដូចសប់ដោយខ្យល់ ។ **ឧទ្ធុមាតក** គឺឧទ្ធុមាតនោះឯង ។ ម្យ៉ាងទៀត សាកសពដែលហើមធំឡើងៗ គួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា ឧទ្ធុមាតកៈ ។ សាកសពដែលមានពណ៌ប្រែប្រួលទៅ លោកហៅថា **វិនីល** ។ **វិនីលក** គឺវិនីលនោះឯង ។ ម្យ៉ាងទៀត សាកសពដែលមានពណ៌ខៀវជាំ រហូតគួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិនីលក** ពាក្យថា វិនីលកៈនេះ ជាឈ្មោះរបស់សាកសពដែលមានពណ៌ក្រហម ក្នុងទីដែលប៉ោងឡើង មានពណ៌ស ក្នុងទីដែលហូរខ្ទុះ និងដោយច្រើន ក៏មានពណ៌ខៀវ ដូចខ្ទប់ដោយសំពត់ពណ៌ខៀវ ក្នុងទីដែលខៀវ ។ សាកសពដែលមានខ្ទុះហូរចេញតាមទ្វារទាំង ៩ ដែលជាទីខ្ទុះចេញ ឈ្មោះថា **វិបុព្វ** ។ **វិបុព្វក** គឺវិបុព្វៈនោះឯង ។ ម្យ៉ាងទៀត សាកសពដែលមានខ្ទុះហូរចេញ គួរខ្ពើម ព្រោះជារបស់បដិកូល ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វក** ។ សាកសពដែលក្លាយជាសពមានខ្ទុះហូរ គឺដល់នូវភាពយ៉ាងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា **វិបុព្វកជាត** ។

បទថា **សោ ឥមមេវ កាយំ** សេចក្តីថា ភិក្ខុនោះនាំកាយរបស់ខ្លួននេះ

ចូលទៅប្រៀបធៀបជាមួយកាយនោះ ដោយញាណ ។ ប្រៀបធៀបដូចម្តេច ប្រៀបធៀបថា សូម្បីកាយនេះឯង ក៏មានយ៉ាងនេះជាធម្មតា នឹងជាយ៉ាងនេះ កន្លងសភាពយ៉ាងនេះទៅ មិនបានឡើយ ។ មានពាក្យអធិប្បាយថា ព្រោះធម៌ទាំង ៣ យ៉ាង គឺអាយុ ភ្លើងធាតុ និងវិញ្ញាណមាន ទើបកាយនេះ គួរដល់ឥរិយាបថ មានការឈរបាន ដើរបានជាដើម តែព្រោះប្រាសចាកធម៌ទាំង ៣ យ៉ាងនេះ រាងកាយនេះ ក៏មានសភាពយ៉ាងនេះ ជាធម្មតា គឺមានសភាពស្អុយរលួយយ៉ាងនេះដូចគ្នា ។ បទថា **ឯវំភាវី** សេចក្តីថា មានការផ្សេងគ្នាជាសាកសពហើមប៉ោងជាដើម យ៉ាងនេះដូចគ្នា ។ បទថា **ឯវំអនតីតោ** សេចក្តីថា មិនកន្លងនូវភាពជាសាកសពហើមប៉ោងយ៉ាងនេះទៅបានឡើយ ។ បទថា **ខជ្ជមានំ** សេចក្តីថា សត្វទាំងឡាយ មានក្អែកជាដើមទំត្រង់ពោះជាដើម ហើយចឹកស៊ីសាច់ពោះ បបូរមាត់ គ្រាប់ភ្នែកជាដើម ។ បទថា **មំសលោហិតំ** បានដល់ សាកសពដែលប្រកបដោយសាច់ និងឈាមប្រឡាក់នៅឡើយ ។ បទថា **និម្មំសលោហិតមក្ខិតំ** សេចក្តីថា ដល់នូវការអស់ទៅហើយ លោហិតក៏មិនទាន់ស្ងួត ។ ពាក្យថា **និម្មំសលោហិតមក្ខិតំ** នេះ លោកពោលសំដៅដល់សាកសពដែលអស់សាច់ តែនៅប្រឡាក់ដោយឈាម ។ បទថា **អញ្ញេន** សេចក្តីថា ដោយទិសផ្សេងៗ ។ បទថា **ហត្ថដ្ឋិកំ** សេចក្តីថា ឆ្អឹងដៃ ទោះបីបែកចេញជា ៦៤ កំណាត់ ក៏ខ្ចាត់ខ្ចាយរាត់រាយទៅ ក្នុងឆ្អឹងជើងជាដើម ក៏មានន័យនេះដូចគ្នា ។

*បទថា* **តេរោវស្សិកានិ** *សេចក្តីថា ឆ្អឹងទាំងឡាយដែលចោលជាង ១ ឆ្នាំ ។ បទថា* **បូតីនិ** *សេចក្តីថា ឆ្អឹងដែលតាំងនៅកណ្តាលវាលជាង ១ ឆ្នាំនោះឯង និងពុកផុយ ព្រោះត្រូវខ្យល់ កម្តៅថ្ងៃ និងភ្លៀង តែឆ្អឹងដែលកប់នៅក្នុងផែនដី នៅបានយូរ ។ បទថា* **ចុណ្ណកជាតានិ** *បានដល់ ខ្ទាត់ខ្ទាយជាលម្អិតតូចធំទៅ ។ ក្នុងបទទាំងអស់ត្រូវធ្វើការប្រកបសេចក្តី ដោយអំណាចនៃសត្វទាំងឡាយ មានសត្វចឹកស៊ីជាដើម ដោយន័យដែលពោលហើយថា* **សោ ឥមមេវ** *ដូច្នេះ ។ បទថា* **អស្មិមានសមុគ្ឃាតាយ** *សេចក្តីថា ដើម្បីដកនូវមានះ ៩ យ៉ាងដែលប្រព្រឹត្តទៅហើយថា អញមានដូច្នេះ ។ បទថា* **អនេកធាតុប្បដិវេធាយ** *សេចក្តីថា ដើម្បីចាក់ធ្លុះនូវធាតុផ្សេងៗ មិនមែនតិច ។ បទថា* **សតោវ អភិក្កមតិ** *សេចក្តីថា កាលនឹងដើរ ក៏ជាបុគ្គលប្រកបទៅដោយសតិបញ្ញា ដើរទៅ ។ បទថា* **សតោវ បដិក្កមតិ** *សេចក្តីថា កាលនឹងថយក្រោយ ក៏ប្រកបទៅដោយសតិបញ្ញាថយក្រោយ ។ សូម្បីបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា* **សតិសម្បជញ្ញាយ** *សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការរឭកបាន និងការដឹង ។ ក្នុងសូត្រនេះព្រះមានព្រះភាគត្រាស់សតិ និងបញ្ញាលាយគ្នា ដោយប្រការដូច្នេះ ។*

## អដ្ឋកថាឧទាយិសូត្រទី ៩ ចប់

# សុត្តន្តបិដក

## អនុត្តរិយសូត្រទី ១០

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ ( ធម្មជាតប្រសើរបំផុត ) នេះមាន ៦ ។ ៦ តើអ្វីខ្លះ ។ គឺទស្សនានុត្តរិយៈ ( ការឃើញដ៏ប្រសើរបំផុត ) ១ សវនានុត្តរិយៈ ( ការស្តាប់ប្រសើរបំផុត ) ១ លាភានុត្តរិយៈ ( ការបានប្រសើរបំផុត ) ១ សិក្ខានុត្តរិយៈ ( ការសិក្សាប្រសើរបំផុត ) ១ បារិចរិយានុត្តរិយៈ ( ការបម្រើប្រសើរបំផុត ) ១ អនុស្សតានុត្តរិយៈ ( ការរឭកប្រសើរបំផុត ) ១ ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ទៅមើលដំរីរ័តន៍ក្តី ទៅមើលសេះរ័តន៍ក្តី ទៅមើលមណិរ័តន៍ក្តី ឬក៏ទៅមើលរបស់ធំតូចណាមួយក្តី ទៅមើលសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការឃើញនុ៎ះ ឈ្មោះថាឃើញហើយ ការឃើញនុ៎ះមិនមែនជាមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ តែថា ការឃើញនុ៎ះជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា ទៅឃើញតថាគត ឬសាវកនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការឃើញនុ៎ះ ទើបប្រសើរបំផុតជាងការឃើញ

ទាំងឡាយ ( ព្រោះប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលទៅឃើញតថាគត ឬសាវកនៃតថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការឃើញនេះទើបតថាគតឲ្យឈ្មោះថា ការឃើញប្រសើរបំផុត ។ ទស្សនានុត្តរិយៈ ដូច្នេះឯង ។ ចំណែកសវនានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ទៅស្តាប់សំឡេងស្គរក្តី ទៅស្តាប់សំឡេងពិណក្តី ទៅស្តាប់សំឡេងច្រៀងក្តី ឬក៏ទៅស្តាប់សំឡេងជំតូចណាមួយក្តី ទៅស្តាប់ធម៌របស់សមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការស្តាប់នុ៎ះ ក៏ឈ្មោះថាស្តាប់ដែរ ការស្តាប់នុ៎ះ មិនមែនថាមិនស្តាប់ទេ ម្នាលភិក្ខុទាំងឡាយ តែថាការស្តាប់នុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែ បុគ្គលណាទៅស្តាប់ធម៌តថាគត ឬសាវកនៃតថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្តាប់នុ៎ះ ទើបប្រសើរបំផុត ជាងការស្តាប់ទាំងឡាយ ព្រោះ

ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលទៅស្តាប់ធម៌តថាគត ឬសាវកនៃតថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះ ទើបតថាគតឲ្យឈ្មោះថា ការស្តាប់ប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ ដូច្នេះឯង ។ ឯលាភានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បានលាភ គឺកូនក្តី បានលាភ គឺប្រពន្ធក្តី បានលាភ គឺទ្រព្យក្តី ឬក៏បានលាភជំតូចណាមួយក្តី បានសេចក្តីជឿក្នុងសមណៈ ឬព្រាហ្មណ៍ ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា លាភនុ៎ះក៏ជាលាភដែរហើយ មិនមែនឥតលាភទេ ម្នាលភិក្ខុទាំងឡាយ តែថាលាភនុ៎ះជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីស្ងប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បានសេចក្តីជឿក្នុងតថាគត ឬក្នុងសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននុ៎ះ ប្រសើរបំផុត ជាងលាភទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បី

កន្លងបង់នូវសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបានសេចក្តីជឿក្នុងតថាគត ឬក្នុងសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបាននេះទើបតថាគតឲ្យឈ្មោះថា ជាលាភប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ ដូច្នេះឯង ។ ចំណែកខាងសិក្ខានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ សិក្សាវិជ្ជាដំរីក្តី សិក្សាវិជ្ជាសេះក្តី សិក្សាវិជ្ជារថក្តី សិក្សាវិជ្ជាធ្នូក្តី សិក្សាវិជ្ជាដងដាវក្តី ឬក៏សិក្សាវិជ្ជាខ្ពស់ទាបក្តី សិក្សា ( វិជ្ជា ) របស់សមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការសិក្សានុ៎ះ ក៏ជាការសិក្សាហើយ មិនមែនមិនសិក្សាទេ ម្នាលភិក្ខុទាំងឡាយ តែថា ការសិក្សានុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរឥតប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីរម្ងាប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណាសិក្សានូវអធិសីល សិក្សានូវអធិចិត្ត សិក្សានូវអធិប្បញ្ញាក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការសិក្សានុ៎ះ ប្រសើរបំផុត ជាងការសិក្សាទាំងឡាយ ព្រោះ

ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គល សិក្សានូវអធិសីលក្តី សិក្សានូវអធិចិត្តក្តី សិក្សានូវអធិប្បញ្ញាក្តី ក្នុងធម្មវិន័យ ដែលតថាគតសម្តែង ហើយ ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះ ទើបតថាគតហៅថា ការសិក្សាប្រសើរបំផុត ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ ដូច្នេះឯង ។ ឯបារិចរិយានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ បម្រើក្សត្រក្តី បម្រើព្រាហ្មណ៍ក្តី បម្រើគហបតីក្តី ឬបម្រើបុគ្គលធំតូចណាមួយក្តី បម្រើសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការបម្រើនុ៎ះ ក៏ជាការបម្រើហើយ មិនមែនមិនបម្រើទេ ម្នាលភិក្ខុទាំងឡាយ តែថា ការបម្រើនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ។បេ។ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណា បម្រើតថាគត ឬសាវករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបម្រើនុ៎ះ ប្រសើរបំផុត ជាងការបម្រើទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក

និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន គឺនៅត្រង់បុគ្គលបម្រើតថាគត ឬសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការបម្រើនេះ ទើបតថាគតហៅថា ការបម្រើប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ បារិចរិយានុត្តរិយៈ ដូច្នេះឯង ។ ចំណែកអនុស្សតានុត្តរិយៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រឭកនូវការបានកូនក្តី រឭកនូវការបានប្រពន្ធក្តី រឭកនូវការបានទ្រព្យក្តី ឬក៏រឭកនូវការបានរបស់តូចធំក្តី រឭកនូវសមណៈ ឬព្រាហ្មណ៍ជាមិច្ឆាទិដ្ឋិ អ្នកប្រតិបត្តិខុសក្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ការរឭកនោះ ក៏ឈ្មោះថា រឭកដែរ មិនមែនមិនរឭកទេ ម្នាលភិក្ខុទាំងឡាយ តែថាការរឭកនុ៎ះ ជារបស់ថោក សម្រាប់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ ឥតប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយទេ ដើម្បីប្រាសចាកតម្រេកទេ ដើម្បីរលត់កិលេសទេ ដើម្បីរម្ងាប់ទុក្ខទេ ដើម្បីដឹងប្រសើរទេ ដើម្បីត្រាស់ដឹងទេ ដើម្បីនិព្វានទេ ។ ម្នាលភិក្ខុទាំងឡាយ លុះតែបុគ្គលណារឭកនូវតថាគត ឬសាវ័ករបស់តថាគត ហើយជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់មាំ ជឿស៊ប់ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ សេចក្តីរឭកនុ៎ះ ប្រសើរបំផុតជាងសេចក្តីរឭកទាំងឡាយ ព្រោះប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធិដល់សត្វទាំងឡាយ

ដើម្បីកន្លងបង់នូវសោក និងខ្សឹកខ្សួល ដើម្បីឲ្យអស់ទៅនៃទុក្ខ និងទោមនស្ស ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវនិព្វាន គឺនៅត្រង់បុគ្គលរឭក នូវតថាគត ឬសាវ័ករបស់តថាគត ជាអ្នកមានសទ្ធាខ្ជាប់ខ្ជួន មានចិត្តស្រឡាញ់ មាំ ជឿស៊ប់ ជ្រះថ្លាខ្លាំង ម្នាលភិក្ខុទាំងឡាយ ការរឭកនេះ ទើបតថាគត ហៅថា ការរឭកប្រសើរបំផុត ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអនុត្តរិយៈ ទាំង ៦ យ៉ាង ។

ពួកជនណា បាននូវទស្សនានុត្តរិយៈផង នូវសវនា-
នុត្តរិយៈផង បាននូវលាភានុត្តរិយៈផង ត្រេកអរក្នុង
សិក្ខានុត្តរិយៈផង តាំងនៅក្នុងបារិចរិយានុត្តរិយៈ
ចម្រើននូវអនុស្សតានុត្តរិយៈ ដែលប្រកបដោយ
វិវេកដ៏ក្សេម ជាគ្រឿងឲ្យដល់និព្វានផង ពួកជន
នោះ រីករាយក្នុងសេចក្តីមិនប្រហែស មានបញ្ញា
ចាស់ សង្រួមហើយក្នុងសីល រមែងដឹងនូវអមត-
និព្វាន ដែលជាទីរលត់ទុក្ខ តាមកាលដ៏គួរ ។

**អនុត្តរិយវគ្គទី ៣ ចប់**

### ឧទ្ទាននៃអនុត្តរិយវគ្គនោះ គឺ

ព្រះដ៏មានព្រះភាគ ទ្រង់គង់ជិតសាមគ្រាម ១
សូត្រ អបរិហានិយធម៌ ១ សូត្រ ភ័យជាឈ្មោះ
របស់កាមជាដើម ១ សូត្រ ភិក្ខុអាចទម្លាយភ្នំ
ហិមពាន្ត ១ សូត្រ ភិក្ខុរមែងស្អាត ១ សូត្រ
ព្រះមហាកច្ចានៈ ១ សូត្រ សម័យ ២ សូត្រ
ឧទាយិត្ថេរ ១ សូត្រ អនុត្តរិយៈ ១ សូត្រ ។

# អដ្ឋកថា

## អនុត្តរិយសូត្រ

[ ៣០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនុត្តរិយសូត្រទី ១០ ដូចតទៅនេះ បទថា **ឧច្ចាវចំ** សេចក្តីថា ម្យ៉ាងទៀត ទៅដើម្បីស្តាប់សំឡេងធំតូចណាមួយ ឈ្មោះថា សំឡេងខ្ពស់ទាប ។ បទថា **ហីនំ** ប្រែថា ថោកទាប ។ បទថា **គម្មំ** សេចក្តីថា ជាការមើលរបស់អ្នកស្រុក ។ បទថា **ពោថុជ្ជនិកំ** សេចក្តីថា ជារបស់មាននៃបុថុជ្ជន ។ បទថា **អនរិយំ** សេចក្តីថា មិនប្រសើរ គឺមិនឧត្តម បានដល់ មិនបរិសុទ្ធិ ។ បទថា **អនត្ថសញ្ហិតំ** សេចក្តីថា មិនប្រកបដោយប្រយោជន៍ឡើយ ។

បទថា **ន និព្វិទាយ** សេចក្តីថា មិនមែនដើម្បីជាប្រយោជន៍ដល់ការ

នឿយណាយក្នុងវដ្តៈ ។ បទថា **ន វិរាគាយ** សេចក្តីថា មិនមែនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ការប្រាសចាករាគៈជាដើម ។ បទថា **ន និរោធាយ** សេចក្តីថា មិនមែនប្រព្រឹត្តទៅដើម្បីរលត់ការមិនប្រព្រឹត្តទៅនៃកិលេស មានរាគៈជាដើម ។ បទថា **ន ឧបសមាយ** គឺមិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់កិលេស មានរាគៈជាដើម ។ បទថា **ន អភិញ្ញាយ** សេចក្តីថា មិនមែនប្រព្រឹត្តទៅដើម្បីដឹងក្រៃលែង ។

បទថា **ន សម្ពោធាយ** សេចក្តីថា មិនមែនចាក់ធ្លុះមគ្គញាណទាំង ៤ ពោល គឺសម្ពោធិញ្ញាណ ។ បទថា **ន និព្វានាយ** សេចក្តីថា មិនមែនប្រព្រឹត្តទៅដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ បទថា **និវិដ្ឋសទ្ធោ** សេចក្តីថា ជាអ្នកមានសទ្ធាតាំងមាំហើយ ។ បទថា **និវិដ្ឋបេមោ** សេចក្តីថា មានសេចក្តីស្រឡាញ់តាំងមាំហើយ ។ បទថា **ឯកន្តគតោ** សេចក្តីថា ដល់នូវទីបំផុត អធិប្បាយថា មានសទ្ធាមិនកម្រើក ។ បទថា **អភិប្បសន្នោ** សេចក្តីថា ជ្រះថ្លាពន់ពេក ។ បទថា **ឯតទានុត្តរិយំ** សេចក្តីថា ការឃើញនេះ ជាការឃើញដែលមិនមានការឃើញដទៃក្រៃលែងជាង ។

បទថា **ហត្ថិស្មិម្បិ សិក្ខតិ** សេចក្តីថា សិក្សាហត្ថិសិប្បៈដែលមានដំរីជានិមិត្ត ដែលត្រូវសិក្សា ក្នុងបទទាំងឡាយដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **ឧច្ចាវចំ** បានដល់ សិក្សាសិប្បៈធំតូច ។ បទថា **ឧបដ្ឋិតា ចារិចរិយេ** សេចក្តីថា បម្រើដោយការប្រណិប័តន៍ ។ បទថា **ភាវយន្តិ អនុស្សតី**

សេចក្តីថា ចម្រើនអនុស្សតិដ៏កំពូល ។ បទថា **វិវេកបដិសញ្ញុត្តំ** សេចក្តីថា ធ្វើឲ្យអាស្រ័យព្រះនិព្វាន ។ បទថា **ខេមំ** បានដល់ ប្រាសចាកឧបទ្ទវន្តរាយ ។ បទថា **អមតគាមិនំ** សេចក្តីថា ឲ្យដល់នូវព្រះនិព្វាន អធិប្បាយថា បំពេញអរិយមគ្គ ។

បទថា **អប្បមាទេ បមុទិតា** សេចក្តីថា ត្រេកអរទូទៅក្នុងការមិនប្រមាទ គោល គឺការមិននៅប្រាសចាកសតិ ។ បទថា **និបកា** សេចក្តីថា ប្រកបដោយបញ្ញាជាគ្រឿងរក្សាខ្លួន ។ បទថា **សីលសំវុតា** សេចក្តីថា សង្រួម គឺរារាំងដោយសីល ។ បទថា **តេ វេ កាលេន បច្ចន្តិ** សេចក្តីថា ភិក្ខុទាំងនោះឯង រមែងដឹងតាមកាលដែលសមគួរ ។ បទថា **យត្ថ ទុក្ខំ និរុជ្ឈតិ** អធិប្បាយថា ភិក្ខុទាំងនោះ រមែងដឹងឋានៈដែលជាទីរម្ងាត់វដ្តទុក្ខទាំងអស់ គឺ អមតមហានិព្វាន ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់អនុត្តរិយៈ ៦ លាយគ្នាដូច្នេះឯង ។

**អដ្ឋកថាអនុត្តរិយសូត្រទី ១០ ចប់**

**អនុត្តរិយវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## សេក្ខបរិហានិយវគ្គ

### សេក្ខសូត្រទី ១

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ (ចាកគុណធម៌ខាងលើ ) ដល់ភិក្ខុជាសេក្ខៈ ( ទាំង ៧ ពួក ) ។ ធម៌ ៦ យ៉ាង ដូចម្តេចខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងការចរចា ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងពួកគណៈ ១ មិនមានសេចក្តីគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុជាសេក្ខៈ ។ ធម៌ ៦ យ៉ាង ដូចម្តេចខ្លះ ។ គឺសេចក្តីមិនត្រេកអរក្នុងការងារ ១ សេចក្តីមិនត្រេកអរក្នុងការចរចា ១ សេចក្តីមិនត្រេកអរក្នុងការដេក ១ សេចក្តីមិនត្រេកអរក្នុងពួកគណៈ ១ គ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់ភិក្ខុជាសេក្ខៈ ។

# អដ្ឋកថា

## សេក្ខបរិហានិយវគ្គទី ៤

### សេក្ខសូត្រ

[ ៣១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសេក្ខសូត្រទី ១ នៃសេក្ខបរិហានិយវគ្គទី ៤ ដូចតទៅនេះ បទថា **សេក្ខស្ស** បានដល់ ព្រះសេក្ខបុគ្គល ៧ ពួក ។ សម្រាប់បុថុជ្ជន មិនមានអ្វីដែលត្រូវពោលដល់ឡើយ ។ បទថា **បរិហានាយ** សេចក្តីថា ដើម្បីវិនាសចាកគុណជាន់ខ្ពស់ ។ល។

អដ្ឋកថា សេក្ខសូត្រទី ១ ចប់

# សុត្តន្តបិដក

## បឋមអបរិហានិយសូត្រទី ២

[ ៣២ ] គ្រានោះ មានទេវតា ១ អង្គ កាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង ដូច

ម្ដេចខ្លះ ។ គឺសេចក្ដីគោរពក្នុងព្រះសាស្ដា ១ សេចក្ដីគោរពក្នុងព្រះធម៌ ១ សេចក្ដីគោរពក្នុងព្រះសង្ឃ ១ សេចក្ដីគោរពក្នុងសិក្ខា ១ សេចក្ដីគោរពក្នុងអប្បមាទធម៌ ១ សេចក្ដីគោរពក្នុងបដិសន្ថារៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យដល់ភិក្ខុ ។ ទេវតានោះ បានក្រាបទូលដូច្នេះហើយ ។ ព្រះសាស្ដាក៏មានព្រះហឫទ័យរីករាយ ។ លុះទេវតានោះដឹងថា ព្រះសាស្ដាមានព្រះហឫទ័យរីករាយនឹងអាត្មាហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយក៏បាត់ក្នុងទីនោះឯង ។ លុះដល់រាត្រីបឋមយាមនោះកន្លងហើយ ព្រះដ៏មានព្រះភាគ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ មានទេវតា ១ រូប កាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពន ទាំងអស់ឲ្យភ្លឺស្វាង ចូលមករកតថាគត លុះចូលមកដល់ថ្វាយបង្គំតថាគត ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះឋិតនៅក្នុងទីសមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង ដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពក្នុងព្រះសាស្ដា ១ សេចក្ដីគោរពក្នុងព្រះធម៌ ១ សេចក្ដីគោរពក្នុងព្រះសង្ឃ ១ សេចក្ដីគោរពក្នុងសិក្ខា ១ សេចក្ដីគោរពក្នុងអប្បមាទធម៌ ១ សេចក្ដីគោរពក្នុងបដិសន្ថារៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បី

សេចក្ដីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយដូច្នេះ លុះនិយាយដូច្នេះហើយ ក៏ថ្វាយបង្គំតថាគតធ្វើប្រទក្សិណ ហើយបាត់ក្នុងទីនោះឯង ។

ភិក្ខុអ្នកគោរពក្នុងព្រះសាស្ដា គោរពក្នុងព្រះធម៌ គោរព
ដ៏ក្លៀវក្លា ក្នុងព្រះសង្ឃ ( គោរពក្នុងសិក្ខា ) គោរពក្នុង
សេចក្ដីមិនប្រមាទ គោរពក្នុងបដិសន្ថារៈហើយ មិនគួរដើម្បី
សាបសូន្យ រមែងតាំងនៅក្នុងទីជិតនៃព្រះនិព្វាន ។

# អដ្ឋកថា

## បឋមអបរិហានិយសូត្រ

[ ៣២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអបរិហានិយសូត្រទី ២ ដូចតទៅនេះ ភាពជាបុគ្គលគោរពក្នុងព្រះសាស្ដា ឈ្មោះថា **សត្ថុគារវតា** ។ ភាពជាអ្នកគោរពក្នុងលោកុត្តរធម៌ ៩ យ៉ាង ឈ្មោះថា **ធម្មគារវតា** ។ ភាពជាបុគ្គលគោរពក្នុងសង្ឃ ឈ្មោះថា **សង្ឃគារវតា** ។ ការធ្វើសេចក្ដីគោរពក្នុងសិក្ខា ៣ ឈ្មោះថា **សិក្ខាគារវតា** ។ ភាពជាអ្នកគោរពក្នុងសេចក្ដីមិនប្រមាទ ឈ្មោះថា **អប្បមាទគារវតា** ។ ភាពជាអ្នកគោរពក្នុងបដិសណ្ឋារៈ ២ យ៉ាង ដោយអំណាចនៃធម៌ និងអាមិស ឈ្មោះថា **បដិសន្ថារគារវតា** ។

ភិក្ខុ ឈ្មោះថា **សត្ថុគរុ** ព្រោះមានសេចក្ដីគោរពក្នុងព្រះសាស្ដា ។ ភិក្ខុ ឈ្មោះថា **ធម្មគរុ** ព្រោះមានសេចក្ដីគោរពក្នុងព្រះធម៌ ។ ការគោរពដ៏ធ្ងន់ ឈ្មោះថា **តិព្វគារវោ** ។ ភិក្ខុ ឈ្មោះថា **បដិសន្ថារគារវោ** ព្រោះមានការគោរពក្នុងបដិសណ្ឋារៈ ។

**អដ្ឋកថា បឋមអបរិហានិយសូត្រទី ២ ចប់**

# ទុតិយអបរិហានិយសូត្រទី ៣

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ យប់មិញនេះ មានទេវតា ១ រូប កាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ចូលមករកតថាគត លុះចូលមកដល់ ថ្វាយបង្គំតថាគត ហើយឋិតក្នុងទីសមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះ ឋិតក្នុងទីសមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង ដូចម្ដេចខ្លះ ។ គឺសេចក្ដីគោរពក្នុងព្រះសាស្ដា ១ សេចក្ដីគោរពក្នុងព្រះធម៌ ១ សេចក្ដីគោរពក្នុងព្រះសង្ឃ ១ សេចក្ដីគោរពក្នុងសិក្ខា ១ សេចក្ដីគោរពក្នុងការខ្មាសបាប ១ សេចក្ដីគោរពក្នុងការខ្លាចបាប ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីមិនសាបសូន្យ ដល់ភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ ទេវតានោះ បាននិយាយដូច្នេះ លុះបាននិយាយ ដូច្នេះហើយ ក៏ថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយបាត់ក្នុងទីនោះឯង ។

ភិក្ខុអ្នកគោរពក្នុងព្រះសាស្តា គោរពក្នុងព្រះធម៌ គោរព
ដ៏ក្លៀវក្លាក្នុងព្រះសង្ឃ ( គោរពក្នុងសិក្ខា ) បរិបូណ៌
ដោយហិរិ និងឱត្តប្បៈ ប្រកបដោយសេចក្តីឱនលំទោន
ដ៏ទន់ភ្លន់ មិនគួរដើម្បីសាបសូន្យ រមែងតាំងនៅក្នុងទីជិត
នៃព្រះនិព្វាន ។

# អដ្ឋកថា

## ទុតិយអបរិហានិយសូត្រ

[ ៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអបរិហានិយសូត្រទី ៣ ដូចតទៅនេះ បទថា **សប្បតិស្សា** បានដល់ មានប្រធាន មានការគោរព ។ ម្យ៉ាងទៀត ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ហិរិឱត្តប្បៈលាយឡំគ្នា ។៚

**អដ្ឋកថា ទុតិយអបរិហានិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មោគ្គល្លានសូត្រទី ៤

[ ៣៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះមហាមោគ្គល្លាន ដ៏មានអាយុ ចូលទៅកាន់ទីស្ងាត់ពួនសម្ងំហើយ មានសេចក្តីត្រិះរិះក្នុងចិត្ត កើតឡើងយ៉ាងនេះថា ពួកទេវតាណា មានសេចក្តីដឹងថា យើងទាំងឡាយ ជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង បាន ត្រាស់ដឹងទៅខាងមុខ យ៉ាងនេះដែរឬទេ ។ សម័យនោះ មានភិក្ខុ ឈ្មោះ តិស្សៈ ធ្វើមរណកាលថ្មីៗ បានទៅកើតក្នុងព្រហ្មលោកណាមួយ ។ ឯពួក ព្រហ្មក្នុងព្រហ្មលោកនោះ ក៏ស្គាល់ព្រហ្មនោះ យ៉ាងនេះថា នេះជាព្រហ្ម ឈ្មោះតិស្សៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ គ្រានោះ ព្រះមហា-មោគ្គល្លានដ៏មានអាយុ បាត់អំពីវត្តជេតពន ទៅប្រាកដឯព្រហ្មលោកនោះ ដូច ជាបុរសដ៏មានកម្លាំងលាដៃដែលខ្ទនបត់ ឬបត់ដៃដែលខ្ទនលា ដូច្នោះឯង ។ តិស្សព្រហ្មបានឃើញព្រះមហាមោគ្គល្លានដ៏មានអាយុ កំពុងនិមន្តមកអំពី ចម្ងាយ លុះឃើញហើយ ក៏បាននិយាយនឹងព្រះមហាមោគ្គល្លានដ៏មានអាយុ យ៉ាងនេះថា បពិត្រព្រះមោគ្គល្លានជាម្ចាស់ សូមលោកនិមន្តចូលមកចុះ បពិត្រ ព្រះមោគ្គល្លានជាម្ចាស់ លោកនិមន្តមកស្រួលហើយ បពិត្រព្រះមោគ្គល្លាន ជាម្ចាស់ លោកបានធ្វើបរិយាយនេះ ដើម្បីមកក្នុងទីនេះ អស់កាលយូរណាស់ ហើយហ្ន៎ បពិត្រព្រះមោគ្គល្លានជាម្ចាស់ សូមលោកគង់ចុះ នេះជាអាសនៈ

ដែលខ្ញុំក្រាលប្រគេន ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ គង់លើអាសនៈ ដែលតិស្សព្រហ្មក្រាលប្រគេន ។ ឯតិស្សព្រហ្ម ថ្វាយបង្គំព្រះមហាមោគ្គល្លាន ដ៏មានអាយុហើយ អង្គុយក្នុងទីសមគួរ ។ លុះតិស្សព្រហ្ម អង្គុយក្នុងទីសមគួរហើយ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានថេរវាចាយ៉ាងនេះថា ម្នាលតិស្សៈ ពួកទេវតាណាហ្ន៎ មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង បានត្រាស់ដឹងទៅខាងមុខយ៉ាងនេះដែរឬទេ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកទេវតា ជាន់ចាតុម្មហារាជិកៈ មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង នឹងបានត្រាស់ដឹងទៅខាងមុខ យ៉ាងនេះដែរ ។ ម្នាលតិស្សៈ ពួកទេវតាជាន់ចាតុម្មហារាជិកៈទាំងអស់ មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះដែរ ឬដូចម្តេច ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកទេវតាជាន់ចាតុម្មហារាជិកៈ មិនមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខយ៉ាងនេះ ទាំងអស់គ្នាទេ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកចាតុម្មហារាជិកៈទេវតាណា មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំក្នុងព្រះសង្ឃ មិនប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរ

ហើយ ពួកចាតុម្មហារាជិកទេវតានោះ មិនមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះទេ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកចាតុម្មហារាជិកទេវតាណា ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរហើយ ទើបពួកចាតុម្មហារាជិកទេវតានោះ មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះបាន ។ ម្នាលតិស្សៈ ចុះមានតែពួកចាតុម្មហារាជិកទេវតាមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខ ប៉ុណ្ណោះឬ ឬក៏ពួកតាវត្តិង្សទេវតាក្តី ។បេ។ ពួកយាមទេវតាក្តី ពួកតុសិតទេវតាក្តី ពួកនិម្មានរតីទេវតាក្តី ពួកបរនិម្មិតវសវត្តីទេវតាក្តី មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹង ទៅខាងមុខយ៉ាងនេះដែរ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកបរនិម្មិតវសវត្តីទេវតាមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹង ទៅខាងមុខយ៉ាងនេះបាន ។ ម្នាលតិស្សៈ ពួកបរនិម្មិតវសវត្តីទេវតា មានសេចក្តីដឹងថា

យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះ ជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹង ទៅខាងមុខយ៉ាងនេះ ទាំងអស់គ្នា ឬដូចម្តេច ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកបរនិម្មិតវសវត្តីទេវតា មិនមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹង ទៅខាងមុខយ៉ាងនេះ ទាំងអស់គ្នាទេ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ ពួកបរនិម្មិតវសវត្តីទេវតាណា មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ មិនប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះសង្ឃ មិនប្រកបដោយសីលទាំង-ឡាយ ដែលព្រះអរិយៈត្រេកអរហើយ ពួកបរនិម្មិតវសវត្តីទេវតាទាំងនោះ មិនមានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះ ជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹងទៅខាងមុខ យ៉ាងនេះទេ ។ បពិត្រព្រះមោគ្គល្លានជាម្ចាស់ លុះតែពួកបរនិម្មិតវសវត្តីទេវតាណា ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមាំទាំ ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលព្រះអរិយៈត្រេកអរហើយ ទើបបានពួកបរនិម្មិតវសវត្តីទេវតាទាំងនោះ មានសេចក្តីដឹងថា យើងជាអ្នកដល់ស្រោតៈ មានសភាពមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង និងមានសេចក្តីត្រាស់ដឹង ទៅខាងមុខ យ៉ាងនេះបាន ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ត្រេកអរអនុមោទនា

កាសិតរបស់តិស្សព្រហ្មហើយ ហើយក៏បាត់ពីព្រហ្មលោក មកប្រាកដឯវត្ត
ជេតពនវិញ ដូចជាបុរសមានកម្លាំងលាដៃដែលខ្លួនបត់ ឬបត់ដៃដែលខ្លួនលា
ដូច្នោះឯង ។

# អដ្ឋកថា

## មោគ្គល្លានសូត្រ

[ ៣៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមោគ្គល្លានសូត្រទី ៤ ដូចតទៅនេះ
បទថា **តិស្សោ នាម ភិក្ខុ** បានដល់ ភិក្ខុដែលជាសទ្ធិវិហារិក នៃព្រះថេរៈ
នោះឯង ។ បទថា **មហិទ្ធិកោ មហានុភាវោ** សេចក្តីថា ភិក្ខុ ឈ្មោះថា
**មហិទ្ធិកោ** ព្រោះមានឫទ្ធិច្រើន ដោយអត្ថថា ញុំាងកិច្ចឲ្យសម្រេចបាន ។
ឈ្មោះថា **មហានុភាវោ** ព្រោះមានអានុភាពច្រើន ដោយអត្ថថា សូម្បីពង្រីក
ទៅរឿយៗ ។ បទថា **ចិរស្សំ ខោ មារិស មោគ្គល្លាន ឥមំ បរិយាយ-
មកាសិ** នេះ ជាពាក្យរាក់ទាក់ដែលគួរស្រឡាញ់ តាមប្រក្រតីរបស់សត្វលោក
អធិប្បាយថា សត្វលោកឃើញអ្នកដទៃ ដែលបែកគ្នាយូរមកខ្លះ ឃើញអ្នក
ដែលមានលក្ខណៈគួរពេញចិត្ត ដែលមិនធ្លាប់មកហើយខ្លះ និងពោលពាក្យ
ជាដើមថា នៃអ្នកដ៏ចម្រើន អ្នកមកអំពីណា នៃអ្នកដ៏ចម្រើន យូរណាស់ហើយ
ទើបអ្នកមក អ្នកដ៏ចម្រើន ដឹងផ្លូវមកទីនេះបានដូចម្តេច អ្នកវង្វេងផ្លូវមកដែរ

ឬយ៉ាងណា តែតិស្សព្រហ្មនេះពោលយ៉ាងនេះ ព្រោះធ្លាប់ឃើញលោកមកហើយ ។ ពិតហើយ ព្រះថេរៈទៅព្រហ្មលោកនោះឯង តាមកាលដ៏សមគួរ ។ បណ្ដាបទទាំងនោះ បទថា **បរិយាយមកាសិ** សេចក្ដីថា បានធ្វើទៅតាមវារៈ ។ បទថា **យទិទំ ឥធាគមនាយ** មានអធិប្បាយដែលលោកពោលថា យូរៗ លោកម្ចាស់នឹងបានធ្វើវារៈដើម្បីមកកាន់ព្រហ្មលោកនេះ ។

បទថា **ឥទមាសនំ បញ្ញត្តំ** សេចក្ដីថា តិស្សព្រហ្មក្រាលព្រហ្មបល្ល័ង្កដែលមានតម្លៃច្រើន ហើយពោលយ៉ាងនេះ ។ បទថា **អវេច្ចប្បសាទេន** សេចក្ដីថា ដោយការជ្រះថ្លាដែលសម្បយុត្តដោយមគ្គ ដែលមិនញាប់ញ័រដែលខ្លួនបានសម្រេចហើយ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់សោតាបត្តិមគ្គញាណ ។

**អដ្ឋកថា មោគ្គល្លានសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## វិជ្ជាភាគិយសូត្រទី ៥

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ ពួកធម៌ជាចំណែកនៃវិជ្ជានេះ មាន ៦ យ៉ាង ។ ធម៌ ៦ យ៉ាង តើដូចម្ដេច ។ គឺសេចក្ដីសម្គាល់ ( ដែលកើតឡើង ) ក្នុងអនិច្ចានុបស្សនាញាណ ១ សេចក្ដីសម្គាល់ ( ដែលកើតឡើង ) ក្នុង

ទុក្ខានុបស្សនាញាណ ១ សេចក្តីសម្គាល់ ( ដែលកើតឡើង ) ក្នុងអនត្តានុបស្សនាញាណ ១ សេចក្តីសម្គាល់ ( ដែលកើតឡើង ) ក្នុងបហានានុបស្សនាញាណ ១ សេចក្តីសម្គាល់ ( ដែលកើតឡើង ) ក្នុងវិរាគានុបស្សនាញាណ ១ សេចក្តីសម្គាល់ ( ដែលកើតឡើង ) ក្នុងនិរោធានុបស្សនាញាណ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ ដែលជាចំណែកនៃវិជ្ជា ៦ យ៉ាង ។

# អដ្ឋកថា

## វិជ្ជាភាគិយសូត្រ

[ ៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិជ្ជាភាគិយសូត្រទី ៥ ដូចតទៅនេះ បទថា **វិជ្ជាភាគិយា** សេចក្តីថា ជាធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា សញ្ញាដែលកើតឡើងក្នុងអនិច្ចានុបស្សនាញាណ ឈ្មោះថា **អនិច្ចសញ្ញា** ។ សញ្ញាដែលកើតឡើងក្នុងទុក្ខានុបស្សនាញាណ ឈ្មោះថា **អនិច្ចេទុក្ខសញ្ញា** ។ សញ្ញាដែលកើតឡើងក្នុងអនត្តានុបស្សនាញាណ ឈ្មោះថា **ទុក្ខេអនត្តសញ្ញា** ។ សញ្ញាដែលកើតឡើង ក្នុងបហានានុបស្សនាញាណ ឈ្មោះថា **បហានសញ្ញា** ។ សញ្ញាដែលកើតឡើងក្នុងវិរាគានុបស្សនាញាណ ឈ្មោះថា **វិរាគសញ្ញា** ។ សញ្ញាដែលកើតឡើងក្នុង និរោធានុបស្សនាញាណ ឈ្មោះថា **និរោធសញ្ញា** ៕

# សុត្តន្តបិដក

## វិវាទមូលសូត្រទី ៦

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ មូលហេតុនៃសេចក្តីវិវាទនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ភិក្ខុនោះមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តាផង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ផង មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃផង ជាអ្នកមិនធ្វើឲ្យបរិបូណ៌ ក្នុងសិក្ខាផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសាស្តា មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះធម៌ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ក្នុងព្រះសង្ឃ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាទេ ភិក្ខុនោះ រមែងបង្កវិវាទក្នុងសង្ឃ ដែលជាវិវាទប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន មិនចម្រើនដល់ជនច្រើន មិនជាប្រយោជន៍ ជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ បានឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ ត្រូវព្យាយាម ដើម្បីលះមូលហេតុនៃវិវាទដ៏លាមកនោះចេញ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនឃើញ

មូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅទេ ម្នាល ភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ សមបីប្រតិបត្តិ ដើម្បីមិនឲ្យ មូលហេតុនៃវិវាទដ៏លាមកនោះ ជាប់តាមតទៅទៀតបាន ។ យ៉ាងនេះ ឈ្មោះថា ការលះមូលហេតុនៃវិវាទដ៏លាមកនោះចេញ ។ យ៉ាងនេះ ឈ្មោះថា មិនមានមូលហេតុនៃវិវាទដ៏លាមកនុ៎ះ ជាប់តាមទៅទៀត ១ ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណ និងវាយឫកស្មើ ១ ។បេ។ ជាអ្នក មានសេចក្តីឫស្យា មានសេចក្តីកំណាញ់ ១ ជាអ្នកអួតអាង មានពុតត្បុត ១ ជាអ្នកមានសេចក្តីប្រាថ្នាដ៏លាមក មានសេចក្តីយល់ខុស ១ ជាអ្នកស្ទាប អង្អែល តាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ស្ទាបអង្អែលតាមសេចក្តីយល់របស់ខ្លួន ប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តាផង មិនគោរពមិនកោតក្រែង ក្នុងព្រះធម៌ផង មិនគោរពមិនកោតក្រែង ក្នុង ព្រះសង្ឃផង មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា មិនគោរពមិនកោតក្រែង ក្នុងព្រះសាស្តា ។បេ។ មិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាទេ ភិក្ខុនោះរមែងបង្កវិវាទឲ្យកើតឡើង ក្នុងព្រះសង្ឃ ដែលជាវិវាទប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិន ចម្រើនដល់ជនច្រើន មិនជាប្រយោជន៍ ជាទុក្ខដល់ទេវតា និងមនុស្សទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញមូលហេតុ

នៃវិវាទ មានសភាពយ៉ាងនេះ ជាខាងក្នុង ឬជាខាងក្រៅហើយ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ ត្រូវព្យាយាម ដើម្បីលះបង់នូវវិវាទមូលដ៏លាមកនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនពិចារណាឃើញនូវវិវាទមូល មានសភាពយ៉ាងនេះ ទាំងខាងក្នុង ទាំងខាងក្រៅទេ ម្នាលភិក្ខុទាំងឡាយ ក្នុងរឿងនោះ អ្នកទាំងឡាយ សមបីប្រតិបត្តិដើម្បីមិនឲ្យវិវាទមូលដ៏លាមកនុ៎ះ ជាប់តាមតទៅទៀតបាន ។ យ៉ាងនេះ ឈ្មោះថា ការលះបង់ចោលនូវវិវាទមូលដ៏លាមកនោះ ។ យ៉ាងនេះ ឈ្មោះថា មិនមានវិវាទមូលដ៏លាមកនុ៎ះ ជាប់តាមតទៅទៀត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហើយ ជាវិវាទមូល ៦ យ៉ាង ។

# អដ្ឋកថា

## វិវាទមូលសូត្រ

[ ៣៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិវាទមូលសូត្រទី ៦ ដូចតទៅនេះ ហេតុនៃវិវាទ ឈ្មោះថា **វិវាទមូល** ។ បុគ្គលដែលប្រកបដោយសេចក្ដីក្រោធមានការអាក់អន់ជាលក្ខណៈ ឈ្មោះថា **កោធន** អ្នកប្រកបដោយការចងសេចក្ដីក្រោធ មានការមិនលះបង់នូវពៀរជាលក្ខណៈ ឈ្មោះថា **ឧបនាហី** ។ បទថា **អហិតាយ ទុក្ខាយ ទេវមនុស្សានំ** សេចក្ដីថា ការទាស់ទែងរបស់

ភិក្ខុ ២ រូប រមែងប្រព្រឹត្តទៅដើម្បីវត្ថុមិនជាប្រយោជន៍ ដើម្បីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

សួរថា ប្រព្រឹត្តទៅបានដូចម្តេច ។ ឆ្លើយថា កាលភិក្ខុ ២ រូបទាស់គ្នា អន្តេវាសិករបស់លោកទាំង ២ នោះ ក្នុងវត្តនោះ ក៏នឹងវិវាទគ្នា ភិក្ខុនីសង្ឃ ដែលទទួលឱវាទនៃភិក្ខុទាំងនោះ ក៏វិវាទគ្នា ដូចក្នុងកោសម្ពិក្ខន្ធកៈ បន្ទាប់អំពីនោះ ឧបដ្ឋាករបស់លោកទាំងនោះ ក៏នឹងវិវាទគ្នា បន្ទាប់មក អារក្ខទេវតានៃមនុស្សទាំងឡាយ ក៏បែកគ្នាជា ២ ចំណែក អារក្ខទេវតាខាងធម្មវាទី ក៏យ៉ាងនោះ គឺជាខាងចំណែកធម្មវាទីភិក្ខុ ទេវតាដែលជាអធម្មវាទី ក៏ជាបក្ខពួកអធម្មវាទី ។ បន្ទាប់អំពីនោះ ភុម្មទេវតាដែលជាមិត្តរបស់អារក្ខទេវតាទាំងឡាយ ក៏បែកបាក់គ្នា ។ បើខាងអធម្មវាទីមានចំនួនច្រើនជាងខាងធម្មវាទី តអំពីនោះ ទេវតា និងមនុស្សទាំងឡាយ ក៏នឹងទាញយកវត្ថុដែលមនុស្សចំនួនច្រើនកាន់យក នាំគ្នាលះបង់ចោលធម៌ កាន់យកអធម៌ដោយច្រើននោះឯង ។ ទេវតា និងមនុស្សទាំងនោះ កាលរស់នៅកាន់យកអធម៌ជាគោល ក៏កើតក្នុងអបាយ ការទាស់ទែងគ្នានៃភិក្ខុទាំង ២ រូប រមែងប្រព្រឹត្តទៅដើម្បីវត្ថុ មិនជាប្រយោជន៍ ដើម្បីជាទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការដូចពណ៌នា ដូច្នេះ ។

បទថា **អជ្ឈត្តំ វា** បានដល់ បរិស័ទខាងក្នុងរបស់លោកទាំងឡាយ ។ បទថា **ពហិទ្ធា** បានដល់ បរិស័ទរបស់អ្នកដទៃ ។ បុគ្គលដែលប្រកប

ដោយការលុបគុណ ដែលមានការលុបគុណរបស់អ្នកដទៃជាលក្ខណៈ ឈ្មោះថា **មក្ខី** ។ បុគ្គលដែលប្រកបទៅដោយការវាយស្មើ មានការប្រៀបផ្ទឹមជាលក្ខណៈ ឈ្មោះថា **បឡាសី** ។ បុគ្គលដែលប្រកបដោយការច្រណែន មានការច្រណែនក្នុងសក្ការៈរបស់អ្នកដទៃជាលក្ខណៈ ឈ្មោះថា **ឥស្សុកី** ។

បុគ្គលប្រកបទៅដោយការកំណាញ់ទាំងឡាយ មានការកំណាញ់លំនៅជាដើម ឈ្មោះថា **មច្ឆរី** ។ បុគ្គលអួតអាង ឈ្មោះថា **សឋ** ។ បុគ្គលដែលបិទបាំងរបស់ដែលធ្វើហើយ ឈ្មោះថា **មាយាវី** ។ បុគ្គលទ្រុស្តសីល ដែលប្រាថ្នានូវការលើកតម្កើងនូវគុណដែលមិនមាន ឈ្មោះថា **ទុស្សីលោ** ។

បទថា **មិច្ឆាទិដ្ឋិ** បានដល់ នត្ថិកវាទីបុគ្គល អហេតុកវាទីបុគ្គល អកិរិយវាទីបុគ្គល ។ បទថា **សន្ទិដ្ឋិបរាមាសី** បានដល់ ប្រកាន់មាំនូវទិដ្ឋិរបស់ខ្លួននោះឯង ។ បទថា **អាធានគ្គាហី** បានដល់ អ្នកប្រកាន់មាំ ។ បទថា **ទុប្បដិនិស្សគ្គី** បានដល់ ជាអ្នកមិនអាចលះទិដ្ឋិដែលខ្លួនប្រកាន់ហើយ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគ ត្រាស់វដ្តៈតែម្យ៉ាងប៉ុណ្ណោះ ៕

**អដ្ឋកថា វិវាទមូលសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ទានសូត្រទី ៧

[ ៣៧ ] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសិកា ជាមាតាព្រះនន្ទ អ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈ តម្កល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាន ។ ព្រះដ៏មានព្រះភាគ បានទតឃើញនន្ទមាតាឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈ ដោយទិព្វចក្ខុដ៏បរិសុទ្ធិ កន្លងចក្ខុរបស់មនុស្សធម្មតា ដែលកំពុងតម្កល់ទាន ប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមោគ្គល្លាន ជាប្រធាន លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ នន្ទមាតាឧបាសិកា អ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈនោះ កំពុងតម្កល់ទាន ប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្ត និងព្រះមោគ្គល្លាន ជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះទានប្រកបដោយអង្គ ៦ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសានានេះ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកទាំងឡាយមាន ៣ ។ ចុះអង្គរបស់ទាយក ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ទាយកជាអ្នកមានចិត្ត ត្រេកអរមុនអំពីកាលឲ្យ ១ កំពុងតែឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា ១ លុះឲ្យហើយ មានចិត្តរីករាយ ១ ។ នេះជាអង្គទាយកមាន ៣ ។ អង្គរបស់បដិគ្គាហកទាំងឡាយមាន ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហក

ជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ ១ ប្រាសចាកទោសៈ ឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ ១ ប្រាសចាកមោហៈ ឬប្រតិបត្តិដើម្បីបន្ទោបង់មោហៈ ១ ។ នេះជាអង្គបដិគ្គាហកមាន ៣ ។ អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកមាន ៣ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវប្រមាណនៃបុណ្យរបស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្ដីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅ ដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នា ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយកំណត់ប្រមាណនូវទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណោះអាឡ្ហកក្ដី ទឹកប៉ុណ្ណោះរយអាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះពាន់អាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះសែនអាឡ្ហកៈក្ដីបានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា គំនរទឹកដ៏ច្រើនប៉ុណ្ណោះបាន ។ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់ប្រមាណនូវបុណ្យនៃទាន ប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នា

ត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យដ៏ច្រើនប៉ុណ្ណោះបាន ក៏យ៉ាងនោះដែរ ។

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ
កំពុងឲ្យ ធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយក៏មានចិត្ត
ត្រេកអរ ( តាមក្រោយ ) នេះជាសេចក្តីបរិបូណ៌
របស់ទាន ។ បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាក
ទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជា
ព្រហ្មចារី មានសេចក្តីសង្រួម ឈ្មោះថា ជាខេត្តនៃ
ទានដ៏បរិបូណ៌ ( ដោយគុណ ) ។ បុគ្គលខ្វល់ខ្វាយ
ដោយខ្លួនឯង ឲ្យទានដោយដៃរបស់ខ្លួន ។ ទាននោះ
ជាទានមានផលច្រើន ព្រោះខ្លួនផង ព្រោះបុគ្គល
ដទៃផង ។ អ្នកប្រាជ្ញជាបណ្ឌិត អ្នកមានសទ្ធា មាន
ចិត្តផុតស្រឡះ ( ចាកសេចក្តីកំណាញ់ ) លុះឲ្យ
ទានយ៉ាងនេះហើយ ក៏រមែងទៅកើតក្នុងទេវលោក
ជាសុខ ឥតមានទុក្ខ ។

# អដ្ឋកថា

## ទានសូត្រ

[ ៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទានសូត្រទី ៧ ដូចតទៅនេះ បទថា **វេឡុកណ្ឌកី** បានដល់ ជាអ្នកក្រុងវេឡុកណ្ឌកៈ ។ បទថា **ឆឡង្គសមន្នាគតំ** សេចក្តីថា ប្រកបទៅដោយអង្គនៃគុណ ៦ ប្រការ ។ បទថា **ទក្ខិណំ បតិដ្ឋាបេតិ** សេចក្តីថា ថ្វាយទាន ។ បទថា **បុព្វេ ទានា សុមនោ** សេចក្តីថា ជាអ្នកដល់នូវសោមនស្សអស់មួយខែថា អញនឹងថ្វាយទាន អធិប្បាយថា បុព្វចេតនាក្នុងពាក្យថា **បុព្វេ ទានា សុមនោ** នេះ រមែងមានដល់អ្នកផ្តើមធ្វើស្រែ ដោយគិតថា អញនឹងថ្វាយទានដោយសម្ទូង ដែលកើតអំពីស្រែនេះ ចាប់តាំងអំពីកាលដែលកើតការគិតឡើងថា អញនឹងថ្វាយទាន ។ ឯមុញ្ចនចេតនាដែលត្រាស់យ៉ាងនេះថា កាលឲ្យរមែងញុំាងចិត្តឲ្យជ្រះថ្លា ដូច្នេះ រមែងមានក្នុងកាលឲ្យទានប៉ុណ្ណោះ តែអបរចេតនានេះថា កាលឲ្យហើយ ក៏មានចិត្តត្រេកអរ ដូច្នេះ រមែងមានដល់បុគ្គលដែលរឭកដល់ ខាងក្រោយក្នុងកាលបន្តៗ មក ។

បទថា **វីតរាគា** បានដល់ ព្រះខីណាស្រពដែលប្រាសចាករាគៈ ។ បទថា **រាគវិនយាយ វា បដិបន្នា** សេចក្តីថា បដិបទាប្រព្រឹត្តទៅដែលជាហេតុនាំរាគៈចេញទៅ ទេសនានេះជាទេសនាយ៉ាងឧក្រិដ្ឋ មិនមែនសម្រាប់ព្រះខីណាស្រពតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីព្រះអនាគាមី ព្រះសកទាគាមី ព្រះសោតាបន្ន ដោយហោច សាមណេរដែលកាន់កណ្ឋៈ បួសហើយក្នុងថ្ងៃនោះ

ទក្ខិណាដែលថ្វាយហើយ រមែងឈ្មោះថា ប្រកបទៅដោយអង្គ ៦ ទាំងអស់ ព្រោះថា សូម្បីសាមណេរ ក៏បួសដើម្បីសោតាបត្តិមគ្គដូចគ្នា ។

ការបរិបូណ៌នៃទាន ឈ្មោះថា **យញ្ញស្ស សម្បទា**។ បទថា **សញ្ញតា** សេចក្តីថា សង្រួមហើយ ដោយការសង្រួម គឺសីល ។ បទថា **សយំ អាចមយិត្វាន** សេចក្តីថា ខ្លួនឯងលាងដៃ លាងជើង ហើយលុបមុខ ។ បទថា **សកេហិ ចាណិភិ** សេចក្តីថា ដោយដៃរបស់ខ្លួន ។ បាឋៈជា **សយេហិ** ក៏មាន ។ បទថា **សទ្ធោ** បានដល់ ជឿគុណព្រះរតនត្រ័យ ។ បទថា **មុត្តេន ចេតសា** សេចក្តីថា មានចិត្តរួចផុតអំពីសេចក្តីកំណាញ់ក្នុងលោកជាដើម ។ បទថា **អព្យាបជ្ឈំ សុខំ លោកំ** បានដល់ ទេវលោកដែលប្រាសចាកទុក្ខ មានតែសុខ និងសោមនស្សដ៏ឧឡារ ៕

## អដ្ឋកថាទានសូត្រទី ៧ ចប់

# សុត្តន្តបិដក

## អត្ថការីសូត្រទី ៨

[ ៣៨ ] គ្រានោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលរួសរាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យរួសរាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់យ៉ាងនេះថា មិនមានការធ្វើ ( កម្ម ) ដើម្បីខ្លួន មិនមានការធ្វើ ( កម្ម ) ដើម្បីបុគ្គលដទៃបានឡើយ ។ ម្នាលព្រាហ្មណ៍ តថាគតមិនដែលជួប មិនដែលឮ មនុស្សនិយាយយ៉ាងនេះ យល់យ៉ាងនេះឡើយ ហេតុអ្វី បានជាមនុស្សឈានដើរទៅមុខខ្លួនឯង ឈានដើរត្រឡប់មកខ្លួនឯង និយាយយ៉ាងនេះថា មិនមានការធ្វើ ( កម្ម ) ដើម្បីខ្លួន មិនមានការធ្វើ ( កម្ម ) ដើម្បីបុគ្គលដទៃ ដូច្នេះបាន ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ហេតុនោះ ដូចម្តេច ការផ្តួចផ្តើមនូវសេចក្តីព្យាយាម មានដែរឬទេ ។ មានដែរព្រះអង្គ ។ កាលបើមានការផ្តួចផ្តើមនូវសេចក្តីព្យាយាមហើយ សត្វទាំងឡាយមានសេចក្តីប្រារព្ធ រមែងប្រាកដឡើងដែរឬទេ ។ មានដែរព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលបើមានការផ្តួចផ្តើមនូវសេចក្តីព្យាយាមហើយ សត្វទាំងឡាយ មានសេចក្តីប្រារព្ធ ប្រាកដដោយហេតុណា ហេតុនេះហើយ ជាការធ្វើ ( កម្ម ) ដើម្បីខ្លួន ជាការធ្វើ ( កម្ម ) ដើម្បីបុគ្គលដទៃ របស់សត្វទាំងឡាយ ។ ម្នាលព្រាហ្មណ៍ អ្នក

សម្គាល់ហេតុនោះដូចម្តេច សេចក្តីព្យាយាម មានសភាពចេញចាកការខ្ជិលច្រអូស មានដែរឬទេ ។បេ។ សេចក្តីប្រឹងប្រែងមានដែរឬទេ សេចក្តីរឹងប៉ឹងមានដែរឬទេ សេចក្តីមាំមួនមានដែរឬទេ សេចក្តីខ្វល់ខ្វាយ មានដែរឬទេ ។ មានដែរព្រះអង្គ ។ កាលបើមានសេចក្តីខ្វល់ខ្វាយហើយ សត្វទាំងឡាយ មានសេចក្តីខ្វល់ខ្វាយ ក៏រមែងប្រាកដឡើងដែរឬទេ ។ មានប្រាកដដែរព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលបើសេចក្តីខ្វល់ខ្វាយមានហើយ សត្វទាំងឡាយ មានសេចក្តីខ្វល់ខ្វាយប្រាកដឡើងដោយហេតុណា ហេតុនេះ ជាការធ្វើ ( កម្ម ) ដើម្បីខ្លួន ជាការធ្វើ ( កម្ម ) ដើម្បីបុគ្គលដទៃ របស់សត្វទាំងឡាយ ម្នាលព្រាហ្មណ៍ តថាគតមិនដែលជួប មិនដែលឮ មនុស្សនិយាយយ៉ាងនេះ យល់យ៉ាងនេះឡើយ ដូចម្តេចក៏មនុស្សឈានដើរទៅមុខខ្លួនឯង ឈានដើរត្រឡប់មកខ្លួនឯង មកនិយាយយ៉ាងនេះថា មិនមានការធ្វើ ( កម្ម ) ដើម្បីខ្លួន មិនមានការធ្វើ ( កម្ម ) ដើម្បីបុគ្គលដទៃ សោះឡើយ ។ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។បេ។ ចាប់ដើមតាំងពីថ្ងៃនេះទៅ ជាអ្នកដល់នូវព្រះអង្គជាទីពឹង ស្មើដោយជីវិត ។

# អដ្ឋកថា

## អត្តការីសូត្រ

[ ៣៨ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងអត្តការីសូត្រទី ៨ ដូចតទៅនេះ បទថា* **អទ្ទសំ វា អស្សោសឹ វា** *សេចក្តីថា អញកុំបីបើកភ្នែកឃើញ កុំបីបានឮថា បុគ្គលនោះនៅក្នុងទីឈ្មោះនោះ ឬកុំបីបានឮពាក្យដែលបុគ្គលនោះពោល ។ បទថា* **កថំ ហិ នាម** *សេចក្តីថា ដោយហេតុអ្វី ។*

*សេចក្តីព្យាយាមដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃការចាប់ផ្តើម ឈ្មោះថា* **អារព្ភធាតុ** *។ សេចក្តីព្យាយាមដែលមានសភាវៈឈានចេញទៅអំពីការខ្ជិលច្រអូស ឈ្មោះថា* **និក្កមធាតុ** *។ សភាវៈនៃការឈានមុខ ឈ្មោះថា* **បរក្កមធាតុ** *។ សភាវៈនៃកម្លាំងកាយ ឈ្មោះថា* **ថាមធាតុ** *។ សភាវៈរបស់ធិតិ ( កម្លាំងប្រាជ្ញា ) ឈ្មោះថា* **ធិតិធាតុ** *។ សភាវៈរបស់សេចក្តីព្យាយាម ឈ្មោះថា* **ឧបក្កមធាតុ** *។ម្យ៉ាងទៀត ពាក្យទាំងអស់នេះ ជាឈ្មោះនៃសេចក្តីព្យាយាមតែម្យ៉ាង ដែលប្រព្រឹត្តទៅហើយ ដោយអាការនោះ ។*

**អដ្ឋកថា អត្តការីសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## និទានសូត្រទី ៩

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយ ៣ យ៉ាងនេះ ដែលផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ។ ហេតុ ៣ យ៉ាង តើដូចម្តេច ។ គឺ លោភៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ ទោសៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ មោហៈ ជាហេតុផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ អលោភៈ មិនកើតមកអំពីលោភៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ លោភៈប្រាកដជាកើតមកអំពីលោភៈដដែល ។ ម្នាលភិក្ខុទាំងឡាយ អទោសៈ មិនកើតមកអំពីទោសៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ ទោសៈប្រាកដជាកើតមកអំពីទោសៈដដែល ។ ម្នាលភិក្ខុទាំងឡាយ អមោហៈ មិនកើតមកអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ មោហៈប្រាកដជាកើតមកអំពីមោហៈដដែល ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាក្តី ពួកមនុស្សក្តី ឬសុគតិណាមួយឯទៀត មិនមែនបានប្រាកដអំពីកម្មដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ នរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ឬក៏ទុគ្គតិណាមួយឯទៀត រមែងកើតប្រាកដមកអំពីកម្ម ដែលកើតអំពីលោភៈ កម្មដែលកើតអំពីទោសៈ កម្មដែលកើតអំពីមោហៈជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះហើយ ដែលផ្តួចផ្តើមឲ្យកើតអកុសលកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ

ហេតុទាំង ៣ យ៉ាងនេះ ដែលផ្ដួចផ្ដើមឲ្យកើតកុសលកម្មទាំងឡាយ ។ ចុះហេតុ ៣ យ៉ាង តើដូចម្ដេច ។ គឺអលោភៈជាហេតុផ្ដួចផ្ដើមឲ្យកើតកុសលកម្មទាំងឡាយ ១ អទោសៈ ជាហេតុផ្ដួចផ្ដើមឲ្យកើតកុសលកម្មទាំងឡាយ ១ អមោហៈ ជាហេតុផ្ដួចផ្ដើមឲ្យកើតកុសលកម្មទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ លោភៈមិនមែនកើតមកអំពីអលោភៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អលោភៈ ប្រាកដជាកើតមកអំពីអលោភៈជដែល ។ ម្នាលភិក្ខុទាំងឡាយ ទោសៈមិនមែនកើតមកអំពីអទោសៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អទោសៈប្រាកដជាកើតមកអំពីអទោសៈជដែល ។ ម្នាលភិក្ខុទាំងឡាយ មោហៈមិនមែនកើតអំពីអមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ អមោហៈប្រាកដជាកើតមកអំពីអមោហៈជដែល ។ ម្នាលភិក្ខុទាំង-ឡាយ នរកក្ដី កំណើតតិរច្ឆានក្ដី ប្រេតវិស័យក្ដី ឬក៏ទុគ្គតិណាមួយឯទៀត មិនកើតប្រាកដមកអំពីកម្មដែលកើតពីអលោភៈ កម្មដែលកើតអំពីអទោសៈ កម្មដែលកើតអំពីអមោហៈទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នោះ ពួកទេវតាក្ដី ពួកមនុស្សក្ដី ឬក៏សុគតិណាមួយឯទៀត តែងកើតប្រាកដមកអំពីកម្មដែលកើតអំពីអលោភៈ កម្មដែលកើតអំពីអទោសៈ កម្មដែលកើតមកអំពីអមោហៈជាប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៣ យ៉ាងនេះហើយ តែងផ្ដួចផ្ដើមឲ្យកើតកុសលកម្មទាំងឡាយ ។

# អដ្ឋកថា

## និធានសូត្រ

[ ៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទានសូត្រទី ៩ ដូចតទៅនេះ បទថា **កម្មានំ** បានដល់ កម្មដែលឲ្យដល់នូវវដ្តៈ ។ បទថា **សមុទយាយ** សេចក្តីថា ដើម្បីជាប្រយោជន៍ដល់ការប្រមូលកម្មមក ។ បទថា **និទានំ** បានដល់ជាបច្ច័យ ។ បទថា **លោភជេន** សេចក្តីថា កើតអំពីលោភៈ ។ បទថា **ន បញ្ញាយន្តិ** សេចក្តីថា មិនប្រាកដថា កើតហើយ ព្រោះកម្មបែបនេះ ។

ក្នុងធម៌ចំណែកស បទថា **កម្មានំ** បានដល់ កម្មដែលឲ្យដល់វិវដ្តៈ ។ ដូច្នោះ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់វដ្តៈផង វិវដ្តៈផង ។

**អដ្ឋកថា និធានសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## កិម្មិលសូត្រទី ១០

[ ៤០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទៀបក្រុងកិមិលា ។ គ្រានោះ ព្រះកិមិលៈដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគរួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះកិមិលៈដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ

ក៏ក្រាបទូលសួរព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេចអេះ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មមិនឋិតថេរនៅអស់កាលយូរបាន ។ ម្នាលកិមិលៈ ក្នុងសាសនានេះ កាលតថាគតបរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាអ្នកមិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តា មិនគោរព មិនកោតក្រែង ក្នុងព្រះធម៌ មិនគោរព មិនកោតក្រែង ក្នុងសង្ឃ មិនគោរព មិនកោតក្រែង ក្នុងសិក្ខា មិនគោរព មិនកោតក្រែង ក្នុងអប្បមាទ មិនគោរព មិនកោតក្រែង ក្នុងបដិសន្ថារៈ ។ ម្នាលកិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មមិនឋិតថេរនៅអស់កាលយូរបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេចអេះ កាលព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មឋិតថេរនៅអស់កាលយូរបាន ។ ម្នាលកិមិលៈ ក្នុងសាសនានេះ កាលបើព្រះតថាគត បរិនិព្វានហើយ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ជាអ្នកគោរព កោតក្រែងក្នុងព្រះសាស្តា គោរព កោតក្រែង ក្នុងព្រះធម៌ គោរព កោតក្រែងក្នុងព្រះសង្ឃ គោរព កោតក្រែង ក្នុងសិក្ខា គោរព កោតក្រែង ក្នុងអប្បមាទ គោរព កោតក្រែង ក្នុងបដិសន្ថារៈ ។ ម្នាលកិមិលៈ នេះជាហេតុ នេះជាបច្ច័យ កាលបើព្រះតថាគតបរិនិព្វានហើយ ព្រះសទ្ធម្មឋិតថេរនៅអស់កាលយូរបាន ។

# អដ្ឋកថា

## កិម្មិលសូត្រ

[ ៤០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកិម្មិលសូត្រទី ១០ ដូចតទៅនេះ បទថា **វេឡុវនេ** បានដល់ ក្នុងព្រៃមុចលិន្ទ ( ព្រៃរាំងអន្ទក់ ) ។ បទថា **សទ្ធម្មោ** បានដល់ ព្រះសទ្ធម្ម គឺព្រះសាសនា ៕

អដ្ឋកថា កិម្មិលសូត្រទី ១០ ចប់

# សុត្តន្តបិដក

## ទារុក្ខន្ធសូត្រទី ១១

[ ៤១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចុះអំពីភ្នំគិជ្ឈកូដជាមួយនឹងពួកភិក្ខុដ៏ច្រើន បានឃើញគំនរឈើដ៏ធំក្នុងប្រទេស ១ ហើយប្រឹក្សានឹងភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ឃើញគំនរឈើដ៏ធំឯណោះដែរឬទេ ។ ឃើញដែរអាវុសោ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុមានឫទ្ធិ ប្រាថ្នាដល់នូវសេចក្តីស្ទាត់ជំនាញក្នុងចិត្ត គប្បីកំណត់នូវគំនរឈើឯណោះថា ជាបឋវីធាតុ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

ម្នាលអាវុសោទាំងឡាយ ព្រោះថា ភិក្ខុមានឫទ្ធិ ដល់នូវសេចក្ដីស្ទាត់ជំនាញក្នុងចិត្ត អាស្រ័យបឋវីធាតុ ក្នុងគំនរឈើឯណោះហើយ គប្បីកំណត់នូវគំនរឈើឯណោះថា ជាបឋវីធាតុ ។ ម្នាលអាវុសោទាំងឡាយ កាលបើភិក្ខុមានឫទ្ធិ ប្រាថ្នាដល់នូវសេចក្ដីស្ទាត់ជំនាញក្នុងចិត្ត គប្បីកំណត់នូវគំនរឈើឯណោះ ថាជាអាបោធាតុ ។បេ។ គប្បីកំណត់ថា ជាតេជោធាតុ គប្បីកំណត់ថាជាវាយោធាតុ គប្បីកំណត់ថា ជាសុភធាតុ គប្បីកំណត់ថាជាអសុភធាតុ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះភិក្ខុមានឫទ្ធិដល់នូវសេចក្ដីស្ទាត់ជំនាញក្នុងចិត្ត អាស្រ័យអសុភធាតុ ក្នុងគំនរឈើឯណោះ គប្បីកំណត់នូវគំនរឈើឯណោះថា ជាអសុភធាតុ ។

# អដ្ឋកថា

## ទារុក្ខន្ធសូត្រ

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទារុក្ខន្ធសូត្រទី ១១ ដូចតទៅនេះ បទថា **ចេតោវសិប្បត្តោ** បានដល់ ជាអ្នកដល់នូវភាពជាអ្នកមានអំណាចចិត្ត ។ បទថា **បឋវីត្វេវ អធិមុច្ចេយ្យ** សេចក្ដីថា គប្បីកំណត់អាការដែលរឹងថាធាតុដី ។ បទថា **យំ និស្សាយ** សេចក្ដីថា អាស្រ័យបឋវីធាតុឯណា ដែលមានអាការរឹងមាន ។ ភិក្ខុអ្នកមានឫទ្ធិ គប្បីបង្អោនចិត្តទៅកាន់កំណាត់ឈើ

នោះថាជាដី បឋវីធាតុនោះ មាននៅក្នុងកំណាត់ឈើនោះ ។ ព្រោះដូច្នោះ សូម្បីបទដ៏សេស គប្បីជ្រាបដោយន័យនេះឯង អធិប្បាយថា ក្នុងកំណាត់ឈើនោះ មានបឋវីធាតុ មានអាការរឹង យ៉ាងណា អាបោធាតុ មានអាការប្រមូលផ្តុំ តេជោធាតុ មានអាការក្តៅ វាយោធាតុ មានលក្ខណៈកម្រើក ក៏មាននៅក្នុងកំណាត់ឈើនោះដូចគ្នា ។ សុភធាតុណា ដែលមានពណ៌ដូចផ្កាបទុម មាននៅក្នុងខ្លឹមឈើ ដែលមានពណ៌ក្រហម ភិក្ខុគប្បីបង្អោនចិត្តទៅគឺកំណាត់ដុំឈើនោះ ដោយអាស្រ័យសុភធាតុនោះថា **សុភំ សុភំ** ស្អាតៗ ដូច្នេះ សុភធាតុណា ដែលមានពណ៌មិនគួរពេញចិត្ត មាននៅក្នុងលម្អិតដែលស្អុយ និងក្នុងក្រមរ ឬស្រោយទាំងឡាយ ភិក្ខុបង្អោនចិត្តទៅ គឺកំណាត់កំណាត់ឈើនោះ ដោយអាស្រ័យអសុភធាតុនោះឯងថា **អសុភំ អសុភំ** មិនស្អាតៗ ដូច្នេះ ។ ក្នុងព្រះសូត្រនេះ លោកពោលឈ្មោះថា មិស្សកវិហារ ។៙

**អដ្ឋកថា ទារុក្ខន្ធសូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ឆាតិតសូត្រទី ១២

[ ៤២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃជាច្រើន ស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈ របស់អ្នកដែនកោសលទាំងឡាយ ។ មានសេចក្តីតំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ទៀបព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈនោះ ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈបានឮថា ព្រះសមណគោតមដ៏ចម្រើន ជាសក្យបុត្តចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ស្តេចមកដល់ស្រុកឥច្ឆានង្គលៈ ហើយគង់ក្នុងដងព្រៃឥច្ឆានង្គលៈ ទៀបស្រុកឥច្ឆានង្គលៈ ។ ឯព្រះគោតមដ៏ចម្រើននោះ មានកិត្តិសព្ទដ៏ពីរោះខ្ទរខ្ទាយទៅយ៉ាងនេះថា ព្រះដ៏មានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវ គឺកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ដោយព្រះអង្គឯង បរិបូណ៌ដោយវិជ្ជា និងចរណៈ ។បេ។ ត្រាស់ដឹងអរិយសច្ចទាំង ៤ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ព្រះដ៏មានព្រះភាគនោះ ទ្រង់ញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ។បេ។ ការបានជួបប្រទះព្រះអរហន្តទាំងឡាយ ។ គ្រាកាលរាត្រីនោះ កន្លងទៅហើយ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ កាន់ខាទនីយភោជនីយាហារដ៏ច្រើន ចូលទៅក្នុងដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ឋិតនៅខាងក្រៅខ្លោងទ្វារ រួចមានសំឡេងគឹកកងយ៉ាងខ្លាំង ។ សម័យនោះ ព្រះ

នាគិតៈដ៏មានអាយុ ជាអ្នកត្រូវវេនបម្រើព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈដ៏មានអាយុថា នែនាគិតៈ ពួកជនណា ស្រែកហ៊ោគឹកកង ទំនងដូចជាព្រានសំណាញ់ដណ្តើមត្រីគ្នា ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍គហបតី អ្នកស្រុកឥច្ឆានង្គលៈនុ៎ះ នាំយកខាទនីយភោជនីយាហារដ៏ច្រើនមុខ ហើយឈរខាងក្រៅខ្លោងទ្វារ ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគផង ភិក្ខុសង្ឃផង ។ ម្នាលនាគិតៈ តថាគតសុំកុំជួបប្រសប់នឹងយសបរិវារ ឯយសក៏កុំជួបប្រសប់នឹងតថាគតយ៉ាងនេះឡើយ ។ ម្នាលនាគិតៈ តថាគតជាអ្នកបានសមតាមប្រាថ្នា បានងាយ បានស្រួលនូវនេក្ខម្មសុខ ( សុខកើតអំពីកិរិយាចេញបួស ) បវិវេកសុខ ( សុខកើតអំពីសេចក្តីស្ងប់ស្ងាត់ ) ឧបសមសុខ ( សុខកើតអំពីសេចក្តីស្ងប់រម្ងាប់ ) សម្ពោធសុខ ( សុខកើតអំពីសេចក្តីត្រាស់ដឹង ) បុគ្គលណា ជាអ្នកមិនបានសមតាមប្រាថ្នា មិនបានងាយ មិនបានស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខទេ បុគ្គលនោះ គប្បីត្រេកអរនឹងសុខកខ្វក់ សុខងុយងោក សុខប្រកបដោយលាភសក្ការៈ និងសេចក្តីសរសើរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្ត សូមព្រះសុគតទ្រង់ទទួលនិមន្តឥឡូវ បពិត្រព្រះអង្គដ៏ចម្រើន កាលនេះគួរព្រះដ៏មានព្រះភាគទទួលនិមន្តណាស់ បពិត្រព្រះអង្គដ៏ចម្រើន កាលនេះគួរព្រះដ៏មានព្រះភាគទទួលនិមន្តណាស់ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះដ៏មានព្រះភាគ

ស្តេចនឹងយាងទៅក្នុងទីណាៗ ពួកព្រាហ្មណ៍ គហបតី អ្នកនិគម ជនបទ នឹងបាក់បបទៅតាមព្រះដ៏មានព្រះភាគក្នុងទីនោះៗ ដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ដូចជាភ្លៀងមានតំណក់ទឹកធំៗ បង្អុរចុះ ទឹករមែងហូរទៅកាន់ទីទំនាបយ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រះដ៏មានព្រះភាគ នឹងស្តេចទៅក្នុងទីណាៗ ពួកព្រាហ្មណ៍ គហបតី អ្នកនិគម ជនបទ នឹងបាក់បបទៅតាមព្រះដ៏មានព្រះភាគ ក្នុងទីនោះៗ ក៏យ៉ាងនោះដែរ ។ ដំណើរនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះដ៏មានព្រះភាគ មានសីល និងបញ្ញា ។ ម្នាលនាគិតៈ តថាគតសុំកុំជួបនឹងយសបរិវារ ឯយសក៏កុំជួបប្រសប់នឹងតថាគត ( យ៉ាងនេះ ) ឡើយ ។ ម្នាលនាគិតៈ តថាគតជាអ្នកបានសមតាមប្រាថ្នា បានងាយ បានស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ បុគ្គលណា មិនបានសមតាមប្រាថ្នា មិនបានងាយ មិនបានស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធ-សុខនេះទេ បុគ្គលនោះ គប្បីត្រេកអរនឹងសុខកខ្វក់ សុខងុយងោក សុខប្រកបដោយលាភសក្ការៈ និងសេចក្តីប្រសើរនោះ ។ ម្នាលនាគិតៈ ក្នុងទីឯណោះ តថាគតឃើញភិក្ខុ នៅក្នុងសេនាសនៈ នាចន្លោះស្រុក កំពុងអង្គុយចម្រើនសមាធិ ម្នាលនាគិតៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ជនជាម្ចាស់អារាម នឹងបៀតបៀននូវលោកដ៏មានអាយុនេះ ឬក៏សាមណេរ មុខជាញុំាងភិក្ខុនោះឲ្យឃ្លាតចាកសមាធិដែរឬទេ ។ ម្នាលនាគិតៈ

ហេតុនោះ តថាគតមិនពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងសេនាសនៈនាចន្លោះស្រុក ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុអ្នកនៅក្នុងព្រៃ កំពុងអង្គុយលក់ក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ បន្ទោបង់នូវសេចក្តីលំបាកក្នុងកិរិយាដេកលក់នេះហើយ ធ្វើមនសិការនូវអរញ្ញសញ្ញាឲ្យប្រសើរឯក ។ ម្នាលនាគិតៈ ហេតុនោះ បានជាតថាគត ពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុអ្នកនៅក្នុងព្រៃ មិនអង្គុយចម្រើនសមាធិក្នុងព្រៃទេ ម្នាលនាគិតៈ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ នឹងតាំងចិត្តដែលមិនទាន់ដល់សមាធិផង រក្សាចិត្តដែលបានដល់សមាធិហើយផង ។ ម្នាលនាគិតៈ ហេតុនេះ បានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុអ្នកនៅក្នុងព្រៃ បានដល់សមាធិ ហើយអង្គុយនៅក្នុងព្រៃ ម្នាលនាគិតៈ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ ញុំាងចិត្តដែលមិនទាន់រួចស្រឡះឲ្យរួចស្រឡះផង រក្សាទុកនូវចិត្តដែលរួចស្រឡះហើយផង ។ ម្នាលនាគិតៈ ហេតុនោះ បានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុអ្នកនៅក្នុងសេនាសនៈនាចន្លោះស្រុក ធ្លាប់បាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-

ភេសជ្ជបរិក្ខារ កាលបើភិក្ខុនោះចង់បានលាភសក្ការៈ សេចក្តីសរសើរនោះហើយ រមែងលះបង់នូវទីសម្ងំ លះបង់នូវសេនាសនៈស្ងាត់ គឺព្រៃ និងដងព្រៃ ក៏ជ្រកនៅតែក្នុងស្រុក និគម រាជធានី ។ ម្នាលនាគិតៈ ហេតុនោះបានជាតថាគតមិនពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងសេនាសនៈនាចន្លោះស្រុក ។ ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុ អ្នកនៅក្នុងព្រៃ ធ្លាប់បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ភិក្ខុនោះបន្ទោបង់នូវលាភសក្ការៈ សេចក្តីសរសើរនោះហើយ មិនលះបង់ទីសេនាសនៈដ៏ស្ងាត់ គឺព្រៃ និងដងព្រៃ ។ ម្នាលនាគិតៈ ហេតុនោះ បានជាតថាគតពេញចិត្តនឹងភិក្ខុនោះ ព្រោះតែនៅក្នុងព្រៃ ។ ម្នាលនាគិតៈ ពេលណា តថាគតដើរទៅកាន់ផ្លូវឆ្ងាយ មិនបានឃើញបុគ្គលណាមួយ ខាងមុខ ឬខាងក្រោយ ម្នាលនាគិតៈ ពេលនោះ តថាគតមានសេចក្តីសុខសប្បាយដោយហោចទៅ ( សូម្បីគ្រាន់តែ ) ធ្វើឧច្ចារបស្សាវៈក៏ស្រួលដែរ ។

**សេក្ខបរិហានិយវគ្គទី ៤ ចប់**

## ឧទ្ទាននៃសេក្ខបរិហានិយវគ្គនោះ គឺ

និយាយអំពីសេក្ខបរិហានិយធម៌ ១ សេក្ខអបរិហា-
និយធម៌ ២ លើក សេចក្តីត្រិះរិះនៃព្រះមហាមោគ្គ-
ល្លាន ១ ធម៌ជាចំណែកនៃវិជ្ជា ១ មូលហេតុនៃវិវាទ
១ ការឲ្យទាន ១ មិនមានការធ្វើ ( កម្ម ) ដើម្បី

ខ្លួន ១ ហេតុឲ្យកើតកម្មទាំងឡាយ ១ ព្រះកិមិលៈ ទូលសួរ ព្រះដ៏មានព្រះភាគ ១ ព្រះសារីបុត្ត បង្ហាញ គំនរឈើដល់ភិក្ខុទាំងឡាយ ១ នាគិតត្ថេរ អ្នកបម្រើ ព្រះដ៏មានព្រះភាគ ១ ។

# អដ្ឋកថា

## នាគិតសូត្រ

[ ៤២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាគិតសូត្រទី ១២ ដូចតទៅនេះ បទថា **គាមន្តវិហារំ** បានដល់ នៅក្នុងសេនាសនៈចុងស្រុក ។ បទថា **សមាហិតំ និសិន្នំ** បានដល់ អង្គុយចូលសមាធិក្នុងសេនាសនៈចុងស្រុកនោះ ។ បទថា **ឥទានិមំ** កាត់បទជា **ឥទានិ ឥមំ** ។ បទថា **សមាធិម្ហា ចាវេស្សតិ** សេចក្ដីថា នឹងចេញអំពីសមាធិ ។ បទថា **ន អត្តមនោ ហោមិ** សេចក្ដីថា រមែងមិនមានចិត្តជារបស់ខ្លួន គឺមិនសប្បាយចិត្ត ។ បទថា **បចលាយមានំ** បានដល់ កំពុងដេកលក់ ។ បទថា **ឯកត្តំ** អធិប្បាយថា ធ្វើអរញ្ញសញ្ញានោះ ឯងក្នុងចិត្ត ឲ្យចិត្តមានឯកគ្គតា ។ បទថា **អនុរក្ខិស្សតិ** បានដល់ នឹងអនុគ្រោះ ។ បទថា **អវិមុត្តំ វា ចិត្តំ វិមោចេស្សតិ** សេចក្ដីថា នឹងដោះចិត្តដែលមិនទាន់រួចផុត ក្នុងកាលដទៃ ដោយវិមុត្តិទាំង ៥ ក្នុងឥឡូវនេះ ។

បទថា **វិញ្ញុតិ** បានដល់ វៀរ គឺលោស់ចោល ។ បទថា **បដិប្បណាមេត្វា** បានដល់ បន្ទោបង់ គឺលោស់ចេញទៅ ។ បទថា **ឧច្ចារបស្សាវកម្មាយ** បានដល់ ដើម្បីបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ។ ដោយហេតុនេះ គឺដោយឋានៈមានប្រមាណប៉ុណ្ណេះ ព្រះបរមសាស្តា បានត្រាស់សរសើរសេនាសនៈព្រៃ ។ តែពាក្យណាដែលពោលក្នុងចំណែកខាងដើមនៃព្រះសូត្រ ខ្ញុំបានពោលហើយខាងដើមនោះឯង ។៚

**អដ្ឋកថាឆាតិតសូត្រទី ១២ ចប់**

**សេក្ខបរិហានិយវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# ធម្មិកវគ្គ

## នាគសូត្រទី ១

[ ៤៣ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី ។ លុះព្រះអង្គចូលទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីរួចហើយ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ទ្រង់ត្រាស់នឹងព្រះអានន្ទ ដ៏មានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅបុព្វារាម ជាមិគារមាតុ-ប្រាសាទ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ចូលទៅបុព្វារាមជាមិគារមាតុប្រាសាទ ជាមួយនឹងព្រះអានន្ទ ដ៏មានអាយុ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ចេញអំពីទីសម្ងំក្នុងសាយណ្ហ-សម័យ ទ្រង់មានព្រះបន្ទូលនឹងអានន្ទដ៏មានអាយុថា ម្នាលអានន្ទ មក យើងនឹងចូលទៅឯស្រះឈ្មោះបុព្វកោដ្ឋកៈ ដើម្បីស្រោចស្រពខ្លួន ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចូលទៅឯស្រះបុព្វកោដ្ឋកៈ ជាមួយនឹងព្រះអានន្ទដ៏មានអាយុ ដើម្បីស្រោចស្រពព្រះអង្គ ។ លុះព្រះដ៏មានព្រះភាគ

ស្រោចស្រពព្រះអង្គក្នុងស្រះបុព្វកោដ្ឋកៈរួចហើយ ទ្រង់ត្រឡប់ឡើងមក មានចីវរតែ ១ ទ្រង់ឈរធ្វើព្រះអង្គឲ្យប្រាកដដូចជាកាលមុន ។ សម័យនោះឯងដំរីឈ្មោះសេតៈរបស់ព្រះបាទបសេនទិកោសល ត្រូវគេដេញជំប្រគំតូរ្យតន្ត្រីដ៏ប្រសើរ ក៏ចូងឡើងមកអំពីស្រះបុព្វកោដ្ឋកៈដែរ ។ មហាជនបានឃើញដំរីនោះហើយ ក៏និយាយយ៉ាងនេះថា យីអើ ដំរីរបស់ស្តេច មានរូបល្អណាស់តើ យីអើ ដំរីរបស់ស្តេច គួរជាទីរមិលមើលណាស់តើ យីអើ ដំរីរបស់ស្តេច គួរជាទីជ្រះថ្លាណាស់តើ យីអើ ដំរីរបស់ស្តេច មានកាយសមរម្យល្អណាស់តើ ។ កាលបើមហាជននិយាយយ៉ាងនេះហើយ ព្រះឧទាយិដ៏មានអាយុ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មហាជនបានឃើញនូវដំរីធំប្រសើរ មានកាយសមរម្យប៉ុណ្ណោះ ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ឬហ្ន៎ ឬថាមហាជនបានឃើញនូវវត្ថុ ឯទៀតណាមួយធំប្រសើរ មានកាយសមរម្យ ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មហាជនបានឃើញដំរីធំប្រសើរ មានកាយសមរម្យក្តី ក៏និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មហាជនបានឃើញសេះធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញគោធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញពស់ធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញដើមឈើធំប្រសើរក្តី ម្នាលឧទាយិ មហាជនបានឃើញមនុស្សធំប្រសើរ មានកាយសមរម្យក្តី ហើយក៏

និយាយយ៉ាងនេះថា យីអើ ប្រសើរណាស់តើ ប្រសើរណាស់តើ ។ ម្នាលឧទាយិ មួយទៀត បុគ្គលណាក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិ-ទេព និងមនុស្សដ៏សេស មិនធ្វើនូវអំពើអាក្រក់ ដោយកាយ ដោយវាចា ដោយចិត្ត តថាគតក៏ហៅបុគ្គលនោះថា នាគ គឺបុគ្គលប្រសើរ ដូច្នេះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ អស្ចារ្យពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ចម្លែកពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពាក្យនេះ ព្រះដ៏មានព្រះភាគ ទ្រង់បានពោលហើយដោយប្រពៃ ។ ម្នាលឧទាយិ មួយទៀត បុគ្គលណាក្នុងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស មិនធ្វើនូវអំពើអាក្រក់ ដោយកាយ ដោយវាចា ដោយចិត្ត តថាគតហៅបុគ្គលនោះថា នាគ ដូច្នេះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងដោយប្រពៃហើយនេះ ខ្ញុំព្រះអង្គសូមអនុមោទនា ដោយគាថាទាំងនេះថា

មនុស្សទាំងឡាយ តែងនមស្ការ ព្រះសម្ពុទ្ធអង្គណា
ដែលជាមនុស្សជាតិ មានព្រះអង្គទូន្មានមានព្រះ
ហឫទ័យតម្កល់មាំ តាំងនៅក្នុងផ្លូវដ៏ប្រសើរ ទ្រង់
ត្រេកអរក្នុងព្រះនិព្វាន ជាទីរម្ងាប់នូវចិត្ត ដល់នូវ
ត្រើយនៃធម៌ទាំងពួង គឺខន្ធ អាយតនៈ ធាតុ ខ្ញុំបាន

ឮអំពីសម្នាក់នៃព្រះអរហន្តថា សូម្បីពួកទេវតា ក៏តែងនមស្ការចំពោះព្រះសម្ពុទ្ធអង្គនោះ ដែលទ្រង់កន្លងបង់នូវសំយោជនៈទាំងអស់ ចេញចាកព្រៃ គឺកិលេស ហើយបានដល់ព្រះនិព្វាន ទ្រង់ត្រេកអរក្នុងការចេញចាកកាមទាំងឡាយ ដូចជាមាសដែលផុតចាកថ្ម ព្រះពុទ្ធជាបុគ្គលប្រសើរ រុងរឿងកន្លងបង់នូវសត្វទាំងពួង ដូចភ្នំហេមពាន្តដែលរុងរឿងជាងភ្នំដទៃ ( ព្រះសម្ពុទ្ធអង្គនោះ ) មាននាមប្រាកដប្រសើរជាងនាគនាមទាំងអស់ ។ តថាគតនឹងសម្តែងនូវពុទ្ធនាគដល់អ្នកទាំងឡាយ ព្រោះថា ពុទ្ធនាគនោះរមែងមិនធ្វើអំពើអាក្រក់ សេចក្តីស្ងប់ស្ងៀម និងសេចក្តីមិនបៀតបៀនទាំង ២ នោះ ទុកជាជើងខាងមុខរបស់ពុទ្ធនាគ តបៈ គឺការសមាទាននូវវត្តព្រហ្មចរិយៈ គឺសីលប្រកបដោយអរិយមគ្គនោះជាជើងខាងក្រោយរបស់ពុទ្ធនាគ មហានាគ ( នោះ ) មានសទ្ធាជាប្រមោយ មានឧបេក្ខាជាភ្លុកស មានសតិជាក មានបញ្ញាជាក្បាល ការគិតនូវធម៌ទុកជាចុង ( ប្រមោយ ) មានធម៌ គឺចតុត្ថជ្ឈានសមាធិ ជា

ពោះសម្រាប់ចម្អែតអាហារ មានសេចក្តីស្ងប់ស្ងាត់ជាកន្ទុយរបស់ពុទ្ធនាគនោះ ពុទ្ធនាគនោះ មានឈាន មានសេចក្តីត្រេកអរ ក្នុងការដកដង្ហើមចេញ មានចិត្តតម្កល់ខ្ជាប់ក្នុងសន្តាន កាលពុទ្ធនាគដើរ ក៏មានចិត្តតម្កល់ខ្ជាប់ កាលពុទ្ធនាគឈរ ក៏មានចិត្តតម្កល់ខ្ជាប់ កាលពុទ្ធនាគសិង ក៏មានចិត្តតម្កល់ខ្ជាប់ សូម្បីអង្គុយ ក៏មានចិត្តតម្កល់ខ្ជាប់ ពុទ្ធនាគបានសង្រួមក្នុងទ្វារទាំងអស់ នេះជាសម្បទានៃពុទ្ធនាគ ។ ពុទ្ធនាគនោះ រមែងបរិភោគភោជនដែលមិនមានទោស មិនបរិភោគភោជន ដែលមានទោស បានគ្រឿងបរិភោគ និងគ្រឿងស្លៀកដណ្តប់ តែងវៀរបង់នូវការសន្សំទុកដាក់ ផ្តាច់បង់នូវចំណង គឺសំយោជនៈតូច និងធំទាំងអស់ បើទៅត្រង់ទីណាៗ មិនអាឡោះអាល័យនូវទីនោះៗ ។ ឈូកសដែលដុះឡើង ចម្រើនឡើងក្នុងទឹក មានក្លិនល្អជាទីត្រេកអរនៃចិត្ត មិនជាប់ដោយទឹក ដូចម្តេចមិញ ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោក ទ្រង់គង់នៅក្នុងលោក ក៏មិនជាប់ដោយលោកឡើយ ដូចជាផ្កាឈូកមិនជាប់

ដោយទឹកដូច្នោះដែរ ។ គំនរភ្លើងធំឆេះឡើង រមែង រលត់ទៅដោយមិនមានអាហារ ភ្លើងសង្ខារទាំងឡាយ ស្ងប់រម្ងាប់ទៅ ហៅថា រលត់ដូច្នេះ នេះជាសេចក្តី ឧបមាជាគ្រឿងពន្យល់ នូវសេចក្តីនោះដែលវិញ្ញូជន ទាំងឡាយ បានសម្តែងហើយ ។ ពួកមហានាគ រមែង ដឹងច្បាស់នូវវត្ថុដ៏ប្រសើរ ដែលពុទ្ធនាគបានសម្តែង ហើយ ពុទ្ធនាគដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈលះបង់នូវសរីរៈ ជាបុគ្គលមិនមានអាសវៈ នឹងបរិនិព្វាន ។

# អដ្ឋកថា

# ធម្មិកវគ្គទី ៥

## នាគសូត្រ

[ ៤៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនាគសូត្រទី ១ នៃធម្មិកវគ្គទី ៥ ដូច្នេះ ពាក្យថា **អាយស្មតា អានន្ទេន សទ្ធឹ** នេះ ព្រះសង្គីតិកាចារ្យពោលព្រោះ ព្រះមានព្រះភាគត្រាស់ហៅព្រះថេរៈថា អានន្ទ មក យើងទៅទាំងអស់គ្នា ដូច្នេះហើយ យាងទៅ ។ ចំណែកព្រះសាស្តា បណ្ឌិតគប្បីជ្រាបថា ភិក្ខុ ៥០០ រូបនោះឯង ហោមរោមហើយ ទ្រង់យាងទៅបុព្វារាមនោះ ។

បទថា **តេនុបសង្កមិ** សេចក្តីថា ភិក្ខុ ៥០០ រូបនោះឯង ហោមរោម ហើយទ្រង់ចូលទៅ ។ បទថា **បរិសិញ្ចិតុំ** នេះ ជាពាក្យវោហារ ដោយអត្ថថា ទ្រង់ស្រពស្រង់ហើយ ។

បទថា **បុព្វសទិសានិ កុរុមានោ** សេចក្តីថា ទ្រង់ស្បង់សំពត់ ២ ជាន់ ដែលជ្រលក់ហើយ ទ្រង់កាន់យកឧត្តរាសង្គ ដោយព្រះហស្តទាំងទ្វេ ប្រថាប់ឈរបែរព្រះបិដ្ឋិទៅកាន់លោកធាតុទិសខាងលិច បែរព្រះភក្ត្រទៅកាន់ លោកធាតុទិសខាងកើត ធ្វើព្រះកាយឲ្យស្ងួតដូចមុន ដោយប្រាសចាកទឹក ។ ឯភិក្ខុសង្ឃ ចុះតាមក្នុងទីនោះៗ ស្រង់ទឹកហើយ បានឡើងមកឈរជុំវិញព្រះ សាស្តាយ៉ាងកុះករ សម័យនោះ ព្រះអាទិត្យគោចរអណ្តែតលយលឿនទៅ កាន់លោកធាតុទិសខាងលិច ដូចកុណ្ឌលមាសកំពុងធ្លាក់ចុះអំពីអាកាស

ដូច្នោះ ៗ ឯលោកធាតុទិសខាងកើត ព្រះចន្ទ ដូចជាមណ្ឌលនៃដុំប្រាក់ដ៏បរិសុទ្ធ ដូច្នោះ ៗ

ត្រង់កណ្តាលលោកធាតុ ព្រះសម្មាសម្ពុទ្ធ មានភិក្ខុ ៥០០ ជាបរិវារ បានប្រថាប់ឈរបញ្ចេញឆព្វណ្ណរង្សី ត្រង់ផ្ទៃរស្មីងបុព្វកោដ្ឋកៈ ៗ

បទថា **តេន ខោ បន សមយេន ។បេ។ សេតោ ឆាម ឆាតោ** សេចក្តីថា នាគ គឺដំរីដែលបានឈ្មោះយ៉ាងនោះ គឺឈ្មោះថា **សេត** ព្រោះមានពណ៌ស ៗ បទថា **មហាតុរិយតាឡិតវាទិតេន** បានដល់ ដោយការប្រគំតន្ត្រីដ៏មហោឡារ ៗ

ក្នុងបទថា **មហាតុរិយតាឡិតវាទិតេន** អធិប្បាយថា ការប្រគំលើកទី ១ ឈ្មោះថា **តាឡិត** ការប្រគំក្នុងកាលតទៅបន្ទាប់អំពីនោះ ឈ្មោះថា **វាទិត** ។

បទថា **ជនោ** បានដល់ មហាជនប្រជុំគ្នាដើម្បីមើលដំរី ៗ បទថា **ទិស្វា ឯវមាហ** សេចក្តីថា មហាជនឃើញដំរីធំនោះ ដែលហ្មដំរីឲ្យងូតទឹកដុសអវយវៈតូចធំ ហើយឡើងមកបញ្ឈរត្រង់ច្រាំង ធ្វើខ្លួនឲ្យស្រស់ទឹក រួចយកគ្រឿងប្រដាប់ដំរីមកបំពាក់ឲ្យ ទើបពោលពាក្យសរសើរថា អ្នកដ៏ចម្រើន ដំរីនេះស្អាតពិតហ្ន៎ ៗ បទថា **កាយូបបន្នោ** បានដល់ ចូលដល់ដោយការដល់ព្រមនៃរាងកាយ អធិប្បាយថា មានអវយវៈតូចធំបរិបូណ៌ ៗ

បទថា **អាយស្មា ឧទាយិ** បានដល់ ព្រះកាឡុទាយិត្ថេរដែលបានបដិ-

សម្ពិទា ។ បទថា **ឯតទវោច** សេចក្តីថា ព្រះកាឡុទាយិត្ថេរឃើញមហាជន នោះពោលសរសើរគុណរបស់ដំរី ទើបគិតថា ជនទេះពោលសរសើរគុណនៃ ដំរីដែលកើតឡើងក្នុងអហេតុកបដិសន្ធិ តែមិនពោលសរសើរព្រះគុណរបស់ ដំរី គឺព្រះសម្ពុទ្ធ ដូច្នេះ អញនឹងពោលសរសើរព្រះគុណរបស់ដំរី គឺព្រះពុទ្ធ ប្រៀបធៀបនឹងដំរីដ៏ប្រសើរនេះ ដូច្នេះ ។ ហើយបានពោលពាក្យជាដើមថា **មនុស្សភូតំ សម្ពុទ្ធំ** ។

បណ្តាបទទាំងនោះ បទថា **មហន្តំ** បានដល់ ដល់ព្រមដោយសណ្ឋាន ទ្រង់ទ្រាយ ។ បទថា **ព្រហន្តំ** បានដល់ ដល់ព្រមដោយទំហំធំ ។ បទថា **ឯវមាហ** បានដល់ ពោលយ៉ាងនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ព្រោះហេតុដែលនាគសព្ទប្រព្រឹត្តទៅ ក្នុងដំរីខ្លះ សេះខ្លះ គោខ្លះ ពស់ខ្លះ ដើមឈើខ្លះ មនុស្សខ្លះ ដូច្នោះ ទើប ត្រាស់ពាក្យជាដើមថា **ហត្ថិម្បិ ខោ** ជាដើម ។

បទថា **អាគុំ** បានដល់ អកុសលធម៌ដែលអាក្រក់លាមក ។ បទថា **តមហំ នាគោតិ ព្រូមិ** សេចក្តីថា តថាគតហៅបុគ្គលនោះថាជានាគ ព្រោះ មិនធ្វើអកុសលកម្មបថ ១០ និងអកុសលចិត្ត ១២ ដោយទ្វារ ៣ នេះ ។ បុគ្គលនេះឈ្មោះថា ជានាគ ដោយអត្ថនេះ គឺមិនធ្វើអាក្រក់ ។

បទថា **ឥមាហិ គាថាហិ អនុមោទាមិ** សេចក្តីថា ខ្ញុំព្រះអង្គអនុមោទនា ដោយគាថា ១៦ ចែកជាបទ បាន ៦៤ បទនេះ ។ បទថា **មនុស្សភូតំ** គឺ

ជាមនុស្សពិតៗ មិនបានចូលដល់ភាពជាទេវតាជាដើមឡើយ ។ បទថា **អត្តទន្តំ** បានដល់ ទូន្មានហើយដោយខ្លួនឯងនោះឯង គឺមិនមានបុគ្គលដទៃនាំចូលទៅកាន់ការទូន្មាន ។

អធិប្បាយថា ព្រះមានព្រះភាគទ្រង់ទូន្មានហើយក្នុងឋានៈ ៦ នេះ គឺ ទ្រង់ទូន្មានតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ដោយការអប់រំដោយមគ្គ ដែលទ្រង់បានឲ្យកើតឡើងឯង គឺទ្រង់ស្ងប់ គឺរលត់ បានដល់ រលត់ឥតសេសសល់ ព្រោះហេតុនោះ ទើបព្រះកាឡុទាយិត្ថេរពោលថា **អត្តទន្តំ** ដូច្នេះ ។

បទថា **សមាហិតំ** បានដល់ តាំងមាំហើយ ដោយសមាធិទាំង ២ យ៉ាង ។ បទថា **ឥរិយមានំ** បានដល់ នៅ ។ បទថា **ព្រហ្មបថេ** បានដល់ ក្នុងផ្លូវដ៏ប្រសើរបំផុត គឺផ្លូវអមតនិព្វាន ។ បទថា **ចិត្តស្សូបសមេ រតំ** បានដល់ អ្នករម្ងាប់នីវរណៈ ៥ ដោយបឋមជ្ឈាន រម្ងាប់វិតក្ក វិចារៈ ដោយទុតិយជ្ឈាន រម្ងាប់បីតិដោយតតិយជ្ឈាន រម្ងាប់សុខ និងទុក្ខដោយចតុត្ថជ្ឈាន ហើយត្រេកអរ គឺត្រេកអរក្រៃលែងក្នុងការស្ងប់របស់ចិត្តនោះ ។

បទថា **នមស្សន្តិ** បានដល់ នមស្ការដោយកាយ នមស្ការដោយវាចា នមស្ការដោយចិត្ត គឺនមស្ការ បានដល់ សក្ការៈ ដោយបដិបត្តិធម៌សមគួរដល់ធម៌ ។ បទថា **សព្វធម្មាន បារគុំ** បានដល់ ទ្រង់ដល់នូវត្រើយ គឺដល់នូវសេចក្ដីសម្រេច ដល់នូវទីបំផុតនៃធម៌ គឺខន្ធ អាយតនៈ ធាតុ ទាំង

អស់ ដោយការដល់នូវត្រើយ ៦ យ៉ាង គឺទ្រង់ដល់នូវត្រើយនៃអភិញ្ញា ទ្រង់ដល់ត្រើយនៃបរិញ្ញា ទ្រង់ដល់ត្រើយនៃបហាន ទ្រង់ដល់ត្រើយនៃភាវនា ទ្រង់ដល់ត្រើយនៃការធ្វើឲ្យជាក់ច្បាស់ ទ្រង់ដល់ត្រើយនៃសមាបត្តិ ។

បទថា **ទេវាបិ តំ នមស្សន្តិ** សេចក្តីថា ទេវតាដែលជាអ្នកជួបនូវទុក្ខទាំងឡាយ មានសុព្រហ្មទេវបុត្រជាដើម និងទេវតាដែលជាអ្នកជួបនូវសុខអាស្រ័យក្នុងចក្រវាលទាំងមួយម៉ឺននោះឯង នាំគ្នានមស្ការព្រះអង្គ ។ ដោយបទថា **ឥតិ មេ អរហតោ សុតំ** ព្រះកាឡុទាយិត្ថេរសម្តែងថា ខ្ញុំព្រះអង្គបានស្តាប់ក្នុងសម្នាក់របស់ព្រះអង្គនោះឯង ដែលបាននូវវោហារថា ជាព្រះអរហន្តដោយហេតុ ៤ យ៉ាង ដូចពណ៌នាមក ដូច្នេះ ។

បទថា **សព្វសំយោជនាតីតំ** បានដល់ ធ្លងផុតសំយោជនៈទាំង ១០ អស់ហើយ ។ បទថា **វនា និព្វានមាគតំ** បានដល់ ចេញចាកព្រៃ គឺកិលេសមកដល់ បានដល់ សម្រេចដល់និព្វានដែលមិនមានព្រៃ គឺវៀរចាកព្រៃ គឺកិលេស ។ បទថា **កាមេហិ នេក្ខម្មរតំ** សេចក្តីថា បព្វជ្ជា ១ សមាបត្តិប្រាំបី ១ អរិយមគ្គបួន ១ ឈ្មោះថា ការចេញចាកកាមទាំងឡាយ ព្រោះចេញទៅហើយចាកកាមទាំង ២ យ៉ាង ជាអ្នកត្រេកអរ គឺត្រេកអរក្រៃលែងក្នុងនេក្ខម្មៈនោះ ។

បទថា **មុត្តំ សេលាវ កញ្ចនំ** បានដល់ ដូចមាសដែលផុតអំពីធាតុគឺថ្ម ។ បទថា **សព្វេ អច្ចរុចិ** សេចក្តីថា ជាបុគ្គលប្រសើរប្រព្រឹត្តទៅលើសព្វ

សត្ថ អធិប្បាយថា ព្រះសោតាបន្ន ឈ្មោះថា ជាបុគ្គលប្រសើរលើបុគ្គលដទៃ ព្រោះមានការប្រសើរលើសបុថុជ្ជន ដែលកើតក្នុងភពទី ៨ ទៅ ព្រះសកទាគាមី ឈ្មោះថា ជាបុគ្គលប្រសើរ ព្រោះរុងរឿងប្រព្រឹត្តទៅលើព្រះសោតាបន្ន ។បេ។ ព្រះបច្ចេកពុទ្ធ ឈ្មោះថា ប្រសើរ ព្រោះរុងរឿង ប្រព្រឹត្តទៅលើព្រះខីណាស្រព ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ប្រសើរ ព្រោះរុងរឿងប្រព្រឹត្តទៅកន្លងបង់នូវព្រះបច្ចេកពុទ្ធ ។

បទថា **ហិមវាញ្ញោ សិលុច្ចយោ** សេចក្ដីថា ព្រះមានព្រះភាគ រមែងប្រសើរលើសបុគ្គលដទៃ ទាំងទេវតា និងមនុស្ស ប្រៀបដូចភ្នំហិមពាន្តប្រសើរលើសភ្នំដទៃៗ ដូច្នោះ ។ បទថា **សច្ចនាមោ** បានដល់ ទ្រង់មានព្រះនាមពិត គឺមានព្រះនាមតាមសេចក្ដីពិត បានដល់ មានព្រះនាមពិតយ៉ាងនេះថា **នាគ** ព្រោះមិនធ្វើអាក្រក់នោះឯង ។

បទថា **សោរច្ចំ** បានដល់ ជាអ្នកមានសីលស្អាត ។ បទថា **អវិហឹសា** បានដល់ ករុណា និងធម៌ដែលជាចំណែកខាងដើមនៃករុណា គឺមេត្តា ។ បទថា **ចរណា នាគស្ស តេ ទុវេ** សេចក្ដីថា ធម៌ទាំង ២ នោះ ជាព្រះបាទខាងមុខរបស់នាគ គឺព្រះពុទ្ធ ។ បទថា **តបោ** បានដល់ ការសមាទានវត្ត ។ បទថា **ព្រហ្មចរិយំ** បានដល់ សីលក្នុងអរិយមគ្គ ។

បទថា **ចរណា នាគស្ស ត្យាបរេ** សេចក្ដីថា តបៈ និងព្រហ្មចរិយៈទាំង ២ នោះ ជាព្រះបាទក្រៅអំពីនេះ គឺជាព្រះបាទខាងក្រោយរបស់នាគ គឺ

ព្រះពុទ្ធ ។ បទថា **សទ្ធាហត្ថោ** បានដល់ ប្រកបដោយប្រមោយ សម្រេច ដោយសទ្ធា ។ បទថា **ឧបេក្ខាសេតទន្តវា** បានដល់ ប្រកបដោយភ្លុកពណ៌ ស ដែលសម្រេចឧឡារុបេក្ខា ។ បទថា **សតិ គីវា** សេចក្តីថា កជាទីតាំង នៃប្រជុំសរសៃ ក្នុងអវយវៈតូចធំរបស់ដំរី យ៉ាងណា សតិ ក៏ជាទីតាំងនៃធម៌ មានសោរច្ចៈជាដើមនៃដំរី គឺព្រះពុទ្ធ ដូច្នោះ ដោយហេតុនោះ ទើបព្រះ កាឡុទាយិត្ថេរពោលថា **សតិ គីវា** ដូច្នេះ ។

បទថា **សិរោ បញ្ញា** សេចក្តីថា ក្បាលជាអវយវៈដ៏ប្រសើររបស់នាគ គឺដំរី យ៉ាងណា ព្រះសព្វញ្ញុតញ្ញាណ ក៏ជារបស់ប្រសើរនៃព្រះពុទ្ធនាគ ដូច្នោះ ព្រោះថា ព្រះពុទ្ធទាំងឡាយទ្រង់ជ្រាបធម៌ទាំងឡាយ ដោយព្រះសព្វញ្ញុតញ្ញាណ នោះ ដោយហេតុនោះ ទើបព្រះកាឡុទាយិត្ថេរពោលថា **សិរោ បញ្ញា** ដូច្នេះ ។

បទថា **វិមំសា ធម្មចិន្តនា** សេចក្តីថា នាគ គឺដំរី ឈ្មោះថា មានចុង ប្រមោយ ជាគ្រឿងពិចារណា ដំរីនោះពិចារណាដល់វត្ថុដែលរឹង ទន់ និង របស់ដែលគួរទំពា ដោយចុងប្រមោយនោះ បន្ទាប់អំពីនោះ ក៏លះវត្ថុដែល គួរលះ ចាប់យកវត្ថុដែលគួរចាប់ យ៉ាងណា ការអាវជ្ជនៈដល់ធម៌ ពោល គឺញាណជាគ្រឿងកំណត់ចំណែកនៃធម៌ ឈ្មោះថា ជាវិមំសារបស់ព្រះពុទ្ធនាគ ដូច្នោះដូចគ្នា ព្រោះថា ព្រះពុទ្ធអង្គនោះទ្រង់ស្គាល់កព្វាកព្វបុគ្គលដោយញាណ នោះ ដោយហេតុនោះ ទើបព្រះកាឡុទាយិត្ថេរពោលថា **វិមំសា ធម្មចិន្តនា** ដូច្នេះ ។

បទថា **ធម្មកុច្ឆិសមាសយោ** សេចក្តីថា សមាធិក្នុងចតុត្ថជ្ឈាន ហៅថាធម៌ ។ ការដុតបំផ្លាញកិលេស គឺកុច្ឆិ ឈ្មោះថា **កុច្ឆិសមាសយ** បានដល់ ទីសម្រាប់ដុតបំផ្លាញ ធម៌ដែលជាទីដុតបំផ្លាញ គឺពោះរបស់បុគ្គលនោះមាន ហេតុនោះ ទើបបុគ្គលនោះ ឈ្មោះថា មានធម៌ជាទីដុតបំផ្លាញ គឺពោះ ។ ព្រោះថា ធម៌ មានឥទ្ធិវិធិជាដើមនោះ រមែងសម្រេចដល់បុគ្គលដែលតាំងនៅក្នុងសមាធិ គឺចតុត្ថជ្ឈាន ព្រោះហេតុនោះ ទើបសមាធិក្នុងចតុត្ថជ្ឈាននោះ លោកហៅថា ធម៌ដែលដុតបំផ្លាញ គឺផ្ទៃ ។

បទថា **វិវេកោ** បានដល់ កាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ រោម កន្ទុយរបស់ដំរី រមែងដេញរុយ យ៉ាងណា វិវេករបស់តថាគត រមែងបណ្តេញគ្រហស្ថ និងបព្វជិត ដូច្នោះ ព្រោះហេតុនោះ ទើបវិវេកនោះ ព្រះកាឡុទាយិត្ថេរពោលថា រោមកន្ទុយ ។

បទថា **ឈាយី** ប្រែថា ជាអ្នកមានប្រក្រតីសម្លឹងដោយឈាន ២ ។ បទថា **អស្សាសរតោ** សេចក្តីថា ផលសមាបត្តិរបស់ព្រះពុទ្ធនាគ ប្រៀបដូចខ្យល់ដង្ហើមចូលចេញរបស់ដំរី ព្រះពុទ្ធទ្រង់ត្រេកអរក្នុងផលសមាបត្តិនោះ អធិប្បាយថា វៀរចាកផលសមាបត្តិនោះ ដែលប្រៀបដូចខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញក៏ប្រព្រឹត្តទៅមិនបាន ។

បទថា **សព្វត្ថ សំវុតោ** បានដល់ សង្រួមហើយគ្រប់ទ្វារ ។ បទថា **អនវជ្ជានិ** បានដល់ ភោជនដែលកើតឡើងអំពីសម្មាអាជីវៈ ។ បទថា

**សាវជ្ជានិ** បានដល់ ភោជនដែលកើតឡើងដោយមិច្ឆាអាជីវៈ ៥ យ៉ាង ។

បទថា **អណុំថូលំ** បានដល់ តិច និងច្រើន ។ បទថា **សព្វំ ឆេត្វាន ពន្ធនំ** បានដល់ កាត់នូវសំយោជនៈទាំង ១០ យ៉ាង ។ បទថា **ន ឧបលិម្បតិ លោកេន** សេចក្តីថា មិនជាប់នៅក្នុងលោកដោយគ្រឿងធ្វើឲ្យជាប់ គឺតណ្ហា មានះ និងទិដ្ឋិ ។

បទថា **មហាគ្គិនិ** បានដល់ គំនរភ្លើងធំ ។ បទថា **វិញ្ញូហិ ទេសិតា** នេះ សេចក្តីថា ព្រះកាឡុទាយិត្ថេរសម្រេចបដិសម្ភិទា ជាវិញ្ញូជន ជាបណ្ឌិត ឧបមាទាំងឡាយដែលព្រះកាឡុទាយិត្ថេរនោះបានសម្តែងហើយ ។

បទថា **វិញ្ញាយន្តិ មហានាគា នាគំ នាគេន ទេសិតំ** សេចក្តីថា នាគ គឺព្រះខីណាស្រពក្រៅអំពីនេះ នឹងដឹងច្បាស់នូវនាគ គឺព្រះពុទ្ធនាគ ព្រះឧទាយី សម្តែងហើយ ។

បទថា **សរីរំ វិជហំ នាគោ បរិនិព្វិស្សតិ** សេចក្តីថា នាគ គឺព្រះពុទ្ធ ទ្រង់រម្ងាត់ឥតសេសសល់ ដោយការរម្ងាត់កិលេស ក្នុងពោធិបល្ល័ង្ក ហើយ ទ្រង់នឹងរម្ងាត់ខន្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងរវាងដើមរាំង ទាំងគូ ។ ព្រះឧទាយិត្ថេរដែលសម្រេចបដិសម្ភិទា បញ្ចប់ទេសនាដោយពោល សរសើរគុណព្រះទសពល ដោយគាថា ១៦ ដោយបទ ៦៤ ដោយប្រការ ដូចពណ៌នាមក ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់អនុមោទនា ចប់ទេសនា សត្វ ៨៤០០០ បាន ផឹកនូវអមតៈ ដោយប្រការដូច្នេះ ។

អដ្ឋកថា នាគសូត្រទី ១ ចប់

# សុត្តន្តបិដក

## មិគសាលាសូត្រទី ២

[ ៤៤ ] លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ វេលានោះ មិគសាលាឧបាសិកា ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះអានន្ទដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះមិគសាលាឧបាសិកា អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងព្រះអានន្ទដ៏មានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គល ២ ពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗ គ្នាក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បិតារបស់ខ្ញុំឈ្មោះបុរាណៈ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ជាធម៌

របស់អ្នកស្រុក កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតាក្នុងស្ថានតុសិត បពិត្រលោកម្ចាស់ដ៏ចម្រើន ចំណែកឥសិទត្ត ជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ ជាអ្នកមិនប្រព្រឹត្តនូវធម៌ដ៏ប្រសើរទេ ជាអ្នកត្រេកអរតែក្នុងប្រពន្ធរបស់ខ្លួន កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិតដែរ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គល ២ ពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗ គ្នា ក្នុងបរលោក ។ ម្នាលនាង រឿងនុ៎ះ ព្រះដ៏មានព្រះភាគទ្រង់ព្យាករយ៉ាងហ្នឹងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ទទួលយកចង្ហាន់បិណ្ឌបាតក្នុងលំនៅនៃមិគសាលាឧបាសិកា រួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ លុះព្រះអានន្ទដ៏មានអាយុ ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏ចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃមិគសាលាឧបាសិកា លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែល

គេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ មិគសាលាឧបាសិកា ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយអង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះមិគសាលាឧបាសិកាអង្គុយក្នុងទីសមគួរហើយ ក៏បាននិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គល ២ ពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗ គ្នា ក្នុងបរលោក ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បិតារបស់ខ្ញុំឈ្មោះបុរាណៈ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រព្រឹត្តឆ្ងាយវៀរចាកមេថុនជាធម៌របស់អ្នកស្រុក កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិត បពិត្រលោម្ចាស់ដ៏ចម្រើន ឥសិទត្តជាទីស្រឡាញ់នៃបិតារបស់ខ្ញុំ ជាអ្នកមិនប្រព្រឹត្តធម៌ដ៏ប្រសើរទេ ជាអ្នកត្រេកអរតែក្នុងប្រពន្ធរបស់ខ្លួន កាលគាត់ធ្វើមរណកាលទៅ ព្រះដ៏មានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិសត្វ បានទៅកើតក្នុងពួកទេវតា ក្នុងស្ថានតុសិតដែរ បពិត្រព្រះអានន្ទដ៏ចម្រើន ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយនេះ គួរឲ្យអ្នកផងដឹងបាន ដោយហេតុដូចម្តេច ដូចយ៉ាងបុគ្គល ២ ពួក គឺព្រហ្មចារីបុគ្គល ១ អព្រហ្មចារីបុគ្គល ១ មានគតិស្មើៗ គ្នាក្នុងបរលោក ។ បពិត្រព្រះអង្គដ៏ចម្រើន កាលមិគសាលាឧបាសិកា និយាយយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយនឹង

មិគសាលាឧបាសិកាដូច្នេះថា ម្នាលនាង រឿងនុ៎ះ ព្រះដ៏មានព្រះភាគព្យាករ យ៉ាងហ្នឹងមែនហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មិគសាលាឧបាសិកាណា ជាស្ត្រីល្ងង់ មិនឈ្លាស មានសភាពជាស្ត្រី មានសញ្ញាជាស្ត្រី ព្រះសម្មាសម្ពុទ្ធទាំងឡាយណា មានវិស័យមិនបានទើសទាល់ ក្នុងសេចក្តីដឹងនូវឥន្ទ្រិយ រឺង និងទន់នៃបុរសបុគ្គលទាំង ២ នោះ ឆ្ងាយអំពីគ្នាណាស់ ។ ម្នាលអានន្ទ បុគ្គល ៦ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គលទាំង ៦ ពួក តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកស្លូត ជាអ្នកមានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយ ( នឹងបុគ្គលនោះ ) ។ បុគ្គលនោះ មិនបានធ្វើដោយការស្តាប់ផង មិនបានធ្វើដោយសេចក្តីព្យាយាមផង មិនចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ គឺបីតិ និងបាមោជ្ជដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ មិនប្រព្រឹត្តទៅដើម្បីគុណវិសេស ជាអ្នកដល់នូវការសាបសូន្យ មិនដល់នូវគុណវិសេស ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកស្លូត មានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយនឹងបុគ្គលនោះ ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ គឺបីតិ និងបាមោជ្ជដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែង

ប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ជាអ្នកដល់នូវគុណវិសេស មិនដល់នូវសេចក្តីសាបសូន្យ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកប្រមាណក្នុងធម៌នោះ រមែងដឹងប្រមាណថា នោះជាធម៌របស់អ្នកនេះ នោះជាធម៌របស់អ្នកឯទៀត ហេតុដូចម្តេចបានជាអ្នកទាំងនោះ មានធម៌មួយថោកទាប មានធម៌មួយឧត្តម ។ ម្នាលអានន្ទ ព្រោះថា ដំណើរនោះ ប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែងដល់បុគ្គលទាំងនោះ ។ ម្នាលអានន្ទ ក្នុងរឿងនោះ បុគ្គលណា ជាអ្នកស្លូត មានសំវាសជាសុខ ពួកសព្រហ្មចារី រមែងត្រេកអរដោយការនៅជាមួយនឹងបុគ្គលនោះ ។ បុគ្គលនោះ បានធ្វើដោយការស្តាប់ផង បានធ្វើដោយសេចក្តីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ គឺបីតិ និងបាមោជ្ជដែលអាស្រ័យនូវការស្តាប់ធម៌សព្វកាលផង ។ ម្នាលអានន្ទ បុគ្គលនោះប្រសើរជាង ឧត្តមជាងបុគ្គលជាន់មុនឯណោះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះធម្មស្សោតៈ គឺវិបស្សនាញាណ រមែងដឹកនាំនូវបុគ្គលនេះ ( ឲ្យបានសម្រេចអរិយភូមិ ) ។ លំដាប់តពីនោះមក អ្នកណាគប្បីដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ ។ ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ កុំប្រកបដោយប្រមាណ ក្នុងបុគ្គលទាំង-ឡាយផង កុំប្រកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយផង ។ ម្នាលអានន្ទ ព្រោះថា បុគ្គលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយហើយ ហៅថា

ជីករម្ចើងនូវគុណ ។ ម្នាលអានន្ទ តថាគតគប្បីកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ឬបុគ្គលណា ប្រហែលនឹងតថាគត ( ក៏គប្បីកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយបានដែរ ) ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្ដីក្រោធ និងមានះគ្របសង្កត់ហើយ លោកធម៌រមែងកើតឡើងដល់បុគ្គលនោះសព្វៗ កាល ។ បុគ្គលនោះ មិនបានធ្វើដោយការស្ដាប់ផង មិនបានធ្វើដោយសេចក្ដីព្យាយាមផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលអាស្រ័យនូវការស្ដាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេស ជាបុគ្គលដល់នូវសេចក្ដីសាបសូន្យ មិនដល់នូវគុណវិសេសឡើយ ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្ដីក្រោធ និងមានះគ្របសង្កត់ហើយ លោកធម៌ រមែងកើតឡើង ដល់បុគ្គលនោះសព្វៗ កាល ។ បុគ្គលនោះ បានធ្វើដោយការស្ដាប់ផង ។បេ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្ដីក្រោធ និងមានះគ្របសង្កត់ហើយ វចីសង្ខាររមែងកើតឡើង ដល់បុគ្គលនោះសព្វៗ កាល ។ បុគ្គលនោះមិនបានធ្វើដោយការស្ដាប់ផង មិនបានធ្វើដោយសេចក្ដីព្យាយាមផង មិនបានចាក់ធ្លុះដោយទិដ្ឋិផង មិនបាននូវវិមុត្តិ ដែលអាស្រ័យនូវការស្ដាប់ធម៌សព្វកាលផង ។ លុះបុគ្គលនោះ បែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ មិនប្រព្រឹត្តទៅ ដើម្បីគុណវិសេស ជាបុគ្គល

ដល់នូវការសោបសូន្យ មិនដល់នូវគុណវិសេស ។ ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្ដីក្រោធ និងមានះគ្របសង្កត់ហើយ វចីសង្ខាររមែងកើតឡើង ដល់បុគ្គលនោះសព្វៗ កាល ។ បុគ្គលនោះ បានធ្វើដោយការស្ដាប់ផង បានធ្វើដោយសេចក្ដីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិ ដែលអាស្រ័យនូវការស្ដាប់ធម៌ សព្វកាលផង ។ លុះបុគ្គលនោះបែកធ្លាយរាងកាយស្លាប់ទៅ រមែងប្រព្រឹត្តទៅ ដើម្បីគុណវិសេស មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីសាបសូន្យ ជាបុគ្គលដល់នូវគុណវិសេស មិនដល់នូវសេចក្ដីសាបសូន្យ ។ ម្នាលអានន្ទ បុគ្គលអ្នកកាន់យកនូវប្រមាណ រមែងដឹងប្រមាណក្នុងធម៌នោះថា នោះជាធម៌របស់អ្នកនេះ នោះជាធម៌របស់អ្នកឯទៀត ព្រោះហេតុអ្វី បានជាបុគ្គលទាំងនោះមានធម៌ ១ ថោកទាប មានធម៌ ១ ឧត្តម ។ ម្នាលអានន្ទ ព្រោះថា ដំណើរនោះប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ អស់កាលជាយូរអង្វែងដល់បុគ្គលទាំងនោះ ។ រឿងនោះ បុគ្គលណាមានសេចក្ដីក្រោធ និងមានះគ្របសង្កត់ហើយ វចីសង្ខារ រមែងកើតឡើងដល់បុគ្គលនោះសព្វៗ កាល ។ បុគ្គលនោះ បានធ្វើដោយការស្ដាប់ផង បានធ្វើដោយសេចក្ដីព្យាយាមផង បានចាក់ធ្លុះដោយទិដ្ឋិផង បាននូវវិមុត្តិដែលអាស្រ័យនូវការស្ដាប់ធម៌សព្វកាលផង ។ ម្នាលអានន្ទ បុគ្គលនេះប្រសើរជាង ឧត្តមជាងបុគ្គលជាន់មុនឯណោះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលអានន្ទ ព្រោះធម្មសោតៈ គឺវិបស្សនាញាណ ដឹកនាំនូវបុគ្គលនេះ

( ឲ្យបានសម្រេចអរិយភូមិ ) ។ លំដាប់តពីនោះមក អ្នកណាគប្បីដឹងបាននូវហេតុនោះកើត លើកលែងតែព្រះតថាគតចេញ ។ ម្នាលអានន្ទ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ កុំប្រកបដោយប្រមាណ ក្នុងបុគ្គលទាំង-ឡាយផង កុំប្រកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយផង ។ ម្នាលអានន្ទ ព្រោះថា កាលបុគ្គលកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយ ហៅថាជីករម្លើងនូវគុណ ។ ម្នាលអានន្ទ តថាគតកាន់យកនូវប្រមាណ ក្នុងបុគ្គលទាំងឡាយបាន ឬបុគ្គលណាប្រហែលនឹងតថាគត ( ក៏គប្បីកាន់យកនូវប្រមាណក្នុងបុគ្គលទាំងឡាយបានដែរ ) ។ ម្នាលអានន្ទ មិគសាលាឧបា-សិកាណាក្តី ជាស្ត្រីល្ងង់ មិនឈ្លាស មានសភាពជាស្ត្រី មានសញ្ញាជាស្ត្រី ព្រះសម្មាសម្ពុទ្ធទាំងឡាយណាក្តី មានវិស័យមិនបានទើសទាល់ ក្នុងសេចក្តីដឹងនូវឥន្ទ្រិយរឹង និងទន់ របស់បុរសបុគ្គល បុគ្គលទាំង ២ នោះ ឆ្ងាយអំពីគ្នាណាស់ ។ ម្នាលអានន្ទ បុគ្គល ៦ ពួកនេះឯង មានប្រាកដក្នុងលោក ។ ម្នាលអានន្ទ បុរាណឧបាសក ប្រកបដោយសីល មានសភាពយ៉ាងណា ឥសិទត្ត ក៏ប្រកបដោយសីល មានសភាពយ៉ាងនោះដែរ តែបុរាណឧបាសកមិនបានដឹងនូវគតិរបស់ឥសិទត្ត ក្នុងលោកនេះឡើយ ។ ម្នាលអានន្ទ ឥសិទត្តប្រកបដោយបញ្ញាមានសភាពយ៉ាងណា បុរាណឧបាសក ក៏ប្រកបដោយបញ្ញាមានសភាពយ៉ាងនោះដែរ តែឥសិទត្តមិនបានដឹងនូវគតិរបស់បុរាណឧបាសកក្នុងលោកនេះឡើយ ។ ម្នាលអានន្ទ បុគ្គលទាំង ២ នាក់នេះ មានសេចក្តីសាបសូន្យចាកអង្គ ១ ដូច្នេះឯង ។

# អដ្ឋកថា

## មិគសាលាសូត្រ

[ ៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមិគសាលាសូត្រទី ២ ដូចតទៅនេះ បទថា **កថំ កថំ នាម** សេចក្តីថា ដោយហេតុអ្វី ។ បទថា **អញ្ញេយ្យោ** ប្រែថា ធម៌ដែលបុគ្គលគប្បីដឹងទូទៅ ។ បទថា **យត្រ ហិ នាម** គឺក្នុងធម៌ណា ។ បទថា **សមសមគតិកា** សេចក្តីថា ព្រហ្មចារីបុគ្គល និងអព្រហ្មចារីបុគ្គល ដែលជនទាំងឡាយដឹងហើយថា នឹងជាបុគ្គលមានគតិស្មើគ្នា ដោយភាវៈដែលស្មើគ្នានោះឯង ។ បទថា **សកទាគាមី សត្តោ តុសិតំ កាយំ ឧបបន្នោ** សេចក្តីថា កើតឡើងជាសកទាគាមិបុគ្គលក្នុងតុសិតភពនោះឯង ។

បទថា **កថំ កថំ នាម** សេចក្តីថា ដោយហេតុអ្វីហ្ន៎ គឺទ្រង់ស្គាល់ហើយទើបសម្តែង ឬទ្រង់មិនស្គាល់ព្រះថេរៈមិនជ្រាបហេតុ ទើបពោលថា ម្នាលប្អូនស្រី សេចក្តីនេះ ព្រះមានព្រះភាគទ្រង់ព្យាករយ៉ាងនេះ ។

បទថា **អម្មកា អម្មកសញ្ញា** សេចក្តីថា មិគសាលាឧបាសិកា ជាស្រី គង់ប្រកបដោយការសម្គាល់ថាជាស្រីនោះឯង ។

ក្នុងបទថា **កេ ច បុរិសបុគ្គលបរោបរិយញ្ញាណេ** នេះ មានអត្ថសន្ធេបដូច្នេះថា ញាណជាគ្រឿងកំណត់ដឹងនូវការធូរ និងការចម្រើនឡើងនៃឥន្ទ្រិយរបស់បុរសបុគ្គលទាំងឡាយថា ខ្លាំងក្លា ឬទន់ខ្សោយ ហៅថា បុរិសបុគ្គលបរោបរិយញ្ញាណ ក្នុងពាក្យថា **កេ ច បុរិសបុគ្គលបរោបរិយញ្ញាណេ** នេះ ។ ព្រោះហេតុនោះ មិគសាលាឧបាសិកាស្រីល្ងង់ គឺអ្នកណា ព្រះសម្មា-

សម្ពុទ្ធទ្រង់មានអារម្មណ៍មិនត្រូវរារាំង ព្រោះញាណជាគ្រឿងដឹងនូវការធូរថយ និងការក្រៃលែងនៃឥន្ទ្រិយរបស់បុរសបុគ្គលទាំងឡាយ ជាអ្នកណា ការប្រៀបធៀបបុគ្គលទាំង ២ នោះ នៅឆ្ងាយគ្នាពន់ពេក ។

ឥឡូវនេះ កាលទ្រង់សម្តែងថា មិគសាលាឧបាសិកា និងទ្រង់ឆ្ងាយក្រៃលែង ទើបព្រះមានព្រះភាគត្រាស់ថា **ឆយិមេ អានន្ទ** ជាដើម ។ បទថា **សោរតោ ហោតិ** សេចក្តីថា បុគ្គលខ្លះ ជាអ្នកវៀរ គឺវៀរចាកដោយល្អអំពីបាប ។ បាឋៈជា **សូរតោ** ដូច្នេះក៏មាន ។

បទថា **អភិនន្ទន្តិ សព្រហ្មចារី ឯកត្តវាសេន** សេចក្តីថា ព្រហ្មចារីបុគ្គលទាំងឡាយ នាំគ្នាសរសើរ គឺត្រេកអរ ដោយការនៅរួមជាមួយបុគ្គលនោះ ។ បាឋៈជា **ឯកន្តវាសេន** ដូច្នេះក៏មាន ដោយអត្ថថា ការនៅជិតគ្នា ។

បទថា **សវនេនបិ អកតំ ហោតិ** សេចក្តីថា មិនបានស្តាប់វត្ថុដែលគួរស្តាប់ ។ ក្នុងបទថា **ពាហុសច្ចេនបិ អកតំ ហោតិ** នេះ មានអត្ថថា វីរិយៈ ហៅថា **ពាហុសច្ច** មិនបានធ្វើវត្ថុដែលគួរធ្វើដោយវីរិយៈ ។ បទថា **ទិដ្ឋិយាបិ អប្បដិវិទ្ធំ ហោតិ** សេចក្តីថា មិនបានចាក់ធ្លុះនូវវត្ថុដែលគួរចាក់ធ្លុះដោយទិដ្ឋិ ។

បទថា **សាមាយិកម្បិ វិមុត្តឹ ន លភតិ** សេចក្តីថា មិនបានបីតិ និងបាមោជ្ជ ដែលកើតឡើងព្រោះអាស្រ័យការស្តាប់ធម៌ តាមកាលដ៏សមគួរ ។ បទថា **ហានគាមីយេវ ហោតិ** សេចក្តីថា រមែងដល់នូវការវិនាសតែម្យ៉ាង

បទថា **បមាណិកា** គឺជាអ្នកកាន់យកប្រមាណក្នុងបុគ្គលទាំងឡាយ ។

បទថា **បមិនន្តិ** បានដល់ ផ្តើមប្រៀបធៀប គឺថ្លឹង ។ បទថា **ឯកោ ហីនោ** សេចក្តីថា បុគ្គលម្នាក់ទាបជាងដោយគុណ ។ បទថា **ឯកោ បណីតោ** សេចក្តីថា បុគ្គលម្នាក់ប្រណីតជាងដោយគុណ ។ បទថា **តញ្ហិ** បានដល់ ធ្វើការប្រៀបធៀបនោះ ។

បទថា **អភិក្កន្តតរោ** គឺល្អជាង ។ បទថា **បណីតតរោ** គឺឧត្តមជាង ។ បទថា **ធម្មសោតោ និព្ពហតិ** សេចក្តីថា វិបស្សនាញាណ ប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា នាំចេញទៅចាកកិលេស គឺឲ្យដល់អរិយភូមិ ។ បទថា **តទនន្តរំ កោ ជានេយ្យ** សេចក្តីថា ជាប់បន្តអំពីនោះ គឺហេតុនោះ ក្រៅអំពីព្រះតថាគតហើយ អ្នកណានឹងដឹង ។

បទថា **កោធមានោ** បានដល់ សេចក្តីក្រោធ និងការប្រកាន់ខ្លួន ។ បទថា **លោភធម្មា** បានដល់ សេចក្តីលោភនោះឯង ។ បទថា **វចីសង្ខារា** បានដល់ ការពោលដោយអំណាចការសន្ទនាប្រាស្រ័យ ។

បទថា **យោ វា បនស្ស មាទិសោ** សេចក្តីថា ឬមួយព្រះសម្មាសម្ពុទ្ធណាដែលដូចនឹងតថាគត គប្បីមានមួយអង្គទៀត ព្រះសម្មាសម្ពុទ្ធអង្គនោះក៏គប្បីកាន់យកប្រមាណក្នុងបុគ្គលទាំងឡាយ ។ បទថា **ឧញ្ញាតិ** បានដល់ ដល់នូវការជីកនូវគុណ ។

បទថា **ឥមេ ខោ អានន្ទ ឆ បុគ្គលា** សេចក្តីថា បុគ្គល ៦ ពួក គឺ

បុគ្គលស្ងប់ស្ងៀម ២ ពួក បុគ្គលសង្កត់សេចក្តីក្រោធ ការប្រកាន់ខ្លួន និង ធម៌ គឺសេចក្តីលោភបាន ២ ពួក បុគ្គលសង្កត់សេចក្តីក្រោធ ការប្រកាន់ខ្លួន និងវចីសង្ខារបាន ២ ពួក ។

បទថា **គតឹ** បានដល់ ញាណគតិ ។ បទថា **ឯកង្គហីនា** សេចក្តីថា បុគ្គលទាំង ២ ពួក គឺបុរាណៈ និងឥសិទត្តៈ ទាបជាងគ្នាដោយអង្គគុណ ម្នាក់ម្យ៉ាង ។ គឺបុរាណៈវិសេសដោយសីល ឥសិទត្តៈវិសេសដោយបញ្ញា សីលរបស់បុគ្គលបុរាណៈ តាំងនៅក្នុងឋានៈស្មើគ្នានឹងបញ្ញារបស់ឥសិទត្តៈ បញ្ញារបស់ឥសិទត្តៈ តាំងនៅក្នុងឋានៈស្មើគ្នានឹងសីលរបស់បុរាណៈ ដូច្នេះ ។៚

**អដ្ឋកថា មិគសាលាសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឥណសូត្រទី ៣

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ សេចក្តីទ័លក្រ ជាទុក្ខនៃកាមភោគីបុគ្គល ( បុគ្គលអ្នកបរិភោគកាម ) ក្នុងលោកដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រ មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាន់យកនូវបំណុលណា ម្នាលភិក្ខុទាំងឡាយ ការកាន់យកនូវបំណុលនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណា ព្រះ

អង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រ មិនមានវត្ថុជារបស់ខ្លួន មិនបាន ជាបុគ្គលស្តុកស្តម្ភ កាន់យកនូវបំណុលហើយ ប្តេជ្ញានូវអំពើចងការណា ម្នាលភិក្ខុទាំងឡាយ អំពើចងការនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រ មិន មានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ ប្តេជ្ញានូវអំពើចងការហើយ មិនឲ្យការដែលគេឲ្យ នាំមកតាមកំណត់កាល ម្ចាស់បំណុលទាំងឡាយ រមែងតឹងទារនូវបុគ្គលនោះ ដោយការតឹងទារណា ម្នាលភិក្ខុទាំងឡាយ ការ តឹងទារនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រ មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គល ស្តុកស្តម្ភ កាលបើគេតឹងទារហើយមិនបានឲ្យគេ រមែងដេញតាមនូវបុគ្គល នោះ ដោយការដេញតាមទារណា ម្នាលភិក្ខុទាំងឡាយ ការដេញតាមនោះ ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុ ទាំងឡាយ បុគ្គលទ័លក្រ មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាលបើគេដេញតាមទារ ក៏មិនបានឲ្យគេ គេរមែងចងនូវបុគ្គលនោះដោយ ចំណងណា ម្នាលភិក្ខុទាំងឡាយ ចំណងនោះជាទុក្ខនៃកាមភោគីបុគ្គលក្នុង លោកដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីទ័លក្រក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការកាន់យកនូវបំណុលក្តី ក៏ជាទុក្ខនៃ កាមភោគីបុគ្គលក្នុងលោក អំពើចងការក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក

ការតឹងទារក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការដេញតាមទារក្តី ក៏ជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោក ការចងក្តី ក៏សុទ្ធតែជាទុក្ខនៃកាមភោគីបុគ្គលក្នុងលោកដោយពិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មិនមានសទ្ធាក្នុងកុសលធម៌ មិនមានហិរិ ក្នុងកុសលធម៌ មិនមានឱត្តប្បៈ ក្នុងកុសលធម៌ មិនមានវិរិយៈ ក្នុងកុសលធម៌ មិនមានបញ្ញា ក្នុងកុសលធម៌ ក៏យ៉ាងដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលទ័លក្រ មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រនោះឯង មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្តុកស្តម្ភ កាលបើមិនមានសទ្ធា ក្នុងកុសលធម៌ មិនមានហិរិ ក្នុងកុសលធម៌ មិនមានឱត្តប្បៈ ក្នុងកុសលធម៌ មិនមានវិរិយៈ ក្នុងកុសលធម៌ មិនមានបញ្ញា ក្នុងកុសលធម៌ហើយ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ តថាគតពោលនូវអំពើនេះថា ជាការកាន់យកនូវបំណុលរបស់បុគ្គលនោះ ។ បុគ្គលនោះ រមែងតម្កល់ទុកនូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុតែការបិទបាំងនូវកាយទុច្ចរិតនោះ ប្រាថ្នាមិនឲ្យជនណាស្គាល់ខ្លួន ត្រិះរិះមិនឲ្យជនណាស្គាល់ខ្លួន ពោលនូវវាចា មិនឲ្យជនណាស្គាល់ខ្លួន ប្រឹងប្រែងដោយកាយ មិនឲ្យជនណាស្គាល់ខ្លួនឡើយ ។ បុគ្គលនោះ ព្រោះហេតុតែការបិទបាំងនូវវចីទុច្ចរិតនោះ ។បេ។ បុគ្គលនោះ រមែងតម្កល់នូវសេចក្តីប្រាថ្នាដ៏លាមក ព្រោះហេតុតែការបិទបាំង នូវមនោទុច្ចរិតនោះ ប្រាថ្នាមិនឲ្យ

ជនណាស្គាល់ខ្លួន ត្រិះរិះមិនឲ្យជនណាស្គាល់ខ្លួន ពោលនូវវាចាមិនឲ្យជនណាស្គាល់ខ្លួន ប្រឹងប្រែងដោយកាយ មិនឲ្យជនណាស្គាល់ខ្លួនឡើយ ។ តថាគតពោលនូវអំពើនេះថា ជាអំពើចង្ការរបស់បុគ្គលនោះ ។ ពួកសព្រហ្មចារីបុគ្គលអ្នកមានសីល ជាទីស្រឡាញ់ និយាយចោទបុគ្គលនោះយ៉ាងនេះថា នេះឯង គឺអ្នកដ៏មានអាយុនោះ ជាអ្នកធ្វើយ៉ាងនេះ មានសមាចារយ៉ាងនេះ ។ តថាគតពោលនូវអំពើនេះថា ជាការតឹងទាររបស់បុគ្គលនោះ ។ អកុសលវិតក្កដ៏លាមក ដែលប្រកបដោយសេចក្ដីក្ដៅក្រហាយ រមែងផុសផុលឡើងចំពោះបុគ្គលនោះ ដែលនៅក្នុងព្រៃក្ដី នៅក្រោមម្លប់ឈើក្ដី នៅក្នុងផ្ទះដ៏ស្ងាត់ក្ដី តថាគតពោលនូវអំពើនេះថា ជាការដេញតាមរបស់បុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទ័លក្រនោះឯង មិនមានវត្ថុជារបស់ខ្លួន មិនបានជាបុគ្គលស្ដុកស្ដម្ភ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងជាប់នៅក្នុងចំណង គឺនរក ឬក្នុងចំណង គឺកំណើតតិរច្ឆាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលឃើញនូវចំណងដទៃណាមួយអាក្រក់យ៉ាងនេះ នាំមកនូវសេចក្ដីទុក្ខយ៉ាងនេះ ធ្វើនូវសេចក្ដីអន្តរាយយ៉ាងនេះ ដល់ការបាននូវព្រះនិព្វាន ជាទីក្សេមចាកយោគៈដ៏ប្រសើរទេ ម្នាលភិក្ខុទាំងឡាយ ដូចជាចំណង គឺនរក ឬចំណង គឺកំណើតតិរច្ឆាននេះឡើយ ។

សេចក្ដីទ័លក្រក្ដី ការកាន់យកនូវបំណុលក្ដី ហៅថា

ជាទុក្ខក្នុងលោក បុគ្គលទ័លក្រកាន់យកនូវបំណុល មកបរិភោគ រមែងលំបាក ព្រោះហេតុនោះ ពួកជនជាម្ចាស់ រមែងដេញតាមបុគ្គលនោះ បុគ្គលនោះរមែងដល់នូវចំណង ចំណងនេះឯង ជាទុក្ខនៃបុគ្គលអ្នកប្រាថ្នានូវកាម និងលាភទាំងឡាយ ។ ក្នុងអរិយ-វិន័យដូច្នោះដែរ បុគ្គលណា មិនមានសទ្ធា មិនមានហិរិ មិនមានឱត្តប្បៈ ជាអ្នកបំប៉ននូវបាបកម្ម ធ្វើនូវកាយទុច្ចរិតផង វចីទុច្ចរិតផង មនោទុច្ចរិតផង ហើយប្រាថ្នាមិនឲ្យជនដទៃស្គាល់ខ្លួនឡើយ ។ បុគ្គលនោះ រមែងញាប់ញ័រដោយកាយ ដោយវាចា ឬដោយចិត្តឈ្មោះថា បំប៉ននូវបាបកម្មរឿយៗ ក្នុងទីនោះៗ ។ បុគ្គលនោះ មានអំពើអាក្រក់ ឥតប្រាជ្ញាកាលដឹងនូវអំពើអាក្រក់របស់ខ្លួន រមែងលំបាកដូចអ្នកទ័លក្រ កាន់យកនូវបំណុល ហើយបរិភោគ ។ សេចក្តីត្រិះរិះដោយចិត្តកើតឡើង អំពីសេចក្តីក្តៅក្រហាយរបស់បុគ្គល ដែលនៅក្នុងស្រុក ឬនៅក្នុងព្រៃក៏ជាទុក្ខ ដូចកូនបំណុល ដែលត្រូវម្ចាស់បំណុលដេញតាមទារ ។ បុគ្គលនោះ មានអំពើអាក្រក់ ឥត

ប្រាជ្ញា កាលដឹងនូវអំពើអាក្រក់របស់ខ្លួន រមែងទៅកាន់កំណើតណាមួយ ឬជាប់ទៅក្នុងនរក អ្នកមានប្រាជ្ញា រមែងផុតស្រឡះចាកចំណង ដែលជាទុក្ខនុ៎ះ ។ បុគ្គលញ៉ាំងចិត្តឲ្យជ្រះថ្លាហើយ ឲ្យទានដោយភោគៈ ដែលបានមកដោយធម៌ ការកាន់យកជម្នះក្នុងធម៌ទាំង ២ នោះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង របស់បុគ្គលអ្នកមានសទ្ធា ជាអ្នកស្វែងរកផ្ទះ បុណ្យ គឺការបរិច្ចាគនុ៎ះ រមែងចម្រើនដល់គ្រហស្ថទាំងឡាយយ៉ាងនេះឯង ។ ក្នុងអរិយវិន័យ បុគ្គលណាមានសទ្ធាតម្កល់នៅ មានហិរិ មានឱត្តប្បៈ មានបញ្ញា សង្រួមក្នុងសីល បុគ្គលនោះឯង ទើបហៅថា រស់នៅជាសុខក្នុងអរិយវិន័យ ។ បុគ្គលបាននូវសេចក្តីសុខប្រាសចាកអាមិសៈ រមែងតម្កល់ចិត្តជាឧបេក្ខា លះបង់នូវនីវរណៈទាំង ៥ ហើយប្រារព្ធសេចក្តីព្យាយាមជានិច្ច បានដល់នូវឈានទាំងឡាយ ជាបុគ្គលមានចិត្តខ្ពស់ឯក មានបញ្ញា មានស្មារតី ចិត្តក៏ផុតស្រឡះដោយប្រពៃ ព្រោះដឹងនូវហេតុនុ៎ះ តាមពិត

ព្រោះមិនបានប្រកាន់យក ដោយប្រការទាំងពួង ក្នុងការអស់ទៅនៃសំយោជនៈទាំងពួង ។ បុគ្គលនោះ លុះមានចិត្តផុតស្រឡះដោយប្រពៃហើយ ជាបុគ្គលមិនកម្រើកដោយលោកធម៌ រមែងមានបច្ចវេក្ខណ-ញាណថា វិមុត្តិរបស់អាត្មាអញមិនបានកក្រើកដូច្នេះ កើតឡើងក្នុងកិរិយាអស់ទៅ នៃភវសំយោជនៈ ។ ញាណនុ៎ះឯងជាញាណដ៏ឧត្តម សេចក្តីសុខក្នុងមគ្គនិងផលនោះ ជាសុខរកសេចក្តីសុខដទៃក្រៃលែងជាងគ្មាន ឥតមានសេចក្តីសោក ប្រាសចាកធូលីគឺកិលេស ជាទីក្សេម អរហត្តផលនុ៎ះ ជាគុណជាតដ៏ឧត្តមជាងការៈនៃបុគ្គលមិនមានបំណុល ។

# អដ្ឋកថា

## ឥណសូត្រ

[ ៤៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥណសូត្រទី ៣ ដូចតទៅនេះ បទថា **ទាលិទ្ទិយំ** បានដល់ ភាពជាអ្នកក្រីក្រ ។ បទថា **កាមភោគិនោ** បានដល់ សត្វដែលបរិភោគកាម ។ បទថា **អស្សកោ** បានដល់ ប្រាសចាកទ្រព្យដែល

ជារបស់ខ្លួន ។ បទថា **អឆន្ទិកោ** បានដល់ មិនស្ដុកស្ដម្ភ ។ បទថា **ឥណំ អាទិយតិ** បានដល់ កាលមិនអាចតាំងនៅបាន ក៏ខ្ចីនូវបំណុល ។

បទថា **វត្តុំ បដិស្សុណាតិ** បានដល់ កាលមិនអាចសងបាន ក៏ឲ្យសញ្ញាថា នឹងឲ្យការប្រាក់ ។ បទថា **អនុចរន្តិបិ នំ** សេចក្ដីថា ម្ចាស់បំណុលទាំងឡាយដេញតាមក្រោយកូនបំណុលទៅ ធ្វើឲ្យបុគ្គលនោះ បានទទួលនូវការភិតភ័យ ដោយការធ្វើ មានការចាប់ចងហាលថ្ងៃ និងបាចធូលីដាក់ជាដើម ក្នុងកណ្ដាលបរិស័ទ និងកណ្ដាលគណៈជាដើម ។

បទថា **សទ្ធា នត្ថិ** បានដល់ មិនមានសូម្បីតែសទ្ធា ។ បទថា **ហិរិ នត្ថិ** បានដល់ មិនមានត្រឹមតែហិរិ ។ បទថា **ឱត្តប្បំ នត្ថិ** បានដល់ មិនមានត្រឹមតែឱត្តប្បៈ ។

បទថា **វីរិយំ នត្ថិ** បានដល់ មិនមានត្រឹមតែសេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅតាមកាយ ។ បទថា **បញ្ញា នត្ថិ** បានដល់ មិនមានត្រឹមតែកម្មស្សកតាបញ្ញា ។ បទថា **ឥណាទានស្មឹ វទាមិ** បានដល់ ខ្ញុំពោលដល់ការខ្ចីបុល ។ បទថា **មា មំ ជញ្ញា** បានដល់ សូមម្ចាស់បំណុលទាំងឡាយកុំបីជួបអញ ។

បទថា **ទាលិទ្ទិយំ ទុក្ខំ** បានដល់ ភាពជាអ្នកក្រទ្រព្យ ជាហេតុឲ្យកើតទុក្ខ ។ បទថា **កាមលាភាភិជប្បិនំ** បានដល់ ជាអ្នកប្រាថ្នាការបានកាម ។ បទថា **បាបកម្មំ វិនិព្វយោ** បានដល់ ជាអ្នកសាងបាបកម្ម ។ បទថា **សំសប្បតិ** បានដល់ អន្ទះអន្ទែង ។ បទថា **ជានំ** បានដល់ ដឹង ។

បទថា **យស្ស វិប្បដិសារជា** សេចក្ដីថា ការត្រិះរិះទាំងឡាយណា របស់បុគ្គលក្រីក្រនោះ កើតមកអំពីការក្ដៅក្រហាយ ។

បទថា **យោនិមញ្ញតរំ** បានដល់ កំណើតសត្វតិរច្ឆានណាមួយ ។ បទថា **ឧជំ ចិត្តំ បសាទយំ** សេចក្ដីថា ធ្វើចិត្តឲ្យជ្រះថ្លា ហើយឲ្យ ។

បទថា **កដគ្គាហោ** បានដល់ ការបាននូវជ័យជម្នះ គឺការបានមិនខុសមាន ។ បទថា **ឃរមេសិនោ** បានដល់ ស្វែងរក ឬនៅគ្រប់គ្រងផ្ទះ ។ បទថា **ចាគោ បុញ្ញំ បវឌ្ឍតិ** សេចក្ដីថា បុណ្យដែលប្រព្រឹត្តទៅក្នុងសង្ឃ គឺចាគៈ រមែងចម្រើន ។ម្យ៉ាងទៀត បាលីថា **ចាគំ បុញ្ញំ** ដូច្នេះក៏មាន ។

បទថា **បតិដ្ឋិតា** សេចក្ដីថា សទ្ធារបស់ព្រះសោតាបន្ន ឈ្មោះថា សទ្ធាដែលតាំងមាំ ។ បទថា **ហិរិមនោ** បានដល់ ចិត្តសម្បយុត្តដោយហិរិ ។ បទថា **និរាមិសំ សុខំ** បានដល់ សុខដែលអាស្រ័យឈាន ៣ កើតឡើង ។

បទថា **ឧបេក្ខំ** បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ បទថា **អារទ្ធ–វីរិយោ** បានដល់ មានសេចក្ដីព្យាយាមផ្គងពេញលេញ ។ បទថា **ឈានានិ ឧបសម្បជ្ជ** បានដល់ សម្រេចឈាន ៤ ។ បទថា **ឯកោទិ និបកោ សតោ** បានដល់ មានចិត្តជាឯកគ្គតា និងប្រកបដោយកម្មស្សកតា-ញាណ និងសតិ ។

បទថា **ឯតំ ញត្វា យថាភូតំ** សេចក្ដីថា ស្គាល់ហេតុនេះ គឺប៉ុណ្ណោះតាមសភាវៈដែលពិត ។ បទថា **សព្វសំយោជនក្ខយេ** បានដល់ ក្នុងនិព្វាន ។

បទថា **សព្វសោ** បានដល់ ដោយអាការទាំងពួង ។ បទថា **អនុបាទាយ** បានដល់ មិនប្រកាន់ ។

ក្នុងបទថា **សម្មា ចិត្តំ វិមុច្ចតិ** មានពាក្យអធិប្បាយដូច្នេះថា ព្រោះមិនប្រកាន់ដោយប្រការទាំងពួងក្នុងនិព្វាន ពោល គឺធម៌ជាទីអស់ទៅនៃសំយោជនៈទាំងពួង ។ ទើបមគ្គចិត្តរួចផុតដោយប្រពៃ គឺដោយហេតុ ដោយន័យ ។ ព្រះសង្គីតិកាចារ្យរចនាបាលីជា **ឯវំ ញត្វា យថាភូតំ សព្វ-សំយោជនក្ខយំ** ដូច្នេះក៏មាន ។ បាលីនោះ មានអត្ថថា ដឹងនិព្វាន ពោល គឺធម៌ជាទីអស់ទៅនៃសំយោជនៈទាំងអស់នោះ តាមសេចក្ដីពិត ។ តែអត្ថបាលី បទមុន និងបទក្រោយ មិនជាប់គ្នាឡើយ ។

បទថា **តស្ស សម្មាវិមុត្តស្ស** សេចក្ដីថា ព្រះខីណាស្រពនោះ គឺរួចផុតដោយប្រពៃ ។ បទថា **ញាណំ ចេ ហោតិ** បានដល់ មានបច្ចវេក្ខណញ្ញាណ ។ បទថា **តាទិនោ** បានដល់ តាំងមាំនៅក្នុងនិព្វាននោះ ។ បទថា **អកុប្បា** សេចក្ដីថា វិមុត្តិ ឈ្មោះថា មិនកម្រើក ព្រោះមានធម៌មិនកម្រើកជាអារម្មណ៍ និងព្រោះមិនមានកិលេសជាគ្រឿងធ្វើឲ្យកម្រើក ។

បទថា **វិមុត្តិ** សំដៅដល់ មគ្គវិមុត្តិផង ផលវិមុត្តិផង ។ បទថា **ភវ-សំយោជនក្ខយេ** សេចក្ដីថា ព្រោះកើតឡើងក្នុងនិព្វាន ពោល គឺធម៌ជាទីអស់ទៅនៃកិលេស ជាគ្រឿងចងសត្វទុកក្នុងភព និងព្រោះកើតឡើងក្នុងទីបំផុត ដែលកិលេសជាគ្រឿងចងសត្វទុកក្នុងភពអស់ទៅ ។ បទថា **ឯតំ**

**ទោ បរមំ ញាណំ** សេចក្តីថា មគ្គញ្ញាណ និងផលញ្ញាណនោះ ឈ្មោះថា បរមញ្ញាណ ។

បទថា **សុខមនុត្តរំ** សេចក្តីថា សុខកើតអំពីមគ្គ និងផលនោះឯង ឈ្មោះថា **អនុត្តរសុខ** ។ បទថា **អានណ្យ មុត្តមំ** សេចក្តីថា បណ្តាបុគ្គលដែលមិនមានបំណុលទាំងអស់ ព្រះខីណាស្រពជាអ្នកមិនមានបំណុលដ៏ឧត្តម ព្រោះហេតុនោះ ទើបព្រះមានព្រះភាគសង្ខេបអត្ថសំខាន់ៗ នៃទេសនា ដោយអរហត្តផលថា អរហត្តផល ជាញាណមិនមានបំណុលដ៏ឧត្តម ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់វដ្តៈមុន ហើយទើបត្រាស់វដ្តៈផង វិវដ្តៈផង ក្នុងគាថាទាំងឡាយ ដូច្នេះ ។

**អដ្ឋកថា ឥណសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មហាចុន្ទសូត្រទី ៤

[ ៤៦ ] សម័យមួយ ព្រះមហាចុន្ទដ៏មានអាយុ នៅក្នុងនិគមឈ្មោះសញ្ញាតិ ជិតដែនឈ្មោះចេតី ។ ក្នុងទីនោះ ព្រះមហាចុន្ទដ៏មានអាយុ មានថេរវាចាហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលស្តាប់ថេរវាចា ព្រះមហាចុន្ទដ៏មានអាយុថា អាវុសោដូច្នេះ ។ ព្រះមហាចុន្ទដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលអាវុសោទាំងឡាយ

ពួកធម្មយោគភិក្ខុ ( ភិក្ខុអ្នកព្យាយាមក្នុងធម៌ ) ក្នុងសាសនានេះ បន្តុះបង្អាប់ពួកឈាយីភិក្ខុ ( ភិក្ខុអ្នកមានឈាន ) ថា ភិក្ខុទាំងនេះរិះគិតថា យើងជាអ្នកមានឈាន យើងជាអ្នកមានឈាន ចុះភិក្ខុទាំងនេះ គិតអ្វី ភិក្ខុទាំងនេះគិតដើម្បីអ្វី ភិក្ខុទាំងនេះ គិតដោយហេតុអ្វី ។ បណ្តាភិក្ខុទាំងនោះ ឯពួកធម្ម-យោគភិក្ខុក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ឯពួកឈាយីភិក្ខុក្នុងសាសនានេះ រមែងបន្តុះបង្អាប់ធម្មយោគភិក្ខុថា ភិក្ខុទាំងនោះ ជាអ្នកមានចិត្តប៉ោងឡើង មានចិត្តខ្ពស់ឡើង មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចារោយរាយ មានសតិភ្លាំងភ្លាត់ មិនបានដឹងព្រម មានចិត្តមិនតម្កល់មាំ មានចិត្តរវើរវាយ មានឥន្ទ្រិយតាំងនៅ ជាប្រក្រតី គិតថា យើងជាអ្នកមានព្យាយាមក្នុងធម៌ យើងជាអ្នកមានព្យាយាមក្នុងធម៌ ភិក្ខុទាំងនេះ ជាធម្មយោគអ្វី ភិក្ខុទាំងនេះជាធម្មយោគដើម្បីអ្វី ភិក្ខុទាំងនេះ ជាធម្មយោគដោយហេតុអ្វី បណ្តាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ពួក

ធម្មយោគភិក្ខុ ក្នុងសាសនានេះ រមែងនិយាយសរសើរ តែភិក្ខុជាធម្មយោគ ដូចគ្នា មិននិយាយសរសើរពួកឈាយីភិក្ខុឡើយ ។ បណ្តាភិក្ខុទាំងនោះ ឯពួកធម្មយោគភិក្ខុ ក៏មិនជ្រះថ្លា ពួកឈាយីភិក្ខុ ក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ឯពួកឈាយីភិក្ខុក្នុងសាសនានេះ រមែងនិយាយសរសើរ តែពួកឈាយីភិក្ខុដូចគ្នា មិននិយាយសរសើរពួកធម្មយោគភិក្ខុឡើយ ។ បណ្តាភិក្ខុទាំងនោះ ឯពួកឈាយីភិក្ខុក៏មិនជ្រះថ្លា ពួកធម្មយោគភិក្ខុក៏មិនជ្រះថ្លា ទាំងមិនបានប្រតិបត្តិ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ជនច្រើន ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងជាធម្មយោគភិក្ខុ នឹងនិយាយសរសើរពួកឈាយីភិក្ខុ ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោទាំងឡាយ ព្រោះថា បុគ្គលណាបានពាល់ត្រូវនូវធាតុ ឈ្មោះ អមតៈ ដោយនាមកាយហើយ បុគ្គលនុ៎ះ ជាបុគ្គលអស្ចារ្យ រកបានដោយក្រក្នុងលោក ។ ម្នាលអាវុសោទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងជាពួកឈាយី-

ភិក្ខុ នឹងនិយាយសរសើរពួកធម្មយោគភិក្ខុ ។ ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។ រឿងនោះ ព្រោះហេតុអ្វី ម្នាលអាវុសោទាំងឡាយ ព្រោះថា បុគ្គលណាត្រាស់ដឹង ឃើញនូវចំណែកនៃអត្ថដ៏ជ្រាលជ្រៅដោយប្រាជ្ញាហើយ បុគ្គលនុ៎ះជាបុគ្គលអស្ចារ្យ រកបានដោយក្រក្នុងលោក ។

# អដ្ឋកថា

## មហាចុន្ទសូត្រ

[ ៤៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាចុន្ទសូត្រទី ៤ ដូចតទៅនេះ បទថា **ចេតីសុ** បានដល់ ក្នុងចេតិរដ្ឋ ។ បទថា **សញ្ជាតិយំ** បានដល់ ក្នុងនិគមមានឈ្មោះយ៉ាងនេះ ។ បទថា **មហាចុន្ទោ** បានដល់ ប្អូនប្រុសរបស់ព្រះធម្មសេនាបតី ។

ភិក្ខុទាំងឡាយ ឈ្មោះថា **ធម្មយោគ** ព្រោះមានការប្រកប គឺការធ្វើរឿយៗ ក្នុងធម៌ ។ ពាក្យថា **ធម្មយោគា** នុ៎ះ ជាឈ្មោះនៃព្រះធម្មកថិកទាំងឡាយ ។ ភិក្ខុ ឈ្មោះថា **ឈាយី** ព្រោះសម្លឹង ។

បទថា **អបសាទេន្តិ** បានដល់ ទ្រគោះបោះបោក គឺរុករាន ។ បទថា **ឈាយន្តិ** បានដល់ គិត ។ បទថា **បជ្ឈាយន្តិ** ជាដើម ពង្រីករូបចេញទៅ

ដោយអំណាចឧបសគ្គ ។ បទថា **កិញ្ចិមេ ឈាយន្តិ** សេចក្តីថា ភិក្ខុជម្ពុកបិកទាំងនេះសម្ងំដូចម្តេច ។

បទថា **កិន្តិមេ ឈាយន្តិ** សេចក្តីថា ភិក្ខុជម្ពុកបិកទាំងនេះចូលឈានដើម្បីអ្វី ។ បទថា **កថញ្ចិមេ ឈាយន្តិ** សេចក្តីថា ភិក្ខុជម្ពុកបិកទាំងនេះចូលឈាន ព្រោះហេតុអ្វី ។

បទថា **អមតំ ធាតុំ កាយេន ផុសិត្វា វិហរន្តិ** ជាដើម សេចក្តីថា ភិក្ខុទាំងឡាយកំណត់កម្មដ្ឋាន បំណាងដល់និព្វានធាតុ ដែលវៀរចាកមរណៈ គឺពាល់ត្រូវនូវនិព្វានធាតុនោះ ដោយនាមកាយតាមលំដាប់ ។

បទថា **គម្ភីរអត្ថបទំ** បានដល់ អត្ថរបស់ខន្ធ ធាតុ អាយតនៈជាដើម គម្ភីរភាព គឺត្រូវអវិជ្ជាបិទបាំង ។ បទថា **បញ្ញាយ អតិវិជ្ឈបស្សន្តិ** សេចក្តីថា ឃើញដោយចាក់ធ្លុះដោយមគ្គប្បញ្ញា ព្រមទាំងវិបស្សនាបញ្ញា ។

តែក្នុងទីនេះ រមែងគួរទាំងបញ្ញាជាគ្រឿងចាក់ធ្លុះ ដោយការពិចារណាផង បញ្ញាក្នុងការរៀន និងការសាកសួរផង ។ល។

## អដ្ឋកថា មហាចុន្ទសូត្រទី ៤ ចប់

# សុត្តន្តបិដក

## បឋមសន្ទិដ្ឋិកសូត្រទី ៨

[ ៤៧ ] គ្រានោះ មោឡិយសិវកបរិព្វាជក ( បរិព្វាជកឈ្មោះ មោឡិយសិវកៈ ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះមោឡិយ-សិវកបរិព្វាជកអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ បពិត្រព្រះអង្គដ៏ចម្រើន ចុះសន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱប-នយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ តើដូចម្តេច ។ ម្នាលសិវកៈ បើដូច្នោះ តថាគតនឹងសួរតបទៅអ្នកវិញ ក្នុងហេតុនុ៎ះ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយសេចក្តីនោះ យ៉ាងនោះចុះ ។ ម្នាលសិវកៈ អ្នកសម្គាល់នូវហេតុនោះដូចម្តេច កាលលោភៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមានក្នុងសន្តានរបស់អាត្មាអញ កាលលោភៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសិវកៈ កាលលោភៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមានក្នុងសន្តានរបស់អាត្មាអញ កាលលោភៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា លោភៈមិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលសិវកៈ យ៉ាងនេះឯង ហៅថា សន្ទិដ្ឋិកធម៌ ។បេ។ ម្នាលសិវកៈ អ្នក

សម្គាល់នូវហេតុនោះដូចម្តេច កាលទោសៈ មានក្នុងសន្តានក្តី ។បេ។ កាលមោហៈមានក្នុងសន្តានក្តី កាលលោភធម៌មានក្នុងសន្តានក្តី ទោសធម៌មានក្នុងសន្តានក្តី មោហធម៌មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មានក្នុងសន្តានរបស់អាត្មាអញ កាលមោហធម៌មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសិវកៈ កាលមោហធម៌មានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មានក្នុងសន្តានរបស់អាត្មាអញ កាលមោហធម៌មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា មោហធម៌មិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលសិវកៈ យ៉ាងនេះឯង ហៅថា សន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ ។ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់លាស់ពេកណាស់ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្គាល់នូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## បឋមសន្ទិដ្ឋិកសូត្រ

[ ៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមសន្ទិដ្ឋិកសូត្រទី ៥ ដូចតទៅនេះ បទថា **សន្តំ វា អជ្ឈត្តំ** បានដល់ មានខាងក្នុងខ្លួន ។ ព្រះមានព្រះភាគទ្រង់សម្តែងអកុសលមូល ៣ ដោយបទថា **លោភោ** ជាដើម ។ ទ្រង់សម្តែង

ធម៌ដែលសម្បយុត្តដោយអកុសលមូល ៣ នោះ ដោយបទថា **លោភជម្មា** ជាដើម ។ល។

## អដ្ឋកថា បឋមសន្ទិដ្ឋិកសូត្រទី ៥ ចប់

# សុត្តន្តបិដក

## ទុតិយសន្ទិដ្ឋិកសូត្រទី ៦

[ ៤៨ ] លំដាប់នោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ដែលហៅថាសន្ទិដ្ឋិកធម៌ សន្ទិដ្ឋិកធម៌ បពិត្រព្រះគោតមដ៏ចម្រើន ចុះសន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិធម៌ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ តថាគតនឹងសួរតបទៅអ្នកវិញក្នុងហេតុនុ៎ះ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយនូវហេតុនោះ យ៉ាងនោះចុះ ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់នូវហេតុនោះដូចម្តេច កាលរាគៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមានក្នុងសន្តានរបស់អាត្មាអញ កាលរាគៈមិនមានក្នុងសន្តានក្តី អ្នកដឹង

ច្បាស់ថា រាគៈមិនមានក្នុងសន្តានរបស់អាត្មាអញដែរឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលរាគៈមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមានក្នុងសន្តានរបស់អាត្មាអញ កាលរាគៈមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា រាគៈមិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលព្រាហ្មណ៍ យ៉ាងនេះឯង ហៅថា សន្ទិដ្ឋិកធម៌ ។បេ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់នូវហេតុនោះដូចម្តេច កាលទោសៈមានក្នុងសន្តានក្តី កាលមោហៈមានក្នុងសន្តានក្តី កាលហេតុជាគ្រឿងប្រទូស្តនៃកាយទ្វារ មានក្នុងសន្តានក្តី កាលហេតុជាគ្រឿងប្រទូស្តនៃវចីទ្វារមានក្នុងសន្តានក្តី ។បេ។ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មានក្នុងសន្តានរបស់អាត្មាអញ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានរបស់អាត្មាអញដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលព្រាហ្មណ៍ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មានក្នុងសន្តានរបស់អាត្មាអញ កាលហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារមិនមានក្នុងសន្តានក្តី អ្នកដឹងច្បាស់ថា ហេតុជាគ្រឿងប្រទូស្តនៃមនោទ្វារ មិនមានក្នុងសន្តានរបស់អាត្មាអញ ដោយហេតុណា ម្នាលព្រាហ្មណ៍ យ៉ាងនេះឯង ហៅថា សន្ទិដ្ឋិកធម៌ អកាលិកធម៌ ឯហិបស្សិកធម៌ ឱបនយិកធម៌ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ-

ធម៌ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់លាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់លាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន សម្គាល់នូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈ ស្មើដោយជីវិតចាប់ដើមអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## ទុតិយសន្ទិដ្ឋិកសូត្រ

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយសន្ទិដ្ឋិកសូត្រទី ៦ ដូចតទៅនេះ បទថា **កាយសណ្ឋោសំ** បានដល់ ហេតុនៃការប្រទូស្តកាយទ្វារ ។ ក្នុងបទដ៏សេស ក៏មានន័យនេះឯង ។

ព្រះមានព្រះភាគ ត្រាស់បច្ចវេក្ខណញ្ញាណក្នុងសូត្រទាំង ២ នេះហើយ ដូច្នេះ ។៚

**អដ្ឋកថា ទុតិយសន្ទិដ្ឋិកសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## ខេមសុមនសូត្រទី ៧

[ ៤៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះខេមៈដ៏មានអាយុ និងព្រះសុមនៈដ៏មានអាយុ នៅក្នុងអន្ធវន ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះខេមៈដ៏មានអាយុ និងព្រះសុមនៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះខេមៈអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណា ជាអរហន្តខីណាស្រព មានមគ្គព្រហ្មចរិយធម៌នៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានភវសំយោជនៈអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះថា បុគ្គលដទៃប្រសើរជាងអាត្មាអញក្តី ប្រហែលអាត្មាអញក្តី ថោកទាបជាងអាត្មាអញក្តី យ៉ាងនេះទេ ។ ព្រះខេមៈដ៏មានអាយុ បានក្រាបបង្គំទូលដូច្នេះហើយ ។ ព្រះសាស្តាក៏សព្វព្រះហឫទ័យ ។ លំដាប់នោះ ព្រះខេមៈដ៏មានអាយុគិតថា ព្រះសាស្តារបស់អាត្មាអញ ទ្រង់សព្វព្រះហឫទ័យហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះខេមៈដ៏មានអាយុ ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះសុមនៈដ៏មានអាយុ ក៏ក្រាបបង្គំ

ទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណាជាអរហន្ត ខីណាស្រព មានមគ្គព្រហ្មចរិយៈនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានភវ-សំយោជនៈអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ មិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា មិនមានបុគ្គលដទៃប្រសើរជាង អាត្មាអញផង មិនមានបុគ្គលដទៃ ប្រហែលនឹងអាត្មាអញផង មិនមានបុគ្គល ដទៃ ថោកទាបជាងអាត្មាអញផង ។ ព្រះសុមនៈដ៏មានអាយុ បានក្រាបបង្គំ ទូលដូច្នេះរួចហើយ ។ ព្រះសាស្ដា ក៏ទ្រង់សព្វព្រះហឫទ័យ ។ គ្រានោះ ព្រះសុមនៈដ៏មានអាយុគិតថា ព្រះសាស្ដារបស់អាត្មាអញ ទ្រង់សព្វព្រះហឫទ័យ ហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ លំដាប់នោះ កាលព្រះខេមៈដ៏មានអាយុ និងព្រះ សុមនៈដ៏មានអាយុ ចៀសចេញទៅ មិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគទ្រង់ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកកុលបុត្តរមែងពោលនូវ អរហត្តផលយ៉ាងនេះឯង ទាំងសេចក្ដី ក៏ពួកកុលបុត្តនោះបានពោលហើយ ទាំងខ្លួន ក៏ពួកកុលបុត្តនោះ មិនបានបង្អោនទៅដោយមានះ ចំណែកមោឃ-បុរសពួកខ្លះ ក្នុងលោកនេះ ហាក់ដូចជារីករាយ ពោលនូវអរហត្តផល ពួក មោឃបុរសទាំងនោះ នឹងដល់នូវសេចក្ដីទុក្ខ ក្នុងកាលជាខាងក្រោយ ។

ព្រះខីណាស្រពទាំងឡាយ មិនបានបង្អោនខ្លួនទៅដោយមានះ ក្នុងពួក

បុគ្គលខ្ពស់ មិនបានបង្អោនខ្លួនទៅដោយមានះ ក្នុងពួកបុគ្គលទាប មិនបាន បង្អោនខ្លួនទៅដោយមានះ ក្នុងបុគ្គលស្មើនឹងខ្លួន ព្រោះមានជាតិអស់ហើយ មានមគ្គព្រហ្មចរិយធម៌នៅរួចហើយ មានចិត្តផុតស្រឡះចាកសំយោជនៈហើយ ។

# អដ្ឋកថា

## ខេមសុមនសូត្រ

[ ៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខេមសុមនសូត្រទី ៧ ដូចតទៅនេះ បទថា **វុសិតវា** បានដល់ អ្នកនៅចប់ព្រហ្មចរិយៈហើយ ។ បទថា **កត-ករណីយោ** បានដល់ អ្នកធ្វើកិច្ចដែលគួរធ្វើដោយមគ្គ ៤ ហើយ ។ បទថា **ឱហិតភារោ** បានដល់ ដាក់នូវខន្ធភារៈ កិលេសភារៈ និងអភិសង្ខារភារៈ ចុះហើយ ។

បទថា **អនុប្បត្តសទត្ថោ** សេចក្តីថា អរហត្ត ហៅថា ប្រយោជន៍ របស់ខ្លួន ដែលសម្រេចប្រយោជន៍របស់ខ្លួននោះ ។ បទថា **បរិក្ខីណភវ-សំយោជនោ** សេចក្តីថា អ្នកមានកិលេស ជាគ្រឿងចងសត្វក្នុងភពអស់ហើយ ។ បទថា **សម្មទញ្ញា វិមុត្តោ** សេចក្តីថា រួចផុតហើយ ព្រោះដឹង ដោយប្រពៃ គឺដោយហេតុ ដោយការណ៍ ។

ព្រះមានព្រះភាគ ទ្រង់បដិសេធមានះ ៣ មានមានះថា អញល្អជាងជាដើម ដែលជារបស់មាននៃបុថុជ្ជន ដែលល្អជាងបុគ្គលដទៃ ដោយបទថា **តស្ស ន ឯវំ ហោតិ អត្ថិ មេ សេយ្យោតិ វា** ជាដើម ព្រោះថា ព្រះខីណាស្រពមិនមានមានះថា អ្នកដែលល្អជាងអាត្មាអញមាន អ្នកដែលស្មើអាត្មាអញមាន អ្នកដែលអាក្រក់ជាងអាត្មាអញមាន ។ ព្រះមានព្រះភាគទ្រង់បដិសេធមានះទាំង ៣ នោះឯង ដោយបទថា **នត្ថិ មេ សេយ្យោ** ជាដើម ។ ព្រោះថា ព្រះខីណាស្រព មិនមានមានះយ៉ាងនេះថា អាត្មាអញនេះឯងល្អជាងគេ អាត្មាអញស្មើគេ អាត្មាអញអាក្រក់ជាងគេ មិនមានបុគ្គលដទៃដែលល្អជាងជាដើម ។

បទថា **អចិរបក្កន្តេសុ** សេចក្តីថា កាលព្រះខេមៈ និងព្រះសុមនៈព្យាករអរហត្តផល ហើយចៀសចេញទៅមិនយូរ ។ បទថា **អញ្ញំ ព្យាករោន្តិ** បានដល់ ពោលដល់អរហត្តផល ។ បទថា **ហសមានកា មញ្ញេ អញ្ញំ ព្យាករោន្តិ** សេចក្តីថា ពោលដូចសើច ។ បទថា **វិឃាតំ អាបជ្ជន្តិ** បានដល់ ជួបនូវទុក្ខ ។

ក្នុងបទថា **ន ឧស្សេសុ ន ឱមេសុ សមត្តេ នោបនិយ្យរេ** នេះ អធិប្បាយថា បទថា **ឧស្សា** បានដល់ បុគ្គលដែលគេសរសើរ គឺបុគ្គលដែលប្រសើរជាងគេ ។

បទថា **ឱមា** បានដល់ បុគ្គលដែលអាក្រក់ជាងគេ ។ បទថា **សមត្តោ**

បានដល់ បុគ្គលដែលស្មើគ្នានឹងគេ ។ បណ្តាបុគ្គលប្រសើរជាងគេ អាក្រក់ជាងគេ និងស្មើគេ ទាំង ៣ ពួកនេះ ព្រះខីណាស្រពដែលមានះ នាំចូលទៅមិនបាន គឺមិនចូលជិត អធិប្បាយថា មិនចូលដល់នូវមានះ ។

បទថា **ខីណា សញ្ញាតិ** បានដល់ ជាតិរបស់ព្រះខីណាស្រពទាំងនោះអស់ហើយ ។ បទថា **វុសិតំ ព្រហ្មចរិយំ** បានដល់ មគ្គព្រហ្មចរិយៈ ដែលព្រះខីណាស្រពនៅចប់ហើយ ។ បទថា **ចរន្តិ សំយោជនវិប្បមុត្តា** សេចក្តីថា ព្រះខីណាស្រពទាំងឡាយ ជាបុគ្គលរួចផុតចាកសំយោជនៈទាំងពួង ត្រាច់ទៅ ។ ព្រះមានព្រះភាគ ត្រាស់ដល់ព្រះខីណាស្រពក្នុងព្រះសូត្រផង ក្នុងគាថាផង ៕

## អដ្ឋកថា ខេមសុមនសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ឥន្ទ្រិយសំវរសូត្រទី ៨

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមិនមានហើយ សីលនៃបុគ្គលដែលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើសីលមិនមានហើយ សម្មាសមាធិនៃបុគ្គលដែលវិបត្តិចាកសីល ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើសម្មាសមាធិមិនមានហើយ យថាភូតញ្ញាណទស្សនៈ នៃបុគ្គលដែលវិបត្តិចាកសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើយថាភូតញ្ញាណទស្សនៈមិនមានហើយ និព្វិទាវិរាគៈនៃបុគ្គលដែលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ កាលបើនិព្វិទាវិរាគៈមិនមានហើយ វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលដែលវិបត្តិចាកនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមឈើដែលវិបត្តិចាកមែក និងស្លឹក ក្រមរនៃដើមឈើនោះក្តី ក៏មិនដល់នូវការពេញលេញ សម្បកក្តី ក៏មិនដល់នូវការពេញលេញ ស្រាយក្តី ក៏មិនដល់នូវការពេញលេញ ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមិនមានហើយ សីលនៃបុគ្គលដែលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យហើយ ។បេ។ វិមុត្តិញ្ញាណទស្សនៈក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមានហើយ សីលនៃបុគ្គលដែលបរិបូណ៌ ដោយឥន្ទ្រិយសំវរៈ ឈ្មោះថា

មានឧបនិស្ស័យបរិបូណ៌ កាលបើសីលមានហើយ សម្មាសមាធិនៃបុគ្គលដែលបរិបូណ៌ដោយសីល ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើសម្មាសមាធិមានហើយ យថាភូតញ្ញាណទស្សនៈនៃបុគ្គលដែលបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើយថាភូតញ្ញាណ-ទស្សនៈមានហើយ និព្វិទាវិរាគៈនៃបុគ្គលដែលបរិបូណ៌ដោយយថាភូតញ្ញាណ-ទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើនិព្វិទាវិរាគៈមានហើយ វិមុត្តិញ្ញាណទស្សនៈនៃបុគ្គលដែលបរិបូណ៌ ដោយនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមឈើដែលបរិបូណ៌ដោយមែក និងស្លឹក ក្រមរនៃដើមឈើនោះក្តី ក៏ដល់នូវការពេញលេញ សម្បកក្តី ក៏ដល់នូវការពេញលេញ ស្រាយក្តី ក៏ដល់នូវការពេញលេញ ខ្លឹមក្តី ក៏ដល់នូវការពេញលេញ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើឥន្ទ្រិយសំវរៈមានហើយ សីលនៃបុគ្គលដែលបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ។បេ។ វិមុត្តិញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា

## ឥន្ទ្រិយសំវរសូត្រ

[ ៥០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយសំវរសូត្រទី ៨ ដូចតទៅនេះ បទថា **ហតូបនិសំ ហោតិ** សេចក្តីថា សីលមានទីអាស្រ័យ គឺឧបនិស្ស័យត្រូវកម្ចាត់ចេញហើយ ។ បទថា **សីលវិបន្នស្ស** បានដល់ ដែលមានសីលវិបត្តិ ។ បទថា **យថាភូតញ្ញាណទស្សនំ** បានដល់ វិបស្សនាញាណយ៉ាងទន់ ។ ក្នុងបទថា **និព្វិទា វិរាគោ** មានអធិប្បាយដូច្នេះ វិបស្សនាដែលមានកម្លាំង ឈ្មោះថា **និព្វិទា** អរិយមគ្គ ឈ្មោះថា **វិរាគ** ។ ក្នុងបទថា **វិមុត្តិញ្ញាណទស្សនំ** នេះ មានអធិប្បាយដូច្នេះ អរហត្តផល ឈ្មោះថា **វិមុត្តិ** បច្ចវេក្ខណញ្ញាណ ឈ្មោះថា **ញាណទស្សន** ។

បទថា **ឧបនិស្សយសម្បន្នំ ហោតិ** សេចក្តីថា សីលមានទីអាស្រ័យដល់ព្រមហើយ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់ឥន្ទ្រិយសំវរៈដែលជាគ្រឿងជួយរក្សាសីល ។ល។

**អដ្ឋកថាឥន្ទ្រិយសំវរសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អានន្ទសូត្រទី ៩

[ ៥១ ] គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសារីបុត្តដ៏មានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ បាននិយាយនឹងព្រះសារីបុត្តដ៏មានអាយុ ដូច្នេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុស្តាប់នូវធម៌ដែលខ្លួនមិនដែលស្តាប់ក្តី ធម៌ដែលភិក្ខុនោះស្តាប់ហើយ មិនដល់នូវសេចក្តីភ្លេចភ្លាំងទៅវិញក្តី ពួកធម៌ណាដែលភិក្ខុនោះ ធ្លាប់ប៉ះពាល់ដោយចិត្តក្នុងកាលមុនធម៌ទាំងនោះក៏ផុសផុលឡើងក្តី ភិក្ខុនោះដឹងច្បាស់នូវធម៌ដែលខ្លួនមិនធ្លាប់ដឹងក្តី តើដោយហេតុប៉ុន្មាន ។ ព្រះសារីបុត្តនិយាយថា អានន្ទដ៏មានអាយុ ជាពហុស្សូតស្រាប់ហើយ សូមអានន្ទដ៏មានអាយុ សម្តែងនូវធម៌នោះទៅ ។ ព្រះអានន្ទតបថា ម្នាលអាវុសោសារីបុត្ត បើដូច្នោះ សូមលោកចាំស្តាប់នូវធម៌ ហើយធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសម្តែង ។ ព្រះសារីបុត្តដ៏មានអាយុ បានទទួលពាក្យព្រះអានន្ទដ៏មានអាយុថា អើ អាវុសោ ។ ព្រះអានន្ទដ៏មានអាយុ ក៏និយាយដូច្នេះថា ម្នាលអាវុសោសារីបុត្ត ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ សម្តែងនូវធម៌តាមទំនង ដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្តារ

បង្រៀននូវធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដោយពិស្ដារ ស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដោយពិស្ដារ ត្រិះរិះរឿយៗ ពិចារណារឿយៗ គិតរឿយៗ នូវធម៌តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រដោយចិត្ត ពួកភិក្ខុថេរៈ ជាពហុស្សូត ជាអ្នកចេះចាំនូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា នៅក្នុងអាវាសណា ក៏ចូលទៅកាន់វស្សា ក្នុងអាវាសនោះ លុះចូលទៅរកភិក្ខុទាំងនោះ សព្វកាលហើយ ក៏សាកសួរ ដេញដោលថា បពិត្រព្រះករុណាដ៏ចម្រើន ពាក្យនេះ ដូចម្ដេច អត្ថរបស់ពាក្យនេះ ដូចម្ដេច ។ ភិក្ខុទាំងនោះ រមែងបង្ហាញនូវធម៌ដ៏កំបាំងផង ធ្វើនូវធម៌ដែលក្រឲ្យទៅជាងាយផង បន្ទោបង់នូវសេចក្ដីសង្ស័យ ក្នុងធម៌ដែលមានប្រការច្រើន ជាទីតាំងនៃសេចក្ដីសង្ស័យផង ដល់ភិក្ខុនោះ ។ ម្នាលអាវុសោសារីបុត្ត ភិក្ខុស្ដាប់នូវធម៌ ដែលខ្លួនមិនដែលបានស្ដាប់ក្ដី ធម៌ដែលភិក្ខុនោះស្ដាប់ហើយ មិនដល់នូវសេចក្ដីភ្លេចភ្លាំងទៅវិញក្ដី ពួកធម៌ណាដែលភិក្ខុនោះ ធ្លាប់ប៉ះពាល់ហើយដោយចិត្តក្នុងកាលមុន ធម៌ទាំងនោះ ក៏ផុសផុលឡើងក្ដី ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ដែលខ្លួនមិនធ្លាប់ដឹងក្ដី ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលអាវុសោ អស្ចារ្យពេកណាស់ ម្នាលអាវុសោ ចម្លែកពេកណាស់ ព្រោះថា ពាក្យនេះ ព្រះអានន្ទដ៏មានអាយុបានពោលហើយ ដោយប្រពៃ ។ យើងចាំទុកនូវព្រះអានន្ទដ៏មានអាយុ ដែលប្រកបដោយធម៌ ៦ យ៉ាងនេះឯង ។ ព្រោះថា

ព្រះអានន្ទដ៏មានអាយុ រៀនយកនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ ព្រះអានន្ទដ៏មានអាយុ រមែងសំដែងធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ បង្ហាញធម៌តាមទំនង ដែលខ្លួនចេះដឹង តាមទំនងដែលខ្លួនបានរៀនសូត្រ ដល់បុគ្គលដទៃដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ ស្វាធ្យាយនូវធម៌ តាមទំនងដែលខ្លួនចេះដឹង តាមទំនង ដែលខ្លួនបានរៀនសូត្រដោយពិស្តារ ព្រះអានន្ទដ៏មានអាយុ ត្រិះរិះរឿយៗ ពិចារណារឿយៗ គិតរឿយៗ នូវធម៌តាមទំនងដែលខ្លួនចេះដឹង តាមទំនង ដែលខ្លួនបានរៀនសូត្រដោយចិត្ត ពួកភិក្ខុថេរៈ ជាពហុស្សូត ជាអ្នកចេះចាំ នូវនិកាយ ទ្រទ្រង់ធម៌ ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា នៅក្នុងអាវាសណា ព្រះអានន្ទដ៏មានអាយុ ចូលទៅកាន់វស្សាក្នុងអាវាសនោះ ព្រះអានន្ទដ៏មានអាយុ រមែងចូលទៅរកភិក្ខុទាំងនោះសព្វ ៗ កាល ហើយសាកសួរដេញដោលថា បពិត្រលោកទាំងឡាយដ៏ចម្រើន ពាក្យនេះ ដូចម្តេច អត្ថរបស់ពាក្យនេះ ដូចម្តេច ។ ភិក្ខុទាំងនោះ ក៏បង្ហាញនូវធម៌ដែលកំបាំងផង ធ្វើនូវធម៌ដែលក្រឲ្យទៅជាងាយផង បន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ដែលមានប្រការច្រើន ជាទីតាំងនៃសេចក្តីសង្ស័យផង ដល់ព្រះអានន្ទដ៏មានអាយុ ។

# អដ្ឋកថា

## អានន្ទសូត្រ

[ ៥១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានន្ទសូត្រទី ៩ ដូចតទៅនេះ បទថា **កិត្តាវតា** បានដល់ ដោយហេតុមានប្រមាណប៉ុនណា ។ បទថា **អស្សុតពេ្វ** សេចក្តីថា ធម៌ដែលមិនធ្លាប់ស្តាប់មកក្នុងកាលដទៃ ។ បទថា **ន សម្មោសំ គច្ឆន្តិ** សេចក្តីថា ធម៌ទាំងឡាយ រមែងមិនដល់នូវការអស់ទៅ ។ បទថា **ចេតសា សម្ផុដ្ឋបុព្វា** សេចក្តីថា ធម៌ទាំងឡាយដែលធ្លាប់ពាល់ត្រូវដោយចិត្ត ។ បទថា **សមុទាចរន្តិ** បានដល់ ត្រាច់ទៅក្នុងមនោទ្វារ ។ បទថា **អវិញ្ញាតពេ្វ វិជានាតិ** សេចក្តីថា ស្គាល់ហេតុដែលមិនទាន់ដឹងមកក្នុងកាលដទៃ ។ បទថា **បរិយាបុណាតិ** បានដល់ ប្រើប្រាស់ គឺពោល ។ បទថា **ទេសេតិ** គឺប្រកាស ។ បទថា **បរំ វាចេតិ** គឺបង្រៀនបុគ្គលដទៃឲ្យរៀន ។ បទថា **អាគតាគមា** សេចក្តីថា ព្រះថេរៈទាំងឡាយ ឈ្មោះថា ជាអ្នកមានអាគម ដែលខ្វនសម្រេចហើយ ព្រោះអត្ថថា ដែលសម្រេចអាគមណាមួយក្នុងបណ្តាអាគមទាំងឡាយ មានទីឃនិកាយជាដើម ។ បទថា **ធម្មធរា** បានដល់ ព្រះថេរៈទាំងឡាយ ដែលទ្រទ្រង់សុត្តន្តបិដក ។ បទថា **វិនយធរា** បានដល់ ព្រះថេរៈទាំងឡាយដែលទ្រទ្រង់វិនយបិដក ។ បទថា **មាតិកាធរា** បានដល់ ព្រះថេរៈទាំងឡាយដែលទ្រទ្រង់បាតិមោក្ខទាំង ២ ។ បទថា **បរិបុច្ឆតិ** បានដល់ សួរដល់ខាងដើម និងខាងចុងនៃអនុសន្ធិ ។ បទថា **បរិបញ្ហតិ** បានដល់ ពិចារណា គឺកំណត់ថា អញនឹងសួរធម៌នេះ និងធម៌នេះ ។

*បទថា* **ឥធំ ភន្តេ កថំ** *សេចក្តីថា ភិក្ខុរមែងសួរថា ខាងដើម និងខាងចុងនៃ អនុសន្ធិនេះ ដូចម្តេច ។ បទថា* **ឥមស្ស ភាសិតស្ស** *សេចក្តីថា ភិក្ខុរមែងសួរថា ភាសិតនេះ មានអត្ថដូចម្តេច ។ បទថា* **អវិវដំ** *បានដល់ ធម៌ដែលមិនទាន់បើកផ្សារ ។ បទថា* **វិវរន្តិ** *បានដល់ ធ្វើឲ្យបើកផ្សារ ។ បទថា* **កង្ខាដ្ឋានិយេសុ** *បានដល់ ក្នុងធម៌ទាំងឡាយដែលជាហេតុនៃសេចក្តីសង្ស័យ ។ ក្នុងបទថា* **កង្ខាដ្ឋានិយេសុ** *នោះ គប្បីជ្រាបអត្ថថា ការសង្ស័យកើតឡើងក្នុងធម៌ណា ធម៌នោះឯង ឈ្មោះថា ជាទីតាំងនៃសេចក្តីសង្ស័យ ។*

**អដ្ឋកថា អានន្ទសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ខត្តិយាភិប្បាយសូត្រទី ១០

*[ ៥២ ] គ្រានោះ ជាណុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកក្សត្រមានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មាន*

អ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកក្សត្រមានភោគៈជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានពួកពលជាទីតាំងមាំ មានប្រឹថពីជាទីប្រកាន់ មានឥស្សរិយៈជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះពួកព្រាហ្មណ៍ មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍ មានភោគៈជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានមន្តជាទីតាំងមាំ មានការបូជាជាទីប្រកាន់ មានព្រហ្មលោកជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះគហបតី មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកគហបតី មានភោគៈជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានសិល្បៈជាទីតាំងមាំ មានការងារជាទីប្រកាន់ មានការងារសម្រេចហើយជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះពួកស្រ្តី មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកស្រ្តីមានប្រុសជាទីប្រាថ្នា មានគ្រឿងអលង្ការជាទីពិចារណា មានបុត្តជាទីតាំងមាំ មិនមានស្រ្តីរួមស្វាមីជាទីប្រកាន់ មានឥស្សរិយៈជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះពួកចោរ មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកចោរមានការលួចយកជាទីប្រាថ្នា មានព្រៃញាតស្បាតជាទីពិចារណា មានគ្រឿងសស្ត្រាជាទីតាំងមាំ មានទី

ផងឹតជាទីប្រកាន់ មានកិរិយាមិនឃើញ គឺការវេះគេចជាទីបំផុត ។ បពិត្រព្រះគោតម ចុះពួកសមណៈ មានអ្វីជាទីប្រាថ្នា មានអ្វីជាទីពិចារណា មានអ្វីជាទីតាំងមាំ មានអ្វីជាទីប្រកាន់ មានអ្វីជាទីបំផុត ។ ម្នាលព្រាហ្មណ៍ ពួកសមណៈមានខន្តិ និងការៈស្មៀមជាទីប្រាថ្នា មានបញ្ញាជាទីពិចារណា មានសីលជាទីតាំងមាំ មានសេចក្តីមិនកង្វល់ជាទីប្រកាន់ មាននិព្វានជាទីបំផុត ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកពេកណាស់ ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវសេចក្តីប្រាថ្នានូវកិរិយាពិចារណា នូវកិរិយាតាំងមាំ នូវសេចក្តីប្រកាន់ នូវទីបំផុត នៃក្សត្រទាំងឡាយផង ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាប ( នូវសេចក្តីប្រាថ្នាជាដើម ) នៃព្រាហ្មណ៍ទាំងឡាយផង ។បេ។ ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាប ( នូវសេចក្តីប្រាថ្នាជាដើម ) នៃគហបតីទាំងឡាយផង ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាប ( នូវសេចក្តីប្រាថ្នាជាដើម ) នៃស្ត្រីទាំងឡាយផង ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាប ( នូវសេចក្តីប្រាថ្នាជាដើម ) នៃចោរទាំងឡាយផង ព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបនូវសេចក្តីប្រាថ្នា នូវកិរិយាពិចារណា នូវកិរិយាតាំងមាំ នូវកិរិយាប្រកាន់ នូវទីបំផុត នៃសមណៈទាំងឡាយផង ។ បពិត្រព្រះគោតមដ៏ចម្រើនច្បាស់លាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈដោយជីវិត ចាប់ដើមអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## ខត្តិយាធិប្បាយសូត្រ

[ ៥២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងខត្តិយាធិប្បាយសូត្រទី ១០ ដូចតទៅនេះ បទថា **ភោគាធិប្បាយា** សេចក្តីថា ក្សត្រទាំងឡាយតាំងព្រះបំណងគឺមានអធ្យាស្រ័យប្រព្រឹត្តទៅដើម្បីប្រមូលភោគៈ ។

បទថា **បញ្ញូបវិចារា** សេចក្តីថា ក្សត្រទាំងឡាយ មានការពិចារណាប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់បញ្ញាយ៉ាងនេះថា សូមយើងទាំងឡាយគប្បីជាអ្នកមានបញ្ញា ។ ការពិចារណានេះឯងនៃក្សត្រទាំងនោះ រមែងត្រាច់ទៅក្នុងចិត្ត ។ បទថា **ពលាធិដ្ឋានា** សេចក្តីថា ក្សត្រទាំងឡាយ មានព្រះវរកាយ ដែលមានកម្លាំងជាទីតាំង ។ សេចក្តីពិត ក្សត្រទាំងនោះបាននូវរាងកាយ ដែលមានកម្លាំងហើយ ឈ្មោះថា បាននូវទីពឹង ។ បទថា **បឋវីអភិនិវេសា** សេចក្តីថា ក្សត្រទាំងឡាយធ្វើការតាំងព្រះហឫទ័យមាំ ដើម្បីជាប្រយោជន៍ដល់ផែនដីយ៉ាងនេះថា អញនឹងជាម្ចាស់នៃផែនដី ។ បទថា **ឥស្សរិយបរិយោសានា** សេចក្តីថា ក្សត្រទាំងឡាយ មានរជ្ជាភិសេកជាទីបំផុត សេចក្តីពិត ក្សត្រទាំងនោះ បានទទួលការអភិសេកហើយ ឈ្មោះថា ដល់ទីបំផុត ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយន័យនេះឯង ។

ចំណែកក្នុងបទដ៏សេស ក្នុងសូត្រនេះ មានអធិប្បាយដូចតទៅនេះថា ដំបូង ព្រាហ្មណ៍ទាំងឡាយបានមន្តហើយ ឈ្មោះថា បានទីពឹង ។ គហបតីទាំងឡាយ បានសិប្បៈណាមួយហើយ ឈ្មោះថា បាននូវទីពឹង ។ ស្រីទាំង-

ឡាយ បានកូនដែលជាម្ចាស់មត៌កក្នុងត្រកូល ឈ្មោះថា បានទីពឹង ។ ចោរទាំងឡាយ បានសស្ត្រាវុធប្រភេទណាមួយហើយ ឈ្មោះថា បានទីពឹង ។ សមណៈទាំងឡាយមានសីលបរិបូណ៌ ឈ្មោះថា បានទីពឹង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់បទទាំងឡាយ មានបទថា **មន្តាធិដ្ឋានា** ជាដើម ។ ម្យ៉ាងទៀត ចិត្តរបស់ព្រាហ្មណ៍ទាំងឡាយ រមែងប្រកាន់មាំថា យើងទាំងឡាយនឹងបូជាយញ្ញ កាលបានចូលដល់ព្រហ្មលោកហើយ ព្រាហ្មណ៍ទាំងឡាយ ឈ្មោះថា ដល់នូវទីបំផុត ព្រោះហេតុនោះ ទើបព្រាហ្មណ៍ទាំងនោះ ព្រះមានព្រះភាគត្រាស់ថា មានយញ្ញជាទីប្រកាន់មាំ មានព្រហ្មលោកជាទីបំផុត ។ គហបតីទាំងឡាយ ឈ្មោះថា មានការងារជាទីប្រកាន់មាំ ព្រោះមានចិត្តប្រកាន់មាំ ដើម្បីធ្វើការងារ កាលការងារស្រេចហើយ គហបតីទាំងឡាយ ឈ្មោះថា ដល់ទីបំផុត ព្រោះហេតុនោះ ទើបគហបតីទាំងឡាយ ឈ្មោះថា មានការងារដែលសម្រេចហើយជាទីបំផុត ។

បទថា **បុរិសាធិប្បាយា** បានដល់ ស្រីទាំងឡាយ មានអធ្យាស្រ័យប្រព្រឹត្តទៅក្នុងបុរសទាំងឡាយ ។ ស្រី ឈ្មោះថា មានចិត្តចង់បានក្នុងគ្រឿងប្រដាប់ ព្រោះមានចិត្តប្រាថ្នាត្រូវការគ្រឿងអលង្ការ ។ ស្រី ឈ្មោះថា មិនមានស្រីរួមប្តីជាទីប្រកាន់មាំ ព្រោះមានចិត្តប្រកាន់មាំយ៉ាងនេះថា សូមឲ្យអាត្មាអញ កុំឲ្យមានស្រីរួមប្តីជាមួយស្រីដទៃ សូមនៅជាធំតែម្នាក់ឯងប៉ុណ្ណោះក្នុងផ្ទះ ស្រី ឈ្មោះថា មានភាពជាធំ ជាទីបំផុត ព្រោះហេតុថា កាលបានភាពជាធំក្នុងការគ្រប់គ្រងផ្ទះ ក៏រាប់ថា ដល់ទីបំផុតហើយ ។

ចោរទាំងឡាយ ឈ្មោះថា មានការឆក់ប្លន់ដែលជាបំណងប្រាថ្នា ព្រោះមានបំណងក្នុងការឆក់ប្លន់យកទ្រព្យរបស់អ្នកដទៃ ។ ចោរទាំងឡាយ ឈ្មោះថា ដាក់ចិត្តក្នុងព្រៃស្តុក ព្រោះមានចិត្តត្រាច់ទៅក្នុងព្រៃស្តុក គឺទីសម្រាប់លាក់ខ្លួន ។ ចោរទាំងឡាយ ឈ្មោះថា មានងងឹតជាទីប្រកាន់ ព្រោះមានចិត្តប្រកាន់មាំក្នុងងងឹត ។ ចោរទាំងឡាយ ឈ្មោះថា មានការមើលមិនឃើញជាទីបំផុត ព្រោះដល់នូវភាវៈដែលមិនមានអ្នកមើលឃើញ ក៏ឈ្មោះថា ដល់ទីបំផុតហើយ ។

សមណៈទាំងឡាយ ឈ្មោះថា មានខន្តិ និងសោរច្ចៈជាទីបំណងប្រាថ្នា ព្រោះមានបំណងប្រាថ្នាក្នុងអធិវាសនខន្តី និងក្នុងសីល ដែលមានការស្អាតជាភាវៈ សមណៈទាំងឡាយ ឈ្មោះថា មិនមានអ្វីជាទីប្រកាន់ ព្រោះមានចិត្តប្រកាន់មាំក្នុងអ្វីតិចតួចមិនមាន គឺក្នុងភាវៈដែលមិនមានការប្រកាន់ ។ សមណៈទាំងឡាយ ឈ្មោះថា មាននិព្វានជាទីបំផុត ព្រោះការសម្រេចនិព្វាន ក៏រាប់ថាដល់ទីបំផុតហើយ ៕

## អដ្ឋកថា ខត្តិយាធិប្បាយសូត្រទី ១០ ចប់

# សុត្តន្តបិដក

## អប្បមាទសូត្រទី ១១

[ ៥៣ ] គ្រានោះ មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ធម៌តែមួយដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ មានដែរឬ ។ ម្នាលព្រាហ្មណ៍ ធម៌តែមួយដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ មានដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះធម៌តែមួយដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ដូចម្តេច ។ ម្នាលព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ ម្នាលព្រាហ្មណ៍ ដូចស្នាមជើងណានីមួយ នៃសត្វទាំងឡាយដែលត្រាច់ទៅលើផែនដី ស្នាមជើងនៃសត្វទាំងអស់នោះ រមែងដល់នូវការប្រជុំចុះ ក្នុងស្នាមជើងនៃដំរី ស្នាមជើងនៃដំរី ប្រាកដជាប្រសើរជាងស្នាម

ជើងនៃសត្វទាំងនោះ ព្រោះស្នាមជើងនៃដំរីនោះធំ យ៉ាងណាមិញ ម្នាល-ព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ដូចបង្កង់ណានីមួយនៃផ្ទះកំពូល បង្កង់ទាំងអស់នោះ ប្រឈមទៅកាន់កំពូល បង្អោនទៅកាន់កំពូល ប្រជុំចុះក្នុងកំពូល កំពូលប្រាកដជាប្រសើរជាងបង្កង់ទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ( អប្បមាទធម៌ ) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចបុគ្គលជាអ្នកប្រូតនូវស្មៅជំណោកទន្សាយ បានប្រូតនូវស្មៅជំណោកទន្សាយ ចាប់យកត្រង់ចុងជដុះរលាស់ហើយបោកនឹងដៃ ឬដើមឈើ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ( អប្បមាទធម៌ ) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចចង្កោមផ្លែស្វាយ ដែលជ្រុះចាកទង ផ្លែស្វាយទាំងឡាយណានីមួយ ដែលជាប់នឹងទង ផ្លែស្វាយទាំងអស់នោះ រមែងប្រព្រឹត្តទៅតាមនូវទងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ( អប្បមាទធម៌ ) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចពួកស្តេចតូចៗ ណានីមួយ ស្តេចទាំងអស់នោះ រមែងប្រព្រឹត្តទៅតាមនូវស្តេចចក្រពត្តិ ស្តេចចក្រពត្តិប្រាកដជាប្រសើរជាងស្តេចទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ ( អប្បមាទ-ធម៌ ) ក៏យ៉ាងនោះដែរ ។បេ។ ម្នាលព្រាហ្មណ៍ ដូចពន្លឺណានីមួយនៃផ្កាយ ពន្លឺនៃផ្កាយទាំងអស់នោះ មិនដល់នូវចំណិតនៃចំណែក ១៦ៗ ដងនៃពន្លឺ

ព្រះចន្ទឡើយ ពន្លឺនៃព្រះចន្ទ ប្រាកដជាប្រសើរជាងពន្លឺនៃផ្កាយទាំងនោះ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ អប្បមាទធម៌ ជាធម៌តែមួយដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ នេះឯងជាធម៌តែមួយ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងបាននូវប្រយោជន៍ទាំង ២ គឺប្រយោជន៍ក្នុងបច្ចុប្បន្ន ១ ប្រយោជន៍ក្នុងបរលោក ១ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់លាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់លាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។

# អដ្ឋកថា

## អប្បមាទសូត្រ

[ ៥៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអប្បមាទសូត្រទី ១១ ដូចតទៅនេះ បទថា **សមធិគ្គយ្ហ** ប្រែថា ប្រកាន់ដោយល្អ ។ បទថា **ជង្គលានំ ចានានំ** បានដល់ សត្វមានជើង ដែលមានប្រក្រតីត្រាច់ទៅលើផែនដី ។ បទថា **បទជាតានិ** បានដល់ ស្នាមជើង ។ បទថា **សមោធានំ គច្ឆន្តិ** បានដល់

ដល់នូវការសង្គ្រោះចូល គឺដាក់ចូល ។ បទថា **អគ្គមក្खायति** បានដល់ដែលសត្វលោកពោលថា ប្រសើរបំផុត ។ បទថា **បព្ពជលាយកោ** បានដល់ អ្នកប្រុតស្បូវក្លាំង ។ បទថា **ឱធុនាតិ** បានដល់ ចាប់ចុងរលាស់ ។ បទថា **និធុនាតិ** បានដល់ គ្រវីទៅទាំងសងខាង ។ បទថា **និច្ឆាទេតិ** បានដល់ ពាក់ត្រង់ដើមដៃ ឬត្រង់ដើមឈើ ។ បទថា **អម្ពបិណ្ឌិយា** បានដល់ចង្កោមផ្លែស្វាយ ។ បទថា **វណ្ដូបនិពន្ធនានិ** បានដល់ ជាប់នៅត្រង់ទង ឬសំយុងនៅត្រង់ទង ។

បទថា **តទន្វយានិ ភវន្តិ** បានដល់ រមែងជ្រុះទៅតាមទង ដោយអត្ថថា រមែងជ្រុះទៅតាមទងរបស់ចង្កោមស្វាយដែលជ្រុះទៅ ។ បទថា **ខុទ្ទរាជានោ** បានដល់ ព្រះរាជាតូច គឺព្រះរាជាធម្មតា ។

## អដ្ឋកថា អប្បមាទសូត្រទី ១១ ចប់

# សុត្តន្តបិដក

## ធម្មិកសូត្រទី ១២

[ ៥៤ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះធម្មិកៈដ៏មានអាយុ ជាចៅអាវាស ក្នុងជាតិភូមិ គឺនៅក្នុងអាវាសទាំង ៧ ក្នុងជាតិភូមិ ។ បានឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតកោសរូសនូវពួកភិក្ខុជាអាគន្តុកៈដោយវាចា ឯអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោត កោសរូស ដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ទំផ្គត់ផ្គង់ភិក្ខុសង្ឃដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ក៏ស្រាប់តែពួកអាគន្តុកភិក្ខុចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាពួកអាគន្តុកភិក្ខុចៀសចេញទៅ មិនឋិតនៅ លះបង់អាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសកមានសេចក្តីត្រិះរិះដូច្នេះថា ច្បាស់ជាព្រះធម្មិកៈដ៏មានអាយុនេះឯង ជេរប្រទេចបៀតបៀន ចាក់ដោតកោសរូសនូវពួកអាគន្តុកៈ ដោយវាចា បានជាអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតកោសរូសដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។ បើដូច្នោះ យើងទាំងឡាយ ត្រូវបណ្តេញព្រះធម្មិកៈដ៏មានអាយុចេញ ។

លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះធម្មិកៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចូរព្រះធម្មិកៈដ៏មានអាយុ ចៀសចេញចាកអាវាសនេះទៅ មិនគួរលោកនៅក្នុងអាវាសនេះទេ ។ វេលានោះ ព្រះធម្មិកៈដ៏មានអាយុ ក៏បានចេញអំពីអាវាសនោះ ទៅកាន់អាវាសដទៃវិញ ។ បានឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតគោសូរូសពួកអាគន្តុកភិក្ខុដោយវាចា ឯពួកអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតគោសូរូសដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោល ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ខំផ្គត់ផ្គង់ភិក្ខុសង្ឃដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ស្រាប់តែពួកអាគន្តុកភិក្ខុ ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាពួកអាគន្តុកភិក្ខុចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។ វេលានោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា ច្បាស់ជាព្រះធម្មិកៈដ៏មានអាយុនេះ ជេរប្រទេចបៀតបៀន ចាក់ដោតគោសូរូសនូវពួកអាគន្តុកភិក្ខុ ដោយវាចា បានជាអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតគោសូរូសដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។

បើដូច្នោះ យើងទាំងឡាយ ត្រូវតែបណ្តេញព្រះធម្មិកៈដ៏មានអាយុចេញ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះធម្មិកៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចូរព្រះធម្មិកៈដ៏មានអាយុ ចៀសចេញចាកអាវាសនេះទៅ លោកមិនគួរនៅក្នុងអាវាសនេះទេ ។ គ្រានោះ ព្រះធម្មិកៈដ៏មានអាយុ ក៏ចេញចាកអាវាសនោះ ទៅកាន់អាវាសដទៃវិញ ។ បានឮថា ក្នុងទីនោះ ព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀន ចាក់ដោតកោសរូសពួកអាគន្តុកភិក្ខុដោយវាចា ឯអាគន្តុកភិក្ខុទាំងនោះ ត្រូវព្រះធម្មិកៈដ៏មានអាយុ ជេរប្រទេចបៀតបៀនចាក់ដោតកោសរូសដោយវាចាហើយ ក៏ចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយ ទំនុកបម្រុងព្រះភិក្ខុសង្ឃ ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ ស្រាប់តែពួកអាគន្តុកភិក្ខុចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាពួកអាគន្តុកភិក្ខុចៀសចេញទៅ មិនឋិតនៅ លះបង់ទីអាវាសចោលអស់ ។ វេលានោះ ពួកជាតិភូមិកឧបាសក មានសេចក្តីត្រិះរិះដូច្នេះថា ។បេ។ បើដូច្នោះ យើងទាំងឡាយ ត្រូវតែបណ្តេញព្រះធម្មិកៈដ៏មានអាយុឲ្យចេញចាកអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ។ លំដាប់នោះ ពួកជាតិភូមិកឧបាសក ចូលទៅរកព្រះធម្មិកដ៏មានអាយុ លុះចូលទៅដល់ហើយ បាន

និយាយនឹងព្រះធម្មិកៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចូរព្រះធម្មិកៈដ៏មានអាយុ ចៀសចេញចាកអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិទៅ ។ គ្រានោះ ព្រះធម្មិកៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញត្រូវពួកជាតិភូមិកបណ្តេញឲ្យចេញចាកអាវាស គ្រប់ទាំង ៧ ក្នុងជាតិភូមិហើយ ឥឡូវនេះ អាត្មាអញនឹងទៅក្នុងទីណាហ្ន៎ ។ លំដាប់នោះ ព្រះធម្មិកៈដ៏មានអាយុ មានសេចក្តីត្រិះរិះ ដូច្នេះថា បើដូច្នោះ គួរតែអាត្មាអញ ចូលទៅរកព្រះដ៏មានព្រះភាគ ។ សម័យនោះ ព្រះធម្មិកៈដ៏មានអាយុ ប្រដាប់បាត្រ និងចីវរដើរសំដៅទៅក្រុងរាជគ្រឹះ ហើយចូលទៅភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ដោយលំដាប់ ដែលព្រះដ៏មានព្រះភាគគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះធម្មិកៈដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគក៏ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ធម្មិកៈ អើ អ្នកមកពីណាហ្នឹង ។ ព្រះធម្មិកៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវពួកជាតិភូមិកឧបាសក បណ្តេញអំពីអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ណ្ហើយ ប្រយោជន៍អ្វីដោយអ្នកឯងនៅក្នុងអាវាសនេះ ។ ពួកជាតិភូមិកឧបាសក បណ្តេញអ្នកឯងអំពីទីនោះៗ អ្នកឯងទាល់តែពួកជាតិភូមិកឧបាសក បណ្តេញអំពីទីនោះៗ ហើយ ទើបបានមកក្នុងសម្នាក់តថាគតវិញ ។

ម្នាលព្រាហ្មណ៍ធម្មិកៈ ពីព្រេងនាយមក មានពួកពាណិជ្ជអ្នកដើរក្នុង

សមុទ្រ ចាប់សត្វស្លាបបង្ហាញត្រើយ ហើយចុះទៅកាន់សមុទ្រដោយសំពៅ ។ ពាណិជ្ជទាំងនោះ កាលបើសំពៅទៅមិនបានឃើញត្រើយ ក៏លែងសត្វស្លាបបង្ហាញត្រើយទៅ ។ សត្វនោះក៏ហើរទៅទិសខាងកើត ហើរទៅទិសខាងលិច ហើរទៅទិសខាងជើង ហើរទៅទិសខាងត្បូង ហើរទៅទិសខាងលើ ហើរទៅទិសតូច បើសត្វនោះឃើញត្រើយដោយជុំវិញហើយ ក៏ហើរបាត់ទៅតែម្តង ។ បើសត្វនោះ មិនបានឃើញត្រើយដោយជុំវិញទេ ក៏ត្រឡប់មកកាន់សំពៅនោះវិញ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ធម្មិកៈ ពួកជាតិភូមិកឧបាសកបណ្តេញអ្នកអំពីទីនោះៗ អ្នកឯងទាល់តែគេបណ្តេញអំពីទីនោះហើយ ទើបបានមកក្នុងសម្នាក់តថាគតវិញ ក៏យ៉ាងនោះដែរ ។

ម្នាលព្រាហ្មណ៍ធម្មិកៈ ពីព្រេងនាយមក មានស្តេចដើមជ្រៃ ឈ្មោះសុប្បតិដ្ឋៈរបស់ព្រះបាទកោរព្យៈមានមែក ៥ មានម្លប់ត្រជាក់ជាទីរីករាយចិត្ត ។

ម្នាលព្រាហ្មណ៍ធម្មិកៈ សុប្បតិដ្ឋនិគ្រោធរាជ មានទំហំ ១២ យោជន៍ មានបណ្តាញឫស ៥ យោជន៍ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ សុប្បតិដ្ឋនិគ្រោធរាជ មានផ្លែធំប៉ុនភាជនៈ សម្រាប់ចម្អិនទូវកត្តចំនួន ១ អាឡ្ហកៈ ផ្លែជ្រៃនោះ មានរសផ្អែមដូចទឹកឃ្មុំ ពុំមានមែក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ព្រះរាជាសោយមែកមួយរបស់សុប្បតិដ្ឋនិគ្រោធរាជ ជាមួយស្រីស្នំ ពួកពល បរិភោគមែកមួយ ពួកអ្នកនិគម ជនបទ បរិភោគមែកមួយ ពួកសមណព្រាហ្មណ៍ បរិភោគមែកមួយ ពួកម្រឹគបក្សីបរិភោគមែកមួយ ម្នាលព្រាហ្មណ៍ធម្មិកៈ មិនមាន

បុគ្គលណា រក្សានូវផ្លែនៃសុប្បតិដ្ឋនិគ្រោធរាជទេ ។ សេចក្ដីតំណាលថា ពួកជនមិនហ៊ានបៀតបៀននូវផ្លែរបស់គ្នានិងគ្នាឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ មានបុរសម្នាក់ ស៊ីផ្លែសុប្បតិដ្ឋនិគ្រោធរាជ ដរាបដល់ឆ្អែត ហើយក៏កាច់យកមែកចៀសចេញទៅ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ វេលានោះ ទេវតាដែលនៅអាស្រ័យលើដើមសុប្បតិដ្ឋិនិគ្រោធរាជ មានសេចក្ដីត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ ហ្ន៎ យីអើ ចម្លែកណាស់ហ្ន៎ កោតតែមនុស្សបាបហ៊ានស៊ីផ្លែសុប្បតិដ្ឋនិគ្រោធរាជដរាបទាល់តែឆ្អែត ហើយកាច់យកមែក ចៀសចេញទៅ បើដូច្នោះ សុប្បតិដ្ឋនិគ្រោធរាជ មិនគួរឲ្យផ្លែតទៅទៀតទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ដើមសុប្បតិដ្ឋនិគ្រោធរាជ ក៏មិនបានឲ្យផ្លែតទៅទៀតឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ ព្រះបាទកោរព្យៈ ចូលទៅរកសក្កទេវានមិន្ទ លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងសក្កទេវានមិន្ទដូច្នេះថា បពិត្រលោកនិរទុក្ខ ដែលគួរគេបូជា លោកគួរជ្រាប ឥឡូវនេះ សុប្បតិដ្ឋ-និគ្រោធរាជ មិនផ្លែទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ លំដាប់នោះ សក្កទេវានមិន្ទបានចាត់ចែងឥទ្ធាភិសង្ខារ គឺការចាត់ចែងដោយឫទ្ធិ មានសភាពដូច្នោះ ឲ្យខ្យល់ និងគ្រាប់ភ្លៀងដ៏មានកម្លាំងបក់បោកមក ឲ្យសុប្បតិដ្ឋនិគ្រោធរាជរលំធ្វើឲ្យមានឫសឡើងលើ ។ ម្នាលព្រាហ្មណ៍ ធម្មិកៈ វេលានោះ ពួកទេវតាដែលអាស្រ័យនៅលើដើមសុប្បតិដ្ឋនិគ្រោធរាជ ក៏ដល់នូវសេចក្ដីទុក្ខ តូចចិត្តមានមុខជោកដោយទឹកភ្នែក ទួញយំ ឈរនៅក្នុងទីសមគួរ ។ ម្នាលព្រាហ្មណ៍

ធម្មិកៈ លំដាប់នោះ សក្កទេវានមិន្ទ ចូលទៅរកទេវតា ដែលនៅលើដើមសុប្បតិដ្ឋនិគ្រោធរាជ លុះចូលទៅដល់ហើយ បាននិយាយនឹងទេវតា ដែលនៅលើដើមសុប្បតិដ្ឋនិគ្រោធរាជថា នែទេវតា អ្នកដល់នូវសេចក្តីទុក្ខ តូចចិត្ត មានមុខជោកដោយទឹកភ្នែក ទួញយំ ឈរនៅក្នុងទីសមគួរ ដោយហេតុដូចម្តេចហ្ន៎ ។ ម្នាលអ្នកនិទ្ទិក្ខ ដ្បិតខ្យល់ និងភ្លៀងខ្លាំង បក់បោកពិកពរបស់ខ្ញុំឲ្យវិលត្រឡប់ ធ្វើឲ្យមានឫសឡើងលើ ។ ម្នាលទេវតា អ្នកឋិតនៅក្នុងរុក្ខធម៌ហើយ ខ្យល់ និងភ្លៀងដ៏ខ្លាំងបក់បោកពិកពឲ្យវិលត្រឡប់ ធ្វើឲ្យមានឫសឡើងលើដែរឬ ។ ម្នាលអ្នកនិទ្ទិក្ខ ចុះដើមឈើឋិតនៅក្នុងរុក្ខធម៌ដូចម្តេច ។ ម្នាលទេវតា ក្នុងលោកនេះ ពួកជនអ្នកត្រូវការដោយឫសឈើ តែងនាំយកឫសទៅ អ្នកត្រូវការដោយសម្បក តែងនាំយកសម្បកទៅ អ្នកត្រូវការដោយស្លឹក តែងនាំយកស្លឹកទៅ អ្នកត្រូវការដោយផ្កា តែងនាំយកផ្កាទៅ អ្នកត្រូវការដោយផ្លែ តែងនាំយកផ្លែទៅ ព្រោះហេតុនោះ ទេវតា មិនត្រូវធ្វើសេចក្តីតូចចិត្តផង នូវសេចក្តីមិនត្រេកអរផងទេ ម្នាលទេវតា យ៉ាងនេះឯងហៅថា ដើមឈើឋិតនៅក្នុងរុក្ខធម៌ ។ ម្នាលអ្នកនិទ្ទិក្ខ ខ្ញុំមិនបានឋិតនៅក្នុងរុក្ខធម៌ហើយ បានជាខ្យល់ និងភ្លៀងដ៏ខ្លាំងបក់បោកពិកពឲ្យវិលត្រឡប់ ធ្វើឲ្យមានឫសឡើងលើ ។ ម្នាលទេវតា ប្រសិនបើអ្នកគប្បីឋិតនៅក្នុងរុក្ខធម៌ហើយ ទើបពិកពរបស់អ្នកនឹងមានដូចកាលមុន ។ ម្នាលអ្នកនិទ្ទិក្ខ ខ្ញុំគប្បីឋិតនៅក្នុងរុក្ខធម៌ សូមឲ្យពិកពរបស់ខ្ញុំកើតឡើងដូចកាលមុខ ។ ម្នាលព្រាហ្មណ៍

ធម្មិកៈ វេលានោះសក្កទេវានមិន្ទ ក៏បានចាត់ចែងនូវឥន្ទាភិសង្ខារ មានសភាព ដូច្នោះ ឲ្យខ្យល់ និងភ្លៀងដ៏ខ្លាំងបក់បោកមក ធ្វើឲ្យសុប្បតិដ្ឋនិគ្រោធរាជដុះឡើង មានឫសពេញដូចដែលវិញ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ អើ ពួកជាតិភូមិកឧបាសក បានបណ្តេញអ្នកឯង ដែលឋិតនៅក្នុងសមណធម៌ ឲ្យចេញចាកអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសមណៈ ឋិតនៅក្នុងសមណធម៌ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ធម្មិកៈ សមណៈក្នុង សាសនានេះ មិនជេរតបបុគ្គលដែលជេរខ្លួន មិនកោសរូសតបបុគ្គលដែល កោសរូសខ្លួន មិនឈ្លោះតបបុគ្គលដែលឈ្លោះនឹងខ្លួនទេ ម្នាលព្រាហ្មណ៍ ធម្មិកៈ យ៉ាងនេះ ឈ្មោះថា សមណៈឋិតនៅក្នុងសមណធម៌ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ពួកជាតិភូមិកឧបាសក បណ្តេញខ្ញុំព្រះអង្គដែលមិនបានឋិត នៅក្នុងសមណធម៌ អំពីអាវាសគ្រប់ទាំង ៧ ក្នុងជាតិភូមិ ។

ម្នាលព្រាហ្មណ៍ធម្មិកៈ ពីព្រេងនាយមក មានគ្រូឈ្មោះសុនេត្តៈ អ្នកធ្វើ នូវកំពង់ជាទីចូង គឺលទ្ធិ ប្រាសចាកសេចក្តីត្រេកត្រអាល ក្នុងកាមទាំងឡាយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ គ្រូសុនេត្តមានសាវកច្រើនរយ ។ គ្រូសុនេត្តបានសម្តែង ធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ដល់ពួកសាវក ។ ម្នាលព្រាហ្មណ៍ ធម្មិកៈ បើពួកជនណា មិនញុំាំងចិត្តឲ្យជ្រះថ្លាដល់គ្រូសុនេត្តៈ កំពុងសម្តែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកទេ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលព្រាហ្មណ៍ធម្មិកៈ

ពួកជនណា ញុំាំងចិត្តឲ្យជ្រះថ្លាដល់គ្រូសុនេត្ត: ដែលកំពុងសម្តែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ។ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ នឹងបានទៅកើតក្នុងសុគតិសួគ៌ទេវលោក ។

ម្នាលព្រាហ្មណ៍ធម្មិក: ពីព្រេងនាយមក មានគ្រូឈ្មោះមូគបក្ខ: ។បេ។ មានគ្រូឈ្មោះអរនេមិ មានគ្រូឈ្មោះកុទ្ទាលក: មានគ្រូឈ្មោះហត្ថិបាល: ។បេ។ មានគ្រូឈ្មោះជោតិបាល ជាអ្នកធ្វើនូវកំពង់ជាទីឆ្លង គឺលទ្ធិ ប្រាសចាកសេចក្តីត្រេកត្រអាលក្នុងកាមទាំងឡាយ ។ ម្នាលព្រាហ្មណ៍ធម្មិក: ឯគ្រូឈ្មោះជោតិ-បាល មានសាវកច្រើនរយ ។ គ្រូជោតិបាល សម្តែងធម៌ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោក ដល់ពួកសាវក ។ ម្នាលព្រាហ្មណ៍ធម្មិក: ពួកជនណា មិនបានញុំាំងចិត្តឲ្យជ្រះថ្លា ដល់គ្រូជោតិបាល ដែលកំពុងសម្តែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកទេ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលព្រាហ្មណ៍ ធម្មិក: ពួកជនណា ញុំាំងចិត្តឲ្យជ្រះថ្លាដល់គ្រូជោតិបាល ដែលកំពុងសម្តែងធម៌ ដើម្បីប្រព្រឹត្តទៅកាន់ព្រហ្មលោកហើយ លុះជនទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ នឹងកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលព្រាហ្មណ៍ធម្មិក: អ្នកសម្គាល់នូវហេតុនោះដូចម្តេច បុគ្គលណាមានចិត្តប្រទូស្ត ជេរប្រទេចគ្រូទាំង ៦ នេះ ដែលជាអ្នកធ្វើនូវកំពង់ជាទីឆ្លង គឺលទ្ធិប្រាសចាកសេចក្តីត្រេកត្រអាល ក្នុងកាមទាំងឡាយ មានពួកសាវកច្រើនរយ ជាបរិវារហើយ បុគ្គលនោះ គប្បី

បាននូវបាបដ៏ច្រើនដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលព្រាហ្មណ៍ ធម្មិកៈ បុគ្គលណា មានចិត្តប្រទូស្តជេរប្រទេចគ្រូទាំង ៦ នេះ ដែលជាអ្នកធ្វើនូវកំពង់ជាទីចូង ប្រាសចាកសេចក្ដីត្រេកត្រអាលក្នុងកាមទាំងឡាយ មានពួកសាវកច្រើនរយជាបរិវារ បុគ្គលនោះ គប្បីបាននូវបាបដ៏ច្រើន ។ បុគ្គលណា មានចិត្តប្រទូស្តជេរប្រទេចបុគ្គលម្នាក់ ដែលបរិបូណ៌ដោយទិដ្ឋិ បុគ្គលនេះរមែងបាននូវបាបដ៏ច្រើនជាងបុគ្គលទាំងនោះ ។ រឿងនោះ ព្រោះហេតុអ្វី ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ( ព្រោះ ) តថាគតមិនសម្ដែងនូវការជីករម្លើងនូវគុណមានសភាពដូច្នេះ ខាងក្រៅអំពីសាសនានេះ ដូចជាការជេរប្រទេចនេះ ក្នុងសព្រហ្មចារីបុគ្គលទាំងឡាយទេ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តដែលប្រទូស្តក្នុងពួកសព្រហ្មចារីបុគ្គលរបស់ខ្លួន នឹងមិនមានដល់យើងឡើយ ។ ម្នាលព្រាហ្មណ៍ធម្មិកៈ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

ក្នុងកាលកន្លងទៅហើយ មានគ្រូទាំង ៦ គឺគ្រូឈ្មោះសុនេត្តៈ ១ ឈ្មោះមូគបក្ខៈ ១ ឈ្មោះអរនេមិ ១ ព្រាហ្មណ៍ឈ្មោះកុទ្ទាលកៈ ១ មាណពឈ្មោះហត្ថិបាលៈ ១ គោវិន្ទគ្រាម ឈ្មោះជោតិបាល ជាបុរោហិតនៃស្ដេចទាំងប្រាំពីរ ១ ជាអ្នកមិនបៀតបៀន ( អ្នកដទៃ ) ជាអ្នកមានយស មិនមានក្លិនខ្ទះខ្ទប គឺក្រោធ មានចិត្តចុះក្នុងសេចក្ដីករុណា កន្លងបង់នូវកាមសំយោជនៈ លះបង់នូវកាមរាគៈ ជាអ្នកចូលទៅកាន់ព្រហ្មលោក ។ ពួកសាវកជាច្រើនរយរបស់គ្រូ

ទាំងនោះ ក៏មិនមានក្ដៅក្រហាយ គឺមានចិត្តឈឺ មានចិត្តឈឺស្រាំរ មានចិត្តឈឺជាប់ មានចិត្តឈឺជាប់ មានចិត្តឈឺចុះ ក្នុងសេចក្ដីករុណា កន្លង

បង់នូវកាមសញ្ញាជនៈ លះបង់នូវកាមរាគៈ ចូលទៅកាន់ព្រហ្មលោកដែរ ។

ជនណាមានចិត្តត្រិះរិះ ដើម្បីប្រទូស្ត ជេរ ប្រទេចពួកឥសីជាខាងក្រៅទាំងនោះ

ដែលប្រាសចាកតម្រេក មានចិត្តតាំងខ្ជាប់ ជនបែបនោះ រមែងបាននូវបាប

ច្រើន ។ មួយទៀត ជនណាមានចិត្តត្រិះរិះ ដើម្បីប្រទូស្ត ជេរ ប្រទេច ភិក្ខុ

១ រូប ដែលបរិបូណ៌ដោយទិដ្ឋិ ជាសាវករបស់ព្រះពុទ្ធ ជននេះ រមែងបាន

នូវបាបច្រើន ជាងជនដែលប្រទូស្តគ្រូទាំង ៦ នោះ ។ ទាំងមិនបានជួបនូវ

បុគ្គលមានសភាពល្អ ជាអ្នកលះបង់នូវហេតុជាទីតាំងនៃទិដ្ឋិ ។ បុគ្គលណា

មានឥន្ទ្រិយទាំង ៥ ដ៏ទន់ គឺសទ្ធា ១ សតិ ១ វិរិយៈ ១ សមថៈ ១

វិបស្សនា ១ បុគ្គលនុ៎ះជាគម្រប់ ៧ របស់អរិយសង្ឃ ហៅថា មិនទាន់

ប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ បុគ្គលនោះ ប្រទូស្តនូវភិក្ខុបែបនោះ

ឈ្មោះថា បៀតបៀននូវខ្លួនមុន លុះបៀតបៀនខ្លួនហើយ ទើបបៀតបៀន

បុគ្គលដទៃជាខាងក្រោយ ។ បុគ្គលណា រក្សាខ្លួន បុគ្គលនោះ ឈ្មោះថា

រក្សាហេតុខាងក្រៅ ព្រោះហេតុនោះ បណ្ឌិតដែលមិនមានសេចក្ដីក្រោធ គប្បី

រក្សាខ្លួនទុកសព្វៗ កាល ។

**ធម្មិកវគ្គទី ៥ ចប់**

## ឧទ្ទាននៃធម្មិកវគ្គនោះ គឺ

និយាយអំពីនាគ ១ អំពីឧបាសិកាឈ្មោះមិគសាលា ១ អំពីបំណុល ១ អំពីមហាចុន្ទដ៏មានអាយុ ១ អំពីសន្ទិដ្ឋិកធម៌ ២ លើក អំពីព្រះខេមៈ ១ អំពីឥន្ទ្រិយ ១ អំពីព្រះអានន្ទ ១ អំពីពួកក្សត្រ ១ អំពីអប្បមាទធម៌ ១ អំពីធម្មិកត្ថេរ ១

បឋមបណ្ណាសក ចប់

# អដ្ឋកថា

## ធម្មិកសូត្រ

[ ៥៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មិកសូត្រទី ១២ ដូចតទៅនេះ បទថា **សព្វសោ** កែជា **សព្វេសុ** ប្រែថា ទាំងពួង ។ បទថា **សត្តសុ អាវាសេសុ** បានដល់ ក្នុងបរិវេណ ៧ កន្លែង ។ បទថា **បរិភាសតិ** បានដល់ សង្កត់សង្កិន គឺញុំាងឲ្យកើតការខ្លាច ។ បទថា **វិហឹសតិ** ប្រែថា បៀតបៀន ។ បទថា **វិតុទតិ** ប្រែថា ចាក់ទម្លុះ ។ បទថា **រោសេតិ** គឺទ្រគោះបោះបោក ដោយវាចា ។ បទថា **បក្កមន្តិ** គឺចៀសទៅកាន់ទិសទាំងឡាយ ។ បទថា **ន សណ្ឋហន្តិ** គឺមិនតាំងនៅ ។ បទថា **វិព្ភន្តិ** គឺចោល បានដល់ លះបង់ ។ បទថា **បព្វាជេយ្យាម** គឺគប្បីនាំចេញ ។ សព្ទថា **ហន្ទ** ជានិបាត ប្រើក្នុងអត្ថថា លះបង់ ។ បទថា **អលំ** មានអត្ថថា ការដែលឧបាសកទាំងឡាយ

គប្បីដេញព្រះធម្មិកៈនោះចេញទៅ ជាការសមគួរ ។

បទថា **តីរទស្សឹ សកុណំ** បានដល់ ក្អែកប្រាប់ទិស ។ បទថា **មុញ្ចន្តិ** បានដល់ ឈ្មួញទាំងឡាយដែលធ្វើដំណើរតាមសមុទ្រ លែងក្អែកទៅ ដើម្បីមើលទិស ។ បទថា **សាមន្តា** បានដល់ ក្នុងទីមិនឆ្ងាយ ។ បាឋៈថា **សមន្តា** ដូច្នេះក៏មាន ប្រែថា ដោយជុំវិញ ។ បទថា **អភិនិវេសោ** បានដល់ ការឈប់របស់មែកឈើដែលផ្សាយចេញទៅគ្របដណ្តប់ ។ បទថា **មូលសន្តានកានំ** បានដល់ ការឈប់របស់ឫសឈើ ។ បទថា **អាឡ្ហកថាលិកា** ឆ្នាំងដាំបាយដាក់អង្ករបានមួយអាឡ្ហកៈ ។ បទថា **ខុទ្ទមធុំ** បានដល់ ទឹកឃ្មុំ ជាប់បន្ទងដែលពួកឃ្មុំផ្អិតធ្វើ ។ បទថា **អនេលកំ** បានដល់ មិនមានទោស ។

បទថា **ន ច សុធំ អញ្ញមញ្ញស្ស ផលានិ ហឹសន្តិ** សេចក្តីថា ផ្លែឈើទាំងឡាយ រមែងមិនបៀតបៀនចំណែកនៃគ្នានិងគ្នា ឈ្មោះថា ដើមឈើដែលនឹងយកចំណែករបស់វាកាត់ឫស សម្បក ឬស្លឹករបស់ដើមដទៃ មិនមាន ។ មនុស្សទាំងឡាយ មានព្រះរាជាជាដើម នឹងបរិភោគចំពោះតែផ្លែដែលជ្រុះទៅខាងក្រោមមែករបស់ដើមឈើនោះៗ ប៉ុណ្ណោះ ។ សូម្បីផ្លែដែលជ្រុះចាកចំណែករបស់ដើមមួយ ទៅធ្លាក់ក្រោមចំណែកដើមឈើមួយ មនុស្សទាំងឡាយ មានព្រះរាជាជាដើម លុះដឹងថា មិនមែនផ្លែអំពីមែកឈើអញ ក៏មិនព្រមបរិភោគ ។

បទថា **យាវតត្ថំ ភក្ខិត្វា** បានដល់ ទំពាស៊ីដោយប្រមាណត្រឹម-ក ។ បទថា **សាខំ ភញ្ជិត្វា** សេចក្តីថា បុរសម្នាក់កាច់ស្លឹកឈើទំហំប៉ុនឆត្រ បាំង

ឲ្យកើតជាម្ជប់ ដើរចៀសចេញទៅ ។ បទថា **យត្រ ហិ ឆាម** បានដល់ **យោ ហិ ឆាម** ប្រែថា បុរសម្នាក់ ។ បទថា **បក្កមិស្សតិ** គឺចៀសចេញទៅហើយ ។ បទថា **ឆាធាសិ** សេចក្ដីថា ស្ដេចឈើឈ្មោះនិគ្រោធក៏មិនបានចេញផ្លែទៀត ដោយអានុភាពរបស់ទេវតា ។ ព្រោះថា ទេវតានោះបានអធិដ្ឋានយ៉ាងនេះ ។

បទថា **តេនុបសង្កមិ** សេចក្ដីថា កាលអ្នកជនបទទៅក្រាបទូលថា បពិត្រមហារាជ ដើមឈើមិនចេញផ្លែឡើយ ជាកំហុសរបស់ពួកទូលបង្គំ ឬរបស់ព្រះអង្គ ។ ព្រះបាទកោរព្យរាជទ្រង់ត្រិះរិះថា មិនមែនកំហុសរបស់ខ្ញុំ មិនមែនកំហុសរបស់អ្នកជនបទ អធម៌ រមែងមិនប្រព្រឹត្តទៅក្នុងដែនរបស់ខ្ញុំ ដើមឈើ មិនចេញផ្លែ ព្រោះហេតុអ្វីហ្ន៎ ខ្ញុំនឹងចូលទៅសួរសក្កទេវរាជ ដូច្នេះហើយ ក៏ចូលទៅគាល់សក្កទេវរាជដល់ស្ថានតាវត្តិង្ស ។ បទថា **បវត្តេសិ** ប្រែថា ធ្វើឲ្យត្រឡប់ ។ បទថា **ឧម្មូលមកាសិ** បានដល់ ធ្វើនិគ្រោធរាជព្រឹក្សឲ្យមានឫសឡើងខាងលើ ។ បទថា **អបិ នុ ត្វំ** ប៉ុនគ្នានឹង **អបិ នុ តវ**។ បទថា **អដ្ឋិតាយេវ** គឺ **អដ្ឋិតាយឯវ** ប្រែថា តាំងនៅមិនបាន ។ បទថា **សច្ឆវីនិ** បានដល់ ឫសឈើត្រឡប់មានពណ៌ដូចដើម គឺតាំងនៅតាមប្រក្រតី ។ បទថា **ន បច្ចក្កោសតិ** គឺមិនជេរតប ។ បទថា **រោសន្តំ** បានដល់ បុគ្គលដែលប៉ះខ្ញប់ ។ បទថា **ភណ្ឌន្តំ** បានដល់ បុគ្គលដែលប្រហារ ។ បទថា **សុនេត្តោ** សេចក្ដីថា ភ្នែក ហៅថា **នេត្ត** ព្រោះភ្នែកទាំងគូស្អាតល្អ ទើប

គ្រូនោះឈ្មោះថា **សុនេត្ត** ។ បទថា **តិត្ថករោ** បានដល់ អ្នកធ្វើកំពង់ គឺលទ្ធិជាទីឈមចុះកាន់សុគតិ ។ បទថា **វីតរាគោ** បានដល់ ប្រាសចាករាគៈដោយអំណាចការសង្កត់សង្កិន ។ បទថា **បសវតិ** បានដល់ រមែងបាន ។ បទថា **ទិដ្ឋិសម្បន្នំ** បានដល់ បុគ្គលសម្បូរដោយទស្សនៈ អធិប្បាយថា គឺព្រះសោតាបន្ន ។ បទថា **ខន្តិំ** បានដល់ ការជីកនូវគុម្ពរបស់ខ្លួន ។ បទថា **យថា មំ សព្រហ្មចារីសុ** សេចក្តីថា ទេវតា និងការបរិភាសក្នុងសព្រហ្មចារីនេះ យ៉ាងណា ខ្ញុំមិនពោលនូវការជីកគុណបែបនេះថាជាដទៃ អំពីការជេរនិងបរិភាសនោះឡើយ ។

មនុស្សរបស់ខ្លួនហៅថា **អាមជន** ក្នុងបទថា **ន នោ អាមសព្រហ្មចារីសុ** នេះ ព្រោះដូច្នោះ ក្នុងទីនេះ ទើបមានអត្ថដូច្នេះថា យើងទាំងឡាយមិនមានចិត្តប្រទូស្តក្នុងសព្រហ្មចារីដែលស្មើគ្នារបស់ខ្លួន ។

បទថា **ជោតិបាលោ ច គោវិន្ទោ** សេចក្តីថា គ្រូនោះ ពោលដោយឈ្មោះ មានឈ្មោះថា ជោតិបាល ពោលដោយតំណែង មានឈ្មោះថា មហាគោវិន្ទ ។

បទថា **សត្តបុរោហិតោ** សេចក្តីថា ជាបុរោហិតរបស់ព្រះរាជា ៧ អង្គ មានព្រះបាទរេណុជាដើម ។ បទថា **អភិសេកា អតីតំសេ** សេចក្តីថា គ្រូទាំង ៦ នេះ មានគ្រូឈ្មោះមូគបក្ខៈជាដើម បានទទួលការអភិសេកមកហើយ ក្នុងចំណែកដែលជាអតីត ។

បទថា **និរាមគន្ធា** បានដល់ មិនមានក្លិនឆ្អាប ដោយក្លិនឆ្អាប គឺសេចក្ដីក្រោធជាដើម ។ បទថា **ករុណេ វិមុត្តា** សេចក្ដីថា រួចផុតហើយព្រោះករុណាឈាន គឺតាំងនៅក្នុងករុណា និងក្នុងធម៌ដែលជាចំណែកខាងដើមនៃករុណា ។ បទថា **យេ តេ** កែជា **យេតេ** ។ ម្យ៉ាងទៀត បាឋៈជា **យេតេ** ដូច្នេះក៏មាន ។ បទថា **ន សាធុរូបំ អាសិទេ** គឺមិនគប្បីប្រកបទាំងសការៈដែលល្អ ។ បទថា **ទិដ្ឋិដ្ឋានប្បហាយិនំ** គឺដែលមានប្រក្រតីលះទិដ្ឋិ ៦២ ។

បទថា **សត្តមោ** បានដល់ ជាបុគ្គលទី ៧ រាប់តាំងអំពីព្រះអរហន្តចុះមក ។ បទថា **អវីតរាគោ** គឺមិនប្រាសចាករាគៈ ។

លោកបដិសេធភាពជាអនាគាមី ដោយបទថា **អវីតរាគោ** នោះ ។ បទថា **បញ្ចិន្ទ្រិយា មុទូ** សេចក្ដីថា ឥន្ទ្រិយក្នុងវិបស្សនា ៥ ទន់ខ្ចី ។ ពិតហើយ ឥន្ទ្រិយទាំងនោះនៃព្រះសោតាបន្ននោះ ប្រៀបធៀបនឹងព្រះសកទាគាមីហើយ រាប់ថា ទន់ខ្ចី ។

បទថា **វិបស្សនា** បានដល់ ញាណជាគ្រឿងកំណត់សង្ខារ ។ បទថា **បុព្វេវ ឧបហញ្ញតិ** បានដល់ ពាល់ត្រូវមុននោះឯង ។ បទថា **អក្កោសោ** បានដល់ មិនត្រូវគាស់រម្លើង គឺមិនត្រូវទ្រគោះបោះបោកដោយការជីកគុណ ។ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ។៚

**អដ្ឋកថា ធម្មិកសូត្រទី ១២ ចប់**

**ធម្មិកវគ្គទី ៥ ចប់**

**បឋមបណ្ណាសក ចប់**

# សុត្តន្តបិដក
# ទុតិយបណ្ណាសក

## មហាវគ្គ
### សោណសូត្រទី ១

[ ៥៥ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសោណៈដ៏មានអាយុ គង់នៅនាព្រៃស្មសាន ឈ្មោះសីតវ័ន ជិតក្រុងរាជគ្រឹះដែរ ។

លំដាប់នោះ ព្រះសោណៈដ៏មានអាយុ សម្ងំនៅក្នុងទីស្ងាត់ មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាមួយ ជាសាវ័ករបស់ព្រះដ៏មានព្រះភាគ ជាអ្នកមានព្យាយាមតឹងតែង បណ្តាភិក្ខុទាំងនោះ អញក៏រាប់ថាជាសាវ័កដែលមានព្យាយាម តឹងតែងមួយដែរ តែបើទុកជាដូច្នោះ ចិត្តរបស់អញក៏មិនរួចស្រឡះចាកកងអាសវៈ ព្រោះមិនប្រកាន់មាំបានឡើយ ឈ្មោះភោគសម្បត្តិក្នុងត្រកូលរបស់អញ ក៏មានគ្រប់គ្រាន់ អញក៏អាចប្រើប្រាស់ភោគសម្បត្តិ និងធ្វើនូវបុណ្យទាំងឡាយបានដែរ បើដូច្នោះ គួរតែអញលានូវសិក្ខា វិលត្រឡប់មកកាន់ហីនភេទ ប្រើប្រាស់នូវភោគសម្បត្តិ និងធ្វើបុណ្យទាំងឡាយវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានជ្រាបច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះសោណៈដ៏មានអាយុ ដោយព្រះហឫទ័យព្រះអង្គ ក៏

ស្រាប់តែបាត់អំពីភ្នំគិជ្ឈកូដ មកប្រតិស្ឋាន ក្នុងទីចំពោះមុខនៃព្រះសោណៈដ៏មានអាយុ នាព្រៃសីតវ័ន ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់លើពុទ្ធាសនៈដែលគេក្រាលថ្វាយ ។ ឯព្រះសោណៈដ៏មានអាយុ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះសោណៈដ៏មានអាយុគង់នៅក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ក៏ត្រាស់សួរយ៉ាងនេះថា នែសោណៈ ក្រែងអ្នកសម្ងំនៅក្នុងទីស្ងាត់ មានសេចក្ដីត្រិះរិះក្នុងចិត្តកើតឡើងយ៉ាងនេះថា ពួកភិក្ខុណាមួយជាសាវ័ក របស់ព្រះដ៏មានព្រះភាគ ជាអ្នកមានព្យាយាមតឹងតែង បណ្ដាភិក្ខុទាំងនោះ អញក៏រាប់ថា ជាសាវ័កដែលមានព្យាយាមតឹងតែងមួយដែរ តែបើទុកជាដូច្នោះ ចិត្តរបស់អញក៏មិនរួចស្រឡះចាកកងអាសវៈ ព្រោះមិនប្រកាន់មាំបានឡើយ ណ្ហើយ ភោគសម្បត្តិក្នុងត្រកូលរបស់អញ ក៏មានគ្រប់គ្រាន់ អញក៏អាចប្រើប្រាស់ភោគសម្បត្តិផង ធ្វើបុណ្យទាំងឡាយបានផង បើដូច្នោះ គួរតែអញលានូវសិក្ខាវិលត្រឡប់មកកាន់ហីនភេទវិញ ហើយគប្បីប្រើប្រាស់នូវភោគសម្បត្តិផង ធ្វើនូវបុណ្យទាំង-ឡាយផង ដូច្នេះមែនឬ ។ ព្រះសោណៈដ៏មានអាយុ ក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរថា នែសោណៈ អ្នកយល់នូវសេចក្ដីនោះថា ដូចម្ដេច ខ្លួនអ្នកកាលនៅជាគ្រហស្ថអំពីដើម ជាអ្នកឈ្លាសវៃក្នុងការដេញខ្សែពិណដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលសោណៈ

អ្នកយល់នូវសេចក្តីនោះថា ដូចម្តេច សម័យណា ខ្សែពិណរបស់អ្នកតឹងពេក សម័យនោះ តើពិណរបស់អ្នក មានសំឡេងពីរោះ ឬគួរដល់ការដេញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលសោណៈ អ្នកយល់នូវសេចក្តីនោះថាដូចម្តេច សម័យណា ខ្សែពិណរបស់អ្នកធូរពេក សម័យនោះ តើពិណរបស់អ្នកមានសំឡេងពីរោះឬ គួរដល់ការដេញដែរឬ ។ មិនដូច្នោះទេ ព្រះអង្គ ។ ម្នាលសោណៈ មួយទៀត សម័យណា ខ្សែពិណរបស់អ្នក មិនតឹងពេក មិនធូរពេកទេ តាំងនៅក្នុងគុណដ៏ស្មើល្មម គឺសំឡេងជាកណ្តាល សម័យនោះ តើពិណរបស់អ្នកមានសំឡេងពីរោះឬ គួរដល់ការដេញដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលសោណៈ ព្យាយាមដែលតឹងពេក រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីអណ្តែតអណ្តូងចិត្ត ព្យាយាមដែលធូរពេក រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស ក៏យ៉ាងនោះដែរ ម្នាលសោណៈ ព្រោះហេតុនោះ អ្នកចូរតាំងសេចក្តីព្យាយាមឲ្យស្មើល្មមផង ចូរតាំងនូវឥន្ទ្រិយទាំងឡាយ ( មានសទ្ធិន្ទ្រិយជាដើម ) ឲ្យស្មើគ្នាផង ចូរកាន់យកនូវនិមិត្ត ក្នុងសេចក្តីព្យាយាមនិងឥន្ទ្រិយដែលស្មើល្មមនោះផង ។ ព្រះសោណៈដ៏មានអាយុ បានទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លុះព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានព្រះសោណៈដ៏មានអាយុ ដោយឱវាទនេះហើយ ក៏ស្រាប់តែបាត់អំពីព្រៃសីតវ័ន ទៅប្រាកដលើភ្នំគិជ្ឈកូដ ដូចជាបុរសដ៏មានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ គ្រាសម័យជាខាង

ក្រោយមក ព្រះសោណៈដ៏មានអាយុ ក៏បានតាំងនូវសេចក្តីព្យាយាម ឲ្យស្មើល្មមផង តាំងនូវឥន្ទ្រិយទាំងឡាយឲ្យស្មើគ្នាផង បានកាន់យកនូវនិមិត្ត ក្នុងសេចក្តីព្យាយាម និងឥន្ទ្រិយដែលស្មើល្មមនោះផង ។ លំដាប់នោះ ព្រះសោណៈដ៏មានអាយុ គេចចេញចាកពួកទៅនៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតបំផ្លាញ ( នូវកិលេស ) មានចិត្តស្ទុងទៅ ( កាន់ព្រះនិព្វាន ) ពួកកុលបុត្តដែលចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរ-ធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯងក្នុងបច្ចុប្បន្ននេះ ហើយបានដឹងច្បាស់ថា ជាតិ ( របស់អញ ) អស់ហើយ ព្រហ្មចរិយធម៌ អញបានប្រព្រឹត្តចប់ហើយ សោឡសកិច្ច អញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ មានសេចក្តីសរសើរថា បណ្តាពួកព្រះអរហន្តទាំងឡាយ ព្រះសោណៈដ៏មានអាយុ រាប់ថាជាអរហន្ត ១ ដែរ ។ លំដាប់នោះ ព្រះសោណៈដ៏មានអាយុកាលបានសម្រេចព្រះអរហត្តហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះគួរតែអញចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ គួរក្រាបទូលនូវអរហត្តគុណ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រះសោណៈដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះ

សោណៈដ៏មានអាយុ គង់ក្នុងទីដ៏សមគួរស៊ប់ហើយ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណា ជាអរហន្ត-ខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បានដាក់ភារៈចុះហើយ មានប្រយោជន៍នៃខ្លួនសម្រេចហើយ មានកិលេសជាគ្រឿងប្រកបក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ ជាអ្នកមានចិត្តចុះស៊ប់កាន់ឋានៈ ៦ យ៉ាង គឺមានចិត្តចុះស៊ប់ក្នុងនេក្ខម្មៈ ( ការចេញចាកកាម ) ១ ចុះស៊ប់ក្នុងបវិវេក ( ទីស្ងប់ស្ងាត់ចាកកិលេស ) ១ ចុះស៊ប់ក្នុងសេចក្តីមិនមានព្យាបាទ ១ ចុះស៊ប់ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ១ ចុះស៊ប់ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ១ ចុះស៊ប់ក្នុងធម៌មិនមានសេចក្តីវង្វេង ១ ។ បពិត្រព្រះអង្គដ៏ចម្រើន លោកខ្លះក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ មានចិត្តចុះស៊ប់ក្នុងនេក្ខម្មៈ ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមតែសទ្ធាម្យ៉ាងដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ បុគ្គលមិនត្រូវយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បើទុកជាមិនបានពិចារណានូវសោឡសកិច្ចរបស់ខ្លួន ឬការសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏គង់មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់

មានចិត្តចុះស៊ប់ ក្នុងនេក្ខម្មៈ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បពិត្រព្រះអង្គដ៏ចម្រើន លោកខ្លះ ក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ កាលប្រាថ្នាលាភសក្ការៈ និងសេចក្តីសរសើរក៏ដោយ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ បុគ្គលមិនត្រូវយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បើទុកជាមិនបានពិចារណានូវសោឡសកិច្ចរបស់ខ្លួន ឬនូវការសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងសេចក្តីស្ងប់ស្ងាត់ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បពិត្រព្រះអង្គដ៏ចម្រើន លោកខ្លះ ក្នុងសាសនានេះ មានសេចក្តីត្រិះរិះយ៉ាងនេះថា លោកនេះ ការត្រឡប់មកកាន់សីលព្វតបរាមាសៈ ថាជាធម៌មានខ្លឹមក៏ដោយ ក៏គង់ជាអ្នកមានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ បុគ្គលមិនត្រូវយល់ឃើញយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានប្រព្រឹត្តព្រហ្មចរិធម៌ចប់ហើយ បានធ្វើសោឡសកិច្ចស្រេចហើយ បើទុកជាមិនបានពិចារណា នូវសោឡសកិច្ចរបស់ខ្លួន ឬនូវការសន្សំរបស់ខ្លួនដែលបានធ្វើហើយទេ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិន

ព្យាបាទ ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិនព្យាបាទ ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។បេ។ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃតណ្ហា ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងធម៌ជាទីអស់ទៅនៃឧបាទាន ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់រាគៈ ព្រោះប្រាសចាករាគៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់ទោសៈ ព្រោះប្រាសចាកទោសៈ ក៏គង់មានចិត្តចុះស៊ប់ ក្នុងការមិនវង្វេង ព្រោះអស់មោហៈ ព្រោះប្រាសចាកមោហៈ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើភិក្ខុមានចិត្តផុតស្រឡះដោយប្រពៃ យ៉ាងនេះហើយ ទោះបីរូបារម្មណ៍យ៉ាងពន្លឹកដែលគប្បីដឹងដោយភ្នែក មកកាន់វង្វង់នៃចក្ខុទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងធឹង ដល់នូវការមិនរំភើប ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង

និងរលត់ទៅនៃចិត្តនោះ ។ ទោះបីសទ្ទារម្មណ៍ យ៉ាងពន្លឹកដែលគប្បីដឹងដោយត្រចៀក ។បេ។ គន្ធារម្មណ៍ ដែលគប្បីដឹងដោយច្រមុះ រសារម្មណ៍ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វារម្មណ៍ ដែលគប្បីដឹងដោយកាយ ធម្មារម្មណ៍ដែលគប្បីដឹងដោយចិត្ត មកកាន់វង្វង់នៃមនោទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងធឹងដល់នូវការមិនរំភើប ទាំងលោកក៏ឃើញនូវការកើតឡើង និងការលត់ទៅនៃចិត្តនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ភ្នំថ្មមិនមានចន្លោះ មិនមានប្រហោង ជាភ្នំតាន់ស៊ុទ្ធ ទោះបីគំនរខ្យល់ដ៏ពន្លឹក បក់បោកមកពីទិសខាងកើតក្តី ក៏ធ្វើភ្នំនោះឲ្យឃ្លាតមិនបាន ឲ្យកម្រើកមិនបាន ឲ្យញាប់ញ័រមិនបាន ទោះបីគំនរខ្យល់ដ៏ពន្លឹក បក់បោកមកអំពីទិសខាងលិចក្តី ។បេ។ ទោះបីគំនរខ្យល់ដ៏ពន្លឹកបក់បោកមកអំពីទិសខាងជើងក្តី ទោះបីគំនរខ្យល់ដ៏ពន្លឹក បក់បោកមកអំពីទិសខាងត្បូងក្តី ក៏ធ្វើភ្នំនោះឲ្យឃ្លាតមិនបាន ឲ្យកម្រើកមិនបាន ឲ្យញាប់ញ័រមិនបាន មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន មានឧបមេយ្យដូចភិក្ខុមានចិត្តផុតស្រឡះដោយប្រពៃ យ៉ាងនេះហើយ ទោះបីរូបារម្មណ៍ដ៏ពន្លឹក ដែលគប្បីដឹងដោយភ្នែក មកកាន់វង្វង់នៃចក្ខុទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងធឹង ដល់នូវការមិនរំភើប ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ទោះបីសទ្ទារម្មណ៍ដ៏ពន្លឹក ដែលគប្បីដឹងដោយ

ត្រចៀក ។បេ។ គន្ធារម្មណ៍ ដែលគប្បីដឹងដោយច្រមុះ រសារម្មណ៍ ដែលគប្បីដឹងដោយអណ្តាត ផោដ្ឋព្វារម្មណ៍ ដែលគប្បីដឹងដោយកាយ ធម្មារម្មណ៍ ដែលគប្បីដឹងដោយចិត្ត មកកាន់រង្វង់នៃមនោទ្វារ ក៏គ្របសង្កត់ចិត្តរបស់ភិក្ខុនោះមិនបាន ចិត្តរបស់លោក ក៏មិនបានច្រឡំដោយអារម្មណ៍ ជាចិត្តនឹងធឹង ដល់នូវការមិនញាប់ញ័រ ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ។

កាលបើភិក្ខុមានចិត្តចុះស៊ប់កាន់នេក្ខម្មៈ កាន់សេចក្តីស្ងប់ស្ងាត់ មានចិត្តចុះស៊ប់កាន់សេចក្តីមិនព្យាបាទ កាន់ធម៌ជាទីអស់ទៅនៃឧបាទាន មានចិត្តចុះស៊ប់កាន់ធម៌ ជាទីអស់ទៅនៃតណ្ហា កាន់សេចក្តីមិនវង្វេង ចិត្តក៏រមែងផុតស្រឡះដោយប្រពៃ ព្រោះឃើញនូវការកើត និងការរលត់ទៅនៃអាយតនៈ កាលបើភិក្ខុនោះ មានចិត្តផុតស្រឡះដោយប្រពៃហើយ មានចិត្តស្ងប់រម្ងាប់ហើយ ការសន្សំនូវកិច្ច ដែលលោកត្រូវធ្វើក៏មិនមាន កិច្ចដែលគួរធ្វើក៏មិនមាន ។ ភ្នំថ្មតាន់សុទ្ធ រមែងមិនកម្រើកដោយខ្យល់ យ៉ាងណា អារម្មណ៍ទាំងឡាយ គឺរូប សំឡេង ក្លិន រស ផស្សៈ ទាំងអស់ជាទីប្រាថ្នាក្តី មិនជាទីប្រាថ្នាក្តី ក៏ធ្វើចិត្តរបស់អ្នកខ្ជាប់ខ្ជួន ជាចិត្តនឹងធឹង រួចស្រឡះចាកកិលេស ឲ្យញាប់ញ័រមិនបាន ទាំងលោកក៏ពិចារណាឃើញនូវការកើតឡើង និងការរលត់ទៅនៃចិត្តនោះ ក៏យ៉ាងនោះដែរ ។

# អដ្ឋកថា
# ទុតិយបណ្ណាសក

## មហាវគ្គទី ១

### អដ្ឋកថាសោណសូត្រ

[ ៥៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសោណសូត្រទី ១ នៃទុតិយបណ្ណាសក ដូចតទៅនេះ បទថា **សោណោ** បានដល់ ព្រះសោណត្ថេរដែលជាសុខុមាលជាតិ ។ បទថា **សីតវនេ** បានដល់ ក្នុងព្រៃស្មសានដែលមានឈ្មោះយ៉ាងនេះ ។

បានឮថា ក្នុងព្រៃស្មសាននោះ គេធ្វើទីចង្រ្កម ៥០០ កន្លែង តាមលំដាប់ ។ បណ្តាទីចង្រ្កម ៥០០ កន្លែងនោះ ព្រះថេរៈជ្រើសរើសយកទីចង្រ្កមមួយកន្លែងដែលជាសប្បាយសម្រាប់ខ្លួន ហើយបំពេញសមណធម៌ ។ កាលព្រះថេរៈនោះ ប្រារព្ធសេចក្តីព្យាយាមដើរចង្រ្កម ផ្ទៃបាតជើងក៏បែក ។ កាលលោកលុតជង្គង់ចង្រ្កម ក្បាលជង្គង់ក្តី បាតដៃក្តី ក៏បែកជាប្រហោងៗ ។ ព្រះថេរៈប្រារព្ធព្យាយាមយ៉ាងនោះ ក៏មិនអាចឃើញសូម្បីត្រឹមតែឱភាស ឬនិមិត្ត ។ ដើម្បីសម្តែងដល់វិតក្កដែលកើតឡើងដល់ព្រះសោណៈនោះ ដែលជាអ្នកលំបាកកាយ ដោយសេចក្តីព្យាយាម ហើយអង្គុយសម្រាកលើផ្ទាំងថ្មក្នុងទីបំផុតទីចង្រ្កម ។ ទើបព្រះអានន្ទត្ថេរពោលពាក្យថា **អថខោ អាយស្មតោ**

ជាដើម ។

បណ្តាបទទាំងនោះ បទថា **អារទ្ធវីរិយា** បានដល់ ផ្គងសេចក្តីព្យាយាមពេញបរិបូណ៌ ។ បទថា **ឆ អនុធាធាយ អាសវេហិ ចិត្តំ វិមុច្ចតិ** សេចក្តីថា ព្រះសោណៈដាក់ចិត្តជឿថា បើអញជាឧគ្ឃដិតញ្ញូ វិបចិតញ្ញូ ឬនេយ្យៈសោត ចិត្តរបស់អញគប្បីរួចផុតបានយ៉ាងពិតប្រាកដ តែនេះ អញជាបទបរមបុគ្គលនោះឯង ទើបចិត្តរបស់អញមិនរួចផុត ដូច្នេះហើយ គិតដល់ហេតុជាដើមថា ភោគៈរបស់អញមាន ។ បណ្តាទាំងនោះ បទថា **ភោគា** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **ចាតុរហោសិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ជ្រាបវារចិត្តរបស់ព្រះថេរៈហើយ ទ្រង់ត្រិះរិះថា ថ្ងៃនេះ សោណៈនេះ អង្គុយលើផែនដី ត្រង់ទីបំពេញព្យាយាម ក្នុងព្រៃសីតវ័ន ត្រិះរិះដល់រឿងនេះ តថាគតនឹងទៅកាន់យកវិតក្កដែលបៀតបៀនលោក ហើយប្រាប់កម្មដ្ឋានដែលឧបមាដោយពិណ ដូច្នេះហើយ បានមកប្រាកដចំពោះមុខព្រះថេរៈ ។ បទថា **បញ្ញត្តេ អាសនេ** សេចក្តីថា ភិក្ខុបំពេញព្យាយាម ក្រាលអាសនៈតាមដែលរកបាន ដើម្បីជាទីគង់របស់ព្រះមានព្រះភាគ ដែលយាងមកដើម្បីត្រាស់ប្រៀនប្រដៅ ដល់ទីលំនៅរបស់ខ្លួនមុនហើយ ទើបបំពេញព្យាយាម បើរកអាសនៈដទៃមិនបាន ក៏ក្រាលស្លឹកឈើចាស់ៗ ហើយក្រាលសង្ឃាដីខាងលើ ។ ឯព្រះថេរៈក្រាលអាសនៈមុនហើយ ទើបបំពេញព្យាយាម ព្រះសង្គីតិកាចារ្យសំដៅយកអាសនៈនោះ ទើបពោលថា **បញ្ញត្តេ អាសនេ**

ដូច្នេះ ។

បទថា **តំ កឹ មញ្ញសិ** សេចក្តីថា ព្រះសាស្តាទ្រង់ត្រិះរិះថា ភិក្ខុនេះមិនមានសេចក្តីត្រូវការដោយកម្មដ្ឋានដ៏សេស ភិក្ខុនេះឈ្លាស ធ្លាប់ជំនាញមកហើយក្នុងសិប្បៈនៃអ្នកតន្រ្តី លោកនឹងកំណត់ឧបមា ដែលតថាគតពោលក្នុងវិស័យរបស់ខ្លួនបានដោយឆាប់រហ័ស ដូច្នេះហើយ ដើម្បីត្រាស់ឧបមាដោយពិណ ទើបទ្រង់ត្រាស់ពាក្យថា **តំ កឹ មញ្ញសិ** ជាដើម ។ ភាពជាអ្នកឈ្លាស ក្នុងការដេញពិណ ឈ្មោះថា ជាអ្នកឈ្លាសក្នុងសំឡេងខ្សែពិណ ។ ព្រះសោណៈនោះ ជាអ្នកស្ទាត់ក្នុងការដេញពិណនោះ ពិតហើយ មាតាបិតានៃព្រះសោណៈនោះគិតថា កូនប្រុសរបស់អញ បើឲ្យសិក្សាសិប្បៈណាមួយក៏នឹងលំបាកកាយ តែសិប្បៈដេញពិណនេះ កូនរបស់អញ អង្គុយលើទីដេកក៏អាចរៀនបាន ទើបឲ្យរៀនចំពោះសិប្បៈរបស់អ្នកតន្រ្តីប៉ុណ្ណោះ ។ សិប្បៈនៃអ្នកតន្រ្តី មានដូច្នេះ ។

សំឡេងទាំងនេះ គឺសំឡេង ៧ ពួក សំឡេងផ្សំ ៣ ពួក លំដាប់សំឡេង ២១ លំដាប់ ឋានៈនៃសំឡេង ៤៩ ឋានៈ ចាត់ជាក្រុមនៃសំឡេង ។ សំឡេងទាំងអស់នោះឯង ព្រះសោណៈបានជំនាញមកហើយទាំងអស់ ។

បទថា **អច្ចាយតា** បានដល់ ពិណដែលតឹងពេក គឺមានលំដាប់សំឡេងរឹង ។ បទថា **សរវតី** បានដល់ ដល់ព្រមដោយសំឡេង ។ បទថា **កម្មញ្ញា** បានដល់ សមនឹងប្រើការងារ គឺប្រើការបាន ។ បទថា **អតិសិថិលា** បាន

ដល់ លំដាប់សំឡេងស្រោល ។ បទថា **សមេ គុណោ បតិដ្ឋិតា** បានដល់ នៅក្នុងលំដាប់សំឡេងកណ្តាល ។ បទថា **អច្ចារទ្ធំ** បានដល់ ការព្យាយាមតឹងពេក ។ បទថា **ឧទ្ធច្ចាយ សំវត្តតិ** សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលរាយមាយ ។ បទថា **អតិលីនំ** បានដល់ ធូរពេក ។ បទថា **កោសជ្ជាយ** បានដល់ ដើម្បីភាពជាអ្នកខ្ជិលច្រអូស ។ បទថា **វីរិយសមតំ អធិដ្ឋាហិ** សេចក្តីថា អ្នកចូរតាំងសមថៈ ដែលសម្បយុត្តដោយវីរិយៈឲ្យមាំ ដោយអត្ថថា ចូរប្រកបវីរិយៈចូលជាមួយសមថៈ ។ បទថា **ឥន្ទ្រិយានញ្ច សមតំ បដិវិជ្ឈ** សេចក្តីថា អ្នកចូរតាំងនៅក្នុងភាពស្មើ គឺភាវៈដែលស្មើគ្នានៃឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមឲ្យមាំ ។

ក្នុងសេចក្តីនោះ ភិក្ខុដែលប្រកបដោយសទ្ធាជាមួយបញ្ញា ប្រកបបញ្ញាចូលជាមួយសទ្ធា ប្រកបវីរិយៈជាមួយសមាធិ ប្រកបសមាធិជាមួយវីរិយៈ ឈ្មោះថា ជាអ្នកតាំងនៅក្នុងភាវៈដែលស្មើគ្នានៃឥន្ទ្រិយទាំងឡាយមាំ ។ ឯសតិ មានប្រយោជន៍ចំពោះធម៌ទាំងពួង សតិនោះ ចំពោះដែលមានកម្លាំងរមែងគួរសព្វកាល ។ វិធីប្រកបឥន្ទ្រិយទាំងនោះចូលជាមួយគ្នានោះ សម្តែងជាក់ច្បាស់ហើយ ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គ ។

បទថា **តត្ថ ច និមិត្តំ គណ្ហាហិ** សេចក្តីថា កាលភាវៈដែលស្មើគ្នានៃឥន្ទ្រិយទាំងឡាយនោះមាន និមិត្តណាគប្បីកើតឡើង ដូចស្រមោលមុខក្នុងកញ្ចក់ អ្នកចូរកំណត់កាន់យកនិមិត្តនោះ ជាសមថនិមិត្តក្តី វិបស្សនានិមិត្តក្តី

មគ្គនិមិត្តក្តី ផលនិមិត្តក្តី គឺចូរធ្វើឲ្យនិមិត្តនោះកើតឡើង ព្រះសាស្តាត្រាស់កម្មដ្ឋានដល់ព្រះសោណៈនោះ សរុបចុះក្នុងអរហត្តផល ដោយប្រការដូចពណ៌នាមកនេះ ។ បទថា **តត្ថ ច និមិត្តំ អគ្គហេសិ** សេចក្តីថា ព្រះសោណៈបានកំណត់កាន់យកនូវសមថនិមិត្តផង វិបស្សនានិមិត្តផង ។

បទថា **ឆដ្ឋានានិ** បានដល់ ហេតុ ៦ យ៉ាង ។ បទថា **អធិមុត្តោ ហោតិ** បានដល់ ជាអ្នកចាក់ធ្លុះ គឺធ្វើឲ្យប្រចក្សតាំងនៅ ។ បទទាំងឡាយមានបទថា **នេក្ខម្មាធិមុត្តោ** ព្រះសោណៈពោល ដោយអំណាចអរហត្តផលនោះឯង ។ ពិតហើយ អរហត្តផល ឈ្មោះថា **នេក្ខម្ម** ព្រោះចេញទៅចាកកិលេសទាំងពួង ឈ្មោះថា **បវិវេក** ព្រោះស្ងាត់ចាកកិលេសទាំងនោះឯង ។ ឈ្មោះថា **អព្យាបជ្ឈ** ព្រោះមិនមានការបៀតបៀន ។ ឈ្មោះថា **តណ្ហាក្ខយ** ព្រោះកើតឡើងក្នុងទីបំផុតនៃការអស់តណ្ហា ។ ឈ្មោះថា **ឧបាទានក្ខយ** ព្រោះកើតឡើងក្នុងទីបំផុតនៃឧបាទាន ។ ឈ្មោះថា **អសម្មោហ** ព្រោះមិនមានការវង្វេង ។ បទថា **កេវលំ សទ្ធាមត្តកំ** បានដល់ វៀរចាកបដិវេធ គឺត្រឹមតែសទ្ធាសុទ្ធៗ ដែលមិនលាយឡំដោយបដិវេធប្បញ្ញា ។ បទថា **បដិចយំ** បានដល់ ការចម្រើនដោយការបំពេញរឿយៗ ។ បទថា **វីតរាគត្តា** បានដល់ ព្រោះរាគៈប្រាសទៅ ដោយការចាក់ធ្លុះមគ្គនោះឯង ។ ភិក្ខុជាអ្នកចាក់ធ្លុះ គឺធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ពោល គឺនេក្ខម្មៈ នឹងជាអ្នកមានចិត្តបង្អោនទៅក្នុងផលសមាបត្តិនោះឯង ។ ក្នុងបទដ៏សេស ក៏មានន័យ

ដូចគ្នានេះឯង ។

បទថា **លាភសក្ការសិលោកំ** បានដល់ លាភ គឺបច្ច័យ ៤ ដែលខ្លួននោះឯងធ្វើល្អហើយ និងការពោលសរសើរគុណ ។ បទថា **និកាមយមានោ** បានដល់ ត្រូវការ គឺប្រាថ្នា ។ បទថា **វិវេកាធិមុត្តោ** សេចក្តីថា ព្យាករអរហត្តផលយ៉ាងនេះថា អាត្មាអញបង្អោនទៅក្នុងវិវេក ។ បទថា **សីលព្វតបរាមាសំ** សេចក្តីថា ត្រឹមតែប្រកាន់សីល និងវត្តដែលខ្លួនបានស្ទាបអង្អែលមកហើយ ។ បទថា **សារតោ បច្ចាគច្ឆន្តោ** បានដល់ នៅដោយភាពជាសារៈ ។ បទថា **អព្យាបជ្ឈាធិមុត្តោ** បានដល់ ព្យាករការមិនបៀតបៀនគ្នាថា ជាអរហត្តផល ។ គប្បីឃើញអត្ថក្នុងទីគ្រប់អន្លើ ដោយន័យនេះឯង ។

ម្យ៉ាងទៀត ក្នុងវគ្គនេះ អាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគត្រាស់អរហត្តផលក្នុងបទនេះថា **នេក្ខម្មាធិមុត្តោ** ត្រាស់និព្វានក្នុង ៥ បទដ៏សេស ។ អាចារ្យមួយពួកទៀតពោលថា ព្រះមានព្រះភាគត្រាស់និព្វានចំពោះក្នុងបទនេះថា **អសម្មោហាធិមុត្តោ** ត្រាស់អរហត្តផល ក្នុងបទដ៏សេស ។ តែក្នុងទីនេះ មានសារសំខាន់ដូច្នេះថា ព្រះមានព្រះភាគ ត្រាស់អរហត្តផលផង និព្វានផង ក្នុងបទទាំងនោះ គ្រប់បទនោះឯង ។ បទថា **ភុសា** បានដល់ មានកម្លាំង គឺដូចរូបទិព្វ ។

បទថា **នេវស្ស ចិត្តំ បរិយាទិយន្តិ** សេចក្តីថា កិលេសទាំងឡាយមិនអាចគ្របសង្កត់ចិត្តរបស់ព្រះខីណាស្រពនោះបាន ។ ពិតហើយ កិលេសទាំង-

ឡាយ កំពុងកើតឡើង ឈ្មោះថា គ្របសង្កត់ចិត្ត ។ បទថា **អមិស្សីកតំ** សេចក្តីថា កិលេសទាំងឡាយ រមែងធ្វើចិត្ត និងអារម្មណ៍ឲ្យផ្សំគ្នា ព្រោះមិនមានកិលេសទាំងនោះ ទើបចិត្ត ឈ្មោះថា មិនធ្វើឲ្យផលផ្សំគ្នា ។ បទថា **ឋិតំ** បានដល់ តាំងមាំ ។ បទថា **អានេញ្ជប្បត្តំ** បានដល់ ដល់នូវការមិនញាប់ញ័រ ។ បទថា **វយញ្ចស្សានុបស្សតិ** សេចក្តីថា ភិក្ខុនេះរមែងឃើញការកើតឡើងផង ការរលត់ផងនៃចិត្តនោះ ។ បទថា **ភុសា វាតវុដ្ឋិ** បានដល់ ខ្យល់ដ៏ខ្លាំងក្លា ។ បទថា **នេវ សង្កម្បេយ្យ** បានដល់ មិនអាចឲ្យញាប់ញ័របានដោយចំណែកមួយ ។ បទថា **ន សម្បកម្បេយ្យ** បានដល់ មិនអាចឲ្យញាប់ញ័របានគ្រប់ចំណែក ។ ដូចមិនអាចឲ្យគុណកម្រើកបាន ដូច្នោះ ។ បទថា **ន សម្បវេធេយ្យ** បានដល់ មិនអាចធ្វើឲ្យកម្រើក គឺញ័ររហូតដល់ញាប់ញ័របាន ។

បទថា **នេក្ខម្មមធិមុត្តស្ស** សេចក្តីថា ចាក់ចុះអរហត្តផល ហើយតាំងនៅ ។ ក្នុងបទដ៏សេស ក៏ត្រាស់ចំពោះអរហត្តដូចគ្នា ។ បទថា **ឧបាទាន-ក្ខយស្ស ច** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ បទថា **អសម្មោហញ្ច ចេតសោ** បានដល់ បង្អោនទៅកាន់ការមិនវង្វេងនៃចិត្ត ។ បទថា **ទិស្វា អាយតនុប្បាទំ** បានដល់ ឃើញនូវការកើតឡើង និងការរលត់នៃអាយតនៈទាំងឡាយ ។ បទថា **សម្មា ចិត្តំ វិមុច្ចតិ** សេចក្តីថា ចិត្តរមែងរួចផុត គឺរមែងបង្អោនទៅក្នុងអារម្មណ៍ គឺព្រះនិព្វានដោយប្រពៃ គឺដោយហេតុ ដោយ

ន័យ បានដល់ ដោយអំណាចផលសមាបត្តិ ព្រោះកិច្ចបដិបត្តិវិបស្សនានេះ ។ម្យ៉ាងទៀត ព្រះមានព្រះភាគ ត្រាស់ដល់បដិបទារបស់ព្រះវីណាស្រេពដោយបទនេះ ។ ព្រោះថា ចិត្តនៃព្រះវីណាស្រេពនោះ រមែងរួចផុតដោយល្អចាកកិលេសទាំងអស់ ដោយអានុភាពអរិយមគ្គ ដែលលោកបានឃើញការកើតឡើងនៃអាយតនៈ ហើយសម្រេចដោយវិបស្សនានេះ កាលព្រះវីណាស្រេពនោះរួចផុតដោយល្អយ៉ាងនេះ ។បេ។ រមែងមិនមាន ។ បណ្ដាបទទាំងនោះបទថា **សន្តចិត្តស្ស** បានដល់ មានចិត្តរម្ងាប់ហើយ ។ បទដ៏សេសក្នុងសូត្រនេះ មានអត្ថងាយយល់ហើយ ៕

## អដ្ឋកថា សោណសូត្រទី ១ ចប់

# សុត្តន្តបិដក

## ផគ្គុណសូត្រទី ២

[ ៥៦ ] សម័យនោះ ព្រះផគ្គុណៈដ៏មានអាយុ មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះផគ្គុណៈដ៏មានអាយុ មានអាពាធ ដល់នូវទុក្ខ ឈឺធ្ងន់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ស្តេចចូលទៅឯលំនៅនៃព្រះផគ្គុណៈដ៏មានអាយុ ដើម្បីអនុគ្រោះ ។ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅឯលំនៅដែលព្រះផគ្គុណៈដ៏មានអាយុនៅ ។ ព្រះផគ្គុណៈដ៏មានអាយុ បានឃើញព្រះដ៏មានព្រះភាគ ស្តេចមកអំពីចម្ងាយលីមៗ លុះឃើញហើយ ក៏គ្រាន់តែសម្តែងអាការជាទីក្រោកឡើងលើគ្រែតូច ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ឃាត់ព្រះផគ្គុណៈដ៏មានអាយុយ៉ាងនេះថា កុំផគ្គុណៈ អ្នកកុំក្រោកអំពីគ្រែតូចឡើយ ។ អាសនៈនេះដែលភិក្ខុឯទៀត ក្រាលបម្រុងទុកមានហើយ តថាគតនឹងអង្គុយលើអាសនៈនោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់គង់លើអាសនៈដែលភិក្ខុក្រាលថ្វាយ លុះព្រះដ៏មានព្រះភាគគង់ហើយ បានត្រាស់សួរព្រះផគ្គុណៈដ៏មានអាយុយ៉ាងនេះថា ម្នាលផគ្គុណៈ អ្នកល្មមអត់ធន់បានទេឬ អ្នក

ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេឬ ទុក្ខវេទនា ( របស់អ្នក ) ធូរថយ មិនចម្រើនឡើង សេចក្តីធូរថយ រមែងប្រាកដ ការចម្រើនឡើងមិនប្រាកដទេឬ ។ ព្រះផគ្គុណៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ ចេះតែចម្រើនឡើង មិនធូរថយសោះ សេចក្តីចម្រើនឡើង ចេះតែប្រាកដ សេចក្តីធូរថយ មិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង យកដែកស្រួចដ៏មុតមកចាក់ទម្លុះក្បាល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្យល់យ៉ាងខ្លាំងតែងចាក់ដោតក្នុងក្បាល ( របស់ខ្ញុំព្រះអង្គ ) ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ ចេះតែចម្រើនឡើង មិនធូរថយសោះ សេចក្តីចម្រើនឡើង ចេះតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បុរសមានកម្លាំងយកព្រ័ត្រដ៏មាំមួយចង្វាយមករុំត្របែងក្បាល យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន វេទនាក្នុងក្បាល ( របស់ខ្ញុំព្រះអង្គ ) ក៏ខ្លាំង យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ ចេះតែចម្រើនឡើង មិនធូរថយសោះ សេចក្តីចម្រើនឡើង ចេះតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចម្រើន នាយគោឃាតក្តី អ្នកជំនួយការនៃនាយគោឃាតក្តី ដែល

ឈ្លាស យកកាំបិតសម្រាប់វះគោដ៏មុត មកវះពោះ យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្យល់យ៉ាងខ្លាំង តែងកាត់នូវផ្ទៃរបស់ខ្ញុំព្រះអង្គ យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ ចេះតែចម្រើនឡើង មិនធូរថយសោះទេ សេចក្តីចម្រើនឡើងចេះតែប្រាកដ សេចក្តីធូរថយមិនប្រាកដទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង ២ នាក់នាំគ្នាចាប់បុរសដែលមានកម្លាំងថយជាង ត្រង់ដើមដៃផ្សេងគ្នា មកដុតរោលអាល លើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីក្តៅក្រហាយយ៉ាងខ្លាំងក្នុងកាយ ( របស់ខ្ញុំព្រះអង្គ ) ក៏យ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនល្មមអត់ធន់បានទេ មិនល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំព្រះអង្គធ្ងន់ណាស់ ចេះតែចម្រើនឡើង មិនធូរថយសោះ សេចក្តីចម្រើន ចេះតែប្រាកដ សេចក្តីធូរថយ មិនប្រាកដទេ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើព្រះផគ្គុណៈដ៏មានអាយុ ឲ្យយល់ឃើញច្បាស់ ឲ្យជឿកាន់តាម ឲ្យក្លៀវក្លា ឲ្យរីករាយ ដោយធម្មីកថា ហើយទ្រង់ក្រោកចាកអាសនៈ ស្តេចចៀសចេញទៅ ។ គ្រាកាលព្រះដ៏មានព្រះភាគទ្រង់ស្តេចចេញទៅ មិនយូរប៉ុន្មាន ព្រះផគ្គុណៈដ៏មានអាយុ ក៏ទទួលមរណភាព ក៏ក្នុងសម័យជាកាលជិតមរណៈនោះ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ជ្រះថ្លា ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ

ចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គទ្រង់ស្តេចចេញមក មិនយូរប៉ុន្មាន ព្រះផគ្គុណៈដ៏មានអាយុ ក៏ទទួលមរណកាល ប៉ុន្តែសម័យជាកាលជិតមរណៈនោះ ឥន្ទ្រិយទាំងឡាយរបស់លោកក៏ជ្រះថ្លា ព្រះដ៏មានព្រះភាគត្រាស់ថា ឱអានន្ទ ឥន្ទ្រិយទាំងឡាយរបស់ផគ្គុណភិក្ខុ នឹងមិនជ្រះថ្លាឯណាបាន ម្នាលអានន្ទ ចិត្តរបស់ផគ្គុណភិក្ខុជាចិត្តមិនទាន់ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងទេ ប៉ុន្តែចិត្តរបស់លោកផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបានវិញ ព្រោះស្តាប់ធម្មទេសនានោះ ។ ម្នាលអានន្ទ អានិសង្សក្នុងការស្តាប់ធម៌ តាមកាលគួរក្នុងការពិចារណាសេចក្តីតាមកាលគួរនេះ មាន ៦ យ៉ាង ។ អានិសង្ស ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានចិត្តមិនទាន់ផុតស្រឡះចាកសញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងទេ ប៉ុន្តែក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះបានជួបប្រទះព្រះតថាគត ព្រះតថាគតសម្តែងធម៌មានពីរោះបទដើម បទកណ្តាល បទចុង ប្រកបដោយអត្ថ ដោយព្យញ្ជនៈ ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធិពេញលេញទាំងអស់ ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបាន ព្រោះស្តាប់ធម្មទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ១

ក្នុងការស្តាប់ធម៌តាមកាលគួរ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុមានចិត្តមិនទាន់ផុតស្រឡះ ចាកសញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងទេ តែក្នុងសម័យកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានជួបប្រទះព្រះតថាគតទេ ប៉ុន្តែបានជួបប្រទះនឹងសាវករបស់ព្រះតថាគត សាវករបស់ព្រះតថាគតក៏សម្តែងធម៌ មានពីរោះបទដើម បទកណ្តាល បទចុង ប្រកបដោយអត្ថ ដោយព្យញ្ជនៈ ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធិពេញលេញទាំងអស់ ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងបាន ព្រោះស្តាប់ធម្មទេសនានោះ នេះជាអានិសង្សទី ២ ក្នុងការស្តាប់ធម៌តាមកាលគួរ ។ ម្នាលអានន្ទ មួយទៀត ចិត្តរបស់ភិក្ខុមិនទាន់ផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងទេ តែក្នុងសម័យជាកាលជិតមរណៈ ភិក្ខុនោះ មិនបានជួបប្រទះព្រះតថាគត មិនបានជួបនឹងសាវករបស់ព្រះតថាគតទេ ប៉ុន្តែត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ពិនិត្យរឿយៗ ក្នុងចិត្ត ចំពោះធម៌ តាមដែលខ្លួនបានស្តាប់ បានរៀនមក កាលភិក្ខុនោះត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ពិនិត្យរឿយៗ ក្នុងចិត្ត ចំពោះធម៌ តាមដែលខ្លួនបានស្តាប់ បានរៀនមក ចិត្តក៏ផុតស្រឡះចាកសញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងបាន ម្នាលអានន្ទ នេះជាអានិសង្សទី ៣ ក្នុងការពិចារណាសេចក្តីតាមកាលគួរ ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានចិត្តផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងស្រេច

ហើយ ប៉ុន្តែមានចិត្តមិនទាន់ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិនៅឡើយទេ លុះក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ បានជួបប្រទះព្រះតថាគត ទាំងព្រះតថាគត ក៏សម្តែងធម៌មានពីរោះបទដើម បទកណ្តាល ។បេ។ ប្រកាសព្រហ្មចរិយធម៌ដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិបាន ព្រោះស្តាប់ធម្មទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ៤ ក្នុងការស្តាប់ធម៌តាមកាលគួរ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុមានចិត្តផុតស្រឡះចាកសញ្ញោជនៈជាចំណែកខាងក្រោម ៥ យ៉ាងស្រេចហើយ ប៉ុន្តែមានចិត្តមិនទាន់ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិនៅឡើយទេ លុះក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានជួបប្រទះព្រះតថាគត ប៉ុន្តែបានជួបប្រទះនឹងសាវ័ករបស់ព្រះតថាគត សាវ័ករបស់ព្រះតថាគត ក៏សម្តែងធម៌មានពីរោះបទដើម ។បេ។ ប្រកាសព្រហ្មចរិយធម៌ ដ៏បរិសុទ្ធិដល់ភិក្ខុនោះ ចិត្តរបស់ភិក្ខុនោះ ក៏ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វាន ជាទីអស់ទៅនៃឧបធិបាន ព្រោះស្តាប់ធម៌ទេសនានោះ ម្នាលអានន្ទ នេះជាអានិសង្សទី ៥ ក្នុងការស្តាប់ធម៌ តាមកាលគួរ ។ ម្នាលអានន្ទ មួយវិញទៀត ភិក្ខុមានចិត្តផុតស្រឡះចាកសញ្ញោជនៈ ជាចំណែកខាងក្រោម ៥ យ៉ាងស្រេចហើយ ប៉ុន្តែមានចិត្តមិនទាន់ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិនៅឡើយទេ លុះក្នុងសម័យជាកាលជិតមរណៈនោះ ភិក្ខុនោះ មិនបានជួបប្រទះ

ព្រះតថាគត ទាំងមិនបានជួបប្រទះនឹងសាវករបស់ព្រះតថាគតទេ ប៉ុន្តែ បាន ត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ពិនិត្យរឿយៗ ក្នុងចិត្ត ចំពោះធម៌ តាមដែលខ្លួនបានស្តាប់ បានរៀនមក កាលភិក្ខុនោះ ត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ពិនិត្យរឿយៗ ក្នុងចិត្ត ចំពោះធម៌ តាមដែលខ្លួនបានស្តាប់ បានរៀនមក ចិត្តក៏ចុះស៊ប់ក្នុងធម៌ដ៏ប្រសើរ គឺព្រះនិព្វានជាទីអស់ទៅនៃឧបធិបាន ម្នាលអានន្ទ នេះអានិសង្សទី ៦ ក្នុងការពិចារណាសេចក្តី តាមកាលគួរ ។ ម្នាលអានន្ទ អានិសង្សក្នុងការស្តាប់ធម៌ តាមកាលគួរ ក្នុងការពិចារណាធម៌ តាមកាលគួរ មាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## ផគ្គុណសូត្រ

[ ៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងផគ្គុណសូត្រទី ២ ដូចតទៅនេះ បទថា **សមធោសិ** បានដល់ សម្តែងអាការក្រោកឡើង ។ បទថា **បដិក្កមន្តិ** បានដល់ ទន់ខ្សោយជាលំដាប់ ។ បទថា **នោ អភិក្កមន្តិ** បានដល់ មិនកម្រើក ។ បទថា **សីសវេឋនំ ទទេយ្យ** បានដល់ រុំក្បាលហើយ យកកូនកំព្រាមួល ។ បទថា **ឥន្ទ្រិយានិ វិប្បសីទឹសុ** សេចក្តីថា ក្នុងកាលជិតស្លាប់នោះ ឥន្ទ្រិយ ៦ ផូរផង់ ។ បទថា **អត្ថុបបរិក្ខាយ** បានដល់ ដោយការពិចារណាដល់

ប្រយោជន៍ និងមិនមែនប្រយោជន៍ គឺហេតុ និងមិនមែនហេតុ ។ បទថា **អនុត្តរេ ឧបធិសង្ខយេ** បានដល់ ក្នុងនិព្វាន ។ បទថា **អធិមុត្តំ ហោតិ** បានដល់ បង្អោនទៅដោយអរហត្តផល ។ល។

អដ្ឋកថា ផគ្គុណសូត្រទី ២ ចប់

# សុត្តន្តបិដក

## ឆឡាភិជាតិយសូត្រទី ៣

[ ៥៧ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បូរណកស្សបៈ បញ្ញត្តជាតិកំណើត ៦ យ៉ាង គឺបញ្ញត្តជាតិខ្មៅ ១ បញ្ញត្តជាតិខៀវ ១ បញ្ញត្តជាតិក្រហម ១ បញ្ញត្តជាតិលឿង ១ បញ្ញត្តជាតិស ១ បញ្ញត្តជាតសសុទ្ធ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តពួកជនអ្នកសម្លាប់ពពែ អ្នកសម្លាប់ជ្រូក អ្នកសម្លាប់សត្វបក្សី អ្នកសម្លាប់ម្រឹគពួកព្រាន ពួកអ្នកសម្លាប់ត្រី ពួកចោរ ពួកអ្នកសម្លាប់ចោរ ពួកអ្នកជាប់គុក

ឬក៏ពួកជនណាមួយក្រៅពីនេះ ដែលមានអំពើអាក្រក់ថាជាជាតិខ្មៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តពួកភិក្ខុដែលមានអធ្យាស្រ័យខ្មៅ ឬក៏ពួកជនណាមួយ ក្រៅពីនេះ ដែលជាកម្មវាទ និងកិរិយវាទ ថាជាជាតិខៀវ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តពួកនិគ្រន្ថ ដែលមានសាដកតែមួយថាជាជាតិក្រហម ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តពួកគ្រហស្ថ អ្នកស្លៀកដណ្តប់សំពត់ស មានសាដក ដូចជាសាដកអចេលកៈ ថាជាជាតិលឿង ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តពួកអាជីវកៈ និងអាជីវកា ថាជាជាតិស ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិ ៦ យ៉ាងនោះ បូរណកស្សបៈ បញ្ញត្តជនឈ្មោះនន្ទវច្ឆៈ ឈ្មោះកច្ចសង្កិច្ចៈ និងឈ្មោះមក្ខលិគោសាល ថាជាជាតិសសុទ្ធ ។ បពិត្រព្រះអង្គដ៏ចម្រើន បូរណកស្សបៈ បានបញ្ញត្តជាតិ ៦ យ៉ាងនេះឯង ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ចុះសត្វលោកទាំងពួង យល់តាមពាក្យរបស់បូរណកស្សបៈ ដែលបញ្ញត្តជាតិ ៦ យ៉ាងនេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនយល់តាមទេ ។ ម្នាលអានន្ទ ដូចជាបុរសទ័លក្រ មិនមានទ្រព្យរបស់ខ្លួន ជាអ្នកមិនស្តុកស្តម្ភ ពួកជនឯទៀត ជំរុញឲ្យចំណែកសាច់ដល់បុរសនោះ ដែលជាអ្នកមិនត្រូវការដោយបន្ទឹថា នែបុរសអើយ អ្នកត្រូវទំពាស៊ីសាច់នេះផង ត្រូវប្រគល់ឲ្យនូវថ្លៃផង យ៉ាងណាមិញ ម្នាលអានន្ទ

បូរណកស្សបៈជាមនុស្សពាល មិនវាងវៃ មិនស្គាល់ខេត្ត ( នៃការបញ្ញត្តិជាតិ ) មិនឆ្លៀវឆ្លាស បានបញ្ញត្តជាតិ ៦ យ៉ាងនេះ របស់ពួកសមណ-ព្រាហ្មណ៍ទាំងនុ៎ះ ដោយគេមិនបានយល់ព្រម ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ ឥឡូវនេះ តថាគតនឹងបញ្ញត្តជាតិ ៦ យ៉ាង អ្នកចូរស្តាប់បញ្ញត្តិនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសម្តែង ។ ព្រះអានន្ទដ៏មានអាយុ ក៏ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទ ចុះជាតិ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិខ្មៅ ប្រព្រឹត្តធម៌ខ្មៅ ១ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិខ្មៅ ប្រព្រឹត្តធម៌ស ១ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិខ្មៅ ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ១ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិស ប្រព្រឹត្តធម៌ខ្មៅ ១ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិស ប្រព្រឹត្តធម៌ស ១ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មានជាតិសដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ១ ។ ម្នាលអានន្ទ ចុះបុគ្គលមានជាតិខ្មៅ ប្រព្រឹតធម៌ខ្មៅ តើយ៉ាងណា ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មកកើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ឬត្រកូលនេសាទ ត្រកូលជាងផែង ត្រកូលជាងរថ ត្រកូលអ្នកយកសំរាម ជាត្រកូលក្រីក្រ មិនមានបាយទឹក និងគ្រឿងប្រើប្រាស់រស់នៅដោយលំបាក ដែលជាត្រកូលរកគ្រឿងបរិភោគ និងគ្រឿងស្លៀកពាក់បានដោយ

ក្រ បុគ្គលនោះឯង ជាអ្នកមានសម្បុរអាក្រក់ លំបាកមើល ជាបុគ្គលទាបតឿ មានអាពាធច្រើន ជាបុគ្គលខ្វាក់ ឬក្ងែង ខ្វក ស្វាប់អវយវៈ ជាអ្នកមិនសូវបាននូវបាយទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលអានន្ទ បុគ្គលជាអ្នកមានជាតិខ្មៅ ប្រព្រឹត្តធម៌ខ្មៅ យ៉ាងនោះឯង ។ ម្នាលអានន្ទ ចុះបុគ្គលមានជាតិខ្មៅ ប្រព្រឹត្តធម៌ស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ កើតមកក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ ជាអ្នកមិនសូវបាននូវទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ បុគ្គលជាអ្នកមានជាតិខ្មៅ ប្រព្រឹត្តធម៌សយ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលអ្នកមានជាតិខ្មៅ ដល់នូវព្រះនិព្វានដែលជាធម៌មិនខ្មៅមិនស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ មកកើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ។បេ។ បុគ្គលនោះឯង ជាអ្នកមានសម្បុរអាក្រក់ លំបាកមើល ជា

មនុស្សទាបតោ បុគ្គលនោះកោរសក់ កោរពុកមាត់ពុកចង្កា ស្លៀកដណ្តប់នូវកាសាវពស្ត្រ ចេញចាកផ្ទះបួសកាន់ផ្នួស លុះបុគ្គលនោះបួសយ៉ាងនេះហើយ ក៏បានលះនូវនីវរណធម៌ ៥ ប្រការ ដែលជាឧបក្កិលេសនៃចិត្តជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកម្លាំង មានចិត្តខ្ជាប់ខ្ជួន ក្នុងសតិប្បដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ តាមសមគួរ ហើយដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ។ ម្នាលអានន្ទ បុគ្គលអ្នកមានជាតិខ្មៅ ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស យ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលអ្នកមានជាតិស ប្រព្រឹត្តធម៌ខ្មៅ តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះ ក្នុងលោកនេះ កើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ឬត្រកូលព្រាហ្មណមហាសាល ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធាន និងធញ្ញាហារច្រើន បុគ្គលនោះ មានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង ជាអ្នកស្ទាក់លាភ ចំពោះបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលអានន្ទ បុគ្គលមានជាតិស ដែលប្រព្រឹត្តធម៌

ខ្មៅយ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលជាអ្នកមានជាតិស ប្រព្រឹត្តធម៌ស តើដូចម្តេច ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មកកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាល ។បេ។ ជាអ្នកស្វាក់លាភ ចំពោះទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបុគ្គលនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតឯសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ បុគ្គលអ្នកមានជាតិស ប្រព្រឹត្តធម៌សយ៉ាងនេះឯង ។ ម្នាលអានន្ទ ចុះបុគ្គលមានជាតិស ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស តើយ៉ាងណា ។ ម្នាលអានន្ទ បុគ្គលខ្លះក្នុងលោកនេះ មកកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយ-មហាសាល ឬត្រកូលព្រាហ្មណមហាសាល ត្រកូលគហបតិមហាសាល ជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ជាទីគាប់ចិត្តច្រើន មានធនធាន និងធញ្ញាហារច្រើន បុគ្គលនោះ ជាអ្នកមានរូបល្អ គួររមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង ជាអ្នកស្វាក់លាភ ចំពោះបាយ ទឹក សំពត់ យាន កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងគ្រឿងប្រទីប បុគ្គលនោះ បានកោរសក់ កោរពុកមាត់ ពុកចង្កា ស្លៀកដណ្តប់នូវកាសាវពស្ត្រ ចេញចាកផ្ទះចូលកាន់ផ្នួស លុះបុគ្គលនោះបួសយ៉ាងនេះហើយ ក៏លះនូវនីវរណៈ ៥ ប្រការ

ដែលជាឧបក្កិលេសនៃចិត្ត ជាគ្រឿងធ្វើប្រាជ្ញាឲ្យថយកម្លាំង មានចិត្តខ្ជាប់ខ្ជួន ក្នុងសតិប្បដ្ឋាន ៤ ចម្រើនពោជ្ឈង្គ ៧ តាមសមគួរ ហើយដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស ។ ម្នាលអានន្ទ បុគ្គលដែលមានជាតិស ដល់នូវព្រះនិព្វាន ដែលជាធម៌មិនខ្មៅមិនស យ៉ាងនេះឯង ។ ម្នាលអានន្ទ ជាតិ ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## ឆឡាភិជាតិយសូត្រ

[ ៥៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឆឡាភិជាតិយសូត្រទី ៣ ដូចតទៅនេះ បទថា **ឆឡាភិជាតិយោ** បានដល់ ជាតិទាំង ៦ ។ បទថា **តត្រិទំ** គឺ **តត្រាយំ** ។ បទថា **លុទ្ទា** បានដល់ ឋោកទារុណ ។ បទថា **ភិក្ខូ កណ្ហា- ធិមុត្តិកា** សេចក្តីថា ពួកសមណៈទាំងនេះ ។ បទថា **ឯកសាដកា** បានដល់ និគ្គណ្ឋទាំងឡាយ បិទខាងមុខ ដោយកំណាត់សំពត់ចាស់មួយផ្ទាំង ប៉ុណ្ណោះ ។ បទថា **អការមកស្ស ពិលំ ឱលគេយ្យុំ** សេចក្តីថា កាលពួករទេះកំពុងដង្ហែក្បួនទៅ កាលគោមួយស្លាប់ អ្នកស្រែទាំងឡាយ ក៏ពន្លះសាច់គោដើម្បីលក់ ហើយទំពាស៊ីបណ្តើរ បែងចែកចំណែកឲ្យដល់អ្នកស្រែម្នាក់ ដែលមិនត្រូវការសាច់គោឡើយ ដោយពោលថា អ្នកចូរបរិភោគចំណែកនេះ ហើយ

ឲ្យតម្លៃផង ដូច្នេះហើយ ប្រគល់ជុំសាច់ ពោល គឺចំណែកនោះឲ្យ អធិប្បាយ ថា ដាក់ក្នុងដៃដោយបង្ខំ ។ បទថា **អក្ខេត្តញ្ញុនា** បានដល់ ដែលមិនស្គាល់ខេត្ត ដោយការបញ្ញត្តិអភិជាតិ ។

បទថា **តំ សុណាហិ** សេចក្តីថា ចូរអ្នកស្តាប់ការបញ្ញត្តិរបស់តថាគតនេះ ។ បទថា **កណ្ហំ ធម្មំ អភិជាយតិ** សេចក្តីថា កើត គឺកើតជាសភាពខ្មៅ ឬក្នុងកំណើតខ្មៅ ។ បទថា **និព្វានំ អភិជាយតិ** បានដល់ សម្រេចនិព្វាន ឬកើតក្នុងនិព្វានជាតិ ពោល គឺអរិយភូមិ ។ល។

**អដ្ឋកថា ឆឡាភិជាតិយសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## អាសវសូត្រទី ៤

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរទទួលនូវវត្ថុដែលគេនាំមកបូជា គួរទទួលនូវវត្ថុដែលគេរៀបទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរធ្វើអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយណាដែលត្រូវលះបង់ ដោយការសង្រួម អាសវៈទាំងឡាយនោះ ភិក្ខុក្នុងសាសនានេះ បានលះបង់ហើយ ដោយការសង្រួម ១ អាសវៈទាំងឡាយណា ដែល

ត្រូវលះបង់ ដោយការសេព ( នូវបច្ច័យ ) អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការសេព ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការអត់ធន់ អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការអត់ធន់ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការវៀរ អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការវៀរ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការបន្ទោបង់ អាសវៈទាំង-ឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការបន្ទោបង់ ១ អាសវៈទាំងឡាយណា ដែលត្រូវលះបង់ ដោយការចម្រើន អាសវៈទាំងឡាយនោះ ភិក្ខុបានលះបង់ហើយ ដោយការចម្រើន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយ ដូចម្តេច ដែលត្រូវលះបង់ ដោយការសង្រួម ភិក្ខុបានលះបង់ ដោយការសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយសង្រួមនូវចក្ខុន្ទ្រិយសំវរៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនសង្រួមនូវចក្ខុន្ទ្រិយសំវរៈទេ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានសង្រួមនូវចក្ខុន្ទ្រិយសំវរៈ អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះរមែងមិនមានដោយឧបាយយ៉ាងនេះ ។ ភិក្ខុពិចារណាដោយឧបាយ ហើយសង្រួមនូវសោតិន្ទ្រិយ ... ឃានិន្ទ្រិយ ... ជិវ្ហិន្ទ្រិយ ... កាយិន្ទ្រិយ ... មនិន្ទ្រិយ-សំវរៈ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនសង្រួមនូវមនិន្ទ្រិយ-

សំវរៈទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានសង្រួមនូវមនិន្ទ្រិយសំវរៈ អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនសង្រួមនូវសំវរៈទេ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះបានសង្រួមនូវសំវរៈ អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការសង្រួម ភិក្ខុក៏បានលះបង់ ដោយការសង្រួម ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំង-ឡាយដូចម្ដេច ដែលត្រូវលះបង់ ដោយការសេព ភិក្ខុក៏បានលះបង់ដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសានេះ ពិចារណាដោយឧបាយហើយ ប្រើប្រាស់នូវចីវរ ដើម្បីការពារត្រជាក់ ដើម្បីការពារកម្ដៅ ដើម្បីការពារសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ ដើម្បីបិទបាំងអវយវៈ ដែលធ្វើនូវសេចក្ដីខ្មាសឲ្យកម្រើក ។ ពិចារណាដោយឧបាយហើយ បរិភោគនូវបិណ្ឌបាត ដើម្បីលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីឲ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីធ្វើឲ្យផូរផង់ពណ៌សម្បុរដូចអ្នករបាំក៏ទេ បរិភោគគ្រាន់តែដើម្បីឲ្យតាំងនៅនៃរាងកាយនេះ ដើម្បី

ញ៉ាំងជីវិតិន្ទ្រិយ ឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះ ដល់ព្រហ្មចរិយធម៌ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីស្រេកឃ្លាន ដែលមានហើយផង ញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបាន ផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មាន មិនប្រអូសកាយ មិនប្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថ ទាំង ៤ ក្តី នឹងមានដល់អញ ។ ពិចារណាដោយឧបាយហើយ ប្រើប្រាស់ នូវសេនាសនៈ ដើម្បីការពារត្រជាក់ ដើម្បីការពារកម្តៅ ដើម្បីការពារ សម្ផស្ស របោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយ ដើម្បី បន្ទោបង់នូវអន្តរាយ ដែលកើតអំពីរដូវ ហើយអភិរម្យសម្ងំនៅក្នុងព្រះ កម្មដ្ឋាន ។ ពិចារណាដោយឧបាយហើយ ប្រើប្រាស់នូវគ្រឿងបរិក្ខារ គឺថ្នាំ ជាបច្ច័យដល់អ្នកជំងឺ ដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀន ផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំង ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មិនសេព ( នូវបច្ច័យណាមួយដោយឧបាយ ) ទេ អាសវៈ ទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើ ភិក្ខុនោះ បានសេព ( នូវបច្ច័យណាមួយដោយឧបាយ ) អាសវៈដែលជា គ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាង នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះបង់ ដោយការសេព ភិក្ខុក៏បានលះបង់បានដោយការសេព ។ ម្នាលភិក្ខុទាំងឡាយ

ចុះអាសវៈទាំងឡាយដូចម្ដេច ដែលត្រូវលះបង់ ដោយការអត់ធន់ ភិក្ខុក៏បាន លះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយហើយ អត់ធន់នូវត្រជាក់ ក្ដៅ ឃ្លាន ស្រេក ជាបុគ្គល អត់ធន់ចំពោះសម្ផស្ស របោម មូស ខ្យល់ កម្ដៅថ្ងៃ និងពស់តូច ពស់ធំ ទាំងឡាយ និងពាក្យទ្រគោះ អាក្រក់ដែលអាស្រ័យនៅ សរីរៈជាទុក្ខក្លាខ្លាំង ខ្លោចផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ជាវេទនា អាចនាំយកជីវិតទៅ បានដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនអត់ ធន់ ( ចំពោះហេតុណាមួយទេ ) អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀត ចង្អល់ ក្ដៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានអត់ធន់ ( នូវ ហេតុណាមួយ ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្ដៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈដែលត្រូវលះបង់ដោយការអត់ធន់ ភិក្ខុក៏បានលះបង់ដោយការអត់ធន់ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្ដេច ដែលត្រូវលះបង់ ដោយ ការវៀរ ភិក្ខុបានលះបង់ ដោយការវៀរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង សាសនានេះ ពិចារណាដោយឧបាយ ហើយចៀសវាងដំរីកាច ចៀសវាង សេះកាច ចៀសវាងគោកាច ចៀសវាងឆ្កែកាច ពស់ ដង្កត់ឈើ ចម្រូង បន្លា អណ្ដូង ជ្រោះ រណ្ដៅទឹកស្អុយ និងប្រឡាយទឹកស្អុយ ។ ពួកសព្រហ្មចារី ទាំងឡាយជាអ្នកដឹង គប្បីកំណត់ទុក នូវបុគ្គលដែលអង្គុយលើអាសនៈ មិន

សមគួរ យ៉ាងណា ដែលត្រាច់ទៅក្នុងទីមិនសមគួរ យ៉ាងណា ដែលសេពគប់នូវពួកបាបមិត្ត យ៉ាងណា ជាដូចជាទីអាក្រក់ ភិក្ខុនោះ ពិចារណាដោយឧបាយ ហើយចៀសវាងនូវអាសនៈមិនសមគួរនោះផង ទីគោចរមិនសមគួរនោះផង ពួកបាបមិត្តនោះផង ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនចៀសវាង ( នូវហេតុណាមួយ ) ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានចៀសវាង ( នូវហេតុណាមួយ ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈដែលត្រូវលះបង់ដោយការចៀសវាង ភិក្ខុក៏បានលះបង់ដោយការចៀសវាង ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្តេច ដែលត្រូវលះបង់ ដោយការបន្ទោបង់ ភិក្ខុក៏បានលះបង់ ដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយអត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាននូវកាមវិតក្កដែលកើតឡើង នូវព្យាបាទវិតក្កដែលកើតឡើង ។បេ។ នូវវិហិង្សាវិតក្កដែលកើតឡើង... អត់ធន់ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស បំផ្លាញនូវពួកអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនបន្ទោបង់ ( នូវវិតក្កណាមួយ ) ទេ អាសវៈទាំងឡាយដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះ បានបន្ទោបង់

( នូវវិតក្កណាមួយ ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយ ទាំងនោះ រមែងមិនមានដោយឧបាយយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយដែលត្រូវលះ ដោយការបន្ទោបង់ ភិក្ខុក៏បានលះដោយការបន្ទោបង់ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាសវៈទាំងឡាយដូចម្តេច ដែលត្រូវលះដោយការចម្រើន ភិក្ខុក៏បានលះបង់ដោយការចម្រើន ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាដោយឧបាយ ហើយចម្រើននូវសតិ-សម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវធម៌ជាគ្រឿងប្រាសចាករាគៈ អាស្រ័យធម៌ជាទីរលត់ទុក្ខ ជាធម៌បង្អោនទៅដើម្បីលះកិលេស ពិចារណាដោយឧបាយ ហើយចម្រើនធម្មវិចយសម្ពោជ្ឈង្គ ។បេ។ ចម្រើនវិរិយសម្ពោជ្ឈង្គ ចម្រើនបីតិសម្ពោជ្ឈង្គ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ចម្រើនសមាធិសម្ពោជ្ឈង្គ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យធម៌ជាទីប្រាសចាករាគៈ អាស្រ័យធម៌ជាទីរលត់ទុក្ខ ជាធម៌បង្អោនទៅដើម្បីលះកិលេស ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មិនចម្រើន ( សម្ពោជ្ឈង្គណាមួយ ) ទេ អាសវៈទាំងឡាយ ដែលជាគ្រឿងចង្អៀតចង្អល់ក្តៅក្រហាយ គប្បីកើតឡើងបាន បើភិក្ខុនោះបានចម្រើន ( សម្ពោជ្ឈង្គណាមួយ ) អាសវៈដែលជាគ្រឿងចង្អៀតចង្អល់ ក្តៅក្រហាយទាំងនោះ រមែងមិនមាន ដោយឧបាយយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាសវៈទាំងឡាយ ដែលត្រូវលះដោយការចម្រើន ភិក្ខុក៏បានលះបង់ដោយការចម្រើន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរទទួលវត្ថុដែលគេនាំមកបូជា គួរទទួលវត្ថុដែលគេរៀបទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរធ្វើនូវអញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

# អដ្ឋកថា

## អាសវសូត្រ

[ ៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាសវសូត្រទី ៤ ដូចតទៅនេះ បទថា **សំវរា បហាតព្វា** បានដល់ អាសវៈទាំងឡាយគប្បីលះបានដោយសំវរៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **បដិសង្ខា** គឺពិចារណា បានដល់ ជ្រាប អធិប្បាយថា ពិចារណា ។ បទថា **យោនិសោ** គឺដោយឧបាយ បានដល់ ដោយគន្លងម្យ៉ាងទៀត ក្នុងសូត្រនេះ ការពិចារណាទោស ក្នុងអសំវរៈ គប្បីជ្រាបថា ជាការពិចារណាដោយឧបាយ ឯការពិចារណានេះ គប្បីជ្រាបតាមអាទិត្តបរិយាយសូត្រ មានពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ចក្ខុន្ទ្រិយដែលបុគ្គលអាលដោយបន្ទះដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះរុងរោចន៍ សន្ធោសន្ធៅ ប្រសើរជាងការកាន់យកនិមិត្តដោយអនុព្យញ្ជនៈ ក្នុងរូបដែលបុគ្គលគប្បីដឹងដោយចក្ខុ មិនប្រសើរទេ ។

ក្នុងបទថា **ចក្ខុន្ទ្រិយសំវរសំវុតោ វិហរតិ** នេះ មានអធិប្បាយដូចតទៅនេះ ឥន្ទ្រិយ គឺចក្ខុ ឈ្មោះថា ចក្ខុន្ទ្រិយ ។ ឈ្មោះថា **សំវរ** ព្រោះសង្រួម មានអធិប្បាយថា ព្រោះបិទ គឺព្រោះរាំង ។ ពាក្យថា **សំវរ** នោះ ជាឈ្មោះរបស់សតិ ។ សំវរៈក្នុងចក្ខុន្ទ្រិយ ឈ្មោះថា **ចក្ខុន្ទ្រិយសំវរ** ចក្ខុន្ទ្រិយ-សំវរៈនេះ កាលជវនចិត្តកើតឡើង ក៏ហៅថា **ចក្ខុន្ទ្រិយសំវរ** ព្រោះហាមកិលេសទាំងឡាយ មិនឲ្យកើតឡើងក្នុងទ្វារនោះ ។ បទថា **សំវុតោ** បានដល់ ប្រកបដោយសំវរៈនោះ សេចក្តីពិតយ៉ាងនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឥមិនា ចាតិមោក្ខសំវរេន ឧបេតោ ហោតិ ។បេ។ សមន្នាគតោ** ដូច្នេះ ក្នុងវិភង្គថា **ចាតិមោក្ខសំវរសំវុតោ** ។ ម្យ៉ាងទៀត បទថា **សំវរ** ប្រែថា រាំងហើយ មានពាក្យអធិប្បាយថា រាំងហើយ គឺ បិទហើយ ។ បទថា **ចក្ខុន្ទ្រិយសំវរសំវុតោ** សេចក្តីថា រាំង មានពាក្យអធិប្បាយថា រាំង គឺបិទសន្ទះទ្វារ គឺសតិ ពោល គឺចក្ខុន្ទ្រិយសំវរៈត្រង់ចក្ខុទ្វារ ដូចបិទទ្វារត្រង់ទ្វារផ្ទះ ដូច្នោះ ។

អត្ថដូចពោលមកនេះឯង ក្នុងសូត្រនេះល្អជាង ។ ពិតហើយ អត្ថនេះឯងប្រាកដក្នុងបទនេះ គឺ **ចក្ខុន្ទ្រិយសំវរំ អសំវុតស្ស វិហរតោ សំវុតស្ស វិហរតោ** ប្រែថា ជាអ្នកមិនសង្រួមនូវឥន្ទ្រិយសំវរៈ គឺចក្ខុ ជាអ្នកសង្រួមនូវឥន្ទ្រិយ គឺចក្ខុ ក្នុងបទថា **យំ ហិស្ស** ជាដើម មានអធិប្បាយថា ភិក្ខុនោះមិនសង្រួម គឺមិនរាំង មិនបិទបាំងចក្ខុន្ទ្រិយសំវរៈណា ម្យ៉ាងទៀត **យេ**

អក្ខរៈ អាទេសជា **យំ** ក៏បាន ឯអត្ថក៏ស្មើគ្នានឹង **យេ អស្ស** ។

បទថា **អាសវា វិឃាតបរិឡាហា** សេចក្តីថា អាសវៈ ៤ យ៉ាង និងការក្តៅក្រហាយព្រោះកិលេស ឬក្តៅក្រហាយព្រោះវិបាក ដែលធ្វើការចង្អៀតចង្អល់ឲ្យដល់អ្នកដទៃ អធិប្បាយថា កាលភិក្ខុត្រេកអរ គឺរីករាយក្នុងឥដ្ឋារម្មណ៍ដែលមកកាន់គន្លង ក្នុងចក្ខុទ្វារដោយអំណាចការពេញចិត្តក្នុងខន្ធ កាមាសវៈរមែងកើតឡើង កាលភិក្ខុត្រេកអរដោយការប្រាថ្នាភពថា អញនឹងបានឥដ្ឋារម្មណ៍ ដូច្នេះ ក្នុងសុគតិភពដទៃ ភវាសវៈរមែងកើតឡើង កាលភិក្ខុប្រកាន់ថា សត្វ ឬថា របស់សត្វ ទិដ្ឋាសវៈរមែងកើតឡើង ។ ការមិនដឹងដែលកើតព្រមជាមួយអាសវៈទាំងអស់នោះឯង ឈ្មោះថា **អវិជ្ជាសវ** ។ អាសវៈ ៤ កើតឡើង ដូចពោលមកនេះឯង ។ កិលេសដទៃ ដែលសម្បយុត្តដោយអាសវៈទាំងនោះ ដែលមានការក្តៅក្រហាយ ដែលកើតអំពីការចង្អៀតចង្អល់ ឬវិបាករបស់កិលេសទាំងនោះក្នុងអនាគត លោកពោលថា គប្បីកើតឡើង ដល់ភិក្ខុដែលមិនសង្រួមចាកអាសវៈទាំងនោះ ។ បទថា **ឯវំស តេ** កាត់បទជា **ឯវំ អស្ស តេ** មានពាក្យអធិប្បាយថា មិនមានដោយឧបាយនេះ មិនមានដោយប្រការដទៃ ។

ក្នុងបទថា **បដិសង្ខាយោនិសោ សោតិន្ទ្រិយសំវរសំវុតោ** ជាដើម ក៏មានអត្ថដូចគ្នានេះឯង ។ បទថា **ឥមេ វុច្ចន្តិ អាសវា សំវរាបហាតព្វា** សេចក្តីថា អាសវៈ ២៤ យ៉ាង ដោយចែកម្យ៉ាងជា ៤ ក្នុងទ្វារទាំង ៦ នេះ

ព្រះមានព្រះភាគត្រាស់ថា គប្បីលះបានដោយសំវរៈ ពាក្យណាដែលគប្បីពោលក្នុងបទថា **បដិសង្ខា យោនិសោ ចីវរំ** ជាដើម ពាក្យទាំងអស់នោះបានពោលហើយក្នុងសីលកថា ក្នុងគម្ពីរវិសុទ្ធិមគ្គឯណោះ ។

បទថា **យំ ហិស្ស** សេចក្តីថា កាលភិក្ខុអង្គណាមួយមិនសេពបច្ច័យក្នុងបណ្តាចីវរប្បច្ច័យ និងបិណ្ឌបាតប្បច្ច័យជាដើមក្តី ។ បទថា **អប្បដិ-សេវតោ** បានដល់ មិនសេពដោយឧបាយប្រាជ្ញាយ៉ាងនេះ ។ ក្នុងទីនេះ កាលភិក្ខុប្រាថ្នាបច្ច័យ មានចីវរជាដើម ដែលមិនទាន់បាន ឬត្រេកអរក្នុងចីវរប្បច្ច័យជាដើមនោះដែលបានហើយ គប្បីជ្រាបថា កាមាសវៈកើតឡើង ។ កាលភិក្ខុត្រេកអរ ដោយការប្រាថ្នាភពថា អញនឹងបានបច្ច័យ ដូច្នេះ ក្នុងសុគតិភពដទៃ គប្បីជ្រាបថា ភវាសវៈកើតឡើង ។ កាលភិក្ខុតាំងអត្តសញ្ញាថា អញបាន អញមិនបាន ឬថា ចីវរនេះរបស់អញ គប្បីជ្រាបថា ទិដ្ឋាសវៈកើតឡើង ។ ឯអវិជ្ជាសវៈកើតព្រមជាមួយអាសវៈដទៃទាំងអស់ ការកើតឡើងនៃអាសវៈ ៤ ជាការបង្អៀតបង្អល់ និងការក្តៅក្រហាយ ដូចពណ៌នាមកនេះឯង គប្បីជ្រាបអាសវៈដោយការធ្វើវេទនាថ្មីឲ្យកើតឡើង ។

បទថា **ឥមេ វុច្ចន្តិ ភិក្ខវេ អាសវា បដិសេវនា បហាតព្វា** សេចក្តីថា អាសវៈទាំង ១៦ នេះ ដោយចែកចេញជា ៤ យ៉ាង ក្នុងមួយបច្ច័យ ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការពិចារណា ហើយសេពដែលហៅថា **ញាណសំវរ** នេះ ។

បទថា **បដិសង្ខា យោនិសោ ខមោ ហោតិ សីតស្ស** សេចក្តីថា ភិក្ខុពិចារណាដោយឧបាយ គឺដោយគន្លង ហើយរមែងជាអ្នកអត់ធន់ចំពោះរងា គឺរមែងសង្កត់ រមែងអត់ធន់នូវរងា បានដល់ មិនញាប់ញ័រ គឺមិនលះបង់កម្មដ្ឋានព្រោះរងាត្រឹមតែតិចតួច ដូចមនុស្សដែលទន់ខ្សោយ ។ ក្នុងការក្តៅជាដើម ក៏មានន័យនេះឯង ។ ក្នុងទីនេះ ពាក្យពោលនោះឯង គប្បីជ្រាបថាជាគន្លងនៃពាក្យ ។

ក្នុងបទថា **ទុក្ខានំ** ជាដើម មានអធិប្បាយថា វេទនា គប្បីជ្រាបថាជា ទុក្ខ ព្រោះអត្ថថា អត់ធន់បានលំបាក ជាវេទនាដ៏ខ្លាំងក្លា ព្រោះអត្ថថាច្រើន ជាវេទនារឹង ព្រោះអត្ថថា គ្រោតគ្រាត ជាវេទនាក្តៅ ព្រោះអត្ថថាឈឺចាប់ ជាវេទនាមិនសុខសម្រាន្ត ព្រោះវៀរចាកភាពគួរត្រេកអរ ជាវេទនាមិនគួរពេញចិត្ត ព្រោះមិនធ្វើចិត្តឲ្យចម្រើន ជាវេទនារុញច្រានទូវជីវិត ព្រោះអាចរុញច្រានជីវិតបាន ។ បទថា **យំ ហិស្ស** សេចក្តីថា កាលភិក្ខុនោះមិនអត់ធ្មត់ អារម្មណ៍ណាមួយ គឺធម៌ណាមួយ ក្នុងបណ្តារងាជាដើម ។ បទថា **អនធិវាសយតោ** គឺមិនអត់ធ្មត់ បានដល់ មិនអត់ធន់ ។ ចំណែកការកើតឡើងនៃអាសវៈក្នុងអធិការនេះ គប្បីជ្រាបដូចតទៅនេះ កាលភិក្ខុប៉ះនូវរងាប្រាថ្នានូវកម្តៅ កាមាសវៈរមែងកើតឡើង ក្នុងទីគ្រប់អន្ទើក៏យ៉ាងនេះ ។ កាលភិក្ខុប្រាថ្នាភពថា ក្នុងសុគតិភព មិនមានរងា ឬក្តៅ ភវាសវៈរមែងកើតឡើងការប្រកាន់ថា អញរងា អញក្តៅ ដូច្នេះ ជាទិដ្ឋាសវៈ ចំណែកអវិជ្ជាសវៈ

ប្រកបព្រមទឹងអាសវៈដែលពោលមកទាំងអស់នោះឯង ។ បទថា **ឥមេ វុច្ចន្តិ** សេចក្ដីថា អាសវៈទាំងនេះមានចំនួនច្រើន ដោយចែកតែម្យ៉ាង ក្នុងវេរាជាដើម ចែកចេញជា ៤ យ៉ាង ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការអត់ធ្មត់ ដែលហៅថា **ខន្តិសំវរ** នេះ ។

បទថា **បដិសង្ខា យោនិសោ ចណ្ឌហត្ថឹ បរិវជ្ជេតិ** សេចក្ដីថា ភិក្ខុ ពិចារណាដោយឧបាយ គឺដោយគន្លងយ៉ាងនេះថា អាត្មាអញ មិនគួរឈរក្នុង ទីជិតដំរីកាច ព្រោះថា គប្បីមានការស្លាប់ខ្លះ សេចក្ដីទុក្ខទៀបនឹងស្លាប់ខ្លះ ដែលមានហេតុមកអំពីការឈរក្នុងទីឆ្ងាយនោះ ដូច្នេះហើយ ចៀសវាងនូវដំរីកាច គឺថយក្រោយ ។ ក្នុងបទទាំងអស់ក៏មានន័យនេះឯង ។ បទថា **ចណ្ឌំ** បានដល់ ប្រទូស្ត គឺកាច ។ បទថា **ខាណុំ** បានដល់ ដង្គត់គគីរជាដើម ។ បទថា **កណ្ដកដ្ឋានំ** បានដល់ ឱកាសដែលបន្ទាមុត ។ បទថា **សោព្ភំ** បានដល់ ទីដែលដាច់ផ្លូវគ្រប់ទិស ។ បទថា **បបាតំ** បានដល់ ទីដែលដាច់ផ្លូវតែម្ខាង ។ បទថា **ចន្ទនិកំ** បានដល់ ទីដែលចោលទឹក និងមន្ទិលគគ្រិ ជាដើម ។ បទថា **ឱឡិគល្លំ** បានដល់ ជាទីឆ្ងាយនៃកពជាដើមទាំងនោះឯង ។ ទីទាំងនេះ ទោះបីជ្រៅស្មើក្បាលជង្គង់ ក៏ជាទីពេញទៅដោយរបស់មិនស្អាត ។ ស្ថានទីទាំង ២ នេះ ជាទីដែលមានអមនុស្សរស់នៅ ដូច្នោះ ទើបត្រូវវៀរ ។ ក្នុងបទថា **អនាសនេ** នេះ មានអធិប្បាយថា អាសនៈដែលមិនសមគួរ ឈ្មោះថា អនាសនៈ អាសនៈនោះ ដោយអត្ថគប្បីជ្រាបថា បានដល់ អាសនៈ

ដែលរក្សាទុកនៅក្នុងទីកំបាំង ដែលជាវត្ថុមិនពិតប្រាកដ ។ ក្នុងបទនេះថា **អគោចរេ** មានអត្ថថា គោចរមិនសមគួរ ឈ្មោះថា **អគោចរ** អគោចរនោះ មាន ៥ យ៉ាង មានកន្លែងរបស់ស្រីពេស្យាជាដើម ។ បទថា **ចាបកេ មិត្តេ** បានដល់ មិត្រដែលលាមក គឺមិត្រដែលទ្រុស្តសីល បានដល់ មិត្រក្លែងក្លាយ គឺបុគ្គលមិនមែនមិត្រ ។ បទថា **ចាបកេសុ** បានដល់ ថោកទាប ។ បទថា **ឱកប្បេយ្យុំ** គឺគប្បីជឿ បានដល់ គប្បីបង្អោនចិត្តជឿថា លោកដ៏មានអាយុ អង្គនេះបានធ្វើ ឬនឹងធ្វើពិត ។ បទថា **យំ ហិស្ស** សេចក្តីថា កាលភិក្ខុនោះ មិនបន្ទោបង់ អន្តរាយណាមួយ គឺអន្តរាយណាមួយ ក្នុងបណ្តាអន្តរាយ មានដំរីជាដើម ។ ឯការកើតឡើងនៃអាសវៈក្នុងទីនេះ គប្បីជ្រាបដូចតទៅនេះ កាលភិក្ខុជួបនូវទុក្ខ មានដំរីជាដើមជាហេតុប្រាថ្នាសុខ កាមាសវៈរមែងកើតឡើង កាលភិក្ខុប្រាថ្នាភពថា ទុក្ខ ដូច្នេះ មិនមានក្នុងសុគតិភព ភវាសវៈ រមែងកើតឡើង ការប្រកាន់ថា ដំរីជាន់អញ ដូច្នេះ ជាទិដ្ឋាសវៈ ។ អាសវៈដែលប្រកបព្រមជាមួយអាសវៈ ឈ្មោះថា អវិជ្ជាសវៈទាំងអស់នោះឯង ។ បទថា **ឥមេ វុច្ចន្តិ** សេចក្តីថា អាសវៈទាំងនេះមានច្រើនយ៉ាង ដោយបែកតែម្យ៉ាង ក្នុងបណ្តាអន្តរាយ មានដំរីជាដើម ដោយអំណាចបែកចេញជា ៤ ព្រះមានព្រះភាគត្រាស់ថា គប្បីលះដោយការគេចចេញ ពោលគឺសីលសំវរៈនេះ ។

បទថា **បដិសង្ខា យោនិសោ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ**

សេចក្ដីថា ភិក្ខុពិចារណាឃើញទោសក្នុងកាមវិតក្ក ដោយឧបាយប្រាជ្ញា ដោយន័យជាដើមថា វិតក្កនេះជាអកុសលព្រោះហេតុនេះ មានទោសព្រោះហេតុនេះ មានផលជាទុក្ខព្រោះហេតុនេះ វិតក្កនោះឯង រមែងប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនខ្លះ ដូច្នេះហើយ មិនបញ្ឈប់កាមវិតក្កដែលកើតឡើងក្នុងអារម្មណ៍នោះៗ អធិប្បាយថា លើកអារម្មណ៍ឡើងកាន់ចិត្តហើយបញ្ឈាមិនបាន ឬបង្គាប់ឲ្យនៅខាងក្នុងមិនបាន ។ សួរថា ភិក្ខុ កាលបញ្ឈប់មិនបាន តើធ្វើដូចម្ដេច ។ ឆ្លើយថា លះបង់ចោល ។ សួរថា លះបង់ដូចយកកំប្រោងដាក់សំរាមទៅចោលឬ ។ ឆ្លើយថា មិនមែនទេ ដោយពិតនោះ បន្ទោបង់ គឺចាក់ទម្លុះ នាំនូវកាមវិតក្កនោះចេញ សួរថា ចាក់ដូចយកជន្លួញចាក់គោដែលទឹមឬ ។ ឆ្លើយថា មិនមែនទេ ដោយពិតនោះ ធ្វើវិតក្កអកុសលនោះឲ្យអស់ គឺធ្វើឲ្យប្រាសចាកទៅជាទីបំផុត គឺទីបំផុតកាមវិតក្កនោះ នឹងមិនទៅសល់ ដោយហោច សូម្បីត្រឹមតែភង្គក្ខណៈ ដោយប្រការណា ធ្វើកាមវិតក្កនោះដោយប្រការនោះ ។

សួរថា ភិក្ខុធ្វើកាមវិតក្កនោះឲ្យទៅជាយ៉ាងនោះបានដូចម្ដេច ។ ឆ្លើយថា ធ្វើឲ្យដល់នូវការមិនមានតទៅ គឺឲ្យដល់នូវការមិនមានខាងក្រោយ បានដល់ធ្វើដោយប្រការដែលកាមវិតក្កត្រូវសង្កត់ដោយល្អ ដោយវិក្ខម្ភនបហាន ។ ក្នុងវិតក្ក ២ យ៉ាងដ៏សេស ក៏មានន័យនេះឯង ។ បទថា **ឧប្បន្នុប្បន្នេ** បានដល់ វិតក្កដែលកើតឡើងហើយកើតឡើងទៀត មានពាក្យអធិប្បាយថា ដែលត្រឹមតែកើតឡើងប៉ុណ្ណោះ ម្យ៉ាងទៀត មានពាក្យអធិប្បាយថា បន្ទោបង់

វិតក្ក ដែលកើតឡើងតែម្តង ហើយមិនកើចកន្ត្រាក់ក្នុងគ្រាទី ២ បានដល់ បន្ទោបង់វិតក្កដែលកើតឡើងហើយកើតឡើងទៀត ទាំង ៧ ដងនោះឯង ។ បទថា **ចាបកេ អកុសលេ ធម្មេ** បានដល់ វិតក្កទាំងឡាយ មានកាមវិតក្ក ជាដើមទាំងនោះឯង ឬមហាវិតក្កទាំង ៩ ប្រភេទ ។

បណ្តាវិតក្កទាំង ៩ នោះ វិតក្ក ៣ យ៉ាង ព្រះមានព្រះភាគត្រាស់ ហើយ ឯវិតក្ក ៦ យ៉ាងដ៏សេស គឺញាតិវិតក្ក ១ ជនបទវិតក្ក ១ អមរ-វិតក្ក គឺត្រិះរិះដល់ទេវតា ១ វិតក្កដែលទាក់ទងដោយការអាណិតអាសូរអ្នកដទៃ ១ វិតក្កដែលទាក់ទងដោយលាភសក្ការៈ និងពាក្យសរសើរ ១ វិតក្ក ដែលទាក់ទងដោយការមិនមើលងាយ ១ ។ បទថា **យំ ហិស្ស** សេចក្តីថា កាលភិក្ខុនោះមិនបន្ទោបង់វិតក្កណាមួយ ក្នុងបណ្តាវិតក្កទាំងនេះ ។ ម្យ៉ាង ទៀត ក្នុងទីនេះ កាមវិតក្ក គឺកាមាសវៈនោះឯង វិតក្កក្រៅអំពីកាមវិតក្កនោះ ចាត់ជាភវាសវៈ វិតក្កដែលសម្បយុត្តដោយភវាសវៈនោះ ចាត់ជាទិដ្ឋាសវៈ អវិជ្ជាក្នុងវិតក្កទាំងអស់ ចាត់ជាអវិជ្ជាសវៈ គប្បីជ្រាបការកើតឡើងនៃអាសវៈ ដូចពណ៌នាមកនេះឯង ។ បទថា **ឥមេ វុច្ចន្តិ** សេចក្តីថា អាសវៈទាំងនេះ មានប្រការដូចពោលហើយ ដោយអំណាចកាមវិតក្កជាដើម ព្រះមានព្រះភាគ ត្រាស់ថា គប្បីលះដោយការបន្ទោបង់ គឺវិរិយៈ ប្រកបដោយការពិចារណា ឃើញទោសក្នុងវិតក្កនោះៗ ។

បទថា **បដិសង្ខា យោនិសោ សតិសម្ពោជ្ឈង្គំ ភាវេតិ** សេចក្តីថា

ភិក្ខុពិចារណាឃើញទោស ក្នុងការមិនមានភាវនា និងអានិសង្សក្នុងការភាវនា ដោយឧបាយ គឺដោយគន្ធង ហើយចម្រើនសតិសម្ពោជ្ឈង្គ ។ ក្នុងបទទាំងអស់ ក៏មានន័យដូច្នេះ ។ ការចម្រើនពោជ្ឈង្គទាំងឡាយនេះ បានអធិប្បាយពិស្តារ ហើយ ខាងដើមនោះឯង ។ បទថា **យំ ហិស្ស** សេចក្តីថា កាលភិក្ខុនោះ មិនចម្រើនពោជ្ឈង្គណាមួយ ក្នុងបណ្តាពោជ្ឈង្គទាំងនេះ ក្នុងការកើតអាសវៈ ឡើងក្នុងទីនេះ គប្បីជ្រាបន័យដូច្នេះថា អាសវៈពួកណា មានកាមាសវៈជា ដើម ដែលគប្បីកើតឡើង ព្រោះមិនបានចម្រើនពោជ្ឈង្គទាំងឡាយ ដែល សម្បយុត្តដោយអរិយមគ្គទាំងឡាយនេះ អាសវៈទាំងនោះ រមែងមិនមានដល់ បុគ្គលដែលចម្រើនពោជ្ឈង្គយ៉ាងនេះ ។ បទថា **ឥមេ វុច្ចន្តិ** សេចក្តីថា អាសវៈទាំងឡាយ មានកាមាសវៈជាដើមនេះឯង ព្រះមានព្រះភាគត្រាស់ថា លះបានដោយការចម្រើនពោជ្ឈង្គ ដែលជាលោកុត្តរនេះ ។ល។

## អដ្ឋកថាអាសវសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ទារុកម្មិកសូត្រទី ៨

[ ៥៩ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ ដែលធ្វើអំពីឥដ្ឋ ក្នុងនាទិកគ្រាម ។ គ្រានោះឯង គហបតីឈ្មោះទារុកម្មិកៈ បាន ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មាន ព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះទារុកម្មិកគហបតី អង្គុយក្នុងទីសមគួរ ហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតី ចុះទាន ក្នុងត្រកូលអ្នកតែងឲ្យដែរឬ ។ ទារុកម្មិកគហបតីក្រាបបង្គំទូលថា បពិត្រព្រះ អង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គតែងឲ្យ បពិត្រព្រះអង្គដ៏ចម្រើន តែថា ទាននោះ ខ្ញុំព្រះអង្គឲ្យចំពោះតែពួកភិក្ខុ ដែលជាអ្នកប្រព្រឹត្តអារញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបង្សុកូលិកធុតង្គ ជាព្រះអរហន្ត ឬភិក្ខុដែល ដល់នូវអរហត្តមគ្គប៉ុណ្ណោះ ។ ម្នាលគហបតី ខ្លួនអ្នកជាគ្រហស្ថ ជាអ្នក បរិភោគកាមនៅគ្រប់គ្រងដំណេកដ៏ចង្អៀតដោយកូនប្រពន្ធ ប្រើប្រាស់នូវខ្លឹម ចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាប ត្រេកអរនូវមាស និងប្រាក់ កម្រនឹងដឹងហេតុនេះថា ភិក្ខុទាំងនេះ ជាព្រះអរហន្ត ឬភិក្ខុទាំងនេះ បានដល់នូវអរហត្តមគ្គដូច្នេះបានឡើយ ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្ត អារញ្ញិកធុតង្គ ប៉ុន្តែមានចិត្តរាយមាយ ជាអ្នកលើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្តីផ្តេសផ្តាស ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ មិន មានចិត្តតាំងមាំ មានចិត្តវិលវល់ មានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ

ភិក្ខុនោះ គួរគេតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុ អ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ជាអ្នកមិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានវាចាផ្តេសផ្តាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មានចិត្តមូលតែមួយ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តន៍គេ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុទទួលនិមន្តន៍គេ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបង្សុកូលិកធុតង្គ

ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀល ដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបង្សុកូលិកធុតង្គ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរ ដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទ្រទ្រង់នូវគហបតីចីវរ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ជាអ្នកលើកកម្ពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្តីផ្តេសផ្តាស ជាអ្នកភ្លេចភ្លាំងស្មារតី មិនមានសម្បជញ្ញៈ មានចិត្តមិនខ្ជាប់ខ្ជួន មានចិត្តវិលវល់ មានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ ភិក្ខុនោះ គួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទ្រទ្រង់នូវគហបតីចីវរ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ មិនលើកកម្ពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្តីផ្តេសផ្តាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតម្កល់មាំ មានចិត្តមូលតែមួយ ជាអ្នកសង្រួមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរសរសើរដោយហេតុនោះបាន ។ ម្នាលគហបតី អញ្ជើញអ្នកឲ្យទានចំពោះសង្ឃវិញ កាលបើអ្នកឲ្យទានចំពោះសង្ឃហើយ ចិត្តរមែងជ្រះថ្លា លុះអ្នកនោះមានចិត្តជ្រះថ្លាហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ឧគ្គគហបតី ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គនឹងឯង នឹងឲ្យទានចំពោះសង្ឃវិញ ។

# អដ្ឋកថា

## ទារុកម្មិកសូត្រ

[ ៥៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទារុកម្មិកសូត្រទី ៥ ដូចតទៅនេះ បទថា **ទារុកម្មិកោ** បានដល់ ឧបាសកម្នាក់មានមុខរបរលក់អុស ។ បទថា **កាសិកចន្ទនំ** បានដល់ លម្អិតចន្ទន៍ដែលល្អិត ។ បទថា **អគ្គេន** បានដល់ ដោយអង្គមិនជាគុណ គឺដោយអង្គដែលជាគុណខាងសុក្កធម៌ ។ បទថា **នេមន្តនិកោ** បានដល់ ជាអ្នកទទួលនិមន្តន៍ ។ បទថា **សង្ឃេ ទានានិ ទស្សាមិ** គឺខ្ញុំព្រះអង្គនឹងប្រគេនដល់ភិក្ខុសង្ឃ ។ ឧបាសកនោះ កាលក្រាបទូលយ៉ាងនោះហើយ ក៏ថ្វាយបង្គំព្រះសាស្ដា ហើយចៀសចេញទៅ ក្នុងកាលតមក ភិក្ខុជាកុលុបកៈរបស់គាត់ ៥០០ រូប បានដល់នូវភាពជាគ្រហស្ថ គឺសឹក ។ ភិក្ខុដែលជាកុលុបកៈនោះ ឃើញឧបាសកក៏ប្រាប់ថា ភិក្ខុទាំងនោះសឹកអស់ហើយ ក៏ពោលថា ពួកអាត្មាក្នុងទីនេះសឹកអស់ឬ ដូច្នេះហើយ ធ្វើចិត្តឲ្យជាកណ្ដាលមិនបាន ព្រះសាស្ដាទ្រង់សំដៅយកហេតុនេះ ទើបត្រាស់ថា កាលអ្នកថ្វាយទានក្នុងសង្ឃ ចិត្តនឹងជូរផង់ ដូច្នេះ ។ល។

**អដ្ឋកថា ទារុកម្មិកសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ចិត្តហត្ថិសារិបុត្តសូត្រទី ៦

[ ៦០ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ សម័យនោះឯង ពួកភិក្ខុជាថេរៈច្រើនរូប ត្រឡប់អំពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ហើយអង្គុយប្រជុំគ្នានិយាយអភិធម្មកថា ក្នុងរោងមូល ( ឧបដ្ឋានសាលា ) ។ បានឮថា បណ្តាពួកភិក្ខុទាំងនោះ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ កាលដែលពួកភិក្ខុជាថេរៈ កំពុងនិយាយអភិធម្មកថា ក៏និយាយស្កាត់ពាក្យក្នុងចន្លោះៗ ។ លំដាប់នោះ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បាននិយាយឃាត់ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ យ៉ាងនេះថា ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ កាលដែលពួកភិក្ខុជាថេរៈ កំពុងនិយាយអភិធម្មកថា ចេះតែនិយាយស្កាត់ពាក្យក្នុងចន្លោះៗ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ សូមបង្អង់ចាំចប់អភិធម្មកថាសិន ។ កាលបើព្រះមហាកោដ្ឋិកៈដ៏មានអាយុនិយាយឃាត់យ៉ាងនេះហើយ ពួកភិក្ខុជាសម្លាញ់ របស់ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ ក៏បាននិយាយនឹងព្រះមហាកោដ្ឋិកៈដ៏មានអាយុ យ៉ាងនេះថា ព្រះមហាកោដ្ឋិកៈដ៏មានអាយុ មិនសមបើហាមឃាត់ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុសោះ ( ព្រោះ ) ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុជាអ្នកប្រាជ្ញ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ អាចសម្តែងអភិធម្មកថា ជាមួយនឹងពួកភិក្ខុជាថេរៈបាន ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បាននិយាយថា ម្នាលអាវុសោទាំងឡាយ ពួកជនដែលមិនដឹងនូវវារៈនៃចិត្តរបស់ជនដទៃ កម្រនឹងដឹងហេតុនោះបាន ។

ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ កាលនៅអាស្រ័យនឹងគ្រូ ឬសព្រហ្មចារី គួរជាទីគោរពណាមួយនៅឡើយ រមែងជាអ្នកស្លូតបូតណាស់ ជាអ្នកសភាពរាបទាបណាស់ ជាអ្នកស្រគត់ស្រគំណាស់ ។ លុះកាលណាភិក្ខុនោះ ចេញអំពីគ្រូ ចេញអំពីពួកសព្រហ្មចារី គួរជាទីគោរព ភិក្ខុនោះ ក៏ត្រឡប់ជានៅច្របូកច្របល់ ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា ពួកអាមាត្យធំនៃព្រះរាជា ពួកតិត្ថិយ នឹងពួកសាវកនៃតិត្ថិយវិញ កាលដែលភិក្ខុនោះ នៅច្របូកច្របល់ លះបង់ ( មារយាទល្អ ) មានឥន្ទ្រិយជាប្រក្រតី គឺមិនសង្រួមឥន្ទ្រិយ ខ្វល់ខ្វាយតែនិយាយពាក្យឆ្ងើយឆ្ងង រាគៈក៏គ្របសង្កត់ចិត្ត លុះភិក្ខុនោះ ត្រូវរាគៈគ្របសង្កត់ចិត្តហើយ រមែងលាទូវសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាគោ ( ល្មោភ ) ស៊ីសំណាប គេចងទុកដោយខ្សែ ឬគេក្រៀកទុកក្នុងក្រោល ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា គោ ( ល្មោភ ) ស៊ីសំណាបនេះ មុខជាមិនហ៊ានចុះ ( ស៊ី ) សំណាប ក្នុងកាលឥឡូវនេះទៀតឡើយ អើ អាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមានត្រង់ដែលគោល្មោភស៊ីសំណាបនោះ មុខជាផ្តាច់ខ្សែ ឬទម្លាយក្រោល ហើយចុះ ( ស៊ី ) សំណាប ក្នុងកាលជាខាងក្រោយវិញទៀត ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោ

ទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ កាលនៅអាស្រ័យនឹងគ្រូ ឬសព្រហ្មចារី គួរជាទីគោរពណាមួយនៅឡើយ រមែងជាអ្នកស្ងួតបូតណាស់ ជាអ្នកសុភាពរាបទាបណាស់ ជាអ្នកស្រគត់ស្រគំណាស់ ។ លុះកាលណា ភិក្ខុនោះ ចេញអំពីគ្រូ ចេញអំពីពួកសព្រហ្មចារី គួរជាទីគោរព ភិក្ខុនោះ ក៏ត្រឡប់ជានៅច្របូកច្របល់ ដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ព្រះរាជា អាមាត្យធំរបស់ព្រះរាជា ពួកតិរ្ថិយ នឹងសាវកនៃតិរ្ថិយវិញ កាល ដែលភិក្ខុនោះ នៅច្របូកច្របល់ លះបង់មារយាទល្អ មានឥន្ទ្រិយជាប្រក្រតី ខ្វល់ខ្វាយ តែនិយាយពាក្យឆ្លើយឆ្លង រាគៈក៏គ្របសង្កត់ចិត្ត លុះភិក្ខុនោះ ត្រូវ រាគៈគ្របសង្កត់ចិត្តហើយ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាប វិញ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ស្ងប់ស្ងាត់ ចាកកាមទាំងឡាយ ។បេ។ បានចូលកាន់បឋមជ្ឈាន បុគ្គលនោះគិតថា អញ ជាអ្នកបានបឋមជ្ឈាន ដូច្នេះហើយ នៅច្របូកច្របល់ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោ ទាំងឡាយ ដូចភ្លៀងមានតំណក់ទឹកធំៗ បង្អុរចុះមកក្នុងផ្លូវធំ ៤ បំបាត់បង់ នូវធូលី ធ្វើភក់ឲ្យកើតប្រាកដឡើង ម្នាលអាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា ធូលីនឹងមិនមាន ប្រាកដក្នុងផ្លូវធំ ៤ ឯណោះ ក្នុង កាលឥឡូវនេះទៀតឡើយ អើអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាម

ហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមាន គឺពួកមនុស្សគន់ដើរកាត់ ឬពួកគោ និងសត្វចិញ្ចឹមដើរកាត់ ខ្យល់ ឬកម្ដៅថ្ងៃ គង់បក់ផាត់ថែងចាំងឲ្យរីងខះបាន ក្នុងផ្លូវធំ ៤ ឯណោះ កាលបើដូច្នេះ ធូលី និងកើតមានប្រាកដវិញ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានចូលកាន់បឋមជ្ឈាន បុគ្គលនោះគិតថា អញជាអ្នកបានបឋមជ្ឈានដូច្នេះ ហើយនៅប្រឡូកប្រឡល់ ដោយពួកភិក្ខុ ។បេ។ រមែងលាខ្លួនសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ ។បេ។ បានចូលកាន់ទុតិយជ្ឈាន បុគ្គលនោះ គិតថា អញជាអ្នកបានទុតិយជ្ឈាន ដូច្នេះហើយ នៅប្រឡូកប្រឡល់ ដោយពួកភិក្ខុ ។បេ។ រមែងលាខ្លួនសិក្ខា វិលត្រឡប់ទៅកាន់ភេទដ៏ថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាស្រះមួយធំជិតស្រុក ឬនិគម ជួនជាភ្លៀងដែលមានតំណក់ទឹកធំៗ ក៏បង្អុរចុះមកក្នុងស្រះនោះ ញាំងខ្យង គ្រំ ក្រួស និងអំបែងឲ្យសាបសូន្យទៅ ម្នាលអាវុសោទាំងឡាយ បើបុគ្គលណាគប្បីនិយាយយ៉ាងនេះថា ខ្យង គ្រំ ឬក្រួសអំបែង នឹងមិនមានប្រាកដ ក្នុងស្រះឯណោះ ក្នុងកាលឥឡូវនេះទៀតទេ ម្នាលអាវុសោទាំងឡាយ តើបុគ្គលនោះឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោមិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនោះ រមែងមាន គឺពួក

មនុស្សគេផឹក ឬពួកគោ និងពពែគេផឹក ខ្យល់ ឬកម្តៅថ្ងៃ គង់បក់ផាត់ចែង ចាំង ឲ្យរីងខះទៅបាន ក្នុងស្រះនោះ កាលបើដូច្នេះ ខ្យង គ្រុំក្តី ក្រួស និង អំបែងក្តី នឹងមានប្រាកដឡើងវិញ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះរម្ងាប់ នូវវិតក្ក និងវិចារៈ ។បេ។ បានចូលកាន់ទុតិយជ្ឈាន បុគ្គលនោះ គិតថា អញ ជាអ្នកបាននូវទុតិយជ្ឈាន ដូច្នេះហើយ នៅច្របូកច្របល់ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះប្រាសចាកបីតិផង ។បេ។ បានចូលកាន់តតិយជ្ឈាន បុគ្គលនោះគិតថា អញជាអ្នកបាននូវតតិយជ្ឈានដូច្នេះ ហើយនៅច្របូកច្របល់ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចបុរសដែលធ្លាប់ បរិភោគភោជនដ៏ថ្លៃថ្លាហើយ រមែងមិនគាប់ចិត្តនឹងភោជនដែលផ្អូម ម្នាល អាវុសោទាំងឡាយ បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថា បុរសឯណោះ នឹងមិនគាប់ចិត្តចំពោះភោជនថ្មីទៀតឡើយ ម្នាលអាវុសោទាំងឡាយ តើបុគ្គល នោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា បុរសឯណោះ មិនធ្លាប់បរិភោគ ភោជនដ៏ថ្លៃថ្លាហើយ បើឱជារសរបស់ភោជនដ៏ថ្លៃថ្លានោះ នឹងឋិតនៅក្នុងកាយ ត្រឹមណា ក៏នឹងមិនគាប់ចិត្ត ចំពោះភោជនដទៃ ត្រឹមណោះ លុះកាលណា

ឱជារសនៃគោជនដ៏ថ្លៃថ្លានោះ សាបសូន្យទៅ ទើបនឹងគាប់ចិត្តចំពោះគោជនថ្មីទៀតបាន ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំង-ឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះប្រាសចាកបីតិផង ។បេ។ បានចូលកាន់តតិយជ្ឈាន បុគ្គលនោះ គិតថា អញជាអ្នកបាននូវតតិយជ្ឈានដូច្នេះហើយ នៅប្រឫកប្រឫលដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ បានចូលកាន់ចតុត្ថជ្ឈាន បុគ្គលនោះគិតថា អញជាអ្នកបាននូវចតុត្ថជ្ឈាន ដូច្នេះហើយ នៅប្រឫកប្រឫលដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាអន្លង់ទឹកក្នុងចន្លោះភ្នំ ជាអន្លង់ទឹកប្រាសចាកខ្យល់ ប្រាសចាករលក បើបុគ្គលណា គប្បីនិយាយយ៉ាងនេះថាឥឡូវនេះ រលកនឹងមិនមានប្រាកដ ក្នុងអន្លង់ទឹកឯណោះទៀតទេ ម្នាលអាវុសោទាំងឡាយ តើបុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមាន គឺខ្យល់ព្យុះដ៏ខ្លាំងណាបក់ផាត់មកអំពីទិសខាងកើត ខ្យល់ព្យុះដ៏ខ្លាំងនោះ គង់ធ្វើរលកឲ្យកើត មានក្នុងអន្លង់ទឹកនោះបាន ខ្យល់ព្យុះដ៏ខ្លាំងណាបក់ផាត់មកអំពីទិសខាងលិច ។បេ។ ខ្យល់ព្យុះដ៏ខ្លាំងណាបក់ផាត់មក អំពីទិសខាងជើង ខ្យល់ព្យុះដ៏ខ្លាំងណា បក់ផាត់មកអំពីទិសខាងត្បូង ខ្យល់ព្យុះ

ដ៏ខ្លាំងនោះ គង់ធ្វើឲ្យរលកកើតមានក្នុងអន្លង់ទឹកនោះបាន ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ បានចូលកាន់ចតុត្ថជ្ឈាន បុគ្គលនោះគិតថា អញជាអ្នកបាននូវចតុត្ថជ្ឈាន ដូច្នេះហើយ នៅប្រឡូកប្រឡល់ដោយពួកភិក្ខុ ។បេ។ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលខ្លះក្នុងលោកនេះ ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង បានចូលកាន់ចេតោសមាធិ ដែលមិនមាននិមិត្ត បុគ្គលនោះគិតថា អញជាអ្នកបាននូវចេតោសមាធិ ដែលមិនមាននិមិត្ត ដូច្នេះហើយ នៅប្រឡូកប្រឡល់ដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ព្រះរាជា អាមាត្យធំរបស់ព្រះរាជា ពួកតិរ្ថិយ និងសាវ័កនៃតិរ្ថិយ កាលបើបុគ្គលនោះ នៅប្រឡូកប្រឡល់ លះបង់ ( មារយាទល្អ ) មានឥន្ទ្រិយជាប្រក្រតី ខ្វល់ខ្វាយតែខាងនិយាយពាក្យឆ្វើយឆ្វង រាគៈរមែងគ្របសង្កត់ចិត្តលុះបុគ្គលនោះ ត្រូវរាគៈគ្របសង្កត់ចិត្តហើយ រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលអាវុសោទាំងឡាយ ដូចជាព្រះរាជាក្តី អាមាត្យធំរបស់ព្រះរាជាក្តី ដើរទៅកាន់ផ្លូវឆ្ងាយ ដោយចតុរង្គសេនា ហើយចូលទៅស្នាក់នៅក្នុងដងព្រៃណាមួយ អស់រាត្រី ១ សំឡេងគគ្រឹកគគ្រេង ដោយសូរដំរី សូរសេះ សូររថ សូរពលថ្មើរជើង សូរគងរំពងនៃស្គរធំ ស្គរតូច ស័ង្ខ និងពិណក៏បាត់សូន្យទៅក្នុងដងព្រៃនោះ បើបុគ្គលណាគប្បីនិយាយយ៉ាង

នេះថា ឥឡូវនេះ សំឡេងកងរំពងនឹងមិនមានប្រាកដ ក្នុងដងព្រៃឯណោះទៀតឡើយ ម្នាលអាវុសោទាំងឡាយ បុគ្គលនោះ ឈ្មោះថា គប្បីនិយាយសមតាមហេតុឬទេ ។ ពួកភិក្ខុតបថា ម្នាលអាវុសោ មិនសមតាមហេតុទេ ម្នាលអាវុសោ ព្រោះថា ហេតុនុ៎ះ រមែងមាន គឺស្ដេចនោះក្ដី អាមាត្យធំរបស់ស្ដេចនោះក្ដី មុខជាចេញចាកដងព្រៃនោះទៅ វេលានោះ សំឡេងគគ្រឹកគគ្រេងគងមាន ប្រាកដឡើងវិញ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ក៏យ៉ាងនោះដែរ ព្រោះមិនបានធ្វើទុកក្នុងចិត្តនូវនិមិត្តទាំងពួង បានចូលកាន់ចេតោសមាធិ ដែលមិនមាននិមិត្ត បុគ្គលនោះគិតថា អញជាអ្នកបាននូវចេតោសមាធិ ដែលមិនមាននិមិត្ត ដូច្នេះហើយ នៅច្របូកច្របល់ដោយពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ព្រះរាជា អាមាត្យធំរបស់ព្រះរាជា ពួកតិរ្ថិយ និងសាវកនៃតិរ្ថិយវិញ កាលដែលបុគ្គលនោះ នៅច្របូកច្របល់ លះបង់ ( មារយាទល្អ ) មានឥន្ទ្រិយជាប្រក្រតីខ្វល់ខ្វាយតែខាងនិយាយពាក្យផ្ដេសផ្ដាស រាគៈរមែងគ្របសង្កត់ចិត្ត លុះបុគ្គលនោះត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏រមែងលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ គ្រាសម័យជាខាងក្រោយមក ចិត្តហត្ថិសារីបុត្តដ៏មានអាយុ បានលានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ លំដាប់នោះ ពួកភិក្ខុជាសម្លាញ់របស់ចិត្តហត្ថិសារីបុត្ត បានចូលទៅរកព្រះមហាកោដ្ឋិកៈដ៏មានអាយុ លុះចូលទៅដល់ហើយ បានសួរព្រះមហាកោដ្ឋិកៈដ៏មានអាយុ យ៉ាងនេះថា

ព្រះមហាកោដ្ឋិកៈដ៏មានអាយុ បានស្ទង់មើលចិត្តរបស់ចិត្តហត្ថិសារីបុត្តដោយចិត្តរបស់ខ្លួនហើយ ដឹងច្បាស់ថា ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារ-សមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាកទាបវិញដូច្នេះឬ ឬក៏ពួកទេវតា ប្រាប់សេចក្តីនុ៎ះថា បពិត្រព្រះករុណាដ៏ចម្រើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ព្រះមហាកោដ្ឋិកៈដ៏មានអាយុ តបថា ម្នាលអាវុសោ ខ្ញុំបានស្ទង់មើលចិត្ត ( របស់ចិត្តហត្ថិសារីបុត្ត ) ដោយចិត្តរបស់ខ្លួនហើយដឹងច្បាស់ថា ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ទាំងពួកទេវតា ក៏បានប្រាប់សេចក្តីនេះដល់ខ្ញុំថា បពិត្រព្រះករុណាដ៏ចម្រើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយនេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លានូវសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ លំដាប់នោះ ពួកភិក្ខុជាសម្លាញ់របស់ចិត្តហត្ថិសារីបុត្ត បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរស្រេចហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ចិត្តហត្ថិសារីបុត្ត ជាអ្នកបាននូវវិហារសមាបត្តិទាំងឡាយ

នេះផង នេះផង តែបើទុកជាដូច្នោះ ក៏គង់លាទូវសិក្ខា វិលត្រឡប់ទៅកាន់ភេទជាគ្រហស្ថវិញ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចិត្តហត្ថិសារីបុត្ត មិនយូរប៉ុន្មានទេ គង់នឹករឭកដល់នេក្ខម្មគុណវិញ ។ គ្រានោះឯង ចិត្តហត្ថិសារីបុត្ត មិនយូរប៉ុន្មាន ក៏បានកោរសក់ កោរពុកមាត់ ស្លៀកដណ្តប់សំពត់កាសាវៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ លំដាប់នោះ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ ចៀសចេញចាកពួកទៅនៅតែម្នាក់ឯង មិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតបំផ្លាញកិលេស មានចិត្តស្ទុងទៅកាន់ព្រះនិព្វានពួកកុលបុត្ត ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់សម្រេចនូវអនុត្តរធម៌ ដែលមានព្រហ្មចរិយធម៌ជាទីបំផុតនោះ ដោយប្រាជ្ញាដ៏ឧត្តមរបស់ខ្លួនឯង ក្នុងបច្ចុប្បន្ន ដ៏បានដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញ បានប្រព្រឹត្តចប់ហើយ សោឡសកិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីសោឡសកិច្ចនេះមិនមានឡើយ ។ មានសេចក្តីសរសើរថា បណ្តាព្រះអរហន្តទាំងឡាយ ព្រះចិត្តហត្ថិសារីបុត្តដ៏មានអាយុ រាប់ថាជាព្រះអរហន្ត ១ អង្គដែរ ។

# អដ្ឋកថា

## ចិត្តហត្ថិសារិបុត្តសូត្រ

[ ៦០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្តហត្ថិសារិបុត្តសូត្រទី ៦ ដូចតទៅនេះ បទថា **អភិធម្មកថំ** បានដល់ កថាលាយដោយអភិធម្ម ។ បទថា **កថំ ឱបាតេតិ** សេចក្តីថា ព្រះចិត្តហត្ថិសារីបុត្រពោលពាក្យរបស់ខ្លួន កាត់នូវពាក្យរបស់ភិក្ខុទាំងនោះ ។ បទថា **ថេរានំ ភិក្ខូនំ** ជាឆដ្ឋីវិភត្តិ មិនមែនក្នុងអត្ថនៃតតិយាវិភត្តិឡើយ ។ មានអត្ថថា ជាមួយភិក្ខុទាំងឡាយដែលជាថេរៈម្យ៉ាងទៀត មានអត្ថថា អភិធម្មកថារបស់ព្រះថេរៈទាំងឡាយណា សូម្បីព្រះចិត្តហត្ថិសារីបុត្រក៏អាចពោលអភិធម្មកថានេះបាន ។ បទថា **ចេតោបរិយាយំ** បានដល់ វារចិត្ត ។ បទថា **ឥធ** គឺក្នុងលោកនេះ ។ បទថា **សោរត-សោរតោ** គឺជាអ្នកស្ងប់រម្ងាប់ ដូចបុគ្គលអ្នកស្ងប់រម្ងាប់ អធិប្បាយថា ប្រៀបដូចបុគ្គលដែលប្រកបដោយសេចក្តីស្ងប់ស្ងៀម ។ បទថា **និវាតនិវាតោ** គឺជាអ្នកបន្ទាបខ្លួន ដូចបុគ្គលអ្នកបន្ទាបខ្លួន អធិប្បាយថា ប្រៀបដូចបុគ្គលដែលប្រព្រឹត្តឱនលំទោន ។ បទថា **ឧបសន្តុបសន្តោ** គឺជាអ្នកស្ងប់ ដូចបុគ្គលស្ងប់ ។

បទថា **វបកស្សតេវ សត្ថារា** បានដល់ ចៀសចេញទៅអំពីសម្នាក់ព្រះសាស្តា ។ បទថា **សំសដ្ឋស្ស** បានដល់ ប្រឡូកប្រឡំ ដោយការប្រឡូកប្រឡំ ៥ យ៉ាង ។ បទថា **វិស្សដ្ឋស្ស** បានដល់ ត្រូវលែង គឺលះបង់ ។ បទថា **ចាកដស្ស** បានដល់ មានឥន្ទ្រិយប្រាកដ ។ បទថា **ភិជ្ជាតោ** បានដល់ ស៊ីនូវសំណាប ។ បទថា **អន្តរធាយេយ្យ** បានដល់ គប្បីឲ្យវិនាស ។

បទថា **គោបស្ស** បានដល់ គោ និងពពែ ។ បទថា **សិប្បិសម្ពុកំ** បានដល់ ខ្យង និងគ្រុំ ។ បទថា **សក្ខរកឋលំ** បានដល់ ដុំក្រួស និងអំបែង ។ បទថា **អភិទោសិកំ** បានដល់ របស់បរិភោគ ផ្សំដោយស្ងោគែលលក ដែលមានទោសប្រាកដហើយ ។ បទថា **ឆឌ្ឌានេយ្យ** គឺមិនគាប់ចិត្ត ។ បទទុតិយាវិភត្តិថា **បុរិសំ ភុត្តាវី** នុ៎ះ ក្នុងសូត្រនោះ បទនោះ គប្បីឃើញថាប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ បទថា **អមុញ្ញាវុសោ បុរិសំ** សេចក្តីថា នៃអាវុសោបុរសនោះ ។

បទថា **សព្វនិមិត្តានំ** បានដល់ និមិត្តថាទៀងទាំងពួង ។ បទថា **អនិមិត្តំ ចេតោសមាធឹ** បានដល់ សមាធិក្នុងវិបស្សនាដែលមានកម្លាំង ។ បទថា **ចីរិឡិកាសទ្ទោ**(១) បានដល់ សំឡេងចង្រិត ។ បទថា **សរិស្សតិ នេក្ខម្មស្ស** បានដល់ រឭកដល់គុណរបស់បព្វជ្ជា ។ បទថា **អរហតំ អហោសិ** បានដល់ បានជាព្រះអរហន្តមួយអង្គ ក្នុងរវាងព្រះអរហន្តដែលជាសាវ័ករបស់ព្រះមានព្រះភាគ ។

ពិតហើយ ព្រះថេរៈនេះជាគ្រហស្ថ ៧ ដង បួស ៧ ដង ។ ព្រោះហេតុអ្វី បានឮថា ក្នុងសម័យព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ លោកបានពោលសរសើរគុណក្នុងភាពជាគ្រហស្ថដល់ភិក្ខុមួយរូប ។ ព្រោះកម្មនោះឯង

---

១- បិដកខ្មែរ ប្រែថា សំឡេងគគ្រឹកគគ្រេង តែក្នុងឧបមានោះលោកចង់ពោលថា កាលព្រះរាជាស្នាក់នៅក្នុងព្រៃ សំឡេងចង្រិតក៏មិនប្រាកដ កាលព្រះរាជាចេញផុតអំពីព្រៃ សំឡេងចង្រិតក៏ប្រាកដមកវិញ ។

ទាំងដែលកាលឧបនិស្ស័យអរហត្តផលនៅមានពិតៗ លោកក៏សឹកទៅក្នុងភាពជាគ្រហស្ថ ហើយបួសវិញអស់ ៧ ដង បួសក្នុងលើកទី ៧ ទើបបានសម្រេចអរហត្ត ។l។

## អដ្ឋកថា ចិត្តហត្ថិសារិបុត្តសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បរាយនសូត្រទី ៧

[ ៦១ ] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី សម័យនោះឯង ពួកភិក្ខុជាថេរៈច្រើនរូប ត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ហើយអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់សម្រាកកាយ ក៏កើតសម្តីជាចន្លោះនេះឡើងថា ម្នាលអាវុសោទាំងឡាយ ពាក្យនេះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ក្នុងប្រស្នានៃមេត្តេយ្យមាណព ត្រង់បរាយនវគ្គថា

បុគ្គលណាដឹងនូវចំណែកទាំង ២ ដោយប្រាជ្ញា មិន
ជាប់ជំពាក់ក្នុងកណ្តាល តថាគតហៅបុគ្គលនោះថា
ជាមហាបុរស មហាបុរសនោះ បានកន្លងផុតជម្មជាត
ជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះចេញបានហើយ ។

ម្នាលអាវុសោទាំងឡាយ ចុះចំណែកទី ១ តើដូចម្ដេច ចំណែកទី ២ តើដូចម្ដេច អ្វីជាកណ្ដាល ធម្មជាតជាគ្រឿងចាក់ស្រែះ តើដូចម្ដេច ។ កាលបើភិក្ខុទាំងនោះ និយាយយ៉ាងនេះហើយ ភិក្ខុមួយរូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយ ជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ផស្សៈឈ្មោះថាចំណែកទី ១ ផស្សសមុទយៈ ឈ្មោះថាចំណែកទី ២ ផស្សនិរោធឈ្មោះថាកណ្ដាល តណ្ហាឈ្មោះថា ជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងតែចាក់ស្រែះនូវផស្សៈទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណោះឯង ។ ភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។ កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀតបាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ អតីតក្ខន្ធ ឈ្មោះថាចំណែកទី ១ អានាគតក្ខន្ធ ឈ្មោះថាចំណែកទី ២ បច្ចុប្បន្នក្ខន្ធ ជាកណ្ដាល តណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងចាក់ស្រែះនូវខន្ធទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណោះឯង ភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ សុខវេទនាឈ្មោះថាចំណែកទី ១ ទុក្ខវេទនាឈ្មោះថាចំណែកទី ២ អទុក្ខមសុខវេទនាជាកណ្ដាល តណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងចាក់ស្រែះនូវវេទនាទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯង ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យ-ធម៌ កាលបើដឹងច្បាស់នូវអភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ នាមឈ្មោះថាចំណែកទី ១ រូប ឈ្មោះថាចំណែកទី ២ វិញ្ញាណ ជាកណ្ដាល តណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងចាក់ស្រែះនូវធម៌ទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណេះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យ-ធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀត បាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ អាយតនៈ

ខាងក្នុង ៦ ឈ្មោះថា ចំណែកទី ១ អាយតនៈខាងក្រៅ ៦ ឈ្មោះថាចំណែកទី ២ វិញ្ញាណ ជាកណ្តាល តណ្ហាជាគ្រឿងចាក់ស្រេះ ព្រោះថា តណ្ហាតែងចាក់ស្រេះនូវអាយតនៈទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណោះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀតបាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ សក្កាយឈ្មោះថា ចំណែកទី ១ សក្កាយសមុទយៈ ឈ្មោះថាចំណែកទី ២ សក្កាយ-និរោធ ជាកណ្តាល តណ្ហាជាគ្រឿងចាក់ស្រេះ ព្រោះថា តណ្ហាតែងចាក់ស្រេះនូវសក្កាយទាំងនោះ ដើម្បីឲ្យកើតភពនោះៗ បពិត្រលោកដ៏មានអាយុទាំងឡាយ ដោយហេតុប៉ុណ្ណោះឯងហើយ ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ ភិក្ខុ ១ រូបទៀតបាននិយាយនឹងភិក្ខុទាំងឡាយជាថេរៈ ដូច្នេះថា បពិត្រលោកដ៏មានអាយុទាំងឡាយ ពួកយើងទាំងអស់គ្នា ព្យាករតាមសេចក្តីយល់តែរៀងខ្លួនទេ បពិត្រលោកដ៏មានអាយុទាំងឡាយ មក ពួកយើងនឹងចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះ

ចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ នឹងបានព្រះដ៏មានព្រះភាគព្យាករ ដល់យើងយ៉ាងណា យើងនឹងចាំទុកនូវសេចក្តីនុ៎ះយ៉ាងនោះ ។ ភិក្ខុទាំងឡាយជាថេរៈ បានទទួលពាក្យភិក្ខុនោះថា អើអាវុសោ ។ គ្រានោះ ភិក្ខុទាំងឡាយជាថេរៈ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងឡាយជាថេរៈ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលសេចក្តីទាំងប៉ុន្មាន ដែលខ្លួនបានចរចាជាមួយនឹងភិក្ខុទាំងអស់នោះ ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុណានិយាយត្រូវ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងអស់គ្នានិយាយត្រូវតាមបរិយាយ ដែលតថាគតសំដែងក្នុងប្រស្នានៃមេត្តេយ្យមាណព ត្រង់បរាយនវគ្គថា

បុគ្គលណាដឹងនូវចំណែកទាំង ២ ដោយប្រាជ្ញា មិន
ជាប់ជំពាក់ក្នុងកណ្តាល តថាគតហៅបុគ្គលនោះថា
មហាបុរស មហាបុរសនោះ បានកន្លងផុតនូវធម្មជាត
ជាគ្រឿងចាក់ស្រេះ ក្នុងលោកនេះចេញបានហើយ ។

អ្នកទាំងឡាយ ចូរស្តាប់ធ្វើទុកក្នុងចិត្តនូវហេតុនោះឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងឡាយ ទទួលស្តាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ផស្សៈឈ្មោះថាចំណែកទី ១ ផស្សសមុទយៈឈ្មោះថា ចំណែកទី ២

*ផស្សនិរោធ ឈ្មោះថា កណ្តាល តណ្ហាជាគ្រឿងចាក់ស្រែះ ព្រោះថា តណ្ហាតែងចាក់ស្រែះនូវផស្សៈទាំងនោះ ដើម្បីឲ្យកើតភពនោះៗ ម្នាលភិក្ខុទាំងឡាយ ដោយហេតុប៉ុណ្ណោះឯង ទើបភិក្ខុដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ កាលបើដឹងច្បាស់អភិញ្ញេយ្យធម៌ កំណត់ដឹងបរិញ្ញេយ្យធម៌ហើយ ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្នបាន ។*

# អដ្ឋកថា

## បរាយនសូត្រ

*[ ៦១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរាយនសូត្រទី ៧ ដូចតទៅនេះ បទថា* **ចារាយនេ មេត្តេយ្យប្បញ្ហោ** *បានដល់ ក្នុងបញ្ហារបស់មេត្តេយ្យមាណពដែលមកក្នុងបារាយនវគ្គ ។ បទថា* **ឧភន្តេ វិទិត្វាន** *បានដល់ ដឹងទីបំផុត ២ យ៉ាង គឺ ២ ចំណែក ។ បទថា* **មជ្ឈេ មន្តា ន លិម្បតិ** *សេចក្តីថា បញ្ញាហៅថា* **មន្តា** *បុគ្គលណាជ្រាបទីបំផុតទាំង ២ ដោយបញ្ញាដែលហៅថា* **មន្តា** *នោះ ហើយមិនជាប់នៅត្រង់កណ្តាល គឺមិនជាប់នៅត្រង់កណ្តាល ។ បទថា* **សិព្វិនិមច្ចគា** *សេចក្តីថា បុគ្គលនោះ ឆ្លងតណ្ហាដែលហៅថា* **សិព្វិនី** *គឺគ្រឿងរួបរឹតបានហើយ ។ បទថា* **ផស្សោ** *សេចក្តីថា ព្រោះកើតដោយអំណាចផស្សៈ ទើបអត្តភាពនេះមាន ។ បទថា* **ឯកោ អន្តោ** *សេចក្តីថា*

ផស្សៈនេះ ជាចំណែកមួយ ។ បទថា **ផស្សសមុទយោ** មានរូបវិគ្គហៈថា ផស្សៈជាហេតុកើតនៃអត្តភាពនោះ ហេតុនោះ ទើបអត្តភាពនោះ ឈ្មោះថា មានផស្សៈជាហេតុកើត ។ អត្តភាពក្នុងអនាគត នឹងកើតបាន ព្រោះមានផស្សៈ គឺកម្មដែលធ្វើក្នុងអត្តភាពនេះជាបច្ច័យ ។ បទថា **ទុតិយោ អន្តោ** បានដល់ ចំណែកទី ២ ។ បទថា **ផស្សនិរោធោ** បានដល់ និព្វាន ។ បទថា **មជ្ឈេ** សេចក្តីថា និព្វាន ឈ្មោះថា ជាកណ្តាល ព្រោះអត្ថថា ញែកនូវធម៌ គឺផស្សៈ និងហេតុនៃផស្សៈចេញជា ២ ចំណែក ដោយកាត់តណ្ហាជាគ្រឿងរឹតរុំចេញបាន ។ បទថា **តណ្ហា ហិ នំ សិព្វតិ** សេចក្តីថា តណ្ហារមែងរឹតរុំ គឺជាប់ជាមួយផស្សៈ ពោល គឺអត្តភាពទាំង ២ និងហេតុកើតនៃផស្សៈនោះ ចូលជាមួយគ្នា ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះធ្វើភពនោះៗ ឯងឲ្យកើតឡើង អធិប្បាយថា បើតណ្ហាមិនគប្បីរឹតរុំសោត ភពទាំងនោះឯងក៏មិនគប្បីកើត ។

ក្នុងទីនេះ អ្នកប្រាជ្ញទាំងឡាយបានសម្តែងការប្រៀបធៀប រវាងទីបំផុតនិងត្រង់កណ្តាល ។ អធិប្បាយថា ពាក្យថា ទីបំផុត និងត្រង់កណ្តាល លោកពោលសម្រាប់ឈើ ២ កំណាត់ ដែលបុគ្គលផ្គុំចូលគ្នា ហើយយកខ្សែចងត្រង់កណ្តាល ។ កាលខ្សែដាច់ ឈើទាំង ២ កំណាត់ ក៏របូតទាំងសងខាង គឺខាងចុង និងត្រង់កណ្តាល ។ ក្នុងសេចក្តីនេះក៏យ៉ាងនោះ គឺទីបំផុត ២ យ៉ាង មានប្រការដូចពោលហើយ ប្រៀបដូចឈើ ២ កំណាត់

តណ្ហាប្រៀបដូចអំបោះដែលចងរឹត កាលតណ្ហារលត់ ទីបំផុតទាំង ២ ក៏រលត់ផងដែរ ប្រៀបដូចកាលខ្សែដាច់ ឈើទាំង ២ ក៏របូតចាកគ្នាទាំង ២ ខាង ។

បទថា **ឯត្តាវតា** គឺដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រោះដឹងដោយទីបំផុតទាំង ២ ហើយមិនត្រូវតណ្ហាបូកលាបទុកត្រង់កណ្តាលនេះ ទើបភិក្ខុឈ្មោះថា ដឹងក្រៃលែងនូវធម៌ គឺសច្ចៈ ៤ ដែលគួរដឹងក្រៃលែង ទើបឈ្មោះថា កំណត់ដឹងសច្ចៈដែលជាលោកិយទាំង ២ ដែលគួរកំណត់ដឹង ដោយតីរណបរិញ្ញា និងបហានបរិញ្ញា ។ បទថា **ទិដ្ឋេវ ធម្មេ** បានដល់ ក្នុងអត្តភាពនេះឯង ។ បទថា **ទុក្ខស្សន្តករោ ហោតិ** សេចក្តីថា ឈ្មោះថា ជាអ្នកធ្វើទីបំផុត គឺធ្វើការកំណត់ជុំវិញវដ្តទុក្ខ ។

ក្នុងវារៈទី ២ មានអធិប្បាយដូចតទៅនេះថា គប្បីជ្រាបឧបមាដោយអំណាចឈើ ៣ កំណាត់ ពិតហើយ ឈើ ៣ កំណាត់ដែលបុគ្គលយកខ្សែចង កាលខ្សែដាច់ ឈើ ៣ កំណាត់ក៏ធ្លាក់ទៅក្នុងទី ៣ កន្លែង ។ ក្នុងសេចក្តីនេះក៏ដូច្នេះ គឺខន្ធដែលជាអតីត អនាគត និងបច្ចុប្បន្ន ប្រៀបដូចឈើ ៣ កំណាត់ តណ្ហា ប្រៀបដូចខ្សែ ព្រោះតណ្ហានោះ រួបរឹតខន្ធដែលជាអតីត និងខន្ធដែលជាបច្ចុប្បន្ន ព្រោះរួបរឹតខន្ធដែលជាបច្ចុប្បន្នជាប់នឹងខន្ធដែលជាអនាគត កាលតណ្ហារលត់ ខន្ធដែលជាអតីត អនាគត និងបច្ចុប្បន្នក៏ឈ្មោះថា រលត់ផងដែរ ប្រៀបដូចខ្សែដាច់ ឈើ ៣ កំណាត់ ក៏ធ្លាក់ទៅ

ក្នុងទី ៣ កន្លែង ។

ក្នុងវារៈទី ៣ មានអធិប្បាយដូចតទៅនេះថា បទថា **អទុក្ខមសុខា មជ្ឈេ** សេចក្តីថា អទុក្ខមសុខវេទនា ឈ្មោះថា ជាកណ្តាល ព្រោះភាវៈដែលនៅក្នុងវាងវេទនា ២ ទៀត ។ ព្រោះថា សុខ ឈ្មោះថា នៅខាងក្នុងនៃទុក្ខ ឬទុក្ខ ឈ្មោះថា នៅខាងក្នុងនៃសុខមិនមាន ។ បទថា **តណ្ហា សិព្វិនី** បានដល់ ការត្រេកត្រអាល និងតម្រេកក្នុងវេទនាទាំងឡាយ នឹងឈ្មោះថា រួបរឹតវេទនាទាំងនោះ ។

ក្នុងវារៈទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វិញ្ញាណំ មជ្ឈេ** សេចក្តីថា បដិសន្ធិវិញ្ញាណក្តី វិញ្ញាណដ៏សេសក្តី ឈ្មោះថា ជាកណ្តាលនៃនាមរូបទាំងឡាយ ព្រោះកើតឡើងដោយជាបច្ច័យនៃនាមរូប ។

ក្នុងវារៈទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វិញ្ញាណំ មជ្ឈេ** សេចក្តីថា កម្មវិញ្ញាណ ឈ្មោះថា ជាកណ្តាល ម្យ៉ាងទៀត វិញ្ញាណប្រភេទណាមួយក្នុងទីនេះ ឈ្មោះថា ជាកណ្តាល ព្រោះក្នុងបណ្តាអាយតនៈខាងក្នុង មនាយតនៈទទួលយកកម្ម ។ ម្យ៉ាងទៀត ជវនវិញ្ញាណ ឈ្មោះថា ជាកណ្តាល ព្រោះមនោទ្វារាវជ្ជនៈអាស្រ័យអាយតនៈខាងក្នុង ។

ក្នុងវារៈទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សក្កាយោ** បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា **សក្កាយសមុទយោ** បានដល់ សមុទយសច្ច ។ បទថា **សក្កាយនិរោធោ** បានដល់ និរោធសច្ច ។

បទថា **បរិយាយេន** គឺដោយហេតុនោះៗ ។ បទដ៏សេសគប្បីជ្រាបតាមន័យ ដែលពោលហើយ ក្នុងទីគ្រប់អន្លើនោះឯង ។៙

**អដ្ឋកថា បរាយនសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧទកសូត្រទី ៨

[ ៦២ ] សម័យមួយ ព្រះដ៏មានព្រះភាគ ត្រាច់ទៅកាន់ចារិកក្នុងដែន កោសល ជាមួយនឹងភិក្ខុសង្ឃដ៏ច្រើន បានយាងទៅដល់និគមឈ្មោះទណ្ឌ- កប្បកៈ របស់ពួកអ្នកដែនកោសល ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ចេញ ពីផ្លូវហើយ ទៅគង់លើអាសនៈដែលគេក្រាលថ្វាយទៀបគល់ឈើមួយដើម ។ ភិក្ខុទាំងនោះ ចូលទៅរកនិគមឈ្មោះទណ្ឌកប្បកៈ ដើម្បីស្វែងរកទីសម្នាក់ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ក៏សំដៅទៅស្ទឹងអចិរវតី ជាមួយនឹងពួក ភិក្ខុដ៏ចម្រើន ដើម្បីស្រឡាបខ្លួនក្នុងស្ទឹងអចិរវតី លុះស្រឡាបខ្លួនរួចហើយ ក៏ឡើងមក មានតែចីវរ ១ ហើយឈរធ្វើខ្លួនឲ្យប្រាកដ ដូចជាកាលមុន ។ ស្រាប់តែមានភិក្ខុ ១ រូប ចូលទៅរកព្រះអានន្ទដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះអានន្ទដ៏មានអាយុយ៉ាងនេះថា បពិត្រអានន្ទដ៏មានអាយុ ព្រះ ដ៏មានព្រះភាគ ទ្រង់រំពឹងនូវហេតុទាំងអស់ ដោយព្រះហឫទ័យ ហើយព្យាករ

ទេវទត្តថា ទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក តាំងនៅអស់មួយកប្ប រកកែមិនកើតឬហ្ន៎ ឬថា ដោយហេតុណាមួយទេ ។ ម្នាលអាវុសោ ដំណើរនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយយ៉ាងនុ៎ះមែន ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គព្រមទាំងភិក្ខុសង្ឃជាច្រើន ចុះទៅក្នុងស្ទឹងអចិរវតី ដើម្បីស្រឡាបខ្លួនក្នុងស្ទឹងអចិរវតី លុះស្រឡាបខ្លួនរួចហើយ ក៏ឡើងមកមានតែចីវរ ១ ហើយឈរធ្វើខ្លួនឲ្យប្រាកដដូចជាកាលមុន ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ មានភិក្ខុ ១ រូប ចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ក៏និយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រអានន្ទដ៏មានអាយុ ព្រះដ៏មានព្រះភាគ ទ្រង់ប្រមូលហេតុទាំងអស់ដោយព្រះហឫទ័យ ហើយព្យាករទេវទត្តថា ទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក តាំងនៅអស់មួយកប្ប រកកែមិនកើតទេឬ ឬថាកែបាន ដោយហេតុណាមួយដែរ ។

កាលបើភិក្ខុនោះ និយាយយ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាននិយាយនឹងភិក្ខុនោះ ដូច្នេះថា ម្នាលអាវុសោ ហេតុនុ៎ះ ព្រះដ៏មានព្រះភាគ ទ្រង់ព្យាករយ៉ាងនោះដែរ ។ ម្នាលអានន្ទ ភិក្ខុនោះ ជាភិក្ខុខ្ចី

ទើបតែនឹងបួសក្តី ជាថេរៈល្មមក្តី មិនឈ្លាសវៃក្តី ពាក្យណាដែលតថាគត ព្យាករដោយចំណែក ១ ភិក្ខុនោះ នឹងមិនដល់នូវចំណែក ២ ក្នុងពាក្យនោះ ឡើយ ម្នាលអានន្ទ តថាគតមិនដែលឃើញបុគ្គលដទៃ សូម្បីម្នាក់ដែលតថាគត រំពឹងរក នូវហេតុទាំងអស់ដោយចិត្ត ហើយព្យាករដូចជាភិក្ខុទេវទត្តនេះទេ ។ ម្នាលអានន្ទ តថាគតបានឃើញធម៌សរបស់ទេវទត្ត ត្រឹមតែចាក់ដោយចុង បំផុតនៃរោមបាន ដរាបណា តថាគតក៏មិនព្យាករភិក្ខុទេវទត្តថា ទេវទត្ត ជាអ្នក កើតក្នុងអបាយ ទៅនរក តាំងនៅអស់មួយកប្ប កែមិនកើតដរាបនោះ ម្នាល អានន្ទ កាលណាបើតថាគត មិនបានឃើញធម៌សរបស់ទេវទត្ត ត្រឹមតែចាក់ ដោយចុងបំផុតនៃរោមបាន តថាគតព្យាករទេវទត្តនោះថា ភិក្ខុទេវទត្ត ជាអ្នក កើតក្នុងអបាយ ទៅនរក តាំងនៅអស់មួយកប្បកែមិនបាន ក្នុងកាលនោះ ។ ម្នាលអានន្ទ រណ្តៅលាមក ដែលមានជម្រៅជាងមួយជំហរដ៏ពេញដោយ លាមកប្រៀបស្មើមាត់ មានបុរសលិចចុះទៅទាំងក្បាល ក្នុងរណ្តៅលាមក នោះ បុរសណាមួយជាអ្នកប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីចម្រើន ប្រាថ្នា ដើម្បីក្សេមចាកយោគៈដល់បុរសនោះ ប្រាថ្នានឹងស្រង់អំពីរណ្តៅលាមកនោះ ក៏ដើរចូលមកកាន់បុរសនោះ ឯបុរសនោះ ដើរក្រឡឹងជុំវិញរណ្តៅលាមកនោះ ហើយ មិនឃើញសរីរប្រទេសរបស់បុរសនោះ ដែលត្រឹមតែចាក់ដោយចុង បំផុតនៃរោម ដែលមិនប្រឡាក់ដោយលាមក ដែលគួរនឹងចាប់ស្រង់បុរសនោះ ឡើងបាន យ៉ាងណាមិញ ម្នាលអានន្ទ តថាគតមិនបានធម៌សរបស់ទេវទត្ត

ត្រឹមតែចាក់ដោយចុងបំផុតនៃរោមបានក្នុងកាលណា តថាគតព្យាករទេវទត្តថា ភិក្ខុទេវទត្តជាអ្នកកើតក្នុងអបាយ ទៅនរក តាំងនៅអស់មួយកប្ប កែមិនកើត ក្នុងកាលនោះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បើដូច្នោះ អ្នកទាំងឡាយ ត្រូវស្តាប់តថាគតចែកនូវបុរិសិន្ទ្រិយញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរ បពិត្រព្រះសុគត កាលនេះជាកាលគួរ សូមព្រះដ៏មានព្រះភាគចែកនូវបុរិសិន្ទ្រិយញ្ញាណ ពួកភិក្ខុស្តាប់ព្រះដ៏មានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកានៃព្រះសម្ពុទ្ធដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនោះ ។ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយ របស់បុគ្គលនោះបាត់ទៅ អកុសលធម៌កើតឡើងប្រាកដ តែបុគ្គលនោះមិនគាស់ មិនរម្លើងកុសលមូលទេ ព្រោះហេតុនោះ កុសល និងអកុសលរបស់បុគ្គលនោះ នឹងកើតឡើងប្រាកដវិញ បុគ្គលនេះ នឹងមានធម៌មិនសាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ ម្នាលអានន្ទ ដូចពូជទាំងឡាយដែលមិនដាច់ មិនស្អុយ មិនត្រូវខ្យល់ និងកម្តៅថ្ងៃប្រហារ មានបណ្តុលល្អ គេទុកដាក់ដោយល្អ ហើយគេ

សាបព្រោះលើទីដែលភ្ជួររាស់ដោយស្រួលបួល ក្នុងស្រែល្អ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះនឹងដល់នូវការដុះលូតលាស់ឡើងធំ ទង្គំទង្គោលបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតឡើងប្រាកដតែបុគ្គលនោះ មិនគាស់រម្លើងកុសលមូលទេ ហេតុនោះ កុសល និងអកុសលរបស់បុគ្គលនោះ នឹងកើតប្រាកដវិញបាន បុគ្គលនេះ នឹងមានធម៌មិនសាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គលដែលតថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ ដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយ កើតឡើងប្រាកដ ទាំងបុគ្គលនោះ មិនបានគាស់រម្លើង

កុសលមូលទេ ព្រោះហេតុនោះ កុសល និងអកុសលរបស់បុគ្គលនោះ នឹងកើតប្រាកដ បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀត ដោយប្រការយ៉ាងនេះ ម្នាលអានន្ទ ដូចពូជទាំងឡាយ ដែលមិនដាច់ មិនស្អុយ មិនត្រូវខ្យល់និងកម្តៅថ្ងៃប្រហារ មានបណ្តូលនៅល្អ គេទុកដាក់ដោយស្រួល តែគេសាបព្រោះលើថ្មដ៏ក្រាស់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះ មិនងាយនឹងដុះលូតលាស់ឡើង ទន្ទឹំទន្ទោលបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយ កើតឡើងប្រាកដវិញបាន ទាំងបុគ្គលនោះ មិនបានគាស់រម្លើងអកុសលមូលទេ ព្រោះហេតុនោះ កុសល និងអកុសលរបស់បុគ្គលនោះ ក៏កើតប្រាដកវិញបាន បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀតយ៉ាងនេះក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គលដែលតថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ ដែលតថាគតកំណត់ដឹងដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ ដែលតថាគតកំណត់ដឹងដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី

អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា ធម៌សរបស់បុគ្គលនេះ សូម្បីល្មមត្រឹមតែចាក់ដោយចុងបំផុតនៃរោមបាន មិនមានឡើយ បុគ្គលនេះ ប្រកបដោយអកុសលធម៌ទាំងឡាយ ដែលមានពណ៌ខ្មៅសុទ្ធ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលអានន្ទ ដូចពូជទាំងឡាយដែលដាច់ស្អុយ ត្រូវខ្យល់ និងកម្ដៅថ្ងៃប្រហារ ហើយគេសាបព្រោះលើទីដែលគេភ្ជួររាស់ដោយល្អ ក្នុងស្រែល្អ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពូជទាំងនេះនឹងមិនដុះលូតលាស់ទង្គំទង្គោលបានឬទេ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំង-ឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា ធម៌សរបស់បុគ្គលនេះ សូម្បីល្មមត្រឹមតែចាក់ដោយចុងបំផុតនៃរោមបាន មិនមានឡើយ បុគ្គលនេះប្រកបដោយអកុសលធម៌ទាំងឡាយ ដែលមានពណ៌ខ្មៅសុទ្ធ ដល់បែកធ្លាយរាងកាយស្លាប់ទៅ នឹងចូលទៅកាន់អបាយ ទុគ្គតិ វិនិបាត នរក យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដឹងដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគតកំណត់ដឹងដោយចិត្តយ៉ាងនេះផង ។

កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចបញ្ញត្តបុគ្គល ៣ ពួក ក្រៅពីបុគ្គល ៣ ពួកនេះឲ្យមានចំណែកស្មើគ្នា បានឬទេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគតអាចបញ្ញត្តបាន ហើយទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតឡើងប្រាកដ តែបុគ្គលនោះ មិនបានគាស់រម្លើងកុសលមូលទេ ឯកុសលមូលនោះ ដល់នូវការរបើកឡើងដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀតយ៉ាងនេះ ម្នាលអានន្ទ ដូចរងើកភ្លើងទាំងឡាយ កំពុងឆេះរន្ទាលប្រាលឆ្អៅ ដែលគេដាក់លើផែនថ្មដ៏ក្រាស់ ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ នឹងមិនដល់នូវការចម្រើនរាលដាលធំទូលាយឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ មួយទៀត ដូចព្រះអាទិត្យលិចក្នុងសាយណ្ហសម័យ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពន្លឺក៏នឹងបាត់សូន្យទៅ ងងឹតនឹងកើតប្រាកដបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ ពុំនោះសោត ដូចសម័យកត្តកាល ចំពាក់កណ្តាលយប់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ពន្លឺបាត់ទៅ

ងងឹតកើតប្រាកដបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយ របស់បុគ្គលនេះ បាត់សូន្យទៅ អកុសលធម៌ទាំងឡាយ កើតប្រាកដ តែបុគ្គលនេះ មិនបានគាស់រម្លើងកុសលមូលទេ កុសលមូលនោះ ដល់នូវការរបើកឡើង ដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌សាបសូន្យតទៅទៀតដោយប្រការយ៉ាងនេះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគតកំណត់ដឹង ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយរបស់បុគ្គលនេះ បាត់សូន្យទៅ កុសលធម៌ទាំងឡាយ កើតប្រាកដ តែបុគ្គលនោះ មិនបានគាស់រម្លើងអកុសលមូលទេ អកុសលមូលនោះ ដល់នូវការរបើកឡើង ដោយប្រការទាំងពួង បុគ្គលនេះ នឹងមានធម៌មិនបានសាបសូន្យតទៅទៀតយ៉ាងនេះ ម្នាលអានន្ទ ដូចរងើកភ្លើងទាំងឡាយ

ឆេះវន្ទាលប្រាលផ្កៅ ហើយបុគ្គលដាក់លើគំនរស្មៅក្តី គំនរឧសក្តី ដែលស្ងួត ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ នឹងដល់នូវការចម្រើន ធំទូលាយបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ មួយទៀត ដូចព្រះអាទិត្យរះឡើង ក្នុងបច្ចូសសម័យនៃរាត្រី ម្នាលអានន្ទ អ្នកត្រូវដឹងថា ងងឹតទឹងបាត់ទៅ ពន្លឺនឹងកើតប្រាកដឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ ពុំនោះសោត ដូចសម័យកត្តកាល ពេលថ្ងៃត្រង់ជាក់ ម្នាលអានន្ទ អ្នកត្រូវដឹងថា ងងឹតបាត់ទៅ ពន្លឺកើតប្រាកដឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលនោះ ដោយចិត្តយ៉ាងនេះថា អកុសលធម៌ទាំងឡាយ របស់បុគ្គលនេះ សាបសូន្យទៅ កុសលធម៌ទាំងឡាយកើតប្រាកដ តែបុគ្គលនោះ មិនបានគាស់រម្លើងអកុសល-មូលទេ អកុសលមូលនោះ ដល់នូវការរបើកឡើង ដោយប្រការទាំងពួង បុគ្គលនោះ នឹងមានធម៌មិនសាបសូន្យតទៅទៀត យ៉ាងនេះ ក៏យ៉ាងនោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទ បុរិសិន្ទ្រិយញ្ញាណ តថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ សេចក្តីកើតឡើងនៃធម៌តទៅ តថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទ តថាគតកំណត់ដឹងនូវចិត្ត របស់បុគ្គលពួកខ្លះ ក្នុងលោកនេះ

ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ សម័យក្រោយទៀត តថាគតកំណត់ដឹងនូវចិត្តរបស់បុគ្គលនោះដោយចិត្ត យ៉ាងនេះថា អកុសលធម៌របស់បុគ្គលនេះ ត្រឹមតែចាក់ដោយចុងបំផុតនៃរោមបាន មិនមានឡើយ បុគ្គលនេះ ជាអ្នកប្រកបដោយធម៌ទាំងឡាយដែលគ្មានទោស មានពណ៌សសុទ្ធ នឹងបរិនិព្វាន ក្នុងបច្ចុប្បន្ន ម្នាលអានន្ទដូចរងើកភ្លើងទាំងឡាយ ដែលរលត់ត្រជាក់ បុគ្គលដាក់លើគំនរស្មៅ ឬគំនរឧសដ៏ស្ងួត ម្នាលអានន្ទ អ្នកត្រូវដឹងថា រងើកភ្លើងទាំងនេះ មិនដល់នូវការចម្រើន រាលដាលឡើងបានឬទេ ។ ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទតថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដោយចិត្តយ៉ាងនេះថា កុសលធម៌ទាំងឡាយក្តី អកុសលធម៌ទាំងឡាយក្តី មានដល់បុគ្គលនេះ ។ សម័យក្រោយទៀត តថាគត កំណត់ដឹងនូវចិត្តរបស់បុគ្គលនោះដោយចិត្ត យ៉ាងនេះថា អកុសលធម៌របស់បុគ្គលនេះ ត្រឹមតែចាក់ដោយចុងបំផុតនៃរោមមិនមានឡើយ បុគ្គលនេះ ប្រកបដោយធម៌ទាំងឡាយ ដែលមិនមានទោស មានពណ៌សសុទ្ធ នឹងបរិនិព្វាន ក្នុងបច្ចុប្បន្នដូច្នោះឯង ម្នាលអានន្ទ បុរសបុគ្គល តថាគតកំណត់ដឹងដោយចិត្ត យ៉ាងនេះផង ម្នាលអានន្ទបុរិសិន្ទ្រិយញ្ញាណ តថាគត កំណត់ដឹងដោយចិត្តយ៉ាងនេះផង ម្នាលអានន្ទសេចក្តីកើតឡើងនៃធម៌តទៅ តថាគត កំណត់ដឹង ដោយចិត្តយ៉ាងនេះផង ។ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គល ៣ ខាងដើមណា បណ្តាបុគ្គល

ទាំង ៣ នោះ បុគ្គលមួយ មានធម៌មិនបានសាបសូន្យ បុគ្គលមួយ មានធម៌សាបសូន្យ បុគ្គលមួយកើតក្នុងអបាយ ទៅនរក ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គល ៣ ខាងចុងណា បណ្តាបុគ្គលទាំង ៣ នេះ បុគ្គលមួយមានសភាពមិនសាបសូន្យ បុគ្គលមួយមានសភាពសាបសូន្យ បុគ្គលមួយមានសភាពបរិនិព្វាន ។

# អដ្ឋកថា

## ឧទកសូត្រ

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧទកសូត្រទី ៨ ដូចតទៅនេះ បទថា **អញ្ញតរោ** បានដល់ ភិក្ខុមួយអង្គដែលជាបក្ខពួករបស់ទេវទត្តភិក្ខុ ។ បទថា **សមន្នាហរិត្វា** បានដល់ បង្អោននឹក ។ ភិក្ខុទាំងឡាយសួរដល់រឿងនេះ ក៏ដោយបំណងថា ព្រះមានព្រះភាគត្រាស់ ព្រោះទ្រង់ជ្រាប ឬទ្រង់មិនជ្រាប ព្រះមានព្រះភាគត្រាស់ជាឯកង្សិកព្យាករ គឺត្រាស់តែមួយចំណែក ឬថាត្រាស់ជាវិភជ្ជព្យាករ គឺត្រាស់បែក ។ បទថា **អាបាយិកោ** បានដល់ កើតក្នុងអបាយ ។ បទថា **នេរយិកោ** បានដល់ ទៅកាន់នរក ។ បទថា **កប្បដ្ឋោ** បានដល់ តាំងនៅក្នុងនរកអស់កប្ប ព្រោះបានធ្វើកម្មដែលជាហេតុឲ្យតាំងនៅអស់កប្ប ។ បទថា **អតេកិច្ឆោ** បានដល់ មិនអាចកែខៃបាន ។

បទថា **ទេ្វជ្ឈំ** បានដល់ ភាវៈ ២ ។ បទថា **វាលគ្គកោដិនិត្តុទនមត្តំ** បានដល់ សេចក្តីល្អដែលល្មមនឹងសម្តែងបាន ដោយចុងរោមទ្រាយ ឬ សេចក្តីល្អត្រឹមតែយកចុងរោមទ្រាយចាក់ ។

បទថា **បុរិសិន្ទ្រិយញ្ញាណានិ** បានដល់ ញាណជាគ្រឿងដឹងក្រៃលែងនិងការធូរថយនៃឥន្ទ្រិយរបស់បុរសបុគ្គលទាំងឡាយ អធិប្បាយថា ញាណជាគ្រឿងបង្អោនដល់ភាពដែលឥន្ទ្រិយទាំងអស់ចាស់ក្លា និងទន់ខ្ចី ។

បទថា **វិជ្ជមានា កុសលាបិ ធម្មា អកុសលាបិ ធម្មា** សេចក្តីថា តថាគតដឹងថា កុសលធម៌របស់បុគ្គលនេះ មានប៉ុណ្ណេះ អកុសលធម៌ មានប៉ុណ្ណេះ ។ បទថា **អន្តរហិតា** បានដល់ ដល់នូវការមើលមិនឃើញ ។ បទថា **សម្មុខីភូតា** បានដល់ កើតប្រាកដដោយអំណាចការផ្សាយឡើង ។ បទថា **កុសលមូលំ** បានដល់ អធ្យាស្រ័យដែលជាកុសល ។ បទថា **កុសលាកុសលំ** សេចក្តីថា កុសលសូម្បីដទៃក៏នឹងកើតឡើងអំពីអធ្យាស្រ័យដែលជាកុសលនោះ ។ បទថា **សារាទានិ** បានដល់ កាន់យកសារៈបាន គឺមានសារៈ បុគ្គលកាន់យកបាន ឬកើតឡើងក្នុងខែសរទៈ ។ បទថា **សុខសយិតានិ** បានដល់ រួបរួមរក្សាល្អ ។ បទថា **សុក្ខេត្តេ** បានដល់ ក្នុងស្រែដែលសម្បូរដោយជីវ ។ បទថា **និក្ខិត្តានិ** បានដល់ ដែលសាបព្រោះចុះ ។ បទថា **សប្បដិភាគា** បានដល់ ដែលឃើញសមគួរ ។ បទថា **អភិទោសអឌ្ឍរត្តំ** បានដល់ ក្នុងកាលជិតកន្ទះរាត្រី គឺក្នុងកណ្តាលយប់

ប្រាកដចំពោះមុខ ។ បទថា **ភត្តកាលសមយេ** បានដល់ ក្នុងសម័យ ពោល គឺពេលសោយព្រះក្រយាហារនៃរាជត្រកូលទាំងឡាយ ។

សួរថា បុគ្គលណា ដែលព្រះមានព្រះភាគទ្រង់ជ្រាបយ៉ាងនេះថា មាន ការវិនាសជាធម្មតា ។ ឆ្លើយថា ព្រះបាទអជាតសត្តុ ព្រោះថា ព្រះបាទ អជាតសត្តុនោះ ទ្រង់វិនាសចាកមគ្គផល ព្រោះអាស្រ័យបាបមិត្រ ឯបុគ្គល ដទៃ មានព្រះបាទសុប្បពុទ្ធ និងសុនក្ខត្តជាដើម ព្រះមានព្រះភាគទ្រង់ជ្រាប ដូចគ្នា ។

សួរថា បុគ្គលណាដែលព្រះមានព្រះភាគទ្រង់ជ្រាបយ៉ាងនេះថា មានការ មិនវិនាសជាធម្មតា ។ ឆ្លើយថា សុសុមបរិព្វាជក និងបុគ្គលដទៃ ដែលមាន ឧបនិស្ស័យ មានសភាពដូច្នេះ ។

សួរថា បុគ្គលណាដែលព្រះមានព្រះភាគ ទ្រង់ជ្រាបយ៉ាងនេះថា នឹង បរិនិព្វាន ឆ្លើយថា សន្តតិមហាមាត្យ និងបុគ្គលដទៃដែលមានឧបនិស្ស័យ បែបនេះ ។ល។

## អដ្ឋកថា ឧទកសូត្រទី ៨ ចប់

# សុត្តន្តបិដក

## និព្វេធិកសូត្រទី ៩

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវនិព្វេធិកបរិយាយ ( ហេតុដែលទម្លាយនូវលោភក្ខន្ធជាដើម ដែលបុគ្គលមិនបានទម្លាយ ) នឹងធម្មបរិយាយដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់ ធ្វើទុកក្នុងចិត្ត នូវបរិយាយនោះ ឲ្យស្រួលបួលចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ និព្វេធិកបរិយាយ នឹងធម្មបរិយាយនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃកាមទាំងឡាយ បុគ្គលគប្បីដឹង វិបាកនៃកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់កាម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កាម បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតវេទនាទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃវេទនាទាំងឡាយ បុគ្គលគប្បីដឹង វិបាកនៃវេទនាទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់វេទនា បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់វេទនា បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតសញ្ញាទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃសញ្ញាទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់សញ្ញា បុគ្គល

គប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់សញ្ញា បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតអាសវៈទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់អាសវៈទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ កម្ម បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតកម្មទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃកម្មទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់កម្មទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ បុគ្គលគប្បីដឹង ។

ម្នាលភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតកាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីប្លែកគ្នានៃកាមទាំងឡាយ បុគ្គលគប្បីដឹង វិបាករបស់កាមទាំងឡាយ បុគ្គលគប្បីដឹង សេចក្តីរលត់កាម បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កាម បុគ្គលគប្បីដឹង ពាក្យដែលតថាគតសម្តែងហើយដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ កាមគុណនេះ មាន ៥ គឺរូបទាំងឡាយ

ដែលបុគ្គលគួរដឹងច្បាស់ដោយចក្ខុ ជារូបគួរប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្ដីត្រេកអរ ១ សំឡេងទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយត្រចៀក ។បេ។ ក្លិនទាំង-ឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយច្រមុះ រសទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយអណ្ដាត ផោដ្ឋព្វៈទាំងឡាយ ដែលបុគ្គលគួរដឹងច្បាស់ដោយកាយ គួរប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ប្រកបដោយកាម ជាទីតាំងនៃសេចក្ដីត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងនុ៎ះ មិនមែនកាមទេ ធម៌ទាំងនុ៎ះ ហៅថា កាមគុណក្នុងអរិយវិន័យ ។

សេចក្ដីត្រេកអរកើតឡើង ដោយអំណាចការត្រិះរិះ
ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រក្នុងលោក មិន
មែនកាមទេ សេចក្ដីត្រេកអរកើតឡើង ដោយអំណាច
ការត្រិះរិះ ជាកាមរបស់បុរស អារម្មណ៍ដ៏វិចិត្រ
ទាំងឡាយ តែងឋិតនៅក្នុងលោក ដោយប្រការ
ដូច្នោះ តែអ្នកប្រាជ្ញទាំងឡាយ រមែងកម្ចាត់បង់នូវ
សេចក្ដីគាប់ចិត្ត ក្នុងអារម្មណ៍ទាំងឡាយនុ៎ះចេញ ។

ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតកាមទាំងឡាយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតកាមទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះសេចក្ដីប្លែកគ្នានៃកាមទាំងឡាយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ

កាមក្នុងរូបទាំងឡាយ ដោយឡែក កាមក្នុងសំឡេងទាំងឡាយ ដោយឡែក កាមក្នុងក្លិនទាំងឡាយ ដោយឡែក កាមក្នុងរសទាំងឡាយ ដោយឡែក កាមក្នុងផោដ្ឋព្វៈទាំងឡាយ ដោយឡែក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្ដីប្លែកគ្នានៃកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កាមទាំងឡាយ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលប្រាថ្នានូវអារម្មណ៍ណា ញុំាងអត្តភាពដែលកើតអំពីអារម្មណ៍នោះៗ ជាចំណែកបុណ្យក្ដី ចំណែកបាបក្ដី ឲ្យកើតឡើង ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីរលត់កាម តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីរលត់កាម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្ដីរលត់កាម គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវកដឹងច្បាស់នូវកាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតកាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីប្លែកគ្នា នៃកាមទាំងឡាយ យ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់កាមទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីរលត់កាមយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់កាម យ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ដែលជាគ្រឿងទម្លុះទម្លាយ ( នូវគំនរលោភៈជាដើម ) នេះថាជាសេចក្ដីរលត់កាម ។ ម្នាល

ភិក្ខុទាំងឡាយ កាមទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់កាម បុគ្គលគប្បីដឹង ពាក្យណាដែលលតថាគតសម្តែងហើយ ដូច្នេះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់វេទនា បុគ្គលគប្បីដឹង ក៏ពាក្យដែលតថាគតសម្តែងហើយ ដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ វេទនានេះ មាន ៣ យ៉ាង គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតវេទនាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃវេទនាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សុខវេទនា ប្រកបដោយអាមិសៈក៏មាន សុខវេទនា មិនប្រកបដោយអាមិសៈក៏មាន ទុក្ខវេទនា ប្រកបដោយអាមិសៈក៏មាន ទុក្ខវេទនា មិនប្រកបដោយអាមិសៈក៏មាន អទុក្ខមសុខវេទនា ប្រកបដោយអាមិសៈក៏មាន អទុក្ខមសុខវេទនា មិនប្រកបដោយអាមិសៈក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់វេទនាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលទទួលត្រង់រងនូវវេទនាណា តែងញុំាងអត្តភាព ដែលកើតអំពីវេទនានោះៗ ជាចំណែកបុណ្យក្តី ចំណែកបាបក្តី ឲ្យកើតឡើង ម្នាលភិក្ខុ

ទាំងឡាយ នេះហៅថា វិបាករបស់វេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់វេទនា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់វេទនា គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវវេទនាយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតវេទនាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នា នៃវេទនាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាក របស់វេទនាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់វេទនាយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់វេទនាយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ដែលជាគ្រឿងទម្លុះទម្លាយនេះ ថាជាសេចក្តីរលត់វេទនា ។ ម្នាលភិក្ខុទាំងឡាយ វេទនាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់វេទនា បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសម្តែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់សញ្ញា បុគ្គលគប្បីដឹង ក៏ពាក្យដែលតថាគតសម្តែងហើយដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ សញ្ញានេះមាន ៦ យ៉ាង គឺរូបសញ្ញា ១ សទ្ទសញ្ញា

១ គន្ធសញ្ញា ១ រសសញ្ញា ១ ផោដ្ឋព្វសញ្ញា ១ ធម្មសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតសញ្ញាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតសញ្ញាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃសញ្ញាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាក្នុងរូបទាំងឡាយ ដោយឡែក សញ្ញាក្នុងសំឡេងទាំងឡាយ ដោយឡែក សញ្ញាក្នុងក្លិនទាំងឡាយ ដោយឡែក សញ្ញាក្នុងរសទាំងឡាយ ដោយឡែក សញ្ញាក្នុងផោដ្ឋព្វៈទាំងឡាយដោយឡែក សញ្ញាក្នុងធម៌ទាំងឡាយដោយឡែក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃសញ្ញាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាកនៃសញ្ញាទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅសញ្ញាទាំងឡាយថា មានវោហារជាវិបាក បុគ្គលចាំបានយ៉ាងណាៗ និយាយយ៉ាងនោះៗ ថា ខ្ញុំជាអ្នកមានសេចក្តីសម្គាល់យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់សញ្ញាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់សញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់សញ្ញា ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្តីរលត់សញ្ញា គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវកដឹងច្បាស់នូវសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នានៃសញ្ញាទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់សញ្ញាទាំងឡាយ

យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់សញ្ញាយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរទៅកាន់សេចក្តីរលត់សញ្ញាយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទម្លុះទម្លាយនេះ ថាជាសេចក្តីរលត់សញ្ញា ។ ម្នាលភិក្ខុទាំងឡាយ សញ្ញាទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់សញ្ញា បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសម្តែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសម្តែង ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ក៏ពាក្យដែលតថាគតសម្តែងហើយដូច្នេះនុ៎ះ ពាក្យនុ៎ះ តថាគតសម្តែង ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ អាសវៈនេះមាន ៣ យ៉ាង គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អវិជ្ជាជាហេតុនាំឲ្យកើតអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ នាំសត្វឲ្យទៅនរកក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅកាន់កំណើតតិរច្ឆានក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅកាន់បិត្តិវិស័យក៏មាន អាសវៈទាំងឡាយនាំសត្វឲ្យទៅមនុស្សលោកក៏មាន អាសវៈទាំងឡាយនាំសត្វឲ្យទៅទេវលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ វិបាក

របស់អាសវៈទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលុះក្នុងអវិជ្ជាណា ញុំាងអត្តភាពដែលកើតអំពីអវិជ្ជានោះៗ ជាចំណែកបុណ្យក្តី ចំណែកបាបក្តី ឲ្យកើតឡើង ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់អាសវៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់អាសវៈ ព្រោះរលត់អវិជ្ជា ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាដំណើរទៅកាន់សេចក្តីរលត់អាសវៈ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នានៃអាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់អាសវៈទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់អាសវៈយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់អាសវៈយ៉ាងនេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទម្លុះទម្លាយនេះ ថាជាសេចក្តីរលត់អាសវៈ ។ ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ បុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្តីរលត់អាសវៈ បុគ្គលគប្បីដឹង ពាក្យណាដែលតថាគតសម្តែងហើយដូច្នេះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

ម្នាលភិក្ខុទាំងឡាយ កម្មបុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅ

កាន់សេចក្តីរលត់កម្ម បុគ្គលគប្បីដឹង ក៏ពាក្យដែលតថាគតសម្តែងហើយ ដូច្នេះ នុ៎ះ ពាក្យនុ៎ះ តថាគតសម្តែងហើយ ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាថាជាកម្ម ព្រោះបុគ្គលគិតហើយ ទើបធ្វើកម្មដោយកាយ វាចាចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឲ្យកើតកម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឲ្យកើតកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃកម្មទាំងឡាយ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កម្មនាំឲ្យទទួលផលក្នុងនរកក៏មាន កម្មនាំឲ្យទទួលផលក្នុងកំណើតតិរច្ឆានក៏មាន កម្មនាំឲ្យទទួលផលក្នុងបិត្តិវិស័យក៏មាន កម្មនាំឲ្យទទួលផលក្នុងមនុស្សលោកក៏មាន កម្មនាំឲ្យទទួលផលក្នុងទេវលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់កម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវវិបាករបស់កម្មទាំងឡាយ ថាមាន ៣ ប្រការ គឺវិបាករបស់កម្មក្នុងបច្ចុប្បន្ន ១ វិបាករបស់កម្មក្នុងអត្តភាពបន្ទាប់ ១ វិបាករបស់កម្ម ក្នុងអត្តភាពជាលំដាប់តៗ ទៅ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់កម្ម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាមានដំណើរទៅកាន់សេចក្តីរលត់កម្ម គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក

ដឹងច្បាស់នូវកម្មយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីប្លែកគ្នា នៃកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់កម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវសេចក្ដីរលត់កម្មយ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្ដីរលត់កម្មយ៉ាងនេះហើយ អរិយ-សាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទម្លុះទម្លាយនេះថាជាសេចក្ដីរលត់កម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មបុគ្គលគប្បីដឹង ។បេ។ បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់កម្ម បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសម្ដែងហើយ ដូច្នេះ ពាក្យនុ៎ះ តថាគតសម្ដែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង ។ សេចក្ដីរលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ បុគ្គលគប្បីដឹង ពាក្យដែលតថាគតសម្ដែងហើយ ដូច្នេះ នុ៎ះ ពាក្យនុ៎ះ តថាគតសម្ដែងហើយ ព្រោះអាស្រ័យអ្វី ។ ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ ព្យាធិក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសក៏ជាទុក្ខ បុគ្គលចង់បានរបស់ណាហើយ មិនបាននូវរបស់នោះ ក៏ជាទុក្ខ បើនិយាយដោយខ្លី ឧបាទានក្ខន្ធទាំង ៥ ក៏ជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុនាំឲ្យកើតទុក្ខ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ តណ្ហាជាហេតុនាំឲ្យកើតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីប្លែកគ្នានៃទុក្ខ

តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខយ៉ាងខ្លាំងក៏មាន ទុក្ខយ៉ាងខ្សោយក៏មាន ទុក្ខក្រសាយក៏មាន ទុក្ខឆាប់សោយក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះវិបាករបស់ទុក្ខតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតចិត្តហើយ រមែងសោយសោក លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេងវង្វេងវង្វាង មួយទៀត បុគ្គលមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតចិត្តហើយ តែងដល់នូវការស្វែងរកហេតុខាងក្រៅព្រះពុទ្ធសាសនាថា បុគ្គលណាហ្ន៎ ចេះ ( មន្ត អាគម ) តែមួយបទ ឬពីរបទ ដើម្បីរម្ងត់ទុក្ខនេះបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវទុក្ខថា មានសេចក្តីវង្វេងវង្វេងវង្វាង ជាវិបាក ឬការស្វែងរក ជាវិបាក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់ទុក្ខ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់ទុក្ខព្រោះរលត់តណ្ហា ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង ជាបដិបទាមានដំណើរ ទៅកាន់សេចក្តីរលត់ទុក្ខ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវទុក្ខយ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឲ្យកើតទុក្ខយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីប្លែកគ្នានៃទុក្ខយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់ទុក្ខយ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់ទុក្ខយ៉ាងនេះ ដឹងច្បាស់នូវបដិបទាជាដំណើរ ទៅកាន់សេចក្តីរលត់ទុក្ខយ៉ាង

នេះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទម្លុះទម្លាយនេះថា ជាសេចក្ដីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខ បុគ្គលគប្បីដឹង ហេតុនាំឲ្យកើតទុក្ខ បុគ្គលគប្បីដឹង សេចក្ដីប្លែកគ្នានៃទុក្ខ បុគ្គលគប្បីដឹង វិបាករបស់ទុក្ខ បុគ្គលគប្បីដឹង សេចក្ដីរលត់ទុក្ខ បុគ្គលគប្បីដឹង បដិបទាជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ បុគ្គលគប្បីដឹង ពាក្យណា ដែលតថាគតសម្ដែងហើយ ដូច្នេះ ពាក្យនុ៎ះ តថាគតសម្ដែងហើយ ព្រោះអាស័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា និព្វេធិកបរិយាយ ឈ្មោះថា ធម្មបរិយាយ ។

# អដ្ឋកថា

## និព្វេធិកសូត្រ

[ ៦៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិព្វេធិកសូត្រទី ៩ ដូចតទៅនេះ ធម៌ឈ្មោះថា **និព្វេធិកបរិយាយ** ព្រោះទោះ គឺទម្លាយគំនរលោភៈជាដើមដែលមិនធ្លាប់ទោះ មិនធ្លាប់ទម្លាយមកអំពីមុន អធិប្បាយថា បានដល់ ហេតុនៃការទោះទម្លុះ ។ បទថា **និទានសម្ភវោ** សេចក្ដីថា ឈ្មោះថា **និទាន** ព្រោះប្រគល់ឲ្យនូវកាម គឺប្រគល់ឲ្យដោយភាពជាហេតុ អាចឲ្យកើតឡើង ។ ធម៌ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតឡើង ។ សម្ភវៈ គឺនិទាន នោះឯង ទើប

ឈ្មោះថា **និទានសម្ភវ**។ បទថា **វេមត្តតា** បានដល់ ហេតុផ្សេងៗ គ្នា ។

បទថា **កាមគុណា** សេចក្តីថា ឈ្មោះថា **កាម** ព្រោះអត្ថថា ដឹកនាំឲ្យប្រាថ្នា ឈ្មោះថា **គុណា** ព្រោះអត្ថថា ចងទុក ដូចក្នុងប្រយោគជាដើមថា **អន្តគុណំ** ប្រែថា ខ្សែចងពោះវៀន ។ បទថា **ចក្ខុវិញ្ញេយ្យា** សេចក្តីថា ដែលគប្បីឃើញដោយចក្ខុវិញ្ញាណ ។ បទថា **ឥដ្ឋា** មានអធិប្បាយថា ទោះប្រាថ្នាក្តី មិនប្រាថ្នាក្តី ក៏គង់ជាឥដ្ឋារម្មណ៍នោះឯង ។ បទថា **កន្តា** បានដល់ជារបស់គួរប្រាថ្នា ។ បទថា **មនាបា** បានដល់ ជាទីចម្រើនចិត្ត ។ បទថា **បិយរូបា** បានដល់ ជាទីស្រឡាញ់ដោយកំណើត ។ បទថា **កាមូបសំហិតា** សេចក្តីថា កាមដែលកើតឡើង ព្រោះធ្វើបិយរូប ឲ្យជាអារម្មណ៍ត្រេកអរហើយ ។ បទថា **រជនីយា** សេចក្តីថា ជាហេតុនៃការកើតឡើងនៃរាគៈ ។ បទថា **នេតេ កាមា** សេចក្តីថា រូបជាដើមនេះបានឈ្មោះថា ជាកាម ព្រោះអត្ថប្រាថ្នា ក៏មិនមែន ។

បទថា **សង្កប្បរាគោ** បានដល់ រាគៈដែលកើតឡើងដោយអំណាចនៃការត្រិះរិះ ។ បទថា **កាមោ** សេចក្តីថា រាគៈកើតឡើងហើយនេះ អ្នកបដិបត្តិដើម្បីលះកាម ចាំបាច់លះ ។ រូបជាដើម ឈ្មោះថា **កាម** ដោយអត្ថថាជាហេតុប្រាថ្នា ។ បទថា **ចិត្រានិ** បានដល់ មានអារម្មណ៍វិចិត្រល្អ ។

បទថា **ផស្សោ** បានដល់ ផស្សៈដែលកើតឡើងព្រមគ្នា ។ បទថា **កាមយមានោ** បានដល់ បុគ្គលប្រាថ្នាកាម ។ បទថា **តជ្ជំ តជ្ជំ** បានដល់

អត្តភាពដែលកើតឡើងចាកកាមនោះ ។ បទថា **បុញ្ញភាគិយំ** សេចក្តីថា អត្តភាពនៃបុគ្គលដែលប្រាថ្នាកាមជាទិព្វ ហើយកើតក្នុងទេវលោក ព្រោះសុចរិតធម៌បរិបូណ៌ ឈ្មោះថា **បុញ្ញភាគិយា** គឺជាចំណែកកុសល អត្តភាពនៃបុគ្គលដែលកើតក្នុងអបាយ ព្រោះទុច្ចរិតធម៌បរិបូណ៌ ឈ្មោះថា **អបុញ្ញ-ភាគិយ** ដែលចំណែកអកុសល ។

បទថា **អយំ វុច្ចតិ ភិក្ខវេ កាមានំ វិបាកោ** សេចក្តីថា អត្តភាពទាំង ២ នេះ ព្រះមានព្រះភាគត្រាស់ថា ជាវិបាករបស់កម្ម ព្រោះកើតឡើងដោយអាស្រ័យការប្រាថ្នាកាម ។ បទថា **សោ ឥមំ និព្វេធិកំ** សេចក្តីថា ភិក្ខុនោះ រមែងដឹងចរិយាដ៏ប្រសើរនេះ ដែលជាគ្រឿងចោះឋានៈ គឺអាយតនៈ ៣៦ យ៉ាង ។ បទថា **កាមនិរោធំ** សេចក្តីថា កាមនិរោធដែលបានមកយ៉ាងនេះ ព្រោះកាមទាំងឡាយរលត់ទៅ ។ ព្រោះថា ក្នុងទីនេះ ព្រះមានព្រះភាគត្រាស់ហៅមគ្គ ពោល គឺព្រហ្មចរិយៈនោះឯងថា ជាការរម្ងាត់កាម ។

បទថា **សាមិសា** សេចក្តីថា សម្បយុត្តដោយអាមិស គឺកិលេស ។ ក្នុងឋានៈ គឺភវៈទាំងអស់ គប្បីជ្រាបដោយន័យនេះ ។ម្យ៉ាងទៀត គប្បីជ្រាបក្នុងបទថា **វោហារវេបក្កំ** នេះ បានដល់ វោហារវិបាក អធិប្បាយថា វោហារ ពោល គឺពាក្យសម្តី ឈ្មោះថា វិបាករបស់សញ្ញា ។ បទថា **នំ** ក្នុងពាក្យថា **យថា នំ** នេះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ ដូច្នោះ ទើបមានអធិប្បាយថា ព្រោះហេតុដែលព្រះមានព្រះភាគត្រាស់ថា បុគ្គលចាំបានយ៉ាង

ណាៗ រមែងពោលទៅយ៉ាងនោះៗ ដោយគិតថា អាត្មាអញចាំបានយ៉ាងនេះ ដូច្នោះ ទើបឈ្មោះថា **វោហារវេបក្កំ** ។ បទថា **អវិជ្ជា** បានដល់ អវិជ្ជា ដ៏ក្រាស់ ដែលជាធម៌មិនដឹងឋានៈទាំង ៨ ។ អាសវៈទាំងឡាយ ឈ្មោះថា **និរយគាមិនិយា** ព្រោះឲ្យសត្វទៅនរក ជាហេតុឲ្យសត្វកើតក្នុងនរក ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។

បទថា **ចេតនាហំ** កាត់បទជា **ចេតនំ អហំ** ប្រែថា តថាគតពោលចេតនាថា ជាតួកម្ម ។ ក្នុងបទថា **ចេតនាហំ** នេះ ព្រះមានព្រះភាគទ្រង់សំដៅយកចេតនាដែលមានការតាក់តែង ដែលបានសង្គ្រោះធម៌គ្រប់យ៉ាង ។ បទថា **ចេតយិត្វា** បានដល់ ចេតនាដែលប្រព្រឹត្តទៅក្នុងទ្វារ ។ បទថា **មនសា** បានដល់ ចិត្តដែលសម្បយុត្តដោយចេតនា ។ បទថា **និរយវេទនិយំ** បានដល់ ឲ្យនូវវិបាកក្នុងនរក ។ ក្នុងបទទាំងឡាយដ៏សេស ក៏មានន័យនេះឯង ។

បទថា **អធិមត្តំ** បានដល់ ទុក្ខដ៏មានកម្លាំង ។ បទថា **ធន្ធវិរាគិ** សេចក្ដីថា ទុក្ខធ្ងន់ គឺទុក្ខដែលប្រាសទៅបានមិនរហ័ស បានដល់ ប្រាសចាកសន្សឹមៗ ទៅ ។ បទថា **ឧរត្តាឡឹ កន្ទតិ** បានដល់ គក់ទ្រូងកន្ទក់កន្ទេញ ។ បទថា **បរិយេដ្ឋឹ** បានដល់ ការស្វែងរក ។ បទថា **ឯកបទំ ទ្វិបទំ** បានដល់ ដឹងត្រឹមតែផ្លូវ ១ ឬផ្លូវ ២ ប្រាថ្នានឹងដឹងប្រមាណ ។ បទថា **សម្មោហវេបក្កំ** បានដល់ វិបាកនៃសម្មោហៈ អធិប្បាយថា ការវង្វេង ឈ្មោះថា ជាផលហូរចេញនៃសេចក្ដីទុក្ខ ។ ក្នុងបទទី ២ ក៏មានន័យនេះឯង ព្រោះថា ដល់នូវការ

ស្វែងរកដែលជាផលហូរចេញនៃសេចក្ដីទុក្ខនោះ ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ។ល។

### អដ្ឋកថា និព្វេធិកសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ពលសូត្រទី ១០

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតពល របស់ព្រះតថាគតនេះមាន ៦ ដែលព្រះតថាគតបានប្រកបដោយពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្មចក្រ ( ចក្រដ៏ប្រសើរ ) ឲ្យប្រព្រឹត្តទៅ ។ តថាគតពល ៦ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតក្នុងលោកនេះ ដឹងច្បាស់ជាក់លាក់នូវហេតុ តាមហេតុផង ដឹងច្បាស់ជាក់លាក់នូវអំពើ មិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ម្នាលភិក្ខុទាំង-ឡាយ ត្រង់ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវហេតុ តាមហេតុផង ដឹងច្បាស់ជាក់នូវអំពើ មិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ម្នាលភិក្ខុទាំងឡាយ នេះតថាគតពលរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញ៉ាំងព្រហ្ម-ចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវវិបាករបស់កុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយទាំងអតីត ទាំងអនាគត និងបច្ចុប្បន្នតាមបច្ច័យ តាមហេតុ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់ជាក់លាក់នូវវិបាករបស់កុសលកម្ម និងអកុសលកម្ម ដែលសត្វបានធ្វើហើយ ទាំងអតីត ទាំងអនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ដឹងច្បាស់ជាក់លាក់នូវសេចក្ដីសៅហ្មង សេចក្ដីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ។បេ។ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់តថាគត ដែលព្រះតថាគតបានអាស្រ័យពលហើយ ប្ដេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទ ក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតរឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺរឭកឃើញ ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត រឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺរឭក

បាន ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាស ជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធិ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមានចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធិ កន្លងហួសចក្ខុរបស់មនុស្សធម្មតា ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពលរបស់ព្រះតថាគត ដែលព្រះតថាគតបានអាស្រ័យពលហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតធ្វើឲ្យជាក់ច្បាស់សម្រេច ។បេ។ ព្រោះអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះជាតថាគតពល របស់ព្រះតថាគត ដែលព្រះតថាគត បានអាស្រ័យពលហើយ ប្តេជានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពលរបស់

ព្រះតថាគត ទាំង ៦ ប្រការនេះ ដែលព្រះតថាគតបានប្រកបដោយពល ហើយ ប្តេជ្ញានូវហេតុដ៏ប្រសើរ បន្លឺសីហនាទក្នុងពួកបរិស័ទ ញុំាងព្រហ្មចក្រ ឲ្យប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះ តថាគត ហើយសួរប្រស្នាត្រង់ការដឹងជាក់លាក់នូវហេតុ តាមហេតុផង នូវ អំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវហេតុតាមហេតុផង នូវអំពើមិនមែន ជាហេតុ តាមអំពើមិនមែនជាហេតុផង យ៉ាងណាៗ ព្រះតថាគត ក៏ឆ្លើយ ដោះប្រស្នា ដែលពួកជនទាំងនោះសួរហើយ តាមការដឹងជាក់លាក់នូវហេតុ តាមហេតុផង នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង យ៉ាង នោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករក ព្រះតថាគត ហើយសួរប្រស្នាត្រង់ការដឹងជាក់លាក់នូវវិបាករបស់កុសលកម្ម និងអកុសលកម្ម ដែលសត្វធ្វើហើយ ទាំងអតីត ទាំងអនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគតដឹងជាក់ លាក់ នូវវិបាករបស់កុសល និងអកុសលដែលសត្វធ្វើហើយ ទាំងអតីត ទាំង អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុយ៉ាងណាៗ ព្រះតថាគត ក៏ ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះ សួរហើយដោយការដឹងជាក់លាក់ នូវ វិបាករបស់កុសលកម្ម និងអកុសលកម្ម ដែលសត្វធ្វើហើយ ទាំងអតីត ទាំង អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុយ៉ាងនោះៗ បាន ។ ម្នាល

ភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគតហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិយ៉ាងណាៗ ព្រះតថាគតក៏ឆ្លើយដោះប្រស្នាដែលពួកជនទាំងនោះសួរហើយ ដោយការដឹង ជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិយ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់នូវបុព្វេនិវាសានុស្សតិ ម្នាលភិក្ខុទាំង-ឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវបុព្វេនិវាសានុស្សតិយ៉ាងណាៗ តថាគតក៏ឆ្លើយដោះប្រស្នា ដែលពួកជនទាំងនោះសួរហើយ តាមការដឹង ជាក់លាក់នូវបុព្វេនិវាសានុស្សតិ យ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករកព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹង ជាក់លាក់នូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ម្នាលភិក្ខុទាំង-ឡាយ ញាណដែលព្រះតថាគតដឹងជាក់លាក់ នូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយយ៉ាងណាៗ ព្រះតថាគតក៏ឆ្លើយដោះប្រស្នា ដែលពួកជនទាំងនោះសួរហើយ ដោយការដឹងជាក់លាក់នូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយយ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ បើជនទាំងឡាយដទៃ ចូលមករក

ព្រះតថាគត ហើយសួរប្រស្នា ត្រង់ការដឹងជាក់លាក់នូវសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ញាណដែលព្រះតថាគត ដឹងជាក់លាក់នូវសេចក្តីអស់ទៅ នៃអាសវៈទាំងឡាយយ៉ាងណាៗ ព្រះតថាគតក៏ឆ្លើយដោះប្រស្នា ដែលពួកជនទាំងនោះ សួរហើយតាមការដឹងជាក់លាក់ នូវសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ យ៉ាងនោះៗ បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការដឹងជាក់លាក់ នូវហេតុតាមហេតុផង នូវអំពើមិនមែនជាហេតុ តាមអំពើមិនមែនជាហេតុផង នោះថា ជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គល ដែលមានចិត្តមិនតាំងមាំទេ ។ តថាគតពោលនូវការដឹងជាក់លាក់នូវវិបាករបស់កុសលកម្ម និងអកុសលកម្ម ដែលសត្វធ្វើហើយ ទាំងអតីត ទាំងអនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុនោះជាជារបស់បុគ្គល ដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការដឹងជាក់លាក់នូវសេចក្តីសៅហ្មង សេចក្តីផូរផង់ និងការចេញចាកឈាន វិមោក្ខ សមាធិ និងសមាបត្តិនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការដឹងជាក់លាក់ នូវបុព្វេនិវាសានុស្សតិនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ តថាគតពោលនូវការដឹងជាក់លាក់នូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយនោះ ថាជារបស់

បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គលដែលមានចិត្តមិនតាំងមាំទេ ។ តថាគតពោលនូវការដឹងជាក់លាក់នូវសេចក្តីអស់ទៅ នៃអាសវៈទាំងឡាយនោះ ថាជារបស់បុគ្គលដែលមានចិត្តតាំងមាំ មិនមែនរបស់បុគ្គល ដែលមានចិត្តមិនតាំងមាំទេ ។ ម្នាលភិក្ខុទាំងឡាយ សមាធិ ជាផ្លូវត្រូវ អសមាធិជាផ្លូវខុស ដូចបានសម្តែងមកហើយ ។

មហាវគ្គទី ១ ចប់

## ឧទ្ទាននៃមហាវគ្គនោះ គឺ

និយាយអំពីរឿង ព្រះថេរៈឈ្មោះសោណៈ ១ ព្រះថេរៈឈ្មោះផគ្គុណៈ ១ អភិជាតិ ៦ យ៉ាង ១ អាសវៈទាំងឡាយ ១ រឿងទារុកម្មិកៈជ្រះថ្លានឹងភិក្ខុ ៥ រូប ១ ចិត្តហត្ថិសារីបុត្ត ១ មេត្តេយ្យបញ្ហាក្នុងបរាយនវគ្គ ១ ព្រះអានន្ទ ចុះទៅជម្រះខ្លួន ក្នុងទឹកស្ទឹងអចិរវតី ១ និព្វេធិកបរិយាយ ១ ពល ៦ យ៉ាង ១ ។

# អដ្ឋកថា

## ពលសូត្រ

[ ៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពលសូត្រទី ១០ ដូចតទៅនេះ បទថា **អាសភណ្ឋានំ** បានដល់ ឋានៈដ៏ប្រសើរ គឺឋានៈដែលមិនញាប់ញ័រ ។ បទថា

**សីហនាទំ** បានដល់ ការបន្លឺដោយមិនខ្លាចក្រែង គឺបន្លឺក្នុងឋានៈជាប្រមុខ ។ បទថា **ព្រហ្មចក្កំ** បានដល់ ចក្រ គឺញាណដ៏ប្រសើរ គឺបដិវេធញ្ញាណ និងញាណដ៏សេស ។ បទថា **ឋានញ្ច ឋានតោ** បានដល់ ដឹងហេតុ ដោយភាពជាហេតុ ។ បទថា **យម្បិ** សេចក្តីថា ដោយញាណណា ។ បទថា **ឥទម្បិ តថាគតស្ស** សេចក្តីថា ឋានាឋានញ្ញាណនេះ ឈ្មោះថា ជាតថាគតពលរបស់ព្រះតថាគត ។ ក្នុងបទទាំងពួង ក៏គប្បីជ្រាបយ៉ាងនេះ ។ បទថា **កម្មសមាទានានំ** បានដល់ កុសលកម្ម និងអកុសលកម្ម ដែលបុគ្គលតាំងចិត្តធ្វើហើយ ។ ម្យ៉ាងទៀត កម្មនោះឯង ឈ្មោះថា **កម្មសមាទាន ។** បទថា **ឋានសោ ហេតុសោ** សេចក្តីថា ដោយបច្ច័យផង ដោយហេតុផង ។ បណ្តាឋានៈ និងហេតុទាំង ២ យ៉ាងនោះ គតិ មានកំណើតនរកជាដើម ឧបធិ គឺអត្តភាព កាល គឺពេលដែលកម្មឲ្យផល បយោគ គឺការប្រកបកម្ម ជាឋានៈនៃវិបាក កម្មជាហេតុនៃវិបាក ។ បទថា **ឈានវិមោក្ខសមាធិសមាបត្តីនំ** បានដល់ ឈាន ៤ វិមោក្ខ ៨ សមាធិ ៣ អនុបុព្វសមាបត្តិ ៩ ។ បទថា **សង្កិលេសំ** បានដល់ ធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីវិនាស ។ បទថា **វោទានំ** បានដល់ ធម៌ដែលជាចំណែកនៃគុណវិសេស ។ បទថា **វុដ្ឋានំ** បានដល់ ឈានដែលស្ទាត់ជំនាញ ដែលត្រាស់យ៉ាងនេះថា **វោទាន** ក៏ឈ្មោះថា **វុដ្ឋាន** សូម្បីការចេញអំពីសមាធិនោះៗ ក៏ឈ្មោះថា វុដ្ឋាន ១ ភវង្គ និងផលសមាបត្តិ ១ ព្រោះថា ឈានដែលស្ទាត់ជំនាញខាងក្រោមៗ ជា

បាទរបស់ឈានខាងលើៗ ព្រោះដូច្នោះ ទើបរៀកទាន ទ្រង់ត្រាស់ថា ជាវុដ្ឋាន ឯការចេញចាកឈានទាំងពួង រមែងមានបានដោយភវង្គ ។ ការចេញចាកនិរោធសមាបត្តិមានដោយផលសមាបត្តិ ព្រះពុទ្ធវចនៈថា សូម្បីការចេញចាកសមាធិនោះៗ ក៏ឈ្មោះថា វុដ្ឋាន ដូច្នេះ ទ្រង់ត្រាស់បំណងយកការចេញអំពីនិរោធសមាបត្តិនោះ ។

បទថា **អនេកវិហិតំ** ជាដើម បានពណ៌នាហើយ ក្នុងវិសុទ្ធិមគ្គ ។ អាសវក្ខយញ្ញាណ ក៏មានអត្ថដូចពោលហើយ ខាងដើមនោះឯង បុគ្គលបំណងជ្រាបសេចក្តីពិស្តារនៃញាណទាំង ៣ ខាងដើម គប្បីពិនិត្យមើលអត្ថដែលពណ៌នាក្នុងមហាសីហនាទសូត្រ ក្នុងអដ្ឋកថាមជ្ឈិមនិកាយ ។ បទថា **សមាហិតស្ស** ប្រែថា បុគ្គលមានចិត្ត មានអារម្មណ៍តែមួយ ។ បទថា **សមាធិ មគ្គោ** សេចក្តីថា សមាធិ ជាឧបាយដើម្បីសម្រេចឈានទាំងនេះ ។ ការមិនមានចិត្តជាឯកគ្គតា ឈ្មោះថា **អសមាធិ** ។ ផ្លូវដែលខុស ឈ្មោះថា **កុម្មគ្គ** ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ដល់កម្លាំងញាណ របស់ព្រះតថាគត ។ល។

**អដ្ឋកថា ពលសូត្រទី ១០ ចប់**

**មហាវគ្គទី ១ ចប់**

# សុត្តន្តបិដក
# អង្គុត្តរនិកាយ ឆក្កនិបាត
# សត្តមភាគ
# ទុតិយបណ្ណាសក

## ទេវតាវគ្គ
### អនាគាមិសូត្រទី ១

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបានឡើយ ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង គួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបាន ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីមិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលបាន ។

# អដ្ឋកថា

## ទេវតាវគ្គទី ២

### អនាគាមិសូត្រ

[ ៦៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអនាគាមិសូត្រទី ១ នៃទេវតាវគ្គទី ២ ដូចតទៅនេះ បទថា **អស្សទ្ធិយំ** បានដល់ ភាពជាអ្នកមិនមានសទ្ធា ។ បទថា **ទុប្បញ្ញតំ** បានដល់ ភាពជាអ្នកមិនមានបញ្ញា ។ល។

អដ្ឋកថា អនាគាមិសូត្រទី ១ ចប់

# សុត្តន្តបិដក

## អរហត្តសូត្រទី ២

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបានទេ ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីប្រអូសចិត្ត ១ សេចក្តីប្រអូសកាយ ១ សេចក្តីរាយមាយចិត្ត ១ សេចក្តីសោប់សេល់ចិត្ត ១ សេចក្តីមិនជឿ ១ សេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌

៦ យ៉ាង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។ ធម៌ ៦ យ៉ាង គឺអ្វីខ្លះ ។ គឺសេចក្តីប្រមូសចិត្ត ១ សេចក្តីប្រមូសកាយ ១ សេចក្តីរាយមាយចិត្ត ១ សេចក្តីរសាប់រសល់ចិត្ត ១ សេចក្តីមិនជឿ ១ សេចក្តីធ្វេសប្រហែស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់នូវធម៌ ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។

# អដ្ឋកថា

## អរហត្តសូត្រ

[ ៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរហត្តសូត្រទី ២ ដូចតទៅនេះ បទថា **បមាទំ** បានដល់ ការនៅដោយប្រាសចាកសតិ ។ល។

**អដ្ឋកថា អរហត្តសូត្រទី ២ ចប់**

# សុត្តន្តបិដក

## មិត្តសូត្រទី ៣

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ បែរទៅរកតែបុគ្គលអាក្រក់ សេពគប់ ចូលទៅអង្គុយជិតពួកមិត្តអាក្រក់ យកតម្រាប់តម្រាតាមពួកមិត្តអាក្រក់ទាំងនោះ នឹងបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានឡើយ ។ បើមិនបានបំពេញអភិសមាចារិកធម៌ឲ្យបរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសេក្ខធម៌ឲ្យបរិបូណ៌ហើយ នឹងបំពេញសីលទាំងឡាយ ឲ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសីលទាំងឡាយឲ្យបរិបូណ៌បានទេ នឹងលះបង់កាមរាគៈ ឬរូបរាគៈ ឬក៏អរូបរាគៈបាន ហេតុនេះក៏មិនដែលមានទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ មានមិត្តល្អ មានសម្លាញ់ល្អ បែរទៅរកតែមិត្តល្អ សេពគប់ ចូលទៅអង្គុយជិតចំពោះពួកមិត្តល្អ ហើយក៏យកតម្រាប់តម្រាតាមពួកមិត្តល្អទាំងនោះ នឹងបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌បាន ហេតុនេះ ទើបមានមែន ។ បើបានបំពេញអភិសមាចារិកធម៌ ឲ្យបរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ ឲ្យបរិបូណ៌បានទៀត ហេតុនេះ ទើបមានមែន ។ បើបានបំពេញសេក្ខធម៌ហើយ នឹងបំពេញសីលទាំងឡាយបានទៀត ហេតុនេះ ទើបមានមែន ។ បើបានបំពេញសីលទាំងឡាយហើយ នឹងលះបង់កាមរាគៈ ឬរូបរាគៈ ឬក៏អរូបរាគៈចេញបាន ហេតុនេះ ទើបមានមែន ។

# អដ្ឋកថា

## មិត្តសូត្រ

[ ៦៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមិត្តសូត្រទី ៣ ដូចតទៅនេះ បទថា **អាភិសមាចារិកំ** បានដល់ ធម៌ដែលជាសមាចារដ៏ឧត្តម គឺសីលដែលជាបញ្ញត្តដោយអំណាចនៃវត្ត ។ បទថា **សេក្ខធម្មំ** បានដល់ សីលជាបញ្ញត្តិដែលទាក់ទងនឹងសេក្ខិយវត្ត ។ បទថា **សីលានិ** បានដល់ មហាសីល ៤ ។

**អដ្ឋកថា មិត្តសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ឋានសូត្រទី ៤

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នករីករាយ ក្នុងការប្រឞូកប្រឞល់ដោយពួក ត្រេកអរក្នុងការប្រឞូកប្រឞល់ដោយពួក ប្រកបសេចក្តីត្រេកអរ ក្នុងការប្រឞូកប្រឞល់ដោយពួក រីករាយក្នុងពួក ត្រេកអរក្នុងពួក ប្រកបសេចក្តីត្រេកអរក្នុងពួកហើយ ត្រេកអរក្នុងវិវេកតែម្នាក់ឯងបាន ហេតុនេះមិនដែលមានឡើយ ។ កាលបើមិនត្រេកអរក្នុងវិវេក តែម្នាក់ឯង ទើបអាចនឹងទទួលយកនិមិត្តនៃចិត្តបាន ហេតុនេះមិនដែលមានឡើយ ។ កាលបើមិនទទួលយកនិមិត្តនៃចិត្តហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនេះ មិនដែលមាន

ឡើយ ។ លុះមិនបានបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបាន ហេតុនេះ មិនដែលមានឡើយ ។ បើមិនបំពេញសម្មាសមាធិហើយ នឹងលះបង់សញ្ញោជនៈទាំងឡាយបាន ហេតុនេះ មិនដែលមានឡើយ ។ បើមិនលះបង់សញ្ញោជនៈទាំងឡាយ ហើយនឹងធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានបាន ហេតុនោះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទាល់តែភិក្ខុនោះ មិនរីករាយក្នុងការប្រឡូកប្រឡល់ដោយពួក មិនត្រេកអរ ក្នុងការប្រឡូកកប្រឡល់ដោយពួក មិនប្រកបសេចក្ដីត្រេកអរ ក្នុងការប្រឡូកប្រឡល់ដោយពួក មិនរីករាយក្នុងពួក មិនត្រេកអរក្នុងពួក មិនប្រកបសេចក្ដីរីករាយ ក្នុងពួកហើយ ត្រេកអរក្នុងវិវេកតែម្នាក់ឯងបាន ហេតុនេះ ទើបមានមែន ។ កាលបើត្រេកអរក្នុងវិវេកតែម្នាក់ឯងហើយ នឹងទទួលយកនិមិត្តនៃចិត្តបាន ហេតុនេះ ទើបមានមែន ។ កាលបើទទួលយកនិមិត្តនៃចិត្តហើយ នឹងបំពេញសម្មាទិដ្ឋិបាន ហេតុនោះ ទើបមានមែន ។ បើបំពេញសម្មាទិដ្ឋិហើយ នឹងបំពេញសម្មាសមាធិបានទៀត ហេតុនេះ ទើបមានមែន ។ បើបំពេញសម្មាសមាធិហើយនឹងលះបង់សញ្ញោជនៈទាំងឡាយបាន ហេតុនេះ ទើបមានមែន ។ លះបង់សញ្ញោជនៈទាំងឡាយហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបាន ហេតុនេះ ទើបមានមែន ។

# អដ្ឋកថា

## ឋានសូត្រ

[ ៦៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឋានសូត្រទី ៤ ដូចតទៅនេះ បទថា **សង្គណិការាមោ** សេចក្តីថា ត្រេកអរដោយការប្រឡូកប្រឡំក្នុងពួកគណៈ ។ ចំណែកភិក្ខុ ឈ្មោះថា **គណារាម** ព្រោះត្រេកអរក្នុងគណៈ មានគណៈសិក្សាព្រះសូត្រជាដើម ឬក្នុងគណៈ ពោល គឺបរិស័ទនៃខ្លួន ។ បទថា **បវិវេកេ** បានដល់ កាយវិវេក ។ បទថា **ចិត្តស្ស និមិត្តំ** សេចក្តីថា និមិត្តនៃសមាធិចិត្ត និងវិបស្សនាចិត្ត គឺអាការរបស់សមាធិ និងវិបស្សនា ។ បទថា **សម្មាទិដ្ឋឹ** បានដល់ សម្មាទិដ្ឋិក្នុងវិបស្សនា ។ បទថា **សមាធឹ** បានដល់ មគ្គសមាធិ និងផលសមាធិ ។ បទថា **សំយោជនានិ** បានដល់ សំយោជនៈ ១០ យ៉ាង ។ បទថា **និព្វានំ** បានដល់ អប្បច្ចយបរិនិព្វាន ។ល។

**អដ្ឋកថា ឋានសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ទេវតាសូត្រទី ៩

[ ៦៩ ] គ្រានោះ ទេវតាមួយអង្គ កាលបើរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីភ្លឺ ញុំាងវត្តជេតពនជុំវិញទាំងអស់ ឲ្យភ្លឺស្វាង ហើយចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចឈរនៅក្នុងទីដ៏សមគួរ ។ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង ដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីមិនសាបសូន្យដល់ភិក្ខុ ។ ទេវតានោះ បានក្រាបទូលពាក្យនេះហើយ ។ ព្រះសាស្តាទ្រង់សព្វព្រះហឫទ័យ ។ គ្រានោះ ទេវតានោះ បានដឹងថា ព្រះសាស្តាសព្វព្រះហឫទ័យនឹងអញហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយបាត់ក្នុងទីនោះឯង ។ លំដាប់ពីនោះមក ព្រះដ៏មានព្រះភាគ កាលដែលរាត្រីនោះ កន្លងទៅហើយ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញមានទេវតាមួយរូប កាលដែលរាត្រីបឋមយាមកន្លងទៅហើយ មានរស្មីដ៏ភ្លឺ ធ្វើវត្តជេតពនជុំវិញទាំងអស់ឲ្យភ្លឺស្វាង ហើយចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ក្រាបថ្វាយ

បង្គំតថាគត រួចឈរក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ បាននិយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ធម៌ ៦ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីគោរពក្នុងព្រះសាស្តា ១ សេចក្តីគោរពក្នុងព្រះធម៌ ១ សេចក្តីគោរពក្នុងព្រះសង្ឃ ១ សេចក្តីគោរពក្នុងសិក្ខា ១ ភាពជាអ្នកប្រដៅងាយ ១ ភាពជាអ្នកមានមិត្តល្អ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ ៦ យ៉ាងនេះឯង ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសាបសូន្យដល់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ទេវតានោះបាននិយាយយ៉ាងនេះ លុះនិយាយពាក្យនេះចប់ហើយ ក៏ថ្វាយបង្គំតថាគតដើរប្រទក្សិណហើយបាត់ក្នុងទីនោះ ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តដ៏មានអាយុ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយល់សេចក្តីអធិប្បាយនៃធម៌ ដែលព្រះដ៏មានព្រះភាគ សម្តែងបង្រួញនេះ ដោយសេចក្តីពិស្តារយ៉ាងនេះបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ជាអ្នកគោរពក្នុងព្រះសាស្តា ដោយខ្លួនឯងផង ជាអ្នកនិយាយសរសើរគុណនៃសេចក្តីគោរពក្នុងព្រះសាស្តាផង ពួកភិក្ខុណា មិនគោរពក្នុងព្រះសាស្តាទេ ក៏ដឹកនាំពួកភិក្ខុនោះឲ្យគោរពក្នុងព្រះសាស្តាផង ។ ពួកភិក្ខុណាជាអ្នកគោរពព្រះសាស្តាស្រាប់ ក៏និយាយសរសើរគុណរបស់ពួកភិក្ខុនោះដែលមានពិតប្រាកដ តាមកាលគួរផង ជាអ្នកគោរពក្នុងព្រះធម៌ ដោយខ្លួន

ឯងផង ។បេ។ ជាអ្នកគោរពក្នុងព្រះសង្ឃ ជាអ្នកគោរពក្នុងសិក្ខា ជាអ្នកប្រដៅងាយ ។បេ។ ជាអ្នកមានមិត្តល្អ និយាយសរសើរគុណ នៃការមានមិត្តល្អផង បើពួកភិក្ខុណា ជាអ្នកឥតមានមិត្តល្អទេ ក៏ដឹកនាំពួកភិក្ខុទាំងនោះឲ្យមានមិត្តល្អផង បើពួកភិក្ខុណា ជាអ្នកមានមិត្តល្អស្រាប់ហើយ ក៏និយាយសរសើរគុណ របស់ពួកភិក្ខុនោះ ដែលមានពិតប្រាកដ តាមកាលដ៏គួរផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គយល់ច្បាស់ នូវសេចក្តីអធិប្បាយនៃធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបំព្រួញនេះ ដោយសេចក្តីពិស្តារ យ៉ាងនេះបាន ម្នាលសារីបុត្ត ត្រូវហើយ ត្រូវហើយ ម្នាលសារីបុត្ត អ្នកបានយល់ច្បាស់ នូវសេចក្តីអធិប្បាយនៃធម៌ដែលតថាគតសម្តែងបំព្រួញនេះ ដោយសេចក្តីពិស្តារ យ៉ាងនេះបាន ប្រពៃណាស់ ។ ម្នាលសារីបុត្ត ភិក្ខុក្នុងសាសនានេះ ជាអ្នកគោរពក្នុងសាស្តា ដោយខ្លួនឯងផង និយាយសរសើរគុណ នៃសេចក្តីគោរពក្នុងសាស្តាផង បើពួកភិក្ខុណា មិនគោរពក្នុងសាស្តាទេ ក៏ដឹកនាំពួកភិក្ខុទាំងនោះ ឲ្យគោរពក្នុងសាស្តាផង បើពួកភិក្ខុណាគោរពក្នុងសាស្តាស្រាប់ហើយ ក៏និយាយសរសើរគុណរបស់ពួកភិក្ខុទាំងនោះ ដែលមានពិតប្រាកដ តាមកាលគួរផង ។ ជាអ្នកគោរពក្នុងធម៌ ដោយខ្លួនឯងផង ។បេ។ ជាអ្នកគោរពក្នុងសង្ឃ ជាអ្នកគោរពក្នុងសិក្ខា ជាអ្នកប្រដៅងាយ ។បេ។ ជាអ្នកមានមិត្តល្អ ជាអ្នកសរសើរគុណនៃការមានមិត្តល្អផង បើពួកភិក្ខុណា ជាអ្នកឥតមិត្តល្អទេ ក៏បបួលពួកភិក្ខុទាំងនោះ ឲ្យមានមិត្តល្អផង បើភិក្ខុណា

ជាអ្នកមានមិត្តល្អស្រាប់ហើយ ក៏និយាយសរសើរគុណ របស់ពួកភិក្ខុទាំងនោះ ដែលមានពិតប្រាកដ តាមកាលគួរផង ។ ម្នាលសារីបុត្ត សេចក្ដីអធិប្បាយនៃធម៌ ដែលតថាគតសម្ដែងបំប្រួញនេះ អ្នកគួរដឹងដោយសេចក្ដីពិស្ដារ យ៉ាងនេះចុះ ។

# អដ្ឋកថា

## ទេវតាសូត្រ

[ ៦៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទេវតាសូត្រទី ៥ ដូចតទៅនេះថា ភាពជាអ្នកប្រដៅងាយ ឈ្មោះថា **សោវចស្សតា** ។ ភាពជាអ្នកមានមិត្រល្អ ឈ្មោះថា **កល្យាណមិត្តតា**។ បទថា **សត្ថុគារវោ** បានដល់ ដែលប្រកបទៅដោយសេចក្ដីគោរពក្នុងព្រះសាស្ដា ។ ក្នុងបទទាំងពួង ក៏មានន័យដូច្នេះ ។៚

**អដ្ឋកថា ទេវតាសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សតិសូត្រទី ៦

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមិនមានសមាធិ ដ៏ស្ងប់រម្ងាប់ មិនមានសមាធិដ៏ឧត្តម មិនមានទូវបដិប្បស្សទ្ធិ មិនដល់នូវឯកោទិភាព ហើយនឹងបាននូវឥទ្ធិវិធៈច្រើនប្រការ គឺមនុស្សម្នាក់ធ្វើឲ្យទៅជាច្រើននាក់បាន ឬមនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់បាន ។បេ។ នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយរហូតដល់ព្រហ្មលោកបាន ហេតុនេះមិនមានឡើយ ។ ឮនូវសំឡេងទាំង ២ ពួក គឺជាសំឡេងទេវតា និងសំឡេងមនុស្ស ឆ្ងាយក្តី ជិតក្តី ដោយសោតធាតុ ដូចជាទិព្វដ៏បរិសុទ្ធិ កន្លងហួសសោតធាតុជារបស់មនុស្សធម្មតាបាន ហេតុនេះមិនមានឡើយ ។ កំណត់ដឹងនូវចិត្ត របស់សត្វទាំងឡាយដទៃ របស់បុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ។បេ។ ចិត្តមិនទាន់ផុតចាកកិលេសក្តី ក៏ដឹងថា ចិត្តមិនទាន់ផុតចាកកិលេស ហេតុនេះ មិនមានឡើយ ។ រឭកឃើញនូវបុព្វេនិវាស គឺលំដាប់ខន្ធ ដែលសត្វអាស្រ័យនៅ ក្នុងកាលមុនជាច្រើនប្រការ គឺរឭកឃើញ ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាសមានប្រការដ៏ច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ហេតុនេះមិនមានឡើយ ។ មានចក្ខុដ៏បរិសុទ្ធិដូចជាទិព្វ កន្លងចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វ ។បេ។ ដឹងនូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ហេតុនេះមិនមានឡើយ ។ ព្រោះអស់អាសវៈទាំងឡាយ ។បេ។

ធ្វើឲ្យជាក់ច្បាស់ បានដល់ ហេតុនេះ មិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមានសមាធិដ៏ល្អិតដ៏ឧត្តម បាននូវបដិប្បស្សទ្ធិ បានដល់នូវឯកោទិភាព បាននូវឥទ្ធិវិធៈច្រើនប្រការ ។បេ។ នឹងធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយរហូតដល់ព្រហ្មលោកបាន ហេតុនេះទើបមាន ។ អាចឮនូវសំឡេងទាំង ២ ពួក គឺសំឡេងទេវតា ១ សំឡេងមនុស្ស ១ ទោះនៅឆ្ងាយក្តី ជិតក្តី ដោយសោតធាតុ ដូចជាទិព្វដ៏បរិសុទ្ធិ កន្លងសោតធាតុរបស់មនុស្សធម្មតា ហេតុនេះទើបមាន អាចកំណត់ដឹងនូវចិត្តរបស់សត្វទាំង-ឡាយដទៃ របស់បុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ។បេ។ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងថា ចិត្តមិនទាន់រួចស្រឡះ ហេតុនេះ ទើបមាន ។ រឭកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន គឺរឭកឃើញ ១ ជាតិ ២ ជាតិ ។បេ។ រឭកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ហេតុនេះ ទើបមាន ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធិកន្លងចក្ខុរបស់មនុស្សធម្មតា អាចឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ សម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ហេតុនេះ ទើបមាន ។ ធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ហេតុនេះ ទើបមាន ។

# អដ្ឋកថា

## សតិសូត្រ

[ ៧០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសតិសូត្រទី ៦ ដូចតទៅនេះ បទថា **ន សន្តេន** សេចក្តីថា មិនស្ងប់ចាកកិលេសដែលជាសត្រូវទាំងឡាយ ។ បទថា **ន បណីតេន** សេចក្តីថា មិនមែនដោយសមាធិដែលមិនក្តៅក្រហាយ ។ បទថា **ន បដិប្បស្សទ្ធិលទ្ធេន** សេចក្តីថា ដោយសមាធិដែលមិនបាន គឺមិនបានសម្រេចដោយការស្ងប់រម្ងាប់នៃកិលេស ។ បទថា **ន ឯកោទិភាវាធិគតេន** សេចក្តីថា សមាធិដែលមិនចូលដល់ភាពជាបុគ្គលមានឯកគ្គតារម្មណ៍ ។ល។

**អដ្ឋកថា សតិសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## សក្ខិសូត្រទី ៧

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង កាលបើមានហេតុ មិនគួរដើម្បីដល់នូវសេចក្តីជាក់ច្បាស់ក្នុងគុណវិសេសនោះៗ ទេ ។ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្តីសាបសូន្យ ១ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃការតាំងនៅ ១ មិនដឹងច្បាស់តាមពិតថា

នេះពួកធម៌ជាចំណែកដ៏វិសេស ១ មិនដឹងច្បាស់តាមពិតថា នេះពួកធម៌ជាចំណែកនៃសេចក្ដីនឿយណាយ ១ ជាអ្នកមិនធ្វើដោយសេចក្ដីគោរព ១ ជាអ្នកមិនធ្វើសេចក្ដីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើមានហេតុ មិនគួរដល់នូវសេចក្ដីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ ទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង កាលបើមានហេតុ គួរដើម្បីដល់នូវសេចក្ដីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ បាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះ ពួកធម៌ជាចំណែកនៃសេចក្ដីសាបសូន្យ ១ ដឹងច្បាស់តាមពិតថា នេះ ពួកធម៌ជាចំណែកនៃការតាំងនៅ ១ ដឹងច្បាស់តាមពិតថា នេះ ពួកធម៌ជាចំណែកដ៏វិសេស ១ ដឹងច្បាស់តាមពិតថា នេះ ពួកធម៌ជាចំណែកនៃសេចក្ដីនឿយណាយ ១ ជាអ្នកធ្វើដោយសេចក្ដីគោរព ១ ជាអ្នកធ្វើសេចក្ដីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើមានហេតុ គួរដើម្បីដល់នូវសេចក្ដីជាក់ច្បាស់ ក្នុងគុណវិសេសនោះៗ បាន ។

# អដ្ឋកថា

## សក្ខិសូត្រ

[ ៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសក្ខិសូត្រទី ៧ ដូចតទៅនេះ បទថា **តត្រ តត្រ** ស្មើគ្នានឹង **តស្មឹ តស្មឹ វិសេសេ** ប្រែថា ក្នុងគុណវិសេសនោះៗ ។ បទថា **សក្ខិភព្វតំ** បានដល់ ការដឹងច្បាស់ប្រចក្ស ។ បទថា **អាយតនេ** បានដល់ ក្នុងកាលហេតុ ។ ធម៌ទាំងអស់ មានហានភាគិយធម៌ជាដើម ខ្ញុំបានពណ៌នាហើយ ក្នុងគម្ពីរឈ្មោះវិសុទ្ធិមគ្គ ។ បទថា **អសក្កច្ចការី** បានដល់ ធ្វើមិនឲ្យល្អ គឺមិនធ្វើដោយអើពើ ។ បទថា **អសប្បាយការី** បានដល់ មិនធ្វើឲ្យជាទីសប្បាយ គឺមិនធ្វើឲ្យជាធម៌មានឧបការៈ ។

**អដ្ឋកថា សក្ខិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ពលសូត្រទី ៨

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង មិនគួរដើម្បីដល់នូវភាពជាអ្នកមានកម្លាំងក្នុងសមាធិ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនឈ្លាសក្នុងការចូលសមាធិ ១ មិនឈ្លាសក្នុងការតាំងនៅក្នុងសមាធិ ១ មិនឈ្លាសក្នុងការចេញចាកសមាធិ ១ មិនធ្វើនូវសេចក្ដីគោរព ១ មិនធ្វើរឿយៗ ១ មិនធ្វើសេចក្ដីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបដោយធម៌ ៦ យ៉ាងនេះឯង

ជាអ្នកមិនគួរដើម្បីដល់នូវភាពជាអ្នកមានកម្លាំងក្នុងសមាធិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីដល់នូវភាពជាអ្នកមានកម្លាំងក្នុងសមាធិ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងការចូលសមាធិ ១ ឈ្លាសក្នុងការតាំងនៅក្នុងសមាធិ ១ ឈ្លាសក្នុងការចេញចាកសមាធិ ១ ធ្វើនូវសេចក្តីគោរព ១ ធ្វើរឿយៗ ១ ធ្វើសេចក្តីសប្បាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីដល់នូវភាពជាអ្នកមានកម្លាំងក្នុងសមាធិ ។

# អដ្ឋកថា

## ពលសូត្រ

[ ៧២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពលសូត្រទី ៨ ដូចតទៅនេះ បទថា **ពលតំ** បានដល់ ភាពជាអ្នកមានកម្លាំង គឺភាពជាអ្នកមានកម្លាំងក្នុងសមាធិ ។ បទថា **អសាតច្ចការី** សេចក្តីថា មិនធ្វើឲ្យ ជាប់តគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលហើយខាងដើមនោះឯង ។

**អដ្ឋកថា ពលសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមជ្ឈានសូត្រទី ៩

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរបានបឋមជ្ឈាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ទោសក្នុងកាមទាំងឡាយ បុគ្គលនោះមិនបានពិចារណាឲ្យឃើញច្បាស់ ដោយប្រាជ្ញារបស់ខ្លួនតាមពិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរបានបឋមជ្ឈានឡើយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ទើបជាអ្នកគួរបានបឋមជ្ឈាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ទោសក្នុងកាមទាំងឡាយ បុគ្គលនោះពិចារណាឃើញ ដោយប្រាជ្ញារបស់ខ្លួនតាមពិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរបានបឋមជ្ឈាន ។

# អដ្ឋកថា

## បឋមជ្ឈានសូត្រ

[ ៧៣ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមជ្ឈានសូត្រទី ៩ ដូចតទៅនេះ បទថា* **ន យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋោ ហោតិ** *សេចក្តីថា ទោសក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយ បុគ្គលរមែងមិនឃើញច្បាស់ហើយតាមសេចក្តីពិត ដោយឈាន និងបញ្ញា ។*

**អដ្ឋកថា បឋមជ្ឈានសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទុតិយជ្ឈានសូត្រទី ១០

[ ៧៤ ] *ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរបានបឋមជ្ឈាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហិង្សាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរបានបឋមជ្ឈានទេ ។*

*ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ទើបជាអ្នកគួរបានបឋមជ្ឈាន ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១*

វិហិង្សាវិតក្ក ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរបាន បឋមជ្ឈាន ។

*ទេវតាវគ្គទី ២ ចប់*

**ឧទ្ទាននៃទេវតាវគ្គនោះគឺ**

និយាយអំពីអនាគាមិបុគ្គល ១ ព្រះអរហន្ត ១ មិត្ត
១ រឿងទេវតា ១ កាលបើមានហេតុ មិនគួរដល់
នូវសេចក្តីជាក់ច្បាស់ ១ កម្លាំង ( ក្នុងសមាធិ )
១ បឋមជ្ឈាន ១ ឈាន ២ លើកឯទៀត ១ ។

# អដ្ឋកថា

## ទុតិយជ្ឈានសូត្រ

[ ៧៤ ] ក្នុងទុតិយជ្ឈានសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា ទុតិយជ្ឈានសូត្រទី ១០ ចប់**

**ទេវតាវគ្គទី ២ ចប់**

# សុត្តន្តបិដក

## អរហន្តវគ្គ

### ទុក្ខសូត្រទី ១

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាកចង្អៀតចង្អល់ ក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងទុគ្គតិ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហិង្សាវិតក្ក ១ កាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហិង្សាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ហើយ ទៅកើតក្នុងទុគ្គតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង តែងនៅជាសុខ មិនមានសេចក្តីលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ហើយ តែងមានសុគតិជាទីសង្ឃឹម ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺនេក្ខម្មវិតក្ក ១ អព្យាបាទវិតក្ក ១ អវិហឹសាវិតក្ក ១ នេក្ខម្មសញ្ញា ១ អព្យាបាទសញ្ញា ១ អវិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង រមែងនៅជាសុខ មិនមានសេចក្តីលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់

ហើយ តែងមានសុគតិជាទីសង្ឃឹម ។

# អដ្ឋកថា

# អរហន្តវគ្គទី ៣

## ទុក្ខសូត្រ

[ ៧៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុក្ខសូត្រទី ១ នៃអរហន្តវគ្គទី ៣ ដូចតទៅនេះ បទថា **សវិឃាតំ** សេចក្តីថា ប្រកបទៅដោយការបង្កៀតបង្អល់ គឺមានឧបទ្រវ ។ បទថា **សបរិឡាហំ** សេចក្តីថា មានការក្រវល់ក្រវាយ ដោយការក្រវល់ក្រវាយផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ទាដិកង្ខា** សេចក្តីថា គប្បីសង្ឃឹម គឺមានពិតប្រាកដ ។l១៚

**អដ្ឋកថា ទុក្ខសូត្រទី ១ ចប់**

# សុត្តន្តបិដក

## អរហត្តសូត្រទី ២

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ ៦ យ៉ាង ជាអ្នកមិនគួរធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីប្រកាន់ដោយអាងជាតិជាដើម ១ សេចក្តីប្រកាន់ថា អញថោកទាប ១ សេចក្តីប្រកាន់ថា ខ្ពង់ខ្ពស់ ១ សេចក្តីប្រកាន់ថា លើសលុប ១ រឹងត្អឹង ១ សេចក្តីប្រកាន់ថា អញថោកថយជាងគេ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះបង់ធម៌ទាំង ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តទេ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីប្រកាន់ដោយអាងជាតិជាដើម ១ សេចក្តីប្រកាន់ថាថោកទាប ១ សេចក្តីប្រកាន់ថាខ្ពង់ខ្ពស់ ១ សេចក្តីប្រកាន់ថា លើសលុប ១ រឹងត្អឹង ១ សេចក្តីប្រកាន់ថាថោកថយជាងគេ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ទាំង ៦ យ៉ាងនេះឯង ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តបាន ។

# អដ្ឋកថា

## អរហត្តសូត្រ

[ ៧៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរហត្តសូត្រទី ២ ដូចតទៅនេះ បទថា **មានំ** បានដល់ ការសម្គាល់ខ្លួនដោយជាតិជាដើម ។ បទថា **ឱមានំ** បានដល់ សម្គាល់ខ្លួនថា អាត្មាអញជាមនុស្សអាក្រក់ ។ បទថា **អតិមានំ** បានដល់ ប្រកាន់ខ្លួនដ៏ក្រៃលែង ដែលប្រព្រឹត្តទៅកន្លងអ្នកដទៃ ។ បទថា **អធិមានំ** បានដល់ ការសម្គាល់ថា បានសម្រេចយ៉ាងនោះ យ៉ាងនេះ ។ បទថា **ថម្ភំ** បានដល់ ភាពជាអ្នករឹងត្អឹង ព្រោះសេចក្តីក្រោធ និងមានះ ។ បទថា **អតិនិបាតំ** បានដល់ ការសម្គាល់ខ្លួនរបស់មនុស្សអាក្រក់ថា អញជាមនុស្សអាក្រក់ ៕

**អដ្ឋកថា អរហត្តសូត្រទី ២ ចប់**

# សុត្តន្តបិដក

## ឧត្តរិមនុស្សធម្មសូត្រទី ៣

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តមលើសមនុស្សធម៌ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺភ្លេចស្មារតី ១ មិនដឹងខ្លួន ១ មានទ្វារមិនបានគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ និយាយកុហក ១ និយាយលើកជាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនលះបង់ធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តមលើសមនុស្សធម៌ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម លើសមនុស្សធម៌ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺភ្លេចស្មារតី ១ មិនដឹងខ្លួន ១ មានទ្វារមិនបានគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ១ មិនដឹងប្រមាណក្នុងភោជន ១ និយាយកុហក ១ និយាយលើកជាក់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងនេះឯង ទើបជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ឧត្តម លើសមនុស្សធម៌បាន ។

# អដ្ឋកថា

## ឧត្តរិមនុស្សធម្មសូត្រ

[ ៧៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧត្តរិមនុស្សធម្មសូត្រទី ៣ ដូចតទៅនេះ បទថា **ឧត្តរិមនុស្សធម្មា** បានដល់ ធម៌ដែលក្រៃលែងជាងធម៌របស់មនុស្ស ។ បទថា **អលមរិយញ្ញាណទស្សនវិសេសំ** បានដល់ ញាណទស្សនៈពិសេស ដែលអាចធ្វើបុគ្គលឲ្យជាព្រះអរិយៈបាន អធិប្បាយថា បានដល់ មគ្គ ៤ ផល ៤ ។ បទថា **កុហានំ** បានដល់ រឿងកុហក ៣ យ៉ាង ។ បទថា **លបនំ** បានដល់ ការពោលសរសើរ ឬសង្កត់សង្កិន ព្រោះបំណងចង់បាន ។ល។

**អដ្ឋកថា ឧត្តរិមនុស្សធម្មសូត្រទី ៣ ចប់**

# សុត្តន្តបិដក

## សុខសូត្រទី ៤

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមានសុខ និងសោមនស្សដ៏ច្រើនក្នុងបច្ចុប្បន្ន ទាំងហេតុប្រព្រឹត្តទៅដើម្បីអស់អាសវៈទាំងឡាយ ភិក្ខុនោះបានប្រារព្ធហើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រេកអរក្នុងធម៌ ១ ត្រេកអរក្នុងភាវនា ១ ត្រេកអរក្នុងការលះ ១ ត្រេកអរក្នុងបវិវេក ១ ត្រេកអរក្នុងអព្យាបាទ ១ ត្រេកអរក្នុងធម៌មិនធ្វើដំណើរឲ្យយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមានសុខ និងសោមនស្សដ៏ច្រើនក្នុងបច្ចុប្បន្ន ទាំងហេតុប្រព្រឹត្តទៅ ដើម្បីអស់អាសវៈទាំងឡាយ ភិក្ខុនោះ បានប្រារព្ធហើយ ។

# អដ្ឋកថា

## សុខសូត្រ

[ ៧៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុខសូត្រទី ៤ ដូចតទៅនេះ បទថា **យោនិ ចស្ស អារទ្ធា ហោតិ** សេចក្តីថា មួយវិញទៀត ហេតុដែលលោកកំពុងធ្វើឲ្យបរិបូណ៌ គឺផ្គង ។ បទថា **ធម្មារាមោ** សេចក្តីថា ជួបនូវការត្រេកអរក្នុងធម៌ ។ ភិក្ខុ ឈ្មោះថា **ភាវនារាមោ** ព្រោះត្រេកអរក្នុងភាវនា កាលកំពុង

ភាវនា ក៏ត្រេកអរ ។ ឈ្មោះថា **បហានារាមោ** ព្រោះត្រេកអរក្នុងការលះ ឬកាលកំពុងលះក៏ត្រេកអរ ។ ឈ្មោះថា **បវិវេការាមោ** ព្រោះត្រេកអរក្នុងវិវេក ៣ ។ ឈ្មោះថា **អព្យាបជ្ឈារាមោ** ព្រោះត្រេកអរក្នុងការមិនបៀតបៀន គឺក្នុងការមិនមានទុក្ខ ។ ឈ្មោះថា **និប្បញ្ចារាមោ** ព្រោះត្រេកអរក្នុងព្រះនិព្វាន ពោល គឺធម៌ដែលមិនមានការយឺតយូរ ។៚

**អដ្ឋកថា សុខសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អធិគមសូត្រទី ៩

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីបាននូវកុសលធម៌ដែលខ្លួនមិនទាន់បាន ឬដើម្បីធ្វើកុសលធម៌ដែលខ្លួនបានរួចហើយ ឲ្យផ្សាយចេញទៅ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនឈ្លាសក្នុងសេចក្តីចម្រើន ១ មិនឈ្លាសក្នុងសេចក្តីវិនាស ១ មិនឈ្លាសក្នុងឧបាយ ១ មិនញុំាងសេចក្តីចូលចិត្តឲ្យកើតឡើង ដើម្បីបាននូវកុសលធម៌ទាំងឡាយ ដែលខ្លួនមិនទាន់បាន ១ មិនរក្សានូវកុសលធម៌ទាំងឡាយដែលខ្លួនបានហើយ ១ មិនញុំាងកុសលធម៌ឲ្យដល់ព្រមដោយការធ្វើរឿយៗ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកប

ដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីបាននូវកុសលធម៌ ដែលខ្លួនមិនទាន់បាន ឬដើម្បីធ្វើនូវកុសលធម៌ដែលខ្លួនបានរួចហើយ ឲ្យផ្សាយចេញទៅ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីបាននូវកុសលធម៌ដែលខ្លួនមិនទាន់បាន ឬដើម្បីធ្វើនូវកុសលធម៌ ដែលខ្លួនបានរួចហើយ ឲ្យផ្សាយចេញទៅ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកឈ្លាសក្នុងសេចក្តីចម្រើន ១ ឈ្លាសក្នុងសេចក្តីវិនាស ១ ឈ្លាសក្នុងឧបាយ ១ ញ៉ាំងសេចក្តីចូលចិត្តឲ្យកើតឡើង ដើម្បីបាននូវកុសលធម៌ទាំងឡាយ ដែលខ្លួនមិនទាន់បាន ១ រក្សាកុសលធម៌ទាំងឡាយ ដែលខ្លួនបានរួចហើយ ១ ញ៉ាំងកុសលឲ្យដល់ព្រមដោយកិរិយាធ្វើរឿយៗ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីបាននូវកុសលធម៌ ដែលខ្លួនមិនទាន់បាន ឬដើម្បីធ្វើនូវធម៌ដែលខ្លួនបានរួចហើយ ឲ្យផ្សាយចេញទៅ ។

# អដ្ឋកថា

## អធិគមសូត្រ

[ ៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិគមសូត្រទី ៥ ដូចតទៅនេះ បទថា **ន អាយកុសលោ** បានដល់ ជាអ្នកមិនឈ្លាសក្នុងហេតុដែលឲ្យជួប ។ បទថា **ន អបាយកុសលោ** បានដល់ មិនឈ្លាសក្នុងហេតុដែលមិនឲ្យជួប ។

បទថា **ឆន្ទំ** បានដល់ ការពេញចិត្ត គឺភាពជាអ្នក ប្រាថ្នាដើម្បីធ្វើ ។ បទថា **ឩ សារក្ខតិ** បានដល់ មិនរក្សា ។l៙៚

**អដ្ឋកថា អធិគមសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## មហត្តសូត្រទី ៦

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង មិនយូរប៉ុន្មាន គង់ដល់នូវភាពជាធំ ទូលំទូលាយ ក្នុងធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានពន្លឺ គឺញាណដ៏ច្រើន ១ មានព្យាយាមដ៏ច្រើន ១ មានសេចក្តីត្រេកអរដ៏ច្រើន ១ មានសន្តោសដ៏ច្រើន ១ មិនលះធុរៈចោលក្នុងកុសលធម៌ ១ ញុំាងចិត្តឲ្យឆ្លងទៅរកគុណខាងលើ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង មិនយូរប៉ុន្មាន គង់បានដល់នូវភាពជាធំទូលំទូលាយក្នុងធម៌ទាំងឡាយ ។

# អដ្ឋកថា

## មហាត្តសូត្រ

[ ៨០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមហាត្តសូត្រទី ៦ ដូចតទៅនេះ បទថា **អាលោកពហុលោ** បានដល់ ច្រើនទៅដោយពន្លឺនៃញាណ ។ បទថា **យោគពហុលោ** បានដល់ ធ្វើសេចក្ដីព្យាយាមឲ្យច្រើន ។ បទថា **វេទ-ពហុលោ** បានដល់ ច្រើនទៅដោយបីតិ និងបាមោជ្ជ ។ បទថា **អសន្តុដ្ឋិ-ពហុលោ** បានដល់ មិនសន្ដោសក្នុងកុសលធម៌ទាំងឡាយ ។ បទថា **អនិក្ខិត្ត-ធុរោ** បានដល់ ដាក់ធុរៈ គឺផ្ដួងសេចក្ដីព្យាយាម ។ បទថា **ឧត្តរិញ្ច បតារេតិ** បានដល់ ធ្វើសេចក្ដីព្យាយាមក្នុងឥឡូវនេះ និងឲ្យក្រៃលែងឡើងៗ ទៅ ។

**អដ្ឋកថាមហាត្តសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បឋមនិរយសូត្រទី ៧

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងតែង ទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ គឺ ជាអ្នកសម្លាប់ ១ កាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ប្រព្រឹត្តខុសក្នុងកាម ទាំងឡាយ ១ ពោលពាក្យកុហក ១ មានសេចក្ដីប្រាថ្នាអាក្រក់ ១ មាន

ទិដ្ឋិខុស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺជាអ្នកវៀរការសម្លាប់ ១ វៀរការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ មានសេចក្ដីប្រាថ្នាតិច ១ មានទិដ្ឋិត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង តែងទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

## បឋមនិរយសូត្រ

[ ៨១ ] ក្នុងបឋមនិរយសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមនិរយសូត្រទី ៧ ចប់

# សុត្តន្តបិដក

## ទុតិយនិរយសូត្រទី ៨

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងតែង ទៅកើតក្នុងនរកដូចជាគេនាំយកទៅទម្លាក់ ។ ធម៌ ៦ យ៉ាងតើអ្វីខ្លះ ។ គឺ បុគ្គលជាអ្នកនិយាយកុហក ១ និយាយញុះញង់ ១ និយាយអាក្រក់ ១ និយាយឥតប្រយោជន៍ ១ កាចអាក្រក់ ១ ឃ្លើសឃ្លង ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯងតែងទៅកើតក្នុងនរកដូចជា គេនាំយកទៅទម្លាក់ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងតែងទៅកើតក្នុង ឋានសួគ៌ដូចជាគេនាំយកទៅដាក់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជា អ្នកវៀរការនិយាយកុហក ១ វៀរការនិយាយញុះញង់ ១ វៀរការនិយាយ អាក្រក់ ១ វៀរការនិយាយឥតប្រយោជន៍ ១ មិនកាចអាក្រក់ ១ មិនឃ្លើស ឃ្លង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯងតែង ទៅកើតក្នុងឋានសួគ៌ ដូចជាគេនាំយកទៅដាក់ ។

# អដ្ឋកថា

## ទុតិយនិរយសូត្រ

[ ៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយនិរយសូត្រទី ៨ ដូចតទៅនេះ បទថា **បគុណោ** សេចក្តីថា ប្រកបដោយការគ្រាំគ្រងទាំងឡាយ មានការគ្រង ដោយកាយជាដើម ។ល។

**អដ្ឋកថា ទុតិយនិរយសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អគ្គធម្មសូត្រទី ៩

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នក មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសទ្ធា ១ មិនខ្មាសបាប ១ មិនក្តៅក្រហាយនឹងបាប ១ ខ្ជិលច្រអូស ១ អប្បឥត ប្រាជ្ញា ១ មានសេចក្តីអាឡោះអាល័យក្នុងរាងកាយ និងជីវិត ១ ។ ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរដើម្បីធ្វើឲ្យ ជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បី ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ជាធម៌ដ៏ខ្ពង់ខ្ពស់ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ប្រារព្ធព្យាយាម ១ មានប្រាជ្ញា ១ មិនអាឡោះអាល័យក្នុងរាងកាយ និងជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តជាធម៌ដ៏ខ្ពង់ខ្ពស់ ។

# អដ្ឋកថា

## អគ្គធម្មសូត្រ

[ ៨៣ ] ក្នុងអគ្គធម្មសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអគ្គធម្មសូត្រទី ៩ ចប់

# សុត្តន្តបិដក

## រត្តិសូត្រទី ១០

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តីសាបសូន្យក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្តីចម្រើនមិនមានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីប្រាថ្នាច្រើន មានសេចក្តីចង្អៀតចង្អល់ មិនសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ មិនមានសទ្ធា ១ ទ្រុស្តសីល ១ ខ្ជិលច្រអូស ១ ភ្លេចស្មារតី ១ អប្បឥតប្រាជ្ញា ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តីសាបសូន្យ ក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្តីចម្រើនមិនមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តីចម្រើនក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្តីសាបសូន្យមិនមានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនមានសេចក្តីប្រាថ្នាច្រើន មិនមានសេចក្តីចង្អៀតចង្អល់ សន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ តាមមានតាមបាន ១ ជាអ្នកមានសទ្ធា ១ មានសីល ១ ប្រារព្ធសេចក្តីព្យាយាម ១ មានស្មារតី ១ មានប្រាជ្ញា ១ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង យប់ក្តី ថ្ងៃក្តី រមែងមានមក ឯសេចក្តីចម្រើន ក្នុងកុសលធម៌ទាំងឡាយ តែងកើតឡើងប្រាកដ សេចក្តីសាបសូន្យមិនមានឡើយ ។

អរហត្តវគ្គទី ៣ ចប់

## ឧទ្ទាននៃអរហត្តវគ្គនោះ គឺ

និយាយពីការនៅជាទុក្ខ ១ មិនគួរធ្វើឲ្យជាក់ច្បាស់អរហត្ត ១ ឧត្តរិមនុស្សធម៌ ១ សុខ និងសោមនស្សដ៏ច្រើន ១ ការត្រាស់ដឹង និងមិនត្រាស់ដឹង ១ ដល់នូវភាពជាធំ ១ ការទៅកើតក្នុងនរក ២ លើក មិនគួរធ្វើឲ្យជាក់ច្បាស់នូវអគ្គធម៌ និងគួរធ្វើឲ្យជាក់ច្បាស់នូវអគ្គធម៌ ១ យប់ និងថ្ងៃ រមែងមានមក ១ ។

# អដ្ឋកថា

## វត្តិសូត្រ

*គប្បីជ្រាបវិនិច្ឆ័យក្នុងវត្តិសូត្រទី ១០ ដូចតទៅនេះថា*

*[ ៨៤ ] បទថា* **វិឃាតវា** *សេចក្តីថា ជាទុក្ខដោយទុក្ខ ព្រោះលោភៈដែលកើតឡើង ព្រោះអាស្រ័យការប្រាថ្នាច្រើន ។ ពាក្យដ៏សេស ក្នុងបទទាំងពួង មានអត្ថងាយយល់ទាំងអស់ហើយ ៕*

**អដ្ឋកថា វត្តិសូត្រទី ១០ ចប់**

**អរហន្តវគ្គទី ៣ ចប់**

# សុត្តន្តបិដក

# សីតិវគ្គ

## សីតិសូត្រទី ១

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ចិត្ត ដ៏ប្រសើរបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចិត្តដែលគួរសង្កត់សង្កិន ក្នុងពេលណា មិនសង្កត់សង្កិនចិត្តក្នុងពេលនោះ ១ ចិត្តដែលគួរផ្គងឡើង ក្នុងពេលណា មិនផ្គងចិត្តឡើង ក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យរីករាយ ក្នុងពេលណា មិនធ្វើចិត្តឲ្យរីករាយ ក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យព្រងើយ ក្នុងពេលណា មិនធ្វើចិត្តឲ្យព្រងើយ ក្នុងពេលនោះ ១ ជាអ្នកស្ទុះចុះក្នុងធម៌ថោកទាប ១ ត្រេកអរនឹងកាយរបស់ខ្លួន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកមិនគួរ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីត្រជាក់ចិត្ត ដ៏ប្រសើរបាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ចិត្តដ៏ប្រសើរ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចិត្តដែលគួរសង្កត់សង្កិន ក្នុងពេល

ណា ក៏សង្កត់សង្កិនចិត្តក្នុងពេលនោះ ១ ចិត្តដែលគួរផ្គងឡើង ក្នុងពេលណា ក៏ផ្គងចិត្តឡើង ក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យរីករាយ ក្នុងពេលណា ក៏ធ្វើចិត្តឲ្យរីករាយក្នុងពេលនោះ ១ ចិត្តដែលគួរធ្វើឲ្យព្រងើយ ក្នុងពេលណា ក៏ធ្វើចិត្តឲ្យព្រងើយក្នុងពេលនោះ ១ ជាអ្នកស្ងប់ចុះក្នុងធម៌ដ៏ថ្លៃថ្លា ១ ត្រេកអរក្នុងព្រះនិព្វាន ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសេចក្តីត្រជាក់ចិត្តដ៏ប្រសើរ ។

# អដ្ឋកថា
# សីតិវគ្គទី ៤

## សីតិសូត្រ

[ ៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសីតិសូត្រទី ១ នៃសីតិវគ្គទី ៤ ដូចតទៅនេះ បទថា **សីតិភាវំ** បានដល់ ភាពត្រជាក់ ។ ក្នុងបទថា **យស្មឹ សមយេ ចិត្តំ និគ្គណ្ហិតព្វំ** ជាដើម មានអធិប្បាយដូចតទៅនេះថា ធម្មតាចិត្ត គួរសង្កត់ដោយសមាធិ ក្នុងកាលដែលរាយមាយ គួរសង្កត់ដោយព្យាយាម ក្នុងកាលដែលចិត្តធ្លាក់ទៅតាមកោសជ្ជៈ ។ គួរឲ្យក្មៀវក្លាដោយសមាធិ ក្នុងកាលដែលចិត្តដាច់នូវការត្រេកអរ ។ គួរចូលទៅសម្លឹងដោយឧបេក្ខាសម្ពោជ្ឈង្គ ក្នុងកាលដែលចិត្តប្រព្រឹត្តទៅស្មើ ៗ។

**អដ្ឋកថា សីតិសូត្រទី ១ ចប់**

# សុត្តន្តបិដក

## ភព្វសូត្រទី ២

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីចុះកាន់និយាម ៗ គឺមគ្គដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលប្រកបដោយការរារាំង គឺកម្ម ១ ប្រកបដោយការរារាំង គឺកិលេស ១ ប្រកបដោយការរារាំង គឺវិបាក ១ មិនមានសទ្ធា ១ មិនពេញចិត្តនឹងធម៌ ១ អប្បឥតប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើបានស្តាប់ព្រះសទ្ធម្ម ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកមិនប្រកបដោយការរារាំង គឺកម្ម ១ មិនប្រកបដោយការរារាំងគឺកិលេស ១ មិនប្រកបដោយការរារាំងគឺវិបាក ១ មានសទ្ធា ១ ពេញចិត្តនឹងកុសលធម៌ ១ មានប្រាជ្ញា ១ ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់នូវព្រះសទ្ធម្ម ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

# អដ្ឋកថា

## ភព្វសូត្រ

[ ៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងភព្វសូត្រទី ២ ដូចតទៅនេះ បទថា **កម្មាវរណតាយ** បានដល់ ដោយអនន្តរិយកម្មទាំង ៥ ។ បទថា **កិលេសាវរណតាយ** បានដល់ ដោយនិយតមិច្ឆាទិដ្ឋិ ។ បទថា **វិបាកាវរណតាយ** សេចក្តីថា ដោយអកុសលវិបាកបដិសន្ធិ ឬដោយកុសលវិបាកអហេតុកបដិសន្ធិ ។ល។

**អដ្ឋកថា ភព្វសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អាវរណតាសូត្រទី ៣

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរដើម្បីចុះកាន់និយាមដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកផ្តាច់ផ្តិលជីវិតមាតា ១ ផ្តាច់ផ្តិលជីវិតបិតា ១ ផ្តាច់ផ្តិលជីវិតអរហន្ត ១ មានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឲ្យពុរពងឡើង ១ បំបែកសង្ឃ ១ អប្បឥតប្រាជ្ញាធ្គួតលេលា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរដើម្បី

ចុះកាន់និយាមដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង កាលបើបានស្តាប់ព្រះសទ្ធម្មហើយ ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកមិនផ្តាច់ផ្តិលជីវិតមាតា ១ មិនផ្តាច់ផ្តិលជីវិតបិតា ១ មិនផ្តាច់ផ្តិលជីវិតអរហន្ត ១ មិនមានចិត្តប្រទូស្តចំពោះព្រះតថាគត ធ្វើលោហិតឲ្យពុះពងឡើង ១ មិនបំបែកសង្ឃ ១ មានប្រាជ្ញាមិនធ្ងន់ធ្ងរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់ព្រះសទ្ធម្មហើយ ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃក្នុងកុសលធម៌ទាំងឡាយ ។

# អដ្ឋកថា

## អាវរណតាសូត្រ

[ ៨៧ ] ក្នុងអាវរណតាសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអាវរណតាសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សុស្សូសាសូត្រទី ៨

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏ជាអ្នកមិនគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។ ធម៌ ៦ យ៉ាងតើអ្វីខ្លះ ។ គឺកាលបើធម៌វិន័យដែលព្រះតថាគតប្រកាសសម្តែង បុគ្គលមិនស្តាប់ដោយគោរព ១ មិនប្រុងត្រចៀកស្តាប់ ១ មិនតាំងចិត្តស្តាប់ឲ្យបានដឹង ១ កាន់យកតែអំពើ ឥតប្រយោជន៍ ១ លះបង់ប្រយោជន៍ចោល ១ ប្រកបដោយខន្តីដ៏មិនសមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង បើទុកជាកំពុងស្តាប់ព្រះសទ្ធម្ម ក៏មិនគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាង កាលបើបានស្តាប់ព្រះសទ្ធម្ម ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំង-ឡាយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺកាលបើធម្មវិន័យ ដែលព្រះតថាគតទ្រង់ប្រកាសសម្តែង បុគ្គលស្តាប់ដោយគោរព ១ ប្រុងត្រចៀកស្តាប់ ១ តាំងចិត្តប្រុងស្តាប់ឲ្យដឹង ១ កាន់យកនូវប្រយោជន៍ ១ លះបង់នូវអំពើមិនជាប្រយោជន៍ ១ ប្រកបដោយខន្តីដ៏សមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៦ យ៉ាងនេះឯង កាលបើបានស្តាប់ព្រះសទ្ធម្ម ជាអ្នកគួរដើម្បីចុះកាន់និយាមដ៏ប្រពៃ ក្នុងកុសលធម៌ទាំងឡាយ ។

# អដ្ឋកថា

## សុស្សូសាសូត្រ

[ ៨៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសុស្សូសាសូត្រទី ៤ ដូចតទៅនេះ បទថា **អនត្ថំ** បានដល់ ការមិនចម្រើន ។ បទថា **អត្ថំ រិញ្ចតិ** សេចក្តីថា លះនូវប្រយោជន៍ គឺសេចក្តីចម្រើន ។ បទថា **អនលុលោមិកាយ** សេចក្តីថា ដោយការគាប់ចិត្ត ដែលមិនប្រព្រឹត្តទៅ ដោយអនុលោមតាមពាក្យប្រៀនប្រដៅ ។៚

**អដ្ឋកថា សុស្សូសាសូត្រទី ៤ ចប់**

# សុត្តន្តបិដក

## បឋមាតព្វសូត្រទី ៥

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទា ( សោតាបត្តិមគ្គ ) បានឡើយ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនបានលះធម៌ទាំង ៦ យ៉ាងនេះទេ មិនគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទាបានឡើយ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងបាន ទើបគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទា ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ទាំង ៦ យ៉ាងនេះបានហើយ ទើបគួរធ្វើឲ្យជាក់ច្បាស់នូវទិដ្ឋិសម្បទាបាន ។

# អដ្ឋកថា

## បហាតព្វសូត្រ

[ ៨៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបហាតព្វសូត្រទី ៥ ដូចតទៅនេះ បទថា **ទិដ្ឋិសម្បទំ** បានដល់ សោតាបត្តិមគ្គ ។

**អដ្ឋកថា បហាតព្វសូត្រទី ៥ ចប់**

# សុត្តន្តបិដក

## បហីនសូត្រទី ៦

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ទើបលះធម៌ ៦ យ៉ាងនេះបាន ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិ ទើបលះធម៌ទាំង ៦ យ៉ាងនេះបាន ។

# អដ្ឋកថា

## បហីនសូត្រ

[ ៩០ ] ក្នុងបហីនសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបហីនសូត្រទី ៦ ចប់

# សុត្តន្តបិដក

## ឧប្បាទេតព្វសូត្រទី ៧

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរធ្វើធម៌ ៦ យ៉ាងឲ្យកើតឡើងទេ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ រាគៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ទោសៈ ជាហេតុនាំឲ្យទៅកាន់អបាយ ១ មោហៈជាហេតុនាំឲ្យទៅកាន់អបាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបរិបូណ៌ដោយទិដ្ឋិមិនគួរធ្វើធម៌ ៦ យ៉ាង នេះឲ្យកើតឡើងបានទេ ។

# អដ្ឋកថា

## ឧប្បាទេតព្វសូត្រ

[ ៩១ ] ក្នុងឧប្បាទេតព្វសូត្រទី ៧ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាឧប្បាទេតព្វសូត្រទី ៧ ចប់

# សុត្តន្តបិដក

## សត្ថារិសូត្រទី ៨

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ អកព្វដ្ឋាន ( ហេតុដែលមិនគួរ ) នេះមាន ៦ យ៉ាង ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះព្រះសាស្តា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះសង្ឃ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ មិនគោរព មិនកោតក្រែងចំពោះសិក្ខា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរ ដើម្បីត្រឡប់ មកកាន់ហេតុដែលខ្លួនមិនគប្បីប្រកាន់ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរញ៉ាំងភពជាគម្រប់ ៨ ឲ្យកើត ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាងប៉ុណ្ណោះ ។

# អដ្ឋកថា

## សត្ថារិសូត្រ

[ ៩២ ] ក្នុងសត្ថារិសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសត្ថារិសូត្រទី ៨ ចប់

# សុត្តន្តបិដក

## កញ្ចិសង្ខារសូត្រទី ៩

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ ហេតុមិនគួរនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់សង្ខារណាមួយជាទៀង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់សង្ខារណាមួយជាសុខ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រកាន់ធម៌ណាមួយជាខ្លួន ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរធ្វើនូវអនន្តរិយកម្ម ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់ទៅកាន់សេចក្តីបរិសុទ្ធិ ដោយមង្គលភ្ញាក់ផ្អើល ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរស្វែងរកទក្ខិណេយ្យបុគ្គលខាងក្រៅព្រះពុទ្ធសាសនានេះ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## កញ្ចិសង្ខារសូត្រ

[ ៩៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកញ្ចិសង្ខារសូត្រទី ៩ ដូចតទៅនេះ បទថា **កោតូហលមង្គលេន** សេចក្តីថា ដោយទិដ្ឋមង្គល គឺវត្ថុដែលបានឃើញជាមង្គល សុតមង្គល មុតមង្គល ។

**អដ្ឋកថា កញ្ចិសង្ខារសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## មាតុសូត្រទី ១០

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើអ្វីខ្លះ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ផ្តិលជីវិតមាតា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ផ្តិលជីវិតបិតា ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរផ្តាច់ផ្តិលជីវិតអរហន្ត ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរញុំាងលោហិតរបស់ព្រះតថាគត ឲ្យពុះពងដោយចិត្តប្រទូស្ត ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរបំបែកសង្ឃ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរប្រគល់ខ្លួនទៅគ្រូដទៃ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះមាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## មាតុសូត្រ

[ ៩៤ ] ក្នុងមាតុសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាមាតុសូត្រទី ១០ ចប់

# សុត្តន្តបិដក

## សយកតសូត្រទី ១១

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខដែលខ្លួនធ្វើដោយខ្លួនឯង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខដែលបុគ្គលដទៃធ្វើ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខដែលខ្លួនឯងធ្វើផង ដែលបុគ្គលដទៃធ្វើផង ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខ ដែលកើតឡើងដោយមិនអាស្រ័យហេតុ មិនជាអំពើដែលខ្លួនឯងធ្វើ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខ ដែលកើតឡើង ដោយមិនអាស្រ័យហេតុ មិនមែនជាអំពើដែលបុគ្គលដទៃធ្វើ ១ បុគ្គលបរិបូណ៌ដោយទិដ្ឋិ មិនគួរត្រឡប់មកកាន់សុខ និងទុក្ខដែលកើតឡើង ដោយមិនអាស្រ័យហេតុ មិនមែនជាអំពើដែលខ្លួនឯងធ្វើផង មិនមែនជាអំពើដែលបុគ្គលដទៃធ្វើផង ១ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលដែលបរិបូណ៌ដោយទិដ្ឋិនោះ ឃើញច្បាស់លាស់នូវហេតុផង នូវធម៌កើតអំពីហេតុផង ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលមិនគួរនេះ មាន ៦ យ៉ាងប៉ុណ្ណោះឯង ។

**សីតិវគ្គទី ៤ ចប់**

### ឧទ្ទាននៃសីតិវគ្គនោះ គឺ

និយាយអំពីភិក្ខុ មិនគួរធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ ១ គួរធ្វើឲ្យជាក់ច្បាស់នូវសេចក្តីត្រជាក់ ១ ការរារាំង ១ ស្តាប់ដោយគោរព ១ បុគ្គលត្រូវលះបង់ធម៌ ៦ យ៉ាង ១ បុគ្គលលះបង់ធម៌ ៦ យ៉ាងហើយ ១ មិនគួរធ្វើធម៌ ៦ យ៉ាងឲ្យកើតឡើង ១ គោរពក្នុងព្រះសាស្តា ១ មិនគួរប្រកាន់សង្ខារណាមួយ ១ មិនគួរផ្តាច់ផ្តិលជីវិតមាតាជាដើម ១ មិនគួរប្រកាន់សុខទុក្ខដោយការធ្វើខ្លួនឯង ១ មគ្គ ១ ។

## អដ្ឋកថា

## សយកតសូត្រទី ១១

[ ៩៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសយកតសូត្រទី ១១ ដូចតទៅនេះ ពាក្យជាដើមថា **សយំ កតំ** ដូច្នេះ ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចនៃអត្តទិដ្ឋិ ។ បទថា **អធិច្ចសមុប្បន្នំ** សេចក្តីថា កើតឡើងដោយមិនមានហេតុ ។ ពាក្យដ៏សេសក្នុងសូត្រទាំងពួងងាយយល់ហើយ ៕

**អដ្ឋកថា សយកតសូត្រទី ១១ ចប់**

**សីតិវគ្គទី ៤ ចប់**

# សុត្តន្តបិដក

# អានិសំសវគ្គ

## ធាតុភាវសូត្រទី ១

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសភាវៈ ៦ យ៉ាង គឺ បុគ្គលបានដោយក្រក្នុងលោក ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺការកើតឡើងនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ បុគ្គលបានដោយក្រក្នុងលោក ១ បុគ្គលជាអ្នកសម្តែងធម្មវិន័យ ដែលព្រះតថាគតបានប្រកាសហើយ បុគ្គលបានដោយក្រក្នុងលោក ១ សត្វត្រឡប់មកកើតក្នុងប្រទេសជាទីនៅនៃអរិយជន បុគ្គលបានដោយក្រក្នុងលោក ១ ការមិនខូចខាតឥន្ទ្រិយទាំងឡាយ បុគ្គលបានដោយក្រក្នុងលោក ១ ភាពនៃបុគ្គលមិនលេលា មិនធ្លួត បុគ្គលបានដោយក្រក្នុងលោក ១ សេចក្តីពេញចិត្តក្នុងកុសលធម៌ បុគ្គលបានដោយក្រក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសភាវៈ ៦ យ៉ាងនេះ បុគ្គលបានដោយក្រក្នុងលោក ។

# អដ្ឋកថា
# អានិសំសវគ្គទី ៥

## ធាតុការសូត្រ

[ ៩៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងធាតុការសូត្រទី ១ នៃអានិសំសវគ្គទី ៥ ដូចតទៅនេះ បទថា **អរិយាយតនេ** បានដល់ ក្នុងមជ្ឈិមប្រទេស ។ បទថា **ឥន្ទ្រិយានំ** បានដល់ ឥន្ទ្រិយដែលមានចិត្តជាគម្រប់ ៦ ។ល។

**អដ្ឋកថា ធាតុការសូត្រទី ១ ចប់**

# សុត្តន្តបិដក
## អានិសង្សសូត្រទី ២

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលនោះ មាន ៦ យ៉ាង ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលជាអ្នកទៀងត្រង់ក្នុងព្រះសទ្ធម្ម ១ មានធម៌មិនសាបសូន្យ ១ សេចក្តីទុក្ខ មិនមានដល់បុគ្គលអ្នកធ្វើនូវព្រះនិព្វាន ជាទីបំផុតទុក្ខ ១ ប្រកបដោយញាណមិនទូទៅ ( ដល់បុថុជ្ជនទាំងឡាយ ) ១ ហេតុដែលបុគ្គលនោះឃើញដោយប្រពៃ ១ ធម៌ទាំងឡាយកើតឡើងអំពីហេតុ ១ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃ

កិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលមាន ៦ យ៉ាងនេះឯង ។

# អដ្ឋកថា

## អានិសង្សសូត្រ

[ ៩៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអានិសង្សសូត្រទី ២ ដូចតទៅនេះ បទថា **សទ្ធម្មនិយតោ** សេចក្តីថា ជាអ្នកទៀងក្នុងសាសនសទ្ធម្ម ។ បទថា **អសាធារណោណ** សេចក្តីថា ដែលមិនទូទៅដល់បុថុជ្ជនទាំងឡាយ ។

**អដ្ឋកថា អានិសង្សសូត្រទី ២ ចប់**

# សុត្តន្តបិដក

## អនិច្ចសូត្រទី ៣

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះពិចារណានូវសង្ខារណាមួយជាទៀង នឹងប្រកបដោយអនុលោមិកាខន្តិបាន ហេតុនេះ មិនដែលមានឡើយ ។ ភិក្ខុមិនប្រកបដោយអនុលោមិកាខន្តិ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ មិនដែលមានឡើយ ។ កាលភិក្ខុមិនឈានចុះកាន់និយាមដ៏ប្រពៃ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬ

ក៏អរហត្តបាន ហេតុនេះ មិនដែលមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាល ភិក្ខុនោះ ពិចារណានូវសង្ខារទាំងពួង ថាមិនទៀង នឹងប្រកបដោយអនុលោ- មិកខន្តិបាន ហេតុនេះ រមែងមាន ។ ភិក្ខុប្រកបដោយអនុលោមិកខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ រមែងមាន ។ ភិក្ខុឈានចុះកាន់ និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬក៏អរហត្តបាន ហេតុនេះ រមែងមាន ។

# អដ្ឋកថា

## អនិច្ចសូត្រ

[ ៩៨ ] ក្នុងអនិច្ចសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអនិច្ចសូត្រទី ៣ ចប់

# សុត្តន្តបិដក

## ទុក្ខសូត្រទី ៤

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវសង្ខារណាមួយថាសុខ ។បេ។ កាលពិចារណានូវសង្ខារទាំងពួងថាទុក្ខ ។បេ។

# អដ្ឋកថា

## ទុក្ខសូត្រ

[ ៩៩ ] ក្នុងទុក្ខសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុក្ខសូត្រទី ៤ ចប់

# សុត្តន្តបិដក

## អនត្តសូត្រទី ៥

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវធម៌ណាមួយថា ជាខ្លួន ។បេ។ កាលពិចារណានូវធម៌ទាំងពួង ថាមិនមែនខ្លួន ។បេ។

# អដ្ឋកថា

## អនត្តសូត្រ

[ ១០០ ] ក្នុងអនត្តសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាអនត្តសូត្រទី ៥ ចប់

# សុត្តន្តបិដក

## និព្វានសូត្រទី ៦

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវព្រះនិព្វានថា ជាទុក្ខ នឹងប្រកបដោយអនុលោមិកាខន្តិបាន ហេតុនេះ មិនដែលមានឡើយ ។ ភិក្ខុមិនប្រកបដោយអនុលោមិកាខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ មិនដែលមានឡើយ ។ ភិក្ខុមិនឈានចុះកាន់និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬក៏អរហត្តបាន ហេតុនេះ មិនដែលមានឡើយ ។

ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ ពិចារណានូវព្រះនិព្វានថា ជាសុខ នឹងប្រកបដោយអនុលោមិកាខន្តិបាន ហេតុនេះ រមែងមាន ។ ភិក្ខុប្រកបដោយអនុលោមិកាខន្តិហើយ នឹងឈានចុះកាន់និយាមដ៏ប្រពៃបាន ហេតុនេះ រមែងមាន ។ ភិក្ខុឈានចុះកាន់និយាមដ៏ប្រពៃហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឬសកទាគាមិផល អនាគាមិផល ឬក៏អរហត្តបាន ហេតុនេះ រមែងមាន ។

# អដ្ឋកថា

## និព្វានសូត្រ

[ ១០១ ] ក្នុងនិព្វានសូត្រទី ៦ មានអត្ថងាយយល់ហើយ ។

អដ្ឋកថានិព្វានសូត្រទី ៦ ចប់

# សុត្តន្តបិដក

## បឋមអនោធិសសូត្រទី ៧

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាង គួរធ្វើមិនឲ្យមានខេត្តដែន ក្នុងសង្ខារទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថា មិនទៀង ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសង្ខារទាំងឡាយទាំងពួង នឹងប្រាកដថា ជារបស់មិនតាំងនៅខ្ជាប់ខ្ជួនបាន ១ ចិត្តអាត្មាអញនឹងមិនត្រេកអរក្នុងលោកទាំងពួង ១ ចិត្តអាត្មាអញនឹងចេញចាកលោកទាំងពួង ១ ចិត្តឈមទៅរកព្រះនិព្វាន នឹងមានដល់អាត្មាអញ ១ សញ្ញោជនៈទាំងឡាយ របស់អាត្មាអញ នឹងដល់នូវការសាបសូន្យ ១ អាត្មាអញនឹងប្រកបដោយភាពនៃខ្លួនជាសមណៈដ៏ឧត្តម ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្ស ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានខេត្តដែន ក្នុងសង្ខារទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថា មិនទៀង ។

# អដ្ឋកថា

## បឋមអនោធិសសូត្រ

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបឋមអនោទិសសូត្រទី ៧ ដូចតទៅនេះ បទថា **អនោធឹ ករិត្វា** សេចក្តីថា មិនធ្វើឲ្យមានព្រំដែន គឺព្រំដែនយ៉ាងនេះថា សង្ខារមានប្រមាណប៉ុណ្ណេះឯងមិនទៀង ក្រៅអំពីនេះទៅ មិនមែនមិនទៀងឡើយ ។ បទថា **អនវដ្ឋិតតោ** សេចក្តីថា វៀរចាកឋានៈ គឺហេតុដែលប្រព្រឹត្តទៅបាន ព្រោះភាពជារបស់មិនមាំទាំ អធិប្បាយថា ជាសភាវធម៌បែកធ្លាយទៅហើយ ទើបឈប់ ។ បទថា **សព្វលោកេ** សេចក្តីថា ក្នុងលោកទាំងមូល បានដល់ ក្នុងធាតុទាំង ៣ ។ បទថា **សាមញ្ញេន** សេចក្តីថា ដោយភាពជាសមណៈ អធិប្បាយថា បានដល់ អរិយមគ្គ ។៚

**អដ្ឋកថា បឋមអនោធិសសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ទុតិយអនោធិសសូត្រទី ៨

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាង គួរធ្វើមិនឲ្យមានខេត្តដែន ក្នុងសង្ខារទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថា ជាទុក្ខ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីសម្គាល់ក្នុងការរលត់ចំពោះសង្ខារទាំងពួង នឹងតាំងឡើងប្រាកដដល់អាត្មាអញ ដូចនាយពេជ្ឈឃាដ

ដែលឆាដាវឡើង ១ ចិត្តអាត្មាអញនឹងចេញចាកលោកទាំងពួង ១ អាត្មាអញជាអ្នកឃើញនូវសេចក្តីស្ងប់រម្ងាប់ ក្នុងព្រះនិព្វាន ១ អនុសយធម៌ទាំងឡាយរបស់អាត្មាអញ នឹងដល់នូវការគាស់រម្លើង ១ អាត្មាអញនឹងជាអ្នកធ្វើនូវកិច្ចការ ១ ព្រះសាស្តាអាត្មាអញនឹងជាអ្នកបម្រើប្រកបដោយមេត្តា ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានខេត្តដែនក្នុងសង្ខារទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថាជាទុក្ខ ។

# អដ្ឋកថា

## ទុតិយអនោទិសសូត្រ

[ ១០៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយអនោទិសសូត្រទី ៨ ដូចតទៅនេះ បទថា **មេត្តាវតាយ** សេចក្តីថា ដោយការប្រណិប័តន៍ ប្រកបដោយមេត្តា ព្រោះថា ព្រះសេក្ខបុគ្គល ៧ ពួក រមែងប្រណិប័តន៍ព្រះតថាគតដោយការបម្រើប្រកបទៅដោយមេត្តា ។ សូម្បីព្រះខីណាស្រព ក៏ជាអ្នកប្រណិប័តន៍ព្រះសាស្តាដូចគ្នា ៕៚

**អដ្ឋកថា ទុតិយអនោទិសសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## តតិយអនោទិសសូត្រទី ៩

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញនូវអានិសង្សទាំង ៦ យ៉ាង គួរធ្វើមិនឲ្យមានខេត្តដែន ក្នុងធម៌ទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថា អនត្តា ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺអាត្មាអញនឹងមិនមានតម្មយៈ ( គឺតណ្ហាទិដ្ឋិ ) ក្នុងលោកទាំងពួង ១ ពួកអហង្ការទិដ្ឋិ របស់អាត្មាអញនឹងរលត់ទៅ ១ ពួកមមង្ការតណ្ហារបស់អាត្មាអញនឹងរលត់ទៅ ១ អាត្មាអញជាអ្នកប្រកបដោយញាណមិនទូទៅ ១ ហេតុអាត្មាអញនឹងឃើញដោយប្រពៃ ១ ធម៌ទាំងឡាយកើតឡើងអំពីហេតុ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញអានិសង្សទាំង ៦ យ៉ាងនេះឯង គួរធ្វើមិនឲ្យមានខេត្តដែន ក្នុងធម៌ទាំងពួង ហើយតម្កល់នូវសេចក្តីសម្គាល់ថា អនត្តា ។

# អដ្ឋកថា

## តតិយអនោទិសសូត្រ

[ ១០៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយអនោទិសសូត្រទី ៩ ដូចតទៅនេះ បទថា **អតម្មយោ** សេចក្តីថា ជាអ្នកវៀរចាកតណ្ហា និងទិដ្ឋិដែលព្រះមានព្រះភាគត្រាស់ថា **តម្មយ។** បទថា **អហំការា** បានដល់ អហង្ការទិដ្ឋិ

គឺការឃើញថាជាអញ ។ បទថា **មមំការា** បានដល់ មមង្ការតណ្ហា គឺការប្រកាន់ថារបស់អញ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ហើយ ។

**អដ្ឋកថា តតិយអនោធិសសូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ភវសូត្រទី ១០

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ ភព ៣ នេះ បុគ្គលគួរលះហើយគួរសិក្សាក្នុងសិក្ខាទាំង ៣ ។ ភព ៣ ដែលបុគ្គលគួរលះ តើអ្វីខ្លះ ។ គឺកាមភព ១ រូបភព ១ អរូប ១ ។ ភព ៣ យ៉ាងនេះ បុគ្គលគួរលះបង់ចេញ ។ សិក្ខា ៣ ដែលបុគ្គលគួរសិក្សា តើអ្វីខ្លះ ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ បុគ្គលគួរសិក្សាក្នុងសិក្ខាទាំង ៣ នេះ ។ ម្នាលភិក្ខុទាំងឡាយ ភពទាំង ៣ នេះ ជាភពដែលភិក្ខុលះបង់ហើយផង ភិក្ខុជាអ្នកមានសិក្ខាសិក្សាហើយ ក្នុងសិក្ខាទាំងឡាយ ៣ នេះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកបានកាត់នូវតណ្ហា ស្រាយនូវសញ្ញោជនៈ ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះដោយប្រពៃ ។

# អដ្ឋកថា

## ភាវសូត្រ

[ ១០៥ ] ក្នុងភាវសូត្រទី ១០ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាភាវសូត្រទី ១០ ចប់

# សុត្តន្តបិដក

## តណ្ហាសូត្រទី ១១

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ តណ្ហា ៣ នេះបុគ្គលគួរលះ ទាំងមានះ ៣ បុគ្គលក៏ត្រូវលះដែរ ។ តណ្ហា ៣ ដែលបុគ្គលគួរលះ តើអ្វីខ្លះ ។ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ តណ្ហាទាំង ៣ នេះ បុគ្គលគួរលះ ។ មានះ ៣ តើអ្វីខ្លះ ។ គឺមានះ ១ ឱមានះ ១ អតិមានះ ១ ។ នេះមានះ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ កាលណាតណ្ហាទាំង ៣ នេះ ភិក្ខុលះហើយ មានះទាំង ៣ នេះក៏ឈ្មោះថា ភិក្ខុលះហើយដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះទើបហៅថា ភិក្ខុអ្នកបានកាត់នូវតណ្ហា បានរលាស់ចោលនូវសញ្ញោជនៈ ធ្វើនូវទីបំផុតនៃទុក្ខ ព្រោះត្រាស់ដឹងនូវមានះដោយប្រពៃ ។

អានិសំសវគ្គទី ៥ ចប់

### ឧទ្ទាននៃអានិសំសវគ្គនោះ គឺ

និយាយអំពីការកើតប្រាកដ ១ អានិសង្ស ១ អនិច្ចសញ្ញា ១ ទុក្ខសញ្ញា ១ អនត្តសញ្ញា ១ ព្រះនិព្វាន ១ មានះបី ១ មិនធ្វើនូវការបែក ១ ភពទាំងឡាយ ១ តណ្ហា ១ ទាំងអស់ត្រូវជា ១០ ។

ទុតិយបណ្ណាសក ចប់

## អដ្ឋកថា

## តណ្ហាសូត្រ

[ ១០៦ ] ក្នុងតណ្ហាសូត្រទី ១១ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា តណ្ហាសូត្រទី ១១ ចប់**

**អានិសង្សវគ្គទី ៨ ចប់**

# សុត្តន្តបិដក
# បណ្ណាសកាសង្គហិតវគ្គ

## តិកវគ្គ
### រាគសូត្រទី ១

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវចម្រើនធម៌ ៣ ប្រការ ដើម្បីលះធម៌ ៣ ប្រការនេះចេញ ។ ធម៌ ៣ ប្រការ តើអ្វីខ្លះ ។ គឺបុគ្គល ត្រូវចម្រើនអសុភ ដើម្បីលះរាគៈ ១ ត្រូវចម្រើនមេត្តា ដើម្បីលះទោសៈ ១ ត្រូវចម្រើនបញ្ញា ដើម្បីលះមោហៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលត្រូវ ចម្រើនធម៌ទាំង ៣ នេះ ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា
# វគ្គដែលមិនមានសង្គ្រោះចូលក្នុងបណ្ណាសក
# តិកវគ្គទី ១

## រាគសូត្រ

[ ១០៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងរាគសូត្រទី ១ នៃតិកវគ្គទី ១ ដូចតទៅនេះ បទថា **អសុភា** បានដល់ អសុភកម្មដ្ឋាន ។ បទថា **មេត្តា** បានដល់ មេត្តាកម្មដ្ឋាន ។ បទថា **បញ្ញា** បានដល់ មគ្គប្បញ្ញា មួយអន្លើដោយវិបស្សនា ។៚

**អដ្ឋកថា រាគសូត្រទី ១ ចប់**

# សុត្តន្តបិដក
## ទុច្ចរិតសូត្រទី ២

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វី

ខ្លះ ។ គឺបុគ្គលត្រូវចម្រើនកាយសុចរិត ដើម្បីលះកាយទុច្ចរិតចេញ ១ ត្រូវចម្រើនវចីសុចរិត ដើម្បីលះវចីទុច្ចរិតចេញ ១ ត្រូវចម្រើនមនោសុចរិត ដើម្បីលះមនោទុច្ចរិតចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## ទុច្ចរិតសូត្រ

[ ១០៨ ] ក្នុងទុច្ចរិតសូត្រទី ២ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាទុច្ចរិតសូត្រទី ២ ចប់

# សុត្តន្តបិដក

## វិតក្កសូត្រទី ៣

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺកាមវិតក្ក ១ ព្យាបាទវិតក្ក ១ វិហឹសាវិតក្ក ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ១ ។ ៣ យ៉ាង

តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើននេក្ខម្មវិតក្ក ដើម្បីលះកាមវិតក្កចេញ ១ ត្រូវចម្រើនអព្យាបាទវិតក្ក ដើម្បីលះព្យាបាទវិតក្កចេញ ១ ត្រូវចម្រើនអវិហឹសាវិតក្ក ដើម្បីលះវិហឹសាវិតក្កចេញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## វិតក្កសូត្រ

[ ១០៩ ] ក្នុងវិតក្កសូត្រទី ៣ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាវិតក្កសូត្រទី ៣ ចប់

# សុត្តន្តបិដក

## សញ្ញាសូត្រទី ៤

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺកាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងបុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វី

ខ្លះ ។ គឺបុគ្គលត្រូវចម្រើនទេក្ខម្មសញ្ញា ដើម្បីលះកាមសញ្ញា ១ ត្រូវចម្រើន អព្យាបាទសញ្ញា ដើម្បីលះព្យាបាទសញ្ញា ១ ត្រូវចម្រើនអវិហឹសាសញ្ញា ដើម្បី លះវិហឹសាសញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវ ចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។

# អដ្ឋកថា

## សញ្ញាសូត្រ

[ ១១០ ] ក្នុងសញ្ញាសូត្រទី ៤ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាសញ្ញាសូត្រទី ៤ ចប់

# សុត្តន្តបិដក

## ធាតុសូត្រទី ៥

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺកាមធាតុ ១ ព្យាបាទធាតុ ១ វិហឹសាធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើ

អ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើននេក្ខម្មធាតុ ដើម្បីលះកាមធាតុ ១ ត្រូវចម្រើនអព្យាបាទធាតុ ដើម្បីលះព្យាបាទធាតុ ១ ត្រូវចម្រើនអវិហឹសាធាតុ ដើម្បីលះវិហឹសាធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## ធាតុសូត្រ

[ ១១១ ] ក្នុងធាតុសូត្រទី ៥ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាធាតុសូត្រទី ៥ ចប់

# សុត្តន្តបិដក

## អស្សាទសូត្រទី ៦

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺអស្សាទទិដ្ឋិ ( យល់ថាសត្វទៀង ) ១ អត្តានុទិដ្ឋិ ១ មិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើនអនិច្ចសញ្ញា ដើម្បីលះអស្សាទទិដ្ឋិ ១

ត្រូវចម្រើនអនត្តសញ្ញា ដើម្បីលះអត្តានុទិដ្ឋិ ១ ត្រូវចម្រើនសម្មាទិដ្ឋិ ដើម្បីលះមិច្ឆាទិដ្ឋិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## អស្សាទសូត្រ

[ ១១២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអស្សាទសូត្រទី ៦ ដូចតទៅនេះ បទថា **អស្សាទទិដ្ឋិ** បានដល់ សស្សតទិដ្ឋិ ។ បទថា **អត្តានុទិដ្ឋិ** បានដល់ សក្កាយទិដ្ឋិ មានវត្ថុ ២០ ដែលអនុលោមតាមអត្តានោះ ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ទិដ្ឋិ ៦២ យ៉ាង ។ បទថា **សម្មាទិដ្ឋិ** បានដល់ សម្មាទិដ្ឋិក្នុងអង្គមគ្គ ។ម្យ៉ាងទៀត ទិដ្ឋិទាំងឡាយ មានទិដ្ឋិថា ទានដែលឲ្យហើយមិនមានផលជាដើម ឈ្មោះថា មិច្ឆាទិដ្ឋិ ។ កម្មស្សកតាញាណ ឈ្មោះថា សម្មាទិដ្ឋិ ។ល។

**អដ្ឋកថា អស្សាទសូត្រទី ៦ ចប់**

# សុត្តន្តបិដក

## អរតិសូត្រទី ៧

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺអរតិ ( សេចក្តីមិនត្រេកអរ ) ១ វិហឹសា ( ការបៀតបៀន ) ១ អធម្មចរិយា ( ការមិនប្រព្រឹត្តធម៌ ) ១ ។ ម្នាលភិក្ខុទាំង-ឡាយ នេះធម៌ទាំងឡាយ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើនមុទិតា ដើម្បីលះអរតិ ១ ត្រូវចម្រើនអវិហឹសា ដើម្បីលះវិហឹសា ១ ត្រូវចម្រើនធម្មចរិយា ដើម្បីលះអធម្មចរិយា ១ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## អរតិសូត្រ

[ ១១៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអរតិសូត្រទី ៧ ដូចតទៅនេះ បទថា **អធម្មចរិយា** បានដល់ អកុសលកម្មបថ ១០ ។ល។

**អដ្ឋកថា អរតិសូត្រទី ៧ ចប់**

# សុត្តន្តបិដក

## តុដ្ឋិសូត្រទី ៨

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺអសុទ្ធដ្ឋិតា ( សេចក្តីមិនសន្តោស ) ១ អសម្បជញ្ញៈ ( មិនដឹងខ្លួន ) ១ មហិច្ឆតា ( សេចក្តីប្រាថ្នាច្រើន ) ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើនសុទ្ធដ្ឋិតា ដើម្បីលះអសុទ្ធដ្ឋិតា ១ ត្រូវចម្រើនសម្បជញ្ញៈ ដើម្បីលះអសម្បជញ្ញៈ ១ ត្រូវចម្រើនអប្បិច្ឆតា ដើម្បីលះមហិច្ឆតា ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## តុដ្ឋិសូត្រ

[ ១១៨ ] ក្នុងតុដ្ឋិសូត្រទី ៨ មានអត្ថងាយយល់ហើយ ។

**អដ្ឋកថា តុដ្ឋិសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## បឋមឧទ្ទច្ចសូត្រទី ៩

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ធម៌ ៣ យ៉ាង តើអ្វីខ្លះ ។ គឺទោវចស្សតា ( ភាពនៃបុគ្គលជាអ្នកប្រដៅបានដោយក្រ ) ១ បាបមិត្តតា ( ភាពនៃបុគ្គលជាអ្នកមានមិត្តអាក្រក់ ) ១ សេចក្តីរវើរវាយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលគួរចម្រើនសោវចស្សតា ( ភាពនៃបុគ្គលជាអ្នកប្រដៅបានដោយងាយ) ដើម្បីលះទោវចស្សតា ១ ត្រូវចម្រើនកល្យាណមិត្តតា ដើម្បីលះបាបមិត្តតា ១ ត្រូវចម្រើនអានាបានស្សតិ ដើម្បីលះសេចក្តីរវើរវាយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

# អដ្ឋកថា

## បឋមឧទ្ទច្ចសូត្រ

[ ១១៥ ] បឋមឧទ្ធច្ចសូត្រទី ៩ មានអត្ថងាយយល់ហើយ ។

អដ្ឋកថាបឋមឧទ្ធច្ចសូត្រទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយឧទ្ទច្ចសូត្រទី ១០

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺឧទ្ធច្ចៈ ( សេចក្ដីរាយមាយ ) ១ អសំវរៈ ( សេចក្ដីមិនសង្រួម ) ១ បមាទៈ ( សេចក្ដីធ្វេសប្រហែស ) ១ ។ ម្នាលភិក្ខុទាំងឡាយ នេះធម៌ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះចេញ ។ ៣ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលត្រូវចម្រើនសមថៈ ដើម្បីលះឧទ្ធច្ចៈ ១ ត្រូវចម្រើនសំវរៈ ដើម្បីលះអសំវរៈ ១ ត្រូវចម្រើនអប្បមាទៈ ដើម្បីលះបមាទៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលត្រូវចម្រើន ដើម្បីលះធម៌ ៣ យ៉ាងនេះ ។

តិកវគ្គ ចប់

### ឧទ្ទាននៃតិកវគ្គនោះ គឺ

និយាយអំពីរាគៈ ១ ទុច្ចរិត ១ វិតក្ក ១
សញ្ញា ១ ធាតុ ១ អស្សាទទិដ្ឋិ ១ អរតិ
១ តុដ្ឋិ ២ លើក ១ ឧទ្ធច្ចៈ ១ វគ្គ ១ ។

# អដ្ឋកថា

## ទុតិយឧទ្ទុច្ចសូត្រ

[ ១១៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងទុតិយឧទ្ទុច្ចសូត្រទី ១០ ដូចតទៅនេះ បទថា **អសំវរោ** បានដល់ ភាពជាបុគ្គលមានឥន្ទ្រិយបញ្ឈប់មិនបាន ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ហើយ ដូច្នេះ ។

**អដ្ឋកថា ទុតិយឧទ្ទុច្ចសូត្រទី ១០ ចប់**

**តិកវគ្គទី ១ ចប់**

# សុត្តន្តបិដក

## វគ្គាសង្គហិតសុត្តន្ត

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងចេញទេ ជាអ្នកមិនគួរពិចារណាឃើញកាយក្នុងកាយ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺ សេចក្ដីត្រេកអរក្នុងការងារ ១ សេចក្ដីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្ដីត្រេកអរក្នុងការដេក ១ សេចក្ដីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ១ សេចក្ដីមិនសង្រួមទ្វារ ក្នុងឥន្រ្ទិយទាំងឡាយ ១ សេចក្ដីមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងនេះចេញទេ ជាអ្នកមិនគួរពិចារណាឃើញកាយក្នុងកាយឡើយ ។

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងចេញ ជាអ្នកគួរពិចារណាឃើញកាយក្នុងកាយ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្ដីត្រេកអរក្នុងការងារ ១ សេចក្ដីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្ដីត្រេកអរក្នុងការដេក ១ សេចក្ដីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ១ សេចក្ដីមិនសង្រួមទ្វារក្នុងឥន្រ្ទិយទាំងឡាយ ១ សេចក្ដីមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងនេះចេញ ជាអ្នកគួរពិចារណាឃើញកាយក្នុងកាយបាន ។

[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញកាយក្នុងកាយជាខាងក្នុង ។បេ។ ក្នុងកាយខាងក្រៅ... ក្នុងកាយទាំងខាងក្នុង ទាំងខាងក្រៅ...

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញវេទនា ក្នុងវេទនាទាំងឡាយ ។បេ។ ក្នុងវេទនាទាំងឡាយ ជាខាងក្នុង... ក្នុងវេទនាទាំងឡាយ ជាខាងក្រៅ... ក្នុងវេទនាទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ...

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង ជាអ្នកមិនគួរពិចារណាឃើញចិត្តក្នុងចិត្ត ។បេ។ ក្នុងចិត្តជាខាងក្នុង... ក្នុងចិត្តជាខាងក្រៅ ក្នុងចិត្តទាំងខាងក្នុង ទាំងខាងក្រៅ...

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាង មិនគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ។បេ។ ក្នុងធម៌ទាំងឡាយជាខាងក្នុង ... ក្នុងធម៌ទាំងឡាយជាខាងក្រៅ... ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ ។ ធម៌ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីត្រេកអរក្នុងការងារ ១ សេចក្តីត្រេកអរក្នុងតិរច្ឆានកថា ១ សេចក្តីត្រេកអរក្នុងការដេក ១ សេចក្តីត្រេកអរក្នុងការប្រឡូកប្រឡំដោយពួកគណៈ ១ សេចក្តីមិនសង្រួមទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ សេចក្តីមិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលះធម៌ ៦ យ៉ាងនេះទេ ជាអ្នកមិនគួរពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅឡើយ ។

[ ១២៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងបានហើយ ជាអ្នកគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្ដីត្រេកអរក្នុងការងារ ១ ។បេ។ មិនដឹងប្រមាណក្នុងភោជន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលលះធម៌ ៦ យ៉ាងនេះចេញ ជាអ្នកគួរពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅ ។

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ តបុស្សគហបតីប្រកបដោយធម៌ ៦ យ៉ាង ជាអ្នកអស់សង្ស័យក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងព្រះពុទ្ធ ១ សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ១ សេចក្ដីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃ ១ សីលដ៏ប្រសើរ ១ ញាណដ៏ប្រសើរ ១ វិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ តបុស្សគហបតី ប្រកបដោយធម៌ ៦ យ៉ាងនេះឯង ជាអ្នកអស់សង្ស័យក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។

[ ១២៥ ] ម្នាលភិក្ខុទាំងឡាយ ភល្លិកគហបតី ១ សុទត្តគហបតី គឺអនាថបិណ្ឌិក ១ ចិត្តគហបតីនៅក្នុងមច្ឆិកាសណ្ឌៈ ១ ហត្ថកអាឡវកៈ ១ មហានាមសក្កៈ ១ ឧគ្គគហបតីនៅក្នុងក្រុងវេសាលី ១ ឧគ្គតគហបតី ១ សូរអម្ពដ្ឋៈ ១ ជីវកកោមារភច្ច ១ នកុលបិតាគហបតី ១ តវកណ្ណិកគហបតី ១ បូរណគហបតី ១ ឥសិទត្តគហបតី ១ សន្ធានគហបតី ១ វិជយ-គហបតី ១ វជ្ជិយមហិតគហបតី ១ មេណ្ឌកគហបតី ១ វាសេដ្ឋឧបាសក ១ អរិដ្ឋឧបាសក ១ សារទត្តឧបាសក ១ សុទ្ធតែប្រកបដោយធម៌ ៦ យ៉ាង

ជាអ្នកអស់សេចក្តីសង្ស័យក្នុងព្រះតថាគត ជាអ្នកឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។ ៦ យ៉ាង តើអ្វីខ្លះ ។ គឺសេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធ ១ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះធម៌ ១ សេចក្តីជ្រះថ្លាមិនញាប់ញ័រក្នុងព្រះសង្ឃ ១ សីលដ៏ប្រសើរ ១ ញាណដ៏ប្រសើរ ១ វិមុត្តិដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ សាទត្តឧបាសកប្រកបដោយធម៌ទាំង ៦ យ៉ាងនេះ ជាអ្នកអស់សេចក្តីសង្ស័យក្នុងព្រះតថាគត ឃើញអមតធម៌ ហើយធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ ។

[ ១២៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរតែចម្រើនធម៌ ៦ ប្រការ ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការ តើអ្វីខ្លះ ។ គឺការឃើញដ៏ប្រសើរ ១ ការស្តាប់ដ៏ប្រសើរ ១ ការបានដ៏ប្រសើរ ១ ការរៀនដ៏ប្រសើរ ១ ការបម្រើដ៏ប្រសើរ ១ ការរឭកដ៏ប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចម្រើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

[ ១២៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលគួរតែចម្រើនធម៌ ៦ ប្រការ ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការ តើអ្វីខ្លះ ។ គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចម្រើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

[ ១២៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការ បុគ្គលគួរតែចម្រើន

ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។ ៦ ប្រការ តើអ្វីខ្លះ ។ គឺសេចក្ដីសម្គាល់ថាមិនទៀង ក្នុងរបស់មិនទៀង ១ សេចក្ដីសម្គាល់ថាជាទុក្ខក្នុងរបស់ជាទុក្ខ ១ សេចក្ដីសម្គាល់ថាមិនមែនជារបស់ខ្លួន ១ សេចក្ដីសម្គាល់ក្នុងការលះ ១ សេចក្ដីសម្គាល់ក្នុងការប្រាសចាកតម្រេក ១ សេចក្ដីសម្គាល់ក្នុងការរលត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៦ ប្រការនេះ បុគ្គលគួរតែចម្រើន ដើម្បីឲ្យបានដឹងច្បាស់នូវរាគៈ ។

[ ១២៩ ] ម្នាលភិក្ខុទាំងឡាយ ដើម្បីកំណត់ដឹងនូវរាគៈ ។បេ។ ធម៌ ៦ យ៉ាងនេះ បុគ្គលគួរតែចម្រើន ដើម្បីឲ្យអស់រលីង លះបង់អស់ទៅ សូន្យទៅ ប្រាសចាក រលត់ កម្ចាត់ចេញ រលាស់ចេញ ។បេ។

[ ១៣០ ] ដើម្បីដឹងច្បាស់ កំណត់ដឹង អស់រលីង លះអស់ទៅ សូន្យទៅ ប្រាសចាក រលត់ កម្ចាត់ចេញ រលាស់ចេញ នូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានះ អតិមានះ មទៈ បមាទៈ ។បេ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៦ ប្រការនេះឯង បុគ្គលគួរតែចម្រើន ។ លុះព្រះដ៏មានព្រះភាគទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនុ៎ះ មានចិត្តរីករាយ ត្រេកអរ នឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ។

**ឆក្កនិបាត ចប់**

# អដ្ឋកថា

## សូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ

[ ១២៤ ] *គប្បីជ្រាបវិនិច្ឆ័យក្នុងបទបន្ទាប់អំពីនេះទៅ ដូច្នេះ បទថា* **តបុស្សោ** *បានដល់ ឧបាសកដែលបន្ទឹងវាចា ដល់រតនៈ ២ ។ បទថា* **តថាគតេ និដ្ឋង្គតោ** *សេចក្តីថា បុគ្គលមានចិត្តតាំងមាំល្អហើយ គឺលះសេចក្តីសង្ស័យក្នុងព្រះពុទ្ធគុណបានហើយ ។ ភិក្ខុ ឈ្មោះថា* **អមតទ្ទសោ** *ព្រោះបានឃើញអមតធម៌ ។ បទថា* **អរិយេន** *បានដល់ លោកុត្តរសីលដែលមិនមានទោស ។ បទថា* **ញាណេន** *បានដល់ ដោយបច្ចវេក្ខណញ្ញាណ ។ បទថា* **វិមុត្តិយា** *បានដល់ ផលវិមុត្តិរបស់ព្រះសេក្ខៈ ។*

[ ១២៥ ] *បទថា* **តវកណ្ណិកោ** *បានដល់ គហបតីដែលមានឈ្មោះយ៉ាងនេះ ។ បាលីថា* **តបកណ្ណិក** *ដូច្នេះក៏មាន ។*

[ ១២៦ ] *បទថា* **រាគស្ស** *បានដល់ រាគៈដែលសម្បយុត្តដោយកាមគុណ ៥ ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយដូច្នេះ ។*

**ពណ៌នាជក្កនិបាត**

**នៃអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី ចប់**

# ក្បាលទី ២៩

# សុត្តន្តបិដក ចាលីប្រែ -៤៥

## សន្លឹកចង្អុលប្រាប់មាតិកា


| មាតិកា | | លេខទំព័រ |
|---|---|---|
| **ផាសុវិហារវគ្គ** | | |
| វេសារជ្ជករណសូត្រ | ........ ........ .......... | ២ |
| អដ្ឋកថាវេសារជ្ជករណសូត្រ | ........ ........ .......... | ៤ |
| សង្កិតសូត្រ | ........ ........ .......... | ៤ |
| អដ្ឋកថាសង្កិតសូត្រ | ........ ........ .......... | ៥ |
| ចោរសូត្រ | ........ ........ .......... | ៦ |
| អដ្ឋកថាចោរសូត្រ | ........ ........ .......... | ៩ |
| សុខុមាលសូត្រ និងអដ្ឋកថា | ........ ........ .......... | ១០ |
| ផាសុវិហារសូត្រ | ........ ........ .......... | ១៣ |
| អដ្ឋកថាផាសុវិហារសូត្រ | ........ ........ .......... | ១៤ |
| អានន្ទសូត្រ | ........ ........ .......... | ១៥ |
| អដ្ឋកថាអានន្ទសូត្រ | ........ ........ .......... | ១៧ |
| សីលសូត្រ | ........ ........ .......... | ១៨ |
| អដ្ឋកថាសីលសូត្រ | ........ ........ .......... | ១៨ |
| អសេខិយសូត្រ | ........ ........ .......... | ១៩ |
| អដ្ឋកថាអសេខិយសូត្រ | ........ ........ .......... | ១៩ |
| ចាតុទ្ទិសសូត្រ | ........ ........ .......... | ២០ |
| អដ្ឋកថាចាតុទ្ទិសសូត្រ | ........ ........ .......... | ២១ |

អារញ្ញសូត្រ ........ ......... .......... ២១
អដ្ឋកថាអារញ្ញសូត្រ ........ ......... .......... ២២

### អន្ធកាវិន្ទវគ្គ

កុលុបកសូត្រ ........ ......... .......... ២៣
អដ្ឋកថាកុលុបកសូត្រ ........ ......... .......... ២៤
បច្ឆាសមណសូត្រ ........ ......... .......... ២៥
អដ្ឋកថាបច្ឆាសមណសូត្រ ........ ......... .......... ២៦
សមាធិសូត្រ និងអដ្ឋកថា ........ ......... .......... ២៦
អន្ធកវិន្ទសូត្រ ........ ......... .......... ២៨
អដ្ឋកថាអន្ធកវិន្ទសូត្រ ........ ......... .......... ២៩
មច្ឆរិយសូត្រ ........ ......... .......... ៣០
អដ្ឋកថាមច្ឆរិយសូត្រ ........ ......... .......... ៣០
វណ្ណនាសូត្រ ........ ......... .......... ៣១
អដ្ឋកថាវណ្ណនាសូត្រ ........ ......... .......... ៣២
ឥស្សាសូត្រ ........ ......... .......... ៣៣
អដ្ឋកថាឥស្សាសូត្រ ........ ......... .......... ៣៤
ទិដ្ឋិសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤
វាចាសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥
វាយាមសូត្រ និងអដ្ឋកថា ........ ......... .......... ៣៧

### គិលានវគ្គ

គិលានសូត្រទី១ ជាដើម ........ ......... .......... ៣៩
អដ្ឋកថាគិលានសូត្រជាដើម ........ ......... .......... ៤២
ទុតិយឧបដ្ឋាកសូត្រ ........ ......... .......... ៤២

អដ្ឋកថាទុតិយឧបដ្ឋាកសូត្រ ........ ......... .......... ៤៤
បឋមអនាយុស្សសូត្រ ........ ......... .......... ៤៤
អដ្ឋកថាបឋមអនាយុស្សសូត្រ ........ ......... .......... ៤៥
ទុតិយអនាយុស្សសូត្រ និងអដ្ឋកថា ........ ......... .......... ៤៥
អវប្បកាសសូត្រ ........ ......... .......... ៤៧
អដ្ឋកថាអវប្បកាសសូត្រ ........ ......... .......... ៤៨
សមណទុក្ខសូត្រ និងអដ្ឋកថា ........ ......... .......... ៤៨
បរិកុប្បសូត្រ ........ ......... .......... ៥០
អដ្ឋកថាបរិកុប្បសូត្រ ........ ......... .......... ៥០
សម្បទាសូត្រ និងអដ្ឋកថា ........ ......... .......... ៥១

### រាជវគ្គ

ចក្កសូត្រ ........ ......... .......... ៥៣
អដ្ឋកថាចក្កសូត្រ ........ ......... .......... ៥៥
អនុវត្តនសូត្រ ........ ......... .......... ៥៦
អដ្ឋកថាអនុវត្តនសូត្រ ........ ......... .......... ៥៧
រាជសូត្រ និងអដ្ឋកថា ........ ......... .......... ៥៨
យស្សទិសសូត្រ ........ ......... .......... ៦១
អដ្ឋកថាយស្សទិសសូត្រ ........ ......... .......... ៦៣
បឋមបត្ថនាសូត្រ ........ ......... .......... ៦៦
អដ្ឋកថាបឋមបត្ថនាសូត្រ ........ ......... .......... ៦៩
ទុតិយបត្ថនាសូត្រ ........ ......... .......... ៧០
អដ្ឋកថាទុតិយបត្ថនាសូត្រ ........ ......... .......... ៧២

អប្បស្សុបតិសូត្រ ........ ......... .......... ៧៣
អដ្ឋកថាអប្បស្សុបតិសូត្រ ........ ......... .......... ៧៣
កត្ថាទកសូត្រ ........ ......... .......... ៧៤
អដ្ឋកថាកត្ថាទកសូត្រ ........ ......... .......... ៧៥
អក្ខមសូត្រ ........ ......... .......... ៧៦
អដ្ឋកថាអក្ខមសូត្រ ........ ......... .......... ៨៣
សោតវសូត្រ ........ ......... .......... ៨៤
អដ្ឋកថាសោតវសូត្រ ........ ......... .......... ៨៩

## តិកណ្ណកីវគ្គ

ទត្វាអវជានាតិសូត្រ ........ ......... .......... ៩០
អដ្ឋកថាទត្វាអវជានាតិសូត្រ ........ ......... .......... ៩២
អារកសូត្រ ........ ......... .......... ៩៣
អដ្ឋកថាអារកសូត្រ ........ ......... .......... ៩៧
សារន្ទទសូត្រ ........ ......... .......... ៩៨
អដ្ឋកថាសារន្ទទសូត្រ ........ ......... .......... ១០១
តិកណ្ណកីសូត្រ ........ ......... .......... ១០២
អដ្ឋកថាតិកណ្ណកីសូត្រ ........ ......... .......... ១០៤
និរយសូត្រ និងអដ្ឋកថា ........ ......... .......... ១០៦
មិត្តសូត្រ ........ ......... .......... ១០៧
អដ្ឋកថាមិត្តសូត្រ ........ ......... .......... ១០៨
អសប្បុរិសទានសូត្រ ........ ......... .......... ១០៨
អដ្ឋកថាអសប្បុរិសទានសូត្រ ........ ......... .......... ១០៩

សប្បុរិសទានសូត្រ ........ ......... .......... ១១០
អដ្ឋកថាសប្បុរិសទានសូត្រ ........ ......... .......... ១១២
បឋមសមយវិមុត្តសូត្រ និងអដ្ឋកថា ........ ......... .......... ១១២
ទុតិយសមយវិមុត្តសូត្រ និងអដ្ឋកថា ........ ......... .......... ១១៤

### សទ្ធម្មវគ្គ

បឋមសទ្ធម្មនិយាមសូត្រ ........ ......... .......... ១១៦
អដ្ឋកថាបឋមសទ្ធម្មនិយាមសូត្រ ........ ......... .......... ១១៨
ទុតិយសទ្ធម្មនិយាមសូត្រ ........ ......... .......... ១១៩
អដ្ឋកថាទុតិយសទ្ធម្មនិយាមសូត្រ ........ ......... .......... ១២០
តតិយសទ្ធម្មនិយាមសូត្រ ........ ......... .......... ១២០
អដ្ឋកថាតតិយសទ្ធម្មនិយាមសូត្រ ........ ......... .......... ១២១
បឋមសទ្ធម្មសម្មោសសូត្រ ........ ......... .......... ១២២
អដ្ឋកថាបឋមសទ្ធម្មសម្មោសសូត្រ ........ ......... .......... ១២៣
ទុតិយសទ្ធម្មសម្មោសសូត្រ និងអដ្ឋកថា ........ ......... .......... ១២៣
តតិយសទ្ធម្មសម្មោសសូត្រ ........ ......... .......... ១២៦
អដ្ឋកថាតតិយសទ្ធម្មសម្មោសសូត្រ ........ ......... .......... ១៣០
ទុកថាសូត្រ ........ ......... .......... ១៣១
អដ្ឋកថាទុកថាសូត្រ ........ ......... .......... ១៣៥
សារជ្ជសូត្រ និងអដ្ឋកថា ........ ......... .......... ១៣៦
ឧទាយិសូត្រ ........ ......... .......... ១៣៧
អដ្ឋកថាឧទាយិសូត្រ ........ ......... .......... ១៣៨
ទុព្វិនោទយសូត្រ ........ ......... .......... ១៣៩
អដ្ឋកថាទុព្វិនោទយសូត្រ ........ ......... .......... ១៤០

## អាឃាតវគ្គ


បឋមអាឃាតប្បដិវិនយសូត្រ ........ ......... .......... ១៤២
អដ្ឋកថាបឋមអាឃាតប្បដិវិនយសូត្រ ........ ......... .......... ១៤៣
ទុតិយអាឃាតប្បដិវិនយសូត្រ ........ ......... .......... ១៤៤
អដ្ឋកថាទុតិយអាឃាតប្បដិវិនយសូត្រ ........ ......... .......... ១៥១
សាកច្ឆាសូត្រ និងអដ្ឋកថា ........ ......... .......... ១៥៥
សាជីវសូត្រ និងអដ្ឋកថា ........ ......... .......... ១៥៦
បញ្ហាបុច្ឆាសូត្រ ........ ......... .......... ១៥៧
អដ្ឋកថាបញ្ហាបុច្ឆាសូត្រ ........ ......... .......... ១៥៨
និរោធសូត្រ ........ ......... .......... ១៥៩
អដ្ឋកថានិរោធសូត្រ ........ ......... .......... ១៦៥
ចោទនាសូត្រ ........ ......... .......... ១៦៧
អដ្ឋកថាចោទនាសូត្រ ........ ......... .......... ១៧៥
សីលសូត្រ និងអដ្ឋកថា ........ ......... .......... ១៧៧
និសន្តិសូត្រ ........ ......... .......... ១៧៩
អដ្ឋកថានិសន្តិសូត្រ ........ ......... .......... ១៨១
កទ្ទុជិសូត្រ ........ ......... .......... ១៨២
អដ្ឋកថាកទ្ទុជិសូត្រ ........ ......... .......... ១៨៥


## ឧបាសកវគ្គ


សារជ្ជសូត្រទី១ជាដើម ........ ......... .......... ១៨៧
អដ្ឋកថាសារជ្ជសូត្រជាដើម ........ ......... .......... ១៨៩
វេរសូត្រ ........ ......... .......... ១៩០

អដ្ឋកថាវេរសូត្រ ........ ......... .......... ១៩២

ចណ្ឌាលសូត្រ ........ ......... .......... ១៩៣

អដ្ឋកថាចណ្ឌាលសូត្រ ........ ......... .......... ១៩៤

បីតិសូត្រ ........ ......... .......... ១៩៥

អដ្ឋកថាបីតិសូត្រ ........ ......... .......... ១៩៨

វណិជ្ជសូត្រ ........ ......... .......... ១៩៩

អដ្ឋកថាវណិជ្ជសូត្រ ........ ......... .......... ១៩៩

រាជសូត្រ និងអដ្ឋកថា ........ ......... .......... ២០០

គិហិសូត្រ ........ ......... .......... ២០៥

អដ្ឋកថាគិហិសូត្រ ........ ......... .......... ២១០

គវេសិសូត្រ ........ ......... .......... ២១១

អដ្ឋកថាគវេសិសូត្រ ........ ......... .......... ២១៩

អរញ្ញវគ្គ

អរញ្ញសូត្រទី ១ ជាដើម ........ ......... .......... ២២២

អដ្ឋកថាអរញ្ញសូត្រជាដើម ........ ......... .......... ២២៧

ព្រាហ្មណវគ្គ

សោណសូត្រ ........ ......... .......... ២២៩

អដ្ឋកថាសោណសូត្រ ........ ......... .......... ២៣២

ទោណសូត្រ ........ ......... .......... ២៣៣

អដ្ឋកថាទោណសូត្រ ........ ......... .......... ២៤៥

សង្គារវសូត្រ ........ ......... .......... ២៤៩

អដ្ឋកថាសង្គារវសូត្រ ........ ......... .......... ២៥៧

| | | |
|---|---|---|
| ការណបាលីសូត្រ | ........ ......... .......... | ២៦០ |
| អដ្ឋកថាការណបាលីសូត្រ | ........ ......... .......... | ២៦៣ |
| បិង្គិយានីសូត្រ | ........ ......... .......... | ២៦៩ |
| អដ្ឋកថាបិង្គិយានីសូត្រ | ........ ......... .......... | ២៧១ |
| សុបិនសូត្រ | ........ ......... .......... | ២៧២ |
| អដ្ឋកថាសុបិនសូត្រ | ........ ......... .......... | ២៧៦ |
| ហេតុនៃសុបិន ៤ យ៉ាង | ........ ......... .......... | ២៧៦ |
| វស្សសូត្រ | ........ ......... .......... | ២៨៣ |
| អដ្ឋកថាវស្សសូត្រ | ........ ......... .......... | ២៨៤ |
| វាចាសូត្រ និងអដ្ឋកថា | ........ ......... .......... | ២៨៥ |
| កុលសូត្រ និងអដ្ឋកថា | ........ ......... .......... | ២៨៦ |
| និស្សារណីយសូត្រ | ........ ......... .......... | ២៨៧ |
| អដ្ឋកថានិស្សារណីយសូត្រ | ........ ......... .......... | ២៩១ |
| **កិម្ពិលវគ្គ** | | |
| កិម្ពិលសូត្រ | ........ ......... .......... | ២៩៤ |
| អដ្ឋកថាកិម្ពិលសូត្រ | ........ ......... .......... | ២៩៦ |
| ធម្មស្សវនសូត្រ និងអដ្ឋកថា | ........ ......... .......... | ២៩៨ |
| អាជានិយសូត្រ | ........ ......... .......... | ២៩៩ |
| អដ្ឋកថាអាជានិយសូត្រ | ........ ......... .......... | ៣០០ |
| ពលសូត្រ និងអដ្ឋកថា | ........ ......... .......... | ៣០០ |
| ចេតោខីលសូត្រ | ........ ......... .......... | ៣០១ |
| អដ្ឋកថាចេតោខីលសូត្រ | ........ ......... .......... | ៣០២ |
| វិនិពន្ធសូត្រ | ........ ......... .......... | ៣០៤ |

អដ្ឋកថាវិនិពន្ធសូត្រ ........ ......... .......... ៣០៦
យាគុសូត្រ និងអដ្ឋកថា ........ ......... .......... ៣០៧
ទន្តកដ្ឋសូត្រ និងអដ្ឋកថា ........ ......... .......... ៣០៨
គីតសូត្រ និងអដ្ឋកថា ........ ......... .......... ៣០៩
មុដ្ឋស្សតិសូត្រ និងអដ្ឋកថា ........ ......... .......... ៣១០

## អក្កោសកវគ្គ

អក្កោសកសូត្រ ........ ......... .......... ៣១២
អដ្ឋកថាអក្កោសកសូត្រ ........ ......... .......... ៣១៣
ភណ្ឌនសូត្រ និងអដ្ឋកថា ........ ......... .......... ៣១៣
សីលសូត្រ ........ ......... .......... ៣១៥
អដ្ឋកថាសីលសូត្រ ........ ......... .......... ៣១៧
ពហុភាណីសូត្រ និងអដ្ឋកថា ........ ......... .......... ៣១៩
បឋមខន្តិសូត្រ និងអដ្ឋកថា ........ ......... .......... ៣២០
ទុតិយខន្តិសូត្រ និងអដ្ឋកថា ........ ......... .......... ៣២១
បឋមអបាសាទិកសូត្រ និងអដ្ឋកថា ........ ......... .......... ៣២២
ទុតិយអបាសាទិកសូត្រ និងអដ្ឋកថា ........ ......... .......... ៣២៤
អគ្គិសូត្រ និងអដ្ឋកថា ........ ......... .......... ៣២៥
មធុរាសូត្រ ........ ......... .......... ៣២៦
អដ្ឋកថាមធុរាសូត្រ ........ ......... .......... ៣២៦

## ទីឃចារិកវគ្គ

បឋមទីឃចារិកសូត្រទី ១ ........ ......... .......... ៣២៨
អដ្ឋកថាបឋមទីឃចារិកសូត្រ ........ ......... .......... ៣២៩
ទុតិយទីឃចារិកសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣០

អភិនិវាសសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣១

មច្ឆរសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣៣

បឋមកុលុបកសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣៤

ទុតិយកុលុបកសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣៥

ភោគសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣៦

ភត្តសូត្រ ........ ......... .......... ៣៣៧

អដ្ឋកថាភត្តសូត្រ ........ ......... .......... ៣៣៨

បឋមសប្បសូត្រ និងអដ្ឋកថា ........ ......... .......... ៣៣៩

ទុតិយសប្បសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤១


### អាវាសិកវគ្គ


អាវាសិកសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤៣

បិយសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤៤

សោភនសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤៦

ពហុបការសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤៧

អនុកម្បកសូត្រ និងអដ្ឋកថា ........ ......... .......... ៣៤៨

យថាភតអវណ្ណសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥០

យថាភតគេធសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥១

បឋមយថាភតមច្ឆេរសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥៣

ទុតិយយថាភតមច្ឆេរសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥៤

តតិយយថាភតមច្ឆេរសូត្រ និងអដ្ឋកថា ........ ......... .......... ៣៥៥


### ទុច្ចរិតវគ្គ


ទុច្ចរិតសូត្រជាដើម ........ ......... .......... ៣៥៧

អដ្ឋកថាទុច្ចរិតសូត្រជាដើម ........ ......... .......... ៣៦១

សីវថិកាសូត្រ និងអដ្ឋកថា ........ ......... .......... ៣៦១
បុគ្គលប្បសាទសូត្រ និងអដ្ឋកថា ........ ......... .......... ៣៦៤
ពួកសូត្រមិនសង្គ្រោះក្នុងវគ្គ ........ ......... .......... ៣៦៧
អដ្ឋកថាពួកសូត្រមិនសង្គ្រោះក្នុងវគ្គ ........ ......... .......... ៣៧៩

## សុត្តន្តបិដក ចាលីប្រែ -៤៦

### អាហុនេយ្យវគ្គ

បឋមអាហុនេយ្យសូត្រ ........ ......... .......... ៣៨១
អដ្ឋកថាបឋមអាហុនេយ្យសូត្រ ........ ......... .......... ៣៨៣
ទុតិយអាហុនេយ្យសូត្រ និងអដ្ឋកថា ........ ......... .......... ៣៨៤
ឥន្ទ្រិយសូត្រជាដើម និងអដ្ឋកថា ........ ......... .......... ៣៨៧
បឋមអាជានិយសូត្រ និងអដ្ឋកថា ........ ......... .......... ៣៨៩
ទុតិយអាជានិយសូត្រ និងអដ្ឋកថា ........ ......... .......... ៣៩១
តតិយអាជានិយសូត្រ និងអដ្ឋកថា ........ ......... .......... ៣៩២
អនុត្តរិយសូត្រ ........ ......... .......... ៣៩៤
អដ្ឋកថាអនុត្តរិយសូត្រ ........ ......... .......... ៣៩៤
អនុស្សតិសូត្រ និងអដ្ឋកថា ........ ......... .......... ៣៩៦
មហានាមសូត្រ ........ ......... .......... ៣៩៧
អដ្ឋកថាមហានាមសូត្រ ........ ......... .......... ៤០៤

### សារាណីយាទិវគ្គ

បឋមសារាណិយសូត្រ ........ ......... .......... ៤០៧
អដ្ឋកថាបឋមសារាណិយសូត្រ ........ ......... .......... ៤០៩
រឿងព្រះតិស្សត្ថេរ ........ ......... .......... ៤១៤

| | | |
|---|---|---|
| ទុតិយសាកណិយសូត្រ | ........ ......... .......... | ៤២២ |
| អដ្ឋកថាទុតិយសាកណិយសូត្រ | ........ ......... .......... | ៤២៤ |
| មេត្តាសូត្រ | ........ ......... .......... | ៤២៥ |
| អដ្ឋកថាមេត្តាសូត្រ | ........ ......... .......... | ៤៣០ |
| កទូកសូត្រ | ........ ......... .......... | ៤៣២ |
| អដ្ឋកថាកទូកសូត្រ | ........ ......... .......... | ៤៣៥ |
| អនុតប្បិយសូត្រ | ........ ......... .......... | ៤៣៧ |
| អដ្ឋកថាអនុតប្បិយសូត្រ | ........ ......... .......... | ៤៣៩ |
| នកុលបិតុសូត្រ | ........ ......... .......... | ៤៣៩ |
| អដ្ឋកថានកុលបិតុសូត្រ | ........ ......... .......... | ៤៤៥ |
| កុសលសូត្រ | ........ ......... .......... | ៤៤៧ |
| អដ្ឋកថាកុសលសូត្រ | ........ ......... .......... | ៤៥១ |
| មច្ឆសូត្រ | ........ ......... .......... | ៤៥២ |
| អដ្ឋកថាមច្ឆសូត្រ | ........ ......... .......... | ៤៥៥ |
| បឋមមរណស្សតិសូត្រ | ........ ......... .......... | ៤៥៧ |
| អដ្ឋកថាបឋមមរណស្សតិសូត្រ | ........ ......... .......... | ៤៦១ |
| ទុតិយមរណស្សតិសូត្រ | ........ ......... .......... | ៤៦៣ |
| អដ្ឋកថាទុតិយមរណស្សតិសូត្រ | ........ ......... .......... | ៤៦៧ |


## អនុត្តរិយវគ្គ


| | | |
|---|---|---|
| សាមកសូត្រ | ........ ......... .......... | ៤៦៩ |
| អដ្ឋកថាសាមកសូត្រ | ........ ......... .......... | ៤៧២ |
| អបរិហានិយសូត្រ និងអដ្ឋកថា | ........ ......... .......... | ៤៧៣ |

កយសូត្រ ........ ......... .......... ៤៧៤
អដ្ឋកថាកយសូត្រ ........ ......... .......... ៤៧៦
ហិមវន្តសូត្រ ........ ......... .......... ៤៧៧
អដ្ឋកថាហិមវន្តសូត្រ ........ ......... .......... ៤៧៨
អនុស្សតិដ្ឋានសូត្រ ........ ......... .......... ៤៧៩
អដ្ឋកថាអនុស្សតិដ្ឋានសូត្រ ........ ......... .......... ៤៨៣
កច្ចានសូត្រ ........ ......... .......... ៤៨៣
អដ្ឋកថាកច្ចានសូត្រ ........ ......... .......... ៤៨៩
បឋមសមយសូត្រ ........ ......... .......... ៤៩០
អដ្ឋកថាបឋមសមយសូត្រ ........ ......... .......... ៤៩៤
ទុតិយសមយសូត្រ ........ ......... .......... ៤៩៥
អដ្ឋកថាទុតិយសមយសូត្រ ........ ......... .......... ៤៩៩
ឧទាយិសូត្រ ........ ......... .......... ៥០០
អដ្ឋកថាឧទាយិសូត្រ ........ ......... .......... ៥០៤
អនុត្តរិយសូត្រ ........ ......... .......... ៥០៩
អដ្ឋកថាអនុត្តរិយសូត្រ ........ ......... .......... ៥១៦

### សេក្ខបរិហានិយវគ្គ

សេក្ខសូត្រ ........ ......... .......... ៥១៩
អដ្ឋកថាសេក្ខសូត្រ ........ ......... .......... ៥២០
បឋមអបរិហានិយសូត្រ ........ ......... .......... ៥២០
អដ្ឋកថាបឋមអបរិហានិយសូត្រ ........ ......... .......... ៥២២
ទុតិអបរិហានិយសូត្រ ........ ......... .......... ៥២៣

អដ្ឋកថាទុតិអបរិហានិយសូត្រ ........ ......... .......... ៥២៤
មោគ្គល្លានសូត្រ ........ ......... .......... ៥២៥
អដ្ឋកថាមោគ្គល្លានសូត្រ ........ ......... .......... ៥២៩
វិជ្ជាភាគិយសូត្រ ........ ......... .......... ៥៣០
អដ្ឋកថាវិជ្ជាភាគិយសូត្រ ........ ......... .......... ៥៣១
វិវាទមូលសូត្រ ........ ......... .......... ៥៣២
អដ្ឋកថាវិវាទមូលសូត្រ ........ ......... .......... ៥៣៤
ទានសូត្រ ........ ......... .......... ៥៣៧
អដ្ឋកថាទានសូត្រ ........ ......... .......... ៥៤០
អត្តការីសូត្រ ........ ......... .......... ៥៤២
អដ្ឋកថាអត្តការីសូត្រ ........ ......... .......... ៥៤៤
និទានសូត្រ ........ ......... .......... ៥៤៥
អដ្ឋកថានិទានសូត្រ ........ ......... .......... ៥៤៧
កិម្មិលសូត្រ ........ ......... .......... ៥៤៧
អដ្ឋកថាកិម្មិលសូត្រ ........ ......... .......... ៥៤៩
ទារុក្ខន្ធសូត្រ ........ ......... .......... ៥៤៩
អដ្ឋកថាទារុក្ខន្ធសូត្រ ........ ......... .......... ៥៥០
នាគិតសូត្រ ........ ......... .......... ៥៥២
អដ្ឋកថានាគិតសូត្រ ........ ......... .......... ៥៥៧

### ធម្មិកវគ្គ

នាគសូត្រ ........ ......... .......... ៥៥៩
អដ្ឋកថានាគសូត្រ ........ ......... .......... ៥៦៥
មិគសាលាសូត្រ ........ ......... .......... ៥៧៤

អដ្ឋកថាមិគសាលាសូត្រ ........ ......... .......... ៥៨២
ឥណសូត្រ ........ ......... .......... ៥៨៥
អដ្ឋកថាឥណសូត្រ ........ ......... .......... ៥៩១
មហាចុន្ទសូត្រ ........ ......... .......... ៥៩៥
អដ្ឋកថាមហាចុន្ទសូត្រ ........ ......... .......... ៥៩៨
បឋមសន្ទិដ្ឋិកសូត្រ ........ ......... .......... ៦០០
អដ្ឋកថាបឋមសន្ទិដ្ឋិកសូត្រ ........ ......... .......... ៦០១
ទុតិយសន្ទិដ្ឋិកសូត្រ ........ ......... .......... ៦០២
អដ្ឋកថាទុតិយសន្ទិដ្ឋិកសូត្រ ........ ......... .......... ៦០៤
ខេមសុមនសូត្រ ........ ......... .......... ៦០៥
អដ្ឋកថាខេមសុមនសូត្រ ........ ......... .......... ៦០៧
ឥន្ទ្រិយសំវរសូត្រ ........ ......... .......... ៦១០
អដ្ឋកថាឥន្ទ្រិយសំវរសូត្រ ........ ......... .......... ៦១២
អានន្ទសូត្រ ........ ......... .......... ៦១៣
អដ្ឋកថាអានន្ទសូត្រ ........ ......... .......... ៦១៦
ខត្តិយាធិប្បាយសូត្រ ........ ......... .......... ៦១៧
អដ្ឋកថាខត្តិយាធិប្បាយសូត្រ ........ ......... .......... ៦២០
អប្បមាទសូត្រ ........ ......... .......... ៦២៣
អដ្ឋកថាអប្បមាទសូត្រ ........ ......... .......... ៦២៥
ធម្មិកសូត្រ ........ ......... .......... ៦២៧
អដ្ឋកថាធម្មិកសូត្រ ........ ......... .......... ៦៣៨

## ទុតិយបណ្ណាសក

មហាវគ្គ

សោណសូត្រ ........ ......... .......... ៦៤៣

អដ្ឋកថាសោណសូត្រ ........ ......... .......... ៦៥២

ផគ្គុណសូត្រ ........ ......... .......... ៦៦០

អដ្ឋកថាផគ្គុណសូត្រ ........ ......... .......... ៦៦៦

ឆឡាភិជាតិយសូត្រ ........ ......... .......... ៦៦៧

អដ្ឋកថាឆឡាភិជាតិយសូត្រ ........ ......... .......... ៦៧៣

អាសវសូត្រ ........ ......... .......... ៦៧៤

អដ្ឋកថាអាសវសូត្រ ........ ......... .......... ៦៨១

ទារុកម្មិកសូត្រ ........ ......... .......... ៦៩១

អដ្ឋកថាទារុកម្មិកសូត្រ ........ ......... .......... ៦៩៤

ចិត្តហត្ថិសារិបុត្តសូត្រ ........ ......... .......... ៦៩៥

អដ្ឋកថាចិត្តហត្ថិសារិបុត្តសូត្រ ........ ......... .......... ៧០៥

បរាយនសូត្រ ........ ......... .......... ៧០៧

អដ្ឋកថាបរាយនសូត្រ ........ ......... .......... ៧១២

ឧទកសូត្រ ........ ......... .......... ៧១៦

អដ្ឋកថាឧទកសូត្រ ........ ......... .......... ៧២៧

និព្វេធិកសូត្រ ........ ......... .......... ៧៣០

អដ្ឋកថានិព្វេធិកសូត្រ ........ ......... .......... ៧៤២

ពលសូត្រ ........ ......... .......... ៧៤៦

អដ្ឋកថាពលសូត្រ ........ ......... .......... ៧៥២

**ទេវតាវគ្គ**

អនាគាមិសូត្រ និងអដ្ឋកថា ........ ......... .......... ៧៥៥

អរហត្តសូត្រ និងអដ្ឋកថា ........ ......... .......... ៧៥៦

មិត្តសូត្រ និងអដ្ឋកថា ........ ......... .......... ៧៥៨
ឋានសូត្រ និងអដ្ឋកថា ........ ......... .......... ៧៥៩
ទេវតាសូត្រ និងអដ្ឋកថា ........ ......... .......... ៧៦២
សតិសូត្រ និងអដ្ឋកថា ........ ......... .......... ៧៦៦
សក្ខិសូត្រ និងអដ្ឋកថា ........ ......... .......... ៧៦៨
ពលសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧០
បឋមជ្ឈានសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧២
ទុតិយជ្ឈានសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧៣

អរហន្តវគ្គ

ទុក្ខសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧៥
អរហត្តសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧៧
ឧត្តរិមនុស្សធម្មសូត្រ និងអដ្ឋកថា ........ ......... .......... ៧៧៩
សុខសូត្រ និងអដ្ឋកថា ........ ......... .......... ៧៨១
អធិគមសូត្រ និងអដ្ឋកថា ........ ......... .......... ៧៨២
មហត្តសូត្រ និងអដ្ឋកថា ........ ......... .......... ៧៨៤
បឋមនិរយសូត្រ និងអដ្ឋកថា ........ ......... .......... ៧៨៦
ទុតិយនិរយសូត្រ ........ ......... .......... ៧៨៧
អដ្ឋកថាទុតិយនិរយសូត្រ ........ ......... .......... ៧៨៨
អគ្គធម្មសូត្រ និងអដ្ឋកថា ........ ......... .......... ៧៨៨
រត្តិសូត្រ ........ ......... .......... ៧៩០
អដ្ឋកថារត្តិសូត្រ ........ ......... .......... ៧៩២

សីតិវគ្គ

សីតិសូត្រ ........ ......... .......... ៧៩៣

អដ្ឋកថាសីតិសូត្រ ........ ......... .......... ៧៩៥

កព្វសូត្រ ........ ......... .......... ៧៩៦

អដ្ឋកថាកព្វសូត្រ ........ ......... .......... ៧៩៧

អាវរណតាសូត្រ និងអដ្ឋកថា ........ ......... .......... ៧៩៧

សុស្សូសាសូត្រ ........ ......... .......... ៧៩៩

អដ្ឋកថាសុស្សូសាសូត្រ ........ ......... .......... ៨០០

បហាតព្វសូត្រ ........ ......... .......... ៨០០

អដ្ឋកថាបហាតព្វសូត្រ ........ ......... .......... ៨០១

បហីនសូត្រ និងអដ្ឋកថា ........ ......... .......... ៨០២

ឧប្បាទេតព្វសូត្រ និងអដ្ឋកថា ........ ......... .......... ៨០៣

សត្ថុរិសូត្រ និងអដ្ឋកថា ........ ......... .......... ៨០៤

កញ្ចិសន្ធារសូត្រ ........ ......... .......... ៨០៥

អដ្ឋកថាកញ្ចិសន្ធារសូត្រ ........ ......... .......... ៨០៥

មាតរិសូត្រ និងអដ្ឋកថា ........ ......... .......... ៨០៦

សយកតសូត្រ ........ ......... .......... ៨០៧

អដ្ឋកថាសយកតសូត្រ ........ ......... .......... ៨០៨


## អានិសំសវគ្គ


បាតុការសូត្រ ........ ......... .......... ៨០៩

អដ្ឋកថាបាតុការសូត្រ ........ ......... .......... ៨១០

អានិសង្សសូត្រ ........ ......... .......... ៨១០

អដ្ឋកថាអានិសង្សសូត្រ ........ ......... .......... ៨១១

អនិច្ចសូត្រ និងអដ្ឋកថា ........ ......... .......... ៨១១

ទុក្ខសូត្រ និងអដ្ឋកថា ........ ......... .......... ៨១៣

អនត្តសូត្រ និងអដ្ឋកថា ........ ......... .......... ៨១៣

និញ្ញានសូត្រ និងអដ្ឋកថា ........ ......... .......... ៨១៤

បឋមអនោទិសសូត្រ ........ ......... .......... ៨១៥

អដ្ឋកថាបឋមអនោទិសសូត្រ ........ ......... .......... ៨១៦

ទុតិយអនោទិសសូត្រ ........ ......... .......... ៨១៦

អដ្ឋកថាទុតិយអនោទិសសូត្រ ........ ......... .......... ៨១៧

តតិយអនោទិសសូត្រ ........ ......... .......... ៨១៨

អដ្ឋកថាតតិយអនោទិសសូត្រ ........ ......... .......... ៨១៨

កាវសូត្រ និងអដ្ឋកថា ........ ......... .......... ៨១៩

តណ្ហាសូត្រ និងអដ្ឋកថា ........ ......... .......... ៨២០

## បណ្ណាសកាសង្គហិតវគ្គ

### តិកវគ្គ

រាគសូត្រ ........ ......... .......... ៨២២

អដ្ឋកថារាគសូត្រ ........ ......... .......... ៨២៣

ទុច្ចរិតសូត្រ និងអដ្ឋកថា ........ ......... .......... ៨២៣

វិតក្កសូត្រ និងអដ្ឋកថា ........ ......... .......... ៨២៤

សញ្ញាសូត្រ និងអដ្ឋកថា ........ ......... .......... ៨២៥

ធាតុសូត្រ និងអដ្ឋកថា ........ ......... .......... ៨២៦

អស្សាទសូត្រ ........ ......... .......... ៨២៧

អដ្ឋកថាអស្សាទសូត្រ ........ ......... .......... ៨២៨

អរតិសូត្រ ........ ......... .......... ៨២៩

អដ្ឋកថាអរតិសូត្រ ........ ......... .......... ៨២៩

តុដ្ឋិសូត្រ និងអដ្ឋកថា ........ ......... .......... ៨៣០

បឋមឧទ្ទចូសូត្រ និងអដ្ឋកថា ........ ......... .......... ៨៣១
ទុតិយឧទ្ទចូសូត្រ ........ ......... .......... ៨៣២
អដ្ឋកថា ទុតិយឧទ្ទចូសូត្រ ........ ......... .......... ៨៣៣
វគ្គាសង្គហិតសុត្តន្ត ........ ......... .......... ៨៣៤
អដ្ឋកថាសូត្រដែលមិនសង្គ្រោះចូលក្នុងវគ្គ ........ ......... .......... ៨៣៩